# បណ្ឌិត្យសភាគរបាលកម្ពុជា

## កម្មវិធីបណ្តុះបណ្តាលនគរបាលជាតិ

# នីតិវិធី
# នៃការស៊ើបអង្កេត
# បទល្មើសជួញដូរមនុស្ស

## ភាគទី២

២០១៧

សូមរក្សាសិទ្ធិ

# មាតិកា

**Logo and Disclaimer**
**អារម្ភកថាស្តីពីការរៀបចំសៀវភៅគោល**
**អារម្ភកថារបស់អង្គការ IJM**
**លិខិតបង្គាប់ការ**
**លិខិតថ្លែងអំណរគុណ**

**មេរៀន ៖ បច្ចេកទេសសម្ភាស**
**សេចក្តីផ្តើម** ……………………………………………………………១
**១. តើអ្វីដែលហៅថា " ការសម្ភាស "?** ……………………………………………………………១
**២. ការសម្ភាស** ……………………………………………………………១
**៣. ក្រមសីលធម៌ក្នុងការសម្ភាស** ……………………………………………………………២

**ជំពូកទី ១ ការសម្ភាសជនរងគ្រោះ និងសាក្សី** ……………………………………………………………៣
**I. ការយល់ដឹងចំពោះការចងចាំ** ……………………………………………………………៣
**១. មូលដ្ឋានគ្រឹះនៃការចងចាំ** ……………………………………………………………៣
**២. ដំណើរការចងចាំនៃប្រព័ន្ធខួរក្បាល** ……………………………………………………………៣
**៣. ការចងចាំព្រឹត្តិការណ៍ស្មុគស្មាញ** ……………………………………………………………៤
**II. របៀបសួរសំណួរ** ……………………………………………………………៥
**១. សេចក្តីផ្តើម** ……………………………………………………………៥
**២. ប្រភេទសំណួរ** ……………………………………………………………៦
**III. ផែនការសម្ភាស** ……………………………………………………………៦
**១. ការស្រាវជ្រាវពីសាវតារ** ……………………………………………………………៧
**២. ការជ្រើសរើសអ្នកសម្ភាស** ……………………………………………………………៧
**៣. ការបង្កើតគោលបំណងសម្ភាស** ……………………………………………………………៧
**៤. បរិយាកាសទីកន្លែង** ……………………………………………………………៧
**៥. ការរៀបចំបន្ទប់** ……………………………………………………………៨
**៦. ការកត់ត្រា (ថតការសម្ភាស)** ……………………………………………………………៨

៧. ការវាយតម្លៃអ្នកឆ្លើយសម្ភាស ..........៩
IV. ការអង្កេតលើការផ្តល់ចម្លើយក្លែងក្លាយ ..........៩
១. ការណែនាំឱ្យស្គាល់ចម្លើយក្លែងក្លាយ ..........៩
២. វិធីសាស្ត្រអង្កេតលើការផ្តល់ចម្លើយក្លែងក្លាយ ..........១០
៣. កាយវិការពាក្យសម្តី ..........១០
៤. ភាសាកាយវិការ ..........១១
៥. ការធ្វើតេស្តរកការពិត ..........១១
V. យុទ្ធវិធីសម្ភាសការយល់ដឹង ..........១១
១. ប្រវត្តិសង្ខេប ..........១១
២. ជំហាននៃការសម្ភាសខាងផ្លូវចិត្ត ..........១៣
៣. ការលម្អៀងដោយអ្នកសម្ភាស ..........១៧
VI. កង្វះសមត្ថភាពយល់ដឹង (កុមារ) ..........១៧
១. ការពិត និង ការកុហក ..........១៧
២. ចេតនា និងទស្សនៈវិស័យ ..........១៧
៣. សំណួរសម្មតិកម្ម (សំណួរប៉ាន់ស្មាន) ..........១៧
៤. មនុស្សពេញវ័យ ..........១៧
៥. ភាពអវិជ្ជមាន ..........១៨
៦. សមត្ថភាពគណនាចំនួន ..........១៨
VII. ការសម្ភាសកុមារ ..........១៨
១. គោលបំណង ..........១៨
២. រឿងដែលត្រូវចងចាំ ..........១៨
៣. សំណួរបើក និង បិទ ..........១៨
៤. ការសួរសំណួរឡើងវិញ ឬការនិទានរឿងឡើងវិញ ..........១៩
៥. ការនាំឱ្យកុមារយល់ខុស ..........១៩
៦. គោលការណ៍ ៥ យ៉ាងសម្រាប់សម្ភាសន៍កុមារ ..........១៩
៧. ការរៀបចំការសម្ភាសជាមុន ..........២០
VIII. ការសម្ភាសតាមដំណាក់កាល ..........២១
១. ការសម្ភាសផ្លូវចិត្តឱ្យស្របគ្នា ..........២១
២. ការសម្ភាសតាមលំដាប់លំដោយ ..........២១
៣. លក្ខណៈវិនិច្ឆ័យបរិយាកាសបន្ទប់សម្ភាស ..........២១

៤. ជំហានទាំងប្រាំបួននៃការសម្ភាសកុមារ ……………………………………………២១

ជំពូកទី ២ ការសម្ភាសជនរងគ្រោះជាសាក្សី ……………………………………………២៥
I. គោលការណ៍ណែនាំស្តីពីការសម្ភាសរកតស្តុតាង ……………………………………………២៥
II. សារៈសំខាន់នៃជនរងគ្រោះ ……………………………………………២៥
១. ការព្រួយបារម្ភជាគន្លឹះប្រាំយ៉ាង របស់ជនរងគ្រោះ ……………………………………………២៦
២. ចំណុចជាក់លាក់នៃព័ត៌មាន មុនពេលធ្វើការសម្ភាស ……………………………………………២៧
III. ការសម្ភាសជនរងគ្រោះជាសាក្សីដោយអំពើជួញដូរមនុស្ស ……………………………………………២៨
១. ភារកិច្ចរបស់អ្នកសម្ភាស និងគោលបំណងនៃការសម្ភាស ……………………………………………២៨
២. គោលបំណងបីយ៉ាងនៃការសម្ភាសរកតស្តុតាង ……………………………………………២៨
៣. ការប្រឈមនៃការសម្ភាស ……………………………………………២៩
៤. ការគ្រប់គ្រងលើការប្រឈម ……………………………………………២៩
IV. ការរៀបចំផែនការសម្ភាស ……………………………………………៣០
១. គំរូ PEACE ៖ P- ការត្រៀមរៀបចំ ……………………………………………៣១
២. គំរូ PEACE ៖ E-ការអនុវត្ត និងពន្យល់ ……………………………………………៣៦
៣. គំរូ PEACE ៖ A-ការរៀបរាប់រឿងក្តី ……………………………………………៣៨
៤. គំរូ PEACE ៖ C-ការបញ្ចប់ ……………………………………………៤៦
៥. គំរូ PEACE ៖ E-វាយតម្លៃ ……………………………………………៤៧
V. ការសម្ងាត់នៃអត្តសញ្ញាណរបស់ជនរងគ្រោះជាសាក្សី ……………………………………………៤៩
VI. វិធីសាស្ត្រសម្ភាស-ការប្រើបញ្ជីសំណួរ ……………………………………………៥០
១. គម្រោងប្លង់បញ្ជីផ្ទៀងផ្ទាត់ ……………………………………………៥០
២. របៀបប្រើប្រាស់បញ្ជីផ្ទៀងផ្ទាត់ ……………………………………………៥១
៣. ការពន្យល់បញ្ជីផ្ទៀតផ្ទាត់នីមួយៗ ……………………………………………៥២

ជំពូកទី ៣ ការសម្ភាសជនសង្ស័យ ……………………………………………៧៨
I. ការណែនាំឱ្យស្គាល់បច្ចេកទេសសម្ភាសជនសង្ស័យ ……………………………………………៧៨
១. ការសម្ភាសជនអាចមានការសង្ស័យ ……………………………………………៧៨
២. ការសម្ភាសផ្លូវផ្លង (បញ្ជាក់ចម្លើយ) ……………………………………………៧៨
៣. ផលប្រយោជន៍នៃការធ្វើសម្ភាសមួយមុនពេលសម្ភាសផ្លូវផ្លង ……………………………………………៧៩
៤. ការប្រមូលព័ត៌មានមុនពេលធ្វើសម្ភាស ……………………………………………៧៩

**II. ដំណើរការសម្ភាស** ....................................................៨១

**១. ការសម្ភាសក្រៅផ្លូវការ និងផ្លូវការ** ....................................................៨១

**២. ការរៀបចំការសម្ភាសផ្លូវការ** ....................................................៨២

**៣. ដំណើរការសម្ភាសផ្លូវការ** ....................................................៨២

**III. ការចង្អុលបង្ហាញភាពស្មោះត្រង់ ឬការភូតភរក្នុងអំឡុងពេលសម្ភាសផ្លូវការ** ........៨៦

**១. ការចង្អុលបង្ហាញភាពស្មោះត្រង់** ....................................................៨៦

**២. ការចង្អុលបង្ហាញការភូតភរ** ....................................................៨៦

**៣. សំណួរសម្រាប់បញ្ជាក់ចំពោះជនសង្ស័យដែលអាចភូតភរ** ..........................៨៦

**IV. ការត្រៀមរៀបចំ និងវិធីសាស្ត្រក្នុងការសម្ភាសផ្ទាល់ប្រកបដោយជោគជ័យ** ........៨៧

**១. ការជ្រើសរើសអ្នកសម្ភាស** ....................................................៨៧

**២. គុណសម្បត្តិអ្នកសម្ភាស** ....................................................៨៧

**៣. ឥរិយាបថរបស់អ្នកសម្ភាសក្នុងអំឡុងពេលសម្ភាសផ្ទាល់** ..........................៨៨

**V. របៀបដំណើរការដែលអាចខុសឆ្គងក្នុងពេលធ្វើសម្ភាសផ្ទាល់** ..........................៨៩

**១. កត្តាដែលបង្អាក់ដល់ការសារភាព** ....................................................៩០

**២. ការចងចាំ និងការសារភាពក្លែងក្លាយ** ....................................................៩០

**៣. បុព្វហេតុនៃការបដិសេធចំពោះការប្រព្រឹត្តបទល្មើស** ..........................៩២

**៤. ប្រភេទនៃការបដិសេធ** ....................................................៩៣

**៥. ដំណោះស្រាយជាមួយការបដិសេធដាច់អហង្ការ** ..........................៩៣

**៦. ដំណោះស្រាយជាមួយការបដិសេធបែបពន្យល់** ..........................៩៤

**VI. ការវិភាគអាកប្បកិរិយា** ....................................................៩៤

**១. ទិដ្ឋភាពទូទៅ** ....................................................៩៤

**២. ការវាយតម្លៃឥរិយាបថជនសង្ស័យ** ....................................................៩៥

**៣.ចរិតទូទៅរបស់ជនសង្ស័យស្មោះត្រង់ ឬមិនស្មោះត្រង់** ..........................៩៥

**៤. អាកប្បកិរិយាទូទៅរបស់ជនសង្ស័យស្មោះត្រង់ និងមិនស្មោះត្រង់** ..............៩៦

**៥. ការវាយតម្លៃអាកប្បកិរិយាប្រើពាក្យសម្ដី** ..........................៩៧

**៦. ការវាយតម្លៃអាកប្បកិរិយាស្ងៀមស្ងាត់** ..........................៩៨

**៧. កាយវិការ** ....................................................៩៨

**VII. បុព្វហេតុដែលបុគ្គលឆ្លើយសារភាព** ....................................................១០២

**១. គំរូ REID នៃចម្លើយសារភាព** ....................................................១០២

**២. គំរូធ្វើការសម្រេចចិត្តឆ្លើយសារភាព** ....................................................១០៣

**VIII. បច្ចេកទេសសម្ភាសផ្ទុយផ្តងរួមបញ្ចូលគ្នា**……………………………………………………..១០៤
**១. ធ្វើអំណះអំណាងដោយបង្ខំមួយដែលបញ្ជាក់ថាជនសង្ស័យពិតជាមានកំហុស**
**២. មិនត្រូវអនុញ្ញាតឱ្យជនសង្ស័យឆ្លើយបដិសេធ**…………………………………………១០៤
**៣. ផ្តល់លទ្ធភាពជាបន្តបន្ទាប់ពីរបៀប និងហេតុផលដែលបទល្មើសអាចកើតឡើង**
**៤. ការធ្វើឱ្យបាត់ជំនឿទុកចិត្តរបស់ជនសង្ស័យ**……………………………………………..១០៤
**៥. ការផ្តល់នូវអំណះអំណាងបែបបញ្ចុះបញ្ចូលដើម្បីឱ្យជនសង្ស័យប្រាប់ការពិត**
**៦.ការផ្តល់ដំណោះស្រាយដើម្បីបន្ធូរអារម្មណ៍ភ័យខ្លាចរបស់ជនសង្ស័យ** ………១០៥
**៧. ការលើកទឹកចិត្តដល់ជនសង្ស័យ** ……………………………………………………………..១០៥
**៨. ការប្រើប្រាស់សំណួរនាំមុខ និងសំណួរពហុជ្រើសរើស**……………………………..១០៥
**៩. អង្កេតមើលសញ្ញានៃការទទួលស្គាល់**………………………………………………………..១០៥
**១០. វិធីចូលកៀក និងជំរុញឱ្យផ្តល់ចម្លើយសារភាព**…………………………………………..១០៥
**IX. ការប្រើប្រាស់សំណួរជាក់លាក់ ឬបច្ចេកទេសចោទប្រកាន់ដោយទន់ភ្លន់**…………..១០៦
**១. សំណួរជាក់លាក់** ……………………………………………………………………..១០៦
**២. សំណួរចោទប្រកាន់បែបទន់ភ្លន់** ………………………………………………………………..១០៧
**៣. សំណួរពហុជ្រើសរើស** ……………………………………………………………………..១០៨
**X. ការអនុវត្តបច្ចេកទេសគំរូ PEACE ក្នុងការសម្ភាសជនសង្ស័យជួញដូរមនុស្ស**…..១០៨
**១. ការរៀបចំ** (Preparation) ……………………………………………………………………..១១០
**២. សេចក្តីពន្យល់** (Explanation) ……………………………………………………………………..១១៣
**៣. ការរៀបរាប់រឿងហេតុ** (Account) ……………………………………………………………………..១១៣
**៤. ការបញ្ចប់សម្ភាសន៍** (Closure) ……………………………………………………………………..១១៤
**៥. ការវាយតម្លៃ** (Evaluation) ……………………………………………………………………..១១៥
**XI. កំណត់ហេតុ** ……………………………………………………………………..១១៦
**១. បែបបទនៃកំណត់ហេតុ** ……………………………………………………………………..១១៦
**២. ការទទួលខុសត្រូវ ឬការគ្រប់គ្រងរបស់អ្នកសម្ភាស** …………………………………..១១៧
**៣. ការកំណត់ពេលវេលាសម្រាប់ធ្វើកំណត់ហេតុ** ………………………………………..១១៧
**៤. បញ្ហាដែលត្រូវយកចិត្តទុកដាក់** ……………………………………………………………..១១៨
**៥. ការធ្វើកំណត់ហេតុ** ……………………………………………………………………..១១៩
មាត្រា ៩៣ នៃ ក្រមនីតិវិធីព្រហ្មទណ្ឌ ស្តីពីកំណត់ហេតុលើការស្តាប់ចម្លើយ………………………………..**១២០**
**ឯកសារយោង**

**មេរៀន ៖ ការកំណត់អត្តសញ្ញាណ និងការប្រព្រឹត្តិទៅលើជនរងគ្រោះដោយអំពើជួញដូរមនុស្ស**


**សេចក្តីផ្តើម** ……………………………………………………….១

**I. ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស** ……………………….១

**១. ស្តង់ដារអន្តរជាតិ** ……………………………………………………….១

**២. ស្តង់ដារអាស៊ាន** ……………………………………………………….២

**៣. ផលប៉ះពាល់ នៃអំពើជួញដូរមនុស្ស** ……………………………………….៣

**៤. ជំងឺផ្លូវអារម្មណ៍ជះឥទ្ធិពលដល់អ្នកធ្វើសម្ភាស និងអ្នកស៊ើបអង្កេត** …………….៦

**៥. ការគ្រប់គ្រងលើការប៉ះពាល់នៃជំងឺផ្លូវអារម្មណ៍ និងកត្តាគន្លឹះនានា** …………..៧

**៦. ដំណាក់កាលទាំងបួនក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះ** ………………….៩

**II. ការប្រព្រឹត្តិទៅលើជនរងគ្រោះដោយអំពើជួញដូរមនុស្ស** ………………………….១៧

**១. ច្បាប់អន្តរជាតិ** ……………………………………………………….១៧

**២. ស្តង់ដារអាស៊ាន** ……………………………………………………….១៨

**៣. គោលការណ៍ជាមូលដ្ឋាននៃការអនុវត្ត** ……………………………………….១៨

**៤. សេចក្តីត្រូវការជាបន្ទាន់របស់ជនរងគ្រោះ** …………………………………….១៩

**III. សេចក្តីសង្ខេប** ……………………………………………………….២២

**ផ្នែកទី១-ការកំណត់ថាជនណាម្នាក់ជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស** …២២

**ផ្នែកទី២-ការប្រព្រឹត្តិទៅលើជនរងគ្រោះដោយអំពើជួញដូរមនុស្ស** …………….២៥

**ផ្នែកទី៣-គោលការណ៍ណែនាំស្តីពី "បែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណបឋមជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប"** ………..២៥

**ឯកសារយោង**

This curriculum has been prepared by the Police Academy of Cambodia along with the Anti-Human Trafficking and Juvenile Protection Department (AHTJPD) of the Cambodian National Police and International Justice Mission (IJM), with contributions from the Australia-Asia-Program-to-Combat-Trafficking-in-Persons (AAPTIP) and is part of the Cambodia Countering Trafficking-in-Persons program funded by the United States Agency for International Development (USAID) and implemented by Winrock International.

*Disclaimer: This curriculum is made possible by the generous support of the American people through USAID. The contents are the responsibility of the Police Academy of Cambodia, the AHTJPD and IJM and do not necessarily reflect the views of USAID or the United States Government.*

# អារម្ភកថា

នៅចុងទសវត្សរ៍នេះ អំពើជួញដូរមនុស្សបានប្រែក្លាយជាបញ្ហាសកល ហើយកំពុងគំរាមកំហែង និងបន្តធ្វើឱ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដល់សេដ្ឋកិច្ច បុគ្គល គ្រួសារ និងសង្គម ។ ជនល្មើសនៃអំពើជួញដូរមនុស្ស អាជីវកម្មផ្លូវភេទ និងរត់ពន្ធមនុស្ស បាននឹងកំពុងធ្វើសកម្មភាពលាក់កំបាំង ដែលជាការព្រួយបារម្ភ របស់សហគមន៍ សមត្ថកិច្ច និងរាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាប្រទេសក្នុងតំបន់ និងនៅលើពិភពលោក ។

ក្រសួងមហាផ្ទៃបានបង្កើតគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីធ្វើការស្រាវជ្រាវតាក់តែងរៀបចំជាគោលការណ៍ជាតិដ៏មានសារសំខាន់ ជាពិសេសសម្របសម្រួលកែលម្អនូវលិខិតបទដ្ឋានគតិយុត្តិ បែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប ។

នាយកដ្ឋានប្រឆាំងការជួញមនុស្ស និងការពារអនីតិជន ត្រូវបានបង្កើតឡើងជាសេនាធិការឱ្យក្រសួងមហាផ្ទៃ ដើម្បីសហការជាមួយក្រសួងពាក់ព័ន្ធ ភ្នាក់ងារអង្គការសហប្រជាជាតិ និងអង្គការដៃគូក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ និងអំពើរត់ពន្ធមនុស្ស ។

ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងយោងតាមអនុសាសន៍ដ៏មានតម្លៃរបស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងឯកឧត្តមនាយឧត្តមសេនីយ៍ **សេខ ផល្លី** ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា បានចាត់ទុកអំពើជួញដូរមនុស្ស គឺជាបទឧក្រិដ្ឋដែលមិនអាចមើលរំលងបាន ហើយក៏ជាការងារអាទិភាពមួយ ក្នុងចំណោមការងារអាទិភាពដទៃទៀតសម្រាប់បណ្ឌិត្យសភានគរបាលកម្ពុជា ធ្វើការបណ្តុះបណ្តាលកងកម្លាំងនគរបាលជាតិ លើមុខវិជ្ជាស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

បណ្ឌិត្យសភានគរបាលកម្ពុជា បាលរួមសហការជាមួយអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ (IJM) ក្រោមការឧបត្ថម្ភគាំទ្រថវិកា របស់ទីភ្នាក់ងារដើម្បីអភិវឌ្ឍន៍អន្តរជាតិសហរដ្ឋអាម៉េរិក (USAID) តាមរយៈអង្គការវីនរ៉ក់អន្តរជាតិ (WINROCK) ក្នុងការរៀបចំសៀវភៅគោលស្តីពី **នីតិវិធីនៃការស៊ើបអង្កេតបទល្មើសជួញដូរមនុស្ស** មាន៖

**ភាគទី១**

១. ក្រមសីលធម៌មន្ត្រីអនុវត្តច្បាប់

២. ទិដ្ឋភាពទូទៅស្តីពីក្របខណ្ឌគតិយុត្តិពាក់ព័ន្ធអំពើជួញដូរមនុស្សនៅកម្ពុជា

៣. ការប្រមូលព័ត៌មានព្រហ្មទណ្ឌ

៤. ការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ និងការសរសេររបាយការណ៍

៥. ការប្រមូល និងថែរក្សារូបកស្តុតាង

**ភាគទី២**

៦. បច្ចេកទេសសម្ភាស

៧. ការសម្ភាសជនរងគ្រោះជាសាក្សី

៨. ការសម្ភាសជនសង្ស័យ

៩. ការកំណត់អត្តសញ្ញាណ និងការប្រព្រឹត្តលើជនរងគ្រោះដោយអំពើជួញដូរមនុស្ស

**ភាគទី៣**

១០. ការកំណត់អត្តសញ្ញាណ និងការចាប់ខ្លួនជនសង្ស័យ

១១. វិធីសាស្ត្រក្នុងការស៊ើបអង្កេតករណីជួញដូរមនុស្ស

១២. ការកសាង ប្រើប្រាស់អ្នកផ្តល់ព័ត៌មាន និងភ្នាក់ងារសម្ងាត់

១៣. ការគ្រប់គ្រងសាក្សី និងដំណើរការសវនាការ

១៤. ការរៀបចំឡើងសវនាការ

១៥. ការស៊ើបអង្កេតបណ្តាញឧក្រិដ្ឋជន

ការរៀបចំសៀវភៅគោលនេះ គឺសម្រាប់បណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់ ក្នុងគោលបំណងលើកកម្ពស់ការយល់ដឹង និងអភិវឌ្ឍសមត្ថភាព អំពីនីតិវិធីក្នុងការស៊ើបអង្កេតបទល្មើស ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងជួយសង្គ្រោះជនរងគ្រោះ ។

# Preface

International Justice Mission has been honoured to collaborate with the Police Academy of Cambodia and Anti-Human Trafficking and Juvenile Protection Department in the creation of this comprehensive manual on Human Trafficking Investigations.

The publication of this series of training modules marks a significant step forward in the effort to eradicate human trafficking in Cambodia. It is unique in its depth and breadth on the topic, and it carries considerable weight because it is a curriculum created *by* the experts of the Cambodian National Police *for* the benefit of all Cambodian law enforcement officers. It is our hope that this curriculum will equip and empower *every* Cambodian police officer to address human trafficking when they see it, from the newest recruit to the most seasoned officer. It has been carefully designed to be adaptable for use at recruit-level right through to honing the skills of experienced Anti-Trafficking experts.

IJM would like to extend special thanks and congratulations to His Excellency General Seng Phally and His Excellency Lieutenant General Pol Phie They for their support of this work, and to PAC Trainers, Lt. Gen. Khim Sovannavuth, Lt. Gen. Ros Sarith, Maj. Gen. Sen Sathya, Maj. Gen. Uon Sokhon, Brig. Gen. Be Sahor, Brig. Gen. Chan Sophea and AHTJPD Trainer, Maj. Gen. Kim Pheap for their painstaking effort in compiling and refining this curriculum. IJM also wishes to appreciate the great efforts of the International Organisation for Migration (IOM) and Australia-Asia-Program-to-Combat-Trafficking-in-Persons (AAPTIP) to counter trafficking in Cambodia, who have been valued collaborators and partners in this effort, and the support of USAID's Cambodia Counter-Trafficking in Persons program implemented by Winrock International.

IJM continues to be inspired by the commitment of the officers of the CNP, and grateful for the ongoing collaboration, trust and partnership we enjoy. We hope and trust this curriculum will be of value to you all for many years to come.

Phnom Penh, April 20th, 2017

Director

ធីធ័រ វីល្លៀម

# Preface

International Justice Mission has been honoured to collaborate with the Police Academy of Cambodia and Anti-Human Trafficking and Juvenile Protection Department in the creation of this comprehensive manual on Human Trafficking Investigations.

The publication of this series of training modules marks a significant step forward in the effort to eradicate human trafficking in Cambodia. It is unique in its depth and breadth on the topic, and it carries considerable weight because it is a curriculum created *by* the experts of the Cambodian National Police *for* the benefit of all Cambodian law enforcement officers. It is our hope that this curriculum will equip and empower *every* Cambodian police officer to address human trafficking when they see it, from the newest recruit to the most seasoned officer. It has been carefully designed to be adaptable for use at recruit-level right through to honing the skills of experienced Anti-Trafficking experts.

IJM would like to extend special thanks and congratulations to His Excellency General Seng Phally and His Excellency Lieutenant General Pol Phie They for their support of this work, and to PAC Trainers, Lt. Gen. Khim Sovannavuth, Lt. Gen. Ros Sarith, Maj. Gen. Sen Sathya, Maj. Gen. Uon Sokhon, Brig. Gen. Be Sahor, Brig. Gen. Chan Sophea and AHTJPD Trainer, Maj. Gen. Kim Pheap for their painstaking effort in compiling and refining this curriculum. IJM also wishes to appreciate the great efforts of the International Organisation for Migration (IOM) and Australia-Asia-Program-to-Combat-Trafficking-in-Persons (AAPTIP) to counter trafficking in Cambodia, who have been valued collaborators and partners in this effort, and the support of USAID's Cambodia Counter-Trafficking in Persons program implemented by Winrock International.

IJM continues to be inspired by the commitment of the officers of the CNP, and grateful for the ongoing collaboration, trust and partnership we enjoy. We hope and trust this curriculum will be of value to you all for many years to come.

Phnom Penh, April 20th, 2017

Director

ឝីធ័រ ទីល្លៀម

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមហាផ្ទៃ**
**បណ្ឌិត្យសភានគរបាលកម្ពុជា**

លេខ ៖ ០១៥.....ណ.ប៥

# លិខិតបញ្ជាប់ការ

- យោងតាមសំណូមពររបស់អង្គការអន្តរជាតិទេសន្តប្រវេសន៍ប្រចាំកម្ពុជា
- យោងតាមសំណូមពររបស់អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិប្រចាំកម្ពុជា
- យោងតាមភាពចាំបាច់របស់បណ្ឌិត្យសភានគរបាលកម្ពុជា

ត្រូវបានបង្កើតក្រុមការងាររបស់បណ្ឌិត្យសភានគរបាលកម្ពុជា ដើម្បីសហការនិងសម្របសម្រួលជាមួយ អង្គការអន្តរជាតិទេសន្តប្រវេសន៍ប្រចាំកម្ពុជា និងអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិប្រចាំកម្ពុជា ក្នុងការរៀបចំផែនការ កម្មវិធីបណ្តុះបណ្តាល និង ខ្លឹមសារបង្ហាត់បង្រៀន ពាក់ព័ន្ធនឹងជំនាញ ទេសន្តប្រវេសន៍ អំពើរត់ពន្ធជនទេសន្តប្រវេសន៍ អំពើជួញដូរមនុស្ស និង ការគ្រប់គ្រងព្រំដែន ដែលមានសមាសភាព និង ភារកិច្ច ដូចខាងក្រោម ៖

ក.សមាសភាព

ក្រុមការងាររបស់បណ្ឌិត្យសភានគរបាលកម្ពុជា រួមមាន ៖

១. លោកឧត្តមសេនីយ៍ទោ យឹម សុវណ្ណារ៉ុជ អត្តលេខ ០៩៥៥ គ្រូនគរបាលជាតិ ប្រធាន
២. លោកឧត្តមសេនីយ៍ទោ រស់ សារិទ្ធ អត្តលេខ ០៨០១ គ្រូនគរបាលជាតិ អនុប្រធាន
៣. លោកឧត្តមសេនីយ៍ទោ អ៊ួន សុខន អត្តលេខ ០៤៨៩០ គ្រូនគរបាលជាតិ សមាជិក
៤. លោកឧត្តមសេនីយ៍ទោ សេន សត្យា អត្តលេខ ០៥៨៥៤ គ្រូនគរបាលជាតិ សមាជិក
៥. លោកវរសេនីយ៍ឯក បេ សាហោ អត្តលេខ ៣០៥២៣ គ្រូនគរបាលជាតិ សមាជិក
៦. លោកវរសេនីយ៍ឯក ចាន់ សុភា អត្តលេខ ០៥៨៨៤ គ្រូនគរបាលជាតិ សមាជិក

ក្រុមការងាររបស់អង្គការអន្តរជាតិទេសន្តប្រវេសន៍ប្រចាំកម្ពុជា IOM រួមមាន ៖

១. លោក ប្រិដ ឌិកសិន (Mr. Brett Dickson) ប្រធានគម្រោង
២. លោក កេង ម៉េងឡាង មន្ត្រីគម្រោង
៣. លោក នុត សំអុល ជំនួយការគម្រោង

ក្រុមការងាររបស់អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិប្រចាំកម្ពុជា IJM រួមមាន ៖

១. លោកស្រី ម៉ារី ហេល័រ (Mrs. Mary Heller) នាយិកាផ្នែកស៊ើបអង្កេត
២. លោក កែ ហុកស្រ៊ុន អ្នកសម្របសម្រួលនិងត្រួតពិនិត្យការបណ្តុះបណ្តាល

ខ. ភារកិច្ច

- សហការ សម្របសម្រួល រៀបចំ ផែនការ កម្មវិធីការងារ សម្រាប់ដំណើរការ

-រៀបចំខ្លឹមសារមេរៀន និង ពិនិត្យពិភាក្សា លើខ្លឹមសារមេរៀន ដើម្បីរៀបចំ បោះពុម្ព ជាសៀវភៅគោល សម្រាប់ប្រើប្រាស់ក្នុងកម្មវិធីបណ្តុះបណ្តាល

-រៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោល សម្រាប់ដំណើរការបង្ហាត់បង្រៀន តាមកម្មវិធីអប់រំរបស់បណ្ឌិត្យសភានគរបាលកម្ពុជា

-រាយការណ៍អំពីសកម្មភាពនិងលទ្ធផលការងារ ជាបន្តបន្ទាប់ ជូនឯកឧត្តមប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា តាមរយៈក្រុមប្រឹក្សាអភិវឌ្ឍគ្រូនគរបាលជាតិ

ក្រុមការងារមានសិទ្ធិប្រើប្រាស់ មន្ត្រី ឬ បុគ្គលិកក្រោមឱវាទរបស់ខ្លួន សម្រាប់ជួយបំពេញការងារ ដើម្បីសម្រេចភារកិច្ច ដោយជោគជ័យ ។

ឯកឧត្តម អស់លោក លោកស្រី ដែលមានរាយនាមក្នុងលិខិតបង្គាប់ការនេះ ត្រូវអនុវត្តភារកិច្ចរបស់ខ្លួន ឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ។

ជីតជ្ជ ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០១៦

**ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា**

នាយឧត្តមសេនីយ៍ **សេង ផល្លី**

កន្លែងទទួល៖

- ថ្នាក់ដឹកនាំបណ្ឌិត្យសភានគរបាលកម្ពុជា
- សាមីខ្លួន
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
បណ្ឌិត្យសភានគរបាលកម្ពុជា

លេខ ៤០៩ ល.ខ.អ

# លិខិតថ្លែងអំណរគុណ

ការគាំទ្រលើកម្មវិធីកាត់បន្ថយអំពើជួញដូរមនុស្ស រត់ពន្ធមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ កំពុងតែកើតមាននៅជុំវិញពិភពលោក ។ ឯកសារសម្រាប់បណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់ ស្តីពី នីតិវិធីនៃការស៊ើបអង្កេតបទល្មើសជួញដូរមនុស្ស ត្រូវបានរៀបចំតាក់តែងឡើងតាមលិខិតបង្គាប់ការលេខ០១៨ ល.ប.ក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៦ របស់បណ្ឌិត្យសភានគរបាលកម្ពុជា ដើម្បីឱ្យក្រុមការងាររៀបចំផែនការ កម្មវិធីបណ្តុះបណ្តាល និងខ្លឹមសារមេរៀនរវាងបណ្ឌិត្យសភានគរបាលកម្ពុជា សហការជាមួយ អង្គការបេសកកម្មយុត្តធម៌អន្តរជាតិ ។

ឆ្លងតាមការពិនិត្យ ពិភាក្សានិងកែសម្រួល របស់ក្រុមប្រឹក្សាអភិវឌ្ឍគ្រូនគរបាលជាតិ នៃបណ្ឌិត្យសភានគរបាលកម្ពុជា សហការជាមួយអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ ដោយមានតំណាងនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងក្រុមមេធាវីរបស់អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ ជាអ្នកពិគ្រោះយោបល់ ទើបបានបញ្ចប់ការពិនិត្យ ពិភាក្សានិងកែសម្រួលនៅថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៧។

បណ្ឌិត្យសភានគរបាលកម្ពុជាសង្ឃឹមថា សៀវភៅគោល ស្តីពីនីតិវិធីនៃការស៊ើបអង្កេតបទល្មើសជួញដូរមនុស្ស ជាមូលដ្ឋានគ្រឹះក្នុងការបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់ ឱ្យយល់ដឹងកាន់តែច្បាស់ ដើម្បីអនុវត្ត ភារកិច្ច មានប្រសិទ្ធភាពខ្ពស់ក្នុងស្មារតីទទួលខុសត្រូវ គោរពច្បាប់ គោរពសិទ្ធិមនុស្ស និងជួយឱ្យប្រជាពលរដ្ឋទទួលបាននូវផលប្រយោជន៍ដោយមិនមានការរើសអើង ។

ក្នុងនាមប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់ក្រុមការងាររបស់បណ្ឌិត្យសភានគរបាលកម្ពុជា អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ( IJM) តំណាងនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ក្រុមមេធាវីរបស់អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ និងក្រោមការឧបត្ថម្ភថវិកាពី អង្គការ USAID និង WINROCK ដែលបានរួមចំណែកយ៉ាងសកម្មយកអស់កម្លាំងកាយចិត្ត ផ្តល់នូវបច្ចេកទេស និងថវិកាក្នុងការរៀបចំ កែសម្រួលសៀវភៅគោលខាងលើ ។

ធ្វើនៅជីតជ្ញថ្ងៃទី១៧ ខែ មេសា ឆ្នាំ២០១៧

**ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា**

នាយឧត្តមសេនីយ៍ **សេង ផល្លី**

USAID
ជំនួយពីពលរដ្ឋអាមេរិក

WINROCK INTERNATIONAL

IJM

# បណ្ឌិត្យសភានគរបាលកម្ពុជា

## កម្មវិធីបណ្តុះបណ្តាលនគរបាលជាតិ

# បច្ចេកទេសសម្ភាស

២០១៧

សូមរក្សាសិទ្ធិ

មេរៀននេះមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់អង្គការវីនរ៉ក់ ឬរដ្ឋាភិបាលអាមេរិក

# បច្ចេកទេសសម្ភាស

## សេចក្ដីផ្ដើម

ការស្ទង់មតិមួយធ្វើឡើងដោយមានសកម្មភាព ៨ យ៉ាង ដែលមន្ត្រីមួយរូបអនុវត្តបានត្រឹមត្រូវតាមទម្លាប់ រួចហើយស្នើឱ្យអ្នកឆ្លើយសំណួរបញ្ជាក់តាមចំនួនភាគរយនៃពេលវេលា ដែលពួកគេចំណាយដើម្បីបំពេញកាតព្វកិច្ចនេះ ។ សូមច្បាស់ក្នុងចិត្តថា សកម្មភាពទាំង ៨ យ៉ាងនឹងជួយឱ្យអ្នកធ្វើការសន្និដ្ឋានយ៉ាងត្រឹមត្រូវ ។

**១. តើអ្វីដែលហៅថា " ការសម្ភាស " ?**

ទំនាក់ទំនងជាមួយប្រជាពលរដ្ឋ គឺជាផ្នែកមួយដ៏សំខាន់បំផុតនៃការងាររបស់មន្ត្រីនគរបាល ជាពិសេសការសម្ភាសយកព័ត៌មាន ។ ចូរជ្រើសរើសយកវិធីឱ្យបានច្រើនតាមដែលអាចធ្វើទៅបាននៃទំនាក់ទំនងនៅក្នុងសមត្ថកិច្ចប្រមូលព័ត៌មានពីសាធារណជន ដើម្បីបង្ហាញឱ្យឃើញថា ជំនាញដែលគេបានសិក្សានឹងជួយពួកគេនៅគ្រប់ទីកន្លែង មិនមែនត្រឹមតែនៅក្នុងបន្ទប់សម្ភាសប៉ុណ្ណោះទេ ។ នៅទីកន្លែងខ្លះ មន្ត្រីនគរបាលចំណាយពេលវេលា ៨៥% នៃម៉ោងធ្វើការរបស់ខ្លួន ដើម្បីធ្វើទំនាក់ទំនងជាមួយប្រជាពលរដ្ឋ ។

នៅក្នុងការស៊ើបអង្កេតព្រហ្មទណ្ឌ ប្រជាពលរដ្ឋដែលជាសាក្សី ឬក៏ជនរងគ្រោះ មានតួនាទីសំខាន់ណាស់ដូចជា៖

- ផ្ដល់ព័ត៌មាន ឬតម្រុយ
- បង្កើនលទ្ធភាពដល់ការចាប់ខ្លួនជនសង្ស័យ
- បង្កើនលទ្ធភាពដល់ការនាំមកស្ដាប់ចម្លើយ និងការចោទប្រកាន់លើជនសង្ស័យ ។

**២. ការសម្ភាស**

- ទំនាក់ទំនងជាមួយសាក្សី និងជនរងគ្រោះធ្វើឱ្យការសម្ភាសទទួលបានលទ្ធផលល្អ
- ការសម្ភាសត្រូវបានប្រើប្រាស់ ដើម្បីប្រមូលព័ត៌មានអំពីបទល្មើសឱ្យបានច្រើន និងសុក្រឹតដែលអាចធ្វើទៅបាន
- ចំណុចសំខាន់នៃការចម្រាញ់យកព័ត៌មានពីមនុស្សណាម្នាក់ គឺការប្រាស្រ័យទាក់ទងដ៏មានប្រសិទ្ធភាព និងមានគោលបំណង ។

**ក. គោលការណ៍នៃការសម្ភាស**

- សួរសំណួរច្រើនជាងការបង្ខំឱ្យឆ្លើយ
- ប្រើអំណាចបន្តិចបន្តួច
- ស្ទង់ពិនិត្យមើលប្រសើរជាងការសួរសំណួរយ៉ាងល្អិតល្អន់
- សាកសួរប្រសើរជាងការបញ្ចេញយោបល់ប្រឆាំង
- ស្នើសុំប្រសើរជាងការទាមទារ ។

**ខ. ប្រការចៀសវាងក្នុងការស្តាប់ចម្លើយ**

- ការបំភ័យ
- ការបញ្ចោញយោបល់ប្រឆាំង
- ការព្រមាន
- ការចោទប្រកាន់
- ការបដិសេធ
- ការទាមទារ និងការត្រួតត្រា ។

ដូច្នេះ ត្រូវប្រើគោលការណ៍នៃការសម្ភាស ។ នៅក្នុងហេតុការណ៍ណាក៏ដោយ គួរចៀសវាងប្រើពាក្យ " សួរចម្លើយ " ពីព្រោះ វាមានគំនិតអវិជ្ជមាន ។

**គ. ការសម្ភាសល្អ**

ការសម្ភាសល្អផ្តល់ឱ្យយើងនូវព័ត៌មានជាក់លាក់ និងពិស្តារ (ព័ត៌មានពិត) ដែលជួយដល់ការស៊ើបអង្កេត ការចាប់ឃាត់ខ្លួន ឬការនាំមកស្តាប់ចម្លើយ និងធ្វើការចោទប្រកាន់ដោយមិនធ្វើឱ្យជនរងគ្រោះ ឬសាក្សីប៉ះទង្គិចផ្លូវចិត្ត ។

**ឃ. ការសម្ភាសមិនល្អ**

- មិនទទួលបានព័ត៌មានគួរទុកចិត្តតាមសេចក្តីត្រូវការ
- ទទួលព័ត៌មានមិនសុក្រឹត
- ធ្វើឱ្យភាគីពាក់ព័ន្ធប៉ះពាល់ដល់ផ្លូវចិត្ត
- ធ្វើឱ្យសក្ខីកម្មរបស់ជនរងគ្រោះ ឬសាក្សីចុះខ្សោយ ។

**៣. ក្រមសីលធម៌ក្នុងការសម្ភាស**

ជាទូទៅ ក្រមសីលធម៌របស់មន្ត្រីនគរបាលសំខាន់ណាស់ក្នុងការអនុវត្តភារកិច្ច៖

- ភាពជឿជាក់និងសេចក្តីទុកចិត្ត ដែលសារធារណជនមើលឃើញ ជាការសំខាន់ចំពោះមន្ត្រីនគរបាល
- នៅពេលធ្វើការទាក់ទងជាមួយនឹងជនរងគ្រោះ ឬសាក្សី អាកប្បកិរិយារបស់អ្នកស៊ើបអង្កេតអាចប៉ះពាល់ដល់សក្ខីកម្មរបស់ជនរងគ្រោះ និងសាក្សី ។ ដូចនេះ វាជាការសំខាន់ណាស់ដែលមិនត្រូវប្រព្រឹត្តទៅលើជនរងគ្រោះ និងសាក្សីដូចជា៖
    - ការគំរាមកំហែង ការបង្ខិតបង្ខំ ការប្រើកម្លាំង ឬគំរាមដោយប្រើកម្លាំង
    - ការសន្យាមិនស្របច្បាប់ ឬការសន្យាដែលមិនអាចបំពេញបាន
    - ការធ្វើឱ្យប៉ះពាល់កិត្តិយស
    - ការជេរ ឬប្រមាថ
    - ការចាត់ទុកពួកគេថាមានកំហុស
    - ការស្តាប់ចម្លើយហួសនីតិវិធី ( ពន្យាពេលជនរងគ្រោះ/សាក្សី ដើម្បីយកព័ត៌មានបន្ថែម) ។

# ជំពូកទី ១

# ការសម្ភាសជនរងគ្រោះ និងសាក្សី

## I. ការយល់ដឹងចំពោះការចងចាំ

### ១. មូលដ្ឋានគ្រឹះនៃការចងចាំ

ការចងចាំ គឺជាសរីរាង្គធំបំផុតនៃចំណេះដឹងទូទៅ រួមមាន ព័ត៌មានរំលឹក ឬការណែនាំដែលជាបណ្តុំព័ត៌មាន ប្រាប់យើងនូវអ្វីដែលត្រូវធ្វើ ឬរបៀបប្រព្រឹត្ត ឬសម្តែងក្នុងស្ថានភាពដែលកើតឡើងជាច្រើន និងជួយអ្នកឱ្យដំណើរការព័ត៌មានបានលឿន ។ វាផ្តល់នូវព័ត៌មានទូទៅដូចជាព័ត៌មានរំលឹក ។

ឧទាហរណ៍ ៖ នៅពេលអ្នកទៅភោជនីយដ្ឋាន អ្នកដឹងថា អ្នកត្រូវការអង្គុយ រួចហៅភេសជ្ជៈ ពិនិត្យមើលបញ្ជីរាយនាមមុខម្ហូប ហៅយកម្ហូបអាហារដើម្បីបរិភោគ និងបង់ប្រាក់ ។ ក្រៅពីការចងចាំនៅពេលនីមួយៗដែលអ្នកបានទៅភោជនីយដ្ឋាន អ្នកនឹងបង្កើតព័ត៌មានអំពីបទពិសោធន៍ជាទូទៅចំពោះពេលនីមួយៗ ដែលអ្នកបានទៅភោជនីយដ្ឋាន ។

ព័ត៌មាននោះបង្កើតការណែនាំសម្រាប់ប្រើ រាល់ពេលដែលអ្នកបានបំពេញភារកិច្ច ដូច្នេះ វាជួយឱ្យអ្នកកាត់បន្ថយ និងដំណើរការព័ត៌មានមួយចំនួនធំ បានលឿន និងមានគុណភាព ។ អ្នកទទួលព័ត៌មានទាំងអស់ដែលអ្នកត្រូវការ ដើម្បីបំពេញភារកិច្ចដោយមិនចាំបាច់ចងចាំពីពេលវេលានីមួយៗដែលអ្នកបានធ្វើ ដូចនេះ វានឹងជួយឱ្យអ្នកកត់ត្រាសេចក្តីលម្អិតថ្មី ។

បញ្ហានេះ ក៏អាចដូចគ្នានឹងការត្រឡប់ទៅកាន់គេហដ្ឋានរបស់អ្នកវិញ បន្ទាប់ពីអ្នកបានឃ្លាតឆ្ងាយអស់រយៈពេលដ៏យូរ ។ អ្នកនឹងបានឃើញអ្វីថ្មីប្លែកនៅក្នុងផ្ទះរបស់អ្នក ឬសម្ភារដែលត្រូវបានគេប្រមូលចេញ ហើយមិនយកចិត្តទុកដាក់លើសម្ភារដែលនៅនឹងកន្លែងដដែល ។

ឧទាហរណ៍៖

- ព័ត៌មានទាក់ទងនឹងជំនាញ ៖ សំដៅលើចំណេះដឹងចាំបាច់ក្នុងការធ្វើអ្វីមួយ
  - ការបើកបររថយន្ត
  - ការជិះកង់
  - ការចំអិនអាហារ
  - ការចាប់ឃាត់ខ្លួន ។
- បទពិសោធន៍ផ្ទាល់ខ្លួន ៖ សំដៅលើអ្វីកើតឡើងចំពោះអ្នកក្នុងអតីតកាល
  - តើអ្នកបានធ្វើអ្វីកាលថ្ងៃខួបកំណើតលើកទី៥ របស់អ្នក?
  - តើអ្វីបានកើតឡើងចំពោះអ្នកកាលពីចុងសប្តាហ៍មុន ?
  - ការសន្ទនាដែលអ្នកបានធ្វើជាមួយថ្នាក់ដឹកនាំរបស់អ្នក ។

### ២. ដំណើរការចងចាំនៃប្រព័ន្ធខួរក្បាល

- នៅក្នុងខួរក្បាលរបស់យើង មានបញ្ហា៣ ទាក់ទងនឹងការចងចាំព័ត៌មាន៖

ការថតទុក ៖ ព័ត៌មានទទួលបាន និងបញ្ជូនទៅក្នុងនិមិត្តសញ្ញា ។ និមិត្តសញ្ញាគឺជាសញ្ញា ឬបណ្តុំនៃនិមិត្តរូបដែលយើងប្រើដើម្បីតំណាងឱ្យអ្វីមួយ ។ ដូច្នេះ នៅពេលដែលវត្ថុនោះមិននៅ

ចំពោះមុខយើង វាមិនអាចឱ្យយើងមើលឃើញ ប៉ុន្តែយើងអាចនឹកស្រមៃឃើញពីរូបភាពរបស់វាបាន

○ ការរក្សាទុកព័ត៌មាន ៖ នៅអំឡុងពេលព័ត៌មានដែលបានថតទុកហើយ វាត្រូវបានរៀបចំ និងរក្សាទុក

○ ការរំលឹកព័ត៌មាន ៖ នៅអំឡុងពេលដែលអ្នករំលឹកព័ត៌មាននោះម្តងទៀត ដែលបានថតទុកដើម្បីឱ្យចងចាំ ។ ប៉ុន្តែ អ្នកអាចមិនចងចាំព័ត៌មានដោយសារតែ ៖

- ខ្វះការប្រុងប្រយ័ត្នមិនយល់ព័ត៌មានតាំងពីដំបូង
- ការរក្សាព័ត៌មានមិនបានសមស្រប
- គ្មានសមត្ថភាពរំលឹកដំណើរការព័ត៌មាន ។

• លក្ខណៈស្រដៀងនឹងទូឯកសារ

○ ចូរគិតថា ខួរក្បាលរបស់យើង គឺជាថតសម្រាប់ផ្ទុកឯកសារធំមួយ

○ រាល់ព្រឹត្តការណ៍ដែលអ្នកចងចាំ គឺជាសំណុំឯកសារមួយ ដែលបានទាញយកចេញពីថតមួយក្នុងចំណោមថតទាំងឡាយ

○ ចូរគិតអំពីបញ្ហារក្សា និងរំលឹកព័ត៌មាននៅក្នុងបរិបទ " ទូឯកសារ " ដូចគ្នា ។

• ព័ត៌មានដែលអ្នកកំពុងព្យាយាមទទួល អាចត្រូវបានដាក់ផ្លាកសញ្ញាខុស នៅក្នុងសំណុំឯកសាររបស់វា ឬអាចដាក់នៅក្នុងថតគុ ឬក្នុងទូខុសកន្លែង ។ ព្យាយាមចងចាំអ្វីៗទាំងអស់ "នៅចុងមាត់របស់អ្នក " គឺជាឧទាហរណ៍មួយដ៏ល្អនៃការព្យាយាម ដើម្បីធ្វើឱ្យអ្នកចងចាំព័ត៌មានទាំងនោះ ដែលអ្នកបានដាក់នៅក្នុងថតគុ ឬទូខុសទីកន្លែង ។ ការទទួលយកព័ត៌មានសុក្រឹត ឬលម្អិតដែលអាចធ្វើទៅបានពីអ្នកឆ្លើយសម្ភាសដែលស្ថិតនៅក្រោមការស៊ើបអង្កេត គឺមានសារៈសំខាន់ណាស់ ។

## ៣. ការចងចាំព្រឹត្តិការណ៍ស្មុគស្មាញ

ការចងចាំព្រឹត្តិការណ៍ស្មុគស្មាញ ដូចជា ការចងចាំព្រឹត្តិការណ៍របស់ជនរងគ្រោះ និងសាក្សីដែលពួកគេបានជួបប្រទះ ត្រូវទទួលរងឥទ្ធិពលដោយកត្តាមួយចំនួនជាសំខាន់ក្នុងការចងចាំ ។

• ការថតទុកនៃការចងចាំដំបូង ៖ ស្ថានភាពនៃជនរងគ្រោះ ឬក៏សាក្សីនៅពេលកើតហេតុ មានន័យថា ការកំណត់ពេលវេលា ទីកន្លែង សាក្សីពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ ការប្រើប្រាស់គ្រឿងញៀន ឬគ្រឿងស្រវឹងរបស់បុគ្គលណាម្នាក់ ដែលប៉ះពាល់ដល់ការចងចាំព័ត៌មានសុក្រឹត ។

○ ភាពតានតឹង ៖ តាមធម្មតា វាស្ថិតនៅក្រោមលក្ខខ័ណ្ឌតានតឹង និងសមត្ថភាពចងចាំរបស់បុគ្គលណាម្នាក់នឹងថយចុះនូវបរិមាណ ប៉ុន្តែកើនឡើងនូវគុណភាព មានន័យថា មនុស្សនឹងចងចាំបានតិច ប៉ុន្តែមានភាពសុក្រឹតខ្ពស់ ។ ដោយសារភាពតានតឹងបណ្តាលឱ្យបុគ្គលផ្តោតការយកចិត្តទុកដាក់លើទិដ្ឋភាពជាក់លាក់នៃព្រឹត្តិការណ៍តានតឹង សម្រាប់ហេតុផលផ្ទាល់ខ្លួន ឬអ្នកដទៃ គឺត្រូវបានចាត់ទុកថាមានសារៈសំខាន់របស់បុគ្គលនៅពេលនោះ

ឧទាហរណ៍៖ បាតុភូតមួយដែលគេឱ្យឈ្មោះថា ការផ្តោតលើការប្រើប្រាស់អាវុធ នៅពេលជនរងគ្រោះត្រូវបានគេគំរាមដោយអាវុធ ពួកគេទំនងជាចងចាំបានតិចអំពីជនល្មើស ពីព្រោះការប្រុងប្រយ័ត្នរបស់ពួកគេតម្រង់ឆ្ពោះទៅរកអាវុធដែលជាវត្ថុធ្វើឱ្យមានភាពតានតឹង ។

◦ ការចូលរួមរបស់សាក្សី ៖ តាមធម្មតា សាក្សីកាន់តែពាក់ព័ន្ធចំពោះរឿងអ្វីដែលបានកើតឡើង ការចងចាំកាន់តែល្អប្រសើរ

◦ ការប្រុងប្រយ័ត្នៈ ប្រសិនបើចំណុចណាមួយនៃព្រឹត្តិការណ៍មិនត្រូវបានដឹងនៅទីកន្លែងដំបូង នោះវាមិនត្រូវបានចងចាំទេនៅពេលក្រោយ ។ ក្រោយមកអ្វីដែលបុគ្គលជ្រើសរើសក្នុងការផ្តោតការយកចិត្តទុកដាក់គឺជាកត្តានៃចំណេះដឹង ការអប់រំ សេចក្តីរំពឹងទុក បទពិសោធន៍ ឥរិយាបថ និងចំណង់ចំណូលចិត្ត ។

- ការរំលឹកព័ត៌មាន ៖ ត្រូវយល់ដឹងថា ការចងចាំមានប្រយោជន៍ ។ អ្នកបានឃើញ និងថតទុកពីព្រឹត្តិការណ៍ណាមួយ ។ ការរំលឹកព័ត៌មានមកវិញ ត្រូវបានជួយសម្រួលដោយការគិតពិចារណាលើព្រឹត្តិការណ៍ និងចំណេះដឹងទូទៅ ។

◦ សារជាតិរបស់មនុស្ស ៖ មិនអាចដឹងបានទេ ។ ចរិតលក្ខណៈមិនប្រែប្រួលរបស់មនុស្សអាចច្របូកច្របល់ ដោយការថតទុកទៅលើបុគ្គលដែលជួបប្រទះព្រឹត្តិការណ៍ ដែលអាចនាំទៅរកការចងចាំមនុស្សដោយមិនជាក់លាក់

◦ ការប្រកាន់បក្សពួក ៖ ការប្រកាន់បក្សពួកពីបុគ្គល ឬក៏ដំណើររឿងនៅក្នុងព្រឹត្តិការណ៍ដែលមានសារៈសំខាន់ផ្ទាល់ខ្លួនចំពោះសាក្សី ឬជនរងគ្រោះអាចនាំទៅរកសនិទានកម្ម (ធ្វើឱ្យសមហេតុផល)ដែលធ្វើឱ្យការចងចាំពីព្រឹត្តិការណ៍ខុសពីការពិត

◦ កាលៈទេសៈ ៖ ការនាំមនុស្សទៅរកកន្លែង ឬស្ថានភាពដដែលវិញដែលជាព្រឹត្តិការណ៍ពួកគេព្យាយាមរំលឹក អាចជួយពួកគេឱ្យចងចាំ មានន័យថា ជាការនាំយកមនុស្សទៅរកកន្លែងដើមវិញ ការនាំយកផ្នែកមួយនៃទីកន្លែងមករំលឹកចំពោះពួកគេ និងការបង្កើតអារម្មណ៍រំភើប ឬស្ថានភាពផ្លូវចិត្តរបស់ពួកគេឡើងវិញ ។ បញ្ហានេះមិនដំណើរការទេ នៅក្នុងស្ថានភាពដែលធ្វើឱ្យសាក្សីតក់ស្លុត ពីព្រោះអាចធ្វើឱ្យពួកគេមិនអាចចងចាំ ។

## II. របៀបសួរសំណួរ

### ១. សេចក្តីផ្តើម

ការផ្តើមលើកសំណួរ ចូរឱ្យសិក្ខាកាមម្នាក់ចាកចេញពីថ្នាក់រៀន ។ បន្ទាប់មកសួរសិក្ខាកាមដទៃអំពីអ្វីដែលពួកគេបានធ្វើកាលពីពេលព្រឹក ដោយប្រើប្រាស់សំណួរបិទតៗគ្នាពីម្នាក់ទៅម្នាក់ទៀតហើយជានាឱ្យបានលឿន ហើយកត់ត្រានូវអ្វីដែលបានបង្រៀន ។ បន្ទាប់មកហៅសិក្ខាកាមនៅខាងក្រៅចូលមក ហើយសួរសំណួរដោយប្រើសំណួរបើក " តើអ្នកបានធ្វើអ្វីកាលពីពេលព្រឹក? " ហើយប្រៀបធៀបលទ្ធផល ។ ប្រភេទសំណួរផ្សេងគ្នា បង្កើតចម្លើយផ្សេងគ្នា ។

- សំណួរដែលអ្នកសួរសំខាន់ណាស់ពីព្រោះសំណួរមួយចំនួនបង្កើតព័ត៌មានល្អប្រសើរ ។
- របៀបនៃការសួរសំណួរក៏សំខាន់ដែរ ៖ ចំពោះជនរងគ្រោះ ឬសាក្សីភាគច្រើនមិនដែលជួបប្រទះការសម្ភាស ។ ពួកគេមិនធ្លាប់មានការណែនាំទេ ដូច្នេះ ពួកគេតាមដានអ្នកសម្ភាស ថាតើអ្នកសម្ភាសមានអាកប្បកិរិយាបែបណា ។ ប្រសិនបើអ្នកសម្ភាសសួរសំណួរបិទ លឿន ខ្លី ជាបន្តបន្ទាប់

អ្នកឆ្លើយសម្ភាសនឹងផ្តល់ចម្លើយលឿនដោយមិនមានន័យគ្រប់គ្រាន់ និងមិនបានលម្អិតទេ ។

**២. ប្រភេទសំណួរ**

មានរបៀបសួរសំណួរជាច្រើន ដែលអាចជាសំណួរសមស្រប និងមិនសមស្រប ។

**ក. សំណួរសមស្រប**

- សំណួរបើក៖ ត្រូវបានបង្កើតឡើងយ៉ាងទូលំទូលាយ ហើយផ្តល់ឱ្យអ្នកឆ្លើយដោយដោយសេរីក្នុងការបញ្ចេញយោបល់ ដែលធ្វើឱ្យការផ្តល់ព័ត៌មានកាន់តែច្បាស់ ។ សំណួរបើកត្រូវបានគេប្រើដំបូងក្នុងការសម្ភាស ។
  - ពួកគេទទួលបានព័ត៌មានច្បាស់លាស់បំផុត ពីព្រោះអ្នកឆ្លើយសម្ភាស ត្រូវបានអនុញ្ញាតឱ្យមានសេរីភាពរំលឹកពីព្រឹត្តិការណ៍
  - អ្នកសម្ភាសធ្វើឱ្យអ្នកឆ្លើយ យកចិត្តទុកដាក់
  - អនុញ្ញាតឱ្យអ្នកសម្ភាសដឹងអំពីឥរិយាបថ តម្លៃ តម្រូវការ អាទិភាព និងអំណះអំណាងរបស់អ្នកឆ្លើយ ។
- សំណួរបិទ៖ បង្កើតឡើងដោយអនុញ្ញាតឱ្យមានចម្លើយតែមួយ ។ សំណួរទាំងនេះ គួរប្រើនៅលើកទីពីរ បន្ទាប់ពីសំណួរបើកគ្មានប្រសិទ្ធភាព ។ សំណួរបិទអាចប្រើ ដើម្បីបំពេញចន្លោះខ្វះខាតខាងព័ត៌មាន នៅពេលដែលអ្នកឆ្លើយសម្ភាសមិនបានស្ម័គ្រចិត្តឆ្លើយសំណួរបើក ដូចជា នរណា អ្វី នៅពេលណា និងនៅកន្លែងណា ។ អ្នកគួរតែចៀសវាងការប្រើសំណួរពាក្យ ហេតុអ្វី ព្រោះអ្នកឆ្លើយសម្ភាសមិនមែនជាជនសង្ស័យទេ ហើយចម្លើយដែលពួកគេបានផ្តល់ គឺមិនអាចស្មានៗបានទេ ។

**ខ. សំណួរមិនសមស្រប**

- សំណួរនាំមុខ៖ សំណួរដែលបង្ហាញសាក្សីម្នាក់ ថាតើត្រូវឆ្លើយយ៉ាងណា ឬផ្តល់គំនិតឱ្យឆ្លើយចម្លើយដែលគេចង់បាន ។ ប្រភេទនៃសំណួរនេះអាចនាំ ជនរងគ្រោះ ឬសាក្សីឈានទៅរកការរៀបរាប់សាច់រឿងពិត មិនសុក្រឹត និងទីបំផុតធ្វើឱ្យសក្ខីកម្មរបស់ជនរងគ្រោះ ឬសាក្សីឥតបានការ
- សំណួរពហុជ្រើសរើស៖ ធ្វើឱ្យអ្នកឆ្លើយសម្ភាសជ្រើសរើស ពីតារាងចម្លើយមុនពេលសម្រេចចិត្ត ។ សំណួរទាំងនេះធ្វើឱ្យសុក្រឹតភាពថយចុះ ពីព្រោះអ្នកឆ្លើយសម្ភាសទំនងជាជ្រើសរើសចម្លើយដែលអាចធ្វើទៅបាន ទោះបីជាមិនមានចម្លើយត្រឹមត្រូវបំផុតក៏ដោយ ។

## III. ផែនការសម្ភាស

ការលម្អៀងដោយអ្នកសម្ភាស ៖ គំនិត ឬទ្រឹស្តីដឹងមុនអំពីអ្វីដែល ពិតជាបានកើតឡើង អាចបន្ថយការយកចិត្តទុកដាក់របស់អ្នកសម្ភាសចំពោះការរៀបរាប់ពិស្តារទាំងអស់ ហើយបង្កើនការស្តាប់ ។ ការព្យាយាមធ្វើឱ្យចម្លើយរបស់អ្នកឆ្លើយសម្ភាសមានលក្ខណៈស្តង់ដាដើម្បីលប់បំបាត់ការខ្វែងគំនិត ឬធ្វើឱ្យរឹងមាំសម្រាប់ការកាត់ក្តី អាចធ្វើឱ្យខូចដល់សក្ខីកម្មរបស់សាក្សី និងជនរងគ្រោះ ។ មានសកម្មភាពមួយចំនួនដែលត្រូវធ្វើឱ្យបានសម្រេចមុនការសម្ភាសចាប់ផ្តើម ។

**១. ការស្រាវជ្រាវពីសាវតារ**

- អានឯកសាររឿងក្តីទាំងអស់ដែលបានប្រមូល
- ព្យាយាមយល់ពីលក្ខណៈសម្បត្តិផ្ទាល់ខ្លួន ចំណង់ចំណូលចិត្ត ទម្លាប់ ផ្នត់គំនិតរបស់សាក្សី និងជនរងគ្រោះ
- ត្រួតពិនិត្យមើលពីសាវតាររបស់អ្នកឆ្លើយសម្ភាស និងមនុស្សដទៃដែលពាក់ព័ន្ធនឹងរឿងក្តី ដើម្បីទទួលបានលទ្ធផលដ៏មានប្រយោជន៍ ។

**២. ការជ្រើសរើសអ្នកសម្ភាស**

- គួរតែមានអ្នកសម្ភាសតែម្នាក់គត់
- អាយុ ភេទ និងជាតិសាសន៍របស់អ្នកសម្ភាស ត្រូវជ្រើសរើស និងពិចារណា ។

**៣. ការបង្កើតគោលបំណងសម្ភាស**

- តើអ្នកកំពុងស្វែងរកព័ត៌មានសំខាន់ឬទេ? ដូច្នេះត្រូវកំណត់ជាមុននូវព័ត៌មានជាក់លាក់ដែលអ្នកត្រូវការ
- តើអ្នកកំពុងបង្កើតភ្នាក់ងារសម្ងាត់យកព័ត៌មានឬ? ដូច្នេះទំនាក់ទំនងរយៈពេលយូរ គឺជាគោលដៅសំខាន់បំផុតនៃការសម្ភាស
- ការរៀបចំការសម្ភាស
  - តើអ្នកនឹងនិយាយយ៉ាងដូចម្តេច ?
  - តើអ្នកនឹងប្រើវិធីយាបថយ៉ាងដូចម្តេច?
  - តើអ្នកនឹងដឹងពីភាពលម្អិតនៃរឿងក្តីច្រើនប៉ុណ្ណា?
  - តើអ្នកនឹងមានការលើកទឹកចិត្តបែបណា?
  - តើសំណួរអ្វីដែលអ្នកឆ្លើយសម្ភាសនឹងសួរអ្នកវិញ ?

**៤. បរិយាកាសទីកន្លែង**

- ការជ្រើសរើសទីកន្លែង
  - អង្គភាពនគរបាល
    - គុណសម្បត្តិ ៖ អ្នកសម្ភាស ត្រូវត្រួតពិនិត្យល្អិតល្អន់ ទៅលើបរិយាកាសសម្ភាស
    - គុណវិបត្តិ ៖ អាចជាកន្លែងសម្រាប់គំរាមកំហែងខ្លាំង ដល់អ្នកឆ្លើយសម្ភាស ។
  - កន្លែងស្នាក់នៅរបស់សាក្សី ឬជនរងគ្រោះ
    - គុណសម្បត្តិ៖ ជួយឱ្យអ្នកសម្ភាសយល់ដឹងច្រើនពីអ្នកឆ្លើយសម្ភាស ដោយការសង្កេតមើលពីរបៀបរស់នៅរបស់ពួកគេ
    - គុណវិបត្តិ៖ អ្នកមិនមានការត្រួតពិនិត្យច្រើនលើការសម្ភាស ។
- ការជ្រើសរើសពេលវេលា
  - ពេលព្រឹក ៖តាមធម្មតា អ្នកឆ្លើយសម្ភាសមានការប្រុងប្រយ័ត្ន និងយកចិត្តទុកដាក់ ។ ជួយពួកគេក្នុងការយកចិត្តទុកដាក់លើការសម្ភាស និងផ្តល់ឲ្យអ្នកនូវពេលវេលាច្រើន
  - ពេលល្ងាច ៖ អ្នកឆ្លើយសម្ភាសនឿយហត់ ឬអស់កម្លាំងជាខ្លាំង ។ ការកំហិតពេល

វេលាប្រហែលអាចកាត់ការសម្ភាសរបស់អ្នកឱ្យខ្លី និងតាមស្ថិតិ ការផ្តល់ចម្លើយច្រើនកើតមាននៅពេលជិតព្រលប់ ។

**៥. ការរៀបចំបន្ទប់**

- បរិយាកាសបន្ទប់
  - ភាពឯកជនគឺមានសារៈសំខាន់
  - បន្ទប់ត្រូវតែជាកន្លែងស្ងៀមស្ងាត់ដែលជៀសវាងពីការរំខានអារម្មណ៍
  - បន្ទប់ត្រូវតែមានសណ្តាប់ធ្នាប់ និងអនាម័យល្អ បរិយាកាសបន្ទប់ល្អ ពន្លឺបន្ទប់គួរតែមិនឱ្យខ្លាំងពេក ។
- ទីតាំងគ្រឿងសង្ហារឹម
  - មិនគួរមានរបាំងរវាងអ្នកសម្ភាស និងអ្នកឆ្លើយសម្ភាស
  - អ្នកសម្ភាសគួរតែអាចមើលឃើញរូបរាងទាំងស្រុងរបស់អ្នកឆ្លើយសម្ភាស ដើម្បីតាមដានមើលភាសាកាយវិការ និងវាយតម្លៃសមត្ថភាពយល់ដឹងមិនច្បាស់លាស់ របស់អ្នកឆ្លើយសម្ភាសដែលបិទបាំងការពិត
  - កន្លែងអង្គុយរបស់អ្នកឆ្លើយសម្ភាស គួរត្រូវដាក់នៅជាប់ទ្វារឱ្យបានសមស្រប ដែលអាចជួយបន្ថយភាពតានតឹងរបស់អ្នកឆ្លើយសម្ភាស ។

**៦. ការកត់ត្រា (ថតការសម្ភាស)**

ការកត់ត្រា និងថតការសម្ភាសសំខាន់ណាស់ ពីព្រោះវាបង្កើតរបាយការណ៍មួយ ដែលអាចប្រើប្រាស់នៅពេលជម្រះក្តី និងជួយឱ្យអ្នកសម្ភាសពិនិត្យឡើងវិញនូវអ្វីបាននិយាយ ឬស្វែងរកព័ត៌មានបន្ថែមតាមរយៈ ភាសាកាយវិការ ។ល។ ព្រមទាំងការពារមន្ត្រីពីការចោទប្រកាន់ ពីការរំលោភបំពាន និងអាកប្បកិរិយាមិនត្រឹមត្រូវ ។

- ការកត់ត្រា
  - រាល់ករណីសម្ភាសត្រូវធ្វើការកត់ត្រា
  - អាចរំខានដល់អារម្មណ៍របស់អ្នកសម្ភាស
  - អនុញ្ញាតឱ្យអ្នកឆ្លើយសម្ភាសវាយតម្លៃអ្នកសម្ភាសដោយផ្អែកលើកម្រិត និងពេលវេលានៃការសរសេររបស់អ្នកសម្ភាស ។
- ការថតវីដេអូ
  - ផ្តល់របាយការណ៍លម្អិតបំផុត
  - អាចគំរាមកំហែងអ្នកឆ្លើយសម្ភាស
  - ផ្តល់ឱ្យអ្នកសម្ភាសចាប់អារម្មណ៍លើអ្វីដែលអ្នកឆ្លើយសម្ភាសកំពុងនិយាយ ឬក៏កំពុងធ្វើជំនួសឱ្យការកត់ត្រា ។
- ការថតសំឡេង
  - ជម្រើសនេះល្អបំផុត ប្រសិនបើវីដេអូមិនអាចធ្វើទៅបាន

- ការកត់ត្រាគួរតែធ្វើឡើងអំពីភាសាកាយវិការ ទីតាំង និងរូបសម្បត្តិ
- ការថតវីដេអូ និងការថតសំឡេងត្រូវបានប្រព្រឹត្តដោយសម្ងាត់ ។

### ៧. ការវាយតម្លៃអ្នកឆ្លើយសម្ភាស

នៅពេលណាដែលយើងជួបអ្នកឆ្លើយសម្ភាស គួរស្វែងយល់ឱ្យបានច្រើនអំពីអ្នកនោះ ដែលអាចបន្ថែមដល់ការស្រាវជ្រាវសាវតារ ។

- រូបសម្បត្តិ
  - សម្លៀកបំពាក់ ឬគ្រឿងតុបតែងខ្លួន អាចចង្អុលបង្ហាញពីស្ថានភាពនៅក្នុងសង្គម
    - បញ្ហានេះសំខាន់ណាស់ ពីព្រោះមនុស្សស្លៀកពាក់បែបជំនួញ គឺមានផ្នត់គំនិតផ្សេងពីបុគ្គលស្លៀកពាក់អាវយឺត និងខោខូវប៊យ
    - ការស្លៀកពាក់នេះមិនមែនជាក្បួនលំបាកនោះទេ ដែលអាចត្រូវបានប្រើដើម្បីវាយតម្លៃថា តើពួកគេនឹងប្រព្រឹត្តអាកប្បកិរិយាក្នុងការសម្ភាសបែបណា ។ នេះជាការយល់ដឹងតាមរយៈបទពិសោធន៍ ។
  - កាយវិការ ជំហរ ឬអារម្មណ៍ គឺបង្ហាញឱ្យដឹងពីឆន្ទៈក្នុងការឱ្យអ្នកធ្វើសម្ភាស ។
- កត្តាវប្បធម៌ ឬ ជាតិសាសន៍

វាសំខាន់ណាស់ក្នុងការស្រាវជ្រាវតំរិយាបថ ទំនៀមទម្លាប់ ប្រពៃណី វប្បធម៌ផ្សេងៗគ្នាចំពោះបញ្ហាដែលបានបង្ហាញដូចខាងក្រោម៖

- ឆន្ទៈនិយាយពីប្រធានបទជាក់លាក់
- អ្នកមានសិទ្ធិក្នុងជួរវង្សអំណាច
- ការគោរពសាសនាផ្សេងៗគ្នា
- សញ្ញាគោរព ឬមិនគោរព ។

## IV. ការអង្កេតលើការផ្តល់ចម្លើយក្លែងក្លាយ

### ១. ការណែនាំឱ្យស្គាល់ចម្លើយក្លែងក្លាយ

សាក្សី ឬជនរងគ្រោះអាចនិយាយកុហកអ្នកសម្ភាសដោយសារហេតុផលមួយចំនួន ។ អ្នកនិយាយកុហកតម្រូវឱ្យរក្សាអង្គហេតុរបស់ខ្លួនពិតដោយការបង្កើតរឿងគួរឱ្យជឿ ហើយមិនខ្លាចចំពោះការពិនិត្យពិច័យ ។ នេះជាការងារស្មុគស្មាញដែលផ្តល់តម្រុយជាភាសាកាយវិការ និងភាសាប្រើពាក្យសម្តី ។ ការអង្កេតនៃលក្ខណៈនេះមិនមែនជាវិទ្យាសាស្ត្រទេ ហើយអ្នកសម្ភាសមិនអាចទុកចិត្តលើភាពសុក្រឹត ១០០% ទេ ។ កាយវិការអ្នកឆ្លើយសម្ភាសអាចបង្ហាញការកុហក ដោយសារកត្តាជាច្រើន ប៉ុន្តែកាយវិការទាំងនេះអាចត្រូវបានប្រើទាក់ទងនឹងអង្គហេតុ ដែលបានដឹងអំពីរឿងក្តីបង្ហាញដល់អ្នកសម្ភាសក្នុងទិសដៅត្រឹមត្រូវ ដើម្បីអង្កេតចម្លើយក្លែងក្លាយ ។

- វិធីពីរយ៉ាងក្នុងការកុហក
  - ការក្លែងបន្លំ គឺជាការប្រឌិតរឿងកុហកទាំងស្រុង

○ ការព្រួយបារម្ភបិទបាំងរឿងពិត ។

• ការដឹងកំហុស ៖ សំដៅទៅលើសាក្សីមិនមានទោស ក្នុងការពាក់ព័ន្ធបទល្មើសកំពុងស៊ើបអង្កេត ដើម្បីដឹងថាអ្នកសម្ភាសមិនជឿពួកគេ ឬពួកគេអាចមានព័ត៌មានដែលធ្វើឱ្យអាម៉ាស់ ឬដែលគួរឱ្យសង្ស័យដែលមិនទាក់ទងដល់បទល្មើស ដូចជាបុរសម្នាក់បានឃើញការរួមភេទជាមួយកុមារ ប៉ុន្តែមិនសហការជាមួយនគរបាល ពីព្រោះគាត់នៅផ្ទះបនស្រីនោះដែរ

• ក្តីបារម្ភចំពោះការដឹង ៖ សំដៅលើការភ័យខ្លាចរបស់អ្នកកុហកដែលថាការកុហករបស់ខ្លួននឹងត្រូវបានគេដឹង ។ ការចង់ដឹងចង់ឮ (ការអន្ទះសារ) ជាបុព្វហេតុដ៏ចម្បងនៃការចង្អុលបង្ហាញពីភាសាកាយវិការ និងប្រើពាក្យសម្តីនៃការកុហក

• ភាពច្បាស់ក្រឡែត ៖ សំដៅលើការជឿ ដែលអ្នកកុហកតែងតែជឿថា ការកុហករបស់ខ្លួនបានបង្ហាញឱ្យឃើញច្បាស់ក្រឡែត ។

## ២. វិធីសាស្រ្តអង្កេតលើការផ្តល់ចម្លើយក្លែងក្លាយ

យើងគួរតែដឹងថា វាមិនអាចមានលទ្ធភាពដឹងពីការភូតកុហកនោះទេ ។ ខាងក្រោមគ្រាន់តែជាសញ្ញា ឬសកម្មភាពដែលអាចមានការពិត ប៉ុន្តែមិនមែននោះទេ ទោះបីយើងប្រើវាតែមួយ ឬគួបផ្សំជាមួយគ្នាក៏ដោយក៏មិនអាចធានាថា បុគ្គលនោះនិយាយកុហក ឬអត់នោះដែរ ។

• ភាពប្រក្រតី ឬ មិនប្រក្រតី ៖ មនុស្សដែលឈឺចាប់ពីការដឹងកំហុស និងក្តីបារម្ភចំពោះការដឹង ស្ថិតក្រោមភាពតានតឹងខ្លាំង និងបង្ហាញកាយវិការដោយសារលទ្ធផលនៃភាពតានតឹង ។ លើសពីនេះទៅទៀត វាគឺជាការព្យាយាមមួយសម្រាប់អ្នកនិយាយកុហក ដើម្បីប្រឌិតចម្លើយចំពោះសំណួរសាមញ្ញៗ ហើយរំលឹកអ្វីដែលពួកគេក្លែងបន្លំ (កុហក) ។ មនុស្សដែលគួរទុកចិត្តមានកាយវិការចំហ និងការដកដង្ហើមធម្មតា ។ ការនៅមិនស្ងៀម ការប៉ះក្បាល ឬមុខ ការមិនមើលឱ្យចំភ្នែក និងតម្រូវការខ្លាំងចង់ចាកចេញ គឺជាសញ្ញានៃភាពតានតឹងខ្លាំង និងភាពមិនប្រក្រតី

• ការសង្កត់ន័យ ៖ តាមធម្មតា មនុស្សដែលកំពុងនិយាយការពិត គឺមានការប្តេជ្ញាចិត្តខ្លាំងចំពោះអ្វីដែលខ្លួនកំពុងនិយាយ ។ ផ្ទុយទៅវិញ អ្នកដែលកំពុងនិយាយកុហក មានទំនោរទៅរកការបញ្ជាក់តិចតួចលើអំណះអំណាងរបស់ពួកគេ

• ភាពស៊ីចង្វាក់៖ សំដៅលើការស៊ីគ្នានៃភាសាកាយវិការ និងភាសាសម្តី រវាងអ្នកសម្ភាសនិងអ្នកឆ្លើយសម្ភាស ។ ប៉ុន្តែ គ្មានភាពស៊ីគ្នាទេ នៅពេលមានភាគីម្ខាងកំពុងនិយាយកុហក

• ការគ្រប់គ្រងការដឹង ៖ សំដៅទៅលើគោលបំណងដែលអ្នកនិយាយកុហកធ្វើ ដើម្បីឱ្យអ្នកសម្ភាសជឿ ។ ចូរពិនិត្យ តាមដានកាយវិការ ដូចជាអ្នកឆ្លើយសម្ភាសព្យាយាមខ្លាំងក្លា ដើម្បីឱ្យមើលទៅហាក់ដូចជាធុញទ្រាន់ ឬមានភាពប្រក្រតី ។ ត្រូវសង្ស័យចំពោះអ្នកឆ្លើយសម្ភាសនិយាយថា ខ្ញុំមិនដែលកុហកទេ ។

## ៣. កាយវិការពាក្យសម្តី

• រឿងមិនសំខាន់ ឬមិនចាំបាច់៖ ជួនកាលអ្នកកុហកផ្តល់រឿងមិនសំខាន់ ឬមិនចាំបាច់តិចជាងមនុស្សដែលនិយាយពិត (មនុស្សដែលទុកចិត្តបាន)

• យុទ្ធវិធី ៖ ជារឿយៗ មនុស្សកុហកបង្អាក់ការផ្តល់ចម្លើយ ដើម្បីទាមទារពេលវេលាបន្ថែម នៅពេលពួកគេកំពុងផ្តល់ចម្លើយដោយការប្រឌិតឡើង ដោយប្រើប្រាស់យុទ្ធវិធី ដូចជាការសុំឱ្យអ្នកសម្ភាសសួរសំណួរឡើងវិញម្តងទៀត ។

**៤. ភាសាកាយវិការ**

• កាយវិការ ឬជំហរខ្លួន ៖ តាមធម្មតា មនុស្សកុហកនឹងបន្ថយចលនាដៃ ម្រាមដៃ និងជើង ។ កាយវិការនេះមិនធ្វើចលនាមកជិតទេ និងទំនោរទៅរកការទ្រេតដងខ្លួនចេញពីអ្នកសម្ភាស

• ចលនាកែវភ្នែក ៖ ជារឿយៗចលនាកែវភ្នែកអាចបង្ហាញឱ្យឃើញ នៅពេលបុគ្គលម្នាក់កំពុងបង្កើតចម្លើយក្លែងក្លាយ ។ ចលនាកែវភ្នែកសម្រាប់អ្នកឆ្លើយសម្ភាស គួរតែត្រូវបានបង្កើត ឡើងដោយការសួរសំណួរបើកទូទៅ

• ទីតាំង ឬចលនាដៃ ៖ ការប៉ះពាល់ជាញឹកញាប់លើផ្នែក ក ថ្ពាល់ និងក្បាល គឺជាសញ្ញានៃភាពតានតឹងខ្លាំងឡើងៗ ដែលអាចទាក់ទងនឹងការកុហក ។

**៥. ការធ្វើតេស្តរកការពិត**

ប្រសិនបើអ្នកជឿថា សាក្សី ឬជនរងគ្រោះកំពុងនិយាយកុហក មានសំណួរពីរ ឬបី ដែលអ្នកអាចប្រើប្រាស់ជាតេស្តសម្រាប់ស្វែងរកការពិត ៖

• តើខ្ញុំគួរតែជឿអ្នកឬទេ? ប្រសិនបើអ្នកឆ្លើយសម្ភាស ឆ្លើយក្នុងរបៀបក្រៅពីការបញ្ជាក់ឡើងវិញថា ពួកគេនិយាយជាការពិត អ្នកសម្ភាសគួរសង្ស័យលើពួកគេ

• តើជនល្មើសសមនឹងទទួលទណ្ឌកម្មអ្វី ចំពោះអំពើប្រព្រឹត្តបទល្មើសរបស់គេ? ប្រសិនបើអ្នកឆ្លើយសម្ភាសព្យាយាមសម្រាល ឬបន្ថយអំពើល្មើស ឬស្នើសុំដាក់ទណ្ឌកម្មតិចតួចប្លែកពីធម្មតា អ្នកសម្ភាសគួរតែសង្ស័យ ។

## V. យុទ្ធវិធីសម្ភាសការយល់ដឹង

**១. ប្រវត្តិសង្ខេប**

ការសម្ភាសនេះ គឺជាយុទ្ធវិធីមួយឈានទៅរកការសម្ភាសអត្តិភាពនៃចិត្តសាស្ត្រ ដែលបង្កើតឡើងដោយលោក RON FISCHER នៃសកលវិទ្យាល័យអន្តរជាតិហ្លរីដា និងលោក Edward Geiseman នៃសកលវិទ្យាល័យកាលីហ្វូរនីញ៉ា នៅ Los Angeles ។ ជាពិសេស វាត្រូវបានគេរៀបចំឡើងដើម្បីបង្កើនទាំងគុណភាព និងបរិមាណនៃសក្ខីកម្មរបស់សាក្សី ឬជនរងគ្រោះ ។ ការសម្ភាសនេះផ្អែកលើគោលការណ៍ ៣ ៖

• គោលការណ៍នៃការចងចាំ និងការដឹង ៖ ទាក់ទងជាមួយដំណើរការរំលឹកការចងចាំប្រកបដោយសុក្រឹតភាព "ចូរទទួលស្គាល់ថា អារម្មណ៍របស់សាក្សីមានកម្រិត ការសម្ភាសគួរតែធ្វើឡើងនៅទីកន្លែងស្ងាត់ គ្មានការរំខាន ជាពិសេសអ្នកសម្ភាសគួរតែសុំសាក្សីឱ្យយកចិត្តទុកដាក់លើការសម្ភាស" ៖

   ○ ការបង្កើតស្ថានភាពហេតុការពិត ៖ ការបង្កើតស្ថានភាពនៃព្រឹត្តិការណ៍ពិតឡើងវិញ

អាចជួយក្នុងការរំលឹកការចងចាំ

○ ការរំលឹក ៖ ការណែនាំសាក្សី ឱ្យចងចាំបានច្រើនជង និងរំលឹកភិនភាគជនសង្ស័យដោយវិធីផ្សេងៗ ។

- បច្ចេកទេសប្រាស្រ័យទាក់ទង

○ ផ្តល់សិទ្ធិឱ្យសាក្សី ៖ សាក្សីគួរតែត្រូវបានគេទទួលស្គាល់ថា ជាអ្នកជំនាញលើប្រធានបទក្នុងសំណួរ ហើយគួរតែជាអ្នកផ្តល់ចម្លើយចម្បងក្នុងការសម្ភាស ។ សាក្សីដែលយល់ពីបញ្ហានេះ នឹងអាចចូលរួមឆ្លើយយ៉ាងសកម្ម ។ អ្នកសម្ភាសគួរតែប្រើប្រាស់សំណួរបើក ហើយចៀសវាងការរំខានសាក្សីក្នុងការឆ្លើយ

○ ទំនាក់ទំនងជិតស្និទ្ធ៖ ត្រូវបានបង្កើតតាមរយៈការធ្វើសម្ភាសទៅជាលក្ខណៈបុគ្គល ហើយទំនាក់ទំនងដោយក្តីទុកចិត្ត (ការយល់ចិត្ត គឺថាប្រុងប្រយ័ត្នមិនធ្វើឱ្យសាក្សីសៅហ្មង) ។

- ដំណើរការនៃការធ្វើសម្ភាស ៖ ជាទូទៅការសម្ភាសត្រូវធ្វើតាមជំហានដូចខាងក្រោម ៖

| | |
|---|---|
| ជំហានទី ១ | ទទួលស្វាគមន៍ ហើយធ្វើឱ្យការសម្ភាសទៅជាលក្ខណៈបុគ្គល និងបង្កើតទំនាក់ទំនងជិតស្និទ្ធ |
| ជំហានទី ២ | ពន្យល់គោលបំណងសម្ភាស<br>• ការរំលឹក<br>• ផ្តល់ព័ត៌មាន<br>• ដំណើរផ្លាស់ប្តូរនៃការត្រួតពិនិត្យ<br>• គ្មានការក្លែងក្លាយ ឬការប៉ាន់ស្មាន<br>• យកចិត្តទុកដាក់ |
| ជំហានទី ៣ | ផ្តួចផ្តើមរៀបរាប់ដោយសេរី<br>• ការបង្កើតស្ថានភាពហេតុការណ៍ពិត<br>• សំណួរបើក<br>• ការផ្អាក<br>• ប្រើកាយវិការដោយស្ងៀមស្ងាត់ ដោយទឹកមុខរាក់ទាក់ |
| ជំហានទី ៤ | ការសួរសំណួរ<br>• រៀបរាប់អ្វីៗទាំងអស់<br>• សំណួរសមនឹងសមត្ថភាពរបស់អ្នកឆ្លើយសម្ភាស<br>• គ្មានចម្លើយក្លែងក្លាយ<br>• បើមិនដឹង ចូរនិយាយថា " មិនដឹង"<br>• បើមិនយល់ ចូរនិយាយថា " មិនយល់"<br>• យកចិត្តទុកដាក់<br>• សំណួរបិទនិងសំណួរបើក |

| | |
|---|---|
| ជំហានទី ៥ | ដំណើរការរំលឹក ៖ រៀបរាប់សាច់រឿងតាមលំដាប់លំដោយ |
| ជំហានទី ៦ | ការសង្ខេប |
| ជំហានទី ៧ | ការបញ្ចប់ |

## ២. ជំហាននៃការសម្ភាសខាងផ្លូវចិត្ត

### ក. ជំហានទី ១

ការចាប់ផ្តើមនៃការធ្វើសម្ភាស មានឥទ្ធិពលយ៉ាងខ្លាំងក្លាលើដំណើរការរបស់ការសម្ភាសផ្សេងទៀត ។ អ្នកសម្ភាសគួរតែណែនាំខ្លួនរបស់គេ ហើយស្វាគមន៍សាក្សី ។ សំណួរដំបូងត្រូវប្រើដើម្បីបង្កើតទំនាក់ទំនងជិតស្និទ្ធ ហើយគួរតែគ្របដណ្តប់លើប្រធានបទដែលមិនទាក់ទងទៅនឹងឧប្បត្តិហេតុភ្លាមៗទេ ។ សំណួរដំបូងអាចមានតួនាទីដើម្បីផ្តល់ឱកាសបង្កើតចំណាប់អារម្មណ៍របស់សាក្សីដើម្បីជួយអ្នកសម្ភាសអាចធ្វើឱ្យសាក្សីស៊ាំនឹងរបៀបសួរសំណួរបើក ។ សាក្សីគួរតែគិតដូចជាអ្នកសម្ភាសកំពុងទាក់ទងជាមួយពួកគេដោយលក្ខណៈផ្ទាល់ខ្លួន ហើយចៀសវាងបង្ហាញអារម្មណ៍ថាសាក្សីគ្រាន់តែជាអ្នកឆ្លើយសម្ភាសតែប៉ុណ្ណោះ ។ ទំនាក់ទំនងដោយភាពយល់ចិត្តនៅជំហាននេះក៏ជាវិធីដ៏មានប្រសិទ្ធភាពដើម្បីបង្កើតទំនាក់ទំនង ។

- ការមិនប្រើពាក្យសម្តី
    - ការញញឹម៖ បង្កើតទំនុកចិត្ត ភាពសប្បាយ សេចក្តីសាទរនិងការយល់ព្រមទទួលយក ។ ចូរប្រាកដថា ការញញឹមរបស់អ្នក គឺត្រូវមានភាពស្មោះត្រង់ ហើយគ្មានការបង្ខំ ឬក្លែងក្លាយ
    - ទំនាក់ទំនងតាមភ្នែក ៖ មើលកែវភ្នែករបស់ពួកគេនៅពេលពួកគេកំពុងនិយាយ
    - ស្វាគមន៍ ៖ ធ្វើឱ្យមានចំណាប់អារម្មណ៍ដំបូងល្អ ដោយមានទំនាក់ទំនងតាមភ្នែក
    - ជំហរខ្លួនប្រាណ ៖ មានកាយវិការដៃជើង "សមរម្យ " ហើយឱនទៅមុខបន្តិច រួចប្រាស្រ័យទាក់ទងធ្វើឱ្យកក់ក្តៅ មានភាពស្មោះត្រង់ ហើយមានភាពជាមិត្តភ័ក្តិគួររាប់អាន ។ ការងក់ក្បាលក៏អាចផ្តល់ការឯកភាព
    - ការប៉ះស្ទាប ៖ អាចចង្អុលបង្ហាញភាពសម្ងាត់ ចំណូលចិត្ត និងការបញ្ចុះបញ្ចូល កន្លែងល្អបំផុតសម្រាប់មនុស្សប្លែកម្នាក់ប៉ះស្ទាបមនុស្សផ្សេងទៀត គឺនៅត្រង់លើដើមដៃ ។ យុទ្ធវិធីនេះគួរតែប្រើប្រាស់វាដោយមានការប្រុងប្រយ័ត្ន
    - ការធ្វើត្រាប់តាម ៖ ព្យាយាមធ្វើឱ្យសម្លៀកបំពាក់របស់អ្នកស៊ីគ្នានឹងសម្លៀកបំពាក់របស់អ្នកឆ្លើយសម្ភាស អាចជួយបង្កើនការទាក់ទងជិតស្និទ្ធ ។ អ្នកសម្ភាសអាចប្រើចំណុចនេះ ដើម្បីធ្វើឱ្យអ្នកឆ្លើយសម្ភាសស្ងប់ចិត្តតាមរយៈការដកដង្ហើមយឺតៗ ។
- កាយវិការប្រើពាក្យសម្តី
    - សេចក្តីផ្តើម៖ សួស្តី...
    - ការណែនាំខ្លួន ៖ ការប្រើប្រាស់ឋានៈតួនាទីផ្លូវការ អាចបង្ហាញសេចក្តីគោរព ហើយបង្កើតការប្រាស្រ័យទាក់ទងគ្នា

- ពាក្យសម្តី៖ ពាក្យលើកទឹកចិត្ត ដូចជា ខ្ញុំយល់ សូមបន្តទៀត... អាចផ្តល់សញ្ញានៃការចាប់អារម្មណ៍ និងបង្កើតការប្រាស្រ័យទាក់ទងគ្នា
- ការស្វែងរកហេតុផលទូទៅ៖ មនុស្សមានទំនោរចូលចិត្តស្រឡាញ់មនុស្សណាដែលចូលចិត្តធ្វើអ្វីៗដូចគ្នា ។ ការប្រាប់ឱ្យដឹងពីការពិត អំពីអ្វីដែលអ្នកសម្ភាសចូលចិត្តធ្វើ ហើយបន្ទាប់មកពិភាក្សាអំពីបញ្ហាដែលអាចបង្កើតការប្រាស្រ័យទាក់ទងបានលឿន
- ល្បិច
  - ព្យាយាមប្រើសំឡេងឱ្យស៊ីគ្នានឹងល្បឿនសំឡេងរបស់អ្នកឆ្លើយសម្ភាស
  - សុំឱ្យអ្នកឆ្លើយសម្ភាសនិយាយពីព័ត៌មានកីឡា សិល្បៈ និងចំណង់ចំណូលចិត្ត
  - ជួនកាល ការបញ្ឆោរបង្កើតទំនាក់ទំនងជិតស្និទ្ធជាមួយអ្នកឆ្លើយសម្ភាស ប៉ុន្តែជានិច្ចកាល គួរតែមានភាពស្មោះត្រង់
  - ស្នើសុំអ្នកឆ្លើយសម្ភាស ដោយប្រើឃ្លាគួរសម (មិនប្រើពាក្យបញ្ជា)
  - ការនិយាយពីខ្លួនឯងខ្លះៗ អំពីព័ត៌មានដែលគ្មានការគំរាមកំហែង អាចជួយជំរុញការជឿជាក់ និង ផ្តល់សញ្ញាដល់អ្នកឆ្លើយសម្ភាស ឱ្យឆ្លើយដោយស្មោះត្រង់ពីព័ត៌មានផ្ទាល់ខ្លួន
  - នៅពេលទាក់ទងជាមួយជនរងគ្រោះ អ្នកសម្ភាសគួរតែសម្តែងសមានចិត្ត និងសេចក្តីអាណិតអំពីពេលវេលាលំបាករបស់ពួកគេ ។

- ការត្រួតពិនិត្យសម្រាប់ទំនាក់ទំនងជិតស្និទ្ធ
  - សួរសំណួរងាយៗ ៖ ដើម្បីដឹងថាតើទំនាក់ទំនងជិតស្និទ្ធត្រូវបានបង្កើតឡើងឬទេ ?
  - ការឆ្លុះបញ្ចាំង ៖ ព្យាយាមប្រើកាយវិការសមរម្យ ។ ប្រសិនបើអ្នកឆ្លើយសម្ភាសឆ្លើយតបដោយកាយវិការដូចគ្នា អ្នកមានទំនាក់ទំនងជិតស្និទ្ធ
  - កាយវិការខ្លួនប្រាណ ៖ អ្នកឆ្លើយសម្ភាស ដែលឱនដងខ្លួនទៅមុខដោយកាយវិការបើកចំហ គឺជាការផ្តល់សញ្ញានៃទំនាក់ទំនងជិតស្និទ្ធ
  - ការដកដង្ហើម៖ ការដកដង្ហើមធម្មតាហើយស្ងៀមស្ងាត់ គឺជាសញ្ញានៃទំនាក់ទំនងជិតស្និទ្ធ ។ ការដកដង្ហើមវែងៗផ្តល់សញ្ញាថាអ្នកដែលយើងសម្ភាសមិនមានអារម្មណ៍ល្អទេ
  - របាំង ៖ អ្នកឆ្លើយសម្ភាសដែលមានភាពតានតឹង និងខ្វះទំនាក់ទំនងជិតស្និទ្ធ ជារឿយៗនឹងដាក់វត្ថុអ្វីមួយនៅចន្លោះពួកគេ និងអ្នកសម្ភាស ដូចជា ដបទឹក កែវកាហ្វេ កាបូប ។ល។

### ខ. ជំហានទី ២

គោលបំណង និងដំណើរការធ្វើសម្ភាសនៃជំហាននេះ ជួយសាក្សី ឬជនរងគ្រោះឱ្យត្រៀមលក្ខណៈសម្រាប់ការធ្វើសម្ភាស ។ ជនរងគ្រោះ ឬសាក្សីត្រូវបានលើកទឹកចិត្តឱ្យផ្តោតអារម្មណ៍លើការសម្ភាស ។ អ្នកឆ្លើយសម្ភាសគួរដឹងថា ខ្លួនជាអ្នកផ្តល់ព័ត៌មាន និងគ្រប់គ្រងដំណើរការសម្ភាស ។ ការគ្រប់គ្រងដំណើរការសម្ភាស មានប្រយោជន៍ក្នុងការជួយលើកទឹកចិត្តឱ្យចូលរួមយ៉ាងសកម្មពីជនរងគ្រោះ ឬសាក្សី ។

ការណែនាំ "ឱ្យរៀបរាប់ពីអ្វីៗទាំងអស់" ស្ថិតនៅក្នុងដំណាក់កាលនេះ សាក្សី ឬជនរងគ្រោះត្រូវប្រាប់អ្នកសម្ភាសពីអ្វីៗទាំងអស់ដោយមិនគិតថាខ្លួនមានអារម្មណ៍ថា វាមិនពាក់ព័ន្ធនឹងខ្លួនជារឿងមិនសំខាន់ ឬមិនអាចចងចាំសេចក្តីលម្អិតទាំងស្រុងក៏ដោយ ។ មូលហេតុធ្វើយ៉ាងនេះគឺដោយសារថាមនុស្សចងចាំព្រឹត្តិការណ៍តាមកម្រិតផ្សេងៗគ្នា ដោយចាប់ផ្តើមឡើងពីកម្រិតទូទៅ ដែលមានសេចក្តីលម្អិតពិស្តារទូលំទូលាយ ទៅរកភាពជាក់លាក់ និងលម្អិត ។

ក្នុងបរិយាកាសសម្ភាស ជារឿយៗសាក្សី ឬជនរងគ្រោះត្រូវបានបំភិតបំភ័យ ហើយពួកគេគ្រាន់តែផ្តល់ព័ត៌មាននៃកម្រិតទូទៅ ដោយពួកគេជឿថា នគរបាលច្បាស់ជាដឹងយ៉ាងច្រើនអំពីព្រឹត្តិការណ៍ដែលបានកើតឡើងនោះ ហើយអ្នកឆ្លើយសម្ភាសមិនចង់ឱ្យគេគិតថា ពេលវេលារបស់នគរបាលត្រូវបានខាតបង់ទេ ឬពួកគេជឿថា នគរបាលដឹងថាអង្គហេតុណាសំខាន់ និងមិនសំខាន់ ។

ការផ្តល់សេចក្តីណែនាំដល់អ្នកឆ្លើយសម្ភាស ដើម្បីលើកទឹកចិត្តពួកគេឆ្លើយសំណួរឱ្យបានពេញលេញតាមលទ្ធភាពដែលអាចធ្វើទៅបាន ។ រាល់ដំណាក់កាលនៃការសម្ភាស វាសំខាន់ណាស់សម្រាប់អ្នកឆ្លើយសម្ភាសយល់ថា បើខ្លួនមិនដឹងសូមឆ្លើយថាមិនដឹង ។ នៅដំណាក់កាលនេះ អ្នកសម្ភាសគួរតែពន្យល់សាក្សីថា ខ្លួនពេញចិត្តខ្លាំងចំពោះចម្លើយថា ខ្ញុំមិនដឹង ជាងចម្លើយដោយការស្មាន ឬចម្លើយភូតកុហក ។

**គ. ជំហានទី ៣**

គេប្រើបច្ចេកទេសបង្កើតហេតុការណ៍ពិតឡើងវិញ ដោយទាក់ទងទៅនឹងប្រភេទសំណួរបើក ដើម្បីស្វែងរកព័ត៌មានឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន ។ ការណែនាំពី "ការដែលធ្វើឱ្យចងចាំហេតុការណ៍ពិតឡើងវិញ " គឺព្យាយាមធ្វើឱ្យជនរងគ្រោះ ឬសាក្សីនឹកទៅរកព្រឹត្តិការណ៍នោះ ដែលពួកគេកំពុងតែព្យាយាមចងចាំ ។ វាបង្កើតឡើងដោយការសួរសំណួរតាមលំដាប់លំដោយ ។

ឧទាហរណ៍ ៖ ក្នុងការប្លន់ធនាគារមួយ អ្នកសម្ភាសអាចសួរ ៖

- ចូររំលឹកពេលដែលអ្នកនៅធនាគារ
- ចូរស្រមៃថាអ្នកនៅកន្លែងណាក្នុងធនាគារ ?
- ពេលនោះអ្នកគិតយ៉ាងដូចម្តេច ?
- តើអ្នកបានឮអ្វី ?
- ចូរអ្នកគិតអំពីវត្ថុទាំងឡាយនៅក្នុងធនាគារ ?

អ្នកសម្ភាសត្រូវទុកពេលវេលាឱ្យបានច្រើន សម្រាប់ឱ្យអ្នកឆ្លើយសម្ភាសឆ្លើយសំណួរ ។ អ្នកសម្ភាសជួយពួកគេឱ្យរំលឹកការចងចាំឡើងវិញ ដោយធ្វើឱ្យអ្នកឆ្លើយសម្ភាសនឹកគិតពីហេតុការណ៍ពិតនៃព្រឹត្តិការណ៍ឡើងវិញ ។

**ឃ. ជំហានទី ៤**

ជំហាននេះដកចេញពីប្រភេទសំណួរបើក ដើម្បីឈានទៅរកសំណួរបិទ ក្នុងកិច្ចខិតខំដើម្បីប្រមូលព័ត៌មានសំខាន់ៗដែលបាត់បង់ ។ គ្រប់វិធានបានពន្យល់ខាងដើម គួរតែត្រូវបានបញ្ជាក់ឡើងវិញនៅត្រង់ចំណុចនេះ ជាពិសេស "ការរៀបរាប់ពីអ្វីៗទាំងអស់" និង "ការណែនាំដែលថា មិនអី

ទេទោះជាអ្នកមិនដឹងក៏ដោយ" ។ សំណួរនៅក្នុងជំហាននេះ គួរផ្ដោតទៅលើអ្វីដែលអ្នកឆ្លើយសម្ភាស បាននិយាយរួចរាល់នៅក្នុងជំហានទី ២ និងជំហានទី ៣ ។

ប្រភេទដូចគ្នានៃបច្ចេកទេសស្រមៃក្នុងចិត្ត ត្រូវបានប្រើប្រាស់នៅត្រង់ចំណុចនេះ ដែលទាក់ទងជាមួយនឹងសំណួរសំខាន់ទាំងនេះ ។

**ង. ជំហានទី ៥**

ជំហាននេះត្រូវបានត្រួតពិនិត្យឡើងវិញ ជាកិច្ចខិតខំចុងក្រោយក្នុងការស្វែងរកព័ត៌មានពីសាក្សីតាមលទ្ធភាពដែលអាចធ្វើបាន ដោយប្រើបច្ចេកទេសរំលឹកព័ត៌មានឡើងវិញ ដូចជា ការផ្លាស់ប្ដូរលំដាប់នៃពេលវេលា ឬការរំលឹកព្រឹត្តិការណ៍ឡើងវិញពីសាក្សីដទៃទៀត ។

ការរំលឹកឡើងវិញក្នុងការណែនាំតាមលំដាប់លំដោយផ្សេងៗ ៖

- អ្នកឆ្លើយសម្ភាសអាចនឹកឃើញព្រឹត្តិការណ៍តាមលំដាប់លំដោយ ។ នៅពេលរំលឹកព្រឹត្តិការណ៍ឡើងវិញតាមលំដាប់លំដោយ ការសម្ភាសនឹងពឹងផ្អែកលើមធ្យោបាយដូចជា ព័ត៌មានរំលឹក ឬលំនាំ (ដែលបានរៀបរាប់ពីមុន) ដើម្បីជួយដល់ការរំលឹក។
- ការស្នើសុំឱ្យអ្នកឆ្លើយសម្ភាស រំលឹកថយក្រោយពីព្រឹត្តិការណ៍ឡើងវិញ គឺដូចជាបង្ខំឱ្យពួកគេពឹងផ្អែកទៅលើការចងចាំជាក់ស្ដែងរបស់ខ្លួន ។

បច្ចេកទេសរំលឹកអត្តសញ្ញាណ ៖ ការណែនាំនេះគឺស្នើសុំសាក្សីឱ្យរៀបរាប់ឡើងវិញពីព្រឹត្តិការណ៍ពីការនឹកឃើញដល់បុគ្គលណាម្នាក់ ។ តាមធម្មតា បញ្ហានេះទទួលបានជោគជ័យបាន លុះត្រាតែបុគ្គលនោះមានវត្តមាននៅចំពោះមុខពួកគេ ។ សាក្សីគួរតែត្រូវបានប្រាប់យ៉ាងច្បាស់លាស់ថាមិនឱ្យឆ្លើយស្មាននោះទេ ។

**ច. ជំហានទី ៦**

អ្នកសម្ភាសគួរតែនិយាយសារឡើងវិញពីសក្ខីកម្មរបស់សាក្សី ដែលនេះជាវិធីមួយនៃការបញ្ជាក់អះអាងឡើងវិញពីសុក្រឹតភាពនៃសក្ខីកម្ម ។ សាក្សីប្រហែលអាចចងចាំព័ត៌មានបន្ថែមទៀតដោយសារដំណើរការនេះ ហើយគួរប្រាប់សាក្សីថា ពួកគេអាចបន្ថែមព័ត៌មានថ្មីទៀតបាន ពេលដែលពួកគេនឹកឃើញ ។

**ឆ. ជំហានទី ៧**

អ្នកសម្ភាស គួរធ្វើឱ្យការសម្ភាសវិលត្រឡប់ទៅរកប្រធានបទនៃការសន្ទនាមិនពាក់ព័ន្ធដែលត្រូវបានប្រើដើម្បីបង្កើតទំនាក់ទំនងស្និទ្ធស្នាលនៅក្នុងជំហានទី១ ។ អ្នកសម្ភាសគួរឆ្លើយសំណួររបស់សាក្សី ឬជនរងគ្រោះ ។

ព័ត៌មានសម្រាប់ទាក់ទងនឹងអ្នកសម្ភាស គួរត្រូវបានផ្ដល់ជូនសាក្សី ក្នុងករណីសាក្សីចងចាំព័ត៌មានបន្ថែមទៀត ក្រោយពីការសម្ភាស ។ តាមធម្មតា អ្នកសម្ភាសត្រូវថ្លែងអំណរគុណដល់សាក្សី ឬជនរងគ្រោះចំពោះការសហការរបស់ពួកគេ ហើយបើអាចធ្វើបាន ត្រូវធ្វើពួកគេមានចិត្តសប្បាយ ។

តាមរយៈការត្រួតពិនិត្យនៃប្រភេទសំណួរ និងបច្ចេកទេសសម្ភាស វាច្បាស់ណាស់ដែលការសួរសាក្សី ឬជនរងគ្រោះ ប៉ះពាល់ដល់សុក្រឹតភាព ។

### ៣. ការលម្អៀងដោយអ្នកសម្ភាស

មានបញ្ហាដូចគ្នាជាច្រើន ដែលធ្វើឱ្យប៉ះពាល់ដល់ការចងចាំរបស់អ្នកឆ្លើយសម្ភាស ហើយអាចប៉ះពាល់អ្នកសម្ភាសផងដែរ ៖

- គំនិត ឬទ្រឹស្ដីដឹងមុនអំពីអ្វីដែល "ពិតជា" បានកើតឡើង អាចបន្ថយការយកចិត្តទុកដាក់របស់អ្នកសម្ភាស ចំពោះការរៀបរាប់ពិស្ដារទាំងអស់ ហើយបង្កើនការស្ដាប់
- អង្គហេតុ និងគន្លឹះសំខាន់ៗជាច្រើនអាចត្រូវបានបាត់បង់ ។ ការសម្ភាសពីមុន ឬបទពិសោធន៍នៃការអនុវត្តច្បាប់បានធ្វើឱ្យអ្នកសម្ភាសមានការធុញទ្រាន់
- ការព្យាយាមធ្វើឱ្យចម្លើយរបស់អ្នកឆ្លើយសម្ភាសមានលក្ខណៈ"ស្តង់ដា" ដើម្បីលប់បំបាត់ការខ្វែងគំនិត ឬធ្វើឱ្យរឹងមាំសម្រាប់ការជម្រះក្ដី អាចធ្វើឱ្យខូចដល់សក្ខីកម្មរបស់សាក្សីឬជនរងគ្រោះ ។

## VI. កង្វះសមត្ថភាពយល់ដឹង (កុមារ)

### ១. ការពិត និង ការកុហក

- កុមារមានការកំណត់និយមន័យចំពោះអ្វីជាការពិត ផ្សេងៗពីមនុស្សពេញវ័យ
- ជាទូទៅ កុមារមានភាពខ្វះចន្លោះផ្សេងៗ រវាងការពិត និងការកុហក
- ការយល់ដឹងពីការពិតរបស់កុមារ កើតឡើងយឺតៗ ៖
  - ចាប់ផ្ដើមឡើងដោយការកំណត់គោលបំណងនៃអង្គហេតុ និងការប្រឌិត
  - ក្រោយមក កត្តាដូចជា ចេតនានៃអ្នកកុហក និងទឹកចិត្តដែលទាក់ទងនឹងការកុហកត្រូវបានបង្កើតឡើង ។

### ២. ចេតនា និងទស្សនៈវិស័យ

- ជាទម្លាប់ កុមារមិនអាចយល់ពីបញ្ហាទាក់ទងនឹងចេតនារបស់មនុស្សម្នាក់ៗបានទេ
- ការឆ្លើយសំណួរបែបនេះ ទាមទារការយល់ដឹងពីលក្ខណៈចិត្តសាស្ត្រ ដែលបញ្ជាក់ពីអាកប្បកិរិយារបស់ពួកគេដែលមិនទាន់វិវត្ត
- ជាធម្មតា ការឆ្លើយសំណួរបែបនេះ កុមារនឹងបញ្ចេញអារម្មណ៍ និងបំណងរបស់ខ្លួនយ៉ាងសាមញ្ញលើបុគ្គលម្នាក់ៗ ។

### ៣. សំណួរសម្មតិកម្ម (សំណួរប៉ាន់ស្មាន)

- តើមានអ្វីកើតឡើង ប្រសិនបើម្ដាយរបស់អ្នកមិនបានចេញពីទីក្រុងនៅចុងសប្ដាហ៍មុន ?
- កុមារតូចៗភាគច្រើន មិនមានសមត្ថភាពឈានទៅរកមូលហេតុអរូបីយ ដែលចាំបាច់បញ្ចូលព័ត៌មានថ្មីនេះទៅក្នុងដំណើររឿងនោះទេ
- កុមារអាចឆ្លើយបដិសេធចំពោះសំណួរ "តើមានអ្វីកើតឡើង ប្រសិនបើ..." ។

### ៤. មនុស្សពេញវ័យ

- កុមារតូចៗស្មានថា មនុស្សពេញវ័យដឹងពីអ្វីៗដែលបានកើតឡើងចំពោះពួកគេ
- ជាលទ្ធផល ពួកគេនឹងមិនប្រាប់ពីសេចក្ដីលម្អិតសំខាន់ៗ ហើយអាចតម្រូវឱ្យអ្នកសម្ភាស

ប្រើប្រាស់សំណួរដាក់លាក់ថែមទៀត

- ការប្រាប់កុមារយ៉ាងសាមញ្ញថា អ្នកសម្ភាសមិនបានដឹងពីអ្វីៗដែលបានកើតឡើងនោះទេ អាចយកឈ្នះលើបញ្ហានេះបាន ។

### ៥. ភាពអវិជ្ជមាន

- ជាញឹកញាប់ កុមារមិនដឹងថា ខ្លួនមិនដឹងអ្វីនោះទេ
- ពួកគេស្មានថា ខ្លួនដឹងចម្លើយត្រឹមត្រូវចំពោះសំណួរដែលសួរទៅពួកគេ
- វាមានសារៈសំខាន់ចំពោះអ្នកសម្ភាសក្នុងការត្រួតពិនិត្យការយល់ដឹងរបស់កុមារ ។

### ៦. សមត្ថភាពគណនាចំនួន

- កុមារមានការលំបាកក្នុងការគិតពីពេលវេលា ភាពញឹកញាប់ កាលបរិច្ឆេទ អាយុ...
- ជាទម្លាប់ ចំនួនលេខកាន់តែច្រើន ការលំបាកកាន់តែខ្លាំង
- ប្រភេទនៃការគិតទាំងនេះគួរតែត្រូវចៀសវាង ប្រសិនបើអាចធ្វើទៅបាន ។

## VII. ការសម្ភាសកុមារ

### ១. គោលបំណង

- ស្វែងយល់រាល់អ្វីៗដែលកុមារបានដឹងអំពីបទល្មើស
- កំណត់ថាតើកុមារគឺជាសាក្សីគួរឱ្យជឿជាក់ និងទុកចិត្តបាន
- កំណត់ថាតើកុមារដឹងអំពីសាក្សីផ្សេងទៀត អំពីទីកន្លែងនៃភស្តុតាងឬទេ?

### ២. រឿងដែលត្រូវចងចាំ

- អ្នកសម្ភាសចាំបាច់ធ្វើឱ្យប្រាកដថា សុខមាលភាពផ្នែកចិត្តសាស្ត្រ រាងកាយ និងអារម្មណ៍ រំជើបរំជួលរបស់កុមារត្រូវបានគាំពារ
- អ្នកសម្ភាសគួរព្យាយាមធ្វើឱ្យមានការប៉ះទង្គិចផ្លូវចិត្តតិចបំផុតចំពោះកុមារ
- បញ្ហាទាំងនេះ គួរសម្រេចបាននៅពេលចម្រាញ់យកព័ត៌មានគ្រប់គ្រាន់ ដើម្បីធ្វើឱ្យរឿងក្តីមានប្រសិទ្ធភាព ។

### ៣. សំណួរបើក និង បិទ

- កុមារកាន់តែតូច កាន់តែផ្តល់ព័ត៌មានតិច ក្នុងបរិយាកាសនៃការនឹកឃើញដោយសេរី
- សំណួរបែបដាក់លាក់ ឬបិទ ចាំបាច់ត្រូវប្រើ ដើម្បីចម្រាញ់យកព័ត៌មានលម្អិតពីកុមារ ហើយជារឿយៗ វាបង្កើននូវភាពមិនសុក្រឹតនៃព័ត៌មានដោយសារ ៖
    - ប្រភេទសំណួរនេះទំនងជាបង្ខំកុមារយកចិត្តទុកដាក់លើព័ត៌មានដែលមិនត្រូវបានដាក់ថតទុកនៅក្នុងខួរក្បាល
    - តាមពិតជារឿយៗ មនុស្សព្យាយាមឆ្លើយសំណួរដែលសួរពួកគេ ។

### ៤. ការសួរសំណួរឡើងវិញ ឬការនិទានរឿងឡើងវិញ

- សាក្សី ឬជនរងគ្រោះជាកុមារត្រូវបានគេសម្ភាសម្តងហើយម្តងទៀត ដោយមន្ត្រីអនុវត្តច្បាប់ មន្ត្រីតុលាការ បុគ្គលិកសង្គមកិច្ច និងបុគ្គលិកអង្គការសង្គមស៊ីវិលផ្សេងៗគ្នា
- ចំពោះបញ្ហានេះ មានទាំងគុណសម្បត្តិ និងគុណវិបត្តិ
  - គុណសម្បត្តិ
    - ជារឿយៗ កុមារនឹងរៀបរាប់ពីសាច់រឿងមានភាពពិស្តារខុសគ្នាតិចតួច ចំពោះសំណួរបើកដូចគ្នា ដូច្នេះវាបន្ថែមព័ត៌មានមួយចំនួនសម្រាប់អ្នកសម្ភាសពិចារណា
    - ដំណើរការនៃការនិយាយឡើងវិញពីព្រឹត្តិការណ៍ដដែលៗ ក្នុងទម្រង់ជាសាច់រឿង ជួយដល់ដំណើរការចងចាំមិនឱ្យចុះខ្សោយ
    - ចម្លើយនៃសំណួរធ្វើឡើងដដែលៗ បង្រៀនកុមារឱ្យចេះឆ្លើយពេញលេញជាងនេះ ជាបច្ចេកទេសចាំបាច់សម្រាប់នគរបាល និងដំណើរការជម្រះក្តីរបស់តុលាការ ។
  - គុណវិបត្តិ
    - កុមារអាចជឿថា ពួកគេផ្តល់ចម្លើយខុសនៅពេលដំបូងក្នុងការឆ្លើយសំណួរ ដូច្នេះ វាជំរុញឱ្យកុមារព្យាយាម និងកែចម្លើយឡើងវិញ
    - កុមារអាចស្មានចម្លើយដែលពួកគេមិនដឹង
    - ការគំរាមកំហែង ធ្វើឱ្យកុមាររងគ្រោះឡើងវិញ ។

### ៥. ការនាំឱ្យកុមារយល់ខុស

- កុមារអាយុកាន់តែតិច កាន់តែបើកចិត្តស្តាប់ការទូន្មានកាន់តែច្រើន
- ប៉ុន្តែកុមារមានប្រតិកម្មគួរឱ្យភ្ញាក់ផ្អើលចំពោះការទូន្មាន ដែលទាក់ទងនឹងព្រឹត្តិការណ៍ដែលកើតឡើងចំពោះខ្លួនគេផ្ទាល់ ទោះបីពួកគេនៅតែអង់អាចក្នុងការទទួលកំហុសក៏ដោយ
- កុមារដែលទទួលរងឥទ្ធិពលភាគច្រើន អាចត្រូវបានសៅហ្មង ដោយសំណួរប្រភេទជាក់លាក់ ឬសំណួរបិទ
- កត្តាដែលធ្វើឱ្យការចងចាំខ្សោយ ដូចជាការពន្យាពេលរវាងព្រឹត្តិការណ៍កើតឡើង និងការធ្វើសម្ភាស ការសួរសំណួរលើព័ត៌មានដែលបង្ហាញឱ្យឃើញតិចតួច
- ភាពលម្អៀងរបស់អ្នកសម្ភាស ជារឿយៗធ្វើឱ្យខូចដល់សក្ខីកម្មរបស់កុមារ
- អ្នកសម្ភាសប្រើសំឡេងដែលបង្ហាញការចោទប្រកាន់អាចទទួលបានព័ត៌មានក្លែងក្លាយ ។

### ៦. គោលការណ៍ ៥ យ៉ាងសម្រាប់សម្ភាសន៍កុមារ

- កុមារគួរតែត្រូវបានសម្ភាសឱ្យបានកាន់តែឆាប់កាន់តែល្អ បន្ទាប់ពីហេតុការណ៍កើតឡើង។ ផ្អែកលើការយល់ដឹងទូទៅ និងការស្រាវជ្រាវបង្ហាញថា ការពន្យារពេលកាន់តែយូរ រវាងព្រឹត្តការណ៍កើតឡើង និងការធ្វើសម្ភាស បរិមាណនិងគុណភាពនៃសក្ខីកម្មរបស់សាក្សី ឬជនរងគ្រោះកាន់តែមិនល្អ
- កុមារត្រូវរៀនចូលរួមក្នុងការធ្វើសម្ភាស ហើយគួរតែត្រូវបានអនុញ្ញាត ឱ្យស៊ាំទៅនឹងស្ថានភាពនេះ ។ ទំនាក់ទំនងជិតស្និទ្ធ និងវិធានសម្រាប់ដំណើរការសម្ភាសគួរតែត្រូវបានបង្កើតឡើង

- កុមារមិនមែនជាអ្នកជំនាញខាងការសន្ទនាទេ ហើយជាធម្មតា ពួកគេមិនបានយល់ដឹងពីដំណើរការសម្ភាសដែលទាក់ទងទៅនឹងច្បាប់
- វាជាការច្បាស់ណាស់ ដែលត្រូវតែមាននូវការប្រឹងប្រែងខាងការយល់ដឹង និងភាសា ព្រមទាំងតម្រូវការធ្វើឱ្យកុមារស៊ាំនឹងបរិយាកាសសម្ភាសទៀតផង ។

• អ្នកសម្ភាសគួរតែប្រើសំណួរបើក ហើយឆ្ពោះទៅរកសំណួរជាក់លាក់ ។ យុទ្ធវិធីនៃការចម្រាញ់យកព័ត៌មានឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន ដោយប្រើសំណួរបើកប្រកបដោយភាពសុក្រឹត ហើយបន្ទាប់មកប្រមូលព័ត៌មានលម្អិតដោយសួរសំណួរជាក់លាក់ ឬសំណួរបិទ

• អ្នកសម្ភាសគួរតែរក្សានូវអព្យាក្រឹតភាព
  - កុមារឆាប់យល់ដោយអារម្មណ៍ ហើយនិងដឹងអំពីភាពលម្អៀងរបស់អ្នកសម្ភាស
  - តាមធម្មតា ដោយសារកុមារព្យាយាមបំពេញចិត្តមនុស្សពេញវ័យ ភាពលម្អៀងដែលកុមារបានដឹងនឹងធ្វើឱ្យខូចដល់បន្ទាល់របស់កុមារ ។

• អ្នកសម្ភាសគួរតែបញ្ចប់ការសម្ភាស
  - ការបញ្ជាក់ពីព័ត៌មានដែលត្រូវបានរាយការណ៍
  - ប្រាប់ពីរបៀបដែលអាចទាក់ទងអ្នកសម្ភាសនៅពេលក្រោយ ប្រសិនបើមានព័ត៌មានលម្អិតដទៃទៀតត្រូវបន្ថែម
  - ការសន្ទនាដែលមានភាពអព្យាក្រឹតអាចធ្វើឱ្យការសម្ភាសបានសម្រេចលទ្ធផលល្អ ។

**៧. ការរៀបចំការសម្ភាសជាមុន**

• ព័ត៌មានសាវតារ
  - ឈ្មោះកុមារ
  - ស្ថានភាពផ្លូវកាយ និងផ្លូវចិត្ត
  - មនុស្សសំខាន់ដែលកុមារបានទាក់ទង និងឈ្មោះពួកគេដែលកុមារហៅ
  - ទម្លាប់ប្រចាំថ្ងៃរបស់កុមារ
  - អត្តសញ្ញាណរបស់ជនសង្ស័យ
  - ទំនាក់ទំនង និងប្រវត្តិរបស់ជនសង្ស័យជាមួយកុមារ
  - អត្តសញ្ញាណរបស់សាក្សីផ្សេងទៀត
  - អត្ថិភាពនៃរូបភស្តុតាង
  - ព័ត៌មានលម្អិតអំពីគ្រួសាររបស់កុមារ
  - ព័ត៌មានពីការសម្ភាសផ្លូវការ ឬមិនផ្លូវការ
  - តើកុមារចង់ឱ្យអ្វីកើតឡើង ?
  - តើកុមារកំពុងវិវត្ត ឬមានបញ្ហាខាងអាកប្បកិរិយា ?

• ទីតាំងសម្ភាស
  - ទីកន្លែងមានផាសុខភាព

- ទីកន្លែងដែលកុមារគិតថាមានផាសុខភាព
- ទីកន្លែងអព្យាក្រឹត
- ទីកន្លែងឯកជនដោយគ្មានការរំខាន និងការធ្វើឱ្យបែកអារម្មណ៍ ។

## VIII. ការសម្ភាសតាមដំណាក់កាល

### ១. ការសម្ភាសផ្លូវចិត្តឱ្យស្របគ្នា

- ផ្តោតលើទំនាក់ទំនងជិតស្និទ្ធ
- អនុញ្ញាតឱ្យសាក្សី ឬជនរងគ្រោះគ្រប់គ្រងដំណើរការសម្ភាស
- ប្រើសំណួរបើក
- លើកទឹកចិត្តឱ្យមានកិច្ចខិតខំក្នុងការរំលឹកព័ត៌មាន ។

### ២. ការសម្ភាសតាមលំដាប់លំដោយ

- យុទ្ធវិធីនេះធ្វើឱ្យសម្រេចគោលបំណងសំខាន់ៗជាច្រើន
- ធ្វើឱ្យមានការប៉ះទង្គិចផ្លូវចិត្តតិចបំផុតដល់សាក្សី ឬជនរងគ្រោះ ដោយការបង្កើនសមត្ថភាពអ្នកសម្ភាស ហើយបន្ថយតម្រូវការសម្ភាសច្រើនដង
- កាត់បន្ថយជាអតិបរិមាក្នុងការធ្វើឱ្យខូចសក្ខីកម្ម ដោយប្រើការអង្កេតមើល ដោយមិនចាំបាច់ទូន្មាន
- ធ្វើឱ្យការរំលឹកឡើងវិញមានកម្រិតខ្ពស់បំផុត ដោយប្រើបច្ចេកទេសសម្ភាសការយល់ដឹង
- រក្សាសេចក្តីសុចរិតនៃការស៊ើបអង្កេត ដោយជំរុញឱ្យមានការសម្របសម្រួល និងបត់បែនដែលជួយអ្នកសម្ភាសឱ្យអនុវត្តយុទ្ធសាស្ត្រសម្ភាសតាមរយៈរឿងក្តីជាច្រើន
- បង្កើនភាពសុក្រឹត និងភាពទាក់ទងនៃព័ត៌មាន
- ផ្តល់ឱ្យកុមារ នូវឱកាសក្នុងការនិយាយរឿងនិទានដោយសេរីមុនគេ ដោយប្រើសំណួរតិចតួច តែមានប្រសិទ្ធភាពដោយសួរសំណួរជាក់លាក់ជាបន្តបន្ទាប់ ។

### ៣. លក្ខណៈវិនិច្ឆ័យបរិយាកាសបន្ទប់សម្ភាស

- បន្ទប់ស្ងាត់ដែលមិនធ្វើឱ្យបែកអារម្មណ៍ ឬការរំខាន
- ឧបករណ៍ជំនួយការសម្ភាស គួរតែលាក់កុំឱ្យមើលឃើញ រហូតដល់ត្រូវការចាំបាច់
- គ្រឿងសង្ហារឹមគួរតែមានផាសុខភាព និងទំហំសមរម្យ
- មានប្រព័ន្ធថតសំឡេង ថតវីដេអូ ដែលត្រូវបង្ហាញ និងពន្យល់ដល់កុមារមុនពេលដំណើរការចាប់ផ្តើមធ្វើសម្ភាសន៍
- គួរតែកុំឱ្យមានវត្ថុស្ថិតនៅចន្លោះរវាង អ្នកសម្ភាស និងកុមារ ដូចជា កៅអី... ។

### ៤. ជំហានទាំងប្រាំបួននៃការសម្ភាសកុមារ

- ជំហានទី ១ ៖ ទំនាក់ទំនងជិតស្និទ្ធ
  - ការណែនាំដើម្បីធ្វើទំនាក់ទំនងជិតស្និទ្ធជាមួយកុមារដូចគ្នានឹងការណែនាំ ដើម្បីធ្វើ

ទំនាក់ទំនងជិតស្និទ្ធជាមួយមនុស្សពេញវ័យដែរ

- ការសួរសំណួរផ្តួចផ្តើមដំបូង ដែលប្រើដើម្បីធ្វើទំនាក់ទំនងជិតស្និទ្ធ គួរតែសួរពីប្រធានបទអព្យាក្រឹតដែលមិនពាក់ព័ន្ធនឹងហេតុការណ៍
- សំណួរទាំងនេះអាចដើរតួនាទីច្រើនយ៉ាង ជាឱកាសមួយដើម្បីបង្កើតចំណាប់អារម្មណ៍របស់កុមារ ដែលអាចជួយអ្នកសម្ភាសតាមរយៈការជួបប្រទះ និងការវាយតម្លៃកុមារ ព្រមទាំងធ្វើឱ្យកុមារស៊ាំទៅនឹងរបៀបសំណួរបើក ។

• ជំហានទី២ ៖ ការស្នើសុំឱ្យរំលឹកឡើងវិញ

- ការសុំឱ្យកុមាររំលឹកឡើងវិញពីព្រឹត្តិការណ៍ពីរមិនពាក់ព័ន្ធ( ឧទាហរណ៍៖ ពីពិធីជប់លៀងថ្ងៃខួបកំណើត ឬការធ្វើដំណើរទៅហាងទិញរបស់របរចុងក្រោយរបស់ពួកគេ ) ធ្វើឱ្យអ្នកសម្ភាសមានឱកាសវាយតម្លៃគុណភាព និងបរិមាណនៃព័ត៌មានដែលកុមារអាចផ្តល់ឱ្យ
- ជួយឱ្យកុមារស៊ាំទៅនឹងបរិយាកាសសម្ភាស និងរបៀបនៃការសួរសំណួរ ។

• ជំហានទី ៣ ៖ គ្មានអ្វីក្រៅពីសច្ចភាព

- ស្ថិតនៅក្នុងដំណើរការឈ្លាសវៃដោយខ្លួនឯង
- អ្នកសម្ភាសចាប់ផ្តើមដោយសំណួរទូទៅអំពីអ្វីដែលជាការពិត ដើម្បីបង្កើតកម្រិតយល់ដឹងរបស់កុមារ
  - នៅពេលអ្នកសម្ភាសអាចកំណត់ថា កុមារយល់ពីអ្វីជាការពិតហើយ គាត់ចាប់ផ្តើមសួរកុមារអំពីសារប្រយោជន៍នៃការប្រាប់ការពិត និងផលវិបាកនៃការកុហក
  - នៅពេលដែលគំនិតទាំងនេះត្រូវបានយល់ហើយ បន្ទាប់មក អ្នកសម្ភាសយល់ព្រមឱ្យកុមារប្រាប់តែការពិតប៉ុណ្ណោះ ទោះការពិតនោះជាអ្វីក៏ដោយ ។

• ជំហានទី ៤ ៖ ការណែនាំពីប្រធានបទ

- នេះគឺជាជំហានដំណើរការសម្ភាសម្តងទៀត
- អ្នកសម្ភាសចាប់ផ្តើមឡើងដោយសំណួរបើកទូទៅ
- នេះគឺជាកិច្ចខិតខំស្វែងរកប្រធានបទ តាមរយៈការសន្ទនាដោយរង់ចាំកុមារបញ្ចេញគំនិត ដើម្បីឈានទៅរកការសួរសំណួរគោលដៅ
- ប្រសិនបើបន្ទាប់ពីសួរសំណួរទាំងនេះហើយ កុមារនៅតែមិនយកប្រធានបទមកនិយាយ អ្នកសម្ភាសអាចសុំកុមារឱ្យគូររូបនរណាម្នាក់ ហើយដាក់ផ្លាកសញ្ញា និងពិភាក្សាពីផ្នែករាងកាយរបស់ពួកគេ ។

• ជំហានទី ៥ ៖ ការជំរុញទឹកចិត្តឱ្យរៀបរាប់ដោយសេរី

- នៅពេលដែលប្រធានបទត្រូវបានយកមកនិយាយហើយ ត្រូវស្នើសុំឱ្យកុមាររៀបរាប់ពីប្រធានបទនោះ តាំងពីដើមរហូតដល់ចប់ ដោយគ្មានការកាត់អ្វីមួយចោល
- នេះស្រដៀងទៅនិងការណែនាំ "ឱ្យរៀបរាប់ពីអ្វីៗទាំងអស់" នៅក្នុងការសម្ភាស
- នៅដំណាក់កាលនេះ អ្នកសម្ភាសមិនត្រូវបកស្រាយ កែតម្រូវ ឬប្រកែកយកឈ្នះ

លើអ្វីៗដែលកុមារនិយាយនោះទេ

- ត្រូវអនុញ្ញាតឱ្យកុមារប្រាប់ដំណើររឿងតាមលំដាប់លំដោយរបស់ខ្លួន
- ប្រសិនបើកុមារត្រូវបានធ្វើបាបម្តងហើយម្តងទៀត អ្នកសម្ភាសអាចព្យាយាមទាញយកព័ត៌មានលំនាំរបស់កុមារពីព្រឹត្តការណ៍ទាំងនោះ ដោយសួរសំណួរដូចជា "តើអ្នកអាចប្រាប់ខ្ញុំបានទេ នូវអ្វីដែលបានកើតឡើង?"

• ជំហានទី៦ ៖ ការប្រើប្រាស់សំណួរបើក

- គួរតែសួរសំណួរបើក ដើម្បីបញ្ជាក់ឡើងវិញ ឬចម្រាញ់យកព័ត៌មានបន្ថែមទៀត លើប្រធានបទដែលកុមារប្រាប់នៅក្នុងការរៀបរាប់សាច់រឿងដោយសេរី
- ការធ្វើដូចនេះ គឺដើម្បីចាប់ផ្តើមបំពេញភាពចន្លោះនៅក្នុងសាច់រឿងរបស់កុមារ ដែលខ្វះខាតនៅក្នុងការសន្ទនា ។

• ជំហានទី ៧ ៖ សំណួរជាក់លាក់

- ត្រូវប្រើ ប្រសិនបើត្រូវការព័ត៌មានបន្ថែម បន្ទាប់ពីការរៀបរាប់ដោយសេរី និងសំណួរបើកត្រូវបានគេប្រើហើយ
- អាចប្រើការណែនាំសម្ភាស សម្រាប់ការផ្លាស់ប្តូរលំដាប់លំដោយនៃពេលវេលា ឬការរំលឹកតាមកាលៈទេសៈ
- ត្រូវបានប្រើសម្រាប់អះអាងបញ្ជាក់លើភាពមិនច្បាស់លាស់ ក្នុងការរៀបរាប់សាច់រឿងរបស់កុមារ ។

• ជំហានទី ៨ ៖ ឧបករណ៍ជំនួយការសម្ភាស

- ប្រសិនបើព័ត៌មានបន្ថែមនៅតែចាំបាច់ បន្ទាប់ពីជំហានទី ៧ ត្រូវបានប្រើ អ្នកសម្ភាសអាចប្រើឧបករណ៍ជំនួយសម្ភាសដូចជា កូនតុក្កតាសរីរាង្គសាស្ត្រ ឬការសម្ភាសប្រើរូបគំនូរ
    - ▪ កូនតុក្កតាសរីរាង្គសាស្ត្រ
        - កូនតុក្កតាសរីរាង្គសាស្ត្រ មានអវៈយវៈទាំងអស់ដូចមនុស្សពិតដែរ រួមមាន អង្គជាតិ និងរន្ធទ្វារមាស
        - វាមានរូបរាងស្រដៀងគ្នា ដើម្បីឱ្យកុមារចាប់អារម្មណ៍ជាងការនិយាយប្រាប់
        - កូនតុក្កតានេះអាចពង្រឹងទំនាក់ទំនងជិតស្និទ្ធ
        - វាអាចកាត់បន្ថយកម្រិតតានតឹងរបស់កុមារ
        - ដោយបង្ហាញនិងមិននិយាយ កូនតុក្កតាអាចជួយដល់កង្វះខាតខាងវាក្យស័ព្ទរបស់កុមារ
        - រាងកាយរបស់កូនតុក្កតា អាចដើរតួនាទីជាអ្នកជំរុញដល់ដំណើរការគិតដើម្បីឱ្យកុមារនឹកឃើញហេតុការណ៍បន្ថែមទៀត
        - ចំពោះកុមារមួយចំនួន ងាយស្រួលក្នុងការបង្ហាញពីអ្វីដែលបានកើតឡើងចំពោះពួកគេជាងការនិយាយអំពីបញ្ហានោះ ។

- ការសម្ភាសដោយប្រើរូបគំនូរ
  - ឧបករណ៍សម្ភាសនេះ លើកទឹកចិត្តដល់កុមារឱ្យគូរគំនូរផ្ទាល់ខ្លួនរបស់ពួកគេ ។ បន្ទាប់ពីទទួលបានក្រដាសសស្អាតមួយសន្លឹក ការងារដំបូងរបស់អ្នកត្រូវដឹងពីសមត្ថភាពរបស់កុមារ ហើយឱ្យកុមារគូររូបភាពរបស់ខ្លួន
  - អ្នកសម្ភាស និងកុមារគួរតែត្រួតពិនិត្យលើឈ្មោះរបស់កុមារនោះ ឈ្មោះ និងទីកន្លែងរបស់អវៈយវៈផ្សេងៗទៀត
  - កុមារគួរត្រូវបានសុំឱ្យដាក់ឈ្មោះ និងដាក់ផ្លាកសញ្ញាអវៈយវៈផ្លូវភេទ ដែលការធ្វើបែបនេះ មិនត្រឹមតែធ្វើឱ្យអ្នកសម្ភាសយល់ពីចំណេះដឹងខាងផ្លូវភេទរបស់កុមារប៉ុណ្ណោះទេ ថែមទាំងធ្វើឱ្យអ្នកសម្ភាសដឹងពីឈ្មោះពិសេស ដែលកុមារអាចប្រើចំពោះអវៈយវៈទាំងនេះ
  - នៅពេលបញ្ចប់ កុមារគួរតែត្រូវបានផ្តល់ក្រដាសមួយសន្លឹកសស្អាត ហើយ សុំឱ្យគូររូបក្រុមគ្រួសាររបស់ពួកគេ ។ រូបភាពនេះត្រូវបានប្រើដើម្បីកំណត់ថាតើមានមនុស្សផ្សេងធ្លាប់ទាក់ទងជាប្រចាំជាមួយកុមារ ក្រៅពីក្រុមគ្រួសារដែលកុមារនោះស្គាល់ឬក៏អត់ ហើយផ្តល់ឱ្យកុមារនូវក្រដាសសស្អាតមួយសន្លឹកថែមទៀត ដើម្បីឱ្យគូររូបភាពនៃការយាយីផ្លូវភេទដែលបានកើតឡើងចំពោះពួកគេ ។ ជាចុងក្រោយ កុមារគួរត្រូវបានណែនាំឱ្យដាក់ផ្លាកសញ្ញាពីមនុស្សគ្រប់គ្នានៅក្នុងរូបភាព និងសុំឱ្យប្រាប់ពេលវេលាដែលបានកើតឡើងចំពោះហេតុការណ៍នោះ ។

- ជំហានទី ៩៖ ការសន្និដ្ឋាន

○ ដូចជាការសម្ភាសដូច្នេះដែរ កុមារត្រូវការឱកាសដើម្បីឆ្លើយសំណួរ ឬនិយាយពីការព្រួយបារម្ភ ចំពោះដំណើរការសម្ភាស ដំណើរការច្បាប់ ឬបញ្ហាដទៃទៀតដែលពួកគេកំពុងប្រឈមមុខ

○ នៅទីបញ្ចប់ អ្នកសម្ភាសចាំបាច់ពន្យល់ដល់កុមារ នូវអ្វីដែលនឹងកើតឡើងនៅពេលខាងមុខក្នុងដំណើរការរឿងក្តី ដើម្បីផ្តន្ទាទោសជនល្មើស ហើយត្រូវអរគុណដល់កុមារដែលបានជួយដល់ពួកយើង ។

# ជំពូកទី ២
# ការសម្ភាសជនរងគ្រោះជាសាក្សី

## I. គោលការណ៍ណែនាំស្តីពីការសម្ភាសរកភស្តុតាង




## II. សារៈសំខាន់នៃជនរងគ្រោះ

ជានិច្ចកាល អ្នកស៊ើបអង្កេតត្រូវចងចាំនូវចំណុចគន្លឹះដូចខាងក្រោម ៖

- គ្មាននរណាម្នាក់ដឹងប្រវត្តិរឿងក្តីច្រើនជាង និងមានលក្ខណៈលម្អិតជាង ជនរងគ្រោះដែលបានទទួលរងការឈឺចាប់ដោយសារបទល្មើសនេះ
- កិច្ចសហការរបស់ជនរងគ្រោះជាសាក្សី គឺជាភស្តុតាងដែលមានគុណភាពខ្ពស់បំផុត នាំទៅដល់ការចោទប្រកាន់
- បើគ្មានជនរងគ្រោះធ្វើជាសាក្សី ការផ្តន្ទាទោសមិនអាចធ្វើបាន ចំពោះជនល្មើសរំលោភសិទ្ធិជាមូលដ្ឋានធ្ងន់ធ្ងរដែលបានប្រព្រឹត្តទៅលើជនរងគ្រោះ ហើយប្រសិនបើមានការផ្តន្ទាទោសជនល្មើសនឹងទទួលនូវការផ្តន្ទាទោសយ៉ាងធ្ងន់ធ្ងរ
- ប្រសិនបើអ្នកជាអ្នកស៊ើបអង្កេតក្នុងរឿងក្តីជួញដូរ នៅក្នុងប្រទេសប្រភព នោះអាចមានភស្តុតាងទាក់ទងនឹងការកេងប្រវ័ញ្ច ដែលកើតមានឡើងតែនៅកន្លែងគោលដៅ ហើយមានតែ ជនរងគ្រោះប៉ុណ្ណោះ ដែលជាអ្នកដឹង ។

នៅក្នុងការស៊ើបអង្កេតរឿងក្តីព្រហ្មទណ្ឌណាមួយ កិច្ចសហការ និងចម្លើយសាក្សីរបស់ជនរងគ្រោះដោយសារបទល្មើស ជានិច្ចកាល គឺមានសារៈសំខាន់ខ្លាំងណាស់ ។ ប៉ុន្តែនៅក្នុងរឿងក្តីជួញដូរ

មនុស្ស កិច្ចសហការរបស់ជនរងគ្រោះធ្វើជាសាក្សី គឺមានសារៈសំខាន់ខ្លាំងជាងនេះទៅទៀត ដោយសារតែវិធីជួញដូរនៃបទល្មើសនេះ បង្ហាញនូវចំណុចសំខាន់ៗ ពីរយ៉ាង ៖

• បទឧក្រិដ្ឋជួញដូរមនុស្ស ពុំមែនប្រព្រឹត្តឡើងតែឯកឯងនោះទេ ជាធម្មតា វាកើតឡើងដោយពាក់ព័ន្ធបទល្មើសផ្សេងៗទៀត ដែលបង្កឱ្យមានការបំពានធ្ងន់ធ្ងរ និងការរំលោភសិទ្ធិមនុស្ស ដូចជា រំលោភ បង្ករបួសស្នាមធ្ងន់ធ្ងរ និងការដកសិទ្ធិសេរីភាព ។ លក្ខណៈនៃបទល្មើសទាំងនេះគឺមានទោសធ្ងន់ធ្ងរ ជាងបទល្មើសជួញដូរមនុស្សដែលគ្មានស្ថានទម្ងន់ ហើយលទ្ធផលនៃរឿងក្ដីជាច្រើនបង្ហាញថា មានការផ្ដន្ទាទោសជនល្មើសយ៉ាងធ្ងន់ធ្ងរ ។ ដូចនេះគឺវាមានសារៈសំខាន់ក្នុងការព្យាយាមរកឱ្យឃើញបទល្មើសដែលពាក់ព័ន្ធ នៅពេលសវនាការរឿងក្ដី គឺអាស្រ័យទាំងស្រុងទៅលើកិច្ចសហការ និងចម្លើយរបស់ជនរងគ្រោះ

• លើសពីនេះទៅទៀត នៅក្នុងប្រទេសប្រភពនៃអំពើជួញដូរ វិធីប្រតិបត្តិការនៃបទល្មើសមានន័យថា គឺជាការប្រមូលភស្តុតាងទទួលបានលទ្ធផលច្រើនបំផុត សម្រាប់អ្នកស៊ើបអង្កេត ឧទាហរណ៍ ការស៊ើបអង្កេតនៅក្នុងដំណាក់កាលនៃការកេងប្រវ័ញ្ចបទល្មើសជួញដូរមនុស្ស ជាធម្មតាកើតឡើងនៅក្នុងប្រទេសគោលដៅ ។ វិធីប្រតិបត្តិការនៃបទល្មើសជាប្រភពតែមួយគត់នៃភស្តុតាងនៃការកេងប្រវ័ញ្ច ដែលជាផ្នែកដ៏សំខាន់មួយនៃបទឧក្រិដ្ឋជួញដូរមនុស្ស គឺចម្លើយរបស់ជនរងគ្រោះ ។

ដូច្នេះ ការដែលយើងធ្វើអ្វីៗដែលចំបាច់ និងត្រឹមត្រូវ ដើម្បីទទួលបាននូវកិច្ចសហការពីជនរងគ្រោះ វាមិនមានន័យត្រឹមតែការទទួលបាននូវប្រភព ដែលមានគុណភាពល្អបំផុតនៃភស្តុតាងប៉ុណ្ណោះទេ ប៉ុន្តែជាការបង្កើននូវការទទួលបានយុត្តិធម៌សម្រាប់ជនរងគ្រោះ និងលទ្ធផល ដែលមានតម្លៃខ្ពស់បំផុតផងដែរ ។

បន្ទាប់ពីបានវាយតម្លៃជនរងគ្រោះថាជាសាក្សី បញ្ហានេះបានក្លាយទៅជាការចាំបាច់ ក្នុងការកំណត់បញ្ហាគន្លឹះ ដែលតម្រូវឱ្យដោះស្រាយ ដើម្បីធានាឱ្យមានកិច្ចសហការពីជនរងគ្រោះ និងដំណើរការនៃការអនុវត្តគោលការណ៍ប្រតិបត្តិការល្អៗ ។

## ១. ការព្រួយបារម្ភជាគន្លឹះប្រាំយ៉ាង របស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស

ការវិភាគរឿងក្ដីបានបង្ហាញថា ជនរងគ្រោះមានការព្រួយបារម្ភ ដែលធ្វើឱ្យពួកគេមានកង្វល់យ៉ាងខ្លាំង និងផលប៉ះពាល់ទៅលើឆន្ទៈសហការធ្វើជាសាក្សី ។ ប្រភេទនៃការព្រួយបារម្ភទាំងនេះទាក់ទងទៅនឹងករណីរឿងក្ដីមួយចំនួន ប៉ុន្តែការវិភាគបានបង្ហាញថា មានការព្រួយបារម្ភសំខាន់ៗចំនួនប្រាំ ដែលអាចមានផលប៉ះពាល់អវិជ្ជមានយ៉ាងខ្លាំង ទៅលើការត្រៀមខ្លួនយល់ព្រមធ្វើជាសាក្សី ។ ការប្រឈមមុខរបស់អ្នកស៊ើបអង្កេត គឺត្រូវរកឱ្យឃើញបញ្ហាអ្វីដែលពាក់ព័ន្ធទៅនឹងជនរងគ្រោះរូបនោះ និងកំណត់ឱ្យឃើញវិធានការដើម្បីដោះស្រាយបញ្ហាទាំងនោះ ៖

• សុវត្ថិភាពផ្ទាល់ខ្លួន និងអ្នកដែលខ្លួនស្រឡាញ់ ៖ ពិចារណាផ្ដល់កិច្ចការពារសាក្សី ត្រូវស្មោះត្រង់ជាច់ខាត មិនត្រូវសន្យាពីអ្វីដែលមិនអាចធ្វើបាន

• ស្ថានភាពជាជនល្មើស ៖ ជនរងគ្រោះមិនត្រូវចោទប្រកាន់ ពិចារណាពិគ្រោះយោបល់ជាមួយព្រះរាជអាជ្ញា ទាក់ទិនទៅនឹងការមិនចោទប្រកាន់ពីបទល្មើសនានា ដែលកើតចេញពីស្ថាន

ភាពរបស់ខ្លួនជាជនរងគ្រោះ

- ស្ថានភាពនៃការចូលក្នុងប្រទេសដោយខុសច្បាប់ ចំពោះជនរងគ្រោះជាបរទេស ៖ ពិចារណា ទទួលនូវទិដ្ឋាការខាងផ្នែកយុត្តិធម៌ ដើម្បីឱ្យជនរងគ្រោះអាចស្នាក់នៅ ប្រសិនបើគាត់ចង់
- ភាពអៀនខ្មាស និងភាពអាម៉ាស់៖ ពិចារណាវិធានការសម្ងាត់ ដើម្បីការពារទិន្នន័យបុគ្គល ពីប្រព័ន្ធផ្សព្វផ្សាយ ប្រើប្រាស់អំណាចផ្នែកច្បាប់ ដើម្បីហាមឃាត់ការផ្សព្វផ្សាយ ប្រើអត្តសញ្ញាណក្លែងក្លាយ និងការពារទិន្នន័យកុមារ
- ភាពភ័យខ្លាចរបស់ជនរងគ្រោះ ៖ ពិចារណាវិធានការកំណត់អត្តសញ្ញាណ តាមរយៈកញ្ចក់ដែលអាចមើលឃើញតែម្ខាង លក្ខខណ្ឌផ្តល់ចម្លើយសាក្សីនៅតុលាការ ប្រើប្រាស់ផ្ទាំង ក្រណាត់កុំឱ្យឃើញជនសង្ស័យ ឬប្រសិនបើអាច ប្រើប្រាស់បណ្តាញវីដេអូ (វីដេអូឆ្លងឆ្លើយ) ។

**២. ចំណុចជាក់លាក់នៃព័ត៌មាន មុនពេលធ្វើការសម្ភាស**

អ្នកស៊ើបអង្កេត គួរពន្យល់ទៅជនរងគ្រោះ ពីដំណើរនៃកិច្ចសហការ និងពីអ្វីដែលតម្រូវឱ្យជនរងគ្រោះយល់ព្រមធ្វើសាក្សី ។ ការពន្យល់នេះ គួរតែមានការពាក់ព័ន្ធទៅនឹងបញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលតម្រូវឱ្យចាត់វិធានការមួយចំនួន ដែលអាចដោះស្រាយ ពីការភ័យខ្លាច ឬការព្រួយបារម្ភរបស់ជនរងគ្រោះ ទាក់ទងទៅនឹងកិច្ចសហការរបស់ខ្លួន ហើយគួរផ្តោតអារម្មណ៍ទៅលើចំណុចសំខាន់ៗដូចខាងក្រោម ៖

- សុវត្ថិភាពរបស់ជនរងគ្រោះ ៖ តម្រូវឱ្យមានការធានា ដោយសារសុវត្ថិភាពផ្ទាល់ខ្លួន និង និងអ្នកដែលគេស្រឡាញ់ ។ ជាការសំខាន់ ក្នុងការកាត់បន្ថយឱ្យបានអតិបរមា នូវគ្រោះថ្នាក់ដែលពាក់ព័ន្ធទៅនឹងសុវត្ថិភាពរបស់ពួកគេ ។ ការពន្យល់ណាមួយទៅដល់វិធានការការពារ ជនរងគ្រោះ គឺជាការងារដែលអាចធ្វើបាន និងពិតប្រាកដ ។ ចំពោះសាក្សីសំខាន់ៗ អ្នកស៊ើបអង្កេត មិនត្រូវធ្វើឱ្យមានកំហុសឆ្គង ក្នុងការផ្តល់ព័ត៌មានមិនពិត ទាក់ទងទៅនឹងកម្រិតវិធានការសុវត្ថិភាព ដែលមាន
- ស្ថានភាពនៃការចោទប្រកាន់ ៖ ជនរងគ្រោះនឹងចង់ដឹងថា តើខ្លួនត្រូវបានគេចោទប្រកាន់ទាក់ទងទៅនឹងបទល្មើសណាមួយដែលខ្លួនបានប្រព្រឹត្ត ដែលជាលទ្ធផលដោយផ្ទាល់នៃស្ថានភាពដែលជាជនរងគ្រោះដោយសារអំពើជួញដូរមនុស្ស និងថាតើជនរងគ្រោះ ត្រូវបានផ្តល់សិទ្ធិ ក្នុងការមិនចោទប្រកាន់ដែរឬអត់
- ស្ថានភាពនៃលំនៅដ្ឋាន ៖ ក្នុងករណីជនរងគ្រោះជាជនបរទេស ដែលត្រូវគេស្នើសុំឱ្យធ្វើកិច្ចសហការ ជនរងគ្រោះតម្រូវឱ្យមានការធានា និងការបញ្ជាក់ឱ្យបានច្បាស់អំពីស្ថានភាព ជាបន្ទាន់ និងរយៈពេលណាមួយ នៅក្នុងប្រទេសដែលមានការពាក់ព័ន្ធនោះ ។ បញ្ហានេះ គឺសំខាន់ ដែលតម្រូវឱ្យមានភាពស្មោះត្រង់ពេញលេញ ។ ប្រសិនបើជនរងគ្រោះ ធ្វើកិច្ចសហការក្នុងនាមជាសាក្សី ជនរងគ្រោះនោះនឹងត្រូវការចង់ដឹង ថាតើគាត់នឹងត្រូវគេធ្វើមាតុភូមិនិវត្តន៍ ឬក៏បញ្ជូនទៅតុលាការ ឬថាតើគាត់អាចត្រូវបានអនុញ្ញាតឱ្យស្នាក់នៅជាបណ្តោះអាសន្ននៅក្នុងប្រទេសនោះ ដើម្បី រង់ចាំសវនាការរឿងក្តី ចប់សព្វគ្រប់ ឬអាចស្នាក់នៅលើសពីនេះ
- ការធ្វើឱ្យលេចឮតាមរយៈប្រព័ន្ធផ្សព្វផ្សាយ ៖ ចំពោះបញ្ញត្តិច្បាប់ណាមួយ ដែលចែងពី

ការប្រើប្រាស់ឈ្មោះហៅក្រៅ ឬសម្រាប់ដីការបស់តុលាការ ដើម្បីធានាឱ្យមានភាពសម្ងាត់នៃអត្តសញ្ញាណជនរងគ្រោះ គួរត្រូវពន្យល់ដល់ជនរងគ្រោះ

• សេចក្តីភ័យខ្លាចនៅចំពោះមុខជនល្មើស ៖ តម្រូវការណាមួយនៃក្របខ័ណ្ឌច្បាប់ ដែលចែងពីបញ្ហានេះ គួរពន្យល់ទៅដល់ជនរងគ្រោះ និងដោះស្រាយចំពោះបញ្ហានៃការកំណត់នីតិវិធី និងលក្ខខណ្ឌនៃចម្លើយសាក្សី ។ ជនរងគ្រោះគួរតែត្រូវបានគេប្រាប់ ថាតើខ្លួននឹងតម្រូវឱ្យធ្វើការកំណត់អត្តសញ្ញាណជនល្មើស តាមរយៈនីតិវិធីណាមួយ ដូចជាឱ្យជនសង្ស័យឈរនៅជាមួយមនុស្ស ផ្សេងទៀត ដើម្បីឱ្យជនរងគ្រោះធ្វើការកំណត់អត្តសញ្ញាណជនល្មើស ហើយនីតិវិធីនេះតម្រូវឱ្យ ជនរងគ្រោះប្រឈមមុខជាមួយនឹងជនល្មើស ឬតាមរយៈនៃការប្រើប្រាស់វិធីមួយនៃការប្រើប្រាស់ ប្រព័ន្ធកំណត់អត្តសញ្ញាណតាមរយៈកញ្ចក់ ។ ជនរងគ្រោះគួរតែត្រូវបានគេប្រាប់ផងដែរពីវិធីសាស្ត្រ ដែលខ្លួននឹងផ្តល់ចម្លើយសាក្សី ហើយថាតើខ្លួននឹងប្រឈមមុខជាមួយនឹងជនល្មើស នៅក្នុងបន្ទប់សវនាការរបស់តុលាការ ឬថាតើជនរងគ្រោះអាចផ្តល់ភស្តុតាង តាមរយៈកញ្ចក់វីដេអូ ឬថាតើមានបញ្ញត្តិច្បាប់ណាមួយ អនុញ្ញាតឱ្យជនល្មើសចាកចេញពីបន្ទប់សវនាការ នៅពេលជនរងគ្រោះផ្តល់ភស្តុតាង ។

## III. ការសម្ភាសជនរងគ្រោះជាសាក្សីដោយអំពើជួញដូរមនុស្ស

### ១. ភារកិច្ចរបស់អ្នកសម្ភាស និងគោលបំណងនៃការសម្ភាស

គោលការណ៍នៃការអនុវត្តល្អៗនៅក្នុងការសម្ភាសលើជនរងគ្រោះដែលជាសាក្សី គឺអាស្រ័យទៅលើកត្តាគន្លឹះដូចខាងក្រោម៖

• ភារកិច្ចរបស់អ្នកសម្ភាស គឺប្រព្រឹត្តទៅលើជនរងគ្រោះដែលជាសាក្សី ប្រកបដោយភាពប្រុងប្រយ័ត្ន និងប្រកបដោយលក្ខណៈអាជីព ហើយត្រូវគោរពដោយពេញលេញពីសិទ្ធិមនុស្សរបស់ជនរងគ្រោះ

• ដំណើរការនៃការធ្វើសម្ភាស គឺត្រូវធ្វើឡើងដើម្បីធានាថា ដំណើរការនោះ មិនធ្វើឱ្យប៉ះពាល់បន្តទៅទៀតដល់ជនរងគ្រោះដែលជាសាក្សី

• បង្កើតលក្ខខណ្ឌដែលល្អបំផុត តាមដែលអាចធ្វើទៅបាន ដើម្បីឱ្យជនរងគ្រោះអាចផ្តល់ភស្តុតាងរបស់ខ្លួន និងផ្តល់ចម្លើយសាក្សីនៅក្នុងរបៀប ដែលកាត់បន្ថយឱ្យមានកម្រិតទាបបំផុត ពីការប៉ះពាល់ផ្លូវអារម្មណ៍ ដែលមិនអាចជៀសវាងបាន

• ផ្តល់ឱ្យជនរងគ្រោះ នូវឱកាសប្រកបដោយភាពត្រឹមត្រូវ និងស្មើភាព ដើម្បីទទួលបានយុត្តិធម៌ និងដើម្បីផ្តល់ឱ្យជនរងគ្រោះនូវឱកាសរៀបរាប់ពីរឿងរ៉ាវរបស់ខ្លួន ។

### ២. គោលបំណងបីយ៉ាងនៃការសម្ភាសរកភស្តុតាង

គោលបំណងនៃគោលការណ៍នេះ គឺជួយដល់អ្នកធ្វើសម្ភាស ដើម្បីធ្វើកំណត់ហេតុពីរឿងរ៉ាវឱ្យបានលម្អិត និងស៊ីចង្វាក់ពីជនរងគ្រោះ ដើម្បីការស៊ើបអង្កេតទទួលបាននូវគោលបំណងបី ៖




## ៣. ការប្រឈមនៃការសម្ភាស

ការសម្ភាសរកភស្តុតាង មានធាតុផ្សំពីរ៖

ក. ជនរងគ្រោះត្រូវធ្វើការសម្ភាស

ខ. បញ្ហាភស្តុតាង ត្រូវបានផ្តោតនៅពេលសម្ភាស

ការសម្ភាសជនរងគ្រោះដោយសារអំពើជួញដូរមនុស្ស ដែលជាសាក្សីអាចជាការប្រឈមក្នុងចំណោមភារកិច្ចប្រឈមផ្សេងដទៃទៀតរបស់អ្នកសម្ភាស ។ ដើម្បីឱ្យសម្រេចនូវគោលបំណង នៃការសម្ភាស អ្នកធ្វើសម្ភាសត្រូវតែជម្នះការប្រឈមធ្ងន់ធ្ងរ ដែលពាក់ព័ន្ធនឹងជនរងគ្រោះ និងខ្លឹមសារនៃភស្តុតាងដែលបានមកពីការសម្ភាស ៖

- ជំងឺផ្លូវអារម្មណ៍៖ ជនរងគ្រោះអាចត្រូវទទួលរងខាងផ្នែកផ្លូវអារម្មណ៍ តាមរយៈបទពិសោធន៍នៃអំពើជួញដូរមនុស្ស ហើយតម្រូវឱ្យនិយាយពីព្រឹត្តិការណ៍ ដែលជាភស្តុតាងឱ្យបានលម្អិតដែលមានការប៉ះពាល់ និងការឈឺចាប់ខ្លាំង ហើយការរំលឹកពីព្រឹត្តិការណ៍នេះ អាចធ្វើឱ្យមានគ្រោះថ្នាក់ដែលអាចកើតមានឡើងពីការប៉ះពាល់ផ្លូវអារម្មណ៍ឡើងវិញ
- សេចក្តីភ័យខ្លាច៖ នៅដំណាក់កាលដំបូង ជនរងគ្រោះដែលជាសាក្សី ការពិតស្ទើរតែទាំងស្រុង មានការព្រួយបារម្ភ ឬអាចមានការភ័យខ្លាចពីដំណើរការនៃការធ្វើសម្ភាស
- ភាពមន្ទិល៖ នៅក្នុងដំណាក់កាលដំបូង ជនរងគ្រោះអាចមានការសង្ស័យខ្លាំងចំពោះអ្នកធ្វើសម្ភាស ដោយហេតុថា ជនរងគ្រោះដែលជាសាក្សីភាគច្រើន អាចមានបទពិសោធន៍អវិជ្ជមានជាមួយមន្ត្រីអនុវត្តច្បាប់ ។

## ៤. ការគ្រប់គ្រងលើការប្រឈម

ការប្រឈមពាក់ព័ន្ធទៅនឹងជនរងគ្រោះដែលជាសាក្សី និងភាពស្មុគស្មាញនៃទំហំភស្តុតាងតាមរយៈការសម្ភាស មានន័យថា អ្នកសម្ភាសតម្រូវឱ្យមានការគ្រប់គ្រងបានក្នុងពេលតែមួយ លើបញ្ហាជាក់លាក់ ដែលមានការពាក់ព័ន្ធទៅនឹងភាពគ្រោះថ្នាក់បន្តទៅទៀតដល់ជនរងគ្រោះ ហើយស្របពេលគ្នានោះដែរ ត្រូវផ្តោតអារម្មណ៍ទៅលើការគំរាមកំហែង ដែលពាក់ព័ន្ធទៅនឹងភស្តុតាង ។

ការគ្រប់គ្រងនេះ គឺជាការសំខាន់ ពីព្រោះតាមបទពិសោធន៍ប្រតិបត្តិការកន្លងមកបង្ហាញថា ចំណុចគន្លឹះប្រកបដោយភាពជោគជ័យលើការចោទប្រកាន់ក្នុងរឿងក្តីជួញដូរមនុស្ស តាមរយៈការប្រើ

ជនរងគ្រោះជាសាក្សី គឺអាស្រ័យទៅលើសមត្ថភាពរបស់ពួកគេដែលអាចរំលឹកពីព្រឹត្តិការណ៍ ដែលកើតឡើងឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន ដែលជាការបំពេញបន្ថែមទៅលើភស្តុតាង

សមត្ថភាពរបស់អ្នកសម្ភាសគឺស្វែងរក និងដកស្រង់ព័ត៌មាន ដែលមានលក្ខណៈជាភស្តុតាងឱ្យបានច្រើនតាមលទ្ធភាពដែលអាចធ្វើទៅបាន ដើម្បីទទួលបាននូវភាពយុត្តិធម៌ដល់ជនរងគ្រោះ ។

## IV. ការរៀបចំផែនការសម្ភាស

ដើម្បីឆ្លើយតបទៅនឹងការប្រឈមដែលមានភាពស្មុគស្មាញនេះ គឺតម្រូវឱ្យមានវិធីសាស្ត្រជាប្រព័ន្ធ ដើម្បីជួយដល់អ្នកធ្វើសម្ភាស ដូចនេះហើយគំរូនៃការសម្ភាស PEACE ត្រូវបានយកមកប្រើ ។ គំរូនេះត្រូវបានយកមកប្រើប្រាស់នៅក្នុងប្រទេសជាច្រើន ហើយបានបង្ហាញថា វាបានផ្តល់នូវក្របខ័ណ្ឌដែលមានភាពបត់បែនបាន ដែលជាចំណុចសំខាន់ដល់ការសម្ភាសជនរងគ្រោះ ឱ្យទទួលបានជោគជ័យ ។ តារាងខាងក្រោមបានរៀបរាប់ពីសមាសភាពទាំងប្រាំនៃគំរូនេះ៖

| **គំរូសម្ភាស PEACE** | | | | |
|---|---|---|---|---|
| P<br>ការត្រៀមរៀបចំ | E<br>ការអនុវត្ត និងពន្យល់ | A<br>ការរៀបរាប់ | C<br>ការបញ្ចប់ | E<br>ការវាយតម្លៃ |
| **ចំណុចសំខាន់ៗ** | | | | |
| ជ្រើសរើសមន្ត្រីសម្ភាស | បង្កើតអារម្មណ៍លើកទីមួយ | ចាប់ផ្តើមក្របខ័ណ្ឌនៃសាច់រឿង | ចំណាយពេលបិទការសម្ភាសឱ្យល្អ | វាយតម្លៃបញ្ហាពីរ |
| ជ្រើសរើសដៃគូសម្ភាស | ធានាឱ្យមានអារម្មណ៍ល្អ សុវត្ថិភាព និងសុខមាលភាព | គ្រប់ដណ្តប់ទៅលើការជ្រើសរើស ការដឹកជញ្ជូន និងការកេងប្រវ័ញ្ច | ធានាថា ការថតយកការសម្ភាសត្រូវបានយល់ព្រមពីជនរងគ្រោះ | វាយតម្លៃពីការអនុវត្តរបស់អ្នកសម្ភាស |
| វិភាគព័ត៌មានដែលមាន | ណែនាំខ្លួនមនុស្សទាំងអស់ដែលមានវត្តមាន | គោលបំណងចម្បងគឺអង្គហេតុលម្អិត | សង្ខេបពីការរីកចម្រើន និងលើកទឹកចិត្ត | ការពិនិត្យឡើងវិញទៅលើក្រុមសម្ភាស |
| ត្រៀមរៀបចំចំណុចនៃការវិភាគរកភស្តុតាង | បង្កើតទំនាក់ទំនង | ពង្រីករឿងក្តីតាមរយៈជំនាញសួរយកចម្លើយ | ពន្យល់ពីប្រធានបទសម្រាប់ការសម្ភាសលើកក្រោយ | វាយតម្លៃភស្តុតាងដែលមានរហូតដល់ពេលនេះ |
| ត្រៀមរៀបចំទីតាំង | ពន្យល់ពីដំណើរការ | ផ្តោតទៅលើបញ្ហាភស្តុតាងសំខាន់ៗ | យល់ព្រមណាត់ការសម្ភាសលើកក្រោយ | កំណត់ឱ្យឃើញភស្តុតាងដែលមិនទាន់ |

| | | | | ទទួលបាន |
|---|---|---|---|---|
| ពន្យល់ក្រុមសម្ភាស | ពន្យល់វិធាននៃការសម្ភាស | កំណត់ឱ្យឃើញកាលបរិច្ឆេទ ឬចំណុចលំដាប់លំដោយពីពេលវេលាសំខាន់ៗ | ផ្ទៀងផ្ទាត់មើលបញ្ហាសុខមាលភាព | ត្រៀមរៀបចំការសម្ភាសលើកក្រោយ-អនុវត្តគំរូ PEACE ដូចគ្នា |

**១. គំរូ PEACE ៖ P- ការត្រៀមរៀបចំ**

ត្រូវមានការរៀបចំផែនការឱ្យបានត្រឹមត្រូវ សម្រាប់ធ្វើការសម្ភាស ដែលមានសារៈសំខាន់ណាស់ ។ ចូរចងចាំវិធាន ៖ ការត្រៀមរៀបចំឱ្យបានត្រឹមត្រូវ ដើម្បី ទប់ស្កាត់ការអនុវត្តមិនល្អ ។

**សង្ខេបភារកិច្ចសំខាន់ៗនៅក្នុងដំណាក់កាល ត្រៀមរៀបចំ៖**



កត្តាខាងក្រោមនេះ គួរតែពិចារណា៖

- ក្រុមសម្ភាស៖ ចំពោះមូលហេតុដែលបានរៀបរាប់ខាងលើ ការសម្ភាសប្រកបដោយប្រសិទ្ធភាពចំពោះ ជនរងគ្រោះ ដោយសារអំពើជួញដូរមនុស្ស ពុំមែនជាភារកិច្ចរបស់អ្នកធ្វើសម្ភាសតែម្នាក់ឯងនោះទេ ។ ការសម្ភាសតម្រូវឱ្យមានយុទ្ធសាស្ត្រជាក្រុម ដែលមានគ្នាពីរនាក់សម្រាប់សួរយកចម្លើយសាក្សី និងការចូលរួមពីអ្នកអាជីពផ្សេងទៀត ដែលដើរតួនាទីភាពជាដៃគូ ដើម្បីទទួលបាននូវគោលដៅនៃការសម្ភាស ដែលបានកំណត់ខាងលើ
- លក្ខណៈសម្បត្តិនៃអ្នកសម្ភាស៖ តាមដែលអាចធ្វើទៅបាន មន្ត្រីសម្ភាសគួរតែជ្រើសរើសឡើង ដោយឈរលើមូលដ្ឋាននៃជំនាញដែលបានកំណត់ដូចខាងក្រោម៖
  - ជំនាញសាកសួរ៖ លទ្ធភាព និងការបណ្ដុះបណ្ដាល លើការគ្រប់គ្រងនៃការសាកសួរយកភស្តុតាងជាមួយជនរងគ្រោះដែលងាយរងគ្រោះថ្នាក់ ហើយជាអ្នកដែលធ្វើសាក្សី
  - ជំនាញស្ដាប់ដែលមានលក្ខណៈសកម្ម និងយកចិត្តទុកដាក់៖ លទ្ធភាពនៃការស្ដាប់យ៉ាងសកម្ម ពីចម្លើយរបស់ជនរងគ្រោះដោយសារអំពើជួញដូរមនុស្ស និង ការជៀសវាងការកាត់សម្ដីរបស់ជនរងគ្រោះ ជាពិសេសនៅក្នុងដំណាក់កាលនៃការរំលឹកឡើងវិញរបស់ជនរងគ្រោះពីសកម្មភាពដែលកើតឡើង គឺជាគុណសម្បត្តិយ៉ាងសំខាន់របស់អ្នកសម្ភាស
  - លទ្ធភាពនៃការបញ្ជាក់ និងការរៀបចំរបាយការណ៍ ៖ អ្នកសម្ភាសគួរតែបញ្ជាក់ឱ្យបានច្បាស់លាស់ជាមួយជនរងគ្រោះ ពីព្រឹត្តិការណ៍ដែលជនរងគ្រោះបានទទួលរង និងស្វែងរកព័ត៌មានដើម្បីរៀបចំជារបាយការណ៍ ដែលមានមូលដ្ឋានទៅលើភាពជឿជាក់បាន និងការយល់ដឹងពីស្ថានភាពរបស់ជនរងគ្រោះ។ អ្នកសម្ភាសត្រូវយល់ដឹងពីអារម្មណ៍ នៃការទទួលរងអំពើជួញដូរមនុស្សជាងការអាណិតអាសូរដល់ជនរងគ្រោះ ដែលជាចំណុចសំខាន់បំផុតនៅដំណាក់កាលនេះ ។ ជនរងគ្រោះមួយចំនួនមិនមានប្រតិកម្មជាវិជ្ជមាន ពីការបង្ហាញកាយវិការរបស់អ្នកសម្ភាស នូវអារម្មណ៍ទទួលរងអំពើជួញដូរមនុស្សនោះទេ ហើយនៅក្នុងករណីខ្លះ ជនរងគ្រោះអាចចាត់ទុកថាជាកាយវិការ មិនរាក់ទាក់ ពីព្រោះជានិច្ចកាល ជនរងគ្រោះមិនដឹងថាខ្លួនឯងថាជាជនរងគ្រោះនោះទេ
  - សមត្ថភាពខាងផ្នែកវប្បធម៌ ៖ ការមិនយល់ដឹងពីពូជសាសន៍ សាសនា សង្គម វប្បធម៌ ប្រពៃណី និងសីលធម៌ផ្សេងៗគ្នា គឺជាកត្តាធ្វើឱ្យមានការប៉ះពាល់ទៅលើរបៀបណាមួយ ឬទាំងស្រុងនៃ ការសម្ភាស
  - ភាពអំណត់ និងភាពបត់បែន ៖ ធ្វើការកំណត់ និងដកស្រង់អង្គហេតុ ដែលមានលក្ខណៈជាភស្តុតាងពីជនរងគ្រោះដោយសារអំពើជួញដូរមនុស្ស ជានិច្ចកាលគឺ ហាក់ដូចជាតម្រូវឱ្យមានលំដាប់លំដោយនៃការធ្វើសម្ភាស ហើយលំដាប់លំដោយ នីមួយៗ បង្ហាញពីការប្រឈមផ្សេងៗគ្នាដែលអាចពន្យឺតដល់ការប្រមូលភស្តុតាង ដូចជា លក្ខខណ្ឌអារម្មណ៍របស់ជនរងគ្រោះ កម្រិតសហការ និងតម្រូវការឱ្យមានការប្រុងប្រយ័ត្ន ក្នុងការរំលឹកព្រឹត្តិការណ៍ពីអតីតកាលរបស់ជនរងគ្រោះ...។ល។ កត្តាទាំងអស់នេះ គឺតម្រូវឱ្យមានភាពអំណត់ និងភាពអាចបត់បែនបានរបស់អ្នកសម្ភាស ។ ឧទាហរណ៍ ៖ វត្តមាននៃការប៉ះពាល់ផ្លូវអារម្មណ៍របស់ជនរងគ្រោះ អាចតម្រូវឱ្យមានការផ្អាកការធ្វើ

សម្ភាស បន្ទាប់ពីរយៈពេលពីរ-បីនាទីមក ប្រសិនបើមានព្រឹត្តិការណ៍ពិសេសណាមួយទាក់ទងទៅនឹងការរំលឹកពីអតីតកាលរបស់ជនរងគ្រោះ ការសម្ភាសនោះត្រូវការចាំបាច់ឱ្យមានការសម្រាក ដើម្បីឱ្យជនរងគ្រោះធ្វើការប្រមូលអារម្មណ៍ និងអាចសម្ភាសតទៅទៀត ។

○ កាយសម្បទាមាំមួនៈ ការធ្វើសម្ភាស គឺមានតម្រូវការខ្លាំង ហើយអាចបន្តក្នុងរយៈពេលជាច្រើនថ្ងៃ ឬយូរជាងនេះ និងការបង្ហាញពីការទទួលរងអារម្មណ៍វាយប្រហារ ។ អ្នកសម្ភាសគួរតែមានកាយសម្បទារឹងមាំ ដើម្បីធានាឱ្យបានចំពោះកម្រិតការងារ ដែលតម្រូវឱ្យមានការយកចិត្តទុកដាក់ពេញលេញនៅគ្រប់ដំណាក់កាល ហើយមានការគ្រប់គ្រងអារម្មណ៍គ្រប់គ្រាន់ទៅលើគោលដៅនៃការទទួលភស្តុតាងដែលបញ្ហានេះអាចធ្វើឱ្យមានការខឹងសម្បា ទាំងជនរងគ្រោះ ទាំងអ្នកសម្ភាស

○ ជំនាញសង្កេតការណ៍ ៖ ការរំលឹកឡើងពីសកម្មភាពរំលោភបំពានហិង្សា នៅក្នុងអំឡុងពេលនៃការធ្វើសម្ភាស គឺមានផលប៉ះពាល់ទាំងជនរងគ្រោះ និងទាំងអ្នកសម្ភាស ដែលជាអ្នកធ្វើការសង្កេត និងបង្កើនសមត្ថភាពក្នុងការទទួលស្គាល់ពី សញ្ញានៃការខឹងសម្បា ឬព្រួយបារម្ភជាមួយជនរងគ្រោះ ជាពិសេសគឺព្រឹត្តិការណ៍ ទាក់ទងទៅនឹងការបំពារបំពាននានា ដូចជា ការរំលឹកអំពីការរំលោភសេពសន្ថវៈ និងការវាយដំលើរូបរាងកាយ ។ ការទទួលស្គាល់ដំបូងនៃសញ្ញាដែលអាចមើលឃើញទាក់ទងទៅនឹងការខឹងសម្បា ឬការព្រួយបារម្ភ ដូចជា កំហឹងភ្លាមៗ ឬការស្រែកយំភ្លាមៗ ការដកដង្ហើមមិនធម្មតា ការប្រែពណ៌ស្បែក សរសេរនៅលើ ដៃ...អាចធ្វើឱ្យអ្នកសម្ភាសប្រតិកម្មឱ្យបានសមស្រប ដើម្បីកាត់បន្ថយពីគ្រោះថ្នាក់ នៃការទទួលរងការប៉ះពាល់ផ្លូវអារម្មណ៍ឡើងវិញ ឬជួនកាល ធ្វើការសង្កេតទៅលើជនរងគ្រោះ ថាតើគាត់អាចបន្តការសម្ភាសតទៅទៀត ឬក៏ជាការសមរម្យបំផុត ដោយប្តូរសំណួរដែលទាក់ទងទៅនឹងការឈឺចាប់របស់ជនរងគ្រោះ ទៅជាសំណួរ ដែលទាក់ទងទៅនឹងបញ្ហាធម្មតាវិញ ឬសម្រាកជាបន្ទាន់នៅក្នុងព្រឹត្តិការណ៍ណាមួយ ឬក៏ពន្យាររពេលទៅថ្ងៃបន្ទាប់ ។ គោលការណ៍នេះគួរតែអនុវត្តឱ្យបាន មិនត្រូវធ្វើឱ្យមានការប៉ះពាល់ដែលបណ្តាលឱ្យឈឺចាប់ ។ ការដែលជនរងគ្រោះប្រាប់ពីអំពើដែលបានធ្វើទារុណកម្មមកលើខ្លួន អាចធ្វើឱ្យមានផលប៉ះពាល់ទៅលើអ្នកសម្ភាស ឬក្រុមអ្នកសម្ភាសមិនឱ្យមានភាពនឹងនរ ។ ដូចនេះក្រុមអ្នកសម្ភាស ត្រូវបង្កើនសមត្ថភាពយល់ដឹងពីសញ្ញាស្រដៀងគ្នានេះ ដែលទាក់ទងទៅនឹងការរំខានផ្នែកអារម្មណ៍ទៅលើខ្លួន ឬក៏ត្រូវសម្រាកបន្តិចបើសិនជាចាំបាច់ ។

○ អាកប្បកិរិយាមិនមានលក្ខណៈវិនិច្ឆ័យជាមុនៈ វាគឺជាការសំខាន់ ដែលអ្នកសម្ភាសមិនត្រូវវិនិច្ឆ័យមុន ទៅលើជនរងគ្រោះ ឬទៅលើរឿងក្តី ។ អ្នកសម្ភាសគួរតែធ្វើការវិភាគ ទៅលើគំនិតផ្ទាល់របស់ខ្លួន មុននឹងគំនិតរបស់ខ្លួនក្លាយជាព័ត៌មាន និងការធ្វើឱ្យប៉ះពាល់ដល់ជនរងគ្រោះ ឬទុកសាក្សីឱ្យនៅក្រៅបន្ទប់សម្ភាស ។ ជាទូទៅ ជនរងគ្រោះនឹងធ្វើការពិនិត្យតាមដានយ៉ាងខ្លាំង ទៅលើសញ្ញាណាមួយនៃ អាកប្បកិរិយាវិនិច្ឆ័យជាមុនរបស់អ្នកសម្ភាស ដូចនេះ ក្នុងការបង្ហាញពីយុទ្ធសាស្ត្រនៃការមិនវិនិច្ឆ័យមុន គឺជាការសំខាន់ ដែលត្រូវវាយតម្លៃជនរងគ្រោះឱ្យស្មើទៅនឹងការគោរព ភាពជឿជាក់ ដូចប្រជាពលរដ្ឋផ្សេងទៀតដែរ

○ ចំណេះដឹងដែលមានលក្ខណៈអាជីព ៖ តាមដែលអាចធ្វើទៅបាន អ្នកសម្ភាសគួរ

តែមានចំណេះដឹងជាលក្ខណៈអាជីពពីបទឧក្រិដ្ឋជួញដូរមនុស្ស បទល្មើសរំលោភ ផ្លូវភេទ ការបង្កគ្រោះថ្នាក់ដល់រាងកាយ និងបទពិសោធន៍ប្រតិបត្តិការចំពោះបទល្មើសខាងលើ ។ ការវិភាគទៅលើរឿងក្តីបង្ហាញឱ្យឃើញថា រឿងក្តីជួញដូរមនុស្សភាគច្រើន គឺមានការពាក់ព័ន្ធផងដែរ ទៅនឹងការបំពានផ្លូវភេទ រាងកាយ និងចិត្តសាស្ត្រ ដូច្នេះអ្នកសម្ភាសគួរតែមានជំនាញ និងទទួលនូវការបណ្តុះបណ្តាលដើម្បីអាចដោះស្រាយឱ្យទទួលបាននូវភស្តុតាង ដែលទាក់ទងទៅនឹងបទឧក្រិដ្ឋទាំងអស់នេះ ។ គោលបំណងជាទូទៅ គឺធ្វើឱ្យជនរងគ្រោះជឿជាក់ថា ការសម្ភាសនេះគឺគ្រប់គ្រងឡើង ដោយអ្នកស៊ើបអង្កេតដែលមានលក្ខណៈអាជីពប្រឆាំងនឹងអំពើជួញដូរមនុស្ស ។

- ការជ្រើសរើសក្រុមសម្ភាស
  - ក្រុមសម្ភាសគួរតែមានមន្ត្រី ២ រូប ហើយក្រុមនេះគួរតែបែងចែកតួនាទី ឱ្យបានច្បាស់លាស់ ម្នាក់ជាអ្នកដឹកនាំការសម្ភាស និងម្នាក់ទៀតជាអ្នកសម្ភាសបន្ទាប់បន្សំ
  - អ្នកដឹកនាំសម្ភាស គឺជាអ្នកធ្វើសម្ភាស លើកជាសំណួរ និងដឹកនាំសំណួរទៅរកចំណុចជាក់លាក់ ដើម្បីទទួលបានភស្តុតាង
  - តួនាទីរបស់អ្នកសម្ភាសបន្ទាប់បន្សំ គឺជាអ្នកដែលដើរតួរជា "ភ្នែកនិងត្រចៀក" សម្រាប់អ្នកដឹកនាំសម្ភាស ហើយផ្តោតអារម្មណ៍ទៅលើភារកិច្ចពីរយ៉ាង គឺរក្សានូវការយកចិត្តទុកដាក់ឱ្យបានជិតដល់ លើលក្ខខណ្ឌរបស់ជនរងគ្រោះ និងផ្តល់សញ្ញាជាកាយវិការ ឬជាសម្តីឱ្យបានមុនទាក់ទងទៅនឹងការព្រួយបារម្ភ ឬការមិនមានអារម្មណ៍កាន់តែកើនឡើងរបស់ជនរងគ្រោះ ហើយផ្តល់ពីខ្លឹមសារនៃការធ្វើសម្ភាស
  - ក្រុមសម្ភាសដែលមានសមាជិក ២ រូប អាចធ្វើឱ្យជនរងគ្រោះបង្កើននូវទំនាក់ទំនងជាបន្ត ដោយមានការជឿជាក់ និងមានភាពជាដៃគូជាមួយមន្ត្រីទាំង២រូបនេះ ធ្វើដូចនេះ ប្រសិនបើម្នាក់មិនអាចចូលរួមការធ្វើសម្ភាស នៅពេលបន្ទាប់ ដោយមូលហេតុណាមួយ មន្ត្រីម្នាក់ទៀតអាចធ្វើការជំនួស ហើយអាចរក្សានូវទំនាក់ទំនង ។ ការជ្រើសរើសអ្នកសម្ភាស និងតួនាទីរបស់គេ គួរតែកំណត់ទៅតាមកត្តានានានៅជុំវិញអ្នករងគ្រោះដូចជា ភេទ អាយុ ប្រវត្តិរូប...។ល។
  - សួរជនរងគ្រោះ ថាតើគាត់ចង់បានអ្នកសម្ភាស ជាស្ត្រី ឬបុរស
  - ប្រសិនបើជនរងគ្រោះ គឺជាកុមារ បើអាចធ្វើទៅបាន មានតែមន្ត្រីដែលទទួលការបណ្តុះបណ្តាល ជាពិសេស ក្នុងការធ្វើការសម្ភាសជាមួយជនរងគ្រោះជាកុមារ ទើបអាចតែងតាំងជាអ្នកសម្ភាសបាន ។ អ្នកសម្ភាសគួរតែមាន សម្រាប់ដំណើរការសម្ភាសទាំងមូល ទោះបីជាការសម្ភាសតម្រូវឱ្យមានលំដាប់លំដោយ ពេលវេលាក៏ដោយ ។
- សេចក្តីសង្ខេបចំណុចសំខាន់ៗនៃការជ្រើសរើសក្រុមសម្ភាសជាដៃគូ
  - ចំនួន និងប្រវត្តិនានា អាស្រ័យលើកាលៈទេសៈនៃរឿងក្តី ហើយថាតើជនរងគ្រោះស្ថិតនៅក្រោមការគ្រប់គ្រងថៃរក្សា របស់ទីភ្នាក់ងារគាំទ្រដល់ជនរងគ្រោះ
  - ប្រសិនបើជនរងគ្រោះជាកុមារ ជាទូទៅ ក្រមនិតិវិធីព្រហ្មទណ្ឌ តម្រូវឱ្យមានវត្តមានអ្នកឯករាជ្យមួយ តំណាងឱ្យផលប្រយោជន៍របស់កុមារ ដូចជា ឪពុកម្តាយ និងមនុស្សពេញវ័យ ដទៃ

ទៀតនៃក្រុមគ្រួសារ ឬអាណាព្យាបាល

◦ ប្រសិនបើជនរងគ្រោះជាជនបរទេស សេវាបកប្រែ គឺតម្រូវឱ្យមានសម្រាប់រយៈពេលនៃការធ្វើសម្ភាស

◦ ប្រសិនបើជនរងគ្រោះដែលជាសាក្សី ស្ថិតនៅក្រោមការថែរក្សារបស់ទីភ្នាក់ងារគាំទ្រដល់ជនរងគ្រោះ ករណីនេះជនរងគ្រោះអាចទទួលនូវការណែនាំ ខាងផ្នែកចិត្តសាស្រ្ត និង/ឬការប្រឹក្សាខាងផ្នែកច្បាប់ អ្នកតំណាងនោះគួរតែចូលរួមនៅក្នុងដំណាក់កាលនៃការរៀបចំសម្ភាស ដោយឱ្យគាត់ដើរតួជាដៃគូនៅក្នុងដំណើរការនៃការធ្វើសម្ភាស

◦ ធានាថាអ្នកពិគ្រោះយោបល់ខាងផ្នែកចិត្តសាស្រ្ត និងអ្នកច្បាប់ មានភាពឯករាជ្យពេញលេញ ហើយមិនដឹងពីស្ថានភាពដែលមានការពាក់ព័ន្ធទៅនឹងរឿងក្តី ដូចជា សាក្សីដែរ ។

- ការវាយតម្លៃមុនការសម្ភាស

មុននឹងគ្រោងធ្វើការសម្ភាសណាមួយជាមួយជនរងគ្រោះ ក្រុមសម្ភាសគួរធ្វើការវាយតម្លៃមុនការសម្ភាស អាស្រ័យទៅលើព័ត៌មានដែលមានទាំងអស់ ទាក់ទងទៅនឹងមូលដ្ឋាននៃរឿងក្តីលក្ខខណ្ឌនាពេលបច្ចុប្បន្នរបស់ជនរងគ្រោះ និងកាលៈទេសៈនៃរឿងក្តី ។ គោលបំណងនៃការវាយតម្លៃនេះ គឺធ្វើការកំណត់ពីយុទ្ធសាស្រ្តនៃការរៀបចំសម្ភាសឱ្យទទួលបានប្រសិទ្ធភាពល្អបំផុត ។

នៅពេលដែលជនរងគ្រោះ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ទីភ្នាក់ងារគាំទ្រដល់ជនរងគ្រោះ ការវាយតម្លៃនេះអាចជាផ្នែកមួយយ៉ាងសំខាន់ នៃយុទ្ធសាស្រ្តជាដៃគូ ដើម្បីធ្វើការត្រៀមរៀបចំសម្ភាស ហើយគួរតែផ្តល់នូវការប្រឹក្សាខាងផ្នែកចិត្តសាស្រ្ត និងច្បាប់ ។ ការងារជាក្រុមគឺត្រូវតែពិភាក្សា និងយល់ព្រមទៅលើយុទ្ធសាស្រ្ត ដែលមានគោលការណ៍ស្តីពីការដោះស្រាយទៅលើជនរងគ្រោះប្រកបដោយប្រសិទ្ធភាព កត្តាជាក់លាក់ណាមួយ ឬសេចក្តីត្រូវការដែលត្រូវដោះស្រាយ គោលការណ៍ជាក់លាក់ស្តីពីពេលវេលាជាអតិបរមាដែលចំណាយទៅលើការសម្ភាសលើកដំបូង និងការលើកជាសំណួរជាក់លាក់ណាមួយ ដែលគួរតែជៀសវាងនៅក្នុងដំណាក់កាលនៃការធ្វើសម្ភាសលើកទីមួយ ។ ចំណុចទាំងនេះ គឺមានសារៈសំខាន់ខ្លាំងណាស់ ជាពិសេស ចំពោះរឿងក្តីទាំងឡាយណាដែលគេដឹង ឬជឿជាក់ថា ជនរងគ្រោះទទួលរងក្នុងកម្រិតណាមួយនៃការប៉ះពាល់ខាងផ្នែកផ្លូវអារម្មណ៍ ។

◦ ការវិភាគទៅលើភស្តុតាង មុនការធ្វើសម្ភាស

មុននឹងធ្វើការសម្ភាស វាជាការសំខាន់សម្រាប់មន្រ្តីសម្ភាសធ្វើការពិនិត្យ ទៅលើកាលៈទេសៈនានា ដែលបានដឹងពីរឿងក្តី និងធ្វើការកំណត់បទល្មើសដែលអាចប្រព្រឹត្តទៅលើជនរងគ្រោះ ។ បន្ទាប់មក អ្នកសម្ភាសគួរតែធ្វើការវិភាគទៅលើភស្តុតាង ដែលមានរួចទាក់ទងទៅនឹងបទល្មើស ដែលអាចកើតឡើង និងធ្វើការវិភាគទៅលើបញ្ហាជាក់លាក់បន្ថែមទៀត ពីភស្តុតាងដែលត្រូវទទួលបានពីជនរងគ្រោះ ។

◦ ពេលវេលាការងារ និងការគ្រោងធ្វើការសម្ភាស

មន្រ្តីសម្ភាស គួរតែព្យាយាមកំណត់អំពីកាលវិភាគឱ្យបានត្រឹមត្រូវ តាមលំដាប់លំដោយនៃការធ្វើសម្ភាស ដោយឈរលើមូលដ្ឋាននៃលក្ខខណ្ឌនានាដែលបានដឹងពីជនរងគ្រោះ និង

មូលដ្ឋាននៃរឿងក្តី ។

**២. គំរូ PEACE ៖ E-ការអនុវត្ត និងពន្យល់**

ការជួបជនរងគ្រោះលើកដំបូង គឺមានសារៈសំខាន់ខ្លាំងណាស់ ប្រសិនបើការជួបនេះមិនបានដោះស្រាយជាលក្ខណៈអាជីពនោះទេ នោះឱកាសក្នុងការអនុវត្តការសម្ភាសយកភស្តុតាងដែលមានគុណភាពខ្ពស់ នឹងត្រូវកាត់បន្ថយយ៉ាងខ្លាំង ។ ចូរចងចាំនូវវិធាន ៖ អ្នកមិនអាចទទួលបានឱកាស ជាលើកទីពីរ ក្នុងការបង្កើតអារម្មណ៍ជាលើកដំបូងនោះទេ ។




ការអនុវត្តការការសម្ភាស ៖ គោលបំណងនៃដំណាក់កាលនេះ គឺជាការចាប់ផ្តើមការងារដើម្បីឱ្យជនរងគ្រោះ មានការជឿជាក់ថា ការសម្ភាសរបស់ខ្លួន គឺគ្រប់គ្រងឡើងដោយក្រុមការងារអាជីព ដែលគួរទុកចិត្ត ដោយប្រើភាសាកាយវិការ ការណែនាំខ្លួន សុខភាព អារម្មណ៍សុវត្ថិភាព និងបង្កើតទំនាក់ទំនង ។

សង្ខេបចំណុចសំខាន់ៗនៅក្នុងដំណាក់កាលពន្យល់

**E-ពន្យល់-ភារកិច្ច**

- អះអាងពីការយល់ព្រមសម្ភាស
  ជានាថា ជនរងគ្រោះទទួលបាននូវការពន្យល់ពេញលេញពីសិទ្ធិ-អះអាងម្តងទៀតពីការយល់ព្រមសម្ភាស
- ភាពជាដៃគូ និងតួនាទី
  ពន្យល់ពីយុទ្ធសាស្ត្រ និងភាពជាដៃគូជាមួយអ្នកសម្ភាស-ពន្យល់ពីអ្វី ដែលបុគ្គលម្នាក់ៗនៅក្នុងបន្ទប់នឹងត្រូវធ្វើ ក្នុងអំឡុងពេលនៃការសម្ភាស
- ឧបករណ៍
  បង្ហាញឧបករណ៍ដែលប្រើប្រាស់ដើម្បីធ្វើកំណត់ហេតុក្នុងការសម្ភាស-ពន្យល់ពីរបៀបដំណើរការ និងពីអ្វីដែលនឹងកើតមានចំពោះកំណត់ហេតុសម្ភាស
- គោលបំណង
  ពន្យល់ថា គោលបំណងគឺផ្តល់ឱកាសដល់ជនរងគ្រោះក្នុងការរៀបរាប់រឿងហេតុឱ្យបានលម្អិត-មិនត្រូវសន្យា ឬធ្វើការធានាណាមួយ ដែលមិនអាចធ្វើកើត
- វិធីសាស្ត្រ
  ពន្យល់ពីពេលវេលានៃការសម្ភាស ភាពចាំបាច់នៃព័ត៌មានលម្អិត-ពន្យល់ពីភាពពាក់ព័ន្ធរវាងព័ត៌មានបំពេញបន្ថែម និងភាពជឿជាក់
- វិធានសម្ភាស
  ពន្យល់ពីវិធាននៃការសម្ភាស-ភាពលំបាកនៃការរំលឹកពីអង្គហេតុ ភារកិច្ចនិយាយពីការពិត

ក្នុងដំណាក់កាលពន្យល់ មន្ត្រីសម្ភាសគួរធ្វើការអះអាងម្តងទៀតពីការយល់ព្រមសម្រាប់ ការសម្ភាស ពន្យល់ឱ្យបានលម្អិតដល់ជនរងគ្រោះ ពីដំណើរការសម្ភាស និងតួនាទីរបស់ម្នាក់ៗ ដែលមានវត្តមាននៅក្នុងបន្ទប់សម្ភាស ។ ការសម្ភាសត្រូវកត់ត្រាជាលាយលក្ខអក្សរ ប្រសិនបើអាចធ្វើទៅបាន ត្រូវថតវីដេអូ ឬថតសំឡេង ។ មន្ត្រីសម្ភាសគួរតែពន្យល់ពីគោលបំណងទូទៅដល់ជនរងគ្រោះ ដើម្បីស្វែងរកភស្តុតាង អង្គហេតុ និងរកយុត្តិធម៌តាមផ្លូវច្បាប់ ប៉ុន្តែមិនមានន័យថា ជនល្មើសពិតជាត្រូវបានគេផ្តន្ទាទោសនោះទេ ពីព្រោះការសម្រេចផ្តន្ទាទោសគឺជាអំណាចរបស់តុលាការ ។ មន្ត្រីសម្ភាសគួរតែជៀសវាងការសន្យាដាក់លាក់ណាមួយដែលខ្លួនមិនអាចធ្វើបាន ។

ជំហានបន្ទាប់ គឺពន្យល់ជនរងគ្រោះ អំពីវិធីសាស្ត្រនៃការសម្ភាសដែលមានសារសំខាន់ ៖

- ព័ត៌មាន និងការពន្យល់ គឺអាចជួយកាត់បន្ថយពីការថប់អារម្មណ៍ និងសេចក្តីភ័យខ្លាចដែលមិនអាចជៀសវាងបាន ក្នុងដំណើរការនៃការសម្ភាស នឹងកើតមានឡើងចំពោះជនរងគ្រោះ

- ពេលដែលជនរងគ្រោះអាចយល់ពីដំណើរការ និងមូលហេតុនានានៃដំណើរការនោះ ជនរងគ្រោះអាចចូលរួមយ៉ាងសកម្មលើការសម្ភាស ជាជាងដែលជនរងគ្រោះមានអារម្មណ៍ធុញទ្រាន់
- វាអាចបង្ហាញពីការប្ដេជ្ញាចិត្ត ទៅលើយុទ្ធសាស្ត្រនៃភាពជាដៃគូ
- វាអាចធ្វើឱ្យអ្នកសម្ភាស បន្តនូវដំណាក់កាលនៃទំនាក់ទំនងជាមួយជនរងគ្រោះ និងបន្តវាយតម្លៃពីស្ថានភាពអារម្មណ៍ និងសមត្ថភាពយល់ដឹងរបស់ជនរងគ្រោះ ។ ជាចុងក្រោយ មន្ត្រីសម្ភាសគួរពន្យល់ជនរងគ្រោះពីវិធាននៃការធ្វើសម្ភាសមួយចំនួន ដូចជា ឱ្យគាត់ប្រាប់ និងបញ្ជាក់សំណួរ ប្រសិនបើគាត់មិនយល់ ហើយបើគាត់មិនចាំបានទេ ឆ្លើយថាចាំមិនបាន ។ ការសម្ភាសអាចមានសំណួរជាច្រើន ដែលទាក់ទងទៅនឹងព្រឹត្តិការណ៍មួយចំនួន ដែលធ្វើឱ្យ គាត់មានការខឹងសម្បា ឬមានការឈឺចាប់ នៅពេលដែលគាត់រំលឹកពីព្រឹត្តិការណ៍នោះ ។ ជនរងគ្រោះអាចមានពេលវេលាក្នុងការឆ្លើយសំណួរដោយពេញលេញ និងស្មោះត្រង់ ហើយសម្រាក នៅពេលណាមួយដែលចាំបាច់ និងមានសំណួរដែរ ឬទេ ។

**៣. គំរូ PEACE ៖ A-ការរៀបរាប់រឿងក្តី**

នៅក្នុងបរិបទគំរូ PEACE ពាក្យ រៀបរាប់រឿងក្តី គឺជាដំណាក់កាលដែលជនរងគ្រោះនិយាយរឿងរបស់គាត់ បន្ទាប់មក អ្នកសម្ភាសអភិវឌ្ឍរឿងនោះ ឱ្យមានលក្ខណៈលម្អិតតាមរយៈជំនាញសាកសួរ ។ នេះគឺជាដំណាក់កាលទីបី និងសំខាន់បំផុតនៃគំរូ PEACE នៅក្នុងដំណាក់កាលនេះ ជនរងគ្រោះដែលជាសាក្សី នឹងត្រូវសួរជាលើកទីមួយឱ្យនិយាយប្រាប់រឿងទាំងមូល នៅក្នុងបរិបទរកភស្តុតាង ។ សង្ខេបភារកិច្ចសំខាន់ៗនៃដំណាក់កាលរៀបរាប់រឿងក្តី៖

**A-ការនិយាយរឿងហេតុ**

ដំណាក់កាលសំខាន់ៗនៃគំរូ PEACE
ការនិយាយរឿងជាលើកទីមួយ ទាក់ទងនឹងភស្តុតាង អាចមានប្រសិទ្ធភាពបំផុត

បែបបទសម្ភាស
ជាលក្ខណៈអាជីព ចៀសវាងលក្ខណៈផ្លូវការ និងបង្ហាញថា ដឹងពីរឿងក្តី ស្តាប់ និងរក្សាភាសាកាយវិការឱ្យបានល្អ និងទំនាក់ទំនងដោយក្រសែភ្នែក

កាត់សម្តី
មិនត្រូវកាត់សម្តីនៅពេលនិយាយរឿងហេតុ-រក្សាសំណួររហូតដល់ជនរងគ្រោះបញ្ចប់ការនិយាយរឿង

ប្លង់នៃសាច់រឿង
ទទួលទិដ្ឋភាពទូទៅនៃពេលវេលា-ចៀសវាងភាពលម្អិតពេក នៅពេលចាប់ផ្តើម-ស្វែងរកប្លង់នៃប្រវត្តិរឿងហេតុ-កាលបរិច្ឆេទ ទីកន្លែង លក្ខណៈបុគ្គល និង សកម្មភាពសំខាន់ៗ

សំណួរ
ប្រើប្រាស់ជំនាញសាកសួរ ដើម្បីអភិវឌ្ឍប្លង់នៃសាច់រឿង ឱ្យទៅជាការនិយាយរឿងហេតុលម្អិត-មិនត្រូវគាបសង្កត់ឱ្យឆ្លើយ

- របៀបសាកសួរនៅពេលសម្ភាស

មន្ត្រីសម្ភាសគួរតែអនុវត្តតាមឱ្យបានហ្មត់ចត់ ត្រឹមត្រូវ ពីព្រោះជនរងគ្រោះដោយសារអំពើជួញដូរមនុស្សភាគច្រើន ទទួលរងនៅក្នុងកម្រិតមួយ ចំនួននៃការប៉ះពាល់ផ្លូវអារម្មណ៍ ដែលធ្វើឱ្យគេក្លាយទៅជាសាក្សីដែលងាយទទួលរងគ្រោះថ្នាក់ ។ ដើម្បីធ្វើឱ្យមានការរីកចម្រើនដល់ដំណើរការសម្ភាស មន្ត្រីសម្ភាសត្រូវសម្របសម្រួលរបៀបសម្ភាសឱ្យមានលក្ខណៈអាជីព មិនត្រូវមានលក្ខណៈផ្លូវការខ្លាំងពេក មិនត្រូវបង្ហាញថាខ្លួនបានដឹងរឿងនោះទេ ។

មន្ត្រីសម្ភាសត្រូវស្តាប់ដោយយកចិត្តទុកដាក់នៅដំណាក់កាលដែលជនរងគ្រោះរំលឹកពីអ្វីដែលបានកើតឡើង ត្រូវរក្សាទំនាក់ទំនងភ្នែកជាមួយជនរងគ្រោះ ប៉ុន្តែត្រូវប្រុងប្រយ័ត្នមិនត្រូវសម្លឹងមើលយូរពេកទេ ហើយត្រូវលើកទឹកចិត្តតាមរយៈ ងក់ក្បាល ឬក៏និយាយថា អញ្ចើញមាន" "បាទ" ឬ ប្រើពាក្យ "សុំបន្តទៀត" ឬ "និយាយថែមទៀត" "ប្រសាសន៍តទៀត ។

មន្ត្រីសម្ភាសត្រូវអនុញ្ញាតឱ្យជនរងគ្រោះមានពេលសមស្របក្នុងការឆ្លើយសម្ភាស មិនត្រូវកាត់សម្តីនៅពេលរៀបរាប់រឿងហេតុ ពីព្រោះវារារាំងដល់ការរំលឹកឡើងវិញ ។ គួរតែអនុញ្ញាតឱ្យជនរងគ្រោះប្រមូលអារម្មណ៍ ដើម្បីនិយាយការពិតពីព្រឹត្តិការណ៍មួយចំនួន ។

នៅក្នុងការសម្ភាសដែលមានការពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋផ្សេងទៀត ជាធម្មតាជនរងគ្រោះ អាចរំលឹកពីទំនាក់ទំនងរវាងព្រឹត្តិការណ៍ចម្បងនៃរឿងក្តី ទៅនឹងព្រឹត្តិការណ៍ផ្សេងទៀត ។ ដូចនេះ ជនរងគ្រោះត្រូវការរំលឹក ពីដំណាក់កាលលំដាប់លំដោយនៃរឿងហេតុ រហូតដល់ព្រឹត្តិការណ៍ចម្បង ដោយប្រើរយៈពេលយូរ ពីព្រោះជនរងគ្រោះពិបាកក្នុងការរំលឹកអំពីការចងចាំ និង/ឬការប៉ះពាល់ខាងផ្នែកអារម្មណ៍ អាចបង្អាក់ការចងចាំពីព្រឹត្តិការណ៍ឱ្យបានស៊ីចង្វាក់ ។ ដូចនេះ ក្រុមសម្ភាសត្រូវរៀបចំ និងបែងចែកយុទ្ធសាស្ត្រឱ្យបានល្អក្នុងការសម្ភាស ដើម្បីទទួលបានភស្តុតាងសំខាន់ៗ ទាំងអស់ នៅក្នុងដំណាក់កាលនីមួយៗនៃរឿងក្តី ។

វិធីសាស្ត្រក្នុងដំណាក់កាលដំបូងនៃការសម្ភាស គឺស្នើឱ្យជនរងគ្រោះ ផ្តល់ពីចំណុចបប្លង់គ្រួសៗនៃរឿងរ៉ាវរបស់ខ្លួន ដោយមិនរៀបរាប់ឱ្យបានលម្អិតនៅក្នុងដំណាក់នេះទេ ។ ជនរងគ្រោះគួរតែត្រូវបានគេឱ្យបញ្ជាក់ពីពេលវេលានៃរឿងរ៉ាវរបស់ខ្លួន ពេលណាដែលគាត់ត្រូវបាន គេជ្រើសរើសលើកដំបូង ហើយនៅទីកន្លែងណា តើគាត់បានស្នាក់នៅប៉ុន្មានប្រទេស ហើយគេដឹកគាត់ដោយរបៀបម៉េចតើសកម្មភាពកេងប្រវ័ញ្ចប្រភេទណាខ្លះ ដែលគេតម្រូវឱ្យគាត់ធ្វើ តើពេលណាដែលការកេងប្រវ័ញ្ចត្រូវបានបញ្ចប់ អ្នកណាជាអ្នកជួញដូរគាត់ ។

គោលបំណងនេះ គឺដើម្បីទទួលបានពីរូបភាពទូលំទូលាយ តាមរយៈពាក្យសម្តីរបស់ជនរងគ្រោះ ដែលធ្វើឱ្យអ្នកសម្ភាសអាចទទួលបានពីអត្ថន័យទាំងមូលនៃរឿងរ៉ាវ និងទំហំនៃពេលវេលារឿងក្តី ។

ចំពោះការសម្ភាសបន្តបន្ទាប់ ដោយអាស្រ័យលើចំណុចសំខាន់ៗ ដែលជនរងគ្រោះបានផ្តល់ឱ្យអ្នកសម្ភាសគួរតែបែងចែកដំណើរការនៃការសម្ភាសជាផ្នែកៗ តាមលំដាប់លំដោយ ដែលបង្ហាញពីដំណាក់កាលសំខាន់ៗនៃរឿងរ៉ាវរបស់ជនរងគ្រោះ ។ ឧទាហរណ៍ ប្រសិនបើជនរងគ្រោះ ត្រូវ

បានគេជ្រើសរើសនៅក្នុងប្រទេសមួយ ហើយបន្ទាប់មក ត្រូវបានគេជួញដូរ និងកេងប្រវ័ញ្ច នៅក្នុងប្រទេសពីរផ្សេងទៀត ។ នៅទីបញ្ចប់ មុននឹងជនរងគ្រោះត្រូវបានគេជួយសង្គ្រោះនៅ ក្នុងប្រទេសទី៤ ដែលនៅទីនោះការសម្ភាសកំពុងតែចាប់ផ្តើម ដូចនេះ អ្នកសម្ភាសគួរតែបែងចែកយុទ្ធសាស្ត្រនៃការធ្វើសម្ភាសជា ៤ ផ្នែកដាច់ដោយឡែកពីគ្នា ហើយជាដំបូង ផ្តោតអារម្មណ៍ទៅលើការសម្ភាសចំពោះព្រឹត្តិការណ៍ ដែលបានកើតឡើងនៅក្នុងប្រទេសដែលជ្រើសរើសជនរងគ្រោះ ។ ការសម្ភាសគួរតែធ្វើតាមដំណើរការដូចគ្នា ចំពោះដំណាក់កាលទាំង ៤ ប៉ុន្តែនៅក្នុងកាលៈទេសៈនេះ គួរតែសួរជនរងគ្រោះឱ្យផ្តល់ភស្តុតាងលម្អិតពីព្រឹត្តិការណ៍ដែលបានកើតឡើងនៅក្នុងប្រទេស ដែលគាត់ត្រូវបានគេជ្រើសរើសដោយជនសង្ស័យ ។ បន្ទាប់ទៀត ការសម្ភាសគួរតែធ្វើនៅក្នុងរបៀបដូចគ្នា ដែលទាក់ទងទៅនឹងព័ត៌មានលម្អិត ដែលបានកើតឡើងលើជនរងគ្រោះ នៅក្នុងប្រទេសមួយក្នុងចំណោមប្រទេសទាំង ៣ ដែលជនរងគ្រោះត្រូវបានគេជួញដូរជាលើកដំបូង ហើយប្រើវិធីនេះក្នុងការសម្ភាសជាបន្តបន្ទាប់ ។

វិធីសាស្ត្រក្នុងការគ្រប់គ្រងលើដំណើរការនៃការប្រមូលភស្តុតាងពាក់ព័ន្ធទាំងអស់ នៅក្នុងអំឡុងពេលដែលជនរងគ្រោះរំលឹកពីព្រឹត្តិការណ៍ដែលបានកើតឡើងចំពោះខ្លួន ឱ្យមានប្រសិទ្ធភាព គឺអាស្រ័យទៅលើកាលៈទេសៈនានានៃរឿងក្តីនីមួយៗ ប៉ុន្តែនៅក្នុងរឿងក្តីណាដែលអំពើជួញដូរមនុស្សស្ថិតនៅក្នុងរយៈពេលយូរ វាគឺជាការពិបាកក្នុងការពិនិត្យមើលពីរបៀបដំណើរការផ្សេងទៀត ប្រកបដោយប្រសិទ្ធភាព ប្រសិនបើមិនបំបែករឿងរ៉ាវជាផ្នែកៗ ។

សំណួរសម្រាប់ធ្វើការសម្ភាស ៖ ដំណាក់កាលបន្ទាប់នៃដំណើរការសម្ភាស គឺការប្រើសំណួរដើម្បីពង្រីក ឬបញ្ជាក់ឱ្យបានច្បាស់លាស់ ពីចំណុចភស្តុតាងនានា ដែលជនរងគ្រោះ រំលឹកពីអ្វីដែលបានកើតឡើងចំពោះខ្លួន នៅក្នុងអំឡុងពេលនិយាយប្រាប់ពីរឿងក្តី ។

- ចំណុចជាទូទៅនៃរបៀបសួរសំណួរ

រក្សាសំណួរឱ្យមានលក្ខណៈសាមញ្ញ ៖ សំណួរគួរតែសួរម្តងមួយៗ ខ្លីៗ ហើយសាមញ្ញ ជៀសវាងការប្រើឃ្លាអវិជ្ជមានផ្ទួនៗគ្នាឬការរៀបចំឃ្លាពិបាកផ្សេងទៀត។ វាជាការសំខាន់យ៉ាងពិសេស នៅពេលសម្ភាសជាមួយជនរងគ្រោះជាជនបរទេស ដែលការសម្ភាសធ្វើឡើងតាមរយៈការបកប្រែ ។

ប្រើសំឡេងគាំទ្រ ៖ សំណួរគួរតែធ្វើឡើងដោយមានការលើកដាក់សំឡេង ។ វាមានសារៈសំខាន់ណាស់ដែលត្រូវជៀសវាងការប្រើប្រាស់សំឡេងដែលមានលក្ខណៈអវិជ្ជមាន ។

មិនត្រូវប្រើបែបបទគាបសង្កត់ ៖ ជនរងគ្រោះដោយសារការជួញដូរ អាចទទួលរងនូវជំងឺថប់ផ្លូវអារម្មណ៍ អាចឆ្លើយសម្របតាមសំណួរចង់បាន ភាពវៃឆ្លាតនិងការសិក្សាមានកម្រិត ហើយមានអារម្មណ៍គាបសង្កត់ដោយមានមន្ត្រីនគរបាលអម ។ ដោយមូលហេតុទាំងអស់នេះហើយ សំណួរបង្ខំចម្លើយទៅលើជនរងគ្រោះឱ្យឆ្លើយ គឺអាចទទួលបានចម្លើយសម្របតាមសំណួរ ដោយជនរងគ្រោះគិតថា នឹងសម្រាលគំនាបមកលើខ្លួន និង/ឬជាចម្លើយដែលអ្នកសម្ភាសចង់ឮ ការធ្វើដូចនេះ គឺផ្ទុយទៅនឹងចម្លើយដែលឆ្លុះបញ្ចាំងពីការរំលឹកចងចាំរបស់ខ្លួន ។

ជៀសវាងការប្រើពាក្យសម្ងាត់ ៖ ការប្រើពាក្យសម្ងាត់ ឬពាក្យបច្ចេកទេសផ្សេងទៀត គួរតែជៀសវាង ពីព្រោះវាអាចធ្វើឱ្យមានការភ័ន្តច្រឡំដល់ជនរងគ្រោះ ឬវាមិនអាចធ្វើឱ្យមានការបក

ប្រែប្រកបដោយភាពសុក្រឹត ប្រសិនបើមានការប្រើប្រាស់អ្នកបកប្រែ ។

ប្រើពាក្យរបស់ជនរងគ្រោះ ៖ អ្នកសម្ភាសគួរតែព្យាយាមប្រើពាក្យ ដែលជនរងគ្រោះបានប្រើនៅក្នុងការរៀបរាប់រឿងក្តីរបស់ខ្លួន ហើយនៅក្នុងករណីកេងប្រវ័ញ្ចផ្លូវភេទ ដូចជាភៀវរបស់គាត់ និងសកម្មភាពពេស្យាចារ ជាដើម ។

មិនត្រូវប្រើភាសាអាក្រក់នោះទេ ៖ ការប្រើភាសាត្រឹមត្រូវ និងមានលក្ខណៈអាជីព គឺមានសារៈសំខាន់ខ្លាំងណាស់ ។ ភាសាផ្លូវភេទ ឬភាសាអសីលធម៌ដទៃទៀត ឬសញ្ញានៃផ្លូវភេទ មិនគួរប្រើនៅក្នុងដំណាក់កាលណាមួយឡើយ ទោះបីជាការប្រើភាសានោះស៊ីចង្វាក់នឹងពាក្យរបស់ជនរងគ្រោះក៏ដោយ ។

លើកទឹកចិត្តដោយប្រុងប្រយ័ត្ន ៖ វាអាចទទួលយកបាន ក្នុងការលើកទឹកចិត្តដល់ជនរងគ្រោះ ឬធានាជនរងគ្រោះម្តងទៀតថា គាត់បានធ្វើការងារដែលត្រឹមត្រូវ ដរាបណាការលើកទឹកចិត្តនេះ មិនឈានទៅដល់ការប៉ុនប៉ងណាមួយ ដើម្បីឱ្យជនរងគ្រោះបន្តនិយាយលើសពីអ្វីដែលគាត់ចង់និយាយ ។ ការធ្វើឱ្យរីករាយ អាចជួយឱ្យជនរងគ្រោះមានភាពរំសាយអារម្មណ៍ និងលើកទឹកចិត្តឱ្យគាត់និយាយដោយសេរី ប៉ុន្តែការប្រើប្រាស់នេះ គួរតែយកចិត្តទុកដាក់ខ្លាំងបំផុត ដោយហេតុថា វាមានសារៈសំខាន់ណាស់ ក្នុងការជៀសវាងការបង្ហាញអារម្មណ៍មើលងាយ ឬក៏បង្ហាញថា រឿងរ៉ាវរបស់ជនរងគ្រោះមិនមានការចាប់អារម្មណ៍ជាពិសេសណាមួយនោះ ជាធម្មតា វានឹងមិនមានលក្ខណៈសមរម្យទេនៅក្នុងរយៈពេលនៃការធ្វើសម្ភាសលើកដំបូង ។

បង្កើតឱ្យមានភាពលំដាប់លំដោយ ៖ ជាធម្មតា រឿងរ៉ាវជួញដូរមនុស្ស គឺមានការពាក់ព័ន្ធទៅនឹងរយៈពេលយូរអង្វែង ហើយជាធម្មតា វាមានការពិបាកសម្រាប់ជនរងគ្រោះ ក្នុងការរៀបរាប់ពីព្រឹត្តិការណ៍ឱ្យបានសុក្រឹត ទៅតាមពេលវេលាជាក់លាក់ណាមួយ ។ ប៉ុន្តែ វាគឺជាការសំខាន់ សម្រាប់គុណភាពនៃភស្តុតាង គឺតម្រូវឱ្យមានភាពសុក្រឹត តាមដែលអាចធ្វើទៅបាន ទៅតាម កាលប្រវត្តិនៃបទល្មើស និងពេលវេលាជាក់លាក់នៃព្រឹត្តិការណ៍ណាមួយ (ដូចជា កាលបរិច្ឆេទនៃ ការដឹកជញ្ជូន និងការរំលោភ ដែលបានកើតឡើង...) ដែលមានមូលហេតុពីរយ៉ាង ៖ (១) ការកំណត់ភស្តុតាងបំពេញបន្ថែម គឺងាយស្រួលក្នុងការទទួលបាន ប្រសិនបើកាលប្រវត្តិមានភាពសុក្រឹត តាមដែលអាចធ្វើទៅបាន (២) យុទ្ធសាស្ត្រទូទៅរបស់មេធាវីជនសង្ស័យ គឺធ្វើឱ្យជនរងគ្រោះដែលជា សាក្សីមានការភាន់ច្រឡំទៅលើកាលបរិច្ឆេទ ពេលវេលា និងទីកន្លែង...ហើយមិនអាចបញ្ជាក់ពី ពេលវេលាច្បាស់លាស់ នៃព្រឹត្តិការណ៍ណាមួយដែលបានកើតឡើង ហើយជាសញ្ញាមួយបញ្ជាក់ថា សាក្សីនោះមិនគួរទុកចិត្ត ឬមានជំនឿជឿជាក់ទាំងស្រុងបានឡើយ ។

រំលឹកពីពេលវេលានៃរឿងរ៉ាវ ៖ យោងតាមបញ្ហានេះ ជួនកាលវាមានសារៈសំខាន់ក្នុងការសំណូមពរឱ្យជនរងគ្រោះ រៀបចំព្រឹត្តិការណ៍ជាក់លាក់ណាមួយ ទៅនឹងអ្វីមួយដែលមានសារសំខាន់ចំពោះគាត់ ជាជាងសុំឱ្យគាត់ចាំពី ឈ្មោះ ថ្ងៃ ខែ ឆ្នាំ។ ប្រសិនបើជនរងគ្រោះអាចផ្តល់ពីកាលបរិច្ឆេទបាន វាជាការពិត ដែលភស្តុតាងនោះមានគុណភាពខ្លាំងបំផុត ប្រសិនបើជនរងគ្រោះមិនអាចចាំបាន ជនរងគ្រោះគួរតែត្រូវបានគេសុំឱ្យដាក់ពេលវេលាជាក់លាក់នោះទៅនឹងអ្វីមួយ ។

ឧទាហរណ៍សាមញ្ញគឺថា ជនរងគ្រោះគួរតែត្រូវបានគេសុំឱ្យបញ្ជាក់ ថាតើគាត់បានចាកចេញពីប្រទេសរបស់គាត់ មុន ឬបន្ទាប់ពីបុណ្យចូលឆ្នាំសកលឆ្នាំ២០០៣ ឬក៏ព្រឹត្តិការណ៍ផ្សេងទៀតទាក់ទងទៅនឹងសាសនា វប្បធម៌ ឬព្រឹត្តិការណ៍ដែលទាក់ទងនឹងគ្រួសារ ដូចជា មុន ឬក្រោយថ្ងៃបុណ្យកំណើតប្អូនស្រីរបស់គាត់។ល។ គោលបំណងនេះ គឺជួយដល់ជនរងគ្រោះ ក្នុងការ ដាក់ព្រឹត្តិការណ៍ជាក់លាក់ណាមួយ ទៅនឹងពេលវេលាដែលបានកំណត់ ដែលពេលវេលានោះមានខ្លឹមសារបំផុតចំពោះគាត់ ជាជាងកាលបរិច្ឆេទពិសេសណាមួយ ។

- ប្រើសំណួរដើម្បីអភិវឌ្ឍព័ត៌មានលម្អិត-កម្រិតបួននៃសំណួរ




នៅក្នុងករណីធ្វើសម្ភាសជាមួយកុមារ សំណួរដែលលើកឡើងដោយមន្ត្រីសម្ភាស ត្រូវរៀបចំ ផែនការដោយការប្រុងប្រយ័ត្នខ្លាំង ដើម្បីធានាថា ចម្លើយដែលផ្តល់ពីជនរងគ្រោះ គឺត្រូវមានភាពសុក្រឹត តាមដែលអាចធ្វើទៅបាន ហើយជៀសវាងពីឥទ្ធិពលដែលអាចធ្វើឱ្យមានភាពគ្រោះថ្នាក់

កើតឡើង ។ ឧទាហរណ៍ ៖ ជនរងគ្រោះនឹងផ្តល់ចម្លើយច្រើនដែលខ្លួនយល់ឃើញថា មន្ត្រីសម្ភាសចង់ដឹងចង់ឮ ជាជាងការផ្តល់ចម្លើយដោយមានភាពសុក្រឹត តាមសំណួររបស់មន្ត្រីសម្ភាសនោះ ។ បញ្ហាបែបនេះ បានកើតមានឡើងច្រើន ចំពោះការសម្ភាសរឿងក្តីជួញដូរមនុស្ស ។ ជនរងគ្រោះដោយសារអំពើជួញដូរមនុស្ស គឺជាអ្នកដែលងាយរងគ្រោះ ដោយមានមូលហេតុជាច្រើន៖

- ជនរងគ្រោះអាចទទួលរងនៅក្នុងកម្រិតណាមួយនៃការប៉ះពាល់ផ្លូវអារម្មណ៍ ដែលអាចនឹងទទួលឥទ្ធិពលគ្រោះថ្នាក់បាន
- អាចកើតមានឡើងតាមប្រវត្តិរបស់ខ្លួន និងបទពិសោធន៍ផ្ទាល់ខ្លួន ជាមួយមន្ត្រីអនុវត្តច្បាប់ អាចធ្វើឱ្យពួកគេមានការប្រុងប្រយ័ត្ន និងមានអារម្មណ៍ត្រូវគេធ្វើបាប នៅពេលមានវត្តមានរបស់មន្ត្រីសម្ភាសជានគរបាល
- នៅក្នុងករណីជនរងគ្រោះជាជនបរទេស ភាសានិងវប្បធម៌ផ្សេងគ្នា អាចបង្កើននូវគ្រោះថ្នាក់ ដែលនឹងអាចកើតមានឡើង ពីការយល់ច្រឡំ និងចម្លើយមិនមានភាពសុក្រឹត ។ ជាលទ្ធផលនៃកត្តានីមួយៗ ឬកត្តាទាំងអស់ គឺមានភាពគ្រោះថ្នាក់យ៉ាងខ្លាំងដែលជនរងគ្រោះនឹងងាយទទួលរងពីសំណូមពរ ឬផ្តល់ចម្លើយមិនមានភាពសុក្រឹត ដោយមូលហេតុដូចខាងក្រោម៖
  - ជាញឹកញាប់ ជនរងគ្រោះដែលមានការប៉ះពាល់ផ្លូវអារម្មណ៍ ទទួលរងនូវការបាត់បង់ការចងចាំ ដូចនេះ ជនរងគ្រោះអាចប្រឌិតចំពោះចម្លើយរបស់ខ្លួន ដើម្បីបំពេញការខ្វះខាតនៅក្នុងការចងចាំ ដែលជាវិធានការការពារខ្លួនឯង
  - ប្រសិនបើ របៀបសំណួរដែលលើកឡើង មានលក្ខណៈជិតពេក ឬស៊ីចង្វាក់ពេកទៅនឹងអង្គហេតុ ឬលើសពីនេះទៀត អាចមានលក្ខណៈធ្ងន់ធ្ងរ ដោយជនរងគ្រោះមានអារម្មណ៍ថា អ្នកសម្ភាសចង់ឮពីរឿងនោះ ជាជាងការបង្ហាញអ្វីមួយដែលមានភាពសុក្រឹតទៅនឹងអង្គហេតុ ដើម្បីឱ្យរួចខ្លួនពីការឆ្លើយសម្ភាស ។

នៅពេលទំនាក់ទំនងកើតមានរវាងជនរងគ្រោះ និងអ្នកសម្ភាស នៅក្នុងអំឡុងពេលធ្វើសម្ភាសជាបន្តបន្ទាប់នោះ ជនរងគ្រោះអាចផ្តល់ចម្លើយដែលគាត់គិតថា ធ្វើឱ្យក្រុមសម្ភាសមានការសប្បាយចិត្ត ជាងការបង្ហាញចម្លើយដែលមានភាពសុក្រឹតទៅនឹងអ្វីដែលបានកើតឡើងចំពោះគាត់ ។

ដើម្បីធ្វើការគ្រប់គ្រងទៅលើផលប៉ះពាល់ដែលអាចកើតមានឡើងទាំងនេះ ស្របពេលដែលចម្លើយរបស់ជនរងគ្រោះត្រូវបានគេពង្រីក និងត្រូវបានបញ្ជាក់ឱ្យបានច្បាស់ អ្នកសម្ភាសគួរតែប្រើ ប្រភេទសំណួរ៤ យ៉ាងដូចខាងក្រោមនេះ ទៅតាមព្រឹត្តិការណ៍ដែលគេកំណត់៖

- សំណួរបើក

ដោយយោងទៅតាមការអនុវត្តល្អៗនៅក្នុងការសម្ភាស អ្នកសម្ភាសគួរតែប្រើសំណួរបើក នៅក្នុងអំឡុងពេលនៃការសម្ភាសទាំងមូល ។ ការសម្ភាសដោយប្រើសំណួរបើក ត្រូវធ្វើឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន ដើម្បីទទួលចម្លើយប្រកបដោយសុក្រឹតភាពពីជនរងគ្រោះ ។

សំណួរបើកគឺជាសំណួរ ដែលអនុញ្ញាតឱ្យជនរងគ្រោះផ្តល់ព័ត៌មាន ឱ្យបានច្រើនពីបញ្ហាដែលទាក់ទងទៅនឹងសំណួរ ដោយមិនមានការប្រើវិធីស្នើឡើង ឬប្រើសំណួរនាំមុខឱ្យជនរង

គ្រោះ ឆ្លើយពីបញ្ហាជាក់លាក់ណាមួយ ។ ដោយហេតុថា អ្នកសម្ភាសព្យាយាមឱ្យជនរងគ្រោះផ្តល់ចម្លើយ ទូលំទូលាយអំពីព្រឹត្តិការណ៍ពិសេសណាមួយ អ្នកសម្ភាសអាចប្រើសំណួរបើក ដូចជា ៖

- តើអ្នកអាចប្រាប់ខ្ញុំច្រើនជាងនេះ ពីបញ្ហានេះដែរឬទេ?
- តើអ្នកអាចពន្យល់ខ្ញុំថែមទៀតបានដែរឬទេ?
- អ្នកបានបញ្ជាក់នៅក្នុងរឿងរ៉ាវរបស់អ្នកថា...បានកើតឡើង តើអ្នកអាចចងចាំអ្វីផ្សេងអំពីបញ្ហានេះបានដែរឬទេ?

  - សំណួរជាក់លាក់

គោលបំណងនៃការប្រើសំណួរនេះ គឺបង្កើនការផ្តោតអារម្មណ៍លើព្រឹត្តិការណ៍ជាក់លាក់ណាមួយ ដើម្បីរកភស្តុតាង ទទួលបានព័ត៌មានបន្ថែម ឬបញ្ជាក់ពីចំណុច ឬភាពមិនច្បាស់លាស់ណាមួយ ដែលអាចកើតមានឡើងនៅពេលដែលជនរងគ្រោះរំលឹកពីព្រឹត្តិការណ៍ ដែលកើតមានចំពោះខ្លួន ដោយមិនប្រើវិធីស្នើចម្លើយ ។ ស្តង់ដានៃប្រភេទសំណួរនេះមានដូចជា នៅកន្លែងណា ពេលណា អ្វី អ្នកណា ហេតុអ្វី?

ការប្រើសំណួរបែបនេះ តម្រូវឱ្យមានការយកចិត្តទុកដាក់ ហើយអ្នកសម្ភាសគួរធ្វើឃ្លាសំណួរជាក់លាក់នៅក្នុងរបៀបប្រដេញ ។ ឧទាហរណ៍៖ នៅក្នុងករណីកេងប្រវ័ញ្ចទាសភាព នៅតាមផ្ទះ ភស្តុតាងគន្លឹះដែលប្រើប្រាស់ដោយអ្នកសម្ភាស គឺលក្ខខណ្ឌទាសភាពដែលជនរងគ្រោះ ត្រូវបានគេគ្រប់គ្រង ។ ឃ្លាសំណួរនេះគួរតែធ្វើឡើងដូចជា តើម៉ោងណា ក្នុងថ្ងៃណា ដែលគេអនុញ្ញាតឱ្យសម្រាក? ឬតើគេឱ្យម្ហូបអាហារអ្វីខ្លះដល់អ្នក? ប្រសិនបើជនរងគ្រោះមិនអាចផ្តល់ព័ត៌មានទាំងនេះបាន អ្នកសម្ភាសគួរតែរៀបចំឃ្លាឱ្យបានជាក់លាក់ជាងនេះទៀត ដោយសួរថា តើអ្នកត្រូវបានគេអនុញ្ញាតឱ្យសម្រាកខ្លះដែរឬទេ? តើគេឱ្យអ្វីខ្លះដល់អ្នក ដើម្បីបរិភោគ? បើមានចម្លើយ អ្នកសម្ភាសត្រូវត្រឡប់មកសួរសំណួរដែលមានលក្ខណៈជាក់លាក់តិចជាង ដើម្បីពង្រីកចម្លើយឱ្យបានលម្អិត ។

តាមបទពិសោធន៍ ការប្រើសំណួរដោយផ្តើមពាក្យ "ហេតុអ្វី" តម្រូវឱ្យមានការប្រុង ប្រយ័ត្ន ពីព្រោះវាអាចក្លាយជាការចំអក ឬការចោទប្រកាន់ទៅវិញ ហើយករណីនេះ គឺជាការពិតនៅក្នុងការសម្ភាសជាមួយកុមាររងគ្រោះ ក្នុងរឿងក្តីជួញដូរមនុស្ស នៅពេលជនរងគ្រោះត្រូវបានគេលើកជាសំណួរថា ហេតុអ្វីបានជាអ្នកមិនរត់គេចខ្លួន នៅពេលអ្នកមានឱកាស? នេះគឺជាសំណួរ ដែលល្អបំផុត ហើយជាធម្មតា មានភស្តុតាងគ្រប់គ្រាន់ក្នុងការលើកជាសំណួរបែបនេះ ជាញឹកញាប់ ចម្លើយទៅនឹងសំណួរនេះ គឺជាការបង្ហាញពីកម្រិតភ័យខ្លាចរបស់ជនរងគ្រោះ ពីការបំពានមកលើខ្លួនបន្តទៀត ហើយជាការភ័យខ្លាចទៅនឹងការសងសឹក ចម្លើយទៅនឹងសំណួរនេះ គឺការបង្ហាញពីការគំរាមកំហែងទៅលើជនរងគ្រោះ ដែលធ្វើឡើងដោយជនល្មើសជួញដូរមនុស្ស ។

ប៉ុន្តែ ប្រសិនបើសំណួរលើកឡើងមានការបញ្ចេញសំឡេង ដោយមានលក្ខណៈដូចជាការសម្លុត ការចោទប្រកាន់ ឬសំណួរលើកឡើងដដែលៗ ដែលអាចធ្វើឱ្យជនរងគ្រោះ យល់ច្រឡំ ហើយយល់ថាខ្លួនត្រូវគេចោទថាជាអ្នកមានទោស ឬត្រូវគេរិះគន់មកលើខ្លួន ។ ដូចនេះ វាធ្វើឱ្យមានផលប៉ះពាល់ដល់ទំនាក់ទំនង និងភាពទុកចិត្តគ្នារវាងអ្នកស៊ើបអង្កេត និងជនរងគ្រោះ ហើយការ

ប្រើប្រាស់សំឡេង និងរបៀបធ្វើសំណួរ ត្រូវធ្វើឡើងឱ្យបានសមស្រប ឬធ្វើឡើង សម្រាប់តែជាការចាំបាច់នៅក្នុងការពន្យល់ ។ ផ្ទុយទៅវិញ ចំពោះការរិះគន់ គឺជាបញ្ហាដែលមិនគួរកើតមានឡើយ ។ ការជៀសវាងប្រើពាក្យ "ហេតុអ្វី" អាចកាត់បន្ថយភាពផលប៉ះពាល់ ដោយប្រើ សំណួរជំនួសវិញ ដូចជា តើអ្វីទៅដែលរារាំងអ្នកមិនឱ្យរត់គេចខ្លួន ឬតើមានអ្វីខ្លះដែលទប់ស្កាត់អ្នក មិនឱ្យរត់គេចខ្លួន ឬតើអ្នកអាចពន្យល់ខ្ញុំបានទេ តើអ្វីទៅដែលរារាំងអ្នក? ។

○ សំណួរបិទ

សំណួរបិទគឺជាសំណួរដែលធ្វើឡើងដើម្បីកំណត់នូវចម្លើយ ដែលអាចឆ្លើយបាន ហើយដែលជនរងគ្រោះត្រូវបានគេអនុញ្ញាតឱ្យជ្រើសរើសចម្លើយនៅក្នុងសំណួរនោះ ។ សំណួរបិទ ត្រូវបានគេប្រើ នៅពេលដែលការប្រើសំណួរបើក ឬសំណួរជាក់លាក់ ទទួលបរាជ័យដោយមិនទទួលបានភស្តុតាងលម្អិត ឬការបំភ្លឺលើចំណុចជាក់លាក់ណាមួយ ។

ផលប៉ះពាល់ចំពោះសំណួរប្រភេទនេះ គឺថាជនរងគ្រោះអាចព្យាយាមស្មានប្រសិន បើខ្លួនមិនដឹងច្បាស់ពីចម្លើយពិតប្រាកដ ជាពិសេស នៅក្នុងការសម្ភាសជាមួយកុមារ ឬ ជនរងគ្រោះដែលទទួលរងការប៉ះពាល់ផ្លូវអារម្មណ៍ ។ វិធីសាស្ត្រគ្រប់គ្រងលើផលប៉ះពាល់នេះ ដែលអាចកើតមានឡើង គឺត្រូវរំលឹកជនរងគ្រោះថា ពួកគេអាចឆ្លើយថា ខ្លួនមិនដឹងពីចម្លើយ ឬមិនអាចចាំបាន ឬសួរសំណួរជំនួសទៅនឹងចម្លើយ ដូចជា តើគាត់រំលោភអ្នកលើកទីមួយ មុនពេលអ្នកឆ្លងកាត់ព្រំដែន ឬបន្ទាប់ពីអ្នកឆ្លងកាត់ព្រំដែន ឬអ្នកមិនចងចាំ?

តាមវិធានអនុវត្តល្អៗ និងតាមដែលអាចធ្វើទៅបាន ការប្រើសំណួរបិទគួរតែជៀសវាង នៅពេលធ្វើការពិនិត្យឱ្យបានច្បាស់លាស់ទៅលើចំណុចនានានៃភស្តុតាង ដែលទាក់ទងទៅនឹងព្រឹត្តិការណ៍ជាក់លាក់ ជាពិសេសគឺភស្តុតាងទាំងឡាយណាដែលអាចប្រឈមមុខនៅតុលាការ ។ ឧទាហរណ៍នៃការប្រើប្រាស់សំណួរខាងលើ ដែលទាក់ទងទៅនឹងការរំលោភផ្លូវភេទ ការប្រើសំណួរបិទគួរតែជៀសវាង ប្រសិនបើមានចំណុចជាក់លាក់ទាក់ទងទៅនឹងការយល់ព្រមរបស់ជនរងគ្រោះ ការប្រើសំណួរល្អជាងនេះ ដូចជា អ្នកបានប្រាប់ខ្ញុំថា គាត់បានចាប់ផ្តើមរំលោភអ្នក នៅពេលដែលវាកើតឡើង តើអ្នកបានប្រាប់គាត់ឱ្យឈប់ដែរឬទេ ឬអ្នកបានប្រាប់ខ្ញុំថា គាត់បានចាប់ផ្តើមរំលោភអ្នកនៅពេលដែលវាកើតឡើង តើអ្នកបានព្យាយាម រើបម្រះពីគាត់ដែរឬទេ? ជំនួសឱ្យឃ្លាសំណួរខាងលើ គួររៀបសំណួរ ដូចជា អ្នកបានប្រាប់ខ្ញុំថា គាត់បានចាប់ផ្តើមរំលោភអ្នក នៅពេលវាបានកើតឡើង តើអ្នកបានធ្វើ ឬនិយាយអ្វីខ្លះ?

○ សំណួរនាំមុខ

សំណួរនាំមុខ គឺជាសំណួរដែលមានចម្លើយភ្ជាប់មកជាមួយ ឬជាចម្លើយជាក់លាក់ ។ ឧទាហរណ៍ គាត់បានយកលុយរបស់អ្នកទាំងអស់ មែនឬ?

សំណួរនាំមុខ គួរតែប្រើនៅពេលដែលការប្រើសំណួរផ្សេងទៀត មិនបានទទួលចម្លើយពីជនរងគ្រោះពីចំណុចណាមួយដែលយើងចង់បាន ។ សំណួរនាំមុខធ្វើឱ្យមានផលប៉ះពាល់ ដោយសារតែជនរងគ្រោះចេះតែឆ្លើយឱ្យរួចខ្លួនតាមសំណួរនៃការសម្ភាស និងការរំលឹកឡើងវិញ មិន

ត្រឹមត្រូវ ជាពិសេស ទាក់ទងទៅនឹងការសួរសំណួរនាំមុខទៅលើកុមារ និងជនរងគ្រោះដែលមានការប៉ះពាល់ផ្លូវអារម្មណ៍ ។

ប៉ុន្តែចំពោះការសម្ភាសដែលមានការប្រឈម អ្នកសម្ភាសអាចដឹងថា វិធីតែមួយដើម្បីទទួលបានចម្លើយណាមួយ គឺត្រូវតែប្រើសំណួរនាំមុខ ។ ប្រសិនបើអញ្ចឹងមែន សំណួរនាំមុខមិនគួរធ្វើទៅលើចំណុចកស្តុតាងសំខាន់ ដែលតម្រូវឱ្យមានការប្រឈមនៅឯតុលាការ ។ នៅពេលដែលទទួលបានចម្លើយដោយប្រើសំណួរនាំមុខរួចហើយ អ្នកសម្ភាសគួរតែត្រឡប់មកសំណួរបើក និង/ឬ សំណួរជាក់លាក់របស់ខ្លួនវិញ ។

**៤. គំរូ PEACE ៖ C-ការបញ្ចប់**

សង្ខេបភារកិច្ចសំខាន់ៗ នៃដំណាក់កាលបិទ ៖




ជាការសំខាន់ ដែលការសម្ភាសត្រូវតែបញ្ចប់ នៅក្នុងរបៀបជារចនាសម្ព័ន្ធ និងបានទទួលលទ្ធផលវិជ្ជមាន ។ ការសម្ភាសមិនគួរបញ្ចប់តាមចិត្តចង់នោះទេ ហើយក្រុមសម្ភាសគួរធានាថា ដំណើរការសម្ភាសត្រូវបញ្ចប់ទៅតាមពេលវេលាត្រឹមត្រូវ ។ គួរចងចាំថា ភាពជាដៃគូរវាងជនរងគ្រោះ និងក្រុមសម្ភាស ត្រូវតែបន្តរហូតដល់ដំណើរការសវនាការ និងលើសពីនេះទៀត ហើយជាការសំខាន់ ដើម្បីធានាថា ជនរងគ្រោះត្រូវបានគេផ្តល់ព័ត៌មានពេញលេញពីជំហានបន្ទាប់ នៃដំណើរការសម្ភាស និងដំណើរការស៊ើបអង្កេតរឿងក្តី ។

ចំណុចនៃការបញ្ចប់ការសម្ភាសខាងក្រោម គួរតែអនុវត្តតាម៖

• មុននឹងបញ្ចប់ការសម្ភាសជាចុងក្រោយ អ្នកសម្ភាសគួរតែឆ្លៀតឱកាសសាកសួរអ្នកសម្ភាសទីពីរ ថាតើមានចំណុចកស្តុតាងគន្លឹះណាមួយដែលខ្លួនភ្លេច ឬថាតើមានចំណុចណាមួយដើម្បីបញ្ជាក់ឱ្យបានច្បាស់លាស់

• បន្ទាប់មក អ្នកសម្ភាសត្រូវអាន ឬឱ្យជនរងគ្រោះអានដោយខ្លួនឯង នូវកំណត់ហេតុដើម្បីផ្ទៀងផ្ទាត់នូវភាពត្រឹមត្រូវ ។ កំណត់ត្រានៅក្នុងកំណត់ហេតុនេះ ត្រូវតែយកពាក្យរបស់ជនរងគ្រោះ ហើយមិនត្រូវប្រើឃ្លាផ្សេង ដែលមានន័យជំនួសពាក្យរបស់ជនរងគ្រោះនោះឡើយ ។ អ្នកសម្ភាសគួរតែសួរជនរងគ្រោះ ដើម្បីធ្វើការកែតម្រូវទៅលើកំហុសដែលបានធ្វើ ឬបញ្ជាក់ចំណុចជាក់លាក់ណាមួយ ដែលជនរងគ្រោះគិតថាចាំបាច់ ដើម្បីធានាពីសុក្រឹតភាពនៃគំនិតរបស់ជនរងគ្រោះ

• អ្នកសម្ភាសគួរតែសួរទៅជនរងគ្រោះថា តើជនរងគ្រោះអាចទទួលយកបានពីដំណើរការសម្ភាសដែរឬទេ តើជនរងគ្រោះយល់ពេញលេញពីដំណើរការនោះដែរឬទេ តើជនរងគ្រោះមានបញ្ហាណាខ្លះ ប្រសិនបើគាត់ចង់ពិភាក្សាពីអ្វីដែលបានកើតមកលើរូបគាត់ ។ នៅក្នុងដំណាក់កាលនេះជនរងគ្រោះ គួរតែត្រូវបានគេឱ្យសួរពីសំណួរណាមួយដែលគាត់មានចំពោះក្រុមសម្ភាស

• បន្ទាប់មក អ្នកសម្ភាសគួរតែឆ្លៀតឱកាស អរគុណដល់ជនរងគ្រោះ ចំពោះការចូលរួមរបស់គាត់ ហើយត្រូវបញ្ជាក់ពីសារៈសំខាន់នៃតួនាទី និងការចូលរួមរបស់ជនរងគ្រោះ ក្នុងភាពជាដៃគូនៃក្រុមការងារ

• បន្ទាប់មក អ្នកសម្ភាសគួរតែពន្យល់ឱ្យបានលម្អិត ពីផែនការសម្រាប់ជំហានបន្ទាប់នៅក្នុងដំណើរការនេះ ។ ឧទាហរណ៍ ការកំណត់ពេលវេលាសម្រាប់ការសម្ភាស លើកក្រោយ និង ដំណាក់កាលស៊ើបអង្កេតដទៃទៀត ដែលអាចមានការពាក់ព័ន្ធនឹងជនរងគ្រោះ ដូចជា ធ្វើការកំណត់ជនល្មើសតាមរយៈវិធីដែលឱ្យជនល្មើសនៅក្នុងបន្ទប់ជាមួយអ្នកផ្សេងដទៃទៀត ការពិនិត្យផ្នែកវេជ្ជសាស្ត្រ ។ល។ ការពន្យល់នេះគឺមិនគ្រាន់តែជាការពន្យល់ពីយន្តការនៃដំណាក់កាលទាំងនោះទេ ប៉ុន្តែជាការពន្យល់ពីគោលបំណងផងដែរ

• បន្ទាប់មក ក្រុមសម្ភាសគួរតែបំពេញនូវសេចក្តីត្រូវការជាបន្ទាន់ លើសុខមាលភាពរបស់ជនរងគ្រោះ ដូចជា ការដឹកជញ្ជូន ជំនួយសុខភាព ទីជម្រក ថវិកា និងបញ្ហាផ្សេងទៀត ។ល។

### ៥. គំរូ PEACE ៖ E-**វាយតម្លៃ**

សង្ខេបភារកិច្ចសំខាន់ៗនៃដំណាក់កាលវាយតម្លៃ៖

**E-វាយតម្លៃ**

វាយតម្លៃការអនុវត្ត
ពិនិត្យការអនុវត្ត វាយតម្លៃការទំនាក់ទំនង បញ្ហាភាសា វប្បធម៌ កែតម្រូវបើចាំបាច់

វាយតម្លៃភស្តុតាង
ពិនិត្យភស្តុតាងដែលបានទទួល វាយតម្លៃចំណុចដែលត្រូវអភិវឌ្ឍ រកអង្គហេតុថ្មី ពិនិត្យចំណុចវិភាគភស្តុតាង

ចាប់ផ្តើមគំរូ **PEACE** ម្តងទៀត
ចាប់ផ្តើមត្រៀមរៀបចំការសម្ភាសលើកក្រោយ ពិនិត្យនិងធ្វើបច្ចុប្បន្នភាព លើចំណុចភស្តុតាងដែលវិភាគ សម្រាប់ការសម្ភាសលើកក្រោយ

នៅពេលសម្ភាសត្រូវបានធ្វើឡើង ភារកិច្ចចុងក្រោយនៃគំរូ PEACE គឺពិនិត្យ និងវាយតម្លៃការសម្ភាស ។ វាមានសារៈសំខាន់ក្នុងការកត់សម្គាល់ថា ដំណើរការនេះគួរធ្វើទៅតាមក្រោយ បន្ទាប់ពីសម្ភាសន៍នីមួយៗ និងមិនត្រូវទុកចោលរហូតដល់ទីបញ្ចប់នៃដំណើរការសម្ភាសទាំងមូលនោះទេ ។

នៅក្នុងរឿងក្តីជួញដូរមនុស្ស ការសម្ភាសនឹងត្រូវធ្វើឡើងយ៉ាងពិតប្រាកដ ទៅតាមលំដាប់លំដោយនៃការសម្ភាស ហើយវាជាបញ្ហានៃការអនុវត្តល្អផងដែរ ក្នុងការវាយតម្លៃ ។ ដូច្នេះ ការវាយតម្លៃនឹងកំណត់ឱ្យឃើញពីដំណើរការសម្ភាស និងពីចំណាត់ការស៊ើបអង្កេត ដែលត្រូវធ្វើ និងផ្តល់មគ្គុទេសក៏ដ៏មានសារៈសំខាន់ ទៅលើការផ្តោតរកភស្តុតាង សម្រាប់ការសម្ភាសលើកក្រោយ ។

គោលបំណងនៃការវាយតម្លៃក្រោយការសម្ភាស គឺកំណត់ឱ្យឃើញដូចខាងក្រោម ៖

- ពិនិត្យការអនុវត្តរបស់ក្រុមសម្ភាស ។ របៀបទំនាក់ទំនង ដែលធ្វើឡើងរវាងអ្នកដឹកនាំការសម្ភាស និងជនរងគ្រោះដែលធ្វើជាសាក្សី តើការទំនាក់ទំនងបានបង្កើតដែរឬទេ តើមានបញ្ហាខាងផ្នែកវប្បធម៌ ឬភាសា ដែលបង្កឱ្យមានបញ្ហាដែរឬទេ តើត្រូវធ្វើការផ្លាស់ប្តូរចំណុចណាមួយដែរឬទេ ដូចជា តើអ្នកដឹកនាំការសម្ភាស គួរផ្លាស់ប្តូរទីកន្លែងជាមួយនឹងអ្នកសម្ភាសបន្ទាប់ ដែរឬទេ?
- ដោយធ្វើការប្រៀបធៀប ពីចំណុចដំបូងនៃការវិភាគរកភស្តុតាង ចូរពិនិត្យលើភស្តុតាងណាមួយដែលអាចមាន ត្រូវធ្វើការបញ្ជាក់ឱ្យច្បាស់ ដើម្បីសម្ភាសលើកក្រោយ
- កំណត់ឱ្យឃើញអង្គហេតុថ្មី និងអង្គហេតុមុនៗ ដែលត្រូវស្វែងយល់ឱ្យបានស៊ីជម្រៅ និងដើម្បីរកភស្តុតាងមកបំពេញបន្ថែម
- ជំហានបន្ទាប់នានា នៅក្នុងការសម្ភាសនៅពេលបច្ចុប្បន្ន ។

## V. ការសម្ងាត់នៃអត្តសញ្ញាណរបស់ជនរងគ្រោះជាសាក្សី

ភាគច្រើននៃជនរងគ្រោះ គឺមានការភ័យខ្លាចខ្លាំង ពីគ្រោះថ្នាក់នៃការលេចឮអត្តសញ្ញាណពិតរបស់ខ្លួន និងផលវិបាកដែលទាក់ទងទៅនឹងសុវត្ថិភាពផ្ទាល់ខ្លួន និងការបង្ហាញខ្លួនឱ្យគេដឹងជាសាធារណៈ ហើយក្រោយមកប៉ះពាល់ដល់កិត្តិយសរបស់ខ្លួន ។

ជាធម្មតា មានពីរផ្នែកដែលទាក់ទងទៅនឹងការភ័យខ្លាចរបស់ជនរងគ្រោះ គឺសេចក្តីភ័យខ្លាចចំពោះបញ្ហាដែលជនជួញដូរមនុស្សដឹងថា គាត់ជាអ្នកដែលត្រៀមខ្លួនធ្វើជាសាក្សីប្រឆាំងពួកគេ និងសេចក្តីភ័យខ្លាចនៃការលេចឮដល់ក្រុមគ្រួសារ និងមិត្តភក្តិ តាមរយៈនីតិវិធីតុលាការ និងប្រព័ន្ធផ្សព្វផ្សាយ ។ នេះគឺជាការភ័យខ្លាចត្រឹមត្រូវ ហើយជាការភ័យខ្លាចដែលអ្នកសម្ភាសគួរតែ ដោះស្រាយ ។

អាស្រ័យទៅលើក្រមនីតិវិធីព្រហ្មទណ្ឌ មានជម្រើសជាច្រើនដើម្បីដោះស្រាយលើបញ្ហានេះ ៖

- បញ្ញត្តិច្បាប់ដែលការពារមិនឱ្យមានការលេចឮ ពីអត្តសញ្ញាណពិតរបស់ជនរងគ្រោះដែលជាសាក្សី នៅពេលដែលការយកចម្លើយពីសាក្សី ។ នេះមានន័យថា អត្តសញ្ញាណរបស់សាក្សីអាចត្រូវបានដឹងតែក្រុមស៊ើបអង្កេត ហើយមិនត្រូវឱ្យលេចឮដល់មេធាវីការពារជនសង្ស័យឡើយ ។ ការប្រើឈ្មោះក្លែង គឺជាវិធីមួយដែលអាចទទួលយកបាន
- បញ្ញត្តិច្បាប់ការពារមិនឱ្យមានការលេចឮ ពីអត្តសញ្ញាណពិតរបស់ជនរងគ្រោះ ដែលជាសាក្សី នៅក្នុងដំណាក់កាលណាមួយនៃដំណើរការនីតិវិធីព្រហ្មទណ្ឌ ។ នេះមានន័យថា ក្រុមការពារជនសង្ស័យអាចដឹងពីអត្តសញ្ញាណសាក្សី ប៉ុន្តែតាមផ្លូវច្បាប់ គឺមិនអាចឱ្យមានការលេចឮអត្តសញ្ញាណសាក្សី នៅឯបន្ទប់សវនាការ ឬដល់ប្រព័ន្ធផ្សព្វផ្សាយបានឡើយ ។

ចម្លើយសាក្សីដោយប្រើឈ្មោះក្លែង ជាវិធីសាស្ត្រប្រកបដោយប្រសិទ្ធភាព នៅក្នុងការគ្រប់គ្រងទៅលើបញ្ហានេះ គួរតែឱ្យជនរងគ្រោះផ្តល់ចម្លើយសាក្សីរបស់ខ្លួនជាលាយលក្ខអក្សរដោយប្រើឈ្មោះក្លែង ប្រសិនបើវិធីនេះអនុញ្ញាតតាមវិធានរបស់តុលាការ ហើយជនរងគ្រោះស្នើសុំឱ្យធ្វើដូចនេះ ។

គោលបំណង និងហានិភ័យនៃចម្លើយសាក្សីធ្វើឡើងដោយប្រើឈ្មោះក្លែង មានពីរយ៉ាង ៖

- ទីមួយ ចម្លើយសាក្សីអាចត្រូវបានគេប្រើ ដើម្បីទប់ស្កាត់កុំឱ្យសាក្សី និងមេធាវីរបស់ជនសង្ស័យដឹងពីអត្តសញ្ញាណពិតរបស់សាក្សីជាជនរងគ្រោះ មុនពេលចាប់ផ្តើមដំណើរការសវនាការ ហើយនៅក្នុងករណីមួយចំនួន គឺមិនត្រូវឱ្យដឹងលើសពីនេះទៀត ។ ប៉ុន្តែ ការទប់ស្កាត់មិនឱ្យដឹងពីអត្តសញ្ញាណរបស់ជនរងគ្រោះដែលជាសាក្សីនេះ គឺមិនអាចធ្វើទៅបានទេ នៅក្នុងរឿងក្តីជួញដូរមនុស្ស ពីព្រោះព័ត៌មានលម្អិតនៅក្នុងចម្លើយសាក្សីនោះ ដូចជាការប្រើឈ្មោះក្លែង ផ្លូវធ្វើដំណើរ កាលបរិច្ឆេទនៃការធ្វើដំណើរឆ្លងកាត់ព្រំដែន ការកេងប្រវ័ញ្ចដែលមាន ការពាក់ព័ន្ធ... ជាការពិតគឺអាចឱ្យជនសង្ស័យ និងមេធាវី អាចធ្វើការកំណត់ត្រឹមត្រូវពីអត្តសញ្ញាណរបស់សាក្សី នៅពេលចម្លើយសាក្សីនោះដល់ដៃរបស់គេ ។ វាគឺជាការសំខាន់បំផុតដែលជនរងគ្រោះ ត្រូវដឹងពីគ្រោះថ្នាក់នេះ ដែលជាភារកិច្ចរបស់អ្នកសម្ភាសត្រូវប្រាប់ដល់សាក្សីដោយចំហ និងដោយ ស្មោះត្រង់ ។
- ទីពីរ គឺការទប់ស្កាត់មិនឱ្យប្រព័ន្ធផ្សព្វផ្សាយ ដឹងពីដំណើរការនៃរឿងក្តីព្រហ្មទណ្ឌ ដូចជាការធ្វើឱ្យលេចឮដល់ក្រុមគ្រួសារជនរងគ្រោះ ឬអ្នកជាទីស្រឡាញ់ដឹងពីរឿងរ៉ាវពិត ។ បើធ្វើដូចនេះ

បាន វាអាចកាត់បន្ថយគ្រោះថ្នាក់ដែលធ្វើឱ្យលេចឮ និងប៉ះពាល់កិត្តិយសជនរងគ្រោះ ។ ការទប់ស្កាត់ការលេចឮពីតុលាការពិតប្រាកដ នៅពេលដែលឈ្មោះក្លែងត្រូវបានគេប្រើប្រាស់នៅក្នុងកាលៈទេសៈខាងលើ អ្នកស៊ើបអង្កេត (និង/ឬព្រះរាជអាជ្ញា) ត្រូវតែដឹងឈ្មោះពិតរបស់ជនរងគ្រោះ ហើយឈ្មោះពិតនេះត្រូវបានគេរក្សាទុក ។ ការរក្សាទុកឈ្មោះនេះ រួមមាន នាម និងគោត្តនាមពេញលេញ ថ្ងៃខែឆ្នាំកំណើត និងអាសយដ្ឋាន ។ អ្វីដែលចម្លងឈ្មោះទុកនោះ គឺធ្វើឡើងតាមនីតិវិធីរដ្ឋបាល ប៉ុន្តែអ្វីដែលសំខាន់នោះ កំណត់ហេតុឈ្មោះពិតប្រាកដ គឺជាអត្ថប្រយោជន៍ទូទៅ និងការពារដំណើរការរឿងក្តីព្រហ្មទណ្ឌ ដូចនេះកំណត់ហេតុនេះ មិនត្រូវឱ្យមានការលេចឮពីតុលាការឡើយ ។

វិធីសាស្ត្រដែលស្នើឡើង ការទទួលបានចម្លើយសាក្សី និងលិខិតបញ្ជាក់អត្តសញ្ញាណពិតប្រាកដរបស់ជនរងគ្រោះ គួរតែធ្វើកំណត់ហេតុជាលាយលក្ខអក្សរ ហើយកំណត់ហេតុនេះ ជាទូទៅ គេទទួលស្គាល់ថាជាចម្លើយសាក្សី ។

## VI. វិធីសាស្ត្រសម្ភាស-ការប្រើបញ្ជីសំណួរ

### ១. គម្រោងប្លង់បញ្ជីផ្ទៀងផ្ទាត់

- បញ្ជីផ្ទៀងផ្ទាត់(ក)-រឿងហេតុពេញលេញ

បញ្ជីផ្ទៀងផ្ទាត់នេះមានបីផ្នែក ហើយផ្នែកនីមួយៗមានបញ្ជីសកម្មភាព កំណត់ពីសំណួរស្វែងរកភស្តុតាងសំខាន់ៗ ដែលត្រូវលើកឡើងនៅក្នុងដំណាក់កាលទាំងបីនៃ ការជ្រើសរើស ការដឹកជញ្ជូន និងការកេងប្រវ័ញ្ច ។

ប្រភេទផ្សេងៗនៃការកេងប្រវ័ញ្ច តម្រូវឱ្យលើកជាសំណួរផ្សេងៗពីបញ្ជីសកម្មភាព សម្រាប់ដំណាក់កាលកេងប្រវ័ញ្ចនៃបញ្ជីផ្ទៀងផ្ទាត់នេះ ត្រូវបានធ្វើឱ្យទូលាយឡើង ដើម្បីបញ្ចូលសំណួរបន្ថែម និងជាក់លាក់ច្រើនទៀត នៅក្នុងប្រភេទចម្បងបីនៃការកេងប្រវ័ញ្ច រួមមានការកេងប្រវ័ញ្ចផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងការដកហូតសរីរាង្គ ។

- បញ្ជីផ្ទៀងផ្ទាត់(ខ)-ចំណុចជាក់លាក់-សមាសភាគទាំង៥ នៃការជួញដូរ

បញ្ជីផ្ទៀងផ្ទាត់នេះ បានលើកជាសំណួរបន្ថែម ដែលមានលក្ខណៈជាក់លាក់ទៅលើសមាសភាគទាំង ៥ នៃដំណើរការជួញដូររួមមាន ការផ្សព្វផ្សាយ ការជួល ការដឹកជញ្ជូន ការទំនាក់ទំនង និងហិរញ្ញវត្ថុ ។

សំណួរបានកំណត់នៅក្នុងបញ្ជីផ្ទៀងផ្ទាត់នេះ អាចលើកជាសំណួរបាន ដែលពាក់ព័ន្ធទៅនឹងសមាភាគ ទាំង៥ ដោយមិនគិតថា តើវាកើតឡើងនៅក្នុងដំណាក់កាល ប្រភពឆ្លងកាត់ និងគោលដៅនោះទេ ។

- បញ្ជីផ្ទៀងផ្ទាត់(គ)-ការបំពានខាងផ្នែកផ្លូវកាយ ផ្លូវភេទ និងផ្លូវចិត្ត

បញ្ជីផ្ទៀងផ្ទាត់ចុងក្រោយ ផ្តល់នូវសំណួរជាក់លាក់បន្ថែមដើម្បីរកឱ្យឃើញព័ត៌មានចាំបាច់អំពីទម្រង់ណាមួយនៃការបំពាន ដែលមានលក្ខណៈជាទូទៅ នៅក្នុងប្រភេទនៃបទល្មើសនេះ រួមមានការបំពានផ្លូវភេទ ការប៉ះពាល់ដល់បូរណភាពបុគ្គល ការភូតភរ ការប៉ះពាល់ដល់សិទ្ធិសេរីភាព កត្តាផ្លូវ

ចិត្ត និងសេចក្តីភ័យខ្លាច ដែលធ្វើឱ្យមានផលប៉ះពាល់ទៅលើជនរងគ្រោះ ។ ដូចនៅក្នុងបញ្ជីផ្ទៀងផ្ទាត់ (ខ)- សំណួរនៅក្នុងផ្នែកនេះ អាចយកមកប្រើ ទាក់ទងទៅនឹងការបំពានទៅលើជនរងគ្រោះ ទោះបីវាបានកើតឡើង នៅក្នុងដំណាក់កាលណាមួយ ឬដំណាក់កាលទាំងបីនៃប្រភពដើម ឆ្លងកាត់ និងគោលដៅក៏ដោយ ។

## ២. របៀបប្រើប្រាស់បញ្ជីផ្ទៀងផ្ទាត់

- បញ្ជីផ្ទៀងផ្ទាត់ ជាឧបករណ៍ជួយដល់អ្នកស៊ើបអង្កេត ក្នុងការកំណត់ឱ្យឃើញ និងផ្តោតទៅលើបញ្ហានានា ប៉ុន្តែបញ្ហាសំខាន់ៗនឹងត្រូវបានស្វែងរកឃើញនៅក្នុងអំឡុងពេលនៃការសម្ភាស
- បញ្ជីសំណួរគួរតែប្រើ បន្ទាប់ពីជនរងគ្រោះបានរំលឹកពីព្រឹត្តិការណ៍នានា ដែលកើតមានមកលើខ្លួន ។ វាជាការសំខាន់ក្នុងការចងចាំថា ដំណាក់កាលនេះ គឺមិនត្រូវមានការរំខានដោយមន្ត្រីសម្ភាសឡើយ ហើយបញ្ជីសំណួរគួរតែប្រើនៅក្នុងដំណាក់កាលលើកជាសំណួរដោយក្រុមសម្ភាស និងដើម្បីទទួលបានភស្តុតាងជាក់លាក់ទាក់ទងនឹងព័ត៌មាន ដែលទទួលបាននៅក្នុងពេលជនរងគ្រោះរំលឹកឡើងវិញពីព្រឹត្តិការណ៍បានកើតឡើង
- បញ្ជីសំណួរ គឺត្រូវបានរៀបចំឡើង ដើម្បីគ្របដណ្តប់ទៅលើប្រភេទផ្សេងៗនៃឧបាយកលជួញដូរមនុស្សរបស់ជនល្មើស និងដើម្បីបង្ហាញពីសារសំខាន់នៃបញ្ជីសំណួរ ។ វាគឺជាការសំខាន់ដែលមន្ត្រីសម្ភាសរំលឹកពីអត្ថន័យនៃសំណួរ និងសម្របទៅនឹងសំណួរនោះ អាស្រ័យទៅតាមស្ថានភាពជួញដូរមនុស្សជាក់ស្តែងនៅក្នុងប្រទេស ឬតំបន់របស់ខ្លួន ដើម្បីបង្ហាញឱ្យឃើញពីស្ថានភាព នៅពេលបច្ចុប្បន្ន និងបទពិសោធន៍ផ្ទាល់ខ្លួន
- ម៉្យាងវិញទៀត ពេលធ្វើសម្ភាសជនរងគ្រោះដែលស្ថិតក្នុងដំណាក់កាលទាំងមូល នៃការជួញដូរមនុស្ស ដូចជា ដំណាក់កាលជ្រើសរើស ដឹកជញ្ជូន និងកេងប្រវ័ញ្ច ។ សំណួរនៅក្នុងបញ្ជីផ្ទៀងផ្ទាត់(ក) អាចត្រូវបានគេប្រើដើម្បីទទួលបានពីចំណុចសំខាន់ៗ នៃរឿងរ៉ាវក្នុងដំណាក់កាលទាំងបី
- បន្ទាប់ពីធ្វើការងារខាងលើនេះរួច ហើយជនរងគ្រោះបានបង្ហាញពីអង្គហេតុនានា ដែលទាក់ទងនឹងការផ្សព្វផ្សាយ ការជួល ការដឹកជញ្ជូន ការទំនាក់ទំនង ឬការផ្ទេរប្រាក់ នោះសំណួរនានាក្នុងបញ្ជីផ្ទៀងផ្ទាត់(ខ) គួរផ្ទៀងផ្ទាត់ដើម្បីធានាថា រាល់អង្គហេតុដែលពាក់ព័ន្ធទៅនឹងសកម្មភាពពិសេសណាមួយ គួរតែដាក់បញ្ចូលថា ជារឿងរ៉ាវដែលមិនបានដឹង ហើយត្រូវពង្រីកនៅក្នុងចំណុចសំខាន់ៗ នៃបញ្ជីផ្ទៀងផ្ទាត់(ក)
- ប្រសិនបើប្រើបញ្ជីផ្ទៀតផ្ទាត់(ក)ហើយ នៅតែមិនទទួលបានព័ត៌មាន មន្ត្រីសម្ភាសគួរតែប្រើសំណួរនៅក្នុងបញ្ជីផ្ទៀតផ្ទាត់(គ) ដើម្បីទទួលបានអង្គហេតុដែលពាក់ព័ន្ធនឹងការប៉ះពាល់ដល់បូរណភាពបុគ្គល ការបំពានផ្លូវភេទ និងផ្លូវចិត្ត ដែលបានកើតឡើងចំពោះជនរងគ្រោះ នៅក្នុងដំណាក់កាលណាមួយនៃប្រភព ឆ្លងកាត់ និងគោលដៅ នៅពេលជនរងគ្រោះបង្ហាញពីរឿងរ៉ាវរបស់ខ្លួន
- ដំណើរការទាំងមូលនេះ គួរតែធ្វើឡើងម្តងទៀត នៅក្នុងដំណាក់កាលនៃការជ្រើសរើស ការដឹកជញ្ជូន និងការកេងប្រវ័ញ្ច ធ្វើដូចនេះជនរងគ្រោះអាចប្រមូលការចងចាំបានច្រើនចំណុច តាមដែលអាចធ្វើទៅបាន ដែលមាននៅក្នុងបញ្ជីសំណួរ(ក) និង(គ) ទាក់ទងនឹងប្រទេសនីមួយៗ ដែល

ជនរងគ្រោះបានជួបប្រទះ ។

### ៣. ការពន្យល់បញ្ជីផ្ទៀតផ្ទាត់នីមួយៗ

- បញ្ជីផ្ទៀងផ្ទាត់-ក-រឿងហេតុពេញលេញ-សំណួរស្តីពីក្របខណ្ឌការងារ-ការជ្រើសរើស
  - ការជ្រើសរើស ៖ ពេលណា ឯណា នរណា អ្វី ហេតុអ្វី ។

| ការជ្រើសរើស | |
|---|---|
| ពេលណា | ចូរសួរថា៖<br>• តើថ្ងៃ ខែ ឆ្នាំ ឬនៅពេលណា ដែលរឿងនេះបានកើតឡើង? ឧទាហរណ៍៖ តើជនរងគ្រោះបានជួបអ្នកជ្រើសរើស ឬអ្នកពង្រត់ខ្លួនលើកទីមួយនៅពេលណា? (បើជនរងគ្រោះមិនអាចចាំថ្ងៃខែបានទេ ត្រូវព្យាយាមសួរនូវសំណួរដោយចាប់ផ្តើមពីប្រវត្តិការណ៍សំខាន់ៗនៃជីវិតជនរងគ្រោះ ដូចជា ថ្ងៃធ្វើពិធីបុណ្យភូមិ ឬបុណ្យប្រពៃណីជាតិ...)? |
| ឯណា | ចូរសួរថា៖<br>• តើកន្លែងដែលបានជួបគ្នាដំបូងនៅទីណា? រួមទាំងព័ត៌មានលម្អិតមួយចំនួន ដូចជា ទីកន្លែង ឈ្មោះ អាសយដ្ឋាន... ។ |
| នរណា | ចូរសួរថា៖<br>• តើនរណាជាអ្នកមានព័ត៌មានលម្អិតអំពីជនសង្ស័យ ដូចជា ឈ្មោះ ភិនភាគ អាសយដ្ឋាន មធ្យោបាយធ្វើដំណើរ លេខទូរស័ព្ទ... ។ |
| អ្វី | ចូរសួរថា៖<br>• តើមានអ្វីកើតឡើង?<br>• តើជនរងគ្រោះចាកចេញពីផ្ទះរបស់គាត់ដោយរបៀបណា?<br>• តើមានគេបង្ខំដែរឬទេ? បើមាន តើគេបង្ខំគាត់ដោយរបៀបណា?<br>• តើគេសន្យាយ៉ាងដូចម្តេច? តើជាប្រភេទការងារអ្វី? តើថ្លៃឈ្នួល និងលក្ខខណ្ឌការងារដូចម្តេច?<br>• តើជងរងគ្រោះមានច្បាប់ចម្លងអំពីការផ្សាយពាណិជ្ជកម្មរកការងារធ្វើ ឬច្បាប់ចម្លងនៃកិច្ចសន្យាអ្វីមួយដែរឬទេ? (បើមាន សុំយកពីគាត់)? |
| ហេតុអ្វី | ចូរសួរថា៖<br>• តើហេតុអ្វីបានជាជនរងគ្រោះយល់ព្រមតាមកិច្ចសន្យានោះ?<br>• តើហេតុអ្វីបានជាជនរងគ្រោះជឿជាក់ចំពោះការប្រាប់របស់គេ? |

- ការបន្លាស់ទី និងដឹកជញ្ជូន៖ អាចមិនមានការពាក់ព័ន្ធនឹងប្រទេសឆ្លងកាត់ ។

ខ្សែផ្លូវនៃការជួញដូរមនុស្ស អាចកើតឡើងពីប្រទេសដើម ទៅប្រទេសគោលដៅ ដោយគ្មានសម្រាក និងឆ្លងកាត់ប្រទេសជាច្រើន ហើយគួរធ្វើការពិចារណាប្រទេសឆ្លងកាត់នីមួយៗ ។

| ការដឹកជញ្ជូន និងការធ្វើដំណើរ | |
|---|---|
| ពេលណា | ចូរសួរថា៖<br>• តើថ្ងៃ ទី ខែ ឆ្នាំ ឬនៅពេលណា ជនរងគ្រោះបានចាកចេញពីផ្ទះ ឬពីលំនៅដ្ឋានចុងក្រោយ?<br>• តើជនរងគ្រោះមកដល់កន្លែងដែលត្រូវគេកេងប្រវ័ញ្ចនៅពេលណា (បើជនរងគ្រោះមិនអាចចាំថ្ងៃខែបានទេ ត្រូវព្យាយាមសួរនូវសំណួរដោយ ចាប់ផ្តើមពីប្រវត្តិការណ៍សំខាន់ៗនៃជីវិតជនរងគ្រោះ ដូចជា ថ្ងៃធ្វើពិធីបុណ្យភូមិ ឬបុណ្យប្រពៃណីជាតិ...)? |
| ឯណា | ចូរសួរថា៖<br>• តើជនរងគ្រោះចាកចេញពីទីណា?<br>• តើជនរងគ្រោះធ្វើដំណើរមកតាមផ្លូវណា?<br>• បើសិនករណីនេះ ជាករណីឆ្លងដែន តើជនរងគ្រោះត្រូវគេរត់ពន្ធកាត់ព្រំដែនមួយណា បើសិនជនរងគ្រោះត្រូវគេរត់ពន្ធឆ្លងព្រំដែន តើជនរងគ្រោះដឹងថា ច្រកព្រំដែនមួយណាដែលខ្លួនបានឆ្លងកាត់?<br>• បើករណីនេះ ជាករណីឆ្លងដែន តែជនរងគ្រោះមិនត្រូវបានគេរត់ពន្ធទេ តើជនរងគ្រោះចាកចេញពីប្រទេសរបស់ខ្លួនតាមច្រកព្រំដែនមួយណា?<br>• តើច្រកព្រំដែនមួយណាដែលជនរងគ្រោះបានឆ្លងកាត់ចូលទៅក្នុងប្រទេសដែលត្រូវស្នាក់នៅជាបណ្តោះអាសន្ន?<br>• តើច្រកព្រំដែនមួយណាដែលជនរងគ្រោះបានឆ្លងកាត់ចូលទៅក្នុងប្រទេសដែលត្រូវគេធ្វើការកេងប្រវ័ញ្ច? |
| នរណា | ចូរសួរថា៖<br>• តើនរណាជាអ្នកមានព័ត៌មានលម្អិតអំពីជនសង្ស័យមួយណា ដែលបានធ្វើដំណើរជាមួយជនរងគ្រោះ?<br>• តួនាទីដែលជនសង្ស័យទាំងនេះត្រូវធ្វើក្នុងពេលធ្វើដំណើរ?<br>• ព័ត៌មានលម្អិតអំពីជនរងគ្រោះផ្សេងទៀត ដែលបានធ្វើដំណើរជាមួយជនរងគ្រោះម្នាក់នេះ ឈ្មោះ និងភិនភាគ? |
| អ្វី | ចូរសួរថា៖<br>• តើគេប្រើវិធីអ្វីក្នុងការធ្វើដំណើរ ដោយថ្មើរជើង ដោយរថយន្ត រថភ្លើង តាមទូក ឬតាមយន្តហោះ ។ តើគេមានប្រើលិខិតស្នាមសម្រាប់ធ្វើដំណើរ ដែរឬទេ បើមាន តើនៅលើលិខិតនោះ ជនរងគ្រោះប្រើឈ្មោះអ្វី?<br>• បើសិនជាធ្វើដំណើរតាមក្រុមហ៊ុនដឹកជញ្ជូន ត្រូវស្វែងរកព័ត៌មានលម្អិត អំពីក្រុមហ៊ុនយន្តហោះ ក្រុមហ៊ុនកប៉ាល់ ឬសាឡាង ។ល។? |

| | |
|---|---|
| | • បើសិនជាជនរងគ្រោះបានទិញសំបុត្រសម្រាប់ការធ្វើដំណើរ តើនរណាជាអ្នកចេញលុយឱ្យ ហើយតើគេចេញលុយដោយរបៀបណា? <br> • តើជនរងគ្រោះមានអត្តសញ្ញាណប័ណ្ណ ឬលិខិតស្នាមសម្រាប់ការធ្វើដំណើរដែរឬទេ (បើមាន សុំយកពីគាត់សិនមក)? |
| ហេតុអ្វី | ចូរសួរថា៖ <br> • តើហេតុអ្វីបានជាជនរងគ្រោះយល់ព្រមធ្វើដំណើរជាមួយជនសង្ស័យ? <br> • តើហេតុអ្វីបានជាគេប្រើមធ្យោបាយ ធ្វើដំណើរតាមបែបហ្នឹង? |

○ ការកេងប្រវ័ញ្ច៖ អ្នកសម្ភាសគួរពិចារណា នៅពេលអនុវត្តការសម្ភាស ៖

| **ការកេងប្រវ័ញ្ច** | |
|---|---|
| ពេលណា | ចូរសួរថា៖ <br> • ថ្ងៃ ទី ខែ ឆ្នាំ តើការកេងប្រវ័ញ្ចចាប់ផ្តើមនៅពេលណា ហើយតើពេលណាទើបជនរងគ្រោះបានដឹងពីសភាពការពិត? <br> • តើមកដល់ទីកន្លែងថ្មីនេះបានយូរប៉ុណ្ណា ទើបគេចាប់ផ្តើមធ្វើការកេងប្រវ័ញ្ច? (បើជនរងគ្រោះមិនចាំថ្ងៃខែបានទេ ត្រូវព្យាយាមសួរនូវសំណួរ ដោយចាប់ផ្តើមពីប្រវត្តិការណ៍សំខាន់ៗ នៃជីវិតជនរងគ្រោះ ដូចជា ថ្ងៃធ្វើពិធីបុណ្យភូមិ ឬបុណ្យប្រពៃណីជាតិ...)? |
| ឯណា | ចូរសួរថា ៖ សំណួរទាំងនេះសំខាន់ខ្លាំងណាស់ <br> • តើទីកន្លែង នៃការកេងប្រវ័ញ្ចនៅឯណា សួររកព័ត៌មានលម្អិតអំពីការកំណត់ទីតាំងឱ្យបានច្បាស់លាស់តាមដែលអាចធ្វើទៅបាន? <br> • អាស័យដ្ឋាន ឈ្មោះអាគារ ឬទីកន្លែងទាំងនោះ? <br> • សួររកព័ត៌មានអំពីទីតាំងម៉ុំៗនោះ? <br> • ព័ត៌មានលម្អិតអំពីទីតាំង ឬស្ថានភាពនៃអាគារនោះ តើអាគារនោះមានច្រកចូលប៉ុន្មាន សោទ្វារប៉ុន្មាន គន្លឹះបង្អួចប៉ុន្មាន? (បើសិនជាអាចធ្វើទៅបាន សុំឱ្យជនរងគ្រោះជួយគូរប្លង់ និងផ្លូវនៃអាគារនោះ) |
| នរណា | សំណួរសំខាន់ៗសម្រាប់ជនរងគ្រោះផ្សេងទៀត៖ <br> • ព័ត៌មានលម្អិតអំពីជនរងគ្រោះផ្សេងទៀតដែលកំពុងឋិតនៅ កន្លែងគេធ្វើការកេងប្រវ័ញ្ច <br> • ភេទ អាយុ សញ្ជាតិ ភាសា ជំនឿ សាសនា <br> • ព័ត៌មានលម្អិតអំពីថាតើគេមានរបួស ឬមានជំងឺអ្វីផ្សេងដែរឬទេ <br> • តើគេនៅកន្លែងនោះយូរប៉ុណ្ណាហើយ <br> សំណួរសំខាន់ៗសម្រាប់ជនសង្ស័យ៖ <br> • តើមានជនសង្ស័យច្រើនប៉ុណ្ណាទៀតដែលកំពុងនៅទីនោះ? |

| | |
|---|---|
| | • ឈ្មោះ ភេទ អាយុ សញ្ជាតិ ភាសា ជំនឿសាសនា និងភិនភាគរបស់គេ? • តើពួកគេជាមនុស្សកាចសាហាវ ឬយ៉ាងណា ហើយតើពួកគេ មានអាវុធប្រើប្រាស់ដែរឬទេ? |
| អ្វី | ចូរសួរថា៖ • តើវិធីនៃការកេងប្រវ័ញ្ច ជាការកេងប្រវ័ញ្ចលើអ្វីកម្លាំងពលកម្ម ពេស្យាចារ ការបម្រើតាមផ្ទះ ឬការកាត់យកសរីរាង្គ ។ល។? • តើជនរងគ្រោះរស់នៅ និងដេកក្នុងកន្លែងតែមួយ ឬយ៉ាងណា? • បើមិននៅកន្លែងតែមួយទេ កំណត់ពីទីកន្លែងដែលគាត់រស់នៅ? • សួរគ្រួសៗអំពីលក្ខខណ្ឌការងារ និងស្ថានភាពរស់នៅរបស់គាត់? • តើជនរងគ្រោះទទួលបានរបបអាហារសមរម្យដែរឬទេ? បើមិនបានសមរម្យទេ សុំរៀបរាប់អំពីស្ថានភាពម្ហូបអាហារដែលបានទទួល ។ • តើជនរងគ្រោះបានទទួលប្រាក់ថ្លៃឈ្នួលដែរឬទេ? បើបានទទួល តើទទួលប្រាក់ថ្លៃឈ្នួលប៉ុន្មាន ហើយនរណាជាអ្នកបង់ប្រាក់ថ្លៃឈ្នួលឱ្យ? • តើជនរងគ្រោះមានទទួលរងនូវគ្រោះថ្នាក់អ្វីដែរទេ? បើមានទទួលរងនូវគ្រោះថ្នាក់ តើគ្រោះថ្នាក់នោះធ្ងន់ប៉ុណ្ណា ចូររៀបរាប់អំពីអាវុធ ឬឧបករណ៍ដែលប្រើក្នុងការធ្វើឱ្យគ្រោះថ្នាក់ ឬរបួសដល់រាងកាយ ផ្លូវភេទ ឬផ្លូវចិត្ត ។ • តើគេមានឃាត់ឃាំងមិនឱ្យជនរងគ្រោះដើរហើរដែរឬទេ? បើមាន រៀបរាប់ពីអំពើដែលគេបានធ្វើនិងកំណត់ជនសង្ស័យដែលមានសោចូលក្នុងអាគារ ។ល។ |
| ហេតុអ្វី | ចូរសួរថា៖ • បើសិនជាជនរងគ្រោះមានឱកាសអាចរត់បាន តើហេតុអ្វីបានជាពួកគេមិនព្រមរត់? |

- កំណត់ចំណាំ

ការកេងប្រវ័ញ្ច -សំណួរដាក់លាក់បន្ថែមទៀត ៖បញ្ជីនៃសំណួរបន្ថែម និងមានលក្ខណៈស៊ីជម្រៅ ទាក់ទងទៅនឹងប្រភេទសំខាន់ៗបី នៃការកេងប្រវ័ញ្ច រួមមាន ការកេងប្រវ័ញ្ចផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងការដកហូតសរីរាង្គ ។ អ្នកសម្ភាសគួរប្រើបញ្ជីផ្ទៀងផ្ទាត់ខាងលើ ដើម្បីទទួលបានគ្រោងប្លង់នៃការរៀបរាប់រឿងហេតុរបស់ជនរងគ្រោះ នៅក្នុងដំណាក់កាលកេងប្រវ័ញ្ច ត្រូវប្រើសំណួរដូចខាងក្រោម ៖

- ការកេងប្រវ័ញ្ចផ្លូវភេទ-សំណួរស៊ីជម្រៅ
  - តើប្រភេទពេស្យាចារអ្វីដែលគាត់បានធ្វើ? តើជាប្រភេទពេស្យាចារតាមផ្លូវ ឬនៅក្នុងអាគារ ឬនៅផ្ទះបន កន្លែងម៉ាស្សា កន្លែងរាំ ឬកន្លែងទីភ្នាក់ងារនាំស្រី?
  - ប្រសិនបើគាត់បម្រើការងារពេស្យាចារនៅតាមផ្លូវ តើតំបន់ភ្លើងក្រហមណា ដែលគាត់ទៅញឹកញាប់ ហើយតើគាត់ទៅទីនោះដោយរបៀបយ៉ាងម៉េច?

- តើគាត់គ្រប់គ្រងដោយជនជួញដូរនៅពេលគាត់ធ្វើការឬ? ប្រសិនបើមែន តើក្រុមជួញដូរមានប៉ុន្មាននាក់?
- តើគាត់ត្រូវបាននគរបាល ឬភ្នាក់ងារដទៃទៀតសម្គាល់ឃើញយ៉ាងដូចម្ដេច? តើគាត់ ត្រូវបានបញ្ឈប់ ឬចាប់ខ្លួន និងចោទប្រកាន់ពីអំពើអួសទាញដែរឬទេ ប្រសិនបើមែន តើគាត់នៅទីណា កន្លែងណា ហើយអត្តសញ្ញាណអ្វី ដែលគាត់បានប្រើនោះ?
- ប្រសិនបើគាត់បម្រើការងារមិននៅតាមផ្លូវនោះទេ តើគាត់ធ្វើការនៅកន្លែងណា ហើយតើគាត់ទៅទីនោះដោយរបៀបណា អ្នកណាជាអ្នកនាំគាត់ទៅធ្វើការ?
- តើជនជួញដូរប្រភេទណា ដែលបានដឹងថាគាត់ធ្វើការជាពេស្យាចារ និងតើពួកគេដឹងដោយរបៀបណា តើពួកគេមានវត្តមាននៅផ្ទះបន ឬនៅតាមផ្លូវ តើការងាររបស់គាត់ ត្រូវធ្វើការពិភាក្សាឬ? ប្រសិនបើមែន តើពិភាក្សាជាមួយនរណា?
- តើគាត់ត្រូវបានគ្រប់គ្រងដែរឬទេ ប្រសិនបើមែន ដោយនរណា?
- តើគាត់មានសេរីភាពក្នុងកម្រិតណា តើគាត់ចាកចេញពីផ្ទះបន ឬវង្គសាល ឬទីភ្នាក់ងារ នោះ ដោយមិនមានការគ្រប់គ្រងឬទេ?
- តើគាត់ធ្វើការជាមួយស្រីពេស្យាចារផ្សេងទៀត និង/ឬជាមួយស្រីកំដរ ឬអ្នកទទួលភ្ញៀវ បើមែន តើគាត់អាចប្រាប់ឈ្មោះ និងរៀបរាប់ពីរូបរាងរបស់ពួកគេបានដែរឬទេ?
- តើផ្ទះបន វង្គសាល ឬទីភ្នាក់ងារនោះ ធ្លាប់ត្រូវបានពិនិត្យមើលដោយមន្ត្រីអនុវត្តច្បាប់ មន្ត្រីផ្សេងដទៃទៀតដែរឬទេ ប្រសិនបើមែន តើនៅពេលណា អ្នកណាជាអ្នកចូលពិនិត្យ មើលនោះ ហើយគាត់ត្រូវបានគេតម្រូវឱ្យផ្ដល់ឈ្មោះ និងអ្វីជាពិសេសផ្សេងទៀត ប្រសិនបើមែន តើឈ្មោះអ្វីដែលគាត់បានប្រើ និងព័ត៌មានអ្វីខ្លះដែលគាត់បានផ្ដល់ឱ្យ?
- បើគាត់ធ្វើការជាពេស្យាចារតាមផ្លូវ ឬមិនមែន តើម៉ោងណាខ្លះដែលគាត់ធ្វើការ?
- តើសេវាអ្វី ដែលគាត់តម្រូវផ្ដល់ឱ្យភ្ញៀវ?
- នៅពេលប្ដូរវេនការងារ តើគាត់ត្រូវបានបញ្ជូនទៅផ្ទះសុវត្ថិភាព ឬគាត់ស្ថិតនៅកន្លែងផ្ទះបននោះ?
- បើគាត់ទៅផ្ទះសុវត្ថិភាព តើគាត់ទៅដោយរបៀបណា និងទៅជាមួយអ្នកណា?

  - សំណួរគន្លឹះស្ដីពីទាសករផ្លូវភេទ និងផលវិបាក

- តើគាត់មានជម្រើសខ្លះដែរឬទេ ទាក់ទងទៅនឹងភ្ញៀវប្រភេទណាដែលគាត់បម្រើ ឬសេវាណាខ្លះ ដែលគាត់ផ្ដល់ឱ្យ?
- តើគាត់តម្រូវឱ្យផ្ដល់សេវាផ្លូវភេទ ដោយគ្មានស្រោមអនាម័យ ប្រសិនបើគាត់បដិសេធ តើមានផលវិបាកអ្វីខ្លះ?
- តើគាត់មានសមត្ថភាពនិយាយភាសានៅទីនោះដែរឬទេ? តើគាត់ធ្វើការទៅតាមបញ្ជីរាយមុខម្ហូបឬទេ? ប្រសិនបើមែន គាត់មានសមត្ថភាពតិចតួចខាងផ្នែកភាសា តើអ្នកណាជាអ្នកបកប្រែឱ្យគាត់ជាមួយនឹងភ្ញៀវនោះ?

○ សំណួរគន្លឹះនៃចំណុចហិរញ្ញវត្ថុ

- តើគាត់ឱ្យភ្ញៀវបង់ថ្លៃសេវារបស់គាត់ប៉ុន្មាន ?
- តើគាត់អាចបញ្ជាក់ប្រាក់ចំណូលប្រចាំថ្ងៃជាមធ្យម និងវាយតម្លៃសរុបពីអ្វីដែលគាត់រកបានពីអំពើពេស្យាចារ នៅក្នុងអំឡុងពេលទាំងមូលនៃការកេងប្រវ័ញ្ចនោះ ?
- តើប្រាក់ចំណូលដែលបានមកពីពេស្យាចារ នឹងកើនឡើងយ៉ាងដូចម្ដេច នៅពេលចប់ វេនការងារនីមួយៗ ?
- តើការងារនោះត្រូវបានកត់ត្រាទុកដែរឬទេ? ប្រសិនបើមែន ផ្ដល់ព័ត៌មានលម្អិតពីរបៀបកត់ត្រានោះ
- តើគាត់បានទិញឧបករណ៍ណាមួយសម្រាប់អ្នកកេងប្រវ័ញ្ច ដែលប្រើប្រាស់លុយបានមកពីពេស្យាចារ ដូចជា គ្រឿងអលង្ការ ឬសម្លៀកបំពាក់ ប្រសិនបើមែន នៅទីណា ពេលណា រៀបរាប់ពីតម្លៃ និងទីកន្លែងនៃឧបករណ៍នោះ និងវិក្កយបត្រណាមួយ ?
- តើមានភាគរយនៃការបែងចែកប្រាក់ចំណូលជាមួយនឹងជនជួញដូរដែរឬទេ ឬប្រាក់ទាំងអស់ ត្រូវប្រគល់ទៅឱ្យគេ តើអ្នកណាជាអ្នកណែនាំគាត់ពីតម្លៃនៃសេវានោះ ?
- តើមានការរៀបចំឱ្យមានការសងប្រាក់បំណុលដែរឬទេ ប្រសិនបើមាន តើគាត់នៅជំពាក់ប្រាក់ប៉ុន្មាន តើនៅក្នុងអត្រាអ្វីដែលគាត់ត្រូវសងបំណុលនោះ តើបង់ប្រាក់ឱ្យ គាត់យ៉ាងដូចម្ដេច បញ្ជូនដោយផ្ទាល់នៅក្នុងប្រទេសគោលដៅ ឬបញ្ជូនប្រាក់ត្រឡប់ មកប្រទេសដើមរបស់គាត់វិញ ប្រសិនបើមែន តើអ្នកណាជាអ្នកបញ្ជូនប្រាក់នោះ និងបញ្ជូនដោយមធ្យោបាយអ្វី ហើយបញ្ជូនទៅឱ្យគណនីរបស់អ្នកណា តើមានការកត់ត្រាណាមួយពីការសងបំណុល ដែរឬទេ ?
- តើគាត់តម្រូវឱ្យបង់ប្រាក់បន្ថែមទៅលើការចំណាយហេដ្ឋារចនាសម្ព័ន្ធ ដូចជា ការជួល ទីតាំងប្រចាំថ្ងៃ ឬការផ្សព្វផ្សាយពាណិជ្ជកម្ម ប្រសិនបើមែន តើគាត់ត្រូវបានគេប្រាប់ពីការចំណាយ បន្ថែមទាំងនេះឬមុនពេលគាត់ចាកចេញពីប្រទេសដើមរបស់គាត់ ?

○ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម- សំណួរដាក់លាក់បន្ថែម

សំណួរខាងក្រោម អាចយកទៅប្រើបានគ្រប់ទម្រង់ទាំងអស់នៃការកេងប្រវ័ញ្ចពលកម្ម រួមទាំងការងារបម្រើតាមផ្ទះ ។ នៅក្នុងករណីកេងប្រវ័ញ្ចកម្លាំងពលកម្ម គឺវាមានសារៈសំខាន់ក្នុងការបញ្ជាក់ច្បាស់ជាមួយជនរងគ្រោះជាសាក្សីថា ការពិតគាត់ធ្វើការស្ថិតនៅក្នុងលក្ខខណ្ឌនៃការងារបង្ខំ- អាចនិយាយថា គាត់បានធ្វើការងារផ្ទុយពីឆន្ទៈរបស់គាត់ ហើយមិនអាចចាកចេញពីការងារនោះដោយគ្មានទទួលផលវិបាកនោះទេ ។ ការវិភាគមួយធ្វើឡើង ដោយអង្គការពលកម្មអន្តរជាតិ (ILO) បានកំណត់ធាតុផ្សំគន្លឹះទាំង ៦ ដែលមានលក្ខណៈជាការកេងប្រវ័ញ្ចកម្លាំងពលកម្ម ៖

- ប្រើប្រាស់ ឬគំរាមកំហែង ដោយអំពើហិង្សាខាងផ្នែករាងកាយ និង/ឬផ្លូវភេទ
- ការរឹតត្បិតលើការបន្លាស់ទី
- ការឱ្យខ្ចីប្រាក់ដោយមានលក្ខខណ្ឌបង្ខំ
- បង្អកទុក ឬបដិសេធមិនបើកប្រាក់ខែ

- ដកហូតលិខិតឆ្លងដែន និងឯកសារសម្គាល់ខ្លួន...
- គំរាមកំហែងក្នុងការចោទប្រកាន់ពីស្ថានភាពខុសច្បាប់ទៅឱ្យអាជ្ញាធរ ។

អង្គការពលកម្មអន្តរជាតិ បានធ្វើឱ្យប្រសើរឡើងក្នុងការកំណត់នូវប្រភេទសូចនាករ អំពីសមាសភាគគន្លឹះពីរនៃការកេងប្រវ័ញ្ចពលកម្ម ដោយបង្ខំ-មិនស្ម័គ្រចិត្ត(សេរីភាព) និងការគំរាមកំហែង ។ កត្តាទាំងអស់នេះត្រូវបានកំណត់នៅក្នុងតារាងខាងក្រោម៖

| មិនស្ម័គ្រចិត្ត (សេរីភាព) | គំរាមកំហែង-ប្រើប្រាស់ការគំរាមកំហែង |
|---|---|
| កើតមក ឬតពូជ នៅក្នុងទាសករ ឬពលកម្មរំលស់បំណុល | អំពើហិង្សាខាងផ្នែករូបកាយទៅលើកម្មករ គ្រួសារ ឬសាច់ញាតិជិតស្និទ្ធ |
| ការចាប់ពង្រត់ ឬចាប់ជំរិត | អំពើហិង្សាខាងផ្លូវភេទទៅលើកម្មករ គ្រួសារ ឬសាច់ញាតិជិតស្និទ្ធ |
| លក់ជាកម្មសិទ្ធិឱ្យទៅអ្នកដទៃ | ការចងពៀរតប-ឱ្យស្បថថាស្មោះត្រង់... |
| ការឃុំឃាំងខ្លួននៅកន្លែងធ្វើការ | ដាក់គុក និងទម្រង់ដទៃទៀតនៃការឃុំខ្លួន |
| ការបង្ខំផ្លូវចិត្ត-បញ្ជាឱ្យធ្វើការសងវិញ ដែលជា ពិន័យនៃការមិនគោរពតាម | រាយការណ៍ពីស្ថានភាពខុសច្បាប់ទៅអាជ្ញាធរ-នគរបាលអន្តោប្រវេសន៍... និងគំរាមកំហែង បញ្ជូនចេញពីប្រទេស |
| នាំឱ្យមានជំពាក់បំណុល-ការបន្លំគណនេយ្យ បំប៉ោងតម្លៃ កាត់បន្ថយតម្លៃនៃទំនិញ ឬសេវាដែលបានធ្វើ និងការប្រាក់មានតម្លៃហួសហេតុ | បញ្ឈប់ការងារនៅពេលបច្ចុប្បន្ន |
| | បញ្ឈប់ពីការងារនៅពេលអនាគត |
| បន្លំ ឬសន្យាក្លែងក្លាយ ពីប្រភេទនិងលក្ខខណ្ឌនៃការងារ | ដាក់ឱ្យនៅដាច់ពីសហគមន៍ |
| បង្អកទុក ឬមិនបង់ប្រាក់ខែ | ការដកហូតសិទ្ធិសេរីភាព និង/ឬបុព្វសិទ្ធិ |
| ដកហូតទុកឯកសារសម្គាល់ខ្លួន ឬកម្មសិទ្ធិទៅលើរបស់របរមានតម្លៃផ្សេងទៀត | បង្អត់អាហារ ជម្រក និងតម្រូវការចាំបាច់នានា |
| | ប្តូរការងារដែលមានលក្ខខណ្ឌពិបាកជាងមុន |
| | បាត់បង់ឋានៈក្នុងសង្គម |

អ្នកសម្ភាសគួររកឱ្យឃើញពីវិធីសាស្ត្រនៃការកេងប្រវ័ញ្ច និងមធ្យោបាយនៃការបង្ខំឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន ។ ចំណុចសំខាន់ៗដែលត្រូវស្វែងរកគឺ (១) ប្រភេទការងារ និងលក្ខខណ្ឌនានា (២) ថាតើការងារនេះធ្វើឡើងដោយឆន្ទៈ ឬអត់ (៣) មធ្យោបាយបង្ខំ ឬគំរាមកំហែងដែលបានប្រើប្រាស់ ដើម្បីធានាថា ជនរងគ្រោះមិនអាចចាកចេញពីការងារ ឬកន្លែងការងារ ។

- វិធីសាស្ត្រកេងប្រវ័ញ្ច

- តើគាត់ធ្វើការនៅក្នុងប្រភេទអ្វី-ទទួលព័ត៌មានលម្អិតពីសកម្មភាពការងារប្រចាំថ្ងៃ?
- តើ១ សប្តាហ៍គាត់ធ្វើការប៉ុន្មានថ្ងៃ និងមួយថ្ងៃប៉ុន្មានម៉ោង?
- តើគាត់ចាប់ផ្តើមការងារនៅពេលណា?
- នៅពេលគាត់ចាប់ផ្តើមការងារដំបូង តើគាត់ធ្វើការដោយស្ម័គ្រចិត្តឬ? ប្រសិនបើមិនមែនទេ តើកត្តាអ្វីខ្លះដែលធ្វើឱ្យគាត់បំពេញការងារដោយមិនស្ម័គ្រចិត្ត?
- តើការងារនោះផលិតអ្វី វត្ថុជាតុដើម អណ្តូងរ៉ែ សម្លៀកបំពាក់ ផលិតផលកសិកម្ម សំណង់ សេវាតាមផ្ទះ- ជូតសម្អាត-បោកគក់ ដាំស្ល...?
- បើដឹង តើទំនិញដែលផលិតដោយពលកម្មកេងប្រវ័ញ្ចនោះ មានតម្លៃប៉ុន្មាន?
- តើលក្ខខណ្ឌការងារមានអ្វីខ្លះ-ពន្លឺ កម្តៅ ភេសជ្ជៈ បន្ទប់ទឹក សង្គ្រោះបន្ទាន់ និង/ឬ ការព្យាបាល?
- តើជនរងគ្រោះអនុញ្ញាតឱ្យបន្លាស់ទីដោយសេរី នៅក្នុងទីកន្លែងកេងប្រវ័ញ្ចឬទេ? ប្រសិនបើមិនអនុញ្ញាតទេ តើមធ្យោបាយអ្វីដែលបានប្រើប្រាស់ក្នុងការរឹតត្បិតសេរីភាព បន្លាស់ទីនៅក្នុងកន្លែងនោះ ច្រវ៉ាក់ ឬការរឹតត្បិតដទៃទៀត ដាក់នៅក្នុងបន្ទប់ ឬចាក់សោ?
- តើជនរងគ្រោះត្រូវបានអនុញ្ញាតឱ្យបន្លាស់ទីដោយសេរី ក្នុងនិងខាងក្រៅទីកន្លែងកេងប្រវ័ញ្ច ឬប្រសិនបើមិនអនុញ្ញាតទេ តើមធ្យោបាយអ្វីដែលបានប្រើប្រាស់ក្នុងការ រឹតត្បិតសេរីភាព បន្លាស់ទី- បង្ហួចដាក់ចំរឹង ចាក់សោទ្វារចូល អ្នកយាម ឆ្កែយាម...?
- តើគាត់ត្រូវបានគ្រប់គ្រងដោយជនជួញដូរ នៅពេលគាត់ធ្វើការ ឬប្រសិនបើមែន តើអ្នកណាជាអ្នកគ្រប់គ្រងគាត់ តើគេបញ្ជាឱ្យធ្វើអ្វីខ្លះ ក្នុងការអនុវត្តការងារ និងការទទួលខុសត្រូវ?
- តើគាត់ត្រូវបាននគរបាល ឬទីភ្នាក់ងារដទៃទៀតសម្គាល់ឃើញដែរឬទេ? ប្រសិនបើមែន តើនៅពេលណា កន្លែងណា និងលិខិតសម្គាល់អ្វីដែលគាត់ប្រើប្រាស់ ក្នុងការបង្ហាញដល់នគរបាល ឬទីភ្នាក់ងារនោះ?
- តើទីកន្លែងកេងប្រវ័ញ្ច ធ្លាប់ត្រូវបានពិនិត្យមើល ដោយមន្ត្រីអនុវត្តច្បាប់ ឬភ្នាក់ងារដទៃទៀតដែរឬទេ? ប្រសិនបើធ្លាប់ នៅពេលណា អ្នកណាជាអ្នកពិនិត្យ តើគាត់ត្រូវបានគេតម្រូវឱ្យផ្តល់ឈ្មោះ និងឯកសារដទៃទៀតដែរឬទេ? ប្រសិនបើមែន តើឈ្មោះអ្វីដែលគាត់បានប្រើ និងព័ត៌មានអ្វីខ្លះដែលគាត់បានផ្តល់ឱ្យ?
- ប្រសិនបើគាត់ដេកនៅកន្លែងដាច់ដោយឡែក ពីទីតាំងកេងប្រវ័ញ្ច តើគាត់ទៅ និងមកពីកន្លែងស្នាក់នៅ និងកន្លែងកេងប្រវ័ញ្ច ដោយរបៀបដូចម្តេចរៀងរាល់ថ្ងៃ? កំណត់ឱ្យឃើញពីមធ្យោបាយធ្វើដំណើរ និងអ្នកដែលពាក់ព័ន្ធ និងផ្លូវដែលបានប្រើ
- ប្រសិនបើគាត់ស្នាក់នៅដាច់ដោយឡែកពីកន្លែងកេងប្រវ័ញ្ច តើកម្រិតសេរីភាពបន្លាស់ទីអ្វីដែលគាត់មាននៅឯកន្លែងនោះ? ប្រសិនបើសេរីភាពនៃការបន្លាស់ទី ត្រូវបានរឹតត្បិត តើមធ្យោបាយអ្វីខ្លះ ដែលបានប្រើប្រាស់ និងដោយអ្នកណា?

- រៀបរាប់ពីលក្ខខណ្ឌនៃការស្នាក់នៅ ជាញឹកញាប់ ចំនួន និងប្រភេទម្ហូបអាហារ និងភេសជ្ជៈ ដែលផ្តល់ដល់គាត់ កន្លែងដេក ទំហំគ្រែ បង្គន់ និងកន្លែងសម្អាត កន្លែងកម្សាន្ត
- តើគេអនុញ្ញាតឱ្យគាត់មានពេលវេលា ខាងផ្នែកសង្គម ឬកម្សាន្តណាមួយ ដែរឬទេ តើគេអនុញ្ញាតឱ្យគាត់មានទម្រង់ណាមួយ នៃទំនាក់ទំនងសង្គមជាមួយសមាជិកគ្រួសារ អ្នកដែលខ្លួនស្រឡាញ់ មិត្តភក្តិ ឬជនណាមួយក្រៅពីអ្នកដែលធ្វើការជាមួយឬទេ ?
- បើអនុញ្ញាតឱ្យមានទំនាក់ទំនង តើវាកើតឡើងយ៉ាងដូចម្តេច និងញឹកញាប់ប៉ុណ្ណា ?
- នៅក្នុងអំឡុងពេលនៃការពន្យល់ តើជនរងគ្រោះមានឯកសារសម្គាល់ខ្លួន និង/ឬ លិខិតធ្វើដំណើររបស់គាត់ឬទេ ?
- ប្រសិនបើមិនមាន អ្នកណាជាអ្នកកាន់កាប់ឯកសារទាំងនោះ អ្នកណាជាអ្នកយកឯកសារទាំងនោះ ជាលើកទី១ ហើយគេរក្សាទុកវានៅកន្លែងណា ?
- តើមានការពន្យល់ណាមួយ ទាក់ទងទៅនឹងមូលហេតុ ដែលដកទុកលិខិតទាំងអស់នោះ ? ប្រសិនបើមែន តើការពន្យល់នោះថាដូចម្តេច ហើយអ្នកណាជាអ្នកផ្តល់ការពន្យល់នេះ ?
- នៅពេលនេះ ឯកសារទាំងនោះនៅឯណា ?

○ ចំណុចខាងផ្នែកហិរញ្ញវត្ថុ

- តើជនរងគ្រោះ ជឿថាខ្លួនទទួលបានប្រាក់ខែឬទេ ?
- តើគាត់ធ្លាប់ទទួលបានប្រាក់ខែដែរឬទេ ? ប្រសិនបើមាន បញ្ជាក់ពីចំនួនទឹកប្រាក់ កាលបរិច្ឆេទនៃការបើកប្រាក់ខែ និងអ្នកណាជាផ្តល់ប្រាក់ខែឱ្យ ?
- ប្រសិនបើប្រាក់ខែបានបើក តើមានការកត់ត្រាទុក ឬបើកប្រាក់ខែឈរលើអត្រាអ្វី សៀវភៅគណនេយ្យ តើគាត់បានចុះហត្ថលេខាទៅលើការបើកប្រាក់ខែនោះឬ? ប្រសិនបើមែន តើកំណត់ហេតុនៃការចុះហត្ថលេខានោះនៅឯណា ?
- ប្រសិនបើប្រាក់ខែនោះមិនបានបើកទេ តើគាត់ធ្លាប់សួរពីមូលហេតុដែរឬទេ ? ប្រសិន បើមែន តើគាត់សួរអ្នកណា ហើយចម្លើយមានអ្វីដែរ ?
- ប្រសិនបើគាត់បានប្រឈមមុខ ឬតវ៉ាពីការមិនបើកប្រាក់ខែ តើគាត់តវ៉ាជាមួយអ្នកណា តើគេឆ្លើយថាដូចម្តេច ?
- តើគាត់អាចប៉ាន់ស្មានចំនួនទឹកប្រាក់សរុប ដែលគាត់រកបាននៅក្នុងរយៈពេលនោះឬទេ តើមានជំពាក់ប្រាក់ខែ ប្រសិនបើពួកគេមិនបានបើក ?
- ប្រសិនបើប្រាក់ខែបានបើក តើប្រាក់នោះយ៉ាងម៉េចដែរ តើប្រាក់នោះគាត់ទុកខ្លួនឯង ឬគាត់ត្រូវបានគេប្រាប់ថា ប្រាក់នោះគួររក្សាទុកឱ្យមានសុវត្ថិភាព ? ប្រសិនបើមែន អ្នកណាជាអ្នករក្សាទុកប្រាក់ខែនោះ ?
- តើគាត់បានបញ្ជូនប្រាក់ទៅផ្ទះដែរឬទេ បើមែន នៅពេលណា ទៅឱ្យអ្នកណា ចំនួនប៉ុន្មាន តើធ្វើយ៉ាងដូចម្តេច ការបញ្ជូនប្រាក់ ប្រៃសណីយ៍... បញ្ជាក់ពី អាសយដ្ឋានណាមួយដែលពាក់ព័ន្ធទៅនឹងការផ្ទេរប្រាក់នោះ ភ្នាក់ងារប្តូរប្រាក់ ប្រៃសណីយ៍...

▪ តើមានការឱ្យសងប្រាក់ ដែលជំពាក់បំណុល តាមរយៈការងារ ឬសេវា បើមែន តើគេប្រាប់គាត់ថាជំពាក់ប៉ុន្មាន តើគាត់ត្រូវសងក្នុងកម្រិតអត្រាណាទៅលើបំណុលនោះ ?

▪ តើមានពិន័យជាប្រាក់ទៅលើគាត់ដែរឬទេ ដូចជា ពិន័យចំពោះការមិនបំពេញការងារ ទៅតាមគោលដៅ ឬការងារមិនមានគុណភាព ឬពីការតវ៉ាពីស្ថានភាពទាំងអស់នេះ ?

▪ ប្រសិនបើមាន អ្នកណាជាអ្នកប្រាប់គាត់អំពីពិន័យនេះ តើពិន័យនេះមានចំនួនប៉ុន្មាន តើប្រាក់ពិន័យប្រមូលយ៉ាងដូចម្តេច តើគេកាត់ដោយផ្ទាល់ពីប្រាក់ខែឬ ?

▪ តើគាត់តម្រូវឱ្យបង់ការចំណាយបន្ថែមទៅលើហេដ្ឋារចនាសម្ព័ន្ធ ដូចជា ចំណាយការស្នាក់នៅ ម្ហូបអាហារ ឧបករណ៍សម្ភារៈ...? ប្រសិនបើមាន តើការបង់ប្រាក់នេះ ទៅឱ្យអ្នកណា តើប្រាក់នេះកាត់ដោយផ្ទាល់ពីប្រាក់ខែឬ ?

▪ តើគាត់ត្រូវបានគេប្រាប់ពីការបង់ប្រាក់បន្ថែមទាំងនេះ មុនគាត់ចាកចេញពីផ្ទះឬ ?

○ ការគំរាមកំហែង និងបង្ខំ

▪ តើគាត់ត្រូវបានគំរាមកំហែង ឬជាកម្មវត្ថុនៃការបំពាន ហិង្សាខាងផ្លូវភេទនៃដំណាក់កាលណាមួយ ឬប្រសិនបើមាន រៀបរាប់ពីព្រឹត្តិការណ៍ អ្នកណាដែលពាក់ព័ន្ធ និងបរិបទនៃអំពើនោះ

▪ តើគាត់ត្រូវបានគំរាមកំហែង ដោយសងសឹកទៅលើក្រុមគ្រួសារ ឬអ្នកដែលខ្លួនស្រឡាញ់ បើមាន រៀបរាប់ពីព្រឹត្តិការណ៍នោះ អ្នកពាក់ព័ន្ធ និងបរិបទនៃអំពើនោះ ?

▪ តើជនរងគ្រោះត្រូវបានគំរាមកំហែង ដេញចោលមិនឱ្យធ្វើការ ឬដកចេញពីការងារនៅពេលអនាគត ប្រសិនបើមែន តើនៅក្នុងបរិបទអ្វីដែលការគំរាមកំហែងនេះធ្វើឡើង ហើយអ្នកណាជាអ្នកគំរាមកំហែង ?

▪ តើជនរងគ្រោះធ្លាប់ត្រូវបានគំរាមកំហែង ពីការបង្ហាញឱ្យដឹង ឬរាយការណ៍ទៅឱ្យអាជ្ញាធរ ដូចជាការចាប់ខ្លួន និង/ឬការបណ្តេញចេញដោយស្ថានភាពខុសច្បាប់នៅក្នុងប្រទេសនោះ ? ប្រសិនបើមែន តើគេគំរាមកំហែងដោយរបៀបណា ហើយអ្នកណាជាអ្នកគំរាមកំហែង ?

▪ តើមានយន្តការត្រួតត្រា ដែលមានលក្ខណៈបង្ខំផ្សេងទៀតដែរឬទេ ដូចជា ការបង្ខំខាងផ្នែកវប្បធម៌ ឬសាសនា ?

▪ តើយន្តការត្រួតត្រានោះ ត្រូវបានប្រើប្រាស់ដើម្បីធានាឱ្យគាត់ធ្វើតាមការណែនាំរបស់ជនជួញដូរ ទាក់ទងទៅនឹងការងារ ឬទប់ស្កាត់កុំឱ្យរត់គេចខ្លួន ឬទាំងពីរ ?

▪ បញ្ចូលព័ត៌មានពេញលេញ ទាក់ទងទៅនឹងជនជួញដូរ ជនរងគ្រោះ ទីកន្លែង និងយានយន្ត ដែលជាផ្នែកនៃដំណាក់កាលប្រទេសគោលដៅ ហើយជាការបន្ថែមទៅនឹងអ្វី ដែលបានបញ្ជាក់រួចមកហើយ នៅក្នុងដំណាក់កាលប្រភពដើម ឆ្លងកាត់ និងទទួល

▪ ទាក់ទងទៅនឹងចំណុចទាំងអស់ខាងលើនេះ តើមានសាក្សីណាមួយនៅក្នុងព្រឹត្តិការណ៍នេះ ដែរឬទេ ប្រសិនបើមាន ប្រមូលព័ត៌មានឱ្យបានពេញលេញ ។

○ សំណួរគន្លឹះចុងក្រោយ

- តើនៅក្នុងដំណាក់កាលណាមួយនៃរឿងនេះ ដែលគាត់ផ្តល់ការងារ ឬសេវាដែលមិនមានលក្ខណៈស្ម័គ្រចិត្ត និងហេតុអ្វី?
- តើគាត់មានអារម្មណ៍អ្វី ជឿអ្វីខ្លះថាជនជួញដូរនឹងធ្វើ ប្រសិនបើគាត់ប៉ុនប៉ងឈប់បំពេញការងារនោះ?
- តើគាត់មានគំនិតអ្វី ជឿថាអ្វីដែលជនជួញដូរនឹងធ្វើ ប្រសិនបើគាត់ព្យាយាមរត់?
- នៅពេលណា នៅក្នុងអំឡុងពេលនៃដំណាក់កាលកេងប្រវ័ញ្ច ដែលជនរងគ្រោះមានឱកាសរត់គេចខ្លួន ឬមានឱកាសស្វែងរកជំនួយពីមន្ត្រីអនុវត្តច្បាប់?
- ប្រសិនបើមាន តើគាត់បានព្យាយាមធ្វើអ្វី?
- ប្រសិនបើមិនមាន ហេតុអ្វី តើគាត់មានអារម្មណ៍យ៉ាងដូចម្តេច?

○ ការជួញដូរមនុស្សសម្រាប់ការដកហូតសរីរាង្គ-សំណួរដាក់លាក់បន្ថែម

នៅក្នុងករណីជួញដូរមនុស្សសម្រាប់ការដកហូតសរីរាង្គ អ្នកស៊ើបអង្កេតនឹងតម្រូវឱ្យត្រៀមរៀបចំការសម្ភាសពីរប្រភេទសម្រាប់អ្នកផ្តល់សរីរាង្គ និងអ្នកទទួលសរីរាង្គ ។ (ចំពោះពាក្យច្បាប់ដែលមានលក្ខណៈចង្អៀត ទាំងអ្នកផ្តល់ និងអ្នកទទួលសរីរាង្គ អាចនិយាយថា គឺជាអ្នកសមគំនិត នៅក្នុងផែនការអនុវត្តផ្ទេរសរីរាង្គដោយខុសច្បាប់ ប៉ុន្តែ គោលដៅរបស់អ្នកស៊ើបអង្កេត គឺជនជួញដូរដែលទទួលបានប្រាក់ចំណេញយ៉ាងច្រើនពីពាណិជ្ជកម្មនេះ)។

ដោយសារមូលហេតុនេះ សំណួរលម្អិតនៅក្នុងផ្នែកនេះត្រូវបែងចែកជាពីរប្រភេទនៃអ្នកផ្តល់ និងអ្នកទទួលសរីរាង្គ ។

- ការសម្ភាសជាមួយអ្នកផ្តល់សរីរាង្គ(ម្ចាស់អំណោយ)
  - ប្រវត្តិផ្ទាល់ខ្លួន និងក្រុមគ្រួសារ
    - + រកឱ្យឃើញអាយុពិតប្រាកដ ថ្ងៃខែឆ្នាំកំណើត សញ្ជាតិ ប្រវត្តិគ្រួសារ និងរបៀបរស់នៅជាទូទៅ
    - + តើស្ថានភាពសេដ្ឋកិច្ចរបស់ម្ចាស់អំណោយយ៉ាងដូចម្តេច នៅពេលដែលគេជ្រើសរើស?
    - + តើកត្តាអ្វីខ្លះ ដែលធ្វើឱ្យម្ចាស់អំណោយ យល់ព្រមផ្តល់សរីរាង្គ?
  - ប្រវត្តិព្យាបាល
    - + រកឱ្យឃើញប្រវត្តិព្យាបាលទូទៅ មុនការដកហូតសរីរាង្គ
    - + តើស្ថានភាពសុខភាពជាទូទៅរបស់ម្ចាស់អំណោយ យ៉ាងដូចម្តេចដែរ មុនពេលផ្តល់សរីរាង្គ?
    - + តើមានកំណត់ហេតុពីការព្យាបាលណាមួយឬទេ?
    - + តើគាត់ទទួលការព្យាបាលណាមួយទាក់ទងនឹងបញ្ហានៃសរីរាង្គនោះឬ?
  - ទំនាក់ទំនងជាមួយជនជួញដូរ/អ្នកជ្រើសរើស/មេខ្យល់

+ តើអ្នកណា និងតាមមធ្យោបាយអ្វី ដែលធ្វើឱ្យមានទំនាក់ទំនងដំបូង ជាមួយជនជួញដូរ? ទីតាំងណានៃការជួបគ្នា?
+ តើការប្រាស្រ័យទាក់ទងដោយមធ្យោបាយអ្វីជាមួយជនជួញដូរ ៖ ទំនាក់ទំនងដោយផ្ទាល់ ទូរស័ព្ទអ៊ីមែលហ្វាក់ ?
+ ព័ត៌មានលម្អិតអ្វីខ្លះដែលផ្តល់ឱ្យ ទាក់ទងទៅនឹងអត្តសញ្ញាណរបស់អ្នកទទួលសរីរាង្គ?
+ តើម្ចាស់អំណោយ អាចរៀបរាប់ព័ត៌មានលម្អិតពី ឈាម ឬកោសិកា ដែលសមស្របទៅនឹងនីតិវិធី ការណាត់ជួបខាងផ្នែកវេជ្ជសាស្ត្រ ទៅពិនិត្យកន្លែងពិសោធន៍ ឬនៅគ្លីនិក យកឈាមវិភាគ?
+ តើម្ចាស់អំណោយ បានទទួលនូវការពន្យល់ខាងផ្នែកវេជ្ជសាស្ត្រណា មួយជាមុនដែរឬទេ ដែលជាសិទ្ធិរបស់គាត់ ហើយហានិភ័យ និងផលវិបាកទៅលើសុខភាព ពីការដកហូតសរីរាង្គនោះ?

- ការដឹកជញ្ជូន
  + តើផ្លូវណាមួយដែលចេញពីផ្ទះទៅកន្លែងវះកាត់?
  + តើម្ចាស់អំណោយ ធ្វើដំណើរដោយបិទបាំង ឬដោយបើកចំហ?
  + តើវិធីសាស្ត្រអ្វីក្នុងការដឹកជញ្ជូន? រកឱ្យឃើញព័ត៌មានលម្អិត?
  + រកឱ្យឃើញប្រវត្តិពេញលេញ និងការទិញ ឯកសារអត្តសញ្ញាណ និង/ឬធ្វើដំណើរ និងទិដ្ឋាការប្រើប្រាស់ សម្រួលដល់ការធ្វើដំណើរ ។
  + តើម្ចាស់អំណោយ មានអ្នកអមដំណើរឬ បើមាន អមដោយអ្នកណា?
  + តើម្ចាស់អំណោយបានបំពេញបែបបទធ្វើដំណើរ នៃដំណាក់កាលណា មួយនៃការធ្វើដំណើរឬទេ?
  + តើម្ចាស់អំណោយត្រូវបានគេជួប នៅពេលទៅដល់កន្លែងវះកាត់ ឬប្រសិនបើមែន រកឱ្យឃើញព័ត៌មានលម្អិត?
  + តើម្ចាស់អំណោយធ្វើដំណើរយ៉ាងដូចម្តេចពីចំណុចទៅដល់ និងកន្លែងវះកាត់? រកឱ្យឃើញការធ្វើដំណើរឱ្យបានលម្អិត ។
- ការដកហូតសរីរាង្គ
  + ទីតាំងពិតប្រាកដ និងរៀបរាប់ពីកន្លែងវេជ្ជសាស្ត្រ មន្ទីរពេទ្យឬគ្លីនិកឯកជន?
  + រកឱ្យឃើញអត្តសញ្ញាណ និងព័ត៌មានបុគ្គលិកពេទ្យដែលពាក់ព័ន្ធ ។
  + តើមានព័ត៌មានវេជ្ជសាស្ត្រណាមួយដែលបានផ្តល់ឱ្យ ដែលជាសិទ្ធិរបស់ម្ចាស់អំណោយ ឬហានិភ័យ និងផលវិបាកនៃការដកហូតសរីរាង្គ?
  + តើម្ចាស់អំណោយបានចុះហត្ថលេខាទៅលើឯកសារណាមួយ ស្តីពីការយល់ព្រមឱ្យធ្វើការវះកាត់ និង/ឬទទួលស្គាល់ ពីការទទួលបាននូវការពន្យល់ពី

ហានិភ័យ និងផលវិបាកនានា?

+ តើម្ចាស់អំណោយ ត្រូវបានគេឱ្យចុះហត្ថលេខា ទៅលើកិច្ចព្រមព្រៀងសម្ងាត់ណាមួយឬទេ?
+ តើសរីរាង្គណាមួយដែលត្រូវបានយកចេញ?
+ តើម្ចាស់អំណោយ ចំណាយរយៈពេលយូរប៉ុន្មាននៅកន្លែងពេទ្យនោះ?
+ តើម្ចាស់អំណោយបានជួបអ្នកទទួលអំណោយឬទេ?
+ តើរយៈពេល និងប្រភេទថែរក្សាអ្វីខ្លះ ក្រោយពេលវះកាត់?
+ តើការព្យាបាលអ្វីខ្លះដែលផ្តល់ទៅឱ្យម្ចាស់អំណោយ?
+ រកឱ្យឃើញព័ត៌មានលម្អិតពីការធ្វើដំណើរវិលត្រឡប់របស់ម្ចាស់អំណោយ
+ តើមានការពិនិត្យបន្តខាងផ្នែកវេជ្ជសាស្ត្រណាមួយ ឬការថែរក្សា បន្ទាប់ពីការផ្ទេរសរីរាង្គរបស់ម្ចាស់អំណោយ បន្ទាប់ពីគាត់ត្រឡប់ទៅផ្ទះវិញ?

- ការបង់ប្រាក់
  + តើសរីរាង្គថ្លៃប៉ុន្មាន ដែលម្ចាស់អំណោយយល់ព្រម មុនចាកចេញពីផ្ទះ?
  + តើម្ចាស់អំណោយត្រូវបានប្រាប់ពីតម្លៃដែលអ្នកទទួលអំណោយត្រូវបង់ឬ?
  + ប្រសិនបើមែន តើម្ចាស់អំណោយនៅតែយល់ព្រមទៅលើតម្លៃលក់នោះ?
  + តើមានប្រាក់ណាខ្លះដែលបានបង់ជាមុន?
  + តើវិធីបង់ប្រាក់តាមរយៈអ្វី ប្រាក់សុទ្ធ ផ្ទេរតាមធនាគារ ការផ្ទេរប្រាក់? ថ្ងៃខែ ពេលវេលា និងទីតាំងនៃការបង់ប្រាក់ បង់ប្រាក់ដោយអ្នកណា?
  + មានអ្វីកើតឡើងចំពោះប្រាក់នោះ ចាប់តាំងពីថ្ងៃបង់ប្រាក់មក?
- ផលប៉ះពាល់ទៅលើភស្តុតាង
  + តើស្ថានភាពសុខភាពរបស់ម្ចាស់អំណោយយ៉ាងដូចម្តេចដែរ ចាប់តាំងពីការដកហូតសរីរាង្គមក?
  + តើមានផលប៉ះពាល់អ្វីខ្លះ ទៅលើសុខភាព និងរបៀបរស់នៅរបស់គាត់?
  + តើមានសូចនាករណាមួយ ដែលទាក់ទងទៅនឹងភាពអន់ខ្សោយនៃសុខភាពរបស់គាត់?
  + ប្រសិនបើមាន រកឱ្យឃើញព័ត៌មានលម្អិតពីការព្យាបាល ទាក់ទងទៅនឹងបញ្ហាសុខភាពនោះ?
- សាក្សី និងជនសង្ស័យ
  + រកភស្តុតាងនៃចម្លើយសាក្សីបំពេញបន្ថែម គ្រួសារ មិត្តភក្តិ អ្នកជំនាញ វេជ្ជសាស្ត្រនៅឯភូមិកំណើតរបស់គាត់ ។
  + រកឱ្យឃើញព័ត៌មានលម្អិត ពីរូបរាងរបស់ជនសង្ស័យទាំងអស់ ដែលពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋ ទំនាក់ទំនង តួនាទី និងបណ្តាញរបស់ពួកគេ

+ រកឱ្យឃើញព្រឹត្តិការណ៍ជាក់លាក់ណាមួយ រៀបរាប់ពីពិរុទ្ធភាពដែលបានដឹងជាពិសេស ព្រឹត្តិការណ៍ណាមួយ ដើម្បីបង្ហាញថា ជនជួញដូរបានដឹងថាម្ចាស់អំណោយមិនមែនជាសមាជិកគ្រួសារ ឬប្តីប្រពន្ធរបស់អ្នកទទួលអំណោយឡើយ
+ ទទួលព័ត៌មានដែលពាក់ព័ន្ធ មធ្យោបាយធ្វើដំណើរ គណនេយ្យ ការប្រាស្រ័យទាក់ទង... ។

▪ ការសម្ភាសជាមួយអ្នកទទួលអំណោយ-ប្រសិនបើរកឃើញ
  - ប្រវត្តិរូបផ្ទាល់ខ្លួន និងគ្រួសារ
    + រកឱ្យឃើញពីអាយុពិតប្រាកដ ថ្ងៃខែឆ្នាំកំណើត សញ្ជាតិ ប្រវត្តិគ្រួសារ និងរបៀបរស់នៅជាទូទៅ
    + រកឱ្យឃើញពីស្ថានភាពសេដ្ឋកិច្ច នៅពេលដូរសរីរាង្គដោយខុសច្បាប់ ។
  - ប្រវត្តិព្យាបាល
    + រកឱ្យឃើញប្រវត្តិព្យាបាល មុនបទល្មើស សុខភាពទូទៅ កំណត់ហេតុនានានៃការព្យាបាល
    + ព័ត៌មានលម្អិតនៃប្រវត្តិព្យាបាល ទាក់ទងទៅនឹងបញ្ហាណាមួយ ដែលពាក់ព័ន្ធទៅនឹងសរីរាង្គនោះ មជ្ឈមណ្ឌល ឬគ្រូពេទ្យព្យាបាល ទីតាំងនៃកំណត់ហេតុវេជ្ជសាស្ត្រ
    + តើស្ថានភាពសុខភាពរបស់អ្នកទទួលអំណោយ និងការគិតទុកជាមុនខាងផ្នែកវេជ្ជសាស្ត្រ មុនការដូរសរីរាង្គ?
    + តើអ្នកទទួលអំណោយបានជឿពីផលប៉ះពាល់ នៃលក្ខខណ្ឌវេជ្ជសាស្ត្រ និងសេចក្តីរំពឹងទុកនៃជីវិត និងរបៀបរស់នៅដែរឬទេ?
    + តើកត្តាជំរុញអ្វីខ្លះក្នុងការស្វែងរកការដូរសរីរាង្គដោយខុសច្បាប់?
  - ទំនាក់ទំនងជាមួយជនជួញដូរ/អ្នកជ្រើសរើស/មេខ្យល់
    + តើអ្នកណា និងតាមមធ្យោបាយអ្វី ដែលធ្វើឱ្យមានទំនាក់ទំនងដំបូង ជាមួយជនជួញដូរ ទីកន្លែងនៃការជួបគ្នា?
    + តើការប្រាស្រ័យទាក់ទងដោយមធ្យោបាយអ្វីជាមួយជនជួញដូរ៖ ទំនាក់ទំនងដោយផ្ទាល់ ទូរស័ព្ទ អ៊ីម៉ែលហ្វាក់ ?
    + ព័ត៌មានលម្អិតអ្វីខ្លះ ដែលផ្តល់ឱ្យ ទាក់ទងទៅនឹងអត្តសញ្ញាណរបស់អ្នកផ្តល់សរីរាង្គ និងមូលហេតុនៃការផ្តល់សរីរាង្គ
    + តើឈាម និងកោសិកា សមស្របទៅនឹងនីតិវិធី ការណាត់ជួបខាងផ្នែក វេជ្ជសាស្ត្រ ទៅពិនិត្យនៅកន្លែងពិសោធន៍ ឬនៅគ្លីនិក យកឈាមវិភាគ?

+ តើអ្នកទទួលអំណោយ បានទទួលនូវការពន្យល់ខាងផ្នែកវេជ្ជសាស្ត្រណាមួយជាមុនដែរឬទេ ដែលជាសិទ្ធិរបស់គាត់ ហើយហានិភ័យ និងផល វិបាកទៅលើសុខភាព ពីការដកហូតសរីរាង្គនោះ?

- ការដឹកជញ្ជូន
  + តើផ្លូវណាមួយដែលចេញពីផ្ទះទៅកន្លែងវះកាត់?
  + តើអ្នកទទួលអំណោយ ធ្វើដំណើរដោយបិទបាំង ឬដោយបើកចំហ?
  + តើវិធីសាស្ត្រអ្វីក្នុងការដឹកជញ្ជូន? រកឱ្យឃើញព័ត៌មានលម្អិត?
  + រកឱ្យឃើញប្រវត្តិពេញលេញ និងការទិញ ឯកសារអត្តសញ្ញាណ និង/ឬ ធ្វើដំណើរ និងទិដ្ឋាការប្រើប្រាស់សម្រួលដល់ការធ្វើដំណើរ
  + តើមានការបំពេញប័ណ្ណអន្តោប្រវេសន៍ចេញដំណើរ ឬមកដល់ ប្រសិនបើមាន រកព័ត៌មានលម្អិតពីទីតាំង និងឈ្មោះដែលបានប្រើ?
- ការដាក់សរីរាង្គ
  + ទីតាំងពិតប្រាកដ និងរៀបរាប់ពីកន្លែងវេជ្ជសាស្ត្រ មន្ទីរពេទ្យឬគ្លីនិកឯកជន?
  + រកឱ្យឃើញអត្តសញ្ញាណ និងព័ត៌មានបុគ្គលិកពេទ្យដែលពាក់ព័ន្ធ
  + តើមានព័ត៌មានវេជ្ជសាស្ត្រណាមួយ ដែលបានផ្ដល់ឱ្យដែលជាសិទ្ធិ ឬហានិភ័យ និងផលវិបាកនៃការដាក់សរីរាង្គ?
  + តើអ្នកទទួលអំណោយបានចុះហត្ថលេខាទៅលើឯកសារណាមួយ ស្ដីពីការយល់ព្រមឱ្យធ្វើការវះកាត់?
  + តើអ្នកទទួលអំណោយ ត្រូវបានគេឱ្យចុះហត្ថលេខា ទៅលើកិច្ចព្រមព្រៀងសម្ងាត់ណាមួយឬ?
  + តើសរីរាង្គណាមួយដែលត្រូវបានដាក់ចូល?
  + តើអ្នកទទួលអំណោយ ចំណាយរយៈពេលយូរប៉ុន្មាននៅកន្លែងវះកាត់?
  + តើអ្នកទទួលអំណោយ បានជួបគ្រូពេទ្យនៅដំណាក់កាលណាមួយ និង/ឬ អ្នកទទួលអំណោយដឹងអំពីអត្តសញ្ញាណរបស់ម្ចាស់អំណោយឬ?
  + តើរយៈពេល និងប្រភេទថែរក្សាអ្វីខ្លះ ក្រោយពេលវះកាត់?
  + តើការព្យាបាលអ្វីខ្លះដែលផ្ដល់ទៅឱ្យអ្នកទទួលអំណោយ?
  + រកឱ្យឃើញព័ត៌មានលម្អិតពីការធ្វើដំណើររបស់អ្នកទទួលអំណោយមកផ្ទះ
  + តើមានការពិនិត្យបន្តខាងផ្នែកវេជ្ជសាស្ត្រណាមួយ ឬការថែរក្សា បន្ទាប់ពីការទទួលសរីរាង្គដែរឬទេ ប្រសិនបើមែន ផ្ដល់ព័ត៌មានលម្អិត?
- ការបង់ប្រាក់
  + តើសរីរាង្គថ្លៃប៉ុន្មាន ដែលអ្នកទទួលអំណោយ យល់ព្រមទិញ
  + តើប្រភពប្រាក់អ្វីរបស់អ្នកទទួលអំណោយ តើអ្នកទទួលអំណោយបង់ប្រាក់

ពីធនធានរបស់ខ្លួនផ្ទាល់ ខ្ចីប្រាក់ពីគេ ឬប្រាក់នោះបង់តាមរយៈ ធានារ៉ាប់រង ខាងផ្នែកវេជ្ជសាស្ត្រឯកជន?

+ តើវិធីបង់ប្រាក់តាមរយៈអ្វី ប្រាក់សុទ្ធ ផ្ទេរតាមធនាគារ ការផ្ទេរប្រាក់? ថ្ងៃខែ ពេលវេលា និងទីតាំងនៃការបង់ប្រាក់ បង់ប្រាក់ដោយអ្នកណា?
+ តើអ្នកទទួលអំណោយគួរបង់ប្រាក់ទៅតាមតម្លៃ ប្រសិនបើគាត់ដឹង តើតម្លៃប៉ុន្មាន ដែលគាត់បានបង់ទៅឱ្យម្ចាស់អំណោយ?

- ផលប៉ះពាល់ទៅលើភស្តុតាង
  + តើស្ថានភាពសុខភាពរបស់អ្នកទទួលអំណោយយ៉ាងដូចម្តេចដែរ ចាប់តាំងពីការដាក់សេរីរាង្គមក?
  + តើមានផលប៉ះពាល់អ្វីខ្លះ ទៅលើសុខភាព និងរបៀបរស់នៅរបស់គាត់?
- សាក្សី និងជនសង្ស័យ
  + រកភស្តុតាងនៃចម្លើយសាក្សីបំពេញបន្ថែម គ្រួសារ មិត្តភក្តិ អ្នកជំនាញ វេជ្ជសាស្ត្រ នៅឯភូមិកំណើតរបស់គាត់
  + រកឱ្យឃើញព័ត៌មានលម្អិត ពីរូបរាងរបស់ជនសង្ស័យទាំងអស់ ដែលពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋ ទំនាក់ទំនង តួនាទី និងបណ្តាញរបស់ពួកគេ
  + រកឱ្យឃើញព្រឹត្តិការណ៍ជាក់លាក់ណាមួយ រៀបរាប់ពីពិរុទ្ធភាពដែលបានដឹងជាពិសេស ព្រឹត្តិការណ៍ណាមួយដើម្បីបង្ហាញថា ជនជួញដូរបានដឹងថា ម្ចាស់អំណោយមិនមែនជាសមាជិកគ្រួសារ ឬប្តីប្រពន្ធរបស់អ្នកទទួលអំណោយ
  + ទទួលព័ត៌មានដែលពាក់ព័ន្ធណាមួយ មធ្យោបាយធ្វើដំណើរ គណនេយ្យ ការប្រាស្រ័យទាក់ទង... ។

- **បញ្ជីផ្ទៀងផ្ទាត់-ខ-ព័ត៌មានជាក់លាក់បន្ថែម-សមាសភាគគន្លឹះទាំង៥**

នៅក្នុងប្រភេទនីមួយៗខាងក្រោម គួរតែមានទិន្ន័យពីអង្គហេតុឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន រួមទាំងព័ត៌មានលម្អិតទាក់ទងទៅនឹងសាក្សីសំខាន់ៗ ដូចនេះ ទិន្នន័យ និងព័ត៌មាន ទាំងនេះ អាចប្រើប្រាស់ ដើម្បីបំពេញបន្ថែមទៅនឹងការរៀបរាប់របស់ជនរងគ្រោះ ។

**សមាសភាគសំខាន់ទាំង៥ មាន ៖**

- ការផ្សព្វផ្សាយ

▪ តើគាត់ឃើញសេចក្តីផ្សព្វផ្សាយនៅកន្លែងណា? តើសេចក្តីផ្សព្វផ្សាយនោះ ជាកាសែត ទស្សនាវដ្តី ទំនាក់ទំនងដោយផ្ទាល់ ការផ្សព្វផ្សាយជា លក្ខណៈមុខរបរ

▪ ប្រសិនបើមានមែន តើការផ្សព្វផ្សាយមួយណា ហើយវាគឺជាការផ្សព្វផ្សាយនៅថ្នាក់មូលដ្ឋាន ឬថ្នាក់ជាតិ? តើផ្នែកណាមួយដែលបង្ហាញ ផ្សព្វផ្សាយពាណិជ្ជកម្ម រកការងារធ្វើ...?

▪ តើគេផ្សព្វផ្សាយតាមវិទ្យុ ឬតាមទូរទស្សន៍? បើមែន តើប៉ុស្តិ៍មួយណា...?

▪ តើពាក្យពិតប្រាកដនៃការផ្សព្វផ្សាយគេថាយ៉ាងដូចម្តេច? តើការផ្សព្វផ្សាយនោះ

មានលក្ខណៈជាការផ្តល់ឱ្យ ឬបានផ្តល់ឈ្មោះបុគ្គលជាក់ លាក់ណាមួយដើម្បីធ្វើការទំនាក់ទំនង?

- តើទំនាក់ទំនងជាមួយនឹងអ្នកផ្សព្វផ្សាយធ្វើឡើងយ៉ាងដូចម្តេច? តើធ្វើឡើងដោយការទៅជួបបុគ្គលនោះផ្ទាល់ ឬតាមរយៈទូរស័ព្ទ ហ្វាក់ អ៊ីមែល ឬសំបុត្រផ្ញើទៅអាសយដ្ឋាន ដូចជាប្រអប់សំបុត្រ? ប្រសិនបើមែន តើលេខអ្វីខ្លះ និងព័ត៌មានលម្អិតផ្សេងទៀត?
- តើគាត់បានរក្សាទុកឯកសារចម្លងនៃការផ្សព្វផ្សាយនោះដែរឬទេ? ប្រសិនបើមែន តើឯកសារនោះនៅឯណា?

  - ការទិញ និងជួល

- តើការជ្រើសរើសគាត់ មានការពាក់ព័ន្ធទៅនឹងការទៅជួបដល់ការិយាល័យ ឬទីកន្លែងរបស់ភ្នាក់ងារណាមួយដែរឬទេ? ប្រសិនបើមាន សូមទទួល ព័ត៌មានលម្អិត និងពេញលេញ
- តើគេយកគាត់ទៅ ឬទុកនៅកន្លែងឯកជនណាមួយ មុននឹងចាកចេញពីប្រទេស?
- តើកន្លែងអ្វីដែលគាត់ទៅជួប ឬកន្លែងណាដែលគេឃុំគាត់ នៅក្នុងប្រទេសឆ្លងកាត់នោះ? សូមទទួលព័ត៌មានលម្អិត
- តើគាត់ត្រូវបានគេយកទៅនៅក្នុងប្រទេសគោលដៅណា ឬផ្ទះសុវត្ថិភាព? ប្រសិនបើមែន សូមទទួលព័ត៌មានលម្អិត
- សូមទទួលព័ត៌មានលម្អិតពីទីកន្លែងណាមួយ ដែលគាត់ត្រូវបានគេកេងប្រវ័ញ្ច រួមមានការរៀបចំ ការតុបតែង និងលក្ខណៈពិសេសផ្សេងទៀត
- ប្រសិនបើគេយកគាត់ទៅកន្លែងណាមួយ ដែលជាផ្នែកមួយនៃដំណើរការជួញដូរមនុស្ស ដូចជា ផ្នែកស្ថានទូតដែលផ្តល់ទិដ្ឋាការ អាគាររដ្ឋាភិបាល មន្ទីរពេទ្យ សាលាភាសា ។ សូមទទួលព័ត៌មានលម្អិត ។

  - ការដឹកជញ្ជូនទាក់ទងទៅនឹងមធ្យោបាយចាកចេញពីប្រទេស

- កាលបរិច្ឆេទពិតប្រាកដ? ចំណុចចេញដំណើរ? កន្លែងឆ្លងកាត់ព្រំដែន?
- តើគាត់ធ្វើដំណើរតែម្នាក់ឯង ឬធ្វើដំណើរជាមួយជនរងគ្រោះផ្សេងទៀត និង/ឬជនជួញដូរមនុស្ស? ប្រសិនបើមែន សូមទទួលព័ត៌មានលម្អិត
- ប្រសិនបើគាត់ធ្វើដំណើរដោយចំហ តើគាត់ប្រើឯកសារសម្គាល់អ្វី? តើឯកសារនោះ ពិតប្រាកដ ឬក្លែងបន្លំ?
- ប្រសិនបើជាឯកសារក្លែងបន្លំ តើគាត់ប្រើឈ្មោះអ្វី? តើឯកសារនោះទទួលបានយ៉ាងដូចម្តេច និងទទួលបានមកពីណា?
- បើមានការពាក់ព័ន្ធ តើអ្នកណាជាអ្នកនាំគាត់ទៅយកលិខិតឆ្លងដែន ឯកសារសម្គាល់ខ្លួន រូបថត? តើគេយកឯកសារទាំង នោះពីកន្លែងណា?
- ប្រសិនបើគាត់ប្រើប្រាស់លិខិតឆ្លងដែន ឯកសារសម្គាល់ខ្លួនពិតប្រាកដ ឬក្លែងក្លាយ តើការចូល/ចេញពីប្រទេសតម្រូវឱ្យមានទិដ្ឋាការដែរ ឬទេ?

- ប្រសិនបើមានមែន តើស្ថានទូតដែលផ្តល់ទិដ្ឋាការណាមួយដែលគាត់ទៅជួប? តើគាត់បានទៅដោយខ្លួនគាត់ម្នាក់ឯង ឬមានអ្នកអមដំណើរ? ប្រសិនបើមានមែន តើអ្នកណាជាអ្នកអមដំណើរ? កាលបរិច្ឆេទ និងពេលវេលានៃការជួបនោះ?
- តើមានការចំណាយដែរឬទេ? តើអ្នកណាជាអ្នកចេញចំណាយ? ហើយធ្វើឡើងដោយមធ្យោបាយអ្វី?
- តើមានការចេញជាវិក្កយបត្រដែរឬទេ? តើវិក្កយបត្រមានបោះត្រាពីកាលបរិច្ឆេទ និងពេលវេលាដែរឬទេ?
- តើគាត់ស្គាល់ពីអត្តសញ្ញាណរបស់មន្ត្រីដែលផ្តល់ទិដ្ឋាការដែរឬទេ ទាក់ទងនឹងការសុំទិដ្ឋាការនោះ? តើគាត់អាចផ្តល់ព័ត៌មានលម្អិតបានទេ?
- តើមានឯកសារផ្សេងទៀតដែលប្រើដើម្បីសុំទិដ្ឋាការដែរឬទេ? ដូចជា លិខិតរ៉ាប់រងចំណាយ សិស្សសាលា មន្ត្រីរាជការ...? ប្រសិនបើមានមែន តើគាត់មានឯកសារចម្លងណាមួយដែរឬទេ? សូមទទួលព័ត៌មានលម្អិត
- តើសំបុត្រធ្វើដំណើរទិញនៅកន្លែងណា ហើយអ្នកណាជាអ្នកទិញ?
- តើការចំណាយធ្វើឡើងដោយមធ្យោបាយអ្វី ប្រាក់សុទ្ធ លិខិតបើកប្រាក់ ឬប័ណ្ណឥណទាន? តើសំបុត្រនោះគេប្រើឈ្មោះអ្វី?
- តើគាត់ត្រូវបានគេអមដំណើរដល់កន្លែងចេញដំណើរឬ? បើមែន តើគាត់ទៅដល់កន្លែងនោះដោយវិធីយ៉ាងដូចម្តេច និងជាមួយអ្នកណា?
- តើគាត់ធ្វើដំណើរជាមួយជនរងគ្រោះដទៃទៀត ឬជនជួញដូរមនុស្សដែរឬទេ? ប្រសិនបើមែន សូមទទួលព័ត៌មានលម្អិត
- តើអ្នកណាជាអ្នកចុះឈ្មោះធ្វើដំណើរ ជាមួយអ្នកណា នៅម៉ោងប៉ុន្មាន?
- តើឥវ៉ាន់អ្វីខ្លះដែលគេចុះឈ្មោះនោះ?
- តើមានការទិញអ្វីនៅកន្លែងចេញដំណើរដែរឬទេ? បើមានមែន តើទិញដោយប្រើមធ្យោបាយអ្វីខ្លះ?
- តើកៅអីប្រភេទអ្វីដែលគេចេញឱ្យ?អង្គុយជិតអ្នកណាលើយន្តហោះ រថយន្ត...?
- តើមានការទិញរបស់ដោយឥតបង់ពន្ធនៅពេលធ្វើដំណើរដែរឬទេ? បើមានមែន តើទិញដោយមធ្យោបាយអ្វី ហើយអ្នកណាជាអ្នកចំណាយ?
- តើពេលចេញដំណើរមានការត្រួតពិនិត្យមើលដែរឬទេ? តើគាត់ត្រូវបាន មន្ត្រីអន្តោប្រវេសន៍ មន្ត្រីព្រំដែន មន្ត្រីគយសួរមុនចាកចេញដែរឬទេ?
- តើគាត់ត្រូវបំពេញទម្រង់ឯកសារណាមួយដែរឬទេ? ប្រសិនបើមែន តើពួកគេប្រគល់ឱ្យអ្នកណា?
- នៅកន្លែងចូលនៃប្រទេសឆ្លងកាត់ និងប្រទេសគោលដៅ តើគាត់ត្រូវបាន មន្ត្រីណាមួយសាកសួរ តើគាត់បានបំពេញឯកសារចូលណាមួយដែរ ឬទេ? ប្រសិនបើមែន តើនៅពេលណា

និងទីកន្លែងណា? តើឈ្មោះអ្វីដែលគាត់បានផ្តល់ឱ្យនោះ?

▪ តើអ្នកធ្វើដំណើរជាមួយគាត់ត្រូវបានមន្ត្រីអន្តោប្រវេសន៍ ធ្វើការសាកសួរដែរឬទេ? បើមែន តើពួកគេបានបំពេញឯកសារណាមួយដែរឬទេ?

○ ការប្រាស្រ័យទាក់ទង

▪ តើទំនាក់ទំនងធ្វើឡើងយ៉ាងដូចម្តេច រវាងជនរងគ្រោះ និងជនជួញដូរមនុស្ស? តាមរយៈទំនាក់ទំនងផ្ទាល់ខ្លួន សំបុត្រ ទូរស័ព្ទលើតុ ទូរស័ព្ទ ចល័ត ហ្វាក់ ឬអ៊ីមែល?

▪ តើលេខទំនាក់ទំនង និងអាសយដ្ឋានទាំងអស់នោះមានអ្វីខ្លះ?

▪ តើគាត់បានឃើញវិក្កយបត្រណាមួយដែរឬទេ? ប្រសិនបើឃើញមែន តើអ្នកណាផ្តល់ប្រាក់នោះ?

▪ ប្រសិនបើជាទូរស័ព្ទចល័ត តើជាប្រភេទទូរស័ព្ទអ្វី? តើគាត់ដឹងពីបណ្តាញទូរស័ព្ទនោះដែរឬទេ? តើគាត់ធ្លាប់បានឃើញបណ្តាញនៅលើកញ្ចក់ ទូរស័ព្ទនោះដែរឬទេ?

▪ តើជនជួញដូរមនុស្សប្រើកុំព្យូទ័រចល័ត និង/ឬកូនសៀវភៅតូច សម្រាប់ធ្វើកំណត់ហេតុ? ប្រសិនបើមាន តើឧបករណ៍នោះជាប្រភេទអ្វី? តើគាត់ដឹងព័ត៌មានលម្អិត ដូចជាលេខសម្ងាត់កុំព្យូទ័រ ប្រព័ន្ធ អ៊ីមែល... ?

○ ការផ្ទេរហិរញ្ញវត្ថុ

ដំណើរការហិរញ្ញវត្ថុផ្សេងៗ គឺត្រូវតែកើតឡើងនៅក្នុងដំណាក់កាលនេះ ។ ការយល់ដឹងរបស់ជនរងគ្រោះ ទៅលើដំណើរការហិរញ្ញវត្ថុនេះ គឺទំនងជាមានកម្រិត ប៉ុន្តែគាត់អាចដឹងព័ត៌មានមួយចំនួនដោយចៃដន្យ ។

▪ តើគាត់ដឹងពីធនាគារ គណនេយ្យ និងលេខផ្ទាល់ខ្លួន ឬគណនេយ្យ និងលេខពាណិជ្ជកម្ម ឬទីតាំងនៃសាខារបស់ធនាគារដែលពាក់ព័ន្ធនោះ?

▪ តើប័ណ្ណធនាគារ ប័ណ្ណឥណទាន វិក្កយបត្រធ្វើដំណើរ ត្រូវបានប្រើដោយជនជួញដូរមនុស្ស នៅដំណាក់កាលណាមួយ នៃការជ្រើសរើស និងនាំចេញជនរងគ្រោះដែរឬទេ? ប្រសិនបើធ្លាប់ប្រើមែន តើប្រើនៅ កន្លែងណា ពេលណា និងមានគោលបំណងអ្វី? ដើម្បីចំណាយលើ សំបុត្រធ្វើដំណើរឬ? ចំណាយទៅលើការសុំទិដ្ឋាការ? ចំណាយទៅលើទំនិញដោយឥតគិតពន្ធ ឬ...?

▪ តើមានការទិញរូបិយប័ណ្ណបរទេស មុនពេលពេលគាត់ចាកចេញដែរឬទេ? ប្រសិនបើមែន តើការទិញនោះនៅកន្លែងណា ពេលណា និងទិញ ដោយវិធីយ៉ាងដូចម្តេច?

▪ តើគាត់បានឃើញវិក្កយបត្រជួល ផ្សព្វផ្សាយ ឬទូរស័ព្ទដែរឬទេ? បើបានឃើញមែន តើគេបានចំណាយយ៉ាងដូចម្តេច ហើយចំណាយទៅទីណា?

- **បញ្ជីផ្ទៀតផ្ទាត់ "គ"-ការបំពានខាងផ្នែករូបកាយ ផ្លូវភេទ និងផ្លូវចិត្ត**

ជនរងគ្រោះដោយសារអំពើជួញដូរមនុស្ស ត្រូវបានគេបំពានខាងផ្លូវកាយ ផ្លូវភេទ និងផ្លូវចិត្ត នៅក្នុងរបៀបជាច្រើន ហើយទម្រង់នៃការបំពានទាំងបីនេះ អាចកើតមានឡើងនៅក្នុងដំណាក់កាល ប្រភព ឆ្លងកាត់ និងគោលដៅ ។

ការចាប់ពង្រត់ ការឃុំខ្លួនខុសច្បាប់ ការរំលោភ ការបំពានផ្លូវភេទ ការប៉ះពាល់ដល់បូរណភាពបុគ្គល និងការគំរាមសម្លាប់ជនរងគ្រោះ ឬគ្រួសាររបស់គាត់ គឺជាលក្ខណៈទូទៅនៃការបំពាន ដែលកើតមានឡើងនៅក្នុងរឿងក្តីជួញដូរមនុស្ស ហើយទាមទារឱ្យមានការដោះស្រាយតាមកាលប្រវត្តិនៃដំណាក់កាលនីមួយៗ នៃរឿងរ៉ាវដែលបានពិភាក្សាជាមួយជនរងគ្រោះ ។

រឿងក្តីជួញដូរមនុស្សភាគច្រើន គឺមានការពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ ដែលបានកើតឡើងជាយូរណាស់មកហើយ ហើយអាចមិនតម្រូវឱ្យមានការចាត់វិធានការជាបន្ទាន់ ដោយអ្នកស៊ើបអង្កេតទាក់ទងទៅនឹងការពិនិត្យសុខភាព ការធ្វើកោសល្យវិច័យ កិច្ចការពារកន្លែងកើតហេតុ ។ល។ ប៉ុន្តែការចាត់វិធានការទាំងនេះ អាចជាការចាំបាច់ទាក់ទងទៅនឹងជនរងគ្រោះដទៃទៀត ដែលកំពុងតែទទួលរងនូវការកេងប្រវ័ញ្ច ហើយត្រូវតែជួយសង្គ្រោះ តាមរយៈអន្តរាគមន៍របស់នគរបាលដែលធ្វើឡើងតាមរយៈចម្លើយសាក្សី ។

ការស៊ើបអង្កេតលើប្រភេទបទល្មើសទាំងនេះ ជួនកាលមានលក្ខណៈស្មុគស្មាញ ទាំងផ្នែកនីតិវិធី និងច្បាប់ ជាពិសេសទាក់ទងទៅនឹងបណ្តឹងរឿងក្តីរំលោភ ។ វាមិនអាចធ្វើទៅកើត ក្នុងការទទួលពាក្យបណ្តឹងនេះ ដើម្បីធ្វើការពិនិត្យតាមគោលការណ៍ និងវិធាននានា ដែលអាចមាននៅក្នុងប្រទេសផ្សេង ប៉ុន្តែអ្នកស៊ើបអង្កេតករណីជួញដូរមនុស្ស គួរតែធ្វើឱ្យស្របទៅនឹងវិធានច្បាប់ ដែលមាននៅក្នុងប្រទេសរបស់ខ្លួន ។ ដូចនេះ បញ្ជីផ្ទៀតផ្ទាត់ (គ) គឺបង្ហាញយ៉ាងទូលំទូលាយពីការអនុវត្តល្អនៃការស៊ើបអង្កេតបទល្មើស ដែលពាក់ព័ន្ធទៅនឹងការបំពាននានា ។

- ការចាប់ពង្រត់
  - នៅកន្លែងណា នៅពេលណា និងចាប់ពង្រត់យ៉ាងដូចម្តេច?
  - តើមានការប្រើប្រាស់អំពើហិង្សាឬទេ? បើមានមែន តើមានការឈឺចាប់យ៉ាងដូចម្តេច? តើជនរងគ្រោះមានរបួសយ៉ាងដូចម្តេច?
  - តើមានប្រើអាវុធដែរឬទេ? បើមាន សូមទទួលព័ត៌មានលម្អិត
  - តើគេដាក់ថ្នាំគាត់ដែរឬទេ? ប្រសិនបើមាន សូមទទួលព័ត៌មានលម្អិត ។ តើជាការចាក់ថ្នាំ ឬថ្នាំប្រើតាមផ្លូវដង្ហើម ឬលេប?
  - តើគាត់ត្រូវបានគេនិយាយប្រាប់ពីផលវិបាកនានា ប្រសិនបើគាត់ព្យាយាម គេចខ្លួនដែរឬទេ? ប្រសិនបើមែន សូមទទួលព័ត៌មានលម្អិត ពីប្រភេទនៃ ការគំរាមកំហែង និងអ្នកដែលធ្វើការគំរាមកំហែងនោះ
  - តើគេបាននិយាយអ្វីផ្សេងទៀតដែរឬទេ? បើមែន តើគេនិយាយពីអ្វី តើអ្នកណាជាអ្នកនិយាយ ហើយនិយាយភាសាអ្វី ឬមានសូរអ្វី? តើមានការប្រើឈ្មោះ ឬហៅឈ្មោះអ្វីដែរឬទេ?
  - ប្រសិនបើគាត់ដឹង តើគេបញ្ជូនគាត់ទៅកន្លែងណា? តើគេយកគាត់ទៅ កន្លែងនោះដោយរបៀបយ៉ាងដូចម្តេច តើមានចម្ងាយធ្វើដំណើរប៉ុន្មាន ពីចំណុចចាប់ពង្រត់ ទៅកន្លែងឃុំខ្លួន?
  - សូមទទួលព័ត៌មានលម្អិតពីកន្លែងឃុំខ្លួន និងអ្វីៗដែលនៅជុំវិញកន្លែង ។ តើគាត់អាចឮសំឡេង ដូចជា សំឡេងនៅជិតរថភ្លើង ឬព្រលានយន្តហោះ? តើគាត់អាចផ្តល់ព័ត៌មានផ្សេង

ទៀតដើម្បីកំណត់ទីតាំងដែរឬទេ?

- ដូចដែលបានរៀបរាប់ខាងលើ សូមទទួលព័ត៌មានលម្អិតពីជនសង្ស័យ មធ្យោបាយធ្វើដំណើរ និងទីកន្លែង ។

  - ការឃុំខ្លួនខុសច្បាប់

- តើគេទុកគាត់នៅកន្លែងណា ហើយយូរប៉ុណ្ណាដែរ?
- សូមទទួលព័ត៌មានលម្អិតពីកន្លែងខាងក្នុងទីតាំង និងអ្វីដែលនៅជុំវិញ
- តើគេឃុំគាត់យ៉ាងដូចម្តេច? តើគេគាបសង្កត់លើរូបកាយគាត់យ៉ាងដូចម្តេច? បើមែន សូមទទួលព័ត៌មានលម្អិតពីការរឹតត្បិត ការចាក់សោ មធ្យោបាយចេញ-ចូលកន្លែងនោះ ហើយតើអ្នកណាជាអ្នកមានសោ?
- ប្រសិនបើមានអ្នកយាមគាត់ សូមទទួលព័ត៌មានលម្អិតពីអ្នកយាមនោះ និងទំនាក់ទំនងដែលកើតមានឡើង
- តើគេឃុំគាត់នៅក្នុងបន្ទប់មួយ ឬគាត់មានសេរីភាព ក្នុងតំបន់ដាក់លាក់ណាមួយ?
- តើគាត់ត្រូវបានគេប្រាប់ពីផលវិបាកនានា ប្រសិនបើគាត់ព្យាយាមរត់គេចខ្លួន? បើមែន សូមទទួលព័ត៌មានលម្អិតពីប្រភេទនៃការគំរាមកំហែង និងអ្នកដែលគំរាមកំហែងនោះ
- តើមានសាក្សីណាមួយ នៅក្នុងព្រឹត្តិការណ៍ណាមួយខាងលើដែរឬទេ? បើមាន សូមទទួលព័ត៌មានលម្អិត ។

  - ការបំពានលើរូបរាងកាយ និងផ្លូវភេទ

- តើការបំពានកើតឡើងនៅពេលណា ច្រើនដងដែរឬទេ? សូមទទួលព័ត៌មានពីកាលបរិច្ឆេទឱ្យបានច្បាស់លាស់ ។ ប្រើប្រាស់ព្រឹត្តិការណ៍សំខាន់ៗ ដើម្បីកំណត់ពេលវេលា ប្រសិនបើកាលបរិច្ឆេទ ពិតប្រាកដ មិនអាចកំណត់បានច្បាស់លាស់ (ជាញឹកញយ ជនរងគ្រោះរាយការណ៍ថាការបំពានធ្វើឡើងជាញឹកញាប់ ស្ទើរតែរាល់ថ្ងៃ ដោយនិយាយពីព្រឹត្តិការណ៍ច្រើនថាតែមួយ)
- តើការបំពានកើតឡើងនៅកន្លែងណា? សូមទទួលព័ត៌មានលម្អិត ពេញលេញពីកន្លែង ដែលបានបង្ហាញខាងលើ ៖ ការតុបតែងបន្ទប់ គ្រែ សាឡុង សង្ហារឹម សម្លៀកបំពាក់រហែក កម្រាលពូក ខ្នើយ...
- តើប្រភេទនៃការវាយដំគឺអ្វី? សូមទទួលព័ត៌មានលម្អិតពីការបង្ករបួសស្នាម ។ តើការរំលោភធ្វើឡើងតាមប្រដាប់ភេទ រន្ធគូថ តាមមាត់ ឬការស្ទាបផ្លូវភេទ? តើស្ថានភាពលឹង្គរឹង និងទំហំប៉ុណ្ណា? ទឹកកាមចេញឬ? តើមានប្រើស្រោមអនាម័យ ឧបករណ៍ ឬអ្វីបន្ថែមផ្សេងទៀត?
- តើគេបាននិយាយទៅគាត់ថាយ៉ាងដូចម្តេច នៅក្នុងអំឡុងពេលនៃការបំពាននោះ? តើគេប្រើហិង្សាឬ? ហើយអ្នកណាជាអ្នកប្រើហិង្សា?
- តើគោលបំណងនៃការបំពានគឺអ្វី? គឺគ្រាន់តែជាការសប្បាយខាងផ្លូវភេទ ឬជាការវាយដំលើរូបកាយ ឬផ្លូវភេទ ដើម្បីធ្វើទុក្ខបុកម្នេញ បង្ខំ ឬ បង្រៀនគាត់ (បង្រៀនពីការរួមភេទ)? តើវាជាការផ្តន្ទាទោស ដោយសារគាត់មិនគោរពតាមការណែនាំ ឬដោយសារគាត់ប៉ុនប៉ងរត់គេចខ្លួន?

▪ តើគាត់បង្ហាញជាកាយវិការ ឬតាមសម្ដីពីការបដិសេធ ឬមិនយល់ព្រម? ប្រសិនបើមាន តើពិតប្រាកដទៅ គាត់បានធ្វើអ្វី? តើគាត់បានបង្កឱ្យមានរបួសណាមួយទៅលើអ្នកបំពានដែរឬទេ នៅក្នុងអំឡុងពេលនៃការបំពាននោះ? បើមែន សូមទទួលព័ត៌មានលម្អិតពីរបួសស្នាមនោះ

▪ ទាក់ទងនឹងការបំពានខាងផ្លូវភេទ ជួនកាល ជនរងគ្រោះបានរាយការណ៍ថា ខ្លួនមិនដែលបាននិយាយ ឬបានធ្វើអ្វីដើម្បីរើបម្រះឡើយ ហើយបាននិយាយថា ខ្លួនគ្រាន់តែស្ថិតនៅក្រោមរណបនៃការបំពាន ដើម្បីជៀសវាងការវាយដំលើរូបរាងកាយ បន្ថែមទៅនឹងការបំពានផ្លូវភេទ ។ វាគឺជាការសំខាន់ក្នុងការធ្វើកំណត់ហេតុពីបញ្ហានេះ គឺថាមិនត្រឹមតែជាការវាយធ្វើបាបអាចឈានដល់ការរំលោភ សូម្បីតែជនរងគ្រោះមិនបានតតាំង ឬបង្ហាញពីភាពមិនយល់ព្រម ប៉ុន្តែវាជាការបង្ហាញផងដែរពីការគ្រួតត្រា និងទាសភាពទាំងស្រុងទៅលើជនរងគ្រោះ

▪ តើស្ថានភាពរាងកាយរបស់គាត់យ៉ាងដូចម្ដេចដែរ បន្ទាប់មក? តើគាត់បានទទួលរងការបាត់បង់ស្មារតី? ឬគ្រោះថ្នាក់ដល់រាងកាយ?

▪ តើគាត់បានប្រាប់នរណាពីអ្វីដែលបានកើតឡើងចំពោះគាត់? បើមែន សូមទទួលព័ត៌មានលម្អិតពីអ្នកនោះ និងពីអ្វីដែលបាននិយាយប្រាប់

▪ តើគាត់ត្រូវការ ឬទទួលការព្យាបាលណាមួយចំពោះរបួសរបស់គាត់ ដែរឬទេ? ប្រសិនបើមែន សូមទទួលព័ត៌មានលម្អិតពីគ្រូពេទ្យ មន្ទីរពេទ្យ កំណត់ហេតុដែលមាន...។ (ត្រូវជានាផងដែរ ដើម្បីទទួលបានការយល់ព្រមជាលាយលក្ខអក្សរ ដើម្បីទទួលបានកំណត់ហេតុវេជ្ជសាស្ត្រដែល ទាក់ទងទៅនឹងការពិនិត្យណាមួយ)

▪ តើស្ថានភាពអារម្មណ៍របស់គាត់យ៉ាងដូចម្ដេច (មានការភ័យខ្លាច) ទាំងនៅពេលនោះ និងបន្ទាប់មក?

▪ តើគេបាននិយាយយ៉ាងដូចម្ដេច ឬបានធ្វើអ្វីបន្ទាប់មក? តើគាត់ត្រូវបានគេគំរាមកំហែងដោយមានការបំពានតទៅទៀតឬ? បើមាន តើមានទាក់ទងទៅនឹងអ្វី? តើអ្នកបំពានគាត់បង្ហាញនូវភាពសោកស្ដាយឬទេ?

▪ សូមទទួលព័ត៌មានលម្អិតទាក់ទងនឹងរូបកាយរបស់ជនល្មើស ដោយធ្វើការបញ្ជាក់ពីចំណុចពិសេសនៃរូបរាង ដូចជា ចារ សាក់លើស្បែក ចោះរន្ធត្រចៀក សម្លាក របៀបរាប់លក្ខណៈពិសេសនៃប្រដាប់ភេទ ធ្វើការបែងចែកសំឡេង ឬសូរ ក្លិន ទឹកអប់ លក្ខណៈនៃធ្មេញ និងក្រចក ។ល។

▪ តើមានសាក្សីណាមួយទាក់ទងទៅនឹងព្រឹត្តិការណ៍ខាងលើដែរឬទេ? ប្រសិនបើមាន សូមទទួលព័ត៌មានលម្អិត ។

○ ចំណុចចុងក្រោយ-ផលប៉ះពាល់នៃបទល្មើស

អំពើជួញដូរមនុស្សក្នុងគោលបំណងកេងប្រវ័ញ្ចផ្លូវភេទ គឺជាបទឧក្រិដ្ឋធ្ងន់ធ្ងរដែលធ្វើទៅលើសិទ្ធិមនុស្សជាមូលដ្ឋានរបស់ជនរងគ្រោះ ហើយអាចប៉ះពាល់ដល់រូបកាយ និងផ្លូវ ចិត្តរបស់ជនរងគ្រោះ ។ វាគឺជាការសំខាន់ក្នុងការទទួលព័ត៌មានពីគាត់ អំពីផលប៉ះពាល់នៃបទល្មើស ទៅលើរូបគាត់ និងព័ត៌មានលម្អិតទាក់ទងទៅនឹងប្រតិកម្មរបស់គាត់ទៅនឹងបទល្មើសនោះ ព្រមទាំងការបំពាន ការ

បោកប្រាស់ ទាសភាព និងការកេងប្រវ័ញ្ចផ្លូវភេទណាមួយ ដែលគាត់បានទទួលរង ។

មន្ត្រីសម្ភាសគួរតែបញ្ចូលការប៉ះពាល់នេះ នៅចុងបញ្ចប់នៃចម្លើយរបស់ជនរងគ្រោះ ដោយមានព័ត៌មានលម្អិតនៃការប៉ះពាល់ដល់រូបរាងកាយ និងផ្លូវចិត្តដែលគាត់ទទួលរងពីបទល្មើស នោះ ។ ជនរងគ្រោះគួរតែត្រូវបានគេលើកទឹកចិត្ត ឱ្យរៀបរាប់ពីផលប៉ះពាល់នៃបទល្មើស ទៅលើជីវិតរបស់ខ្លួន និងបញ្ជាក់ពីកម្រិតនៃភាពភ័យខ្លាចទាំងរូបគាត់ និងអ្នកដែលគាត់ស្រឡាញ់នោះ ថាតើគាត់អាចរស់នៅដោយសេរីភាព ដូចប្រជាពលរដ្ឋដទៃទៀត ឬតើគាត់មានអារម្មណ៍ថាគាត់អាចត្រឡប់ទៅផ្ទះវិញប្រកបដោយសុវត្ថិភាព និងមានអារម្មណ៍សប្បាយរីករាយមានជំនឿជឿជាក់លើខ្លួន ។

ប្រសិនបើមានរយៈពេលសំខាន់ រវាងការផ្តល់ចម្លើយពីផលប៉ះពាល់នេះ និងកាលបរិច្ឆេទនៃសវនាការរឿងក្តី មន្ត្រីសម្ភាសគួរទទួលចម្លើយសាក្សីដែលទាក់ទងទៅនឹងផលប៉ះពាល់នោះជាលើកទី២ ពីជនរងគ្រោះជាបន្ទាន់ មុនពេលដំណើរការរឿងក្តីនានា ដើម្បីប្រមូលភស្តុតាងនៃការប៉ះពាល់មកលើជនរងគ្រោះឱ្យមានលក្ខណៈជាបច្ចុប្បន្នភាព ។

**សេចក្តីសង្ខេបពីចំណុចសំខាន់**

- ជនរងគ្រោះដោយសារអំពើជួញដូរមនុស្ស ដែលធ្វើសាក្សី គឺជាភស្តុតាងដែលមានតម្លៃខ្លាំងបំផុតសម្រាប់មន្ត្រីអនុវត្តច្បាប់
- លើសពីនេះទៀត នៅក្នុងប្រទេសប្រភពនានា ជនរងគ្រោះអាចជាប្រភពភស្តុតាងតែមួយគត់ នៅក្នុងដំណាក់កាលទាំង ៣ នៃការជួញដូរមនុស្ស
- អ្នកស៊ើបអង្កេត គួរទទួលស្គាល់នូវតម្លៃដ៏សំខាន់របស់ជនរងគ្រោះ ហើយត្រូវស្វែងរកលក្ខខណ្ឌនានាដែលជនរងគ្រោះអាចសហការប្រកបដោយសុវត្ថិភាព ជាមួយប្រព័ន្ធយុត្តិធម៌ និងទទួលបានយុត្តិធម៌
- គោលការណ៍អនុវត្តល្អៗខាងក្រោម គួរតែអនុវត្តៈ
  - ទង្វើទៅលើជនរងគ្រោះ គួរធ្វើឡើងដោយមានការប្រុងប្រយ័ត្ន ប្រកបដោយលក្ខណៈអាជីព និងគោរពសិទ្ធិមនុស្សចំពោះជនរងគ្រោះ
  - នៅក្នុងដំណាក់កាលណាមួយនៃដំណើរការកិច្ចសហការជាមួយប្រព័ន្ធយុត្តិធម៌ ដែលតម្រូវឱ្យមានការយល់ព្រមពីជនរងគ្រោះ គួរធ្វើឡើងតាមគោលការណ៍នៃការបញ្ជាក់ការយល់ព្រម
  - នៅក្នុងការសម្រេចទាំងអស់នេះ ការបកប្រែជាភាសាកំណើតរបស់ជនរងគ្រោះ គួរតែផ្តល់ឱ្យ នៅក្នុងករណីសមត្ថភាពយល់ដឹងភាសាក្នុងស្រុករបស់ជនរងគ្រោះ មានកម្រិត
  - គោលបំណងគឺធ្វើឱ្យមានលក្ខខណ្ឌល្អបំផុត ដែលជនរងគ្រោះអាចផ្តល់ភស្តុតាង របស់ខ្លួន និងផ្តល់ចម្លើយសាក្សី នៅក្នុងរបៀបដែលធ្វើឱ្យការប៉ះពាល់ផ្នែកអារម្មណ៍ ដែលមិនអាចជៀសវាងបានឱ្យមានកម្រិតទាបបំផុត
  - មន្ត្រីអនុវត្តច្បាប់ គួរទទួលយកគំនិតនេះ ពីព្រោះវាមិនមែនតែជាការងារមនុស្សធម៌ និងលក្ខណៈអាជីពប៉ុណ្ណោះទេ ប៉ុន្តែវាជាបញ្ហានៃការអនុវត្តល្អ ព្រោះថា ទង្វើបែបនេះអាចបង្កើនជាអតិបរមានូវសុក្ខានុពលរបស់ជនរងគ្រោះឱ្យមានជំនឿជឿជាក់ នៅក្នុងអំឡុងពេលដំណើរការសវនាការ

រឿងក្តី ហើយអាចផ្តន្ទាទោសជនល្មើសទៀតផង ។

- អ្នកស៊ើបអង្កេត គួរតែផ្តល់ព័ត៌មានពេញលេញទៅជនរងគ្រោះ រួមមានព័ត៌មានលម្អិតជាក់លាក់ពីសមត្ថភាពរបស់ប្រព័ន្ធយុត្តិធម៌ ក្នុងការដោះស្រាយទៅលើការព្រួយបារម្ភលើចំណុចសំខាន់ៗទាំង ៥ ដែលមានផលប៉ះពាល់ដល់ជនរងគ្រោះ ៖
    - សុវត្ថិភាពរបស់ជនរងគ្រោះ និងអ្នកដែលជនរងគ្រោះស្រឡាញ់
    - ស្ថានភាពរបស់ជនរងគ្រោះ ដែលអាចជាជនល្មើស និងស្ថានភាពស្នាក់នៅបណ្តោះអាសន្ន នៅក្នុងប្រទេសនោះ
    - ស្ថានភាពនៃការចូលក្នុងប្រទេសដោយខុសច្បាប់
    - សេចក្តីភ័យខ្លាចនៃការលេចឮពីអ្វីដែលកើតឡើងចំពោះជនរងគ្រោះ និងការប៉ះពាល់ដល់កិត្តិយសរបស់ជនរងគ្រោះ
    - សេចក្តីភ័យខ្លាចនៃស្ថានភាពជនរងគ្រោះ ក្នុងដំណើរការរបស់ប្រព័ន្ធយុត្តិធម៌ នៅក្នុងដំណាក់កាលណាមួយ តម្រូវឱ្យមានវត្តមានជាមួយជនជួញដូរមនុស្ស ។
- បញ្ហាដូចជា ភាពសម្ងាត់ និងលក្ខខណ្ឌនៃចម្លើយសាក្សី គឺតម្រូវឱ្យមានការពន្យល់ដល់ជនរងគ្រោះដោយប្រុងប្រយ័ត្ន និងដោយស្មោះត្រង់ មុនពេលគាត់យល់ព្រមធ្វើជាសាក្សី ដោយយោងទៅតាមការបង្ហាញការយល់ព្រមពីជនរងគ្រោះ
- ការសម្ភាសទៅលើជនរងគ្រោះដោយសារអំពើជួញដូរមនុស្ស ដែលនឹងធ្វើជាសាក្សីគឺមានគោលបំណងបី និងមានការប្រឈមយ៉ាងខ្លាំងដល់មន្ត្រីសម្ភាស ។ ជនរងគ្រោះអាចមានការសង្ស័យស្ទាក់ស្ទើរ និងអាចបដិសេធនៅក្នុងដំណាក់កាលដំបូងនេះ ហើយដើម្បីប្រឈមនឹងការលំបាកនេះមន្ត្រីសម្ភាសត្រូវតែកំណត់ និងប្រមូលអង្គហេតុលម្អិតនៃភស្តុតាង ឱ្យបានគ្រប់ជ្រុងជ្រោយ ដូចជាសមត្ថកិច្ចដោះស្រាយរឿងក្តី ពេលវេលា បទល្មើស ជនសង្ស័យ សាក្សី ។ល។
- ជំងឺផ្លូវអារម្មណ៍អាចប៉ះពាល់ដល់លទ្ធភាពរបស់ជនរងគ្រោះ ក្នុងការផ្តល់ព័ត៌មានរឿងរ៉ាវរបស់ខ្លួនឱ្យបានលម្អិត និងស៊ីចង្វាក់គ្នា នៅក្នុងដំណាក់កាលដំបូងនេះ ហើយអ្នកសម្ភាសអាចប្រឈមផងដែរនឹងហានិភ័យដែលជនរងគ្រោះអាចប្រឌិតរឿង ដើម្បីបំពេញចន្លោះដែលខ្លួនភ្លេច និងគ្រោះថ្នាក់ដែលជនរងគ្រោះទទួលរងនូវការប៉ះពាល់ផ្លូវអារម្មណ៍បន្ថែមទៀត ដោយសារតែជនរងគ្រោះមិនអាចគ្រប់គ្រងអារម្មណ៍បាន ហើយគិតថាខ្លួនកំពុងតែស្ថិតនៅក្នុងស្ថានភាពអតីតកាល ដែលអាចកើតឡើងភ្លាមៗដោយសារដំណើរការសម្ភាស
- វិធីសាស្ត្រឆ្លើយតបទៅនឹងការប្រឈមនេះ គឺអាស្រ័យទៅលើការត្រៀមរៀបចំប្រកបដោយលក្ខណៈប្រុងប្រយ័ត្ន និងលក្ខណៈអាជីពនៃការសម្ភាស ។ វិធីសាស្ត្រនេះរួមមានដូចខាងក្រោម ៖
    - ការជ្រើសរើសក្រុមសម្ភាស អាស្រ័យទៅលើគុណភាពជាលក្ខណៈបុគ្គល និងលក្ខណៈអាជីព និងអាស្រ័យទៅលើបុគ្គលិកដែលមាន
    - ការជ្រើសរើសក្រុមជាដៃគូសម្ភាស សម្រាប់ទីភ្នាក់ងារគាំទ្រដល់ជនរងគ្រោះ
    - ការវាយតម្លៃមុនការសម្ភាសជនរងគ្រោះ

- ការវិភាគលើភស្តុតាង
- ទីកន្លែង និងលក្ខខណ្ឌនៃការសម្ភាស
- បើមានការពាក់ព័ន្ធ ការប្រើប្រាស់ និងការគ្រប់គ្រងអ្នកបកប្រែភាសា ។

• ការជួបជុំដំបូង និងការណែនាំខ្លួននៅឯដំណាក់កាលសម្ភាស គឺជាដំណាក់កាលសំខាន់ និងជាដំណាក់កាលជ័យជម្នះ និងបរាជ័យ ដែលអាស្រ័យលើការរៀបចំល្អនៅក្នុងដំណាក់កាលនេះ

• កុមាររងគ្រោះ និងជនរងគ្រោះពេញវ័យទាំងអស់ ដែលទទួលរងនៅក្នុងកម្រិតណាមួយ នៃការប៉ះពាល់

• ផ្លូវអារម្មណ៍អាចជាកត្តាដែលងាយរងគ្រោះ ជាពិសេសដល់ដំណើរការសម្ភាសទាក់ទងនឹងដំណាក់កាលណែនាំខ្លួនដល់ការសម្ភាស គឺត្រូវតែកាត់បន្ថយពីភាពងាយគ្រោះថ្នាក់នេះ តាមរយៈការបញ្ចូលគ្នានៃការពន្យល់លម្អិតពីដំណើរការ និងតួនាទីរបស់អ្នកចូលរួម និងការព្រមព្រៀងលើវិធានដែលបានកំណត់ និងការបញ្ជាក់ពីអង្គហេតុ ដែលជនរងគ្រោះមិនបានដឹងពីចម្លើយទៅនឹងសំណួរជាក់លាក់ណាមួយ

• ការសម្ភាសគួរតែបំបែកជាបួនដំណាក់កាលដាច់ដោយឡែកពីគ្នា ដែលទាក់ទងទៅនឹងការទំនាក់ទំនង ការរំលឹកពីអ្វីដែលបានកើតឡើង ការលើកជាសំណួរ និងការបិទសម្ភាសន៍

• របៀបនៃការលើកជាសំណួរគួរធ្វើឡើងអាស្រ័យទៅលើការវិវត្តនៃការយល់ដឹងអាយុ ភាសា និងជនជាតិរបស់ជនរងគ្រោះ ហើយបើអាចធ្វើទៅបាន សំណួរគួរធ្វើឡើង ដោយការប្រើសំណួរបើក និងសំណួរជាក់លាក់ ជាជាងការប្រើសំណួរបិទ

• ជានិច្ចកាល សំណួរនាំមុខគួរតែជៀសវាង លើកលែងតែក្នុងករណីបើមិនប្រើសំណួរនាំមុខនោះទេ គឺមិនទទួលបានភស្តុតាង

• វិធានការការពារបន្ថែម គឺតម្រូវចំពោះកុមាររងគ្រោះធ្វើជាសាក្សី

• កត្តាសំខាន់គឺថា អត្ថប្រយោជន៍របស់កុមារត្រូវពិចារណាខ្លាំងបំផុត និងគ្រប់ពេលវេលា

• វិធានការបន្ថែម គួរតែបញ្ចូលវត្តមានរបស់ភាគីឯករាជ្យទីបី និងការវាយតម្លៃជាលក្ខណៈឯកទេស មុនការសម្ភាស ដោយអ្នកចិត្តសាស្ត្រខាងផ្នែកកុមារ

• អាស្រ័យទៅតាមកាលៈទេសៈនៃរឿងក្តី អាចជាការសំខាន់ក្នុងការប្រើសំណួរជាក់លាក់ ដើម្បីឱ្យកុមារមានលទ្ធភាពយល់ពីភារកិច្ចដែលនិយាយប្រាប់ពីការពិត

• ទម្រង់កំណត់ហេតុនៃការធ្វើសម្ភាស គួរតែធ្វើឡើងជាលាយលក្ខអក្សរ ថតជាសំឡេង ថតវីដេអូ ។ បើច្បាប់អនុញ្ញាត និងអាចធ្វើទៅបាន ការថតវីដេអូ គឺជាមធ្យោបាយដ៏ល្អបំផុត ក្នុងការទទួលបានការរៀបរាប់ពីជនរងគ្រោះដែលធ្វើជាសាក្សី

• យោងតាមបទបញ្ញត្តិច្បាប់ ភាពសម្ងាត់នៃអត្តសញ្ញាណរបស់ជនរងគ្រោះ គួរតែការពារនៅក្នុងដំណើរការនៃការសម្ភាស ។ ភាពសម្ងាត់នេះអាចធ្វើទៅបាន តាមរយៈការប្រើឈ្មោះក្លែង ឬការប្រើប្រាស់អំណាចស្របច្បាប់ក្នុងការការពារអត្តសញ្ញាណជនរងគ្រោះ តាំងពីដំណាក់កាលដំបូង

- វិធានការអ្វីក៏ដោយដែលបានប្រើ គឺជាការសំខាន់ដើម្បីធានាថា ជនរងគ្រោះយល់ថា វាមិនអាចជៀសវាងបានទាំងស្រុងនោះទេ ការដែលជនជួញដូរមនុស្ស អាចដឹងពីអត្តសញ្ញាណ ពីអ្នកដែលផ្តល់ចម្លើយសាក្សីពីរឿងរ៉ាវដែលបានកើតឡើងនោះ ។

**សំណួររំឭកមេរៀន**

- រៀបរាប់ពីគោលការណ៍អនុវត្តល្អៗ ដែលទាក់ទងទៅនឹងជនរងគ្រោះ
- ហេតុអ្វីបានជាវាសំខាន់ក្នុងការប្រើប្រាស់ជនរងគ្រោះជាសាក្សី
- រៀបរាប់ពីការព្រួយបារម្ភសំខាន់ៗរបស់ជនរងគ្រោះដែលជាសាក្សី និងកំណត់ពីដំណោះស្រាយផ្សេងៗដែលអាចធ្វើទៅបាន
- តើគោលបំណងនៃការសម្ភាសជាមួយជនរងគ្រោះគឺជាអ្វី?
- រៀបរាប់ពីដំណាក់កាលនានា ដែលមន្ត្រីអនុវត្តច្បាប់តម្រូវឱ្យអនុវត្តតាម ដើម្បីសម្ភាសជាមួយជនរងគ្រោះដោយសារអំពើជួញដូរមនុស្ស
- រៀបរាប់ពីជំនាញជាលក្ខណៈបុគ្គល និងលក្ខណៈអាជីព ដែលមន្ត្រីសម្ភាសអាចធ្វើការសម្ភាសប្រកបដោយជោគជ័យ
- រៀបចំផែនការសម្ភាស ដោយគិតដល់ជនរងគ្រោះជាចម្បង យុទ្ធសាស្ត្រសិទ្ធិមនុស្ស
- តើមន្ត្រីអនុវត្តច្បាប់គួរធ្វើការណែនាំខ្លួនយ៉ាងដូចម្តេចនៅពេលសម្ភាស?
- ធ្វើការសម្ភាសជាមួយជនរងគ្រោះ ដោយយោងតាមគំរូអនុវត្តល្អៗ
- រៀបរាប់បន្ថែមទាក់ទងនឹងការសម្ភាសកុមាររងគ្រោះដោយសារអំពើជួញដូរមនុស្ស ៕

# ជំពូកទី ៣
# ការសម្ភាសជនសង្ស័យ

## I. ការណែនាំឱ្យស្គាល់បច្ចេកទេសសម្ភាសជនសង្ស័យ

នៅក្នុងការស៊ើបអង្កេតព្រហ្មទណ្ឌ មានជំនាញមួយក្នុងចំណោមជំនាញសំខាន់ៗ ដែលអ្នកស៊ើបអង្កេតអាចអភិវឌ្ឍបាន ពោលគឺជាសមត្ថភាពទទួលបានព័ត៌មានពីជនសង្ស័យតាមរយៈការសម្ភាសផ្ទផ្ទង ។ អ្នកស៊ើបអង្កេត ត្រូវតែយល់ដឹងដំបូងថា ការសម្ភាសផ្ទផ្ទងជាមួយជនសង្ស័យ មានភាពខុសគ្នាស្រឡះពីការសម្ភាសជនសង្ស័យ ។

### ១. ការសម្ភាសជនអាចមានការសង្ស័យ

ការសម្ភាសត្រូវធ្វើនៅពេលមនុស្សម្នាក់អាចពាក់ព័ន្ធនឹងការសង្ស័យ ប៉ុន្តែត្រូវបានសាកសួរព័ត៌មានដើម្បីកំណត់ថា តើព័ត៌មានរបស់គាត់មានសារៈសំខាន់ដល់រឿងក្តីរបស់អ្នកស៊ើបអង្កេតដែរឬទេ ។ ជាមូលដ្ឋាន ការសម្ភាសត្រូវបានប្រើជាបច្ចេកទេសមួយដើម្បីប្រមូលព័ត៌មាន ។

#### ក. គោលបំណងនៃការសម្ភាស

- ប្រមូលព័ត៌មាន
- ស្វែងយល់ពីទំនាក់ទំនងរវាងជនសង្ស័យ និងជនរងគ្រោះ
- បង្កើតកំណត់ហេតុរបស់ជនសង្ស័យ ដែលបញ្ជាក់ថា នៅ ឬមិននៅកន្លែងកើតហេតុនៅពេលបទល្មើសកើតឡើង
- ដឹងពីលទ្ធភាពចេញចូលរបស់ជនសង្ស័យទៅកាន់កន្លែងកើតហេតុ
- វាយតម្លៃភាពអាចគួរជឿទុកចិត្តបានរបស់ជនសង្ស័យ ។

#### ខ. លក្ខណៈជាមូលដ្ឋាននៃការសម្ភាស

- មិនមានការចោទប្រកាន់
- និយាយហូរហែដោយសេរី
- អ្នកសម្ភាសចំណាយពេលនិយាយ ៥% រីឯជនសង្ស័យចំណាយពេលនិយាយ៩៥%
- ការសម្ភាសអាចត្រូវបានធ្វើនៅកន្លែងណាក៏បាន
- ចម្ងាយកៅអីរវាងអ្នកសម្ភាស និងជនសង្ស័យ ត្រូវដាច់ពីគ្នា (ប៉ុន្តែជិតគ្នាបន្តិច)
- អាចកត់ត្រា និងកត់សម្គាល់សម្ដីដែលបាននិយាយ ។

### ២. ការសម្ភាសផ្ទផ្ទង (បញ្ជាក់ចម្លើយ)

ការសម្ភាសផ្ទផ្ទងត្រូវបានសម្រេចនៅពេលជនណាម្នាក់ដែលកំពុងត្រូវបានគេសម្ភាស គឺជាជនសង្ស័យនៅក្នុងរឿងក្តី ។ ការសម្ភាសផ្ទផ្ទង គឺជាការសម្ភាសផ្ទាល់ជាមួយជនសង្ស័យ ។

#### ក. គោលបំណងនៃការសម្ភាសផ្ទផ្ទង

- ដើម្បីផ្ទផ្ទងព័ត៌មានថ្មីជាមួយជនសង្ស័យ និងទទួលបានចម្លើយសារភាព
- យល់ដឹងពីការពិតនៃបទល្មើស និងមូលហេតុដែលបទល្មើសបានកើតឡើង

- ទទួលបានការស្គាល់កំហុស (ពិរុទ្ធភាព)
- ទទួលបានការណ៍ពិត ដើម្បីកំណត់វិធីសាស្ត្រអនុវត្ត និងស្ថានភាពបទល្មើស
- ប្រមូលព័ត៌មានដែលធ្វើឱ្យអ្នកស៊ើបអង្កេតអាចធ្វើសេចក្តីសន្និដ្ឋានត្រឹមត្រូវ
- ផ្តល់ព័ត៌មានសម្រាប់ប្រើក្នុងការចោទប្រកាន់នៅក្នុងនីតិវិធីតុលាការ ។

**ខ. លក្ខណៈជាមូលដ្ឋាននៃការសម្ភាសផ្លូវការ**

- ជាការចោទប្រកាន់
- ជារចនាសម្ព័ន្ធ
- អ្នកសម្ភាសចំណាយពេលនិយាយ ៩៥% រីឯជនសង្ស័យចំណាយពេលនិយាយ ៥%
- អ្នកសម្ភាសត្រូវតែធ្វើការសម្ភាសផ្លូវការនៅក្នុងអង្គភាពនគរបាល
- ចម្ងាយកៅអីអ្នកសម្ភាសអង្គុយ និងជនសង្ស័យត្រូវឱ្យដាច់ពីគ្នា (ប៉ុន្តែជិតគ្នាបន្តិច) ដើម្បីងាយស្រួលសម្រាប់ទំនាក់ទំនងស្និទ្ធស្នាល
- នៅពេលដែលជនសង្ស័យសារភាព ត្រូវកត់ត្រា (ប្រសិនបើជនសង្ស័យមិនឆ្លើយសំណួរទាំងអស់ អ្នកសម្ភាសត្រូវចុះនិទ្ទេស)
- អ្នកសម្ភាសសម្តែងអាកប្បកិរិយាស្ងៀមស្ងាត់ និងស្មោះត្រង់
- គ្មានពេលវេលាកំណត់ច្បាស់លាស់ អាចចំណាយពេលវេលាយូរ ។

**៣. ផលប្រយោជន៍នៃការធ្វើសម្ភាសមួយមុនពេលសម្ភាសផ្លូវការ**

ជានិច្ចកាល ការសម្ភាសជាមួយជនសង្ស័យគួរតែធ្វើឡើង មុនឈានដល់ការសម្ភាសផ្លូវការ ។ ការសម្ភាសបែបមិនចោទប្រកាន់ទៅលើជនសង្ស័យ គឺមានសារៈសំខាន់ខ្លាំងណាស់ ដើម្បីបញ្ជាក់ថា តើជនសង្ស័យមានកំហុសពិតឬទេ ។ វាមិនជាការល្អទេ ប្រសិនបើធ្វើការសម្ភាសផ្លូវការ ដោយរំលងដំណើរការសម្ភាសនេះ ពីព្រោះ ៖

- លក្ខណៈមិនចោទប្រកាន់ដល់ជនណាម្នាក់ក្នុងបទសម្ភាស អនុញ្ញាតឱ្យអ្នកស៊ើបអង្កេតបង្កើតបាននូវទំនាក់ទំនងស្និទ្ធស្នាល និងការជឿជាក់ជាមួយជនសង្ស័យ
- ជនសង្ស័យដែលមានកំហុស អាចមិនសារភាព ក្នុងអំឡុងពេលសម្ភាសផ្លូវការ
- ជារឿយៗ ក្នុងពេលសម្ភាស អ្នកស៊ើបអង្កេតដឹងនូវព័ត៌មានសំខាន់ៗ អំពីជនសង្ស័យដែលនឹងផ្តល់គុណប្រយោជន៍ក្នុងពេលសម្ភាសផ្លូវការ
- ជនសង្ស័យត្រូវជឿទុកចិត្តដល់ភាពមិនលម្អៀងនិងភាពស្មោះត្រង់របស់អ្នកសម្ភាស ។

**៤. ការប្រមូលព័ត៌មានមុនពេលធ្វើសម្ភាស**

មុនពេលចាប់ផ្តើមការធ្វើសម្ភាសណាមួយ អ្នកស៊ើបអង្កេតត្រូវតែមានព័ត៌មានស្តីពីសាវតារជាតិជាចាំបាច់ ដើម្បីដំណើរការសម្ភាស ។ តាមធម្មតា ការហ្វឹកហាត់ស្វែងយល់ និងបទពិសោធន៍ទៅលើអង្គហេតុរឿងក្តី បានពង្រឹង និងបង្កើនយ៉ាងខ្លាំងនូវសមត្ថភាពរបស់មន្ត្រី ដើម្បីកំណត់អត្តសញ្ញាណជនសង្ស័យដែលមានកំហុស និងគ្មានកំហុសឱ្យបានត្រឹមត្រូវ ។ ព័ត៌មានស្តីពីសាវតារជាតិទទួលបានពីប្រភព ដូចខាងក្រោម ៖

- របាយការណ៍ និងឯកសារ
  - របាយការណ៍បទល្មើស
  - របាយការណ៍ស៊ើបអង្កេតបន្ត
  - របាយការណ៍ចាប់ឃាត់ខ្លួន
  - រូបថតសម្រាប់កំណត់អត្តសញ្ញាណ
  - សំណុំឯកសារស្លាកស្នាមម្រាមដៃ
  - សំណុំឯកសារចុះបញ្ជីកាំភ្លើង ។
- ការសម្ភាសសាក្សី និងជនរងគ្រោះ
- ការពិនិត្យមើលឡើងវិញលើលទ្ធផលស៊ើបអង្កេត ។

**ក. ការវិភាគ និងការវាយតម្លៃព័ត៌មានពិត**

មុនពេលចាប់ផ្តើមធ្វើការសម្ភាស អ្នកស៊ើបអង្កេតគួរតែ ៖

- យល់ឱ្យកាន់តែច្បាស់អំពីអង្គហេតុ និងគ្រប់ស្ថានភាពទាំងអស់នៃបទល្មើស
- ទទួលបានព័ត៌មានទាំងអស់ពីប្រភពដែលអាចគួរទុកចិត្តបំផុត ឬយកជាការបាន
- ជាដំបូង ត្រូវសម្ភាសជនសង្ស័យដែលអាចមានកំហុសតិចតួចបំផុត និងសម្ភាសជនរងគ្រោះមុនគេ ប្រសិនបើរឿងក្តីពាក់ព័ន្ធជនរងគ្រោះនោះ
- មិនត្រូវពឹងផ្អែកតែលើការប៉ាន់ប្រមាណ ពីពេលវេលានៃមរណៈភាព ធ្វើឡើងដោយគ្រូពេទ្យ
- ជាធម្មតា ត្រូវយល់ដឹងថា ភស្តុតាងផ្អែកលើសេចក្តីសន្និដ្ឋាន ឬភស្តុតាងប្រយោល និងរូបភស្តុតាងចង្អុលបង្ហាញបុគ្គលណាម្នាក់ ថាជាអ្នកប្រព្រឹត្តបទល្មើស
- ធ្វើកំណត់ហេតុ និងកត់ត្រាសំណួរដែលអ្នកទទួលបាន ពេលប្រមូលព័ត៌មានពីអ្នកផ្តល់អង្គហេតុ
- នៅពេលសម្ភាសបុគ្គលណាម្នាក់ដែលជាប់ពាក់ព័ន្ធនឹងអង្គហេតុនៃរឿងក្តី ចូរសួរពីអ្វីដែលគាត់ជឿថា វាអាចកើតឡើង និងសួរពីជនណាដែលជាជនសង្ស័យសំខាន់ ហើយដោយសារមូលហេតុអ្វី ។

**ខ. ព័ត៌មានជាក់លាក់ដែលមានសារៈសំខាន់ដល់អ្នកស៊ើបអង្កេត**

- ព័ត៌មានអំពីបទល្មើស រួមមាន ៖
  - លក្ខណៈនៃសកម្មភាពល្មើសនឹងច្បាប់ (រំលោភ ប្លន់ គាស់ផ្ទះ... )
  - កាលបរិច្ឆេទ ពេលវេលា និងទីកន្លែងកើតហេតុ
  - ពិពណ៌នាអំពីទីកន្លែងបទល្មើស និងចំណុចកើតហេតុ
  - របៀបដែលបទល្មើស អាចត្រូវបានកើតឡើង
  - មូលហេតុដែលបណ្តាលឱ្យមានការប្រព្រឹត្តបទល្មើស
  - កត្តាដែលនាំឱ្យមានពិរុទ្ធភាពចំពោះជនសង្ស័យណាម្នាក់ ។

- ព័ត៌មានអំពីជនសង្ស័យម្នាក់ ឬច្រើននាក់ រួមមាន ៖
  - ព័ត៌មានសាវតារជាតិផ្ទាល់ខ្លួន
  - ស្ថានភាពផ្លូវចិត្ត និងរាងកាយបច្ចុប្បន្ន ព្រមទាំងប្រវត្តិព្យាបាល
  - ឥរិយាបថចំពោះការស៊ើបអង្កេត
  - ទំនាក់ទំនងជាមួយជនរងគ្រោះ ឬកន្លែងកើតហេតុ
  - អង្គហេតុដែលនាំឱ្យមានពិរុទ្ធភាព ឬមូលហេតុដែលជំរុញឱ្យកើតមាន
  - សេចក្តីដោះសារ ឬអំណះអំណាងដទៃទៀត
  - ទំនាក់ទំនងស្និទ្ធស្នាលខាងសាសនា ឬមិត្តភាព
  - ស្ថានភាពនៃទីស្នាក់អាស្រ័យ
  - ឥរិយាបថទូទៅក្នុងសង្គម
  - ការកំសាន្ត (ចំណូលចិត្តធ្វើពេលទំនេរ)
  - ចំណាប់អារម្មណ៍ ឬការគ្មានអារម្មណ៍ខាងផ្លូវភេទ
  - សមត្ថភាព ឬកាលានុវត្តភាព (ឱកាស)ដើម្បីប្រព្រឹត្តបទល្មើស ។
- ព័ត៌មានអំពីជនរងគ្រោះម្នាក់ ឬច្រើននាក់
  - លក្ខណៈរបួស ឬការឈឺចាប់
  - អាយុ ភេទ ស្ថានភាពគ្រួសារ និងការទទួលខុសត្រូវក្នុងគ្រួសារ
  - ឥរិយាបថក្នុងសង្គមចំពោះពូជសាសន៍ សញ្ជាតិ សាសនា
  - ទំនាក់ទំនងស្និទ្ធស្នាលជាមួយជនល្មើស
  - ស្ថានភាពសង្គម និងសេដ្ឋកិច្ច
  - លក្ខណៈផ្លូវចិត្ត និងផ្លូវកាយ ។

## II. ដំណើរការសម្ភាស

ក្នុងរយៈពេល ២៤ ម៉ោង បានកន្លងផុតទៅ តាំងពីពេលផ្តើមនៃការឃាត់ខ្លួនមកនោះ បុគ្គលដែលឃាត់ខ្លួន អាចសុំសន្ទនាជាមួយមេធាវី ឬជាមួយជនណាម្នាក់ដែលខ្លួនជ្រើសរើស កុំឱ្យតែជននោះមានការទាក់ទិននៅក្នុងរឿងជាមួយ ។ ជននេះត្រូវបានទទួលដំណឹងពីការស្នើសុំជ្រើសរើសនេះ តាមគ្រប់មធ្យោបាយ និងជាបន្ទាន់ ។ ជននេះអាចចូលទៅកាន់កន្លែងឃាត់ខ្លួន និងទាក់ទងជាមួយបុគ្គលសាមីខ្លួនបាន ៣០ (សាមសិប) នាទី ក្នុងលក្ខខណ្ឌធានាការសម្ងាត់នៃការសន្ទនានេះ ។ ក្រោយការសន្ទនា ជននេះអាចធ្វើកំណត់សម្គាល់ជាលាយលក្ខអក្សរ ដែលត្រូវភ្ជាប់ជាមួយសំណុំរឿង (មាត្រា ៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ស្តីពីសិទ្ធិរបស់ជនសង្ស័យ) និងមាត្រា ៩៩ ស្តីអំពីជំនួយរបស់គ្រូពេទ្យនៅក្នុងពេលឃាត់ខ្លួន ។

### ១. ការសម្ភាសក្រៅផ្លូវការ និងផ្លូវការ

#### ក. ការសម្ភាសក្រៅផ្លូវការ

- ត្រូវបានធ្វើនៅកន្លែងកើតហេតុ ឬក្នុងអំឡុងពេលការស៊ើបអង្កេតបន្តនៅស្រុកកំណើតរបស់ជនល្មើស
- ការសម្ភាសត្រូវធ្វើឡើងដោយម៉ត់ចត់ ដើម្បីស្វែងរកការពិតជាមូលដ្ឋាន អំពីបទល្មើស
- ត្រូវធ្វើឱ្យបានឆាប់មុនការស៊ើបអង្កេត
- ព័ត៌មានដែលបានប្រមូលក្នុងពេលសម្ភាសក្រៅផ្លូវការមានគុណប្រយោជន៍សម្រាប់ការសម្ភាសលើកក្រោយ
- ជួយកំណត់អត្តសញ្ញាណភាគីដែលមានកំហុស ។

**ខ. ការសម្ភាសផ្លូវការ**

- ត្រូវធ្វើនៅក្នុងបរិយាកាសដែលបានត្រួតពិនិត្យ
- ការសម្ភាសធ្វើតាមលំដាប់លំដោយជារចនាសម្ព័ន្ធ ដើម្បីងាយស្រួលក្នុងការប្រមូលព័ត៌មានដែលមានសារៈសំខាន់បំផុត
- វាអាចមានលទ្ធភាពធ្វើការសម្ភាស (ផ្ទួផ្ទង ) ចោទប្រកាន់ភ្លាមៗ បន្ទាប់ពីមានការសម្ភាសផ្លូវការ ។

**២. ការរៀបចំការសម្ភាសផ្លូវការ**

- មិនត្រូវប្រាប់ជនសង្ស័យថា គាត់គឺជាជនសង្ស័យសំខាន់នៅក្នុងរឿងក្ដី ។ ភាគច្រើនជនសង្ស័យដែលមានកំហុសយល់ព្រមជួបជាមួយអ្នកស៊ើបអង្កេត ប្រសិនបើគាត់ជឿថា អ្នកស៊ើបអង្កេតមិនបានបង្កើតរឿងក្ដីធ្ងន់ធ្ងរដើម្បីប្រឆាំងគាត់
- ចៀសវាងនិយាយពីភស្តុតាងជាក់លាក់ប្រឆាំងនឹងជនសង្ស័យ ឬការជំទាស់លើអំណះអំណាងពីដំបូងរបស់ជនសង្ស័យ ឬទំនាក់ទំនងដំបូងនៅក្នុងការសម្ភាសក្រៅផ្លូវការលើកមុន
- ធ្វើការសម្ភាសក្នុងឥរិយាបថធម្មតា ដែលស្ដែងចេញនូវគុណប្រយោជន៍ដល់ជនសង្ស័យ
- ប្រាប់ជនសង្ស័យថា មនុស្សផ្សេងទៀតដែលមានការពាក់ព័ន្ធ ក្នុងការស៊ើបអង្កេត បានយល់ព្រមជួបអ្នក ឬអ្នកទាំងនោះត្រូវបានសម្ភាសរួចរាល់ហើយ
- ប្រាប់ជនសង្ស័យថា គាត់មានសិទ្ធិមិនឆ្លើយសំណួរ និងស្នើសុំមេធាវី ។

**៣. ដំណើរការសម្ភាសផ្លូវការ**

រាល់ការសម្ភាសផ្លូវការគួរតែមានសេចក្ដីផ្ដើម តួសេចក្ដី និងសេចក្ដីបញ្ចប់ ។

**ក. សេចក្ដីផ្ដើម**

ការចាប់ផ្ដើមសម្ភាសផ្លូវការមានកត្តាបួនដែលត្រូវចងចាំ រួមមាន ៖

- ភាពនៅដាច់ពីគេ ៖ សាក្សី និងជនសង្ស័យត្រូវតែបំបែកចេញដាច់ពីគ្នា ឱ្យកាន់តែឆាប់កាន់តែល្អ ដើម្បីបង្ការការបាត់បង់គុណភាពនៃព័ត៌មានរបស់ពួកគេ
- ភាពឯកជន (គ្មានការរំខាន) ៖ ជនសង្ស័យត្រូវតែមានអារម្មណ៍ថា ខ្លួនពិតជាទទួលបានភាពឯកជន មិនត្រូវបានគេរំខានដោយមធ្យោបាយណាមួយ
- ការគ្រប់គ្រង ៖ នៅក្នុងស្ថានការណ៍សម្ភាសណាក៏ដោយ អ្នកសម្ភាសតែងតែទទួល

ខុសត្រូវ ។ អ្នកសម្ភាសត្រូវតែបង្កើត និងរក្សាការគ្រប់គ្រងលើការសម្ភាស

- ភាពគួរសម (សុភាពរាបសារ) ៖ ការសម្ភាសទាំងអស់គួរតែទទួលបានជោគជ័យ នៅក្នុងឥរិយាបថសុភាពរាបសារ ដែលគ្មានការរំលោភបំពានខាងពាក្យសម្តី រាងកាយ ឬផ្លូវអារម្មណ៍ ។

**ខ. តួសេចក្តី (ភាពសំខាន់អំឡុងពេលសម្ភាស)**

ភាពសំខាន់ក្នុងអំឡុងពេលសម្ភាស ត្រូវបានប្រើជាមូលដ្ឋានសម្រាប់អង្គហេតុ ដែលជនសង្ស័យពិតជាអាចប្រាប់ព័ត៌មានសំខាន់ៗ ។

- ទំនាក់ទំនងស្និទ្ធស្នាល

អ្នកស៊ើបអង្កេតគួរតែបង្កើតឱ្យមានទំនាក់ទំនងស្និទ្ធស្នាល ជាមួយជនសង្ស័យមុនពេលសួរសំណួរដែលពាក់ព័ន្ធដោយផ្ទាល់នឹងបញ្ហាដែលកំពុងត្រូវបានស៊ើបអង្កេត ។ សាក្សី ឬជនសង្ស័យត្រូវតែមានទំនាក់ទំនងជាមួយអ្នកស៊ើបអង្កេត ដោយពឹងផ្អែកលើភាពគួរជឿជាក់ និងភក្តីភាព នៅក្នុងដំណាក់កាលនេះ ។ ទំនាក់ទំនងស្និទ្ធស្នាលអាចសម្រេចបានដោយ ៖

  - ការសំឡឹងមើល និងការឆ្លើយតបទៅនឹងភាសាកាយវិការរបស់ជនសង្ស័យ
  - ការបញ្ជាក់ពីអត្ថន័យណាមួយដោយអ្នកស៊ើបអង្កេតប្រើភាសាកាយវិការ
  - ធ្វើឱ្យជនសង្ស័យយល់ពីគំនិតឆ្លុះបញ្ចាំងរបស់អ្នកស៊ើបអង្កេត ទៅលើខ្លួនឯង ។

គោលបំណងសម្រាប់បង្កើតឱ្យមានទំនាក់ទំនងស្និទ្ធស្នាល នៅដំណាក់កាលចាប់ផ្តើមការសម្ភាស និងមុនពេលសម្ភាសផ្លូវផ្លង រួមមាន ៖

  - ជនសង្ស័យអាចដឹង និងវាយតម្លៃអ្នកស៊ើបអង្កេត។ ជនសង្ស័យនឹងសន្និដ្ឋានដោយក្តីសង្ឃឹមថា អ្នកស៊ើបអង្កេតជាអ្នកមានវិជ្ជាជីវៈ ចំណេះដឹង និងមិនរិះគន់អ្នកដទៃ
  - ជាដំបូង អ្នកស៊ើបអង្កេតធ្វើការវាយតម្លៃជនសង្ស័យ ដែលរួមមាន ការសង្កេតពិនិត្យលើជំនាញទំនាក់ទំនង ភាពតានតឹងក្នុងចិត្ត និងអាកប្បកិរិយាធម្មតារបស់ជនសង្ស័យ
  - អ្នកស៊ើបអង្កេតអាចបង្កើតកម្រងសំណួរ និងចម្លើយសម្រាប់ការសម្ភាស ។

- កំណត់ហេតុដំបូង

នៅពេលទំនាក់ទំនងស្និទ្ធស្នាលត្រូវបានបង្កើតនៅក្នុងពេលសម្ភាសផ្លូវការ ជាទូទៅអ្នកស៊ើបអង្កេតត្រូវធ្វើកំណត់ហេតុដំបូង ។ គោលបំណងធ្វើកំណត់ហេតុដំបូង រួមមាន ៖

  - ដើម្បីបញ្ជាក់ពីបញ្ហាដែលកំពុងត្រូវបានស៊ើបអង្កេត
  - ដើម្បីកំណត់ដំណោះស្រាយនៃភាពលម្អៀងរបស់អ្នកស៊ើបអង្កេត ដែលពាក់ព័ន្ធនឹងភាពស្មោះត្រង់ ឬការភូតភររបស់ជនសង្ស័យ
  - ប្រាប់ជនសង្ស័យថា ប្រសិនបើគាត់កុហក គេនឹងដឹង ។

- ការរៀបចំសំណួរឱ្យច្បាស់លាស់ក្នុងអំឡុងពេលសម្ភាសផ្លូវការ (តួសេចក្តី)

មានវិធីសាស្ត្រពីរដែលអាចប្រើបន្តបន្ទាប់គ្នាក្នុងការសាកសួរជនសង្ស័យ ៖

  - លំដាប់អនុមានរួម ៖ ចាប់ផ្តើមជាមួយការស្វែងរកព័ត៌មានលម្អិត ហើយឈានទៅរកឱភាសកម្ម (ទូទៅនីយកម្ម) ។ ប្រើដើម្បីឱ្យគោលដៅដែលមានអារម្មណ៍ធូរស្បើយច្រើន

◦ លំដាប់អនុមានញែក ៖ ចាប់ផ្តើមជាមួយសំណួរទូទៅហើយឈានទៅរកលក្ខណៈពិសេសដោយឡែក ។ ប្រើសម្រាប់ជនសង្ស័យដែលមានអារម្មណ៍តានតឹងច្រើន ។

សមត្ថភាពរបស់អ្នកស៊ើបអង្កេតដើម្បីទទួលបានព័ត៌មានដែលមានសារៈសំខាន់ ពីជនសង្ស័យ ដើម្បីឈានទៅដល់ដំណើរការសម្ភាសផ្ទួផ្ទង ដែលទាក់ទងដោយផ្ទាល់ទៅនឹងជំនាញរបស់គាត់នៅក្នុងការរៀបចំសំណួរឱ្យបានច្បាស់លាស់ អ្នកស៊ើបអង្កេតគួរតែ ៖

◦ សួរជនសង្ស័យនូវសំណួរបើកទីមួយ ដើម្បីចម្រាញ់យកការរៀបរាប់ពីដំណើរនៃព្រឹត្តិការណ៍ ឬរៀបរាប់ពីព័ត៌មានលម្អិតអំពីឧប្បត្តិហេតុ ។ អនុញ្ញាតឱ្យជនសង្ស័យឆ្លើយតបទៅនឹងសំណួរដោយគ្មានការបង្អាក់រំខាន

◦ សួរសំណួរបញ្ជាក់ឡើងវិញ ដែលទាក់ទងនឹងចម្លើយរបស់ជនសង្ស័យ ចំពោះសំណួរបើកទីមួយ ។ សំណួរដែលត្រូវប្រើគួរតែជាសំណួរបើក ដែលអនុញ្ញាតឱ្យជនសង្ស័យប្រាប់ពីភាពពិស្តារបន្ថែមទៀតដល់ព័ត៌មានដែលបានផ្តល់រួច

◦ សួរជនសង្ស័យ ដើម្បីដឹងពីជំហរជាក់លាក់របស់គាត់ នូវចំណុចដែលមិនទាន់ច្បាស់

◦ ប្រសិនបើការឆ្លើយតបទៅនឹងសំណួរផ្ទាល់មាននិមិត្តហេតុ (សញ្ញា) នៃការភូតភរ អ្នកស៊ើបអង្កេតគួរតែសួរសំណួរបន្តឱ្យបានសមរម្យ ។

- ការធ្វើឱ្យចងចាំឡើងវិញក្នុងអំឡុងពេលសម្ភាសផ្លូវការ

អ្នកស៊ើបអង្កេតត្រូវតែត្រៀម ដើម្បីដោះស្រាយនឹងលទ្ធភាពនៃការបាត់បង់ការចងចាំដែលបានពីជនសង្ស័យ ។ មធ្យោបាយត្រឹមត្រូវបំផុតសម្រាប់ការធ្វើឱ្យចងចាំឡើងវិញ គឺធ្វើតាមដំណាក់កាល ។ ជាទូទៅ មានវិធីសាស្ត្រ ៤ សម្រាប់ពញ្ញាក់ឱ្យមានការចងចាំឡើងវិញ ៖

◦ គួរតែសួរជនសង្ស័យឱ្យរំលឹកស្ថានភាពជុំវិញឧប្បត្តិហេតុ

◦ គួរតែសួរជនសង្ស័យឱ្យរៀបរាប់ពីព្រឹត្តិការណ៍ដែលកើតមាន

◦ គួរតែសួរជនសង្ស័យឱ្យរំលឹកព្រឹត្តិការណ៍ដែលកើតមានតាមដំណាក់កាល

◦ គួរតែសួរជនសង្ស័យឱ្យរកនឹកពីរូបភាពប្រហាក់ប្រហែលរបស់នរណាម្នាក់ នៅក្នុងហេតុការណ៍នោះ ។

ចំពោះការកំណត់អត្តសញ្ញាណផ្ទាល់ខ្លួន មានបញ្ជីព្រាងចំណាំពីរូបរាង ៖

◦ កាយសាស្ត្រ ឬភិនភាគ
  - ពូជសាសន៍ ឬជនជាតិ
  - ភេទ ៖ ប្រុស ស្រី
  - កម្ពស់
    - តិចជាង ១ ម៉ែត្រ ៥២
    - ពី ១ ម៉ែត្រ ៥២ ដល់ ១ ម៉ែត្រ ៧០
    - ពី ១ ម៉ែត្រ ៧១ ដល់ ១ ម៉ែត្រ ៨៣
    - ពី ១ ម៉ែត្រ ៨៤ ឡើងទៅ ។

- ទម្ងន់
  - តិចជាង ៤៥ គីឡូក្រាម
  - ពី ៤៥ ដល់ ៦៣ គីឡូក្រាម
  - ពី ៦៤ ដល់ ៨១ គីឡូក្រាម
  - លើសពី ៨១ គីឡូក្រាម ។
- មាឌធំ ល្មម តូច
- មុខរាងមូល ជ្រុង ទ្រវែង ស្រួច ពងក្រពើ
- ក្បាលរាងសំប៉ែតលើ មូល ខាងក្រោយត្រង់ ថ្ងាសធក
- សម្បុរស្បែកស ខ្មៅស្រអែម ខ្មៅខ្លាំង ក្រហមព្រឿង
- ពណ៌សក់ សណ្ឋានសក់ ម៉ូដសក់
- រោមមុខ
- ពណ៌ភ្នែក សណ្ឋានភ្នែក ចិញ្ចើម ត្របកភ្នែក ពិការភ្នែក
- ច្រមុះមើលចំពីមុខ និងចំហៀង
- បបូរមាត់ ធ្មេញ
- ចង្កាមើលចំពីមុខ និងចំហៀង
- ត្រចៀកមើលចំពីមុខ និងចំហៀង ។

○ អាកប្បកិរិយា
- សម្ដី ៖ ទន់ភ្លន់ ការសង្កត់សំឡេង សម្ដីតឹងដើមក សម្ដីអាក់អួល
- ទម្លាប់ខាំក្រចក ទំពារស្ករកៅស៊ូ អេះក្បាល និងអេះខ្លួន
- ដំណើរដើរ
- ជំងឺសរសៃប្រសាទ
- ជក់បារី គ្រឿងញៀន និងស្រា ។

## គ. សេចក្ដីបញ្ចប់

ផ្នែកចម្បងទីបីនៃការសម្ភាស គឺសេចក្ដីបញ្ចប់នេះឯង ។ នៅត្រង់ចំណុចនេះ ជនសង្ស័យត្រូវតែត្រៀមខ្លួនសម្រាប់ការសម្ភាសជាថ្មីដែលនឹងអាចកើតមាន ។ ប្រាប់ពួកគេថា រឿងក្ដីនេះកំពុងតែដំណើរការហើយ វានឹងត្រូវបានដោះស្រាយឆាប់ៗនេះ ។

លំនាំមុខចំពោះភាពស្មោះត្រង់ និងការភូតភរះ ជាបន្តបន្ទាប់ អ្នកស៊ើបអង្កេតគួរតែចងចាំថា វាមិនអាចមានលទ្ធភាពរកឱ្យឃើញការភូតភរ ឬកំណត់ភាពស្មោះត្រង់របស់អ្នកឆ្លើយសម្ភាសដោយគ្រាន់តែផ្អែកទៅលើអំណះអំណាង ឬសកម្មភាពរបស់ពួកគេ ។ ព័ត៌មាននេះត្រូវបានផ្ដល់សម្រាប់ជំនួយដល់អ្នកសម្ភាសតែប៉ុណ្ណោះ ។

## III. ការចង្អុលបង្ហាញភាពស្មោះត្រង់ ឬការភូតភរក្នុងអំឡុងពេលសម្ភាសផ្លូវការ

### ១. ការចង្អុលបង្ហាញភាពស្មោះត្រង់

- សេចក្តីលម្អិតស្រដៀងគ្នាជុំវិញរឿងហេតុ ៖ ប្រសិនបើរឿងហេតុនោះពិតប្រាកដ គួរតែមានសេចក្តីលម្អិតស្រដៀងគ្នាជុំវិញរឿងហេតុ
- ព័ត៌មានមិនតាមលំដាប់លំដោយ ៖ ជាញឹកញាប់ ជួយជំរុញឱ្យនឹកឃើញឡើងវិញពីព្រឹត្តិការណ៍
- ការសម្តែងគំនិត និងការរំជួលចិត្ត ៖ នៅពេលកំពុងប្រតិកម្មទៅនឹងឧប្បត្តិហេតុ ដែលប៉ះទង្គិច ជាធម្មតាជនសង្ស័យដែលស្មោះត្រង់នឹងមានអារម្មណ៍រំជួលចិត្តនៅពេលឆ្លើយសំណួរ ។

### ២. ការចង្អុលបង្ហាញការភូតភរ

- កម្រិតនៃសេចក្តីលម្អិតផ្សេងៗគ្នា ៖ អ្នកស៊ើបអង្កេតគួរតែមានមន្ទិលសង្ស័យថា រឿងហេតុអាចជាការភូតភរ ប្រសិនបើវាមានពិពណ៌នាលម្អិតច្រើន ដែលផ្តល់តម្រុយទៅរកឧប្បត្តិហេតុសំខាន់ៗ ប៉ុន្តែព្រឹត្តិការណ៍សំខាន់ខ្វះខាតនូវកម្រិតនៃសេចក្តីលម្អិតនេះ
- ដំណាក់កាលសុក្រឹតនៅក្នុងរឿងហេតុ ៖ រឿងហេតុដែលប្រព្រឹត្តតាមដំណាក់កាលពី **A** ដល់ **Z** ដោយគ្មានការរំលងពេលវេលាណាមួយ ជាញឹកញាប់ វាគួរឱ្យសង្ស័យណាស់
- អវត្តមានគំនិត និងការរំជួលចិត្ត ៖ ប្រសិនបើរឿងហេតុត្រូវបានប្រឌិតឡើង ជាញឹកញាប់ ជនសង្ស័យមានកង្វះខាតខាងគំនិត ឬការរំជួលចិត្ត
- ការប្រើសម្តីបញ្ឆិតបញ្ឆៀង ៖ ជនសង្ស័យភូតភរពឹងផ្អែកទាំងស្រុងលើអ្នកស៊ើបអង្កេតដែលធ្វើការដាក់លាក់ពីអ្វីដែលប្រហែលអាចនឹងកើតឡើង ។

### ៣. សំណួរសម្រាប់បញ្ជាក់ចំពោះជនសង្ស័យដែលអាចភូតភរ

នៅពេលជនសង្ស័យបានឆ្លើយតបទៅនឹងសំណួររបស់អ្នកស៊ើបអង្កេតទាំងអស់ ហើយការសម្ភាសផ្លូវការត្រូវបានចប់រួចរាល់ អ្នកស៊ើបអង្កេតគួរតែសួរសំណួរបញ្ជាក់ឡើងវិញ ។ ផ្នែកដែលអាចត្រូវការបញ្ជាក់បន្ថែម គឺ ៖

- សេចក្តីលម្អិតត្រួសៗ
- ឥរិយាបថដែលមិនអាចពន្យល់បាន ឬមិនត្រឹមត្រូវ
- ការប្រើឃ្លាសម្តីដាច់ៗ
- ការប្រើសម្តីបញ្ឆិតបញ្ឆៀង
- មនុស្សដែលមិនត្រូវបានកំណត់អត្តសញ្ញាណ
- ការសន្ទនា
- ការប្រើឃ្លាសម្រាប់បញ្ជាក់ ( ខ្ញុំជឿថា ខ្ញុំគិតថា ដូចដែលខ្ញុំនឹកឃើញ ) ។

សំណួរសម្រាប់បញ្ជាក់ គឺជាសំណួរបើកដែលអាចត្រូវបានបែងចែកជាបីប្រភេទគឺ ៖

- សំណួរដែលធ្វើឱ្យទទួលបានព័ត៌មានច្រើនថែមទៀត
- សំណួរដែលស្វែងរកពីការពន្យល់ពីព្រឹត្តិការណ៍

- សំណួរដែលទទួលបាននូវព័ត៌មានពីអារម្មណ៍ ឬគំនិតរបស់ជនសង្ស័យ ។

កត្តារំលឹកពីការលំបាកក្នុងការវាយតម្លៃការពិត និងការភូតភរ ៖ អ្នកស៊ើបអង្កេតគួរតែចងចាំថា វាមិនអាចមានលទ្ធភាពដើម្បីរកឱ្យឃើញការភូតភរ ឬកំណត់ការពិតនៃអ្នកឆ្លើយសម្ភាស ដោយគ្រាន់តែផ្អែកទៅលើអំណះអំណាង ឬសកម្មភាពរបស់ពួកគេ ។ ព័ត៌មាននេះត្រូវបានផ្តល់សម្រាប់ជំនួយដល់អ្នកសម្ភាសតែប៉ុណ្ណោះ ។

## IV. ការត្រៀមរៀបចំ និងវិធីសាស្ត្រក្នុងការសម្ភាសផ្លូវផ្លងប្រកបដោយជោគជ័យ

### ១. ការជ្រើសរើសអ្នកសម្ភាស

មុនឈានដល់ការធ្វើសម្ភាសផ្លូវផ្លង ការជ្រើសរើសអ្នកសម្ភាសគួរតែត្រូវធ្វើការពិចារណា ។ មានឧទាហរណ៍ជាច្រើនបង្ហាញថា បុគ្គលដែលពិតជាអ្នកស្រាវជ្រាវរឿងក្តី អាចមិនមែនជាបុគ្គលល្អដើម្បីធ្វើសម្ភាសទេ ។ អ្នកសម្ភាសដែលមានចរិតឈ្លោះប្រកែក មិនងាយយល់ព្រម ឬអារម្មណ៍តានតឹងប្រឆាំងអ្នកស៊ើបអង្កេតដោយសារការចាប់ឃាត់ខ្លួន មិនត្រូវបានជ្រើសរើសឱ្យធ្វើការសម្ភាសផ្លូវផ្លងទេ។

លក្ខណៈសម្បត្តិចាំបាច់របស់អ្នកធ្វើសម្ភាស រួមមាន ៖

- បញ្ញាឆ្លាតវៃល្អ
- ការយល់ដឹងខ្ពស់ពីលក្ខណៈធម្មជាតិរបស់មនុស្ស
- សមត្ថភាពចុះសម្រុងជាមួយមនុស្សដទៃ
- ការតស៊ូ និងការអត់ធ្មត់
- ជាអ្នកពូកែស្តាប់
- ជាអ្នកប្រសប់ទាក់ទង
- ជាអ្នកឆាប់ចាប់បានចំណុចដែលគួរឱ្យសង្ស័យ
- មានការគ្រប់គ្រងអារម្មណ៍ និងឫកពារបានល្អ
- មានការទុកចិត្តសមត្ថភាពខ្លួនឯងក្នុងការស្វែងយល់ពីការភូតភរ
- មានអារម្មណ៍ភ្លឺថ្លាក្នុងការប្រើប្រាស់បច្ចេកទេសសម្ភាសផ្លូវផ្លង

### ២. គុណសម្បត្តិអ្នកសម្ភាស

តាមទ្រឹស្តី អ្នកស៊ើបអង្កេតដែលបានសម្ភាសជនសង្ស័យណាម្នាក់ គួរតែធ្វើការសម្ភាសផ្លូវផ្លងលើជនសង្ស័យនោះដែរ ។ ហេតុផលចំពោះការធ្វើបែបនេះគឺថា ការសម្ភាសបែបមិនចោទប្រកាន់ធ្វើឱ្យអ្នកស៊ើបអង្កេតមានទំនាក់ទំនងដែលគួរជឿទុកចិត្តបានជាមួយជនសង្ស័យ ដែលធ្វើឱ្យមានប្រយោជន៍ដល់ការខិតខំប្រឹងប្រែងធ្វើឱ្យជនសង្ស័យឆ្លើយសារភាពក្នុងពេលសម្ភាសផ្លូវផ្លងបែបចោទប្រកាន់ ។

- អ្នកសម្ភាសត្រូវតែបញ្ចៀសអារម្មណ៍ផ្ទាល់ខ្លួន ឬគំនិតព្យាបាទដែលខ្លួនអាចមានទៅលើជនសង្ស័យ
- អ្នកសម្ភាសដែលចង់ឱ្យជនសង្ស័យផ្តល់សំណាងលើបទល្មើស នឹងបង្កលក្ខខណ្ឌដែលនាំទៅដល់ការសារភាពមិនពិត
- អ្នកសម្ភាសត្រូវតែមានសមត្ថភាព ចម្រាញ់យកចម្លើយសារភាពពីកំហុស ហើយត្រៀម

ធ្វើការសម្រេចចិត្តលើភាពស្មោះត្រង់

- អ្នកសម្ភាសត្រូវតែមានសមត្ថភាពដឹងពីអាកប្បកិរិយារបស់ជនសង្ស័យ ហើយដោះស្រាយយ៉ាងមានប្រសិទ្ធភាពចំពោះហេតុការណ៍ ។

### ៣. ឥរិយាបថរបស់អ្នកសម្ភាសក្នុងអំឡុងពេលសម្ភាសផ្ទួផ្ទង

- នៅក្នុងដំណាក់កាលដំបូងនៃការសម្ភាសផ្ទួផ្ទង អ្នកសម្ភាសគួរតែអង្គុយចម្ងាយប្រមាណ ១.២០ ម៉ែត្រ ទល់មុខជនសង្ស័យ
- អ្នកស៊ើបអង្កេតគួរតែអង្គុយក្នុងឥរិយាបថត្រឹមត្រូវ ដើម្បីបង្ហាញពីការជឿទុកចិត្ត និងយកចិត្តទុកដាក់ខ្លាំង
- គួរតែមិនត្រូវមានអ្វីនៅពីមុខអ្នកស៊ើបអង្កេត និងជនសង្ស័យទេ ដូចជា ដបទឹក...
- អ្នកស៊ើបអង្កេតគួរតែអង្គុយនៅកន្លែងដដែល ហើយកុំដើរចេញពីបន្ទប់ ។ ធ្វើដូច្នេះ ជនសង្ស័យកាន់តែមានការលំបាកក្នុងការបិទបាំងការភូតភររបស់ខ្លួន នៅពេលអ្នកសម្ភាសកំពុងផ្ដោតការយកចិត្តទុកដាក់យ៉ាងខ្លាំងជាមួយគាត់
- អ្នកស៊ើបអង្កេតគួរតែជៀសវាងផ្តល់ចំណាប់អារម្មណ៍ថា ខ្លួនកំពុងស្វែងរកចម្លើយសារភាព ឬការចោទប្រកាន់ដើម្បីផ្តន្ទាទោស ។ អ្នកស៊ើបអង្កេតគួរតែបំពេញតួនាទីរបស់ខ្លួន ដើម្បីស្វែងរកការពិតឱ្យឃើញ
- កុំប្រើប្រាស់ពាក្យសម្ដីដែលធ្វើឱ្យរំជួលចិត្ត ដូចជា ពាក្យរំលោភ សម្លាប់ឬច្របាច់កឱ្យស្លាប់
- ដោយមិនគិតដល់លក្ខណៈនៃបទល្មើស អ្នកសម្ភាសត្រូវតែមានសមត្ថភាពនិយាយជាមួយជនសង្ស័យដោយសមានចិត្ត និងការយោគយល់
- ជនសង្ស័យគួរតែមិនត្រូវបានដាក់ខ្នោះ ឬច្រវាក់ក្នុងពេលសម្ភាសទេ
- មន្ត្រីនគរបាលមិនគួរកាន់អាវុធទេក្នុងពេលសម្ភាសផ្ទួផ្ទង ។ អ្នកស៊ើបអង្កេតគួរតែមើលទៅជនសង្ស័យក្នុងឋានៈជាមនុស្សដូចគ្នា ប្រសើរជាងចាត់ទុកជនសង្ស័យក្នុងឋានៈអ្នកទោស
- អ្នកស៊ើបអង្កេតត្រូវតែដឹងថា មនុស្សគ្រប់រូបមានចំណុចល្អ តែផ្ទុយទៅវិញចំណុចអាក្រក់ក៏អាចកើតមានដែរ ។

អ្នកសម្ភាស ត្រូវតែស្លៀកពាក់ឯកសណ្ឋាន ហើយមើលទៅហាក់ដូចជា អ្នកមានអាជីពច្បាស់លាស់គ្រប់ពេលវេលា ទោះបីការធ្វើបែបនេះអាចពិតនៅក្នុងស្ថានភាពខ្លះក៏ដោយ អ្នកស៊ើបអង្កេតគួរតែពិចារណាផងដែរទៅលើតម្រូវការរបស់ជនសង្ស័យ ។ អ្នកសម្ភាសគួរតែផ្លាស់ប្តូរឥរិយាបថខាងក្រៅ ដោយអាស្រ័យលើជនសង្ស័យដែលខ្លួនកំពុងសម្ភាស ។

### ក. ការប្រើភាសា

- ការទាក់ទាញទឹកចិត្តជនសង្ស័យឱ្យឆ្លើយសារភាពកំហុស គឺជាភាពជោគជ័យនៃទំនាក់ទំនងស្និទ្ធស្នាល និងទំនាក់ទំនងខាងភាសារបស់អ្នកសម្ភាសជាមួយជនសង្ស័យ
- ការប្រើភាសាគឺសំខាន់ ដើម្បីធ្វើឱ្យជនសង្ស័យយល់ដឹងនូវអ្វីដែលត្រូវបានសួរ
- អ្នកសម្ភាសគួរតែកុំព្យាយាមយកប្រៀបលើជនសង្ស័យ

• អ្នកសម្ភាសអាចបញ្ជាក់ពីភាពសំខាន់នៃឧប្បត្តិហេតុ ដោយការលើកដាក់សំឡេង និងការជ្រើសរើសពាក្យនិយាយ

• ពាក្យសម្តីមិនពិរោះស្តាប់ដែលបង្កប់ន័យទណ្ឌកម្ម អាចប្រើដើម្បីជួយបង្កើតឡើងវិញនូវភាពសំខាន់នៃឧប្បត្តិហេតុដែលស្ថិតក្រោមការស៊ើបអង្កេត ។

**ខ. សំណុំរឿង និងភស្តុតាង**

• ការសម្ភាសផ្ទួផ្ទងលើជនសង្ស័យ ដែលប្រើប្រាស់សំណុំរឿងក្តី អាចជួយធ្វើឱ្យមានចម្លើយសារភាព

• វាអាចមានគុណប្រយោជន៍ផងដែរ ក្នុងការទទួលបានភស្តុតាងណាមួយពីជនសង្ស័យនៅក្នុងបន្ទប់សម្ភាសដែលជាប់ពាក់ព័ន្ធបន្ថែមទៀត ។

**គ. ភាពឯកជន**

ការរៀបចំដាច់ដោយឡែកមួយជួយជំរុញដល់ភាពឯកជន និងភាពស្និទ្ធស្នាល ដែលអ្នកសម្ភាសមានក្នុងការសម្ភាសផ្ទួផ្ទង ។ ការរៀបចំនេះគួរតែ ៖

• ចាត់ចែងឱ្យបានល្អ ដើម្បីកាត់បន្ថយការរំខាន និងការបែកអារម្មណ៍ឱ្យមានកម្រិតអប្បបរមា និងដើម្បីឱ្យជនសង្ស័យអាចផ្តោតអារម្មណ៍លើការសម្ភាស

• រៀបចំឱ្យបានល្អក្នុងពេលសម្ភាស

• ស្ថិតក្នុងកន្លែងណាមួយដែលនឹងមានការរំខានតិចតួច

• អនុញ្ញាតឱ្យជនសង្ស័យអង្គុយបែរខ្នងទៅទ្វារ (តាមស្ថានភាពជាក់ស្តែង)

• យកចេញឱ្យអស់នូវសម្ភារទាំងឡាយ ដែលអាចធ្វើឱ្យជនសង្ស័យបែកអារម្មណ៍

• យកចេញក្រៅនូវសម្ភារសាមញ្ញ ដូចជា ប្រដាប់កឹបក្រដាស ខ្មៅដៃ និងរបស់របរដទៃទៀតនៅក្នុងបន្ទប់ កុំឱ្យជនសង្ស័យឃើញ ។

## V. របៀបដំណើរការដែលអាចខុសឆ្គងក្នុងពេលធ្វើសម្ភាសផ្ទួផ្ទង

ការសម្ភាសផ្ទួផ្ទងរបស់នគរបាលអាច " ខុសឆ្គង " ក្នុងហេតុផលដែលថា វានាំទៅរកផលវិបាកដែលមិនចង់បានសម្រាប់ជនសង្ស័យ ឬប្រព័ន្ធយុត្តិធម៌ ។ ការខុសឆ្គងអាចកើតឡើងតាមវិធី ៖

• ចម្លើយសារភាពក្លែងក្លាយដោយសារការបង្ខិតបង្ខំ ៖ អាចកើតឡើងនៅពេលដែលមន្ត្រីនគរបាលសន្មតខុស ថាជនសង្ស័យមានកំហុស និងមានអារម្មណ៍ថាខ្លួនគ្មានកំហុស ក្នុងការបង្ខិតបង្ខំដើម្បីទទួលបានចម្លើយសារភាពពីជនសង្ស័យ

• ចម្លើយសារភាពដែលមិនអាចយកជាការបាន ៖ នៅពេលនគរបាលបង្ខិតបង្ខំឱ្យឆ្លើយសារភាព ចម្លើយសារភាពរបស់ជនសង្ស័យ ទោះបីជាពិតក៏ដោយ ក៏អាចប្រកាសថាមិនអាចយកជាការបាននៅក្នុងតុលាការដែរ

• ចម្លើយសារភាពត្រូវគេបង្ខំនាំឱ្យមានវិប្បដិសារៈ ៖ នៅពេលជនសង្ស័យមានអារម្មណ៍ ថាត្រូវបានគេបង្ខិតបង្ខំឱ្យផ្តល់ចម្លើយសារភាព ពួកគេមានអារម្មណ៍អាក់អន់ចិត្តចំពោះនគរបាល ហើយ

ពួកគេអាចបដិសេធចម្លើយសារភាពរបស់ខ្លួនក្នុងតុលាការ

- ការបង្ខិតបង្ខំកើតមានពីអារម្មណ៍ច្របូកច្របល់ដោយការភ័យខ្លាចពីមុន ៖ បច្ចេកទេសសម្ភាសដោយប្រើសម្តីទ្រគោះបក់បោក អាចបង្កឱ្យមានការរំខានអារម្មណ៍ផ្លូវចិត្តយ៉ាងខ្លាំងដល់ជនសង្ស័យមួយចំនួន
- ការធ្វើឱ្យជនសង្ស័យបាត់ទំនុកចិត្ត ៖ បច្ចេកទេសសម្ភាសរបស់នគរបាលដែលប្រើប្រាស់យ៉ាងប្រសប់ក្នុងការបង្ខិតបង្ខំ អាចធ្វើឱ្យជនសង្ស័យបាត់ទំនុកចិត្តលើខ្លួន ។

**១. កត្តាដែលបង្អាក់ដល់ការសារភាព**

មានកត្តាមួយចំនួនដែលធ្វើឱ្យមានការលំបាកដល់បុគ្គលដើម្បីឆ្លើយសារភាពចំពោះបទល្មើសដែលខ្លួនបានប្រព្រឹត្ត រួមមាន ៖

- ការភ័យខ្លាចការដាក់ទណ្ឌកម្មតាមផ្លូវច្បាប់
- ការបារម្ភអំពីកេរ្តិ៍ឈ្មោះរបស់ខ្លួន
- ការមិនចង់ទទួលថាពិតពីអ្វីដែលខ្លួនបានធ្វើ
- ការមិនចង់ឱ្យគ្រួសារ និងមិត្តភក្តិ ដឹងពីការប្រព្រឹត្តិបទល្មើសរបស់ខ្លួន
- ការភ័យខ្លាចសងសឹក ៖ អាចមានអារម្មណ៍ថា អ្នកដទៃដែលពាក់ព័ន្ធនឹងបទល្មើសនោះនឹងសងសឹក ។

**២. ការចងចាំ និងការសារភាពក្លែងក្លាយ**

**ភាពខុសគ្នារវាងការទទួលស្គាល់ និងការសារភាព**

- ការទទួលស្គាល់៖ ការទទួលស្គាល់ដោយស្ម័គ្រចិត្ត ឬអំណះអំណាងទទួលស្គាល់នូវអង្គហេតុ ឬការពិតនៃអ្វីមួយ
- ការសារភាព៖ ការអះអាងដោយទទួលស្គាល់នូវកំហុសក្នុងការប្រព្រឹត្តិបទល្មើស ឬការអះអាងផ្លូវការដោយទទួលថា ខ្លួនមានកំហុសដោយបានប្រព្រឹត្តបទល្មើស ។

ទោះបីជាគោលបំណងសំខាន់នៃការស្រង់ចម្លើយជនសង្ស័យ គឺទទួលបាននូវការពិតទាក់ទងនឹងជនសង្ស័យដែលបានពាក់ព័ន្ធនឹងបទល្មើសក៏ដោយ ក៏ជនសង្ស័យអាចមិនសារភាពពីការពាក់ព័ន្ធរបស់ខ្លួន គ្រប់ពេលនោះដែរ ។ នៅក្នុងអំឡុងពេលនៃការស្រង់ចម្លើយ អ្នកសម្ភាសគួរតែធ្វើយ៉ាងណាឱ្យជនសង្ស័យទទួលស្គាល់អង្គហេតុ ឬការពិត ដែលមានសារសំខាន់ដល់ការស៊ើបអង្កេត ។ ជាញឹកញាប់ ជនសង្ស័យនឹងទទួលស្គាល់ ប៉ុន្តែមិនសារភាពពីកំហុសរបស់ខ្លួន ។ ការទទួលស្គាល់របស់ជនសង្ស័យមានសារសំខាន់ ដើម្បីឱ្យដឹងថា គាត់ជាប់ពាក់ព័ន្ធនៅក្នុងបទល្មើស ទោះបីមិនសារភាពក៏ដោយ ។ ទោះយ៉ាងណាក៏ដោយ ការទទួលស្គាល់ជាបន្តបន្ទាប់ នឹងនាំទៅដល់ការសារភាព ។ ឧទាហរណ៍៖ ក្នុងករណីឃាតកម្ម ជនសង្ស័យអាចទទួលស្គាល់ថា ខ្លួនស្ថិតនៅកន្លែងកើតហេតុ ប៉ុន្តែមិនទទួលស្គាល់ថា ខ្លួនបានសម្លាប់ជនរងគ្រោះទេ ។ ការទទួលស្គាល់នេះមានសារសំខាន់ ដោយបានបង្ហាញថា ជនសង្ស័យបានស្ថិតនៅកន្លែងកើតហេតុ និងជាអង្គហេតុសំខាន់ ឬការពិត សម្រាប់ការស៊ើបអង្កេត ។

លោក Ofshe ជាសង្គមវិទូជនជាតិអាម៉េរិក (1989) ឱ្យនិយមន័យទៅលើពាក្យ “ចម្លើយសារភាពក្លែងក្លាយ” គឺជាភាពក្លែងក្លាយប្រសិនបើវាត្រូវបានចម្រាញ់យកចម្លើយ ដើម្បីឆ្លើយតបទៅនឹងការទាមទារឱ្យមានចម្លើយសារភាព ហើយត្រូវបានប្រឌិតឡើងដោយចេតនា ឬមិនផ្អែកលើការយល់ដឹងការណ៍ពិតជាក់ស្តែង ។

**ក. ប្រភេទនៃការសារភាពក្លែងក្លាយ**

- ការសារភាពក្លែងក្លាយដោយស្ម័គ្រចិត្ត ៖ កើតឡើងនៅពេលដែលជនសង្ស័យទទួលស្គាល់នូវទង្វើរបស់ខ្លួនដោយគ្មានការគាបសង្កត់ពីអ្នកណាម្នាក់ ឬពីប្រភពខាងក្រៅ
- ការសារភាពក្លែងក្លាយដែលធ្វើតាមគេដោយបង្ខំចិត្ត ៖ ឱ្យលទ្ធផលនៅពេលដែលជនសង្ស័យជឿថា ខ្លួនទទួលផលប្រយោជន៍ភ្លាម ដែលអាចរួចផុតពីការផ្តន្ទាទោស
- ការសារភាពក្លែងក្លាយធ្វើដោយខ្លួនឯងដោយបង្ខំចិត្ត ៖ កើតឡើងនៅពេលដែលជនសង្ស័យជឿថា ខ្លួនពិតជាបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ។

**ខ. កត្តាដែលអាចរួមចំណែកដល់ចម្លើយសារភាពក្លែងក្លាយ**

- អាយុរបស់ជនសង្ស័យ ៖ កុមារភាគច្រើន ឱ្យចម្លើយសារភាពខុសគ្នាទៅលើបទល្មើសបើប្រៀបធៀបទៅនឹងមនុស្សពេញវ័យ ពីព្រោះ ៖
    - កុមារខ្វះបទពិសោធន៍នៅពេលជួបបញ្ហាក្នុងសង្គម និងដោះស្រាយជម្លោះ
    - ជាញឹកញាប់ កុមារព្យាយាមបំពេញចិត្តមនុស្សពេញវ័យ ជាពិសេសនៅពេលដែលខ្លួនស្ថិតក្នុងបរិយាកាសមិនធ្លាប់ជួប
    - ចម្លើយដែលត្រូវបានផ្តល់ជាអនុសាសន៍ដល់កុមារ ជាញឹកញាប់ មានឥទ្ធិពលដល់ការឆ្លើយតបមកវិញរបស់កុមារ
    - សំណួរនាំមុខប្រើដោយមនុស្សពេញវ័យ អាចលើកទឹកចិត្តដល់ការឆ្លើយតបពិតប្រាកដពីកុមារ ។
- ការចងចាំ និងបញ្ញា ៖ ការចងចាំខ្សោយ និងបញ្ញាអន់ អាចបណ្តាលឱ្យមនុស្សឆ្លើយសារភាពក្លែងក្លាយ
    - ជាញឹកញាប់ ជនសង្ស័យដែលបាត់ការចងចាំ គឺអ្នកញៀនស្រា ឬប្រើគ្រឿងញៀន
    - មនុស្សដែលគ្មានបញ្ញាឆ្លាតវៃ អាចមិនយល់ច្បាស់ពីសំណួរ
    - ជាញឹកញាប់ មនុស្សមានវិបត្តិផ្លូវចិត្ត ឆាប់ប្រតិកម្មលើការស្តីបន្ទោស ។
- ការមិនយល់ដឹងពីការគិតអរូបី ៖
    - ជាញឹកញាប់ បុគ្គលម្នាក់ៗមានបញ្ហាលំបាកក្នុងការយល់នូវវិសាលភាពពេញលេញនៃពាក្យសម្តី ឬភាសាដែលប្រើ
    - កុមារ និងមនុស្សមានវិបត្តិផ្លូវចិត្ត អាចនិយាយដោយត្រង់ក្នុងការបកស្រាយភាសារបស់ពួកគេ និងមិនយល់នូវពាក្យសម្តីដែលមានន័យច្រើនយ៉ាង ។

### ៣. បុព្វហេតុនៃការបដិសេធចំពោះការប្រព្រឹត្តបទល្មើស

ជាញឹកញាប់ បុព្វហេតុចម្បងនៃការបដិសេធ គឺដោយសារតែអ្នកសម្ភាស ។ ជនសង្ស័យអាចមានការបដិសេធ ដែលជាអាកប្បកិរិយាគេចវេស ឬការពារខ្លួន ។ ជាធម្មតា មនុស្សម្នាក់ៗចេះសម្រប ខ្លួនក្នុងសង្គមដើម្បីស្វែងរកផលប្រយោជន៍ ហើយប្រសិនបើផលប្រយោជន៍នៃការប្រាប់ការពិតមាន សារៈសំខាន់ជាងផលវិបាកនៃការទទួលស្គាល់ ជនសង្ស័យនឹងសារភាពចំពោះទង្វើរបស់ខ្លួន ។

**ក. ការភ័យខ្លាចរបស់ជនសង្ស័យ** គឺជាហេតុផលមួយក្នុងចំណោមហេតុផលចម្បងៗ ដែលជនសង្ស័យមិនឆ្លើយសារភាពចំពោះការប្រព្រឹត្តបទល្មើស ។ ជាធម្មតា ការភ័យខ្លាចរបស់ជនសង្ស័យ បង្ហាញឱ្យឃើញនូវប្រភេទមួយនៃប្រភេទទាំង ៥ ៖

- ការភ័យខ្លាចការចោទប្រកាន់
- ការភ័យខ្លាចការបាត់បង់ការងារ
- ការភ័យខ្លាចការអាម៉ាស់មុខ
- ការភ័យខ្លាចសំណងបដិទាន (ការសងការខូចខាត ឬបាត់បង់)
- ការភ័យខ្លាចចំពោះសុវត្ថិភាពផ្ទាល់ខ្លួន និងអ្នកដទៃ ។

**ខ. បរិយាកាស**

- ក្នុងបរិយាកាសគ្មានភាពឯកជន (ត្រូវបានគេរំខាន) ជនសង្ស័យអាចមានអារម្មណ៍ភ័យខ្លាចពីការអាម៉ាស់កាន់តែខ្លាំងឡើង ដែលជាញឹកញាប់ធ្វើឱ្យមានការឆ្លើយបដិសេធ
- ជនសង្ស័យមិនគួរត្រូវបានសម្ភាសក្នុងបរិយាកាសស្និទ្ធស្នាល និងគាំទ្រទេ បើមិនដូច្នេះ ពួកគេកាន់តែបានចិត្តក្នុងការបដិសេធចំពោះការជាប់ពាក់ព័ន្ធនឹងបទល្មើស
- កម្រិតបរិយាកាសងាយស្រួលកាន់តែខ្ពស់ ហាក់បីដូចជាធ្វើឱ្យជនសង្ស័យបានចិត្ត ហើយប្រានចោលភស្តុតាងដែលប្រឆាំងនឹងពួកគេ
- អ្នកសម្ភាសគួរជៀសវាងជំហរណាមួយ ដែលបង្កើនដល់ការការពាររបស់ជនសង្ស័យ ដូចជា ឈរកៀកនឹងជនសង្ស័យ ឬការសម្លឹងមើលយ៉ាងជិត ។

**គ. អ្នកសម្ភាស**

- អ្នកសម្ភាសដែលគ្មានការអត់ធ្មត់ មានចរិតរំលោភបំពាន ឬគ្មានសមានចិត្តចំពោះជនសង្ស័យ ជាញឹកញាប់ ជំរុញឱ្យជនសង្ស័យការពារខ្លួន និងបដិសេធ
- អ្នកសម្ភាសដែលអសកម្ម និងមិនចាប់អារម្មណ៍ អាចបណ្តាលឱ្យជនសង្ស័យវាយតម្លៃថា ជាមនុស្សអន់ ហើយបណ្តាលឱ្យពួកគេបដិសេធចំពោះទង្វើរបស់ខ្លួន
- ប្រសិនបើអ្នកសម្ភាសហាក់បីដូចជាមិនខ្វល់ (មិនយកចិត្តទុកដាក់) មិនគប្បី ឬមិនយុត្តិធម៌ចំពោះជនសង្ស័យ ភាគច្រើន ជនសង្ស័យអាចបដិសេធ
- ជនសង្ស័យដែលមើលឃើញអ្នកសម្ភាសខ្វះទំនុកចិត្ត អាចមិនសារភាព
- ការបញ្ជាក់ពីភាពធ្ងន់ធ្ងរនៃបទល្មើសដោយអ្នកសម្ភាស អាចបណ្តាលឱ្យជនសង្ស័យធ្វើការបដិសេធ

- អ្នកសម្ភាសដែលអង្គុយទល់មុខជាមួយជនសង្ស័យភ្លាមៗដោយមិនបង្កើតទំនាក់ទំនងស្និទ្ធស្នាលជាដំបូង ជាញឹកញាប់ធ្វើឱ្យជនសង្ស័យមានលេសបដិសេធទោសកំហុស
- បើជនសង្ស័យដឹងថា អ្នកសម្ភាសមានភស្តុតាងមិនគ្រប់ ពួកគេអាចបដិសេធ
- ជានិច្ចកាល ការចោទប្រកាន់ត្រង់ៗ អាចធ្វើឱ្យជនសង្ស័យបដិសេធ ។

**ឃ. ជនសង្ស័យ**

- ជនសង្ស័យអាចមានអារម្មណ៍ថា ការបដិសេធ ល្អជាងប្រាប់ការពិត
- ជាញឹកញាប់ ជនសង្ស័យដែលបានដឹងពីភាពធ្ងន់ធ្ងរនៃបទល្មើស នឹងបដិសេធ
- ជនសង្ស័យដែលគិតថា ការប្រព្រឹត្តរបស់ខ្លួនមិនមានកំហុស ភាគតិចអាចសារភាព
- ជីវប្រវត្តិ វប្បធម៌ និងជំនឿរបស់ជនសង្ស័យ អាចធ្វើឱ្យពួកគេបដិសេធ
- ជនសង្ស័យដែលស្ថិតក្នុងសភាពមិនប្រក្រតីណាមួយ ក្នុងពេលកំពុងប្រព្រឹត្តបទល្មើស អាចបដិសេធកំហុសរបស់ខ្លួន ពីព្រោះពួកគេប្រហែលជាមិនអាចចងចាំបាន
- ជាទូទៅ ជនសង្ស័យដែលបានប្រព្រឹត្តបទល្មើសតែម្នាក់ឯង ភាគច្រើនអាចបដិសេធ
- នៅពេលជនសង្ស័យប្រឈមនឹងផលវិបាកធ្ងន់ធ្ងរ ពួកគេភាគច្រើនអាចបដិសេធ ។

**៤. ប្រភេទនៃការបដិសេធ**

**ក. ការបដិសេធដាច់អហង្ការ ៖** ចម្លើយដែលជនសង្ស័យបដិសេធទទួលស្គាល់ភាពពិត ។ ការបដិសេធដាច់អហង្ការរបស់ជនសង្ស័យអាចមានទាំងកាយវិការ និងពាក្យសម្តី ៖

- កាយវិការ
  - គ្រវីក្បាល
  - ចងចិញ្ចើម
  - ពេបមាត់
  - ដកដង្ហើមធំ
  - មានទំនាក់ទំនងតាមភ្នែក ។
- ពាក្យសម្តី
  - ជនសង្ស័យអាចរំខានបង្អាក់អ្នកសម្ភាស
  - ជនសង្ស័យផ្តល់ចម្លើយតបដំណាលគ្នាទៅនឹងការសួររបស់អ្នកសម្ភាស
  - ជនសង្ស័យទុកឱ្យអ្នកសម្ភាសស្វែងយល់ថាគាត់មិនបានប្រព្រឹត្តបទល្មើសទេ ។

**ខ. ការបដិសេធដោយពន្យល់ ៖** ការបដិសេធ ដែលជនសង្ស័យកំពុងព្យាយាមបង្វែងជានអ្នកសម្ភាស ដោយធ្វើឱ្យអ្នកសម្ភាសប្រឹងប្រែងអស់សមត្ថភាព ដើម្បីស្វែងរកអំណះអំណាងពិត ។

**៥. ដំណោះស្រាយជាមួយការបដិសេធដាច់អហង្ការ**

- កុំប្រកែកជាមួយជនសង្ស័យអំពីការជាប់ពាក់ព័ន្ធរបស់គាត់ក្នុងបទល្មើស
- ការបដិសេធដាច់អហង្ការមានភាពខុសគ្នាដាច់ស្រឡះពីការបដិសេធបែបពន្យល់
- ប្រើឈ្មោះធម្មតារបស់ជនសង្ស័យ ដើម្បីទាញចំណាប់អារម្មណ៍

- ប្រាប់ជនសង្ស័យថា គាត់នឹងមានឱកាសនិយាយ
- ផ្តល់ដំបូន្មានដល់ជនសង្ស័យថា បើមិននិយាយ ប្រសើរជាងការនិយាយកុហក
- និយាយបង្អាក់ជនសង្ស័យ ហើយលើកឡើងពីការបដិសេធរបស់គាត់
- បង្កើតចំណាប់អារម្មណ៍ចង់ដឹងចង់ឮ
- អ្នកសម្ភាសអាចប្រើសំណួរហ៊ុំព័ទ្ធ ដើម្បីបញ្ឈប់ជនសង្ស័យពីការបដិសេធ ។

### ៦. ដំណោះស្រាយជាមួយការបដិសេធបែបពន្យល់

- អ្នកសម្ភាសគួរតែទទួលយកការបដិសេធបែបពន្យល់ ថាជាការរៀបរាប់ការពិត ហើយចាត់ទុកវាជាហេតុផលមួយផ្សេងទៀតសម្រាប់ឱ្យជនសង្ស័យធ្វើការសារភាព
- អ្នកសម្ភាសត្រូវតែសួរសំណួរម្តងទៀត ដើម្បីគ្រប់គ្រងការសន្ទនា
- អ្នកសម្ភាសអាចពិភាក្សាលើការរៀបរាប់របស់ជនសង្ស័យ ។

## VI. ការវិភាគអាកប្បកិរិយា

### ១. ទិដ្ឋភាពទូទៅ

អ្នកស៊ើបអង្កេតត្រូវតែយល់ដឹងនូវវិធី ៣ ផ្សេងៗគ្នា ដែលយើងធ្វើទំនាក់ទំនង ដើម្បីវាយតម្លៃមុខងារនិមិត្តអាកប្បកិរិយា ៖

- ពាក្យសម្តី ៖ ការជ្រើសរើសពាក្យ និងការរៀបចំពាក្យសម្តី ដើម្បីនិយាយឱ្យគេយល់
- ការប្រើលក្ខណៈសូរនៃភាសា ៖ លក្ខណៈសូរនៃការនិយាយ ប្រាប់ពីអត្ថន័យនៃពាក្យដែលបាននិយាយ
- ភាសាកាយវិការ ៖ របៀបដើរ ឬអង្គុយ ចលនាដៃជើង ការសម្តែងទឹកមុខ និងទំនាក់ទំនងតាមភ្នែក ។

មានគោលការណ៍សំខាន់មួយចំនួន ដែលពាក់ព័ន្ធនឹងការវិភាគអាកប្បកិរិយា និងមិនមានអាកប្បកិរិយាពិសេសច្បាស់លាស់ណាមួយ ក្នុងចំណោមអាកប្បកិរិយាជាច្រើនដែលទាក់ទងនឹងការពិត ឬមិនស្មោះត្រង់នោះទេ ៖

- តាមការសង្កេតអាកប្បកិរិយា ដែលត្រូវបានធ្វើឡើងដោយអ្នកស៊ើបអង្កេត ឆ្លុះបញ្ចាំងទៅនឹងលក្ខណៈរំជួលចិត្តរបស់ជនសង្ស័យ ដែលធ្លាប់កើតមានក្នុងអំឡុងពេលឆ្លើយតប
- ការរំជួលចិត្ត ៖ មានកំហឹង ការជឿទុកចិត្ត ការភ័យខ្លាច និងមានកំហុស
- ការវិភាគអាកប្បកិរិយា ពាក់ព័ន្ធដល់ការធ្វើសេចក្តីសន្និដ្ឋាន អំពីភាពស្មោះត្រង់របស់ជនសង្ស័យដែលបានពឹងផ្អែកលើការសង្កេតអាកប្បកិរិយា
- វិធីវាយតម្លៃ៣ យ៉ាងនៃទំនាក់ទំនង (ពាក្យសម្តី សូរសំឡេង និងកាយវិការ) ក្នុងពេលដំណាលគ្នា ៖
    - នៅពេលវិធីទាក់ទងទាំង៣ ធ្វើឱ្យដឹងដូចគ្នា អ្នកស៊ើបអង្កេតអាចមានទំនុកចិត្តខ្លាំងជឿលើសម្តីរបស់ជនសង្ស័យ
    - ប្រសិនបើមានភាពមិនស៊ីគ្នារវាងវិធីទាក់ទងទាំង៣ អ្នកស៊ើបអង្កេតចាំបាច់ត្រូវតែវាយ

តម្លៃបុព្វហេតុដែលបណ្តាលឱ្យមានភាពមិនស៊ីគ្នាទាំងនោះ ។

- ការវាយតម្លៃអាកប្បកិរិយាស្ងៀមស្ងាត់ និងលក្ខណៈសូរនៃភាសាក្នុងខ្លឹមសារនៃសម្តីរបស់ជនសង្ស័យ៖ នៅពេលធ្វើការវាយតម្លៃអត្ថន័យមិនប្រាកដពីលក្ខណៈរំជួលចិត្តរបស់ជនសង្ស័យ ជានិច្ចកាល លក្ខណៈសូរសំឡេង និងអាកប្បកិរិយាស្ងៀមស្ងាត់ត្រូវតែបានពិចារណានៅក្នុងខ្លឹមសារនៃសម្តី
- វាយតម្លៃប្រភេទណាមួយនៃអាកប្បកិរិយា ដែលកើតឡើងនៅពេលសម្ភាស ៖ ប្រសិនបើការវាយតម្លៃអាកប្បកិរិយា ក្នុងការសម្ភាសលើសពី ៣០ ឬ៤០ នាទី គឺគួរឱ្យទុកចិត្តជាងការវាយតម្លៃអាកប្បកិរិយាក្នុងការសម្ភាសរយៈពេល ៥ នាទី
- ការកំណត់អាកប្បកិរិយាធម្មតារបស់ជនសង្ស័យ ៖ ជនសង្ស័យនីមួយៗ នឹងមានអាកប្បកិរិយាផ្ទាល់ខ្លួន ដូចជា កាយវិការ ពាក្យសម្តី និងកម្រិតទំនាក់ទំនងតាមភ្នែក ។

### ២. ការវាយតម្លៃឥរិយាបថជនសង្ស័យ

ឥរិយាបថជនសង្ស័យអាចត្រូវបានចាត់ទុកជា " ការរំពឹងទុកជាមុនចំពោះស្ថានការណ៍ ឬព្រឹត្តិការណ៍ក្នុងអំឡុងពេលស៊ើបអង្កេតដែលធ្វើឡើងដោយអ្នកសម្ភាស ដោយផ្អែកទៅលើការយល់ដឹងពីកំហុស ឬគ្មានកំហុសរបស់ជនសង្ស័យចំពោះស្ថានការណ៍ដែលស្ថិតនៅក្រោមការស៊ើបអង្កេត "។

- មូលដ្ឋានគ្រឹះនៃការវិភាគអាកប្បកិរិយា គឺជាឥរិយាបថ ឬអត្តចរិតដែលពិបាកយល់របស់ជនសង្ស័យ
- តាមចិត្តសាស្ត្រ ឥរិយាបថមានឥទ្ធិពលលើចំណាប់អារម្មណ៍ ប្រក្បត្យារម្មណ៍ ការយល់ឃើញ និងគំនិតរបស់មនុស្ស ត្រូវបានឆ្លុះបញ្ចាំងឱ្យឃើញនៅក្នុងការរំជួលចិត្ត និងអាកប្បកិរិយារបស់ជនសង្ស័យ
- ពេលដែលជនសង្ស័យយល់ព្រមភ្លាម ឱ្យគេសួរចម្លើយពាក់ព័ន្ធនឹងបញ្ហាដែលស្ថិតនៅក្រោមការស៊ើបអង្កេត គាត់នឹងបង្កើតឥរិយាបថមួយចំពោះការសម្ភាស និងអ្នកស៊ើបអង្កេត ដែលជារឿយៗ ឆ្លុះបញ្ចាំងនូវភាពមានកំហុស ឬគ្មានកំហុសរបស់គាត់ ។

### ៣.ចរិតទូទៅរបស់ជនសង្ស័យស្មោះត្រង់ ឬមិនស្មោះត្រង់

- ការឆ្លើយធម្មតា និងការឆ្លើយដោយប្រុងប្រយ័ត្ន
  - ជាទូទៅ ជនសង្ស័យស្មោះត្រង់ផ្តល់ចម្លើយវែង ដោយនិយាយហូរហែក្នុងពេលសម្ភាស និងផ្តល់ព័ត៌មានដោយស្ម័គ្រចិត្ត
  - ជនសង្ស័យភូតភរអាចផ្តល់ចម្លើយខ្លីដោយមានព័ត៌មានតិចបំផុត ។
- ភាពស្មោះត្រង់ និងភាពមិនស្មោះត្រង់
  - ជនសង្ស័យស្មោះត្រង់សម្តែងដោយចំហនូវលក្ខណៈរំជួលចិត្តសមស្រប
  - ជនសង្ស័យដែលផ្តល់ចម្លើយភូតភរអាចសម្តែងទំនាក់ទំនងគួរសមហួសហេតុ ។
- ការជួយ និងការមិនជួយ
  - ជនសង្ស័យស្មោះត្រង់មានចិត្តអន្ទះអន្ទែង ដូចអ្នកស៊ើបអង្កេតដែរ ដើម្បីចាប់ជនល្មើស
  - ជនសង្ស័យភូតភរមិនជួយដល់ការស៊ើបអង្កេតទេ ។

- ក្ដីបារម្ភ និងការមិនបារម្ភ
  - ជនសង្ស័យស្មោះត្រង់ ឆ្លើយតបដោយក្ដីបារម្ភ
  - ជនសង្ស័យកុហកអាចចូលរួមក្នុងការសម្ភាសដោយស្ងៀមស្ងាត់ ហើយនិយាយតិចតួច ដើម្បីកុំឱ្យគេសង្ស័យនៅក្នុងការស៊ើបអង្កេត ។
- ការសហការ និងការមិនសហការ
  - ជនសង្ស័យស្មោះត្រង់យល់ថា ការសម្ភាសជាមធ្យោបាយមួយ នៃការប្រកាសខ្លួនឯងឱ្យរួចពីការចោទប្រកាន់
  - ជនសង្ស័យកុហកអាចផ្ដល់ការដោះសារមិនគួរឱ្យជឿ ដើម្បីបញ្ជាក់ពីបុព្វហេតុដែលគាត់មិនអាចឱ្យគេសម្ភាសបាន ។

### ៤. អាកប្បកិរិយាទូទៅរបស់ជនសង្ស័យស្មោះត្រង់ និងមិនស្មោះត្រង់

#### ក. អាកប្បកិរិយាស្រគត់ស្រគំ

ការធ្វើអាកប្បកិរិយាស្រគត់ស្រគំនៅពេលដំបូងក្នុងការចាប់ផ្ដើមសម្ភាស គឺជាអាកប្បកិរិយាទូទៅចំពោះជនសង្ស័យមានកំហុស និងគ្មានកំហុស ។ អ្នកស៊ើបអង្កេតដែលមានការអត់ធ្មត់ និងយល់ដឹងស៊ីជម្រៅ អាចធ្វើឲ្យជនសង្ស័យស្មោះត្រង់ដែលមានអាកប្បកិរិយាស្រគត់ស្រគំ ព្រួយបារម្ភតិចតួច ហើយឆ្លើយតាមធម្មតា ។

#### ខ. អាកប្បកិរិយាភ័យខ្លាច

ជារឿងធម្មតាទេចំពោះជនសង្ស័យគ្មានកំហុស និងមានកំហុស បង្ហាញឱ្យឃើញនូវសញ្ញាភ័យខ្លាចនៅពេលត្រូវបានចោទសួរដោយមន្ត្រីអនុវត្តច្បាប់ ។ មនុស្សគ្មានកំហុសអាចភ័យខ្លាចដែលត្រូវគេយល់ខុសថាខ្លួនមានកំហុស ។ តាមការជាក់ស្ដែង ជនសង្ស័យមានកំហុសសម្ដែងឱ្យឃើញនូវអាកប្បកិរិយាភ័យខ្លាច ព្រោះគាត់ខ្លាចគេរកឃើញកំហុសរបស់គាត់ ។

#### គ. ការខឹងសម្បា

ជារឿងធម្មតាទេចំពោះជនសង្ស័យគ្មានកំហុស សម្ដែងចេញនូវភាពតូចចិត្តដោយសារការយល់ថា គាត់ត្រូវបានចាត់ទុកដូចជនសង្ស័យមានកំហុសពិតប្រាកដដែរ ។ ក្នុងស្ថានភាពបែបនេះ ជនសង្ស័យគ្មានកំហុសអាចក្រេវក្រោធ ដោយសារខ្លួនត្រូវបានគេសង្ស័យថា បានប្រព្រឹត្តបទល្មើស ។

តាមធម្មតា ជនសង្ស័យគ្មានកំហុសមានការអត់ធ្មត់ មិនខឹងសម្បាក្នុងពេលសម្ភាស តែផ្ទុយទៅវិញ ជនសង្ស័យមានកំហុសធ្វើពុតជាខឹង ប៉ុន្តែជាទូទៅមិនបន្តអារម្មណ៍ខឹងសម្បាក្នុងពេលសម្ភាសទេ ។

#### ឃ. ភាពអស់សង្ឃឹម និងការសុខចិត្តទទួលយក

ជនសង្ស័យទោះបីមានកំហុស ឬគ្មានកំហុសក៏ដោយ អាចបង្ហាញឱ្យឃើញនូវសញ្ញានៃភាពអស់សង្ឃឹម និងសុខចិត្តទទួលយក ពីព្រោះជនសង្ស័យមានកំហុសអាចមានអារម្មណ៍ថា ជីវិតខ្លួនត្រូវចប់សព្វគ្រប់ហើយ ជនសង្ស័យគ្មានកំហុសអាចមានអារម្មណ៍ថាខ្លួនមិនត្រូវបានគេជឿថាគ្មានកំហុសទេ ។

### ង. ភាពតានតឹងចិត្ត

មានកត្តា ៣ ដែលបណ្ដាលមានជំងឺតានតឹងចិត្ត ដែលពាក់ព័ន្ធនឹងស្ថានភាពសម្ភាសរបស់នគរបាល ទោះបីជាជនសង្ស័យនោះមានកំហុស ឬគ្មានកំហុសក៏ដោយ ៖

- ភាពតានតឹងចិត្តកើតឡើងដោយសារស្ថានភាពផ្លូវកាយនៅអង្គភាពនគរបាល
- ភាពតានតឹងចិត្តកើតឡើងដោយការបង្ខាំងទុក និងការដាក់ឱ្យនៅឯកា
- ភាពតានតឹងចិត្តកើតឡើងដោយសារការចុះចូលរបស់ជនសង្ស័យចំពោះអាជ្ញាធរ
- ចំណាត់ថ្នាក់នីមួយៗនៃកត្តាដែលបណ្ដាលឱ្យមានភាពតានតឹងចិត្តទាំងនេះ អាចបង្កឱ្យមានការថប់បារម្ភខ្លាំង ការភ័យខ្លាច និងមានការរំភើបខ្លាំងខាងផ្លូវចិត្តរបស់ជនសង្ស័យ
- ជនសង្ស័យអាចភ័យខ្លាចដោយសារតែភាពមិនប្រាកដ និងកង្វះខាតការគ្រប់គ្រងខ្លួនឯងពេលនៅអង្គភាពនគរបាល
- ជនសង្ស័យមិនអាចផ្លាស់ប្ដូរទីកន្លែងអង្គុយដោយសេរី ទូរស័ព្ទ និងជួបអ្នកមកសួរសុខទុក្ខនៅក្នុងអង្គភាពនគរបាល ។

### ៥. ការវាយតម្លៃអាកប្បកិរិយាប្រើពាក្យសម្ដី

ក្នុងអំឡុងពេលសម្ភាសផ្ទួផ្ទង ការជ្រួលច្រាល់ក្នុងចិត្តរបស់ជនសង្ស័យ និងនិមិត្តអាកប្បកិរិយាជាច្រើនត្រូវបានបញ្ចេញឱ្យឃើញ ដោយជនសង្ស័យមិនស្មោះត្រង់បង្ហាញនូវការខិតខំប្រឹងប្រែងដែលដឹងដោយអារម្មណ៍ ឬបានដឹងជាមុន ដើម្បីកាត់បន្ថយការជ្រួលច្រាលក្នុងចិត្តរបស់ខ្លួន ។

ជនសង្ស័យស្មោះត្រង់ អាចបដិសេធទាំងស្រុង ប៉ុន្តែជនសង្ស័យកុតករអាចផ្ដល់ការបដិសេធនូវចំណុចខ្លះ ។ ជាញឹកញាប់ ជនសង្ស័យស្មោះត្រង់ នឹងប្រើប្រាស់ឃ្លាដូចខាងក្រោម ៖

- ខ្ញុំប្រាកដថា ខ្ញុំមិនដែលបានរំលោភក្មេងស្រីនោះទេ...
- ខ្ញុំប្រាកដថា គ្មានមធ្យោបាយណា...

ជនសង្ស័យស្មោះត្រង់ ផ្ដល់ចម្លើយជាក់លាក់ទុកចិត្តបាន រីឯជនសង្ស័យកុតករអាចផ្ដល់ចម្លើយដែលមិនជាក់លាក់ ។ ជនសង្ស័យមិនស្មោះត្រង់ អាចប្រើឃ្លាដើម្បីធ្វើឱ្យចម្លើយពិតដូចជា ៖

- ជាធម្មតា...
- ជាទូទៅ...
- តាមទម្លាប់...
- ខ្ញុំចូលចិត្ត...
- កម្រ...
- មិនញឹកញាប់...
- មិនពិតប្រាកដ...
- ភាគច្រើន... ។

ការបដិសេធកុតករ អាចត្រូវបានបញ្ជាក់ឡើងវិញ ដើម្បីធ្វើឱ្យគេស្ដាប់ទៅកាន់តែជឿជាក់ថែមទៀត ។ ជាញឹកញាប់ ឃ្លាខាងក្រោមត្រូវបានប្រើដើម្បីបញ្ជាក់ឡើងវិញដល់ការរៀបរាប់កុតករ ៖

- សូមឱ្យព្រះជាម្ចាស់ធ្វើជាសាក្សី...
- ខ្ញុំសូមស្បថ...
- ខ្ញុំសូមស្បថចំពោះផ្នូរថា...
- និយាយដោយស្មោះ... ។

**៦. ការវាយតម្លៃអាកប្បកិរិយាស្ងៀមស្ងាត់**

នៅពេលផ្តល់ចម្លើយកុហក អ្នកនិយាយកុហក់មានការថប់បារម្ភ ។ ចិត្ត និងខ្លួនប្រាណរបស់ពួកគេធ្វើការរួមគ្នាដើម្បីបន្ធូរក្តីបារម្ភនេះ ។ តាមផ្លូវកាយ មានមធ្យោបាយ៣ ក្នុងការឆ្លើយតបទៅនឹងស្ថានភាពគំរាមកំហែង ៖

**ក. ការតបត ឬការគេចចេញ ៖** ចម្លើយតបដោយការវាយប្រហារ ឬការដើរចេញគឺជាចម្លើយតបកើតឡើងដោយស្វ័យប្រវត្តិពីកំណើត (សភាវចម្លើយ) របស់មនុស្ស ដែលត្រៀមរៀបចំខ្លួនប្រាណដើម្បី " តបត " ឬ " ដើរគេចចេញ " ពីគ្រោះថ្នាក់ដែលដឹងដោយអារម្មណ៍ ដូចជា ការវាយប្រហារ ការឈឺចាប់ ឬការគំរាមកំហែង ដើម្បីមានជីវិតរស់នៅ ។

**ខ. ភាពនៅស្ងៀម៖** ជនសង្ស័យអាចរង់ចាំរហូតដល់បានធូរស្បើយពីភាពតានតឹងក្នុងចិត្ត ។

**៧. កាយវិការ**

**ក. សញ្ញា ៖** អាកប្បកិរិយាមិននិយាយស្តី បញ្ជាក់ពីទំនាក់ទំនងទាំងស្រុង នៅក្នុងអារម្មណ៍របស់ជនសង្ស័យ ៖

- មេដៃឡើងលើ មានន័យថា ល្អ និងមានន័យថា សុំជិះឡានដោយសារនៅតាមផ្លូវ
- មេដៃផ្កាប់ចុះក្រោមមានន័យថា អាក្រក់ ឬមិនសូវល្អ ។

**ខ. ការចង្អុលបង្ហាញ ៖** អាកប្បកិរិយាមិននិយាយស្តី ដែលជួយឱ្យអ្នកស្តាប់យល់ដឹងពីទំនាក់ទំនងខាងការនិយាយស្តីកាន់តែច្បាស់ ៖

- កាយវិការដៃបង្ហាញនូវទម្ងន់សម្តីរបស់អ្នកនិយាយ
- ការសម្តែងទឹកមុខមិនយល់ព្រម ហាក់ដូចជាកំពុងបរិភោគអ្វីមួយដែលមិនឆ្ងាញ់
- គោះតុដោយប្រើកណ្តាប់ដៃក្នុងពេលនិយាយដោយខឹងសម្បា ។

**គ. ការសម្របខ្លួនតាម ៖** អាកប្បកិរិយាកាយវិការដែលបង្វែងដាន គ្មានគោលបំណងជួយដល់ទំនាក់ទំនងពាក្យសម្តីទេ ជាញឹកញាប់ ធ្វើឱ្យទំនាក់ទំនងអន់ថយ ៖

- ការត្រដុសដៃ
- ការអង្អែល
- ការច្បិចយក
- ការគក់ច្របាច់
- ការស្ទាបប៉ះ ។

**ឃ. ឥរិយាបថឈរ ឬអង្គុយ ៖** ឥរិយាបថឈរ ឬអង្គុយរបស់ជនសង្ស័យ បង្ហាញឱ្យដឹងពីការជាប់ទាក់ទងខាងការរំជួលចិត្ត ទំនុកចិត្ត និងកម្រិតចំណាប់អារម្មណ៍ក្នុងការសម្ភាស ។

- ជនសង្ស័យស្មោះត្រង់អាចនឹង ៖
  - អង្គុយត្រង់នៅលើកៅអី
  - អង្គុយទ្រេតទៅមុខទោរទៅរកអ្នកសម្ភាស ដើម្បីបញ្ជាក់ពីអំណះអំណាង
  - អង្គុយហាក់ដូចជាមានអារម្មណ៍ធូរស្បើយតាមធម្មតា
  - សម្តែងចេញនូវជំហរអង្គុយច្រើនបែបក្នុងការសន្ទនា ។
- ជនសង្ស័យភូតភរអាចនឹង ៖
  - អង្គុយហាក់ដូចជាគ្មានកម្លាំង (ដូចអត់ឆ្អឹង)
  - អង្គុយធ្វើព្រងើយហាក់ដូចជាមិនស្និទ្ធស្នាល
  - អង្គុយងាកមុខចេញពីអ្នកសម្ភាស
  - អង្គុយគងអន្ទាក់ខ្លា និងក្រពាត់ដៃក្នុងជំហរការពារខ្លួន ។

**ង. ប្រអប់ដៃ ៖** ក្នុងអំឡុងពេលឆ្លើយតប ប្រអប់ដៃរបស់ជនសង្ស័យអាចនៅស្ងៀម ធ្វើចលនាចេញពីដងខ្លួន ហើយធ្វើកាយវិការ ឬអាចមានទំនាក់ទំនងជាមួយផ្នែកណាមួយនៃដងខ្លួន ។

- កាយវិការសម្អាត ដូចជា បេះកម្ទេចពីសម្លៀកបំពាក់ ពិនិត្យក្រចកដៃ តម្រង់សក់ ឬទាញស្រោមជើងឡើងលើ មិនមានអត្ថន័យទេ ប៉ុន្តែនៅពេលកាយវិការសម្អាតនេះស្តែងឡើងស្រប ជាមួយនឹងចម្លើយតបខាងពាក្យសម្តី ការកំណត់ពេលវេលានៃអាកប្បកិរិយាអាចធ្វើឱ្យការបញ្ចេញកាយវិការនេះក្លាយជាកត្តាសំខាន់
- កាយវិការខ្លួនប្រាណ ដូចជា ការអេះ ត្រដុស ឬគោះម្រាមដៃលើតុ អាចបង្ហាញថាជនសង្ស័យមិនមានអារម្មណ៍ស្រួលជាមួយការឆ្លើយតប ឬសំណួររបស់អ្នកសម្ភាស
- កាយវិការទម្រ ដូចជា យកដៃច្រត់ចង្កា ឬច្រត់ក្បាល អាចបង្ហាញនូវឯករាជ្យភាពរបស់ជនសង្ស័យក្នុងពេលសម្ភាស ។

**ច. ប្រអប់ជើង**

- ជើងនៅតែកម្រើកក្នុងអំឡុងពេលសម្ភាសមានន័យថា ជនសង្ស័យមានការភ័យខ្លាច ហើយគួរតែមិនត្រូវបានចាត់ទុកជាកាយវិការភូតភរទេ
- ឥរិយាបថគោះជើងបណ្តើរឆ្លើយបណ្តើរ អាចជាសញ្ញាភូតភរ
- ការអង្គុយផ្លាស់ជើងគងអន្ទាក់ខ្លាទៅវិញទៅមក ជាការបង្ហាញដ៏ច្បាស់ពីការភូតភរពេលដែលកាយវិការនេះកើតភ្លាម ឬកើតឡើងស្របទៅនឹងការឆ្លើយតបពាក្យសម្តីរបស់ជនសង្ស័យ ។

**ឆ. ការសម្តែងទឹកមុខ និងទំនាក់ទំនងតាមភ្នែក ៖** ភាពប្រែប្រួលនៃការសម្តែងទឹកមុខអាចបណ្តាលមកពីការភ័យខ្លាចពីការស៊ើបអង្កេតភាពមិនពិត ឬដឹងពីការភូតភរដែលត្រូវលាតត្រដាង ។ មគ្គុទេសក៏ ៥យ៉ាង គួរតែត្រូវបានពិចារណានៅពេលប្រើទំនាក់ទំនងតាមភ្នែក ដើម្បីវាយតម្លៃថា តើជនសង្ស័យនោះនិយាយពិត ឬកុហក ៖

- ជាទូទៅ ជនសង្ស័យដែលមិនប្រើភ្នែកមើលឱ្យចំត្រង់ គឺកំពុងលាក់បាំងព័ត៌មានពិត
- មិនថាក្នុងកាលៈទេសៈណាទេ អ្នកស៊ើបអង្កេតគួរតែប្រឹងប្រែងឱ្យអស់ពីសមត្ថភាព

ដើម្បីធ្វើឱ្យជនសង្ស័យមើលឱ្យចំភ្នែករបស់គាត់

- ក្រៅពីការសំឡឹងមើលជនសង្ស័យ អ្នកស៊ើបអង្កេតគួរតែសង្កេតមើលភ្នែករបស់ជនសង្ស័យផងដែរ និងសង្កេតមើលនិមិត្តអាកប្បកិរិយាដទៃទៀត ដើម្បីជៀសវាងធ្វើឱ្យជនសង្ស័យមានអារម្មណ៍មិនសុខស្រួល
- ជនសង្ស័យគួរតែមិនត្រូវបានអនុញ្ញាតឱ្យពាក់វ៉ែនតាខ្មៅទេ ក្នុងអំឡុងពេលសម្ភាសលុះត្រាតែមានហេតុផលវេជ្ជសាស្ត្រតម្រូវឱ្យប្រើក្នុងបន្ទប់
- និមិត្តអាកប្បកិរិយារបស់ជនសង្ស័យ ត្រូវបានវាយតម្លៃ ដោយយោងតាមមគ្គុទេសក៏ទូទៅដូចខាងក្រោម ៖
    - អង្កេតមើលការបង្ហៃងដាននៃអាកប្បកិរិយាធម្មតារបស់ជនសង្ស័យ ។ អាកប្បកិរិយាធម្មតាអាចត្រូវបានកំណត់ដោយការស៊ើបអង្កេតប្រវត្តិរូប ឬសួរជនសង្ស័យក្នុងពេលសម្ភាស
    - វាយតម្លៃការសម្តែងអាកប្បកិរិយាទាំងអស់ ដោយផ្អែកលើមូលដ្ឋានថាអាកប្បកិរិយាបានកើតឡើងនៅពេលណា ហើយញឹកញាប់ដែរឬទេ
    - ដើម្បីធ្វើជាឧបករណ៍ចង្អុលបង្ហាញការពិត ឬការភូតភរដែលគួរឱ្យជឿបាន ការផ្លាស់ប្តូរខាងអាកប្បកិរិយា គួរតែកើតឡើងភ្លាមៗក្នុងពេលឆ្លើយតបទៅនឹងសំណួរ ឬកើតឡើងដំណាលគ្នានឹងចម្លើយរបស់ជនសង្ស័យ ។

**ជ. ភាពស្មោះត្រង់ (ការនិយាយប្រាប់ការពិត)**

- មានអារម្មណ៍ធូរស្រាលក្នុងខ្លួន និងមានជំនឿជឿជាក់ប្រាកដ
- មើលមុខអ្នកសម្ភាសត្រង់ៗ ឬមើលចំតែម្តង
- ប្រើប្រាស់ការស្រាយបំភ្លឺ
- ការដាក់ជើង និងប្រអប់ជើងតាមធម្មតា ឬនៅស្ងៀម ។

**ឈ. ការភូតភរ (ការនិយាយមិនពិត)**

- មានអារម្មណ៍តានតឹង និងមានលក្ខណៈការពារខ្លួន
- ការធ្វើកាយវិការដងខ្លួនបែបគេចវេស
- ប្រើប្រាស់ការសម្របតាម
- អារម្មណ៍តានតឹង និយាយច្រំដែល ជើង និងប្រអប់ជើងកម្រើកមិនឈប់ ។

| **កាយវិការ** | **បំណកស្រាយ** |
|---|---|
| ក្បាល និង មុខ | |
| • បន្ទាបចិញ្ចើម ឬចងចិញ្ចើមចុះក្រោម<br>• លើកចិញ្ចើម ឬញាក់ចិញ្ចើមឡើងលើ<br>• បើកភ្នែកធំៗ<br>• ដោះវ៉ែនតា | ➢ ការប្រមូលអារម្មណ៍ ឬខឹងសម្បា<br>➢ ភ្ញាក់ផ្អើល ការគិតសំណួរទុកជាមុន<br>➢ លើកកម្ពស់ការចាប់អារម្មណ៍ ការភ័យខ្លាច<br>➢ ការដកខ្លួនចេញ |

| | |
|---|---|
| • យកម្រាមដៃបិទរន្ធច្រមុះ | ➢ ការមើលងាយ មិនស្តាប់បង្គាប់ មិនជឿ |
| • យកម្រាមដៃចង្អុលដាក់ស្របនឹងខ្នង់ច្រមុះ | ➢ មន្ទិលសង្ស័យ |
| • បើកមាត់ចំហ | ➢ ធុញទ្រាន់ មិនប្រាកដខ្លួនឯង |
| • រន្ធចុងច្រមុះរីកធំ | ➢ ស្អប់ខ្ពើម និងរំលោភបំពាន |
| • ថ្ពាល់ផតចូលក្នុង | ➢ មិនយល់ស្រប រិះគន់អ្នកដទៃ |
| • ខាំបបូរមាត់ | ➢ ការបន្ទាបខ្លួនឯង |
| • បន្ទាបចង្កា និងសំឡឹងចុះក្រោម | ➢ មានភាពរុញរាក្នុងចិត្ត ភាពខ្មាសអៀន |
| • ច្បិចមុខ ឬខាំក្រចក | ➢ មិនប្រាកដ មានអារម្មណ៍មិនល្អអំពីខ្លួនឯង |
| • យកអណ្តាតលិតធ្មេញ ឬមាត់ | ➢ បញ្ចេញកាយវិការខាងការរួមភេទ |
| ដៃ និងប្រអប់ដៃ | |
| • ម្រាមដៃដាក់ ឬប៉ះកអាវ | ➢ ប្រាថ្នាចង់គេចចេញ |
| • ប្រអប់ដៃដាក់លើបេះដូងឬចំកណ្តាលទ្រូង | ➢ ភាពស្មោះត្រង់ |
| • យកម្រាមដៃជូតក្រោមច្រមុះ | ➢ ចរិតឈ្លានពាន រំលោភបំពាន |
| • គោះម្រាមដៃខ្លាំង ឬបន្តើរស្រាលៗ | ➢ គ្មានអំណត់ បង្កភាពជម្លោះ ភាពខកចិត្ត |
| • ផ្តុំម្រាមដៃចង្អុលចូលគ្នា | ➢ បង្ហាញនូវឧត្តមភាព |
| • ដៃកាន់ដាក់ខាងក្រោយក្បាល | ➢ ភាពគួរជឿទុកចិត្ត ឧត្តមភាព |
| • បុរសយកម្រាមដៃជ្រោងសក់ | ➢ ឧត្តមភាព |
| • លេងសក់ | ➢ ការចែចង់ម្ញិម្ញ៉ក់ |
| • ដាក់ដៃគងលើភ្លៅ | ➢ ការពារប្រឆាំងការជំទាស់ |
| • ការអេះ និងច្បិចខ្លួនឯង | ➢ ការរំលោភបំពាន |
| • ស្ត្រីលាតត្រដាងបាតដៃទៅកាន់បុរស | ➢ ការចែចង់ ម្ញិម្ញ៉ក់ |
| • ត្រដុសវត្ថុអ្វីមួយ | ➢ ការធ្វើឱ្យមានអារម្មណ៍ ទំនុកចិត្តឡើងវិញ |
| • ក្តោបដៃគោះ (តុ...) ឬលើកកណ្តាប់ដៃ | ➢ ការរំលោភបំពាន |
| • យកដៃគ្របមុខ | ➢ ការពារខ្លួន |
| • ការអង្អែល ការបោសអង្អែលថើបខ្លួនឯង | ➢ ត្រេកត្រអាលនឹងកាមគុណ |
| • យកដៃគ្របភ្នែក | ➢ ភ័យខ្លាច ឬមានការខ្មាសអៀន |
| ជើង និង ប្រអប់ជើង | |
| • គងអន្ទាក់ខ្លា ឬអោបដៃដាក់ពីមុខ | ➢ ភ័យខ្លាចការទាក់ទងជាមួយមនុស្ស |
| • គោះជើង | ➢ ក្តៅក្រហាយ ការរំខាន ឬការរំលោភបំពាន |
| • យោលជើងចុះឡើងដូចទឹករលកតិចៗ | ➢ ខឹង |
| • ពត់បត់ម្រាមជើងឡើងចុះៗ | ➢ ចំណាប់អារម្មណ៍ខាងផ្លូវភេទ |
| • ចលនាជើងរសាប់រសល់នៅមិនស្ងៀម | ➢ ក្តីបារម្ភ |

| ខ្លួនប្រាណ ឬ ដងខ្លួន | |
|---|---|
| • ទម្រេតទៅមុខ | ➢ ការចាប់អារម្មណ៍ ការទទួលយក |
| • ទម្រេតទៅក្រោយ | ➢ ខ្វះចំណាប់អារម្មណ៍ មិនទទួលយក |
| • ស្មាទម្លាក់ចុះក្រោម ឬធ្លាក់ចុះ | ➢ នឿយហត់ ទុក្ខព្រួយ ដកខ្លួនថយ |
| • ស្មាក្តោបណែន ឬស្មានៅត្រង់ | ➢ ជំហរវាយប្រហារឈ្លានពាន |
| • ស្មាញាក់ ឬការញាក់ស្មា | ➢ វាមិនមែនជាកំហុសរបស់ខ្ញុំទេ |
| • ដោះឡេវសម្លៀកបំពាក់ | ➢ សហការ យល់ព្រម ទាក់ទាញខាងផ្លូវភេទ |
| • បិទឡេវសម្លៀកបំពាក់ | ➢ បដិសេធ ដកខ្លួន មិនចាប់អារម្មណ៍ផ្លូវភេទ |
| • ងាកខ្លួនចេញ | ➢ ការបដិសេធ |
| • ងាកខ្លួនទៅរក ឬមករក | ➢ ការទទួលយក |

## VII. មូលហេតុដែលបុគ្គលឆ្លើយសារភាព

ហេតុផលរួមច្រើនបំផុតសម្រាប់ចម្លើយសារភាព គឺថាជនសង្ស័យគិតថា កំហុសរបស់ខ្លួនត្រូវបានគេដឹងរួចហើយ ។ នៅពេលពួកគេជឿថា កំហុសរបស់ខ្លួនអាចត្រូវបានបង្ហាញថាពិត ការតស៊ូរបស់ពួកគេត្រូវបានកាត់បន្ថយច្រើនបំផុត ។ ប្រសិនបើពួកគេមានអារម្មណ៍ថា ខ្លួនត្រូវបានគេជឿថាមានកំហុស នោះខ្លួននឹងទទួលថាពិតពីបទល្មើស ប៉ុន្តែពន្យល់សមហេតុសមផលចំពោះការប្រព្រឹត្តិបទល្មើស ។ ជនសង្ស័យអាចសារភាព ពីព្រោះគាត់មានអារម្មណ៍ថា មានកំហុសចំពោះការប្រព្រឹត្តិបទល្មើស ហើយជនល្មើសអាជីព និងសមាជិកក្រុមជនពាល អាចសារភាពដើម្បីបង្កើនកេរ្តិ៍ឈ្មោះជាមួយបក្សពួករបស់ខ្លួន ។

ជួនកាល ជនសង្ស័យសារភាពកំហុស ដោយសារតែជំងឺផ្លូវចិត្តម្យ៉ាងដែលបង្កើតដោយអ័រម៉ូនជំរុញឱ្យឆ្លើយតបទៅនឹងភាពតានតឹងចិត្ត ភ្ជាប់ជាមួយកំហុស ដែលបណ្តាលឱ្យមានការឆ្លើយទទួលថាពិតដោយឯកឯង ។ ការជឿទុកចិត្ត ការធ្វើឫកពារក្លាហាន ឬតម្រូវការចាំបាច់ ដើម្បីប្រាប់ភាពពាក់ព័ន្ធរឿងសម្ងាត់ទាំងឡាយ ឈានទៅដល់ការទទួលថាពិត ។ ចម្លើយសារភាពខ្លះត្រូវបានផ្តល់ដោយជនសង្ស័យដែលមានកំហុស ដើម្បីធ្វើឱ្យអ្នកស៊ើបអង្កេតមិនអាចរកឃើញ ឬចោទសួរជនសង្ស័យអំពីបទល្មើសដទៃទៀតដែលពួកគេបានប្រព្រឹត្ត ។

ជនសង្ស័យខ្លះអាចសារភាព ដើម្បីដោះស្រាយបញ្ហា និងបន្តជីវិតបានតទៅទៀត និងពិភាក្សាដោយសេរី នូវការជាប់ពាក់ព័ន្ធរបស់ខ្លួន ក្នុងបទល្មើស ពីព្រោះពួកគេមិនជឿថា ខ្លួនបានប្រព្រឹត្តអំពើណាមួយខុសឆ្គងទេ ហើយជនសង្ស័យខ្លះអាចសារភាពផងដែរ ពីព្រោះពួកគេទទួលស្គាល់ថា ខ្លួនមិនអាចគ្រប់គ្រងខ្លួនឯងបាន ក្នុងពេលប្រព្រឹត្តបទល្មើស ។

### ១. គំរូ REID នៃចម្លើយសារភាព

គំរូនេះបកស្រាយការសម្ភាសផ្ទុផ្ទងជាការភូតកុហកតាមចិត្តសាស្ត្រ ។ ប្រភេទផលវិបាកពីរដែលត្រូវបានរកឃើញក្នុងការភូតកុហក គឺ ៖

**ក. ផលវិបាកពិត ៖** ការបាត់បង់សិទ្ធិសេរីភាព ការទទួលពិន័យ ឬទណ្ឌកម្មខាងហិរញ្ញវត្ថុ ។

**ខ. ផលវិបាកផ្ទាល់ខ្លួន ៖** ការឱ្យតម្លៃទាបចំពោះខ្លួនឯង និងសេចក្តីសុចរិតត្រូវគេបំផ្លាញ ។

យោងតាមគំរូខាងលើនេះ ជនសង្ស័យសារភាពនៅពេលគាត់បានដឹងក្នុងចិត្តថា ផលវិបាកនៃការសារភាពធ្វើឱ្យគាត់ចង់បានជាងការព្រួយបារម្ភដែលកើតចេញពីការភូតភរ ។ តាមចិត្តសាស្ត្រ អ្នកសម្ភាសអាចសម្របសម្រួលផលវិបាកដែលបានដឹងក្នុងចិត្តនោះដោយយោងទៅតាមគំរូ REID ។ ផ្អែកលើគំរូនេះ មានលក្ខណៈវិនិច្ឆ័យសំខាន់៤ សម្រាប់ផ្លាស់ប្តូរក្តីសង្ឃឹម និងជំនឿរបស់ជនសង្ស័យ ៖

- ព័ត៌មានដែលផ្តល់ដោយអ្នកសម្ភាសត្រូវតែដឹងក្នុងចិត្តថា អាចគួរជឿទុកចិត្តបាន ។ ការធ្វើបែបនេះ ត្រូវបានធ្វើឱ្យមានពីភាពស្មោះត្រង់ និងភាពជឿទុកចិត្ត
- អ្នកសម្ភាសមានការយល់ដឹងជ្រៅជ្រះនៅក្នុងឥរិយាបថ និងភាពទន់ខ្សោយរបស់ជនសង្ស័យ ។ វាមានសារៈសំខាន់យ៉ាងពិសេស ដើម្បីវាយតម្លៃនូវអ្វីដែលជាផលវិបាកដែលជនសង្ស័យគិតថា គាត់កំពុងគេចវេសដោយការបដិសេធ
- ជនសង្ស័យចាំបាច់ទទួលយកអនុសាសន៍រួមពីអ្នកសម្ភាស
- អ្នកសម្ភាសត្រូវសង្កេតយ៉ាងខ្ជាប់ខ្ជួនថា តើជនសង្ស័យទទួល ឬមិនទទួលនូវអនុសាសន៍ខ្លីៗដែលបានស្នើឡើង និងសង្កេតមើលផងដែរ ថាតើជនសង្ស័យបង្កើនក្តីព្រួយបារម្ភថែមទៀតឬអត់ និងថាតើមានពេលវេលាសមរម្យ ដើម្បីបង្ហាញនូវជម្រើសផ្សេងដែរឬទេ ។

យោងតាមគំរូខាងលើនេះ ជោគជ័យនៃការសម្ភាសផ្តួងពឹងផ្អែកលើវិសាលភាពដែលអ្នកសម្ភាសទទួលបានដោយជោគជ័យក្នុងការកំណត់ចំណុចខ្សោយខាងផ្លូវចិត្តរបស់ជនសង្ស័យ ដើម្បីកែប្រែជំនឿរបស់ពួកគេ និងប្រកុក្យត្យារម្មណ៍លើផលវិបាកនៃការសារភាព ។

**២. គំរូធ្វើការសម្រេចចិត្តឆ្លើយសារភាព**

Hilgendorf និង Irving ជាអ្នកនិពន្ធ និងអ្នកស្រាវជ្រាវជនជាតិអូស្ត្រាលី (១៩៨១) បានពឹងផ្អែកគំរូនេះដោយឈរលើអំណះអំណាងដែលថា នៅពេលដែលជនសង្ស័យត្រូវបានសម្ភាស ពួកគេបានចូលរួមក្នុងដំណើរការសម្រេចចិត្តដែលតម្រូវឱ្យមាន និងភាពស្មុគស្មាញ ។ ដំណើរការសម្រេចចិត្តទាំងនេះ រួមមាន ៖

- តើនិយាយ ឬនៅស្ងៀមស្ងាត់?
- តើទទួលស្គាល់នូវការធ្វើពិរុទ្ធកម្មខ្លួនឯង ឬក៏អត់?
- តើប្រាប់ការពិត ឬក៏អត់?
- តើប្រាប់ការពិតទាំងស្រុង ឬផ្នែកណាមួយនៃការពិត?
- ឆ្លើយសំណួររបស់អ្នកសម្ភាសយ៉ាងដូចម្តេច ។

Hilgendorf និង Irving អះអាងថា ការសម្រេចចិត្តត្រូវបានកំណត់ ដូចខាងក្រោម ៖

- ប្រក្យត្យារម្មណ៍នៃដំណើរវិវត្តរបស់សកម្មភាព
- ប្រក្យត្យារម្មណ៍ ដែលពាក់ព័ន្ធនឹងលទ្ធភាព អាចកើតមានផលវិបាកផ្សេងៗនៃការវិវត្តរបស់សកម្មភាព
- តម្លៃ ឬការទទួលបានអត្ថប្រយោជន៍ដែលទាក់ទងនឹងដំណើរវិវត្តនៃសកម្មភាព ។

## VIII. បច្ចេកទេសសម្ភាសផ្ទួផ្ទងរួមបញ្ចូលគ្នា

បច្ចេកទេសសម្ភាសផ្ទួផ្ទងរួមបញ្ចូលគ្នា ធ្វើឱ្យសមត្ថភាពរបស់អ្នកសម្ភាស ឡើងដល់ចំណុចអតិបរមាដើម្បីទទួលបានចម្លើយសារភាពពីជនសង្ស័យដែលមានកំហុស ។ បច្ចេកទេសនេះផ្តោតលើកត្តាសំខាន់ ១០ ដែលត្រូវបានណែនាំឱ្យប្រើក្នុងការសន្ទនាដដែលៗពេលធ្វើសម្ភាស ៖

**១. ធ្វើអំណះអំណាងដោយបន្ទំមួយដែលបញ្ជាក់ថាជនសង្ស័យពិតជាមានកំហុស**

- អ្នកសម្ភាសត្រូវតែចាប់ផ្តើម ដោយមានកំណត់ហេតុជាក់លាក់ ពីកំហុសរបស់ជនសង្ស័យ ដោយបញ្ជាក់ប្រាប់គាត់ថា ខ្លួនជឿពិតប្រាកដថា គាត់(ជនសង្ស័យបានប្រព្រឹត្តបទល្មើស
- ជាធម្មតា ជនសង្ស័យស្មោះត្រង់និយាយកាត់សម្តី ហើយចាប់ផ្តើមជំទាស់ ។ ចំណែកឯជនសង្ស័យមិនស្មោះត្រង់នៅតែរក្សាភាពស្ងៀមស្ងាត់មិននិយាយស្តី ឬប្រឆាំងតប ។

**២. មិនត្រូវអនុញ្ញាតឱ្យជនសង្ស័យឆ្លើយបដិសេធ**

នៅពេលជនសង្ស័យចាប់ផ្តើមបដិសេធការជាប់ពាក់ព័ន្ធក្នុងបទល្មើស អ្នកសម្ភាសត្រូវតែបញ្ឈប់ការបដិសេធ ដោយនិយាយលើកដាក់សំឡេងខ្លាំងៗដាក់គាត់ ឬលើកដៃរបស់គាត់ដើម្បីកុំឱ្យជនសង្ស័យនិយាយ ។

**៣. ផ្តល់លទ្ធភាពជាបន្តបន្ទាប់ពីរបៀប និងហេតុផលដែលបទល្មើសអាចកើតឡើង**

- អ្នកសម្ភាសត្រូវតែផ្តល់នូវរឿងហេតុ ដែលអាចកើតមានឡើង ដើម្បីពន្យល់ហេតុអ្វីបានជាបទល្មើសអាចត្រូវបានប្រព្រឹត្ត
- រឿងហេតុជាច្រើនក្នុងចំណោមរឿងហេតុទាំងនេះ នឹងកាត់បន្ថយជាអប្បបរមានូវការស្តីបន្ទោសដែលមានឥទ្ធិពលប៉ះពាល់ដល់ទង្វើរបស់ជនសង្ស័យ ដោយធ្វើឱ្យគាត់មានការងាយស្រួលដើម្បីទទួលស្គាល់នូវការជាប់ពាក់ព័ន្ធរបស់គាត់
- ជាញឹកញាប់ ជនសង្ស័យនឹងទម្លាក់កំហុសទៅលើជនរងគ្រោះ ឬលទ្ធភាពដែលអាចស្វែងរកវិធីដើម្បីកាត់បន្ថយការទទួលខុសត្រូវរបស់ខ្លួន ។

**៤. ការធ្វើឱ្យបាត់ជំនឿទុកចិត្តរបស់ជនសង្ស័យ**

- មិនត្រូវសំឡុត គំរាមកំហែងដែលបង្កើនការភ័យខ្លាចដល់ជនសង្ស័យ
- ប្រសិនបើជនសង្ស័យដឹងថា អ្នកសម្ភាសកំពុងតែប្រើការសំឡុត គំរាមកំហែង ជនសង្ស័យនឹងលែងជឿជាក់លើអ្នកសម្ភាស
- អ្នកសម្ភាស គួរតែបំបាត់ជំនឿទុកចិត្តរបស់ជនសង្ស័យ ដោយប្រើសំណួរ "តើអ្វី... ប្រសិនបើ...?" (មានគេបានឃើញអ្នកប្រព្រឹត្ត តើអ្នកនិយាយថាដូចម្តេចដែរ?)។

**៥. ការផ្តល់នូវអំណះអំណាងបែបបញ្ចុះបញ្ចូលដើម្បីឱ្យជនសង្ស័យប្រាប់ការពិត**

- ជនសង្ស័យគួរតែត្រូវបានរំលឹកឱ្យដឹងថា ប្រសិនបើគាត់សហការជាមួយនឹងសមត្ថកិច្ចគាត់មានឱកាសទទួលបានស្ថានសម្រាលទោស
- អ្នកសម្ភាស ត្រូវតែប្រាប់ការពិតដល់ជនសង្ស័យ ដែលកើតពីការភ័យខ្លាចនៃការដាក់ទណ្ឌកម្ម ។

**៦.ការផ្តល់ដំណោះស្រាយដើម្បីបន្ធូរអារម្មណ៍ភ័យខ្លាចរបស់ជនសង្ស័យ**

- អ្នកសម្ភាសដាច់ខាត មិនត្រូវធ្វើការសន្យាណាមួយឱ្យជនសង្ស័យឡើយ
- នៅពេលដែលមានលទ្ធភាព អ្នកសម្ភាសអាចរកវិធីសាស្រ្តជម្នះលើឧបសគ្គ ដែលរារាំងដល់ជនសង្ស័យ មិនឱ្យប្រាប់ការពិត ។

**៧. ការលើកទឹកចិត្តដល់ជនសង្ស័យ**

- ការប្រើពាក្យសរសើរដល់ជនសង្ស័យ និងទទួលស្គាល់ចំណុចល្អរបស់គាត់ ដែលសហការ ។ អ្នកសម្ភាសកាន់តែងាយថែមទៀត បើជនសង្ស័យទទួលស្គាល់ការពិតថា ខ្លួនមានចំណុចអាក្រក់ ហើយសហការ
- អ្នកសម្ភាសត្រូវលើកទឹកចិត្តឱ្យជនសង្ស័យគិតពីអនាគតក្រុមគ្រួសារ ឬអ្នកដែលជាទីស្រឡាញ់របស់ខ្លួន ហើយប្រាប់ជនសង្ស័យថា ជម្រើសដ៏ល្អបំផុតរបស់គាត់ គឺប្រាប់ការពិត ។

**៨. ការប្រើប្រាស់សំណួរនាំមុខ និងសំណួរពហុជ្រើសរើស**

- ការប្រើសំណួរនាំមុខ និងសំណួរពហុជ្រើសរើស អ្នកសម្ភាសមានការងាយស្រួលច្រើនដើម្បីធ្វើឱ្យជនសង្ស័យទទួលស្គាល់ថា ពិតជាកំហុសរបស់ខ្លួន
- សំណួរពហុជ្រើសរើសជួយសម្រួល ដល់ការឆ្លើយតបជាវិជ្ជមាន ប៉ុន្តែវាកាត់បន្ថយពិរុទ្ធភាពខណៈដែលសំណួរនាំមុខ អាចធ្វើឱ្យមានការទទួលស្គាល់ ដែលមានការគំរាមកំហែងតិចតួចដោយធ្វើតាម និងមិននិយាយស្តី ។

**៩. អង្កេតមើលសញ្ញានៃការទទួលស្គាល់**

អ្នកសម្ភាសត្រូវដឹងពីសញ្ញាដែលជនសង្ស័យបម្រុងប្រាប់ការពិត ។ សញ្ញាទាំងនោះមានៈ

- ស្ងៀមស្ងាត់ភ្លាមៗ
- ស្តាប់ដោយយកចិត្តទុកដាក់
- ងក់ក្បាល ។

**១០. វិធីចូលកៀក និងជំរុញឱ្យផ្តល់ចម្លើយសារភាព**

- នៅពេលដែលខ្លួនដឹងនូវសញ្ញានៃការទទួលស្គាល់ អ្នកសម្ភាសត្រូវតែខិតចូលជិត ហើយជំរុញឱ្យផ្តល់ចម្លើយសារភាព
- ការជំរុញរបស់អ្នកសម្ភាសគួរតែរាប់បញ្ចូលនូវសំណួរនាំមុខ ឬសំណួរពហុជ្រើសរើស ដោយប្រើសំដីសមរម្យ ។

លោក Leo ជាអ្នកនិពន្ធ និងអ្នកស្រាវជ្រាវជនជាតិអាម៉េរិក (១៩៩៤) បានបញ្ជាក់ពីយុទ្ធវិធី ១២ យ៉ាងសម្រាប់ការសម្ភាសផ្លូវផ្លង ដែលត្រូវបានប្រើដោយមន្ត្រីនគរបាល ។ យុទ្ធវិធីដែលត្រូវបានប្រើទូទៅ រួមមាន ៖

១. បញ្ជាក់ពីចំណាប់អារម្មណ៍ផ្ទាល់ខ្លួនរបស់ជនសង្ស័យ

២. ឱ្យជនសង្ស័យ ដោះស្រាយជាមួយភស្តុតាងនៃភាពមានទោសដែលមានស្រាប់

៣. បំបាត់ការជឿទុកចិត្តក្នុងការបដិសេធភាពមានទោសរបស់ជនសង្ស័យ

៤. បញ្ជាក់ពីភាពផ្ទុយគ្នាក្នុងរឿងរ៉ាវរបស់ជនសង្ស័យ
៥. សំណួរនៃការសម្ភាស និងវិភាគលើអាកប្បកិរិយា
៦. បញ្ជាក់ពីសារៈសំខាន់នៃកិច្ចសហការ
៧. ផ្តល់នូវយុត្តិកម្មផ្លូវចិត្ត(អ្នកសម្ភាសយល់ស្របនឹងគំនិតអះអាងរបស់ជនសង្ស័យ)
៨. ប្រើប្រាស់ភស្តុតាងក្លែងក្លាយ ដើម្បីទទួលបានចម្លើយពិត
៩. ប្រើប្រាស់ការលើកសរសើរ ឬការសរសើរបញ្ជោរ
១០. បញ្ជាក់ពីកោសល្យវិច័យរបស់អ្នកស៊ើបអង្កេត
១១. បញ្ជាក់ពីមនសិការរបស់ជនសង្ស័យ
១២. ស្ថានសម្រាលទោស ។

លោក Leo បានសន្និដ្ឋានថា យុទ្ធវិធី ៤ យ៉ាងក្នុងចំណោមយុទ្ធវិធីសម្ភាសផ្សេងៗ ប្រកបដោយជោគជ័យបំផុតទាក់ទងទៅនឹងការទទួលបាននូវចម្លើយសារភាព គឺមានដូចខាងក្រោម (អត្រាជោគជ័យចំពោះយុទ្ធវិធីនេះបញ្ជាក់ប្រាប់ក្នុងវង់ក្រចក) ៖

- បញ្ជាក់ពីមនសិការរបស់ជនសង្ស័យ (៩៧ %)
- បញ្ជាក់ពីភាពផ្ទុយគ្នាក្នុងរឿងរ៉ាវរបស់ជនសង្ស័យ (៩១%)
- ប្រើប្រាស់ការលើកសរសើរ ឬការសរសើរបញ្ជោរ (៩១%)
- ផ្តល់យុត្តិកម្មផ្លូវចិត្ត (៩០%)

យោងតាមគំរូនេះ អាចរារាំងភាពជឿទុកចិត្តបាននៃចម្លើយសារភាពរបស់ជនសង្ស័យ ៖

- មន្ត្រីនគរបាលអាចប្រើប្រាស់យ៉ាងប៉ិនប្រសប់ នូវគំនិតបម្រើបុគ្គលខ្លួនឯង និងសាធារណជន នៅពេលសម្ភាស ដើម្បីជះឥទ្ធិពលដល់ការធ្វើសេចក្តីសម្រេចចិត្តរបស់ជនសង្ស័យ
- អ្នកសម្ភាស អាចប្រើប្រាស់យ៉ាងប៉ិនប្រសប់ នូវប្រក្បត្យារម្មណ៍នៃលទ្ធផលរបស់ជនសង្ស័យដែលជាប់ពាក់ព័ន្ធនឹងដំណើរវិវត្តនៃសកម្មភាព ។ អ្នកសម្ភាសអាចធ្វើរឿងនេះបានដោយកាត់បន្ថយជាអប្បបរមានូវភាពធ្ងន់ធ្ងរនៃបទល្មើសដែលត្រូវចោទប្រកាន់
- អ្នកសម្ភាសអាចធ្វើឱ្យសមត្ថភាពរបស់ជនសង្ស័យចុះខ្សោយ ដើម្បីប្រឈមមុខក្នុងការដោះស្រាយជាមួយនឹងរឿងហេតុ និងសេចក្តីសម្រេចចិត្តដោយមធ្យោបាយផ្សេងៗ ។

## IX. ការប្រើប្រាស់សំណួរដាក់លាក់ ឬបច្ចេកទេសចោទប្រកាន់ដោយទន់ភ្លន់

### ១. សំណួរដាក់លាក់

ដោយពឹងផ្អែកលើសនិទានកម្ម (ហេតុផលត្រឹមត្រូវ) ដែលខ្លួនបានផ្តល់ក្នុងអំឡុងពេលធ្វើសម្ភាស អ្នកសម្ភាសត្រូវប្រើប្រាស់បច្ចេកទេសសំណួរដាក់លាក់ ។ ជានិច្ចកាល សំណួរដាក់លាក់អះអាងថា ជនសង្ស័យបានពាក់ព័ន្ធនៅក្នុងឧប្បត្តិហេតុ ប៉ុន្តែ អ្នកសម្ភាសត្រូវជៀសវាងសំណួរទាំងឡាយ ដូចជា " តើអ្នកបានធ្វើវាទេ? " ។

- អ្នកសម្ភាស ត្រូវជៀសវាងការប្រើភាសាមិនពិរោះស្តាប់ ដូចជា (សម្លាប់ ពិឃាត)

• តាមរយៈការប្រើប្រាស់សនិទានកម្ម អ្នកសម្ភាសកាត់បន្ថយជាអប្បបរមា នូវភាពធ្ងន់ធ្ងរនៃការជាប់ពាក់ព័ន្ធរបស់ជនសង្ស័យ ។

មុនពេលអ្នកសម្ភាសសួរសំណួរដែលបានរៀបចំ ដើម្បីចម្រាញ់យកការទទួលស្គាល់ ជាដំបូងគាត់គួរតែមានអារម្មណ៍ដឹងថា ជនសង្ស័យត្រៀមខ្លួនសារភាព ។ វិធីនេះអាចត្រូវបានធ្វើតាមមធ្យោបាយជាច្រើន ៖

ដំណាក់កាលស្ងាបស្ទង់ ៖ ធ្វើឱ្យមានការស្ទាប់ស្ទង់ស្ថានភាពដ៏ស្មុគស្មាញ នៅពេលដែលអ្នកសម្ភាស ដឹងពីតម្រុយខាងអាកប្បកិរិយា ដែលជនសង្ស័យប្រុងប្រៀបនឹងទទួលថាពិត ។ តម្រុយខាងអាកប្បកិរិយាទាំងនេះ រួមមាន ឈប់មើលចំមុខ អង្គុយដោយទម្លាក់ស្មា ។

• បន្ទាប់មក អ្នកសម្ភាសគួរតែប្រើប្រាស់ឈ្មោះរបស់ជនសង្ស័យ ហើយផ្តល់ជនសង្ស័យនូវសនិទានកម្ម

• ខណៈកំពុងធ្វើដំណាក់កាលនេះ អ្នកសម្ភាសត្រូវឃ្លាំមើលប្រតិកម្មរបស់ជនសង្ស័យ ។

ប្រសិនបើអ្នកសម្ភាសសង្កេតឃើញថា ជនសង្ស័យកំពុងចាប់ផ្តើមធ្វើទំនាក់ទំនងតាមភ្នែក និងពង្រឹងឥរិយាបថឈរ ឬអង្គុយ ជនសង្ស័យអាចមិនបានត្រៀមខ្លួនដើម្បីធ្វើការទទួលស្គាល់ទេ ។

## ២. សំណួរចោទប្រកាន់បែបទន់ភ្លន់

មធ្យោបាយមួយទៀត ដើម្បីពិសោធភាពងាយរងឥទ្ធិពលរបស់ជនសង្ស័យ ចំពោះការទទួលស្គាល់ គឺត្រូវសួរសំណួរពហុជ្រើសរើស ឬធ្វើការចោទប្រកាន់បែបទន់ភ្លន់ ។ អ្នកសម្ភាសអាចសួរសំណួរទាំងនេះដល់ជនសង្ស័យយូរៗម្តង ដើម្បីកំណត់នូវការតស៊ូអត់ទ្រាំរបស់គាត់ក្នុងការទទួលស្គាល់ ។

• នៅពេលជនសង្ស័យប្រុងប្រៀបទទួលស្គាល់ការពិត ដោយមិនបានប្រើទំនាក់ទំនងតាមភ្នែកទេ ហើយឈប់ធ្វើការបដិសេធទាំងអស់ ជនសង្ស័យនោះប្រហែលជាត្រៀមខ្លួនសម្រាប់ទទួលស្គាល់ការពិត

• អ្នកសម្ភាសត្រូវតែចងចាំថា ការប្រុងប្រៀបទទួលស្គាល់របស់ជនសង្ស័យ អាចខុសគ្នាពីឥរិយាបថដកខ្លួនចេញ ឥរិយាបថចង់ឈ្នះ និងឥរិយាបថស្ងៀមស្ងាត់ខាងផ្លូវអារម្មណ៍

• សំណួរដាក់លាក់ប្រាប់ឱ្យដឹងថា ជនសង្ស័យពិតជាបានប្រព្រឹត្តបទល្មើស និងសុំទទួលស្គាល់ការពិត ដែលពាក់ព័ន្ធដល់ទិដ្ឋភាពខ្លះនៃបទល្មើស ។

ជាទូទៅ ការចោទប្រកាន់បែបទន់ភ្លន់ត្រូវធ្វើឡើង ចំពោះផ្នែកណាមួយនៃបទល្មើស ហើយមានលក្ខណៈទូលំទូលាយគ្រប់គ្រាន់លើកំណត់ហេតុពីបញ្ហាមួយចំនួន ៖

• អ្នកសម្ភាសធ្វើការចោទប្រកាន់បែបទន់ភ្លន់ ដោយនិយាយសម្តីយឺតៗ និងប្រុងប្រយ័ត្ន ដើម្បីបញ្ជាក់ពីទិដ្ឋភាពខ្លះនៃបទល្មើស ។ ឧទាហរណ៍ ៖

  - តើអ្នកបានពិចារណាពេលដំបូងដើម្បីទិញកាំភ្លើងនៅពេលណា?
  - តើនៅពេលណាអ្នកបានសម្រេចចិត្តថា នឹងធ្វើឱ្យនាងឈឺចាប់?
  - តើអ្នកប្រើប្រាស់ថ្នាំញៀនខុសច្បាប់ដំបូងនៅពេលណា?

- អ្នកសម្ភាសធ្វើការទាក់ទងតាមភ្នែកដោយត្រង់ៗ ជាមួយជនសង្ស័យ ដើម្បីឈានដល់ចុងបញ្ចប់នៃការចោទប្រកាន់បែបទន់ភ្លន់
- ជនសង្ស័យនឹងឆ្លើយតបទៅនឹងសំណួររបស់អ្នកសម្ភាស ដោយប្រើមធ្យោបាយមួយក្នុងចំណោមមធ្យោបាយទាំង៣ ៖
  - បដិសេធ
  - ធ្វើការទទួលស្គាល់ការពិត
  - បង្អេរបង្អង់ដើម្បីពិចារណានូវជម្រើសរបស់គាត់ ។
- ប្រសិនបើជនសង្ស័យបង្អេរបង្អង់ដើម្បីពិចារណារកចម្លើយ អ្នកសម្ភាសត្រូវតែប្រញាប់សួរសំណួរបន្តទៀត ដែលសំណួរនោះមានន័យបន្ថែមភាពធ្ងន់ធ្ងរនៃការជាប់ពាក់ព័ន្ធរបស់ជនសង្ស័យ
- ជាទូទៅ នៅពេលជនសង្ស័យត្រូវបានសួរសំណួរបំផ្លើសទាំងនេះ នឹងមានចម្លើយតបបដិសេធភ្លាម ។

**៣. សំណួរពហុជ្រើសរើស**

សំណួរពហុជ្រើសរើសជាសំណួរជាក់លាក់ដោយសួរអំពីទិដ្ឋភាពខ្លះនៃឧប្បត្តិហេតុ ។ សំណួរនេះមានលក្ខណៈខុសគ្នា ពីព្រោះវាផ្តល់ឱ្យជនសង្ស័យនូវជម្រើសពីរដែលជាប់ពាក់ព័ន្ធនឹងបទល្មើស ។

- ជាទូទៅ សំណួរពហុជ្រើសរើស រួមបញ្ចូលជម្រើសល្អ (ដែលអាចទទួលយកបាន និងជម្រើសមិនល្អ (ដែលមិនអាចទទួលយកបាន)
- ការសម្រាំងយកសំណួរជ្រើសរើសទាំងពីរនេះ ធ្វើឡើងដោយការទទួលស្គាល់ការពិតពីការជាប់ពាក់ព័ន្ធដំបូងរបស់ជនសង្ស័យ ។ ឧទាហរណ៍ ៖
  - តើអ្នកប្រើប្រាក់ដើម្បីជួលឃាតករស៊ីឈ្នួល ឬដើម្បីទិញកាំភ្លើង?
  - តើអ្នកមានបំណងធ្វើរឿងនេះ ឬវាជាឧប្បត្តិហេតុ?
- សំណួរពហុជ្រើសរើសគួរត្រូវសួរ តែនៅពេលដែលជនសង្ស័យបានបង្ហាញសញ្ញាខាងអាកប្បកិរិយាដែលទទួលស្គាល់ការពិត ហើយឈប់បដិសេធ
- អ្នកសម្ភាសគួរតែលើកទឹកចិត្តជនសង្ស័យ ឱ្យយកជម្រើសណាមួយដែលល្អប្រសើរអាចទទួលយកបានក្នុងជម្រើសទាំងពីរ
- នៅពេលជនសង្ស័យទទួលស្គាល់ការជាប់ពាក់ព័ន្ធ អ្នកសម្ភាសត្រូវតែប្រាប់ឱ្យគាត់ដឹងថា គាត់បានសារភាពហើយ ។

## X. ការអនុវត្តបច្ចេកទេសគំរូ PEACE ក្នុងការសម្ភាសជនសង្ស័យជួញដូរមនុស្ស

ក្របខណ្ឌសម្ភាសគំរូ PEACE ត្រូវបានប្រើជាច្រើន ទៅលើជនរងគ្រោះជាសាក្សី ឬជនសង្ស័យ។ អក្សរកាត់មានដូចខាងក្រោម ៖

P - Preparation ការរៀបចំ

E - Explanation ការពន្យល់

A - Account ការរៀបរាប់រឿងហេតុ

C - Closure ការបិទការសម្ភាស

E - Evaluation ការវាយតម្លៃ

| គំរូ PEACE-សម្ភាសជនសង្ស័យ | | | | |
|---|---|---|---|---|
| **P**<br>ការរៀបចំ | **E**<br>ការពន្យល់ | **A**<br>ការរៀបរាប់ | **C**<br>ការបញ្ចប់ | **E**<br>ការវាយតម្លៃ |
| ជ្រើសរើសក្រុមសម្ភាស គុណភាព និង ជំនាញ វប្បធម៌ | ណែនាំខ្លួន ពន្យល់ពីគោលបំណង និង វិធីសាស្ត្រ | ដំណាក់កាលទី១ របៀបរស់នៅ-ផ្ទះ ប្រាក់ចំណូល ការងារ | អានឱ្យជនសង្ស័យស្តាប់ ផ្ទៀងផ្ទាត់លើ កំណត់ហេតុ | តម្រូវការសម្ភាស បន្ថែមទៀតជាមួយ ជនសង្ស័យ- ភាព មិនច្បាស់លាស់ ភស្តុតាងថ្មី |
| ពិនិត្យ វិភាគ ភស្តុតាង និង កំណត់ពីគោល បំណងនៃការ សម្ភាស | ពន្យល់ពីអំណាច ស្របច្បាប់ សម្រាប់ការ សម្ភាស | ទំនាក់ទំនងជា មួយជនរងគ្រោះ និងជនសង្ស័យ ដទៃទៀតនៅក្នុង ការស៊ើបអង្កេត | ឱ្យជនសង្ស័យ សួរ ទទួលយក ឬបដិសេធទៅ លើការចោទ ប្រកាន់ដាក់ លាក់ | កោសល្យវិច័យ និង ការពិនិត្យខាងវេជ្ជ សាស្ត្រ ដើម្បី អះអាង ឬបដិសេធ ការពាក់ព័ន្ធរឿងក្តី |
| កំណត់បទ ល្មើស រៀបចំ ចំណុចវិភាគ ភស្តុតាង | ជូនដំណឹងដល់ ជនសង្ស័យពី សិទ្ធិ នៅពេល សម្ភាស | ទំនាក់ទំនង ខាង ក្រៅ និងហិរញ្ញវត្ថុ ជាមួយជនរង គ្រោះ | ឱ្យជនសង្ស័យ កែតម្រូវ និង ផ្តិតម្រាមដៃ ឬ ចុះហត្ថលេខា | ការកំណត់អត្ត សញ្ញាណ ប្រសិនបើ ជនសង្ស័យ បដិសេធពីការស្គាល់ ជនរងគ្រោះ |
| ពិចារណាពី ពេលវេលា ទីកន្លែង និង ឧបករណ៍ | ប្រាប់ជនសង្ស័យ ពីមូលហេតុនៃ ការសម្ភាស ឬ ការឃាត់ខ្លួន | ដាក់បណ្តឹងចោទ ប្រកាន់ ដាក់លាក់ ដល់ជនសង្ស័យ នៅក្នុងដំណាក់ កាលទី ១ | ឱ្យជនសង្ស័យ ចុះហត្ថលេខា និងបោះត្រា លើខ្សែអាត់ | ស្វែងរកភស្តុតាង បំពេញបន្ថែម ដើម្បី អះអាង ឬបដិសេធ តួនាទីរបស់ជន សង្ស័យ |
| រៀបចំផែនការ ដើម្បីគ្រប់គ្រង | ពិនិត្យ និងទទួល ស្គាល់ភស្តុតាង នៃការចាប់ខ្លួន | ដំណាក់កាលទី២ សំណួរ ភស្តុតាង មិនស៊ីចង្វាក់ | ពន្យល់ជំហាន បន្ទាប់នៅក្នុង ការស៊ើបអង្កេត | ការអនុវត្តរបស់ក្រុម សម្ភាស តើតម្រូវឱ្យ មានការផ្លាស់ប្តូរឬ? |

**១. ការរៀបចំ** ( Preparation )

ការផ្តោតអារម្មណ៍ទៅលើដំណើរការរៀបចំ និងត្រូវកំណត់ដោយចំនួនជនសង្ស័យ ដែលត្រូវសម្ភាស និងចំនួនអ្នកសម្ភាសដែលមាន ។ នៅក្នុងការស៊ើបអង្កេតរឿងក្តីជួញដូរមនុស្សភាគច្រើន អាចមានជនសង្ស័យច្រើននាក់ដែលត្រូវធ្វើការសម្ភាស ដូចនេះដំណាក់កាលរៀបចំផែនការ ត្រូវគិតទៅដល់បញ្ហាធនធានដែលមាន ។

មានចំណុចជាច្រើនត្រូវពិចារណានៅក្នុងដំណាក់កាលការរៀបចំផែនការសម្រាប់សម្ភាស ៖

• គោលបំណង៖ តើការសម្ភាសអាចជួយដល់ការស៊ើបអង្កេតយ៉ាងដូចម្តេចដែរ? តើវានឹងផ្តល់ឱកាសឱ្យមានយុត្តិធម៌ ដល់ជនសង្ស័យក្នុងការបង្ហាញពីរឿងរ៉ាវរបស់ខ្លួនដែរឬទេ តើរឿងរ៉ាវនោះ អះអាង ឬបដិសេធការពាក់ព័ន្ធរបស់ជនសង្ស័យ នៅក្នុងបទល្មើស ដែលបានចោទឬ?

• នីត្យានុកូលភាព៖ ដើម្បីធានាថា វិធីសាស្ត្រសម្ភាសត្រូវគោរពទៅតាមបទបញ្ញត្តិ នៃច្បាប់ជាតិ និងនីតិវិធីដែលតម្រូវ

• ការវិភាគ៖ តើបទល្មើសអ្វី ដែលបានប្រព្រឹត្ត ហើយធាតុផ្សំអ្វីខ្លះនៅក្នុងបទល្មើសទាំងអស់នោះ នៅក្នុងមាត្រានៃច្បាប់ និងចំណុចដែលត្រូវបង្ហាញភស្តុតាង

• ភស្តុភារ៖ ការរៀបចំអនុវត្ត ដូចជា ទីតាំង ឧបករណ៍ ពេលវេលា ការងារ ។

**ក. ការជ្រើសរើសក្រុមសម្ភាស**

ការជ្រើសរើសក្រុមសម្ភាស គឺអាស្រ័យលើលក្ខណៈបុគ្គល និងជំនាញជាអាជីព ដូចជា ៖

• ទំនាក់ទំនង៖ សមត្ថភាពក្នុងការទំនាក់ទំនងជាមួយជនសង្ស័យ និងយុទ្ធសាស្ត្រដែលមិនមានលក្ខណៈវិនិច្ឆ័យជាមុន ។ ការសម្ភាសជាដំណាក់កាលដំបូង ដែលអាចជួយដល់ដំណើរការទាំងមូលបាន ប្រសិនបើអ្នកសម្ភាសអាចបង្កើតទំនាក់ទំនងល្អ ជាមួយជនសង្ស័យ

• ជំនាញឯកទេស ៖ មានជំនាញ ទទួលការបណ្តុះបណ្តាល និងបទពិសោធន៍លើការសួរចម្លើយ

• ចំណេះដឹងវិជ្ជាជីវៈ ៖ មានចំណេះដឹងជាលក្ខណៈអាជីពលើបទល្មើសជួញដូរមនុស្ស និងបទល្មើសដទៃទៀត ដែលមានការពាក់ព័ន្ធជាទូទៅនឹងបទល្មើសជួញដូរមនុស្ស ដូចជា ការប៉ះពាល់ដល់បូរណភាពបុគ្គល ការប៉ះពាល់ផ្លូវភេទ ការឃុំឃាំងខុសច្បាប់ និងបទល្មើសអន្តោប្រវេសន៍។ល។

• អំណត់ និងភាពបត់បែន៖ ការសម្ភាសជាមួយជនសង្ស័យ នៅក្នុងរឿងក្តីជួញដូរមនុស្ស គឺត្រូវការចំណាយពេលវេលាច្រើន ដោយហេតុថា ការសម្ភាសត្រូវធ្វើឡើង ទៅតាមដំណាក់កាលនៃកាលប្រវត្តិ ដែលត្រូវចោទប្រកាន់ទៅលើជនសង្ស័យ ។ ដូចនេះជាការចាំបាច់ តម្រូវឱ្យមានការសម្រាកជាច្រើនដង ដើម្បីឱ្យជនសង្ស័យអាចទទួលការប្រឹក្សាពីមេធាវីរបស់ខ្លួនបន្តទៀត ឬដើម្បីសម្រាកស្រស់ស្រូបអាហារ ។ល។

• ជំនាញខាងផ្នែកវប្បធម៌ ប្រសិនបើជនសង្ស័យជាជនបរទេស៖ ជនសង្ស័យនៅក្នុងរឿងក្តីជួញដូរមនុស្ស អាចជាជនបរទេស ដូច្នេះអ្នកសម្ភាសត្រូវមានជំនាញខាងផ្នែកវប្បធម៌ របស់ជនរងគ្រោះ និងជនសង្ស័យ ។ ការសម្ភាស គឺជាឱកាសមួយសម្រាប់ ជនសង្ស័យក្នុងការផ្តល់រឿងរ៉ាវរបស់

ខ្លួន ហើយអ្នកសម្ភាសត្រូវព្យាយាមយល់ដឹងពីកត្តាវប្បធម៌ណាមួយ ដែលធ្វើឱ្យប៉ះពាល់ដល់លទ្ធភាពរបស់ជនសង្ស័យ ក្នុងការផ្តល់ព័ត៌មានដោយសេរី ។ ដូចការសម្ភាសជនរងគ្រោះដែរ អ្នកសម្ភាសត្រូវបង្ហាញពីទិដ្ឋភាពទូទៅ ដល់អ្នកបកប្រែ មុននឹងធ្វើការសម្ភាសអំពីកត្តាវប្បធម៌ជាក់លាក់ណាមួយដែលត្រូវយកចិត្តទុកដាក់ ។

### ខ. ការវិភាគមុនការសម្ភាស

អ្នកសម្ភាសត្រូវពិនិត្យពីភស្តុតាងមានស្រាប់ ដែលប្រមូលបានតាមរយៈការស៊ើបអង្កេត ហើយប្រៀបធៀបភស្តុតាងទាំងនោះទៅនឹងធាតុផ្សំនៃបទល្មើស ។ តាមរយៈនៃបទល្មើសនេះ ជនសង្ស័យត្រូវបានចាប់ខ្លួន និងស្តាប់ចម្លើយ ។ ភស្តុតាងមានស្រាប់ រួមមានដូចខាងក្រោម ៖

- ព័ត៌មានលម្អិតនៃការចោទប្រកាន់ដែលមាននៅក្នុងចម្លើយរបស់ជនរងគ្រោះ
- ភស្តុតាងបំពេញបន្ថែមទៅលើចម្លើយរបស់ជនរងគ្រោះ
- ភស្តុតាងប្រមូលបន្ថែមនៅក្នុងដំណាក់កាលនៃការចាប់ខ្លួន ឆែកឆេរ និងរឹបអូស
- ការយល់ព្រម ការបដិសេធ ឬយោបល់ផ្សេងទៀតរបស់ជនសង្ស័យ
- វត្ថុតាងដែលត្រូវបានរឹបអូសក្នុងដំណាក់កាលឆែកឆេរ ដូចជា ឧបករណ៍ ប្រើសម្រាប់វាយធ្វើបាប ឬបម្រើផ្លូវភេទ កំណត់ហេតុ ឯកសារ អត្តសញ្ញាណប័ណ្ណ ឬលិខិតធ្វើដំណើរ ។ល។

យុទ្ធសាស្ត្រល្អបំផុត គឺត្រូវបំបែកភស្តុតាងដែលមានឱ្យទៅជាធាតុផ្សំដូចខាងក្រោម ៖

- ដំណាក់កាលជួញដូរទាំង ៣ នៃការជ្រើសរើស ដឹកជញ្ជូន និងកេងប្រវ័ញ្ច
- សមាសភាគទាំង ៥ នៃការផ្សាយពាណិជ្ជកម្មៈ ទិញ ជួល ការដឹកជញ្ជូន ការប្រាស្រ័យទាក់ទង និងការផ្ទេរហិរញ្ញវត្ថុ ។

ភស្តុតាងដែលមាន គួរពិនិត្យឡើងវិញតាមរយៈការវិភាគទៅលើប្រភេទខាងលើ និងផ្ទៀងផ្ទាត់ទៅនឹងចំណុចបង្ហាញភស្តុតាងនៃមាត្រានីមួយៗ របស់ក្រមនីតិវិធីព្រហ្មទណ្ឌ ដែលត្រូវបានគេរំលោភ ។ បើបណ្តឹងពាក់ព័ន្ធការបំពានលើរូបរាងកាយ និង/ឬផ្លូវភេទ ការបំបែកទៅជាផ្នែកតូចៗ គួរបញ្ចូលភស្តុតាងវេជ្ជសាស្ត្រណាមួយពាក់ព័ន្ធទៅនឹងការបង្ហាញភស្តុតាងនៃបទល្មើស ។

ភស្តុតាងដែលទាក់ទងទៅនឹងការសម្ភាស គួរឱ្យមានជាស្រេច ដើម្បីបង្ហាញទៅដល់ជនសង្ស័យ នៅក្នុងអំឡុងពេលនៃការសម្ភាស ។

### គ. ពេលវេលាក្នុងការរៀបចំ

នៅក្នុងរឿងក្តីជួញដូរមនុស្ស មន្ត្រីសម្ភាសអាចត្រូវប្រឈមទៅនឹងពេលវេលា ដែលមានការកំណត់ ដោយកត្តាមួយចំនួន ៖

- អ្នកបកប្រែ ៖ ជនសង្ស័យមួយចំនួន អាចជាជនបរទេស ដូច្នេះការសម្ភាសតម្រូវឲ្យមានវត្តមានអ្នកបកប្រែ ដែលអាចចំណាយពេលក្នុងការរៀបចំ
- មេធាវីជនសង្ស័យៈ រង់ចាំការមកដល់របស់មេធាវីជនសង្ស័យ និងអនុញ្ញាតឱ្យមេធាវីចំណាយពេលវេលាសមរម្យមួយ ដើម្បីឱ្យដឹងពីមូលហេតុនៃការចោទប្រកាន់ទៅលើជនសង្ស័យ និង

អនុញ្ញាតឱ្យមេធាវីពិភាក្សាជាមួយជនសង្ស័យ មុនដំណើរការសម្ភាស ។ (មាត្រា៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

- ជនសង្ស័យច្រើននាក់ ៖ សេចក្តីត្រូវការសម្ភាសជាមួយជនសង្ស័យដទៃទៀត ដើម្បីទទួលបាននូវការចោទប្រកាន់ពេញលេញទៅលើជនសង្ស័យ ។ ជាការពិតណាស់ គ្មានការប្រព្រឹត្តបទល្មើសជួញដូរមនុស្សដោយមានជនសង្ស័យតែម្នាក់នោះទេ ហើយនៅក្នុងរឿងក្តីជាច្រើន ក្រុមសម្ភាសនឹងត្រូវប្រឈមការសម្ភាសជាមួយជនសង្ស័យទាំងនោះ ហើយជនសង្ស័យទាំងនោះ តម្រូវឱ្យអ្នកសម្ភាសរៀបចំលំដាប់លំដោយអាទិភាព នៃការពាក់ព័ន្ធរបស់គេទៅនឹងបទល្មើស ។ ភាគច្រើននៃរឿងក្តី យោងទៅតាមបទពិសោធន៍ល្អៗនានា បានបង្ហាញថា ការសម្ភាសធ្វើឡើងមុនគេ គឺការសម្ភាសជាមួយជនសង្ស័យ ដែលមិនសូវសំខាន់ ដើម្បីទទួលបាននូវទិដ្ឋភាព ពេញលេញពីរឿងក្តី មុននឹងធ្វើការសម្ភាសជាមួយជនជួញដូរមនុស្សសំខាន់ៗ ។ ការដែលធ្វើដូចនេះ គឺត្រូវការចំណាយពេលវេលាច្រើន ដើម្បីឱ្យស្របទៅនឹងនីតិវិធីនៃការឃាត់ខ្លួនជនសង្ស័យ ។
- ការពិនិត្យកោសល្យវិច័យផ្នែកវេជ្ជសាស្ត្រ ៖ អនុញ្ញាតឱ្យមានការពិនិត្យផ្នែកវេជ្ជសាស្ត្រ និងកោសល្យវិច័យពេញលេញ នៅក្នុងរឿងក្តីចោទប្រកាន់ទាក់ទងទៅនឹងការបំពារបំពានផ្លូវភេទប្រព្រឹត្តដោយជនសង្ស័យ ។ ការប្រើប្រាស់អំពើហិង្សាលើរូបរាងកាយ និងផ្លូវភេទ គឺជាលក្ខណៈទូទៅនៃរឿងក្តីជួញដូរមនុស្ស
- ការពិនិត្យវត្ថុតាង ៖ សេចក្តីត្រូវការពិនិត្យលើភស្តុតាងដែលបានរឹបអូសណាមួយ នៅពេលជនសង្ស័យត្រូវបានចាប់ខ្លួន ការស៊ើបអង្កេតរឿងក្តីជួញដូរមនុស្ស និងប្រតិបត្តិការចាប់ខ្លួន ជាធម្មតា ត្រូវរកឱ្យឃើញវត្ថុតាងជាច្រើន ជាពិសេសភស្តុតាងដែលមានតម្លៃ ហើយតម្រូវឱ្យធ្វើការកំណត់សម្គាល់នានា ដើម្បីដាក់បន្ទុកទៅលើជនសង្ស័យ មុននឹងធ្វើការសម្ភាស ។

**ឃ. ទីកន្លែង និងឧបករណ៍**

ទីកន្លែងសម្ភាស ត្រូវកំណត់ និងត្រួតពិនិត្យជាមុន ហើយត្រូវមានលក្ខណៈសមរម្យផាសុខភាព គ្មានការរំខាន និងត្រៀមឧបករណ៍ចាំបាច់សម្រាប់ការសម្ភាស ។

**ង. រៀបចំផែនការជាលាយលក្ខអក្សរ**

ផែនការសម្ភាសជាលាយលក្ខអក្សរ ត្រូវសង្ខេបពីគោលបំណងនៃការសម្ភាស និងផ្តល់នូវក្របខណ្ឌការងារសម្រាប់សួរចម្លើយជនសង្ស័យ ។ ផែនការជាលាយលក្ខអក្សរត្រូវផ្តល់ដល់អ្នកស៊ើបអង្កេតជាលក្ខណៈសម្ងាត់ និងជាលក្ខណៈដែលអាចបត់បែនបាន សម្រាប់ធ្វើការសម្ភាសជាលក្ខណៈអាជីព និងប្រកបដោយប្រសិទ្ធភាព ។ ផែនការសម្ភាសជាលាយលក្ខអក្សរ ជាឧបករណ៍ប្រកបដោយប្រសិទ្ធភាព សម្រាប់ជួយដល់អ្នកស៊ើបអង្កេតលើដំណើរការសម្ភាស ៖

- បណ្តឹងចោទប្រកាន់
- ចំណុចចាំបាច់ដើម្បីបង្ហាញពីធាតុផ្សំនៃបទល្មើស តាមរយៈការស៊ើបអង្កេត
- ចំណុចណាមួយ ដែលជនសង្ស័យអាចការពារ ថាខ្លួនមិនបានប្រព្រឹត្តបទល្មើស តាមរយៈការស៊ើបអង្កេត

- ការបង្ហាញវត្ថុតាង ឬភស្តុតាងផ្សេងទៀត ដែលអាចបង្ហាញថា ជនសង្ស័យបានប្រព្រឹត្ត ឬមិនបានប្រព្រឹត្តបទល្មើស
- ភាពអាចបត់បែនដើម្បីទទួលបានភស្តុតាង ឬព័ត៌មាននានា ពីការសម្ភាស ដោយមិនបានដឹងជាមុន ។ ព័ត៌មាន និងភស្តុតាងទាំងនោះ អាចធ្វើឱ្យប៉ះពាល់ ទៅដល់ដំណើរការកំណត់ទិសដៅនៃការសម្ភាស ។

**២. សេចក្តីពន្យល់** ( Explanation )

គោលការណ៍ណែនាំខាងក្រោម ត្រូវគោរពតាម ដោយហេតុថា វាជាការអនុវត្តល្អៗនៅក្នុងការសម្ភាសជាមួយជនសង្ស័យ ហើយត្រូវអនុវត្តដូចគ្នា ទៅនឹងជនសង្ស័យនៅក្នុងរឿងក្តីជួញដូរមនុស្ស ។ ដំណាក់កាលនៃការចាប់ផ្តើមសម្ភាស ដូចគ្នាទៅនឹងដំណាក់កាលនៃការទំនាក់ទំនងធ្វើសម្ភាសជាមួយជនរងគ្រោះ ហើយគួរតែធ្វើការវាយតម្លៃស្រដៀងគ្នា ។ ដំណាក់កាលនេះអាចប្រើដើម្បី ៖

- ពន្យល់ជនសង្ស័យពីគោលបំណងនៃការសម្ភាស
- អំណាចផ្លូវច្បាប់នៃការសម្ភាស
- សិទ្ធិស្របច្បាប់របស់ជនសង្ស័យ នៅក្នុងដំណើរការសម្ភាស
- ពិនិត្យមើលភស្តុតាងចាប់ខ្លួន និងប្រាប់ជនសង្ស័យម្តងទៀតអំពីបទល្មើស ពិតប្រាកដដែលជាមូលហេតុនៃការចាប់ខ្លួន និងមូលហេតុនៃការសម្ភាស
- អានខ្លឹមសារនៃកំណត់ហេតុចាប់ខ្លួន និងឆែកឆេរ ឱ្យជនសង្ស័យស្តាប់ ហើយធ្វើការចុះនិទ្ទេសពីចំណុចយល់ព្រម និងមិនយល់ព្រមរបស់ជនសង្ស័យ ទៅលើខ្លឹមសារនៃកំណត់ហេតុនោះ ។ យុទ្ធសាស្ត្រនេះត្រូវបានទទួលលទ្ធផលដូចខាងក្រោម ៖
  - បញ្ជាក់ពីអង្គហេតុឡើងវិញ និងអះអាងពីសុក្រឹតភាពនៃកំណត់ហេតុដែលបានកើតឡើងរហូតមកដល់ពេលនេះ
  - ជំហាននេះមានយុត្តិធម៌ណាស់សម្រាប់ជនសង្ស័យ ពីព្រោះវាផ្តល់ឱកាសដល់ជនសង្ស័យឱ្យលើកពីបញ្ហាណាមួយ ដែលទាក់ទងទៅនឹងកិច្ចប្រតិបត្តិការចាប់ខ្លួន និងឆែកឆេរ ឬលើកពីសុក្រឹតភាពនៃកំណត់ហេតុ ។ បើមានចំណុចណាមួយត្រូវប្រឈម ចំណុចនានាដែលជនសង្ស័យលើកឡើង ត្រូវធ្វើកំណត់ហេតុនៅក្នុងជំហាននេះ ។

**៣. ការរៀបរាប់រឿងហេតុ** ( Account )

ដំណាក់កាលរៀបរាប់ គួរបែងចែកទៅជាពីរផ្នែក ដែលពាក់ព័ន្ធគ្នា ៖

**ក. ដំណាក់កាលទី ១ របៀបរស់នៅជាទូទៅ ប្រវត្តិ និងបណ្តឹងចោទប្រកាន់**

គោលបំណង គឺរកឱ្យឃើញរបៀបរស់នៅជាទូទៅរបស់ជនសង្ស័យ ទំនាក់ទំនងជាមួយជនរងគ្រោះ ជនសង្ស័យដទៃទៀត និងបទល្មើសដែលបានចោទប្រកាន់ ។ ត្រូវសួរជនសង្ស័យអំពី ៖

- ព័ត៌មានសង្ខេបពីរបៀបរស់នៅរបស់គាត់ ផ្ទះ ក្រុមគ្រួសារ ការងារ ប្រាក់ចំណូល ការចំណាយ និងរបៀបរស់នៅទូទៅ
- ការពាក់ព័ន្ធរបស់គាត់ជាមួយជនរងគ្រោះ

• ការពាក់ព័ន្ធ និងទំនាក់ទំនងរបស់គាត់ជាមួយជនសង្ស័យដទៃទៀត ដែលស្ថិតនៅក្រោមការស៊ើបអង្កេត

• តើពួកគេជួបគ្នាដោយរបៀបណា នៅទីណា ពេលណា ការបន្លាស់ទី ការដឹកជញ្ជូន និងទីតាំងកេងប្រវ័ញ្ច

• ព័ត៌មានពីទំនាក់ទំនងជាមួយជនរងគ្រោះ

• ព័ត៌មានទំនាក់ទំនងហិរញ្ញវត្ថុជាមួយជនរងគ្រោះ ។

មុននឹងបញ្ចប់ដំណាក់កាលនេះ អ្នកសម្ភាសគួរពិនិត្យមើលភស្តុតាងដែលមានជាមួយជនសង្ស័យ និងស្វែងរកពីចំណុចយល់ព្រម និងមិនយល់ព្រមរបស់ជនសង្ស័យ ទៅលើចំណុចណាមួយនៃភស្តុតាង ។

នៅទីបញ្ចប់ បណ្តឹងចោទប្រកាន់ជាក់លាក់ត្រូវអានដោយជនសង្ស័យ និងបញ្ជាក់ពីការទទួល ឬបដិសេធលើចម្លើយដែលពាក់ព័ន្ធនឹងអំពើល្មើស ។

**ខ. ដំណាក់កាលទី២-សំណួរជាក់លាក់បន្ថែម**

គោលបំណង គឺសាកល្បងរកឱ្យឃើញប្រវត្តិរបស់ជនសង្ស័យ និងការពន្យល់ពីជនសង្ស័យ ទាក់ទងទៅនឹងភស្តុតាងជាក់លាក់ណាមួយ និងដើម្បីពន្យល់ភាពមិនស៊ីចង្វាក់គ្នា ដែលបានបញ្ជាក់នៅក្នុងចម្លើយ បានផ្តល់នៅក្នុងដំណាក់កាលទី១ នៃការសម្ភាស ។

ដំណាក់កាលនេះ គួរផ្លាស់ប្តូរយុទ្ធសាស្ត្រនៃការសម្ភាស ពីលក្ខណៈទូទៅ ទៅចំណុចជាក់លាក់មួយដើម្បីសាកសួរ ពីព្រឹត្តិការណ៍ជាក់លាក់ យោងទៅតាមភស្តុតាងដែលអ្នកសម្ភាសមាន ។ គោលបំណងនៅទីនេះ គឺដើម្បីសាកល្បងរកឱ្យឃើញរឿងរ៉ាវណាមួយ ដែលជនសង្ស័យផ្តល់ឱ្យ ដោយធៀបទៅនឹងភស្តុតាងដែលមាន ។ សំណួរគួរសួរទៅជនសង្ស័យដោយលក្ខណៈទន់ភ្លន់ ដើម្បីទទួលបាននូវការពន្យល់ពីភាពខុសគ្នារវាងរឿងរ៉ាវរបស់គាត់ និងភស្តុតាងដែលមាន ។ បើអាចធ្វើបាន វត្ថុតាងណាមួយ ដែលប្រឈមទៅនឹងរឿងហេតុ គួរធ្វើការបង្ហាញដល់ជនសង្ស័យឱ្យបានដឹង ហើយឱ្យជនសង្ស័យផ្តល់យោបល់ទៅលើវត្ថុតាងទាំងនោះ ។ បើវត្ថុតាងទាំងអស់នោះ អាចបង្ហាញថា ចម្លើយដែលបានផ្តល់កាលពីលើកមុន នៅក្នុងអំឡុងពេលនៃដំណើរការដំណាក់កាលទី១ គឺខុស ឬមិនស៊ីចង្វាក់ នោះត្រូវធ្វើការបញ្ជាក់ពីអង្គហេតុនោះ ហើយត្រូវឱ្យជនសង្ស័យពន្យល់ពីមូលហេតុដែលគាត់ផ្តល់ចម្លើយមិនអាចជឿជាក់បាន ។

**៤. ការបញ្ចប់សម្ភាសន៍** (Closure)

ដំណាក់កាលបញ្ចប់ គឺជាការអនុវត្តដ៏ល្អមួយទាក់ទងទៅនឹងការសម្ភាសជាមួយជនសង្ស័យរឿងក្តីណាក៏ដោយ ហើយត្រូវអនុវត្តដូចគ្នាទៅនឹងការបញ្ចប់សម្ភាសន៍ជាមួយជនសង្ស័យក្នុងរឿងក្តីជួញដូរមនុស្សដែរ ។ នីតិវិធីខាងក្រោម ត្រូវតែអនុវត្ត ៖

• អាន និងបញ្ជាក់ឱ្យច្បាស់នៅក្នុងសេចក្តីសន្និដ្ឋាននៃការសួរចម្លើយ អ្នកសម្ភាសគួរសង្ខេបពីខ្លឹមសារនៃការសម្ភាស និងឱ្យជនសង្ស័យបន្ថែមចំណុចណាមួយ ឬបញ្ជាក់ឱ្យបានច្បាស់លាស់លើចំណុចណាមួយដែលមានភាពស្រពិចស្រពិល ។ល។

• ផ្ទៀងផ្ទាត់ និងចុះហត្ថលេខា ៖ ក្រុមសម្ភាសត្រូវឱ្យជនសង្ស័យ ពិនិត្យមើលកំណត់ហេតុនៃការធ្វើសម្ភាស(វត្តមានរបស់មេធាវីរបស់ខ្លួន) និងចុះហត្ថលេខាទៅលើកំណត់ហេតុនោះ

• មុននឹងចាកចេញពីកន្លែងសម្ភាស អ្នកសម្ភាសត្រូវពន្យល់ទៅដល់ជនសង្ស័យ (មេធាវីរបស់ខ្លួន) អំពីអ្វីដែលនឹងកើតមានឡើងចំពោះជនសង្ស័យ ក្នុងអំឡុងពេលនៃការឃាត់ខ្លួន ។

**៥. ការវាយតម្លៃ** (Evaluation)

បន្ទាប់ពីបញ្ចប់ការសម្ភាសជាមួយជនសង្ស័យ បើអាចធ្វើទៅបាន ក្រុមសម្ភាសគួរពិនិត្យ និងវាយតម្លៃពីខ្លឹមសារនៃការធ្វើសម្ភាស និងកំណត់អំពីជំហានស៊ើបអង្កេតនៅដំណាក់កាលក្រោយទៀត ដោយឈរលើមូលដ្ឋាននៃការវាយតម្លៃ ៖

• ការសម្ភាសបន្ថែម ៖ ដើម្បីពិនិត្យទៅលើភស្តុតាងបន្ថែមទៀត ។ ការពិនិត្យនេះ អាចកើតមានឡើងចំពោះរឿងក្តីជួញដូរមនុស្ស ព្រោះវាដូចទៅនឹងការសម្ភាសជាមួយជនរងគ្រោះដែរ ។ ក្រុមសម្ភាសត្រូវពិនិត្យទៅលើពេលវេលាការងារ នៃបណ្តឹងចោទប្រកាន់ លើកលែងតែជនសង្ស័យបដិសេធផ្តល់យោបល់ណាមួយ និងលើកលែងតែការសម្ភាសនោះបានបញ្ចប់សព្វគ្រប់

• កោសល្យវិច័យផ្នែកវេជ្ជសាស្ត្រ ៖ បញ្ហានេះអាចកើតមានឡើង អាស្រ័យទៅលើប្រភេទនៃបណ្តឹងចោទប្រកាន់ ។ ប្រសិនបើបណ្តឹងចោទប្រកាន់ មិនបានបញ្ចូលអំពើហិង្សាលើរូបរាងកាយ ឬផ្លូវភេទ ការពិនិត្យផ្នែកវេជ្ជសាស្ត្រទំនងជាមិនមានការចាំបាច់ដែរ ។ ប្រសិនបើមានបណ្តឹងចោទប្រកាន់បែបនេះ អ្នកសម្ភាសត្រូវវាយតម្លៃថា តើការពិនិត្យកោសល្យវិច័យផ្នែកវេជ្ជសាស្ត្រអាចជួយធ្វើការបញ្ជាក់ ឬបដិសេធពីការពាក់ព័ន្ធរបស់ជនសង្ស័យ

• នីតិវិធីកំណត់អត្តសញ្ញាណ ៖ បញ្ហានេះអាចនឹងកើតមានឡើងបានតែក្នុងករណីជនសង្ស័យ បដិសេធបណ្តឹងចោទប្រកាន់ ដែលធ្វើឡើងដោយជនរងគ្រោះជាសាក្សី ។ វាអាចមិនកើតឡើងទេ នៅក្នុងរឿងក្តីជួញដូរមនុស្ស ពីព្រោះ ជាធម្មតាមានភស្តុតាងគ្រប់គ្រាន់នៃការទំនាក់ទំនងរវាងជនរងគ្រោះ និងជនសង្ស័យ ហើយវាជាការពិបាកសម្រាប់ជនសង្ស័យក្នុងការបដិសេធថា ខ្លួនមិនដែលជួបជនរងគ្រោះទាល់តែសោះ ។ ប៉ុន្តែ ប្រសិនបើជនសង្ស័យបានទាមទារដូច្នោះមែន នោះអ្នកសម្ភាសត្រូវរៀបចំនីតិវិធីកំណត់អត្តសញ្ញាណពាក់ព័ន្ធ ដើម្បីឱ្យរឿងក្តីមានដំណើរការទៅមុខ

• ការចាប់ខ្លួន៖ ការចាប់ខ្លួនជនសង្ស័យពាក់ព័ន្ធ ឬការឆែកឆេរអាសយដ្ឋាន គឺជាលទ្ធផលនៃដំណើរការសម្ភាស បញ្ហាទាំងនេះអាចនឹងកើតមានឡើង គឺអាស្រ័យទាំងស្រុងទៅលើអ្វីដែលជនសង្ស័យបាននិយាយប្រាប់ នៅក្នុងអំឡុងពេលនៃការសម្ភាស ។ ប្រសិនបើជនសង្ស័យមិនមានយោបល់អ្វីទេ នោះការចាប់ខ្លួនជនពាក់ព័ន្ធ និងការឆែកឆេរមិនអាចកើតមានឡើយ ។ ម៉្យាងវិញទៀត ប្រសិនបើជនសង្ស័យសារភាព បង្ហាញឱ្យឃើញអង្គហេតុ ពេលនោះការចាប់ខ្លួន និងការឆែកឆេរ អាចជាការចាំបាច់ ដូចជាជនសង្ស័យអាចប្រាប់ពីជនសង្ស័យដទៃទៀត ឬជនរងគ្រោះស្ថិតនៅកន្លែងណា ឬបង្ហាញពីទីតាំងនៃវត្ថុតាងនានា ដូចជា ប្រាក់ ឬឯកសារ

• ការស៊ើបអង្កេតបន្ថែម ៖ ដើម្បីប្រមូលភស្តុតាងបំពេញបន្ថែម គឺមានគោលបំណងគាំទ្រ

ដល់ដំណើរការស៊ើបអង្កេត ។ ដូចបានរៀបរាប់ខាងលើ ភស្តុតាងបំពេញបន្ថែមណាមួយ អាចប្រមូលបាន អាស្រ័យទាំងស្រុងទៅលើអ្វីដែលជនសង្ស័យបាននិយាយប្រាប់ នៅក្នុងអំឡុងពេលសម្ភាស

- ការអនុវត្ត ៖ តាមពេលវេលាសមស្រប ការវាយតម្លៃទៅលើការអនុវត្តរបស់ខ្លួន ក្នុងឋានៈជាអ្នកសម្ភាសជនសង្ស័យ ត្រូវអនុវត្តឲ្យបានល្អ និងជំនាញលើការងារ ។ វាមិនអាចធ្វើបានភ្លាមៗនោះទេ ប៉ុន្តែ ជានិច្ចកាល អ្នកសម្ភាសគួរតែរកពេលវេលាណាមួយ ដើម្បីជជែក និងពិនិត្យមើលការអនុវត្តរបស់ខ្លួន តាមរយៈការបង្ហាញពីចំណុចខ្លាំង និងចំណុចខ្សោយរបស់ខ្លួន ។ ការសម្ភាសជាមួយជនសង្ស័យក្នុងរឿងក្តីជួញដូរមនុស្សមានភាពស្មុគស្មាញ ហើយតម្រូវឱ្យបំពេញការងារ ដូចជាការ សម្ភាសជាមួយជនរងគ្រោះ អញ្ចឹងដែរ ។ ភាពស្មុគស្មាញ ដោយសារមានបញ្ហាជាច្រើន ពាក់ព័ន្ធទៅនឹងបណ្តឹងចោទប្រកាន់ និងពេលវេលាដែលមានការពាក់ព័ន្ធ អ្នកសម្ភាសអាចបង្កើនសមត្ថភាពរបស់ខ្លួន បានតែតាមរយៈការដកបទពិសោធន៍លើការងារ ។

## XI. កំណត់ហេតុ

កំណត់ហេតុចុងក្រោយ គឺជាឯកសារសរសេរជាលាយលក្ខអក្សរ ឬជារបាយការណ៍ថតវីដេអូ ឬថតសំឡេងដែលបានទទួលពីជនសង្ស័យ ដោយរាប់បញ្ចូលទាំងការពិភាក្សាដែលកើតឡើងក្នុងពេលសម្ភាស ។ គោលបំណងនៃកំណត់ហេតុ គឺដើម្បីធ្វើឱ្យជនសង្ស័យប្រាប់ព័ត៌មានលម្អិតពីបទល្មើសដែលខ្លួនបានទទួលស្គាល់ការពិត ឬកំណត់ហេតុដែលបានធ្វើក្នុងអំឡុងពេលសម្ភាស ។

កំណត់ហេតុនេះត្រូវបានប្រើនៅក្នុងសវនាការព្រហ្មទណ្ឌ ឬរដ្ឋប្បវេណី ។

### ១. បែបបទនៃកំណត់ហេតុ

**ក. កំណត់ហេតុជនសង្ស័យ** អាចត្រូវបានធ្វើតាមបែបបទមួយក្នុងចំណោមបែបបទពីរគឺ ៖

- បែបបទទីមួយ បដិសេធការជាប់ពាក់ព័ន្ធ ប៉ុន្តែដំណាលប្រាប់ការដោះសាររបស់គាត់ ឬស្ថានការណ៍ជុំវិញឧប្បត្តិហេតុ ។
    - នៅពេលព័ត៌មាននេះ ត្រូវបានធ្វើកំណត់ហេតុជាឯកសារ ជនសង្ស័យដែលមានកំហុសមិនងាយស្រួលក្នុងការផ្លាស់ប្តូររឿងរ៉ាវរបស់ខ្លួនទេ
    - ដោយការធ្វើឱ្យជនសង្ស័យប្រាប់ព័ត៌មានលម្អិត ពីស្ថានការជុំវិញព្រឹត្តិការណ៍នៃបទល្មើស ការស៊ើបអង្កេតត្រូវធ្វើឡើងដោយយកចិត្តទុកដាក់យ៉ាងច្បាស់លើការបង្ហាញ ឬការមិនបង្ហាញថាពិតនូវព័ត៌មានដែលមាននៅក្នុងកំណត់ហេតុ ។
- បែបបទទីពីរនៃកំណត់ហេតុរបស់ជនសង្ស័យគឺការទទួលស្គាល់កំហុសរបស់ខ្លួន
    - ពិពណ៌នាលម្អិតនៃការទទួលស្គាល់ការពិត និងកត្តាផ្សំចាំបាច់ដើម្បីបង្ហាញថា បទល្មើសពិតជាកើតមាន គឺត្រូវបានសរសេរបញ្ចូលក្នុងកំណត់ហេតុនេះ
    - ការទទួលស្គាល់ការពិតពីកំហុស ដែលត្រូវសរសេរជាលាយលក្ខអក្សរ ឬថតជាសំឡេង ឬវីដេអូ មានឥទ្ធិពលខ្លាំងលើអង្គសវនាការរបស់តុលាការ ។

**ខ. កំណត់ហេតុផ្ទាល់មាត់** អាចត្រូវសរសេរជាលាយលក្ខអក្សរខុសគ្នាក្នុងទម្រង់ផ្សេងៗ គឺ ៖

- ការរៀបរាប់បែបនិទាន ៖ ជារឿងហេតុដែលសរសេរផ្ទាល់ដៃ ដោយជនសង្ស័យតាមធម្មតា គឺជាជនសង្ស័យដំបូងដែលរៀបរាប់ពីសកម្មភាពនៅក្នុងឧប្បត្តិហេតុ
    - ជនសង្ស័យរៀបរាប់ពីឧប្បត្តិហេតុ ហើយចង្អុលបង្ហាញភស្តុតាងពីការជាប់ពាក់ព័ន្ធរបស់គាត់ជាមួយព័ត៌មានលម្អិត
    - ពិពណ៌នាបែបនិទានមានធាតុផ្សំនៃបទល្មើស ករណីខ្លះ វារួមបញ្ចូលអារម្មណ៍ផ្ទាល់ខ្លួនរបស់ជនសង្ស័យនៅក្នុងឧប្បត្តិហេតុ ។
- សំណួរ និងចម្លើយ
    - នៅក្នុងកំណត់ហេតុសំណួរ និងចម្លើយ អ្នកសម្ភាសសរសេរដោយដៃទៅតាមគំរូលិខិត នូវប្រភេទសំណួរបន្តបន្ទាប់គ្នាដែលជនសង្ស័យធ្វើការឆ្លើយតប
    - ទម្រង់នេះអនុញ្ញាតឱ្យជនសង្ស័យឆ្លើយតប ចំពោះព័ត៌មានលម្អិតជាក់លាក់ នៃឧប្បត្តិហេតុ
    - ទម្រង់សំណួរ និងចម្លើយ អនុញ្ញាតឱ្យអ្នកសម្ភាសបញ្ជាក់ឱ្យបានច្បាស់ ពីចំណុចទាំងឡាយដែលមិនទាន់ច្បាស់នៅក្នុងកំណត់ហេតុបែបនិទានរបស់ជនសង្ស័យ ។
- កំណត់ហេតុផ្លូវការ
    - ក្នុងរឿងក្តីដែលមានភាពធ្ងន់ធ្ងរ ជារឿងសំខាន់ កំណត់ហេតុផ្លូវការគួរតែទទួលបាន
    - កំណត់ហេតុផ្លូវការប្រើប្រាស់អ្នកយកព័ត៌មាននៅតុលាការ ឬក្រឡាបញ្ជី ដើម្បីកត់ត្រាសំណួរ និងចម្លើយរបស់ជនសង្ស័យ
    - ជាញឹកញាប់ កំណត់ហេតុផ្លូវការត្រូវតែទទួលបាន ទោះបីកំណត់ហេតុទាំងនោះវែងពេក ឬមានការលំបាកក្នុងការសរសេរដោយដៃ ក៏ដោយ ។
- កំណត់ហេតុធ្វើដោយថតវីដេអូ ឬថតសំឡេង
    - កំណត់ហេតុថតវីដេអូ ឬថតសំឡេង អាចធ្វើឱ្យមានចំណាប់អារម្មណ៍យ៉ាងខ្លាំងនៅពេលជំនុំជម្រះរឿងក្តី ពីព្រោះវាបង្ហាញពីជនសង្ស័យនូវពេលវេលានៃការឆ្លើយសារភាព
    - ជាទូទៅ កំណត់ហេតុនេះត្រូវតែបានយល់ព្រមឱ្យធ្វើពីជនសង្ស័យ ។

### ២. ការទទួលខុសត្រូវ ឬការគ្រប់គ្រងរបស់អ្នកសម្ភាស

- ដោយមិនគិតពីប្រភេទនៃកំណត់ហេតុដែលបានប្រើ អ្នកសម្ភាសត្រូវតែរក្សាការគ្រប់គ្រង ឬទទួលខុសត្រូវ ដើម្បីធានាអះអាងកំណត់ហេតុស្រង់យកចម្លើយ
- ការផ្តល់សំណួរនាំមុខដល់ជនសង្ស័យនឹងធានាការរាប់បញ្ចូលនូវពិពណ៌នាលម្អិត ពាក់ព័ន្ធដែលមានសារៈសំខាន់ ដើម្បីបង្ហាញភស្តុតាងរបស់ធាតុផ្សំនៃបទល្មើស
- អ្នកសម្ភាសត្រូវតែផ្តល់ឱ្យជនសង្ស័យ នូវកំណត់ហេតុផ្ទាល់មាត់ និងសរសេរជាលាយលក្ខអក្សរ រួចអានឱ្យជនសង្ស័យស្តាប់ ។

### ៣. ការកំណត់ពេលវេលាសម្រាប់ធ្វើកំណត់ហេតុ

- កំណត់ហេតុរបស់ជនសង្ស័យត្រូវតែធ្វើឡើងភ្លាម នៅពេលមានសេចក្តីសន្និដ្ឋានពី

ការសម្ភាស

- អ្នកសម្ភាស ត្រូវតែទទួលបាននូវកំណត់ហេតុសរសេរជាលាយលក្ខអក្សរ ដោយមិនចាកចេញពីបន្ទប់សម្ភាស
- នៅពេលជនសង្ស័យយល់ព្រមសរសេរកំណត់ហេតុ អ្នកសម្ភាសត្រូវតែប្រគល់ក្រដាស ឬបែបបទដែលមានសារៈសំខាន់ឱ្យជនសង្ស័យដើម្បីបំពេញ ។

**៤. បញ្ហាដែលត្រូវយកចិត្តទុកដាក់**

- ជនសង្ស័យចោទថា កំណត់ហេតុ គឺត្រូវគេហៅឱ្យគាត់សរសេរ
  - ជាញឹកញាប់ ជនសង្ស័យនឹងនិយាយថាគាត់បានសរសេរ តែអ្វីដែលគាត់ត្រូវបានហៅឱ្យសរសេរ
  - អ្នកសម្ភាសគួរជៀសវាងណែនាំពាក្យទាំងឡាយ ដែលមិនត្រូវបានប្រើជាទូទៅ ឱ្យជនសង្ស័យ ។
- ជនសង្ស័យនិយាយថា គាត់មិនអាចអាន ឬសរសេរបានទេ
  - នៅក្នុងស្ថានភាពខ្លះ ជនសង្ស័យអាចអះអាងថា គាត់មិនអាចសរសេរ ឬអានបានទេ ដើម្បីគេចវេសពីការសរសេរកំណត់ហេតុ
  - អ្នកសម្ភាសអាចសរសេរកំណត់ហេតុជំនួសឱ្យជនសង្ស័យ ប៉ុន្តែដាច់ខាតត្រូវតែត្រួតពិនិត្យកំណត់ហេតុនោះម្តងទៀតជាមួយជនសង្ស័យ ។
- ការកត់ត្រាកំណត់ហេតុអាចត្រូវបានសង្ស័យៈ អ្នកសម្ភាសដែលប្រើប្រាស់ការកត់ត្រាកំណត់ហេតុដោយអេឡិចត្រូនិក គួរតែប្រមើលថាវាអាចកើតមានបញ្ហា
- ជនសង្ស័យចោទថា គាត់មិនត្រូវបានប្រាប់ឱ្យដឹងអំពីសិទ្ធិរបស់គាត់
  - នៅក្នុងករណីដែលជនសង្ស័យស្ថិតក្នុងការឃាត់ខ្លួន ក្នុងនីតិវិធីគឺតម្រូវឱ្យប្រាប់អំពីសិទ្ធិ ហើយត្រូវរាប់បញ្ចូលជាផ្នែកមួយនៃកំណត់ហេតុជាលាយលក្ខអក្សរ
  - ដោយបានរាប់បញ្ចូលការប្រាប់អំពីសិទ្ធិនៅក្នុងចម្លើយសារភាព អ្នកសម្ភាសអះអាងថែមទៀតថា ជនសង្ស័យបានយល់អំពីសិទ្ធិរបស់គាត់ ។
- ជនសង្ស័យចោទថា មានការបង្ខិតបង្ខំនៅក្នុងការធ្វើកំណត់ហេតុ
  - អ្នកសម្ភាសអាចសុំឱ្យជនសង្ស័យឆ្លើយតបថា គាត់ ( ជនសង្ស័យ ) មិនត្រូវបានបង្ខិតបង្ខំដោយមធ្យោបាយណាមួយឱ្យសរសេរកំណត់ហេតុ ។ ដូច្នេះជនសង្ស័យមិនអាចចោទថាមានការបង្ខិតបង្ខំឡើយ
  - អ្នកសម្ភាសស្នើឱ្យជនសង្ស័យទទួលស្គាល់ដោយមាត់ទទេថា កំណត់ហេតុ គឺពិតជាត្រឹមត្រូវ
  - អ្នកសម្ភាសត្រូវប្រាប់ជនសង្ស័យ អំពីសកម្មភាពរបស់ខ្លួនក្នុងអំឡុងពេលសម្ភាស ។
- ជនសង្ស័យមិនទទួលស្គាល់ការពិតពីធាតុផ្សំ ឬព័ត៌មានលម្អិតនៃបទល្មើស ៖ ករណីនេះ អ្នកសម្ភាសត្រូវតែចុះនិទ្ទេសនៅរឹមទំព័រនៃកំណត់ហេតុ នូវចំណុចដែលជនសង្ស័យសុំកែតម្រូវ ។

### ៥. ការធ្វើកំណត់ហេតុ

- សេចក្តីណែនាំ ត្រូវតែរួមបញ្ចូលព័ត៌មានស្តីពីជីវប្រវត្តិអំពីជនសង្ស័យ
- ការទទួលស្គាល់ការពិត ត្រូវតែរួមបញ្ចូល ៖
    - ការទទួលស្គាល់ការពិតរបស់ជនសង្ស័យ ថាខ្លួនឯងបានប្រព្រឹត្តបទល្មើស
    - ការទទួលស្គាល់ការពិតតាំងពីដំបូងថា ខ្លួនឯងជាប់ពាក់ព័ន្ធក្នុងបទល្មើស រួមមានជាតុផ្សំនៃភស្តុតាង ប៉ុន្តែ មានកង្វះខាតនូវព័ត៌មានលម្អិតនៃការទទួលស្គាល់ ។ ការទទួលស្គាល់នេះត្រូវបានធ្វើឡើងសម្រាប់ហេតុផលជាច្រើន
    - ការធ្វើឱ្យជនសង្ស័យទទួលស្គាល់ការពិតទាំងស្រុងចំពោះបទល្មើស រៀបចំឱ្យមានភស្តុតាងសម្រាប់សំអាងនៅពេលក្រោយ
    - ការទទួលស្គាល់ ផ្តល់ផងដែរដល់អង្គជំនុំជម្រះ នូវឱកាសដើម្បីស្តាប់ការទទួលស្គាល់ដំបូង ។
- សំអាង
    - នៅក្នុងផ្នែកនេះ ជនសង្ស័យត្រូវបានស្នើសុំឱ្យបង្ហាញភស្តុតាង ចំពោះការទទួលស្គាល់ដោយមានព័ត៌មានលម្អិតនៃបទល្មើស
    - នៅដំណាក់កាលនេះ អ្នកសម្ភាសស្នើសុំជនសង្ស័យឱ្យធ្វើកំណត់ហេតុអំពីព័ត៌មានលម្អិតជាក់លាក់នៃឧប្បត្តិហេតុ (ស្ម័យសារភាព)
    - ក្នុងសំអាង អាចរួមបញ្ចូលនូវ អត្តសញ្ញាណភស្តុតាង រូបភាព ឬឯកសាររបស់ជនសង្ស័យ ។
- ការស្ម័គ្រចិត្ត
    - ជនសង្ស័យគួរតែទទួលស្គាល់ថា គាត់បានប្រាប់ការពិត
    - ជនសង្ស័យ គួរតែទទួលស្គាល់ផងដែរថា ខ្លួនកំពុងធ្វើកំណត់ហេតុដោយសេរីតាមឆន្ទៈផ្ទាល់ខ្លួន
    - អ្នកសម្ភាសត្រូវតែធ្វើការបញ្ជាក់ឱ្យកាន់តែច្បាស់ថែមទៀត នូវការចាំបាច់ដែលពាក់ព័ន្ធនឹងកំណត់ហេតុនៅពេលវេលានោះ ។
- ហត្ថលេខា ឬផ្តិតមេដៃស្តាំ និងការកែតម្រូវពាក្យ
    - នៅពេលជនសង្ស័យ បានបំពេញកំណត់ហេតុត្រង់ផ្នែកបែបនិទានណាមួយ ដោយបានបញ្ចូលសំអាង និងបានទទួលស្គាល់ឆន្ទៈនៃកំណត់ហេតុដោយស្ម័គ្រចិត្តហើយ ជនសង្ស័យ និងអ្នកសម្ភាស ត្រូវចុះហត្ថលេខា ឬផ្តិតមេដៃស្តាំលើកំណត់ហេតុ
    - អ្នកសម្ភាសគួរតែសួរជនសង្ស័យថា តើគាត់មានអ្វីផ្សេងទៀតចង់បន្ថែម ទៅលើកំណត់ហេតុដែរឬទេ ?
    - ដើម្បីជានាកុំឱ្យបាត់ទំព័រណាមួយ អ្នកសម្ភាសត្រូវតែចុះលេខទំព័រនីមួយៗ
    - គ្រប់កំណត់ហេតុទាំងអស់ មុននឹងចុះហត្ថលេខា ឬផ្តិតមេដៃស្តាំ អ្នកសម្ភាសត្រូវ

អានឱ្យជនសង្ស័យស្តាប់ ឬអនុញ្ញាតឱ្យជនសង្ស័យអានដោយផ្ទាល់ខ្លួនឯងចំពោះចម្លើយរបស់ខ្លួនក្នុងដំណាក់កាលនេះ ក្នុងករណីឯកភាព ជនសង្ស័យត្រូវចុះហត្ថលេខា ឬផ្តិតមេដៃស្តាំលើទំព័រនីមួយៗនៃកំណត់ហេតុ ។ ក្នុងករណីមិនឯកភាពត្រង់ចំណុចណាមួយ ជនសង្ស័យស្នើសុំឱ្យអ្នកសម្ភាសកែតម្រូវត្រង់ចំណុចនោះ ។

- ការបញ្ចប់ការសម្ភាស ៖ នៅដំណាក់កាលនេះ គោលដៅរបស់អ្នកសម្ភាស គឺបញ្ចប់ការសម្ភាសដោយឥរិយាបថគួរសម និងមានវិជ្ជាជីវៈ ។
    - អ្នកសម្ភាស ដែលខកខានមិនបានបញ្ចប់ការសម្ភាស ដោយឥរិយាបថវិជ្ជាជីវៈ លទ្ធផលនៃការសម្ភាសធ្វើឱ្យជនសង្ស័យមិនចង់សហការ នៅពេលសម្ភាសលើកក្រោយ
    - អ្នកសម្ភាសគួរតែទុកនាមប័ណ្ណដែលមានសរសេរឈ្មោះ និងលេខទូរស័ព្ទរបស់ខ្លួនឱ្យទៅជនសង្ស័យ ហើយលើកទឹកចិត្តឱ្យជនសង្ស័យទូរស័ព្ទប្រាប់ខ្លួន ប្រសិនបើពួកគេនឹកឃើញព័ត៌មានផ្សេងទៀត
    - អ្នកសម្ភាសអាចត្រូវការចំណាយពេលវេលា ដើម្បីបន្តទំនាក់ទំនងស្និទ្ធស្នាលជាមួយជនសង្ស័យ និងស្វែងយល់ពីចំណាប់អារម្មណ៍ទូទៅរបស់ពួកគេ
    - ការចំណាយពេលវេលា ដើម្បីធ្វើឱ្យជនសង្ស័យប្រាប់ព័ត៌មានក្នុងចម្លើយសារភាពរបស់ខ្លួន ជាញឹកញាប់ ធានាដល់កិច្ចសហការលើកក្រោយរបស់ពួកគេ នៅពេលរឿងក្តីឡើងដល់តុលាការ
    - អ្នកសម្ភាសត្រូវជាអ្នកមានវិជ្ជាជីវៈ និងសុភាពរាបសារ ហើយមិនត្រូវខឹងទេ ទោះបីជាខ្លួនគ្មានសមត្ថភាពទទួលបានចម្លើយសារភាពក៏ដោយ
    - អ្នកសម្ភាស ត្រូវតែដឹងពីសេចក្តីត្រូវការនៃការរំជួលចិត្ត និងអារម្មណ៍របស់ជនសង្ស័យ ។ អ្នកសម្ភាសត្រូវតែគាំទ្រជនសង្ស័យ ហើយផ្តោតការយកចិត្តទុកដាក់លើអនាគតជាក់លាក់របស់ជនសង្ស័យ
    - នៅពេលជនសង្ស័យបានផ្តល់ការទទួលស្គាល់ការពិតទាំងស្រុងពីកំហុស និងធ្វើកំណត់ហេតុជាលាយលក្ខអក្សររួចហើយ អ្នកសម្ភាសគួរតែត្រៀមរៀបចំធ្វើការបង្ហាញណែនាំស្តីពីអង្គហេតុរឿងក្តី និងធ្វើរបាយការណ៍សំយោគជូនព្រះរាជអាជ្ញា ។

### មាត្រា ៩៣ នៃ ក្រមនីតិវិធីព្រហ្មទណ្ឌ ស្តីពីកំណត់ហេតុលើការស្តាប់ចម្លើយ

មន្ត្រីនគរបាលយុត្តិធម៌អាចហៅ និងនាំមកកាន់អង្គភាពរបស់ខ្លួននូវបុគ្គលគ្រប់រូប ដែលសង្ស័យថា បានចូលរួមក្នុងបទល្មើស ។ មន្ត្រីនគរបាលយុត្តិធម៌ធ្វើការស្តាប់ចម្លើយជនទាំងនោះ ។

- ការស្តាប់ចម្លើយនីមួយៗ ត្រូវមានធ្វើកំណត់ហេតុ ។
- កំណត់ហេតុត្រូវដកស្រង់តាមដោយត្រឹមត្រូវ នូវសេចក្តីរាយការណ៍របស់បុគ្គល ដែលផ្តល់ចម្លើយ ។
- ក្នុងករណីចាំបាច់មន្ត្រីនគរបាលយុត្តិធម៌ អាចរកអ្នកបកប្រែដែលស្បថថា និយាយការពិត

ស្របតាមជំនឿ ឬសាសនារបស់ខ្លួន ។ អ្នកបកប្រែមិនអាចជ្រើសរើសយកពីក្នុងចំណោមនគរបាលកងរាជអាវុធហត្ថ ឬបុគ្គលដែលទាក់ទិនក្នុងរឿងជាមួយគ្នាបានទេ ។

- ទំព័រនីមួយៗ នៃកំណត់ហេតុ ត្រូវចុះហត្ថលេខា ឬផ្តិតស្រាមមេដៃដោយបុគ្គល ដែលបានឆ្លើយ ។ មុននឹងចុះហត្ថលេខា ឬផ្តិតស្រាមដៃ បុគ្គលនោះត្រូវអានកំណត់ហេតុឡើងវិញ ។ ក្នុងករណីចាំបាច់ មន្រ្តីនគរបាលយុត្តិធម៌ត្រូវអានដោយសំឡេងខ្លាំងៗ នូវខ្លឹមសារកំណត់ហេតុ ។
- មន្រ្តីនគរបាលយុត្តិធិម៌អាចហៅរកអ្នកបកប្រែបាន ។

កាលណាបុគ្គលនោះមិនព្រមចុះហត្ថលេខា ឬមិនព្រមផ្តិតស្រាមដៃទេ មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុ ៕

ឥឥឥ ✸ ៙៙៙

# ឯកសារយោង


- ឯកសារមេរៀនរបស់អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ ២០០៣
  - Bourg, Wendy et al; *A Child Interviewer's Guidebook*, Thousand Oaks, CA: Sage Publications, 1999
  - Goodman, Gail; Bottoms, Bette; *Child Victims, Child Witnesses: Understanding and Improving Testimony*, New York, NY: The Guilford Press, 1993
  - Mapes, Bruce; *Child Eyewitness Testimony in Sexual Abuse Investigations*, Brandon, VT: Clinical Psychology Publishing Co., 1995
  - Milne, Rebecca; Bull, Ray; *Investigative Interviewing: Psychology and Practice*, Chichester, West Sussex, UK: John Wiley & Sons Press, 1999
  - Morgan, Marcia; *How to Interview Sexual Abuse Victims Including the Use Of Anatomical Dolls*, Thousand Oaks, CA: Sage Publications, 1995
  - Poole, Debra A; *Investigative Interviews of Children: A Guide for Helping Professionals*, Washington, DC: American Psychological Association, 1998
  - Schafer, John; Navarro, Joe; *Advanced Interviewing Techniques: Proven Strategies for Law Enforcement, Military, and Security Personnel*, Springfield. IL: Thomas Books, 2003
  - Shuy, Roger W.; *The Language of Confession, Interrogation, and Deception*, Thousand Oaks, CA: Sage Publications, 1998
  - Swanson, Charles R. et al; *Criminal Investigation*, Boston, MA: McGraw Hill Publications, 2003, 8th edition
  - Yeschke, Charles; *The Art of Investigative Interviewing: A Human Approach to Testimonial Evidence*, Boston, MA: Butterworth-Heinemann Press, 1997

**MANUALS USED**

  - Faller, Kathleen C.; *Child Sexual Abuse: Intervention and Treatment Issues*, U.S. Department of Health and Human Services Administration for Children and Families, McLean, VA: The Circle, Inc, 1993
  - Ministry of Interior, General Director of National Police, Kingdom of Cambodia; *Understanding and Investigating Child Sexual Exploitation*, Law Enforcement Against Sexual Exploitation and Trafficking of Children Project, 2000
  - Ministry of Interior, General Director of National Police, Kingdom of Cambodia; *Training Document on Child Victim Sensitivity*, Law Enforcement Against Sexual Exploitation and Trafficking of Children Project, 2003
  - Sas, Louise; *The Interaction Between Children's Developmental Capabilities and the Courtroom Environment: The Impact on Testimonial Competency*, Report prepared for the Department of Justice Canada, 2002

**OTHER MATERIALS USED**

  - U. S. Department of State Trafficking in Persons Report, 2004

**WEB SITES USED**

  - HTTP://www.childdevelopmentinfo.com/development/language_development.shtml
  - HTTP://www.families.qld.gov.au/projectaxis/orgbooklet/development.html
  - HTTP://danenet.wicip.org/dcccrsa/saissues/parent/1.html
  - HTTP://www.aacap.org/publications/factsfam/develop.htm
  - HTTP://www.secasa.com.au/index.php/family/12/120
  - HTTP://www.earlychildhoodbehavioralhealth.com/ChildDev/sexdevelop.htl
  - HTTP://www.ces.perdue.edu/providerparent/Child%20Growth-Development/SexualDEV.htm
  - HTTP://www.state.gov/g/tip/rls/tiprpt/2004/34021pf.htm

- ឯកសារមេរៀនរបស់ ARTIP ២០០៩ ។

# បណ្ឌិត្យសភានគរបាលកម្ពុជា

## កម្មវិធីបណ្តុះបណ្តាលនគរបាលជាតិ

# ការកំណត់
# អត្តសញ្ញាណ និងការប្រព្រឹត្ត
# នៅលើជនរងគ្រោះដោយអំពើជួញដូរមនុស្ស

២០១៧

សូមរក្សាសិទ្ធិ

មេរៀននេះមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់អង្គការវីនរ៉ក់ ឬរដ្ឋាភិបាលអាមេរិក

# ការកំណត់អត្តសញ្ញាណ និងការប្រព្រឹត្តិ
# ទៅលើជនរងគ្រោះដោយអំពើជួញដូរមនុស្ស

## សេចក្តីផ្តើម

វិធីសាស្ត្រនៃការកំណត់អត្តសញ្ញាណជនរងគ្រោះ គឺជាការគ្រប់គ្រងទៅលើដំណើរការ និងពិនិត្យពីការប្រឈមរបស់មន្ត្រីអនុវត្តច្បាប់ នៅពេលដែលខ្លួនព្យាយាមកំណត់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលទទួលរងនូវការប៉ះពាល់លើរូបរាងកាយ និងផ្លូវចិត្ត ។

គោលបំណងនៃមេរៀននេះ គឺពិនិត្យទៅលើប្រភេទនៃបញ្ហាដែលមានភាពស្មុគស្មាញ ដើម្បីធ្វើការកំណត់ និងការប្រព្រឹត្តិឱ្យបានត្រឹមត្រូវ ចំពោះជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការបែងចែកជនរងគ្រោះដោយអំពើជួញដូរមនុស្ស ជនដែលត្រូវគេរត់ពន្ធ ឬជនដែលធ្វើចំណាកស្រុកដោយខ្លួនឯង ។

## I. ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស

### ១. ស្តង់ដារអន្តរជាតិ

គោលការណ៍ និងសេចក្តីណែនាំរបស់អង្គការសហប្រជាជាតិ ស្តីពីសិទ្ធិមនុស្ស និងការជួញដូរមនុស្ស ទទួលស្គាល់ថា ការកំណត់ជនណាម្នាក់ថាជា ជនរងគ្រោះដោយអំពើជួញដូរមនុស្ស គឺជាជំហានដំបូងនៃការទទួលស្គាល់សិទ្ធិរបស់ពួកគេ ។ ជួនកាល វាមានភាពងាយស្រួលចំពោះរដ្ឋ ក្នុងការប្រមូលបញ្ចូលគ្នារាល់ជនចំណាកស្រុកទាំងអស់ ទោះបីជាគ្មានឯកសារបញ្ជាក់ជា "ជនចំណាកស្រុកខុសច្បាប់" ឬ "ជនដែលត្រូវគេរត់ពន្ធ" ក៏ដោយ ។ ការកំណត់ជនណាជាជនដែលត្រូវគេជួញដូរ គឺជាការងារលំបាក ហើយតម្រូវឱ្យមានយុទ្ធសាស្ត្រជាលក្ខណៈអាជីពច្រើន ពីមន្ត្រីអនុវត្តច្បាប់ និងដៃគូរបស់ខ្លួន ។ ការទទួលស្គាល់នូវភាពចាំបាច់នៃដំណើរការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្សមានសារៈសំខាន់ក្នុងការធានាយុត្តិធម៌ដល់ជនរងគ្រោះ ។

គោលការណ៍ទី១ ៖ ការកំណត់ជនណាជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងជនជួញដូរ

- ការជួញដូរមនុស្ស មានន័យច្រើនជាងការបន្លាស់ទីមនុស្ស ដោយទទួលបានអត្ថប្រយោជន៍ ។ កត្តាបន្ថែមសំខាន់គឺថា ការបែងចែកពីភាពខុសគ្នារវាង ការជួញដូរមនុស្ស និងការរត់ពន្ធមនុស្ស គឺតម្រូវឱ្យមានការបង្ហាញតាមរយៈ ការប្រើកម្លាំង ការបង្ខំ និង/ឬការបោកប្រាស់ ឬនៅដំណាក់កាលខ្លះនៃដំណើរការជួញដូរ ដែលប្រើប្រាស់ក្នុងគោលបំណងកេងប្រវ័ញ្ច ។ ទោះបីជាការបន្ថែមធាតុផ្សំខ្លះ ដែលធ្វើឱ្យមានភាពខុសគ្នាយ៉ាងច្បាស់រវាង ការជួញដូរមនុស្ស និងការរត់ពន្ធមនុស្សក៏ដោយ ក៏នៅក្នុងរឿងក្តីជាច្រើន បានធ្វើឱ្យមានការលំបាកក្នុងការបែងចែកភាពខុសគ្នា ។ បញ្ហានេះតម្រូវឱ្យមានការស៊ើបអង្កេត ។ ការមិនបានកំណត់ ជនណាម្នាក់ថាជាជនរងគ្រោះ ឱ្យបានត្រឹមត្រូវ គឺអាចនាំឱ្យមានការបដិសេធសិទ្ធិរបស់ពួកគេ ដែលមាននៅពេលខាងមុខ ។ ដូចនេះ រដ្ឋត្រូវមាន

កាតព្វកិច្ច ធានាថា ការកំណត់ជនណាម្នាក់ថាជាជនរងគ្រោះ គឺអាចធ្វើទៅបាន

- រដ្ឋទាំងអស់ត្រូវមានកាតព្វកិច្ច ក្នុងការកំណត់ឱ្យបានត្រឹមត្រូវនូវជនណាម្នាក់ថាជា ជនជួញដូរមនុស្ស រួមទាំងជនដែលមានការពាក់ព័ន្ធទៅនឹងការគ្រប់គ្រង និងការកេងប្រវ័ញ្ច លើជនដែលត្រូវគេជួញដូរ
- បើអាចធ្វើទៅបាន រដ្ឋ អង្គការជាតិ អន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាល គួរតែពិចារណាទៅលើ ៖
    - បង្កើតគោលការណ៍ និងនីតិវិធីដល់អាជ្ញាធររដ្ឋ និងមន្ត្រីពាក់ព័ន្ធ ដូចជា មន្ត្រីនគរបាល អ្នកការពារព្រំដែន មន្ត្រីអន្តោប្រវេសន៍ និងអ្នកដែលពាក់ព័ន្ធ ក្នុងការស្វែងរក ឃុំឃាំង ទទួល និងចាត់វិធានការទៅលើចំណាកស្រុកខុសច្បាប់ ដើម្បីឱ្យអ្នកទាំងនោះ អាចកំណត់ឱ្យបានឆាប់ និងមានភាពពិតប្រាកដ ថាតើជនណាម្នាក់ត្រូវបានគេជួញដូរដែរឬទេ
    - ផ្តល់ការបណ្តុះបណ្តាលសមរម្យដល់អាជ្ញាធរ និងមន្ត្រីពាក់ព័ន្ធ នៅក្នុងការកំណត់ជនដែលត្រូវគេជួញដូរ និងអនុវត្តឱ្យបានត្រឹមត្រូវលើគោលការណ៍ និងនីតិវិធីខាងលើ
    - ធានាឱ្យមានកិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរ មន្ត្រី និងអង្គការក្រៅរដ្ឋាភិបាល ដើម្បីសម្របសម្រួលលើការកំណត់ និងផ្តល់ជំនួយដល់ជនដែលត្រូវគេជួញដូរ ។ ការរៀបចំ និងការអនុវត្តលើកិច្ចសហប្រតិបត្តិការបែបនេះ គួរតែធ្វើឡើង ដើម្បីបង្កើននូវប្រសិទ្ធភាពរបស់ខ្លួន
    - កំណត់ពីកិច្ចអន្តរាគមន៍សមស្រប ដើម្បីធានាថា ជនចំណាកស្រុក ត្រូវបានគេព្រមានអំពីភាពដែលអាចកើតមានគ្រោះថ្នាក់ និងផលវិបាកនៃការជួញដូរមនុស្ស និងការទទួលព័ត៌មានដែលអាចធ្វើឱ្យគេរកអ្នកជួយបាន ប្រសិនបើស្ថានភាពតម្រូវ
    - ធានាថា ជនដែលត្រូវគេជួញដូរ មិនត្រូវបានចោទប្រកាន់ពីការរំលោភច្បាប់អន្តោប្រវេសន៍ ឬពីសកម្មភាពដែលខ្លួនពាក់ព័ន្ធ ដែលស្ថិតនៅក្នុងស្ថានភាពជាអ្នកដែលត្រូវគេជួញដូរ
    - ធានាថា ជនដែលត្រូវគេជួញដូរ នៅក្នុងស្ថានភាពណាក៏ដោយ មិនត្រូវបានគេឃុំខ្លួនពីបទឆ្លងដែនខុសច្បាប់ ឬទម្រង់ផ្សេងៗទៀតនៃការឃុំឃាំង
    - ធានាថា មាននីតិវិធី និងដំណើរការ សម្រាប់ទទួល និងពិចារណាទៅលើសំណើសុំសិទ្ធិជ្រកកោនពីជនដែលត្រូវគេជួញដូរ និងអ្នកដែលត្រូវគេរត់ពន្ធ ដើម្បីស្វែងរកសិទ្ធិជ្រកកោន និងគោលការណ៍មិនបញ្ជូនមកព្រំដែនវិញ ត្រូវបានគោរព និងយល់ព្រម គ្រប់ពេលវេលា ។

(ប្រភពឯកសាររបស់ឧត្តមស្នងការរបស់អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស-UNHCHR)

**២. ស្តង់ដារអាស៊ាន**

រដ្ឋសមាជិកអាស៊ានបានដោះស្រាយផងដែរ ទៅលើបញ្ហានៃការកំណត់ឱ្យឃើញ និងការប្រព្រឹត្តទៅលើជនរងគ្រោះដោយអំពើជួញដូរមនុស្សតាមរយៈសេចក្តីប្រកាសរបស់ខ្លួននៅឆ្នាំ២០០៤។

សេចក្តីប្រកាសអាស៊ានស្តីពីការប្រឆាំងអំពើជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ

- ដើម្បីបែងចែកភាពខុសគ្នារវាងជនរងគ្រោះដោយអំពើជួញដូរមនុស្ស ពីជនប្រព្រឹត្តបទល្មើស និងកំណត់ឱ្យឃើញពីប្រទេសប្រភព និងសញ្ជាតិ របស់ជនរងគ្រោះទាំងនេះ ហើយបន្ទាប់មកធានាថា ជនរងគ្រោះនេះត្រូវទទួលបាននូវការប្រព្រឹត្តទៅលើពួកគេជាលក្ខណៈមនុស្សធម៌ និងផ្តល់

កិច្ចគាំពារសំខាន់ៗ ផ្នែកវេជ្ជសាស្ត្រ និងទម្រង់ដទៃទៀតនៃកិច្ចគាំពារ ដែលមានលក្ខណៈសមស្រប ទៅនឹងប្រទេសទទួល រួមមាន ការធ្វើមាតុភូមិនិវត្តន៍ភ្លាម ទៅប្រទេសកំណើតពួកគេ (ចំណុចទី៥)

- ដើម្បីចាត់វិធានការក្នុងការគោរព រក្សាសេចក្ដីថ្លៃថ្នូរ និងសិទ្ធិមនុស្ស របស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស (ចំណុចទី៦)

ការឆ្លើយតបរបស់ប្រព័ន្ធយុត្តិធម៌អាស៊ាន ទៅលើការជួញដូរមនុស្ស - គោលការណ៍ណែនាំអាស៊ានសម្រាប់អ្នកអនុវត្តផ្ទាល់ ។

- តាមដែលអាចធ្វើទៅបាន ជនរងគ្រោះដោយអំពើជួញដូរមនុស្ស មិនត្រូវបានចោទប្រកាន់ ឬផ្តន្ទាទោសពីបទល្មើសដែលខ្លួនបានប្រព្រឹត្ត ហើយបទល្មើសទាំងនោះ គឺជាផលវិបាកដោយផ្ទាល់នៃអំពើជួញដូរមនុស្ស (គោលការណ៍ណែនាំ C.២) ។

### ៣. ផលប៉ះពាល់ នៃអំពើជួញដូរមនុស្ស

ជនរងគ្រោះដោយអំពើជួញដូរមនុស្សភាគច្រើន ដែលត្រូវបានគេកំណត់ និងជួយសង្គ្រោះនៅក្នុងបណ្តាប្រទេសសមាជិកអាស៊ាន និងតំបន់ផ្សេងទៀត ត្រូវបានរកឃើញមូលហេតុនៃការទទួលរងយ៉ាងធ្ងន់ធ្ងរផ្នែកសុខភាព ដែលគេហៅថា " វិបត្តិផ្លូវអារម្មណ៍"( Post Traumatic Stress Disorder – PTSD ) ។ លក្ខខណ្ឌនេះ បង្កឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរដល់សុខភាពផ្លូវចិត្ត និងការរស់នៅរបស់ជនរងគ្រោះ ជួនកាល មិនអាចធ្វើឱ្យជនរងគ្រោះត្រឡប់មកជាធម្មតាវិញបានឡើយ ។

កម្រិតគ្រោះថ្នាក់ខាងផ្លូវចិត្ត អាចមានអត្រាលើសពី ៥០ ភាគរយ នៃជនរងគ្រោះដែលត្រូវគេជួញដូរ ហើយការឈឺចាប់ខាងផ្លូវចិត្ត ជាធម្មតា បណ្តាលមកពី ៖

- ការបំពារបំពានលើរូបរាងកាយ
- ការបំពានខាងផ្លូវភេទ
- ការដកសិទ្ធិសេរីភាព
- ការដកសិទ្ធិក្នុងការជ្រើសរើស និងធ្វើអ្វីមួយ
- ការរស់នៅមិនមានលក្ខណៈជាមនុស្ស និងលក្ខខណ្ឌការងារ ដូចជាកង្វះអាហារូបត្ថម្ភ
- ផលប៉ះពាល់នៃការកេងប្រវ័ញ្ចរយៈពេលយូរ ។

ជាធម្មតា ការបញ្ចូលគ្នានៃកត្តាបំពារបំពាន ដូចបានកំណត់ខាងលើ បង្កើតឱ្យមានការថប់ផ្លូវអារម្មណ៍ កាន់តែធ្ងន់ធ្ងរឡើង ដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ហើយជួនកាលអាចមានផលប៉ះពាល់ អស់មួយជីវិត ទៅដល់សុខភាព និងការរស់នៅរបស់ជនរងគ្រោះទៀតផង ។

ការយល់ដឹងពីកត្តាទាំងអស់នេះ មានសារៈសំខាន់សម្រាប់មន្ត្រីស៊ើបអង្កេត ហើយប្រសើរជាងនេះទៀត គឺការពាក់ព័ន្ធរបស់មន្ត្រីស៊ើបអង្កេតទៅលើស្ថានភាពគន្លឹះទាំងពីរខាងក្រោម ៖

- ការកំណត់ជាលើកដំបូង ថាតើជនណាម្នាក់ជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស
- ការប្រព្រឹត្តិ និងការគ្រប់គ្រងទៅលើជនរងគ្រោះ ដែលទទួលរងនូវការប៉ះពាល់ផ្លូវអារម្មណ៍ ហើយជនរងគ្រោះនេះ គឺជាសាក្សីដ៏សំខាន់នៅក្នុងដំណើរការរឿងក្តីព្រហ្មទណ្ឌ ។

#### ក. តើការប៉ះពាល់ផ្លូវអារម្មណ៍គឺជាអ្វី?

នៅក្នុងករណីជាច្រើន ការកើតឡើងនៃលក្ខខណ្ឌនេះ គឺមានការពាក់ព័ន្ធទៅនឹងការប្រើ

ប្រាស់អំពើហិង្សាលើរូបរាងកាយ និងផ្លូវភេទ ដែលមានលក្ខណៈធ្ងន់ធ្ងរខ្លាំង ហើយបានធ្លាក់ទៅលើការរស់នៅជាជនរងគ្រោះ ។ ដូចនេះ ជនរងគ្រោះមិនអាចយល់ពីបញ្ហាដែលកើតមានចំពោះខ្លួន ឬជនរងគ្រោះអាចបដិសេធថា បញ្ហានេះមិនដែលធ្លាប់កើតមានចំពោះខ្លួនឡើយ ។

សញ្ញាណនៃការប៉ះពាល់ផ្លូវអារម្មណ៍ គឺជនរងគ្រោះមិនអាចបែងចែកអំពីអ្វី ដែលបានកើតឡើងចំពោះខ្លួន ហើយពុំមានលទ្ធភាពប្រតិកម្មទៅលើការបំពានដោយជនល្មើស និងអាចធ្វើឱ្យមានសញ្ញាណដទៃទៀត ៖

- ជនរងគ្រោះអាចថា បទពិសោធន៍នោះ "មិនមានពាក់ព័ន្ធនឹងខ្លួន" ហើយចាត់ទុកថា វាបានកើតឡើង ទៅលើអ្នកផ្សេងទៀតដូចគ្នាដែរ
- ជនរងគ្រោះមិនអាចចងចាំពេលវេលាដែលបានកន្លងទៅ
- ជនរងគ្រោះ អាចមានប្រតិកម្មទៅលើការបំពានមកលើខ្លួន ខុសពីប្រក្រតី ឬគ្មានអារម្មណ៍ ដែលបង្ហាញពីអង្គហេតុថា ខ្លួនមិនអាចដឹងការពិត ចំពោះការបំពារបំពាននោះទេ
- ជនរងគ្រោះអាចទទួលរងនូវការបាត់បង់ផ្នែកខ្លះនៃអារម្មណ៍ ស្មារតី និងភាពចងចាំ
- រោគសញ្ញាសំខាន់ផ្សេងទៀតនៃជំងឺផ្លូវអារម្មណ៍ គឺការកើតឡើងនៃអារម្មណ៍ចងចាំពីអតីតកាល ហើយធ្វើឱ្យខ្លួនឯងមានអារម្មណ៍ថា ខ្លួនកំពុងស្ថិតនៅក្នុងស្ថានភាពនោះម្តងទៀត ហើយការបំពារបំពានកំពុងតែមានមកលើខ្លួនពិតៗ ។ អារម្មណ៍បែបនេះ ជាញឹកញាប់ កើតឡើងដោយសារតែជនរងគ្រោះអសមត្ថភាពក្នុងការរៀបរាប់ពីរឿងរ៉ាវរបស់ខ្លួន ។ បញ្ហានេះអាចកើតឡើង ដោយសារមានបញ្ហាតែមួយគត់ ដូចជា ក្លិន សំឡេងពិសេសណាមួយ ឬវិញ្ញាណ ដែលទាក់ទងទៅនឹងអារម្មណ៍ការស្អប ឬរូបភាព ។

សង្ខេបមកវិញ បទពិសោធន៍នៃការធ្វើឱ្យប៉ះពាល់ផ្លូវអារម្មណ៍ គឺស្ថិតនៅរាប់ឆ្នាំ ហើយនៅក្នុងករណីខ្លះ បញ្ហានេះស្ថិតនៅអស់មួយជីវិតជនរងគ្រោះ ដោយសារបញ្ហានេះគ្រប់គ្រងលើផ្លូវចិត្ត ហើយអាចធ្វើឱ្យជនរងគ្រោះមានការឈឺចាប់ ភ័យខ្លាច អស់សង្ឃឹម ដែលបង្ហាញឱ្យជនរងគ្រោះ មានការស្រមើស្រមៃ សុបិន្ត ខឹងសម្បា និងមានជំងឺខាងផ្លូវចិត្តដែលមានអារម្មណ៍ពីអតីតកាល ។

ជនរងគ្រោះ អាចមិនចងចាំបាន និងមិនអាចរៀបរាប់ពីបទពិសោធន៍របស់ខ្លួន ឱ្យបានក្បោះក្បាយពីព្រឹត្តិការណ៍នៃការប៉ះទង្គិចផ្លូវអារម្មណ៍ ។ វាគឺជាការសំខាន់ ក្នុងការសម្គាល់ថា នៅក្នុងករណីជាច្រើន ជនរងគ្រោះមិនអាចចងចាំពីព្រិត្តិការណ៍ដែលកើតមានលើខ្លួនឡើយ ។ ជនរងគ្រោះអាចចងចាំបានតែទៅលើអ្វីដែលមិនមានការពាក់ព័ន្ធគ្នានៅក្នុងអារម្មណ៍ ។

**ខ. តើជនរងគ្រោះដោះស្រាយបញ្ហានៃការប៉ះពាល់ផ្លូវអារម្មណ៍យ៉ាងដូចម្តេច?**

វិធីដើម្បីដោះស្រាយជាមួយជនល្មើសជួញដូរមនុស្ស ៖ ជនដែលត្រូវបានគេជួញដូរ ត្រូវបង្ខំឱ្យស្ថិតនៅក្នុងស្ថានភាពកេងប្រវ័ញ្ច ដោយមានទំនាក់ទំនងជាមួយជនជួញដូរមនុស្ស នៅក្នុងរយៈពេលយូរ ។ ស្ថានភាពនេះធ្វើឱ្យមានការប៉ះពាល់ផ្លូវអារម្មណ៍ ដែលការប៉ះពាល់នេះមិនជាប់ពាក់ព័ន្ធព្រឹត្តិការណ៍តែមួយនៃអំពើហិង្សាខ្លាំងក្លានោះទេ ប៉ុន្តែការប៉ះពាល់នេះមានជាប់ពាក់ព័ន្ធទៅនឹងអំពើហិង្សាជាប្រព័ន្ធ ឬការបំពារបំពានរយៈពេលយូរ ដែលក្លាយទៅជាបញ្ហាគ្របដណ្តប់នៃអំពើហិង្សា ។ ផលវិបាកនេះ គឺថាជនរងគ្រោះមានពេលវេលាសម្របទៅនឹងអាកប្បកិរិយារបស់ជនជួញដូរមនុស្ស

ដើម្បីកាត់បន្ថយនូវគ្រោះថ្នាក់នៃការបំពារបំពានមកលើខ្លួនថែមទៀត ។ ទម្រង់នៃអាកប្បកិរិយាសម្រប ទៅនឹងជនល្មើស ជាធម្មតា គេហៅថា "វិធីសង្គ្រោះជីវិត" ដែលមាន ៖

- ការមិនមានប្រតិកម្ម (ការគេចវេស) - ជនរងគ្រោះនឹងធ្វើអ្វីៗតាមដែលអាចធ្វើទៅបាន ដើម្បីគេចវេសពីអំពើហិង្សា ឬការបំពាន ។ ឧទាហរណ៍៖ ជនរងគ្រោះអាចនៅស្ងៀម និងធ្វើទៅតាមការបញ្ជារបស់ជនជួញដូរមនុស្សទាំងស្រុង ឬនៅក្នុងករណីនៃការជួញដូរផ្លូវភេទ ជនរងគ្រោះអាចមើលទៅមានការពេញចិត្តនឹងការងារពេស្យាចារ ប៉ុន្តែតាមពិត អ្វីៗដែលពួកគេបានធ្វើ គឺដើម្បីបំពេញចិត្តភ្ញៀវ "មានការសប្បាយ" បានប្រាក់ និងដើម្បីឱ្យជនជួញដូរមនុស្ស មានការពេញចិត្ត
- អាកប្បកិរិយាដូចជនជួញដូរមនុស្ស - វិធីនេះ (ជួនកាលគេហៅថា រោគសញ្ញា Stockholm Syndrome ) ដែលកើតឡើងនៅពេលជនរងគ្រោះមានអារម្មណ៍ថា ខ្លួនមិនអាចទ្រាំទ្រនឹងអំពើហិង្សា ហើយជនរងគ្រោះត្រូវបានគេដាក់ឱ្យនៅឯកោ ដោយមិនអាចរត់គេចខ្លួនបានឡើយ ឬជួនកាលមានគ្រោះថ្នាក់ខ្លាំងណាស់ ហើយទោះបីជាមានអំពើហិង្សា និងការគំរាមកំហែង ជនរងគ្រោះដឹងថា ជនល្មើសនឹងមានប្រតិកម្មទៅនឹងអ្វីដែលជនរងគ្រោះបានធ្វើ ដូចនេះហើយ វាគឺជាការសំខាន់របស់ជនរងគ្រោះក្នុងការយកវិធីរស់ ដើម្បីធានាថា ខ្លួននឹងទទួលបាននូវការយល់ព្រម ពីជនជួញដូរមនុស្ស ។ ដើម្បីឱ្យខ្លួនមានលទ្ធភាពសម្រេចបាននូវគោលដៅនេះ ជនរងគ្រោះនឹងព្យាយាមធ្វើខ្លួនឱ្យដូចជនជួញដូរមនុស្ស ហើយសម្របគំនិត និងអារម្មណ៍របស់ខ្លួន ឱ្យដូចអ្វីដែលខ្លួនមានឆន្ទៈធ្វើមែន ។ ដូចនេះ ជនរងគ្រោះអាចកំណត់ និងសម្របទៅនឹងប្រភេទនៃអាកប្បកិរិយា ដែលជនល្មើសអាចទទួលយកបាន ។
    - ឧទាហរណ៍៖ បទពិសោធន៍កន្លងមកទាក់ទងទៅនឹងការកំណត់ជនណាម្នាក់ថា ជាជនរងគ្រោះ គឺជនរងគ្រោះតែងតែបដិសេធម្តងហើយម្តងទៀត ក្នុងកិច្ចសហការជាមួយមន្ត្រីអនុវត្តច្បាប់ ឬជនរងគ្រោះប្រើល្បិចផ្សេងៗ ដើម្បីកុំឱ្យមានការរំដោះខ្លួន ។ នៅក្នុងករណីខ្លះ ដំណើរការកំណត់ជនណាម្នាក់ថា ជាជនរងគ្រោះពិតប្រាកដ បានបង្ហាញនូវព័ត៌មាន ដែលមិនមានលក្ខណៈពិតប្រាកដ ទោះបីមានភស្តុតាងរឹងមាំថា ខ្លួនត្រូវបានគេជួញដូរក៏ដោយ ។ មូលហេតុ ដែលជនរងគ្រោះធ្វើដូចនេះ គឺដើម្បីឱ្យស្របទៅនឹងគោលបំណងរបស់ជនជួញដូរមនុស្ស
    - ជួនកាល ដំណើរការកំណត់ជនរងគ្រោះ គឺពិបាកជាងនេះទៀត ប្រសិនបើជនល្មើសធ្វើលេសជាអ្នកថែរក្សា និងយកចិត្តទុកដាក់ជនរងគ្រោះ ។ បញ្ហានេះ គឺជាការបន្ថែមឱ្យមានភាពស្មុគស្មាញ និងធ្វើឱ្យមានការបាត់បង់គោលដៅរបស់ជនរងគ្រោះ ហើយស្របពេលគ្នានេះ ថែមទាំងបង្កើនឱ្យជនរងគ្រោះមានសង្ឃឹមថា ខ្លួនអាចគ្រប់គ្រងស្ថានភាព និងជៀសវាងពីអំពើហិង្សា ដោយខ្លួនបានធ្វើត្រឹមត្រូវតាមការណែនាំរបស់ជនជួញដូរមនុស្ស ។
- អារម្មណ៍ស៊ាំនឹងស្ថានភាព - នៅទីបញ្ចប់ ជនរងគ្រោះដែលមានការសម្របសម្រួលខ្លួនខ្លាំងពេកទៅនឹងជនល្មើស បានធ្វើឱ្យជនរងគ្រោះ មិនមានការគិតដល់អារម្មណ៍ និងគំនិតរបស់ខ្លួន ហើយធ្វើឱ្យជនរងគ្រោះបាត់បង់ការគ្រប់គ្រងខ្លួនឯង និងកាត់បន្ថយអារម្មណ៍ដែលខ្លួនមាន ។ ឧទាហរណ៍ ភាពព្រងើយកន្តើយខ្លាំង ឬមិនមានការចាប់អារម្មណ៍ ទៅលើការឈឺចាប់របស់ខ្លួន គឺជាលក្ខណៈនៃវិធីនេះ ។

គ. តើជនរងគ្រោះរៀនដោះស្រាយ និងស្តារស្ថានភាព ពីផលប៉ះពាល់នៃការប៉ះទង្គិចផ្លូវអារម្មណ៍ បានដោយរបៀបណា?

ជនរងគ្រោះដែលជាសះស្បើយពីជំងឺប៉ះពាល់ផ្លូវអារម្មណ៍ គឺជាដំណើរការស្មុគស្មាញមួយ តម្រូវឱ្យជនរងគ្រោះចំណាយពេលវេលា និងមានការគាំទ្រចាំបាច់ជាពិសេសមួយ ដើម្បីរៀនដោះស្រាយពីជំងឺប៉ះពាល់ផ្លូវអារម្មណ៍ ។ ការមិនបានផ្តល់សេចក្តីត្រូវការនេះ ជនរងគ្រោះនឹងទទួលនូវជំងឺថប់ផ្លូវអារម្មណ៍ជាអចិន្ត្រៃយ៍ និងធ្ងន់ធ្ងរ ។

សង្ខេបមកវិញ មានដំណាក់កាល ៤ យ៉ាង ដែលធ្វើឱ្យជនរងគ្រោះជាសះស្បើយ ៖

- កុំធ្វើឱ្យប៉ះពាល់អារម្មណ៍ជនរងគ្រោះ ជាពិសេស ការប្រព្រឹត្តរបស់មន្ត្រីអនុវត្តច្បាប់
- ធ្វើការពន្យល់ និងណែនាំអំពីអនាគត
- ការស្តារ និងចងចាំឡើងវិញ
- ការធ្វើសមាហរណកម្មទៅក្នុងសង្គម ។

ព្រំដែន និងពេលវេលានៃប្រភេទទាំង ៤ នេះ គឺមិនងាយដឹងច្បាស់លាស់នោះទេ ហើយជនរងគ្រោះ អាចមានការផ្លាស់ប្តូរ នៅក្នុងដំណាក់កាលទាំង ៤ នៅក្នុងពេលវេលាផ្សេងៗនៃដំណើរការជាសះស្បើយ ។

**៤. ជំងឺផ្លូវអារម្មណ៍ជះឥទ្ធិពលដល់អ្នកធ្វើសម្ភាស និងមន្ត្រីស៊ើបអង្កេត**

ប្រភេទផ្សេងៗនៃរោគសញ្ញា បង្ហាញដោយជនរងគ្រោះពីផលប៉ះពាល់ផ្លូវអារម្មណ៍ គឺមានការពាក់ព័ន្ធច្រើនទៅនឹងលទ្ធភាពរបស់មន្ត្រីអនុវត្តច្បាប់ ក្នុងការកំណត់ ថាតើជនណាម្នាក់ជាជនរងគ្រោះដោយអំពើជួញដូរមនុស្សពិតប្រាកដ និងធ្វើការងារជាមួយពួកគេជាលក្ខណៈអាជីព និងមនុស្សធម៌ពិសេសចំពោះរឿងក្តីទាំងឡាយណាដែលជនរងគ្រោះស្ម័គ្រចិត្តធ្វើជាសាក្សី ។

រោគសញ្ញាសំខាន់ៗនៃជំងឺប៉ះពាល់ផ្លូវអារម្មណ៍ ដែលអាចមានការប៉ះពាល់ខ្លាំងគឺ ៖

- ជនរងគ្រោះដែលទទួលរងនូវការប៉ះពាល់ផ្លូវអារម្មណ៍ ជួនកាលបដិសេធថា គាត់មិនត្រូវបានគេជួញដូរ ទោះបីជាមានភស្តុតាងផ្ទុយយ៉ាងណាក៏ដោយ
- ជនរងគ្រោះអាចមានបទពិសោធន៍ទទួលរងគ្រោះ ហើយលំបាកក្នុងការផ្តល់ចម្លើយឱ្យបានច្បាស់លាស់ និងស៊ីចង្វាក់ទៅដល់មន្ត្រីស៊ើបអង្កេត ។ ជនរងគ្រោះអាចមានការលំបាកក្នុងការចងចាំអ្វីដែលបានកើតឡើង
- ជនរងគ្រោះខ្លួនឯង មិនដឹងហេតុអ្វីបានជា ខ្លួនមិនអាចចងចាំពីព្រឹត្តិការណ៍ ដែលធ្វើឱ្យគាត់មានការប៉ះពាល់ផ្លូវអារម្មណ៍ ដូចនេះជនរងគ្រោះអាចមានបំណងបំពេញបន្ថែមនូវអ្វីដែលមានការខ្វះចន្លោះនៅក្នុងការចងចាំរបស់គាត់ ដែលស្ថិតនៅក្នុងស្ថានភាពទទួលរងនូវការប៉ះពាល់ផ្លូវអារម្មណ៍ ដែលធ្វើឱ្យចម្លើយរបស់គាត់មានភាពផ្ទុយទៅនឹងភស្តុតាង ។

រោគសញ្ញាមួយ ឬទាំងអស់ មានការពាក់ព័ន្ធយ៉ាងខ្លាំងទៅនឹង ៖

- ការកំណត់ជនណាម្នាក់ជាជនរងគ្រោះ នៅក្នុងដំណាក់កាលដំបូង
- លទ្ធភាពរបស់ពួកគេក្នុងការសម្រេចចិត្ត ថាតើត្រូវសហការ ឬមិនត្រូវសហការជាមួយប្រព័ន្ធយុត្តិធម៌ ។

### ៥. ការគ្រប់គ្រងលើការប៉ះពាល់នៃជំងឺផ្លូវអារម្មណ៍ និងកត្តាគន្លឹះនានា

មន្ត្រីស៊ើបអង្កេតគួរយល់ដឹង និងគ្រប់គ្រងទៅលើកត្តាគន្លឹះនានាដូចខាងក្រោម ៖

- ផលប៉ះពាល់-ការទទួលស្គាល់ពីផលប៉ះពាល់នៃជំងឺផ្លូវអារម្មណ៍ ទៅលើជនរងគ្រោះដោយអំពើជួញដូរមនុស្ស
- រោគសញ្ញា-ការទទួលស្គាល់រោគសញ្ញា
- ហានីភ័យនៃការធ្វើអត្តឃាត - ជនរងគ្រោះមួយចំនួន មានបទពិសោធន៍ក្នុងការធ្វើអត្តឃាត នៅក្នុងអំឡុងពេលដែលត្រូវគេកេងប្រវ័ញ្ច ហើយអាចស្ថិតនៅក្នុងអារម្មណ៍ ទោះបីជាពួកគេត្រូវបានសង្គ្រោះក៏ដោយ
- ការឃ្លាំមើលខ្ទាប់ខ្ជួន-នៅក្នុងករណីទាំងអស់ ដែលមានមូលដ្ឋានជឿជាក់ថា ជនរងគ្រោះដែលទទួលរងគ្រោះនៅក្នុងកម្រិតណាមួយនៃជំងឺផ្លូវអារម្មណ៍ ហានីភ័យនៃការប៉ុនប៉ងធ្វើអត្តឃាតនៅតែមាន ។ មន្ត្រីស៊ើបអង្កេតត្រូវធានាថា ជនរងគ្រោះមានសុវត្ថិភាព និងថែរក្សាឱ្យបានត្រឹមត្រូវ នៅក្នុងអំឡុងពេលដែលជនរងគ្រោះស្ថិតនៅក្រោមការគ្រប់គ្រងរបស់មន្ត្រីនគរបាល
- ការខឹងសម្បា-កម្រិតខ្ពស់នៃកំហឹង និងប្រវត្តិអាក្រក់ គឺជាប្រតិកម្មទូទៅរបស់អ្នកដែលមានជំងឺផ្លូវអារម្មណ៍ ដូចនេះ មន្ត្រីអនុវត្តច្បាប់គួរចងចាំអំពីកត្តានេះ និងហានីភ័យដែលពាក់ព័ន្ធនឹងជនរងគ្រោះ និងមន្ត្រីផងដែរ
- កង្វះខាតកិច្ចសហការ - គួរយល់ដឹងពីកង្វះខាតនៃកិច្ចសហការ ឬយល់ដឹងពីភាពអាម៉ាស់របស់ជនរងគ្រោះ សមត្ថភាពអន់ខ្សោយពីការរំលឹកឡើងវិញនូវព្រឹត្តិការណ៍ឱ្យបានលម្អិត ភាពមិនស៊ីចង្វាក់គ្នា ការរៀបរាប់ដែលមានលក្ខណៈខុសឆ្គង ឬកែតម្រូវជាញឹកញាប់ ឬប្រឌិតព្រឹត្តិការណ៍ជាក់លាក់ដែលពាក់ព័ន្ធ ទាំងអស់នេះអាចកើតមានឡើង ដែលជាផលវិបាកនៃជំងឺផ្លូវអារម្មណ៍
- ធ្វើឱ្យទទួលរងម្តងទៀត-ជៀសវាងការធ្វើឱ្យជនរងគ្រោះទទួលរងគ្រោះម្តងទៀត តាមរយៈការស្វែងរកកំហុសនៃសកម្មភាពរបស់ជនរងគ្រោះ
- មិនត្រូវវិនិច្ឆ័យជាមុន-ជៀសវាងការប្រព្រឹត្ត ឬនិយាយទៅកាន់ជនរងគ្រោះ នៅក្នុងរបៀបបុរេវិនិច្ឆ័យ
- មិនត្រូវគាបសង្កត់-ជៀសវាងការគាបសង្កត់ ទៅលើជនរងគ្រោះដើម្បីឱ្យជនរងគ្រោះរៀបរាប់ពីអង្គហេតុ សម្រាប់ធ្វើការស៊ើបអង្កេត
- ការផ្តល់សុវត្ថិភាព និងថែទាំជាបន្ទាន់ - ផ្តល់សុវត្ថិភាពដល់ជនរងគ្រោះជាបន្ទាន់
- ការយល់ចិត្ត- ធ្វើឱ្យជនរងគ្រោះទទួលបានកិច្ចគាំពារជាលក្ខណៈអាជីព ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន (ការសម្ភាសអាចនឹងទទួលបានផលល្អ បន្ទាប់ពីជនរងគ្រោះ ដែលទទួលរងជំងឺផ្លូវអារម្មណ៍នេះ បានទទួលកិច្ចគាំពារជាលក្ខណៈអាជីព ហើយនៅក្នុងរយៈពេលមួយ ជនរងគ្រោះនឹងអាចផ្តល់ព័ត៌មាន ដោយស្ម័យប្រវត្តិពីការសម្រេចចិត្តរបស់ខ្លួន ឬផ្តល់ព័ត៌មានពីអ្វីដែលបានកើតឡើងយ៉ាងលម្អិត) ។

ដូចនេះ វិធីសាស្ត្រល្អបំផុត ក្នុងការគ្រប់គ្រងជនរងគ្រោះដែលទទួលរងជំងឺផ្លូវអារម្មណ៍ នៅក្នុងរបៀបជាលក្ខណៈអាជីព និងមនុស្សធម៌ តម្រូវឱ្យមានវិធីសាស្ត្រពីរដំណាក់កាល ៖

- ធ្វើឱ្យជនរងគ្រោះមានលំនឹងផ្លូវចិត្ត តាមរយៈការផ្តល់កិច្ចគាំពារខាងផ្នែកសន្តិសុខ និងជំនួយផ្នែកចិត្តសាស្ត្រ
- ករណីដែលអាចធ្វើទៅបាន ត្រូវស្វែងរកការចាប់ផ្តើមដំណើរការកំណត់អត្តសញ្ញាណ និង/ឬ ការស៊ើបអង្កេត បន្ទាប់ពីជនរងគ្រោះ ទទួលបានភាពលំនឹងផ្លូវចិត្ត ។

ជានិច្ចកាល មន្ត្រីស៊ើបអង្កេតគួរតែគោរពទៅតាមវិធីសាស្ត្រនេះ ដោយសារវិធីសាស្ត្រនេះមានលក្ខណៈត្រឹមត្រូវ និងអនុវត្តទៅតាមសិទ្ធិមនុស្ស ថែមទាំងជាផលប្រយោជន៍ល្អបំផុតសម្រាប់ការស៊ើបអង្កេត ។ ការធ្វើដូចនេះគឺដោយសារកិច្ចសហការរបស់ជនរងគ្រោះនឹងធ្វើឱ្យជនរងគ្រោះជាសាក្សីមានអារម្មណ៍ល្អ ប្រសិនបើយើងផ្តល់ពេលវេលាក្នុងកិច្ចគាំទ្រដល់ជនរងគ្រោះ ដើម្បីទទួលបាននូវព័ត៌មានដែលបានកើតឡើងចំពោះពួកគេ ។

## ៦. ដំណាក់កាលទាំងបួនក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះ

**ក. ទំនាក់ទំនងដំបូង**

មន្ត្រីអនុវត្តច្បាប់នៅថ្នាក់មូលដ្ឋាន មានទំនាក់ទំនងជាមួយបុគ្គលម្នាក់ ដែលខ្លួនមានការជឿជាក់ថា ជននោះអាចត្រូវគេជួញដូរ

**ខ. ដំណាក់កាលទី១៖ សូចនាករមុនការសម្ភាស**

ប្រមូលព័ត៌មានទាំងអស់ដោយអនុវត្តសូចនាករ ៖

- អាយុ
- ភេទ/យេនឌ័រ
- សញ្ជាតិ/ភាសា
- ឯកសារ ឬលិខិតស្នាម
- ការបន្លាស់ទី/ទីតាំងចុងក្រោយ
- ឥរិយាបថ
- ភស្តុតាងនៃការបំពាន
- ការវាយតម្លៃលើទីភ្នាក់ងារទទួលជនរងគ្រោះ
- ការអនុវត្តចំណេះដឹងនៅពេលបច្ចុប្បន្ន

យោងតាមសូចនាករ បើអ្នកនៅតែជឿជាក់ថា ជននោះអាចត្រូវបានគេជួញដូរឬ? ប្រសិនបើមែន៖

**គ. ដំណាក់កាលទី២**

- **បង្កើតលក្ខខណ្ឌសម្ភាស**

ចូរចងចាំពីផលប៉ះពាល់នៃជំងឺផ្លូវអារម្មណ៍ ធានាឱ្យមានជីវិតឯកជន មិនត្រូវបំបែកចេញពីអ្នកផ្សេង ធ្វើឱ្យមានអារម្មណ៍ល្អ រកអ្នកបកប្រែភាសា និងអ្នកពិគ្រោះយោបល់ ប្រើសញ្ញាថា "សូមកុំរំខាន" មិនត្រូវធ្វើការវាយតម្លៃសន្និដ្ឋានជាមុន បង្កើតទំនាក់ទំនងជាមួយពួកគេ ណែនាំខ្លួន

- **ធ្វើការសម្ភាស**

ពន្យល់ពីគោលបំណង ដើម្បីទទួលបានព័ត៌មានដោយផ្តោតលើ៖

១. ការជ្រើសរើស

២. ការដឹកជញ្ជូន

៣. ការកេងប្រវ័ញ្ច

**ឃ. ដំណាក់កាលទី៣៖ឯកសារផ្សេងទៀត**

អត្តសញ្ញាណបណ្ណ

ឯកសារធ្វើដំណើរ

ការព្យាបាលជំងឺ

ឯកសារចម្លងនៃកិច្ចសន្យា ឬការផ្សាយពាណិជ្ជកម្ម សៀវភៅកំណត់ហេតុ

កំណត់ហេតុពីប្រាក់ចំណូល

**ង. ដំណាក់កាលទី៤៖ សេចក្តីសម្រេច**

១. សូចនាករ

២. ការសម្ភាស

៣. វត្ថុ និងឯកសារផ្សេងទៀត

តើជននោះអាចត្រូវគេជួញដូរដែរ ឬទេ ?បាទ ឬចាស

**៧. ប្រសិនបើ បាទ ឬចាស ៖ ធានាសុវត្ថិភាព ផ្តល់កិច្ចគាំពារឱ្យបានឆាប់**

ខាងក្រោមនេះ ផ្តល់នូវការពន្យល់យ៉ាងលម្អិត ពីប្រអប់នីមួយៗ ដែលមាននៅក្នុងតារាង ៖

**ក. ទំនាក់ទំនងដំបូង**

សេចក្តីត្រូវការនៃការឆ្លើយតបទៅលើជនរងគ្រោះដោយអំពើជួញដូរមនុស្ស អាចមានវិធីច្រើន ៖

- តាមរយៈជនរងគ្រោះដែលរត់គេចខ្លួនរួចពីការកេងប្រវ័ញ្ច គាត់អាចស្វែងរកជំនួយពីមន្ត្រីអនុវត្តច្បាប់
- ជនរងគ្រោះត្រូវបានគេរកឃើញ ឬត្រូវកំណត់ថា ជាជនរងគ្រោះដោយមន្ត្រីអនុវត្តច្បាប់ ក្នុងអំឡុងពេលនៃការស៊ើបអង្កេត ឬការបង្ក្រាបដែលមិនទាក់ទងទៅនឹងការជួញដូរមនុស្ស
- ជនរងគ្រោះត្រូវបានគេរកឃើញ ឬត្រូវកំណត់ថា ជាជនរងគ្រោះដោយមន្ត្រីអនុវត្តច្បាប់ នៅក្នុងអំឡុងពេលនៃការស៊ើបអង្កេតប្រឆាំងការជួញដូរមនុស្សជាក់លាក់
- ជនរងគ្រោះត្រូវគេរាយការណ៍ទៅមន្ត្រីអនុវត្តច្បាប់ តាមប្រភពផ្សេងៗ ដូចជាក្រុមគ្រួសារ ជនរងគ្រោះផ្សេងទៀត តតីយជន មន្ត្រីអនុវត្តច្បាប់ ទីភ្នាក់ងារសារព័ត៌មាន សេវាសង្គម ឬអង្គការក្រៅរដ្ឋាភិបាល... ។

វាមានសារៈសំខាន់ណាស់ ក្នុងការចងចាំថា ព័ត៌មានណាមួយដែលទាក់ទងទៅនឹងរឿងក្តីគួរតែផ្តល់ទៅឱ្យមន្ត្រីនៃប្រទេសប្រភព ឆ្លងកាត់ និងគោលដៅនៃជនល្មើសជួញដូរមនុស្ស ។ នៅក្នុងករណីនីមួយៗ មន្ត្រីអនុវត្តច្បាប់មានភារកិច្ចច្បាស់លាស់ក្នុងការចាត់វិធានការលើព័ត៌មាន ទៅតាមមធ្យោបាយសមស្រប ។ របាយការណ៍ទាំងអស់ដែលផ្តល់ទៅឱ្យមន្ត្រីអនុវត្តច្បាប់ ឬសមត្ថកិច្ចផ្សេងទៀត ត្រូវធ្វើការវិភាគដើម្បីទទួលបានព័ត៌មានអំពីរឿងក្តី និងអំពីជនរងគ្រោះឱ្យបានច្រើន តាមដែលអាចធ្វើទៅបាន ទោះបីមុនពេលធ្វើការសាកសួរជនរងគ្រោះក៏ដោយ ។

**ខ. ដំណាក់កាលទី១ ៖ សូចនាករមុនការសាកសួរ**

ដំណើរការនៃការកំណត់ថា ជនណាម្នាក់ជាជនរងគ្រោះ គឺត្រូវពិចារណាពីស្ថានភាពជុំវិញករណីនីមួយៗ មុននឹងសួរជនណាម្នាក់អំពីបញ្ហាជួញដូរមនុស្សជាក់ស្តែង ។ ចំណុចសំខាន់ៗនៃការកំណត់សូចនាករ ៖

- ជួយវាយតម្លៃនៅក្នុងដំណើរការនៃការកំណត់អត្តសញ្ញាណជនរងគ្រោះ
- មានលក្ខណៈជាទូទៅ អាស្រ័យទៅលើចំណេះដឹងនៃវិធីជួញដូរមនុស្ស
- មានករណីលើកលែងមួយចំនួន ទាក់ទងទៅនឹងសូចនាករទាំងអស់នោះ
- ផ្តល់ឱ្យមន្ត្រីអនុវត្តច្បាប់នូវស្ថានភាពជុំវិញបុគ្គលដែលខ្លួននឹងធ្វើការសម្ភាស
- លក្ខខណ្ឌមួយចំនួនអាចតម្រូវឱ្យសម្របទៅនឹងសូចនាករ ឬការបញ្ចូលសូចនាករថ្មីៗ
- មានតម្លៃ នៅពេលដែលសូចនាករនោះរៀបចំឡើងដោយមន្ត្រីនៅថ្នាក់មូលដ្ឋាន ដែលមានចំណេះដឹងពីស្ថានភាពជួញដូរមនុស្ស
- គួរពិចារណា ដោយសារសូចនាករមួយក្នុងចំណោមសូចនាករទាំងអស់ អាចមានចម្លើយផ្ទាល់របស់វា ។

ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស អាចកើតមានឡើងបាន

ទោះបីជាជនរងគ្រោះ មិនទទួលស្គាល់ថា ខ្លួនជាជនគ្រោះក៏ដោយ ។ ប៉ុន្តែជនរងគ្រោះមួយចំនួន បាន ទាមទារយ៉ាងពិតប្រាកដនូវស្ថានភាពរបស់ខ្លួនថាជាជនរងគ្រោះ នៅក្នុងដំណាក់កាលប្រឈមដំបូង ជាមួយមន្ត្រីនគរបាល ហើយមន្ត្រីអនុវត្តច្បាប់មានភារកិច្ចពិនិត្យមើលកាលៈទេសៈទាំងអស់ ពាក់ព័ន្ធ នឹងបុគ្គលណាម្នាក់និងធ្វើការវិនិច្ឆ័យឱ្យមានតុល្យភាព ដោយអាស្រ័យលើកត្តានានាដែលបានដឹង ។

សូចនាករមុនការសម្ភាស គឺជាមធ្យោបាយធ្វើឱ្យមន្ត្រីនគរបាលទទួលបានជោគជ័យ ។ នៅពេលសូចនាករត្រូវបានគេប្រើប្រាស់ជាមួយនឹងការសម្ភាស សូចនាករទាំងនោះនឹងផ្តល់មធ្យោបាយ ជាច់ដោយឡែកក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះ ទោះបីបុគ្គលនោះសហការ ឬមិនសហការ ទទួលស្គាល់ ឬមិនទទួលស្គាល់ថា ខ្លួនជាជនរងគ្រោះក៏ដោយ នៅក្នុងអំឡុងពេលនៃការសម្ភាស ។

ជាយុទ្ធសាស្ត្រទូទៅ សូចនាករខាងក្រោមនេះត្រូវបានបង្កើត និងវាយតម្លៃ ៖

- អាយុ
  - តើជននោះមានអាយុស្ថិតក្នុងកម្រិតមួយ ដែលយើងអាចកំណត់បាន នៅក្នុងវិធីថ្មីៗ ដែលប្រើប្រាស់ដោយជនជួញដូរដែរឬទេ ?
  - ក្នុងន័យទូទៅគឺថា មនុស្សកាន់តែចាស់ ទំនងជាមិនត្រូវបានគេជួញដូរនោះទេ
  - ការជួញដូរសម្រាប់ការកេងប្រវ័ញ្ចពលកម្ម ជាធម្មតា នឹងផ្តោតទៅលើជនរងគ្រោះក្មេងៗ ដោយជនជួញដូរដឹងថា ការងារលំបាកៗផ្នែកពលកម្ម ដែលមានលក្ខណៈដូចគ្នាទៅនឹងទាសភាព តម្រូវឱ្យជននោះមានវ័យក្មេង និងធ្វើជាក្រុម
  - ចំណុចដូចគ្នា គឺអាចធ្វើបាន ទាក់ទងទៅនឹងការជួញដូរផ្លូវភេទ ជាទូទៅភ្ញៀវចង់បានជនរងគ្រោះវ័យក្មេង
  - ទាក់ទងទៅនឹងការជួញដូរសរីរាង្គ ជនរងគ្រោះកាន់តែក្មេង គឺជាការប្រសើរសម្រាប់អ្នកទទួលសរីរាង្គ
  - ចូរចងចាំថា មនុស្សចាស់ត្រូវបានគេជួញដូរផងដែរ ។ ជនរងគ្រោះអាយុច្រើន ត្រូវបានគេជួញដូរ នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ និងតំបន់ដទៃទៀត សម្រាប់ពលកម្មលំបាកៗ ដូចជាកម្មករជំនាញ កាត់ដេរ និងសម្រាប់ការងារតាមផ្ទះ ។ មនុស្សចាស់ ជួនកាល ជាជនរងគ្រោះពិការ ត្រូវបានគេជួញដូរ នៅក្នុងតំបន់នេះ សម្រាប់ឱ្យសុំទាន
  - ជនរងគ្រោះកាន់តែក្មេងអាចត្រូវបានគេជួញដូរនៅក្នុងកម្រិតជាសកល គឺមានការកើនឡើង នូវចំនួនកុមារដែលត្រូវបានគេជួញដូរ សម្រាប់គោលបំណងកេងប្រវ័ញ្ចផ្សេងៗ ។
- ភេទ/យេនឌ័រ
  - តើស្ត្រីមានការជួញដូរច្រើនជាងបុរស ក្នុងការជួញដូរចេញទៅក្រៅ ឆ្លងកាត់ ឬចូលទៅក្នុងប្រទេស ឬយ៉ាងណា ?
  - តើយេនឌ័រគឺជាសូចនាករមួយ ដែលមានការពាក់ព័ន្ធ ដែរឬទេ ក្នុងទម្រង់ជាទូទៅនៃការជួញដូរមនុស្សនៅក្នុងប្រទេស ?
  - ការពាក់ព័ន្ធនៃទំហំយេនឌ័រ វាអាស្រ័យខ្លាំងទៅលើទីតាំង និងប្រភេទនៃការកេងប្រវ័ញ្ចដែលពាក់ព័ន្ធ ។

○ ការជួញដូរផ្លូវភេទប៉ះពាល់ទៅលើស្ត្រីយ៉ាងច្រើន ពីព្រោះ ពេស្យាចារលើភេទខុសគ្នា នៅតែជាទម្រង់ដែលអាចរកប្រាក់ និងអាចមើលឃើញច្រើនជាងគេបំផុតនៃការកេងប្រវ័ញ្ច

○ ការជួញដូរបុរសសម្រាប់គោលបំណងពេស្យាចារ ជាពិសេស ក្មេងប្រុសជំទង់ និងកុមារា គឺកំពុងតែមានការកើនឡើង

○ ចំណុចនៃការវាយតម្លៃព័ត៌មានចុងក្រោយ ទៅលើការជួញដូរកុមារក្នុងស្រុក និងក្រៅស្រុក សម្រាប់គោលបំណងនៃការបំពានផ្លូវភេទលើកុមារ និងការផលិតរូបភាពអាសអាភាស ដែលមានលក្ខណៈពាណិជ្ជកម្ម ឬមិនមានលក្ខណៈពាណិជ្ជកម្ម ។ និន្នាការនេះ អាចប៉ះពាល់ទៅលើកុមារ

○ តួនាទី និងសារៈសំខាន់នៃយេនឌ័រក្នុងការជួញដូរ សម្រាប់ការកេងប្រវ័ញ្ចពលកម្ម គឺអាស្រ័យ ទៅលើបរិបទរបស់វា

○ ប្រសិនបើការកេងប្រវ័ញ្ចពលកម្ម តម្រូវឱ្យមានកម្លាំងរាងកាយខ្លាំង ដូចជា ការជីករករ៉ែ សំណង់ ឬនៅលើទូកនេសាទ វាអាចប៉ះពាល់ធ្ងន់ទៅលើការជួញដូរបុរសច្រើនជាងស្ត្រី

○ ប្រសិនបើការងារតម្រូវឱ្យមានពលកម្មស្រាលៗផ្នែកកសិកម្ម ដូចជា បេះផ្លែឈើ ពលកម្មជំនាញ ឬអ្នកបម្រើតាមផ្ទះ នោះស្ត្រីអាចត្រូវបានគេជួញដូរច្រើន ។

- សញ្ជាតិ/ភាសា

○ តើជននោះមកពីប្រទេសណា និងស្គាល់វិធីនៃការជួញដូរដែរឬទេ?

○ បណ្តាញផ្គត់ផ្គង់ជនរងគ្រោះ អាស្រ័យទៅលើការកេងប្រវ័ញ្ច និងអាចមកពីកត្តាជាច្រើន រួមមាន ភាពក្រីក្រ ការរើសអើង និងកង្វះខាតឱកាស...

○ ជនរងគ្រោះពិតប្រាកដអាចមិនមកពីប្រទេសអ្នកមាន ផ្នែកឧស្សាហកម្ម ដូចជា អាម៉េរិកខាងជើង អូស្ត្រាលី ឬអឺរ៉ុបខាងលិច ។ ឧទាហរណ៍ ដូចជា ជនរងគ្រោះជនជាតិថៃត្រូវបានគេជួញដូរនៅក្នុងតំបន់ និងឆ្លងទ្វីប ដូចនេះវាមានសារៈសំខាន់ក្នុងការចងចាំថា សេដ្ឋកិច្ចរីកចម្រើនក៏មានជនរងគ្រោះត្រូវគេជួញដូរដែរ ដោយហេតុថា ប្រទេសទាំងនោះក៏មានតំបន់ក្រីក្រ ដែលស្ថិតនៅក្នុងភាពងាយរងគ្រោះ សម្រាប់ការផ្គត់ផ្គង់ផ្នែកការជួញដូរមនុស្ស

○ តើជននោះអាចនិយាយភាសារបស់ប្រទេសដែលខ្លួនកំពុងរស់នៅ បានដែរ ឬទេ?

○ តើជននោះនិយាយភាសាតំបន់ ឬប្រទេសដើម ដែលបង្ហាញឱ្យយើងដឹងពីវិធីនៃការជួញដូរដែរឬទេ?

○ តើជននោះនិយាយភាសានៃប្រទេសនោះស្ទាត់ ដោយបង្ហាញឯកសារណាមួយដែលខ្លួនមានដែរឬទេ?

- ឯកសារ ឬលិខិតស្នាម

○ តើជននោះមានអត្តសញ្ញាណប័ណ្ណ និង/ឬ ឯកសារធ្វើដំណើរដែរឬទេ? តើជននោះដឹងអំពីវិធីនៃការជួញដូរមនុស្សដែរឬទេ?

○ មានអត្តសញ្ញាណប័ណ្ណ ឬគ្មាន និង/ឬ ឯកសារធ្វើដំណើរអាស្រ័យទៅលើបរិបទ និងកាលៈទេសៈ

○ ឯកសារ គឺជាសូចនាករដែលអាចជឿជាក់ ហើយគួរធ្វើការយកចិត្តទុកដាក់ដោយ

ប្រុងប្រយ័ត្ន

- ○ ទំហំភូមិសាស្ត្រនៃបណ្តាញជួញដូរ នឹងមានផលប៉ះពាល់ទៅលើការប្រើប្រាស់ និងការពាក់ព័ន្ធនៃឯកសារ
- ○ វិធានទូទៅនៃការជួញដូរមនុស្ស បើត្រូវធ្វើដំណើរកាន់តែឆ្ងាយ តម្រូវឱ្យប្រើប្រាស់អត្តសញ្ញាណប័ណ្ណ និងឯកសារធ្វើដំណើរកាន់តែច្រើន
- ○ ការប្រើប្រាស់ឯកសារ នឹងតម្រូវឱ្យមានច្រើនសម្រាប់ការធ្វើដំណើរ ដោយយាន្តជំនិះជាពិសេស យន្តហោះ ។ ប្រសិនបើចូលក្នុងប្រទេសណាមួយដោយខុសច្បាប់ វានឹងបង្ហាញឱ្យឃើញភស្តុតាងមួយចំនួន ដូចជាអត្តសញ្ញាណប័ណ្ណ និង/ឬ លិខិតធ្វើដំណើរ
- ○ ការរឹបអូស ការដកហូតអត្តសញ្ញាណប័ណ្ណ និងលិខិតធ្វើដំណើរ គឺជារូបភាពទូទៅនៃយន្តការត្រួតត្រា និងបង្ខំ ដែលប្រើប្រាស់ដោយជនជួញដូរ ហើយជនរងគ្រោះដែលគ្មានឯកសារ គឺជាសូចនាករដ៏សំខាន់មួយ
- ○ ចូរចងចាំថា ចំណុចដូចគ្នា អាចធ្វើឡើងពាក់ព័ន្ធនឹងបញ្ហាជាច្រើននៃអ្នកសុំសិទ្ធិជ្រកកោន និងអ្នកត្រូវគេរត់ពន្ធ ដែលអាចត្រូវគេជួញដូរ ។

- ការបន្លាស់ទី/ទីតាំងចុងក្រោយ
  - ○ តើជននោះប្រើប្រាស់ផ្លូវធ្វើដំណើរ ដែលស្គាល់ថា ជាវិធីនៃការជួញដូរឬទេ?
  - ○ តើជននោះប្រើប្រាស់មធ្យោបាយដឹកជញ្ជូន ឬក្រុមហ៊ុនលក់សំបុត្រ ដែលទំនងជាស្ថិតនៅក្នុងវិធីនៃការជួញដូរឬទេ?
  - ○ តើជននោះមានអត្តសញ្ញាណប័ណ្ណ ឬលិខិតស្នាម ដើម្បីបង្ហាញថា ខ្លួនបានទិញសំបុត្រ ។ ជាធម្មតា ជនជួញដូរ បានចេញថ្លៃសំបុត្រនេះ ហើយការចំណាយនេះ គឺជាដំណើរការនៃបំណុលដែលមានលក្ខខណ្ឌបង្ខំ
  - ○ តើជននោះធ្វើដំណើរជាមួយជនផ្សេងទៀត ឬយ៉ាងណា? ទោះបីជាមួយជនរងគ្រោះដទៃទៀត ឬអាចជាមួយអ្នកជួញដូរក្តី ដែលស៊ីចង្វាក់គ្នាទៅនឹងវិធីនៃការជួញដូរ
  - ○ តើជននោះអាចស្ថិតក្រោមការត្រួតត្រាពីជនណាម្នាក់ ដែលខ្លួនកំពុងនៅជាមួយឬ?
  - ○ ត្រូវចាំថា ជនជួញដូរតែងតែរួមដំណើរជាមួយជនរងគ្រោះរបស់ខ្លួន ក្នុងដំណាក់កាលនៃការដឹកជញ្ជូន
  - ○ ទីតាំងរបស់ជនរងគ្រោះចុងក្រោយ គឺមានសារៈសំខាន់សម្រាប់មន្ត្រីអនុវត្តច្បាប់
  - ○ ការសង្គ្រោះពីកន្លែងដែលដឹងថា ជាកន្លែងងាយរងគ្រោះនៅក្នុងបរិបទនៃការជួញដូរ ដូចជាកន្លែងបម្រើសេវាផ្លូវភេទ អណ្តូងរ៉ែ ភោជនីយដ្ឋាន សំណង់ និងកសិកម្ម ដែលជាសូចនាករនៃការកេងប្រវ័ញ្ច ។

- ឥរិយាបថ
  - ○ តើជននោះគេចវេសមិនចង់ឆ្លើយសំណួរ ឬបានបញ្ចេញចរិតគួរឱ្យសង្ស័យឬ?
  - ○ តើជននោះបង្ហាញនូវចរិតភ័យខ្លាច ឆាប់ខឹង គួរឱ្យសង្ស័យ ឬធ្លាក់ទឹកចិត្តដែរឬ?
  - ○ តើជននោះទំនងជាឆ្លើយនឹងសំណួរ នៅក្នុងរបៀបដែលបានត្រៀមទុកជាមុនឬ?

- ○ តើជននោះទំនងជាបានហាត់រៀនឱ្យរៀបរាប់ពីអង្គហេតុឬ?
- កស្តុតាងនៃការបំពានៈ តើមានសញ្ញានៃការរំលោភបំពានអ្វីខ្លះ ដែលអាចមើលឃើញនៅលើជននោះ? ទោះជាការមើលឃើញថាមាន ស្នាមរបួសលើរាងកាយ សញ្ញាបង្ហាញឱ្យឃើញថាខ្វះអាហារូបត្ថម្ភ ឬភាពភ័យបាក់ស្បាតខាងផ្លូវចិត្តឬ?
- ការវាយតម្លៃពីទីភ្នាក់ងារពាក់ព័ន្ធ
  - ○ បើជននោះត្រូវស្ថាប័នផ្សេងទៀតនាំមកឱ្យមន្ត្រីអនុវត្តច្បាប់ ដូចជា មកពីមន្ទីរពេទ្យ ឬទីភ្នាក់ងារគាំពារជនរងគ្រោះ តើស្ថាប័ន ឬទីភ្នាក់ងារទាំងនោះ បានធ្វើការវាយតម្លៃពីស្ថានភាពជនរងគ្រោះយ៉ាងណា?
  - ○ តើទីភ្នាក់ងារនោះមានព័ត៌មានផ្សេងទៀតដែលអាចជួយដល់ការវាយតម្លៃនេះទេ?
- ចំណេះដឹងនៅពេលបច្ចុប្បន្ន ៖ នៅក្នុងប្រភេទទាំងអស់ខាងលើ តើមានកាលៈទេសៈណាខ្លះដែលពាក់ព័ន្ធទៅនឹងករណីរឿងក្តី ដែលបានដឹងតាមចំណេះដឹង និងបទពិសោធន៍នៅថ្នាក់មូលដ្ឋាននាពេលបច្ចុប្បន្ន ពីវិធីនៃការជួញដូរ?

ជានិច្ចកាលត្រូវចងចាំ នៅពេលអនុវត្តសូចនាករដូចខាងក្រោម ៖

- សូចនាករនីមួយៗ អាចបកស្រាយនៅក្នុងរបៀបជាច្រើន
- គ្មានសូចនាករណាមួយដែលនឹងអាចធ្វើការអះអាងថា តើជននោះគឺជា ជនរងគ្រោះដោយការជួញដូរឬទេ
- គោលបំណងនៃការវាយតម្លៃសូចនាករទាំងអស់បញ្ចូលគ្នា អាចកំណត់អត្តសញ្ញាណ
- ការប្រើប្រាស់សូចនាករ នឹងអាចទទួលបានផលប្រយោជន៍ច្រើន លុះត្រាតែវាត្រូវបានពិនិត្យ និងកែតម្រូវ ដោយមន្ត្រីស៊ើបអង្កេតនៅថ្នាក់មូលដ្ឋានដែលមានចំណេះដឹង និងបទពិសោធន៍ ។

សូមធ្វើការកត់សម្គាល់ ទោះបីជនណាម្នាក់ ដែលរងគ្រោះដោយសារជនជួញដូរមនុស្ស ឬជនរត់ពន្ធមនុស្ស ឬគ្រាន់តែជាអ្នកចំណាកស្រុកដោយខ្លួនឯង រាល់ការប្រព្រឹត្តិទៅលើជនទាំងនោះត្រូវធ្វើឡើងដោយមានការប្រុងប្រយ័ត្ន ហើយត្រូវមានការគោរពចំពោះសិទ្ធិមនុស្ស ។

**គ. ដំណាក់កាលទី២៖ ការបង្កើតលក្ខខណ្ឌសម្រាប់ការសម្ភាស**

ការសម្ភាសជនរងគ្រោះ គឺជាការងារប្រឈម សម្រាប់មន្ត្រីអនុវត្តច្បាប់ ដោយមូលហេតុមួយចំនួនដូចជា កង្វះខាតអំពីកិច្ចសហការពីជនរងគ្រោះ ព័ត៌មានជាមូលដ្ឋានក្នុងការរៀបចំសំណួរ ពេលវេលាក្នុងការរៀបចំ និងសម្ភារក្នុងការសម្ភាស ។

ជនរងគ្រោះអាចមានអារម្មណ៍មិនរាក់ទាក់ មិនជឿជាក់ ហើយមិនចង់ប្រាប់ហេតុការណ៍អ្វីឡើយ ។ ការខ្លាចរអាចំពោះជនណាម្នាក់ ក្នុងការផ្តល់ព័ត៌មានលម្អិត គឺអាចជាការបង្ហាញឱ្យឃើញនូវការភ័យខ្លាចរបស់ជនរងគ្រោះចំពោះជនជួញដូរមនុស្ស ការភ័យខ្លាចពីព័ត៌មានត្រូវបែកការ ជនរងគ្រោះមិនមានការទុកចិត្តលើមន្ត្រីអនុវត្តច្បាប់ ឬនៅក្នុងករណីធ្ងន់ធ្ងរ ជនរងគ្រោះអាចមានការប៉ះពាល់ផ្លូវអារម្មណ៍ខ្លាំង ក្នុងការរៀបរាប់ពីព័ត៌មាននោះ ។

- លក្ខខណ្ឌនៃការសម្ភាស
  - ○ ជនរងគ្រោះត្រូវតែសម្ភាសដាច់ដោយឡែក ពីជនដែលគេសង្ស័យថា ជាជនជួញដូរ

មនុស្ស ឬជនរងគ្រោះដទៃទៀត ដែលស្ថិតនៅក្នុងក្រុមរបស់ជនរងគ្រោះនោះ ហើយប្រសិនបើមានសញ្ញាបញ្ជាក់ថា ជនរងគ្រោះអាចទទួលរងនូវការប៉ះពាល់ផ្លូវអារម្មណ៍ បើអាចធ្វើទៅបាន ជនរងគ្រោះគួរតែសម្ភាស ដោយមានវត្តមានអ្នកពិគ្រោះយោបល់ ដែលមានជំនាញផ្នែកចិត្តសាស្ត្រ

○ មន្ត្រីសម្ភាសដែលព្យាយាមកំណត់ ថាតើជនណាម្នាក់ជាជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស គួរតែចងចាំអំពីផលប៉ះពាល់ដែលអាចមានពីជំងឺផ្លូវអារម្មណ៍ និងយុទ្ធសាស្ត្រ ដើម្បីសង្គ្រោះជីវិតរបស់ជនរងគ្រោះ ដូចដែលបានកំណត់ខាងលើ ។ នៅពេលកត្តាទាំងនេះបានកើតឡើង វាអាចជាមូលហេតុ ដែលធ្វើឱ្យជនរងគ្រោះបដិសេធថា ខ្លួនមិនមែនជាជនរងគ្រោះដោយអំពើជួញដូរនោះទេ ទោះបីជាមានភស្តុតាងផ្ទុយរឹងមាំយ៉ាងណាក៏ដោយ ។ ដូចនេះ មន្ត្រីដែលទទួលបន្ទុកសម្ភាសគួរតែសម្រេចឱ្យបានត្រឹមត្រូវ ចំពោះគ្រោះថ្នាក់ទាំងនេះ ហើយមិនត្រូវឱ្យជនរងគ្រោះបដិសេធដោយសារការប៉ះពាល់ផ្លូវអារម្មណ៍នោះទេ

○ ការកំណត់លើការសម្ភាស-ដៃគូសម្ភាស ៖ បន្ថែមទៅនឹងបញ្ហាសំខាន់ បញ្ហាដែលបង្កឡើងដោយការប៉ះពាល់ផ្លូវអារម្មណ៍ មន្ត្រីសម្ភាសនឹងលំបាកស្វែងរកអង្គហេតុ ដែលអាចកើតឡើងនៅក្នុងអំឡុងពេលទំនាក់ទំនងដំបូង រវាងមន្ត្រីដែលទទួលបន្ទុកធ្វើការសម្ភាស និងជនរងគ្រោះ ។ វាអាចបណ្តាលមកពីការគំនាបផ្នែកពេលវេលា ទៅលើអ្នកសម្ភាស ទីតាំងនៃការសម្ភាសអាចមិនសមស្រប ហើយមិនមានពេលវេលាក្នុងការបង្កើតទំនាក់ទំនង ឬភាពជឿទុកចិត្តគ្នា

○ ទោះបីយ៉ាងណាក៏ដោយ ការដែលមិនមានបំណង ឬការខ្វះខាតនៃកិច្ចសហការពីពួកគេ មន្ត្រីទទួលបន្ទុកសម្ភាសគួរតែព្យាយាមឱ្យអស់ពីសមត្ថភាព ក្នុងការអាណិតអាសូរ ចំពោះពួកគេ ហើយចូរចងចាំថា ការបង្កើតទំនាក់ទំនងល្អជាមួយជនរងគ្រោះ ធ្វើឱ្យមានកិច្ចសហការកាន់តែច្រើន ក្នុងការផ្តល់ចម្លើយ

○ អ្នកបកប្រែភាសា ៖ បើជនរងគ្រោះមិនមានចំណេះដឹងផ្នែកភាសាគ្រប់គ្រាន់ នៅពេលសម្ភាស សេវាបកប្រែភាសាត្រូវតែផ្តល់ឱ្យ ។ វាគឺជាការសំខាន់ដែលជននោះអាចយល់ពីសំណួរដែលគេសួរ ហើយបើអាចធ្វើទៅបាន ការសម្ភាសនោះ គួរតែធ្វើឡើងជាភាសាកំណើតរបស់ជននោះ

○ អ្នកពិគ្រោះយោបល់ផ្នែកចិត្តសាស្ត្រ ៖ បើមានការប៉ះពាល់ផ្លូវអារម្មណ៍ពិតប្រាកដលើជនរងគ្រោះដោយអំពើជួញដូរមនុស្ស អ្នកពិគ្រោះយោបល់គួរតែមានវត្តមាននៅក្នុងពេលសម្ភាស

○ អ្នកពិគ្រោះយោបល់ផ្នែកច្បាប់ ៖ ដូចគ្នានេះដែរ ប្រសិនបើមានអ្នកប្រឹក្សាផ្នែកច្បាប់ ដែលផ្តល់ឱ្យតាមរយៈទីភ្នាក់គាំពារជនរងគ្រោះ ឬប្រសិនបើមានតម្រូវការច្បាប់ក្នុងស្រុក អ្នកច្បាប់គួរតែមានវត្តមាននៅគ្រប់ដំណាក់កាលនៃការសម្ភាសទាំងអស់

○ ភាគីទីបី សម្រាប់ជនរងគ្រោះដែលជាកុមារ ៖ ជនរងគ្រោះដែលជាកុមារ គឺងាយនឹងទទួលរងគ្រោះថ្នាក់ខ្លាំងណាស់ ហើយការសម្ភាសត្រូវធ្វើឡើងដោយមានវត្តមានភាគីទីបី ដែលមានភាពឯករាជ្យ ហើយបើអាចធ្វើទៅបាន គឺត្រូវមានវត្តមានអ្នកពិគ្រោះយោបល់ជំនាញផ្នែកចិត្តសាស្ត្រ ឬមេធាវី ។ នៅក្នុងករណីជាច្រើន វត្តមាននៃភាគីទីបី ដែលមានភាពឯករាជ្យនៅក្នុងអំឡុងពេលធ្វើការសម្ភាស ដូចជា សាច់ញាតិ ឬគ្រូបង្រៀន គឺជាការតម្រូវផ្នែកច្បាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

- ការសម្ភាស

ការសម្ភាសជនណាម្នាក់ដែលអាចត្រូវបានគេជួញដូរ គឺជាការប្រឈមដ៏ធំមួយ ហើយអាចមានការលំបាកខ្លាំង ។

**ចូរចងចាំថា ជនរងគ្រោះអាចមានអារម្មណ៍**

១. ការមន្ទិលសង្ស័យលើអ្នកសម្ភាស ពីទីតាំង និងស្ថានភាពនៃការសម្ភាស

២. ការយល់ច្រឡំ អាចមិនយល់ ឬមិនអាចស្តាប់យល់ពីភាសារបស់អ្នកសម្ភាស

៣. ការមិនជឿជាក់លើមន្ត្រីនគរបាល ឬពួកគេមិនមានអារម្មណ៍វិជ្ជមានចំពោះអ្នកសម្ភាស

៤. ការភ័យខ្លាចចំពោះជនជួញដូរមនុស្ស អ្នកសម្ភាស និងផលវិបាកនានាក្នុងការរៀបរាប់

៥. ការឈឺចាប់ផ្លូវកាយ ផ្លូវចិត្ត និងផ្លូវភេទ

៦. ជំងឺថប់អារម្មណ៍ តានតឹង អត្តឃាត ខឹងសម្បារ យំ ហេវហត់ បដិសេធ និងមិនអាចរំលឹកការចងចាំបាន

មិនត្រូវធ្វើឱ្យជនរងគ្រោះមានការឈឺចាប់ និងកាត់បន្ថយបញ្ហាខាងលើដោយៈ

១. ធានាពីភាពឯកជន ទីតាំងបិទទ្វា សីតុណ្ហភាពបន្ទប់ គ្មានការរំខាន បិទទូរស័ព្ទ ដាក់សញ្ញា សូមកុំរំខាន

២. ការទាក់ទងគ្នា ផ្ទៀងផ្ទាត់មើលពីការយល់ដឹង រកអ្នកបកប្រែភាសា ក្នុងករណីចាំបាច់

៣. កិច្ចគាំពារ ពិនិត្យមើលសុខភាព ផ្តល់ការព្យាបាលបើចាំបាច់ ធានាសុវត្ថិភាព រកអ្នកពិគ្រោះយោបល់ ធ្វើឱ្យមានអារម្មណ៍ល្អ

៤. អាកប្បកិរិយាប្រកបដោយវិជ្ជាជីវៈ ការគោរព គ្មានការវិនិច្ឆ័យជាមុន បង្កើតទំនាក់ទំនង និងធ្វើឱ្យជឿជាក់

៥. ការណែនាំខ្លួន តួនាទី និងភារកិច្ចរបស់អ្នកសម្ភាស និងអ្នកមានវត្តមានផ្សេងទៀត

៦. ការពន្យល់៖ គោលបំណង ពេលវេលា សម្រាក បញ្ជាក់ពីសំណួរ ផ្ទៀងផ្ទាត់ការយល់ដឹង និងទទួលការយល់ស្រប

មានឱកាសធ្វើឱ្យជនរងគ្រោះឆ្លើយសំណួរ និងផ្តល់ព័ត៌មាន ដើម្បីធ្វើការកំណត់អត្តសញ្ញាណឱ្យបានត្រឹមត្រូវ

**ឃ. ដំណាក់កាលទីបី ៖ ឯកសារ សម្ភារបំពេញបន្ថែម**

ឯកសារគាំទ្របន្ថែម អាចជាការបន្ថែមទៅនឹងធន្ទៈរបស់ជនរងគ្រោះ និងជួយឱ្យមានការសម្រេចចិត្ត ។ ឯកសារ ឬសម្ភារគាំទ្រដទៃទៀត អាចទទួលបានពីស្ថាប័នដែលពាក់ព័ន្ធ ឬផ្តល់ដោយជនរងគ្រោះខ្លួនឯង ។ ខាងក្រោមនេះគឺជាឧទាហរណ៍ ៖

- របាយការណ៍នគរបាល ឬស្ថាប័នអន្តោប្រវេសន៍
- ឯកសារ ឬលិខិតធ្វើដំណើរ
- លិខិតចាកចេញ ឬលិខិតចូល
- លិខិតពេទ្យដែលផ្តល់ឱ្យទាក់ទងទៅនឹងការព្យាបាល
- ឯកសារចម្លងនៃកិច្ចសន្យាការងារ ឬឯកសារផ្សព្វផ្សាយច្បាប់ដើមរបស់ជនល្មើស
- កំណត់ហេតុនៃប្រាក់ចំណូល សៀវភៅកំណត់ត្រាប្រចាំថ្ងៃ លិខិតស្នាមផ្សេងៗដែលសរសេរដោយជនរងគ្រោះ ។

**ង. ដំណាក់កាលទី៤ ៖ សេចក្តីសម្រេចចុងក្រោយ**

នៅចុងបញ្ចប់នៃការសម្ភាស មន្ត្រីសម្ភាសត្រូវវាយតម្លៃរួមទៅលើសូចនាករ ដែលមានដោយបែងចែកជា ៣ ប្រភេទ ៖

- ចំណុចនៃការវាយតម្លៃ
- ចម្លើយដែលផ្តល់ឱ្យដោយជនរងគ្រោះ
- សម្ភារឯកសារបំពេញបន្ថែមទៀត

បន្ទាប់ពីបានធ្វើដូចនេះហើយ មន្ត្រីសម្ភាសនឹងអាចធ្វើការសម្រេចចិត្ត តាមដែលអាចធ្វើទៅបាន ថាជាការត្រឹមត្រូវ នៅក្នុងកាលៈទេសៈនេះ ថាតើជនរងគ្រោះត្រូវបានគេជួញដូរ ឬរត់ពន្ធ ឬជាអ្នកចំណាកស្រុកដោយខ្លួនឯងដោយមូលហេតុខាងផ្នែកសេដ្ឋកិច្ច ។

ប្រសិនបើ ការសម្រេចចិត្តថា បុគ្គលនោះ គឺជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស នោះត្រូវមានការប្រព្រឹត្តិចំពោះជនរងគ្រោះ យោងទៅតាមគោលការណ៍ណែនាំ មាននៅក្នុងផ្នែកទីពីរ នៃមេរៀននេះ ។

## II. ការប្រព្រឹត្តិទៅលើជនរងគ្រោះដោយអំពើជួញដូរមនុស្ស

ផ្នែកទីពីរនៃមេរៀន ពិនិត្យទៅលើស្តង់ដាផ្នែកច្បាប់ ដែលទាក់ទងទៅនឹងការប្រព្រឹត្តិទៅលើជនដែលត្រូវគេកំណត់ថា ជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងកំណត់ពីការអនុវត្តជាស្តង់ដាល្អបំផុតដែលមន្ត្រីអនុវត្តច្បាប់ប្រព្រឹត្តតាម ។ ចំណុចសំខាន់នៅក្នុងបញ្ហានេះ គឺ ៖

- កិច្ចសហប្រតិបត្តិការជិតស្និទ្ធរវាងស្ថាប័នអនុវត្តច្បាប់ និងទីភ្នាក់ងារគាំពារជនរងគ្រោះ
- ការទទួលស្គាល់ និងការឆ្លើយតបជាបន្ទាន់ទៅលើសេចក្តីត្រូវការរបស់ជនរងគ្រោះ ។

**១. ច្បាប់អន្តរជាតិ**

នៅក្នុងប្រទេសជាច្រើន ដែលស្ថានភាពជនរងគ្រោះដោយអំពើជួញដូរមនុស្ស ភាគច្រើនមានលក្ខណៈលំបាកខ្លាំងនៅពេលជនរងគ្រោះទាំងនោះ ចូលរួមនៅក្នុងដំណើរការនៃប្រព័ន្ធយុត្តិធម៌ ។

បញ្ហានេះមិនគួរនឹងកើតឡើងនោះទេ ។ មានចំណុចសំខាន់ ២ ដែលគួរចងចាំ ទាក់ទងនឹងការប្រព្រឹត្តិទៅលើជនដែលត្រូវគេជួញដូរ ៖

- ជនរងគ្រោះដោយអំពើជួញដូរមនុស្ស មិនត្រូវបានផ្តន្ទាទោសពីអន្តោប្រវេសន៍ខុសច្បាប់ ឬបទល្មើសផ្សេងទៀត (ពេស្យាចារ)ដែលទាក់ទងដោយផ្ទាល់ទៅនឹងអង្គហេតុ ដែលត្រូវគេជួញដូរ
- ជនរងគ្រោះដោយអំពើជួញដូរមនុស្ស មិនត្រូវបានរងគ្រោះម្តងទៀត ដោយសារការប្រព្រឹត្តិនៃមន្ត្រីអនុវត្តច្បាប់ ។

ស្តង់ដាអន្តរជាតិដែលពាក់ព័ន្ធ មាននៅក្នុងពីពិធីសារប៉ាឡឺម៉ូ ស្តីពីការជួញដូរមនុស្ស គោលការណ៍ និងសេចក្តីណែនាំរបស់អង្គការសហប្រជាជាតិ (កិច្ចការពារ និងកិច្ចគាំពារ-កឋាខណ្ឌ ទី ៧ គោលការណ៍ណែនាំ ៖ សេចក្តីណែនាំ ទី១ សេចក្តីណែនាំ ទី២ កឋាខណ្ឌ ទី ៥ កឋាខណ្ឌ ទី ៦)។

**២. ស្តង់ដារអាស៊ាន**

**ក. សេចក្តីប្រកាសអាស៊ានស្តីពីការប្រឆាំងអំពើជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ**

ដើម្បីបែងចែកភាពខុសគ្នា រវាងជនរងគ្រោះដោយអំពើជួញដូរមនុស្ស ពីជនប្រព្រឹត្តបទល្មើស និងកំណត់ឱ្យឃើញពីប្រទេសប្រភព និងសញ្ជាតិរបស់ជនរងគ្រោះទាំងនេះ ហើយបន្ទាប់មកធានាថា ជនរងគ្រោះនេះ ត្រូវបានទទួលនូវការប្រព្រឹត្ត ទៅលើពួកគេជាលក្ខណៈមនុស្សធម៌ និងផ្តល់កិច្ចគាំពារសំខាន់ៗខាងផ្នែកវេជ្ជសាស្ត្រ និងទម្រង់ដទៃទៀតនៃកិច្ចគាំពារ ដែលមានលក្ខណៈសមស្របទៅនឹងប្រទេសទទួល រួមមាន ការធ្វើមាតុភូមិនិវត្តន៍ភ្លាម ទៅប្រទេសកំណើតរបស់ខ្លួន(ចំណុចទី៥)។

ដើម្បីចាត់វិធានការក្នុងការគោរព និងរក្សាសេចក្តីថ្លៃថ្នូរ និងសិទ្ធិមនុស្សរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងមានគោលការណ៍ណែនាំអាស៊ានសម្រាប់អ្នកអនុវត្តផ្ទាល់ ដោយមិនចោទប្រកាន់ លើជនរងគ្រោះ ឬផ្តន្ទាទោសពីបទល្មើសដែលបានប្រព្រឹត្តដោយពួកគេ ហើយបទល្មើសទាំងនោះ គឺជាផលវិបាកដោយផ្ទាល់នៃអំពើជួញដូរមនុស្ស (ចំណុចទី៦ និងគោលការណ៍ណែនាំអាស៊ានសម្រាប់អ្នកអនុវត្តផ្ទាល់ និងគោលការណ៍ណែនាំ C.២ ) ។

**ខ. ការគោរពទៅតាមស្តង់ដានិងនីតិវិធីអន្តរជាតិ**

- ត្រូវធានាឱ្យមានសន្តិសុខតាមព្រំដែនរបស់រដ្ឋ និងអនុវត្តច្បាប់ព្រហ្មទណ្ឌរបស់ប្រទេស
- ត្រូវឱ្យស្របទៅនឹងស្តង់ដានៃការប្រព្រឹត្តិទៅលើជនរងគ្រោះដោយអំពើជួញដូរមនុស្ស
- មន្ត្រីអនុវត្តច្បាប់មិនត្រូវធ្វើការឃុំឃាំង ចោទប្រកាន់ និងផ្តន្ទាទោសដល់ជនរងគ្រោះ ។

**គ. ការគោរពតាមនីតិវិធី**

- មន្ត្រីអនុវត្តច្បាប់ គួរតែយល់ព្រមចំពោះការទាមទារពួកគេថា ខ្លួនជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងធ្វើទៅលើគាត់ទៅតាមឋានៈជាជនរងគ្រោះ ព្រមទាំងផ្តល់វិធានការគាំពារនានា
- ជនរងគ្រោះមិនត្រូវបានឃុំឃាំង ចោទប្រកាន់ ឬផ្តន្ទាទោស ដូចជាជនសង្ស័យឡើយ
- ត្រូវថ្លឹងថ្លែងដោយផ្តល់អាទិភាពទៅលើការប្រព្រឹត្តិផ្នែកសិទ្ធិមនុស្សដល់ជនរងគ្រោះ ។

**៣. គោលការណ៍ជាមូលដ្ឋាននៃការអនុវត្ត**

មន្ត្រីអនុវត្តច្បាប់ មានភារកិច្ចច្បាស់លាស់ ក្នុងការឆ្លើយតបឱ្យបានឆាប់តាមដែលអាចធ្វើបាន បើជនរងគ្រោះ មកផ្តល់ព័ត៌មាន ឬកស្តុតាងដែលទាក់ទងទៅនឹងអំពើជួញដូរមនុស្ស ។ ចាប់ពីពេល

ទទួលបានព័ត៌មាន មន្ត្រីអនុវត្តច្បាប់ត្រូវតែគោរពទៅតាមគោលការណ៍ជាមូលដ្ឋាន ស្តីពីការប្រព្រឹត្តិទៅលើជនរងគ្រោះ ដូចខាងក្រោម ៖

- ការប្រព្រឹត្តិ និងជួយជនរងគ្រោះដោយសារបទល្មើស ៖ ទោះបីជនរងគ្រោះសហការ ឬមិនសហការ មន្ត្រីអនុវត្តច្បាប់ត្រូវចាត់ទុកថា ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ជាជនរងគ្រោះធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ ហើយចាត់ទុកថាជាសាក្សីដ៏សំខាន់ ។ ការអនុវត្តទៅតាមគោលការណ៍នេះ មិនត្រូវដាក់ជាលក្ខខណ្ឌឱ្យជនរងគ្រោះសហការជាមួយមន្ត្រីអនុវត្តច្បាប់ទេ
- តាមការអនុវត្តជាក់ស្តែង មន្ត្រីអនុវត្តច្បាប់គួរកត់សម្គាល់ផងដែរថា តាមបទពិសោធន៍ប្រតិបត្តិការកន្លងមក បង្ហាញឱ្យឃើញថា ការអនុវត្តទៅតាមសិទ្ធិ និងគោលការណ៍ ជានិច្ចកាល ជាចំណុចចាប់ផ្តើមនៃការបង្កើតទំនាក់ទំនង ជំនឿជឿជាក់ជាមួយជនរងគ្រោះ ដែលអាចបង្កើននូវសេចក្តីសង្ឃឹមយ៉ាងខ្លាំងចំពោះជនរងគ្រោះឱ្យយល់ព្រមសហការធ្វើជាសាក្សី
- សុវត្ថិភាព និងសុខុមាលភាពរបស់ជនរងគ្រោះ គ្រួសារ និងអ្នកជាទីស្រឡាញ់របស់ពួកគេ ត្រូវបានយកចិត្តទុកដាក់គ្រប់ពេលវេលា ហើយជាការទទួលខុសត្រូវរបស់មន្ត្រីអនុវត្តច្បាប់
- វាជាបញ្ហាសុវត្ថិភាពជាបន្ទាន់របស់ជនដែលត្រូវគេកំណត់ថា ជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស ។ ការទទួលខុសត្រូវបន្តទៀត មន្ត្រីអនុវត្តច្បាប់អាចត្រូវការពិចារណាផងដែរ ទៅលើសុវត្ថិភាព របស់បុគ្គលិកសង្គមកិច្ច ដែលផ្តល់ការគាំពារដល់ជនរងគ្រោះ
- មន្ត្រីអនុវត្តច្បាប់ មានភារកិច្ចវាយតម្លៃលើហានីភ័យដល់សុវត្ថិភាព និងសុខុមាលភាពរបស់ជនរងគ្រោះ និងគ្រួសាររបស់គេ នៅគ្រប់ដំណាក់កាលនៃដំណើរការស៊ើបអង្កេត
- មន្ត្រីអនុវត្តច្បាប់ត្រូវបង្ហាញនូវភាពបើកចំហ និងស្មោះត្រង់ ដែលអាចឱ្យជនរងគ្រោះជឿជាក់ ធ្វើដូចនេះ ជនរងគ្រោះអាចយល់ពីបញ្ហាទទួលខុសត្រូវ ផលវិបាកសំខាន់ៗ និងហានីភ័យកើតមានឡើងមកពីសេចក្តីសម្រេចណាមួយដែលជនរងគ្រោះបានធ្វើ
- មន្ត្រីអនុវត្តច្បាប់ត្រូវធានាថា ជនរងគ្រោះបានទទួលព័ត៌មានពេញលេញជាភាសាដែលខ្លួនអាចយល់បានពីអ្វីដែលជាវិធានការគាំទ្រ ដើម្បីជួយខ្លួនឱ្យជម្នះលើបញ្ហាលំបាក
- ជនរងគ្រោះដោយអំពើជួញដូរមនុស្ស មិនអាចនឹងស្តារស្ថានភាព ដែលខ្លួនបានទទួលរងលើរូបរាងកាយ ផ្លូវភេទ និងចិត្តសាស្ត្របានឡើយ ។ ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ វាមានសារៈសំខាន់ណាស់ចំពោះជនរងគ្រោះត្រូវបានគេផ្តល់នូវសេវាគាំពារ និងថៃរក្សា ដែលអាចជួយឱ្យគេទទួលបានសេវាស្តារនីតិសម្បទាឡើងវិញ ។

### ៤. សេចក្តីត្រូវការជាបន្ទាន់របស់ជនរងគ្រោះ

ត្រូវយកចិត្តទុកដាក់នូវសេចក្តីត្រូវការជាបន្ទាន់របស់ជនរងគ្រោះ ទោះបីជាជនរងគ្រោះត្រៀមរៀបចំខ្លួនសហការ ឬមិនសហការក៏ដោយ ក៏មន្ត្រីអនុវត្តច្បាប់ត្រូវ ៖

- ផ្តល់សុវត្ថិភាពដល់ជនរងគ្រោះ សម្រាប់រយៈពេលខ្លី
- ព្យាបាលរបួស ឬជំងឺដែលទទួលរងពីការប៉ះពាល់សុខភាពផ្នែករាងកាយ និងផ្លូវភេទ
- គាំពារផ្នែកចិត្តសាស្ត្រចំពោះជនរងគ្រោះដែលទទួលរងការប៉ះពាល់ផ្លូវចិត្ត

- ទទួលបានការពិគ្រោះយោបល់ផ្នែកច្បាប់ និងសុខុមាលភាពសង្គម នៅក្នុងអំឡុងពេលនៃការកំណត់ជនណាម្នាក់ជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស ។

មន្ត្រីអនុវត្តច្បាប់ត្រូវធ្វើការកំណត់ពីកម្រិតនៃវិធានការគាំពារនានា ដល់ជនរងគ្រោះ ដូចនេះ កិច្ចសហប្រតិបត្តិការរវាងស្ថាប័នអនុវត្តច្បាប់ និងផ្នែកសេវាគាំពារជនរងគ្រោះ គឺជាការសំខាន់ ហើយបង្កើនការឆ្លើយតបជាដៃគូចម្រុះទៅលើបទល្មើសជួញដូរមនុស្ស ។

| សេចក្តីត្រូវការជាបន្ទាន់របស់ជនរងគ្រោះ | |
|---|---|
| **សុវត្ថិភាព** | មិនត្រូវចាប់ខ្លួន និងត្រូវយកជនរងគ្រោះចេញពីកន្លែងជួញដូរ ហើយនាំទៅកន្លែងមានសុវត្ថិភាព ៖ អង្គភាពនគរបាល មណ្ឌលថែទាំជនរងគ្រោះ មន្ទីរពេទ្យ... |
| **សុខភាព** | ស្វែងរកជំនួយសេវាសុខាភិបាល ដើម្បីពិនិត្យរបួសស្នាម រោគសញ្ញា ឬកង្វះអាហារូបត្ថម្ភ ពិនិត្យសុខភាពផ្លូវភេទ |
| **ការពិគ្រោះយោបល់** | ការវាយតម្លៃលើជំងឺផ្លូវអារម្មណ៍ ផ្តល់នូវការប្រឹក្សា និងគាំពារផ្នែកចិត្តសាស្ត្រ |
| **ការប្រឹក្សាយោបល់** | ពន្យល់ពីជម្រើសផ្នែកច្បាប់ ការទទួលខុសត្រូវ សិទ្ធិទទួលបានទិដ្ឋាការស្នាក់នៅបណ្តោះអាសន្ន និងគាំទ្រដល់ការធ្វើមាតុភូមនិវត្តន៍ |
| **កិច្ចគាំពារ** | ផ្តល់ព័ត៌មានស្តីពីវិធានការជំនួយផ្នែកសង្គម ហិរញ្ញវត្ថុ និងសុខុមាលភាព ។ សម្គាល់ ៖ ភារកិច្ចរបស់អ្នក គឺផ្តល់ឱ្យជនរងគ្រោះទទួលបានសេវាគាំពារ តែមិនមែនផ្តល់កិច្ចគាំពារនោះទេ ។ |

### ក. យុទ្ធសាស្ត្រជាដៃគូ-កិច្ចសហប្រតិបត្តិការ និងវិធានការផ្សេងៗ

នេះគឺជាបញ្ហានៃការយល់ព្រមរួមគ្នារវាងទីភ្នាក់ងារទាំងអស់ ដែលធ្វើការងារនៅក្នុងការប្រឆាំងអំពើជួញដូរមនុស្ស ដែលកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូ រវាងពហុស្ថាប័នគឺជាការសំខាន់ ប្រសិនបើលក្ខណៈនៃឧក្រិដ្ឋកម្មមានភាពស្មុគស្មាញ ដែលតម្រូវឱ្យដោះស្រាយប្រកបដោយភាពត្រឹមត្រូវ ។ ចំពោះគោលការណ៍នេះ ទំនាក់ទំនងរវាងស្ថាប័នអនុវត្តច្បាប់ និងទីភ្នាក់ងារគាំពារជនរងគ្រោះ គឺជាការសំខាន់បំផុត ដោយហេតុថា ពួកគេជាអ្នកប្រឈមនឹងជនរងគ្រោះដោយអំពើជួញដូរមនុស្សមុនគេ និងជាអ្នកត្រូវដោះស្រាយជាមួយជនរងគ្រោះដោយផ្ទាល់ ។

លើសពីនេះទៀត ទំនាក់ទំនងកិច្ចសហប្រតិបត្តិការ គឺបានផ្តល់អត្ថប្រយោជន៍ជាអតិបរមាដល់ជនរងគ្រោះ ។ វាគឺជាការសំខាន់ដែលភាគីទាំងសងខាងទទួលស្គាល់ និងយល់ដឹងពីការទំនាក់ទំនងគ្នាទៅវិញទៅមក ព្រមទាំងមានអត្ថប្រយោជន៍ទាំងសងខាង ។

ចំពោះទស្សនទានរបស់ទីភ្នាក់ងារគាំពារជនរងគ្រោះ ពួកគេអាស្រ័យទៅលើអំណាចផ្នែកច្បាប់ និងសមត្ថភាពរបស់ទីភ្នាក់ងារអនុវត្តច្បាប់ នៅក្នុងកិច្ចអន្តរាគមន៍ជួយសង្គ្រោះជនរងគ្រោះ

ដើម្បីស៊ើបអង្កេត និងចោទប្រកាន់ជនជួញដូរមនុស្ស ។ ចំពោះទស្សនទានរបស់មន្ត្រីអនុវត្តច្បាប់វិញ ពួកគេអាស្រ័យទៅលើទីភ្នាក់ងារគាំពារជនរងគ្រោះ ក្នុងការផ្តល់វិធានការគាំទ្រ ដែលជាមូលដ្ឋាននៃការប្រព្រឹត្តិទៅលើជនរងគ្រោះប្រកបដោយលក្ខណៈអាជីព និងមនុស្សធម៌ ។

នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ មានអង្គការជាតិ អន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលជាច្រើន បានផ្តល់មធ្យោបាយគាំទ្រផ្សេងៗ នៅក្នុងការកំណត់ថា តើជនណាម្នាក់ជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស ។ មធ្យោបាយគាំទ្រទាំងនោះ អាចមានដូចខាងក្រោម ៖

- ផ្តល់ជម្រកស្នាក់នៅជាបណ្តោះអាសន្ន
- វាយតម្លៃទៅលើសុខភាព និងការព្យាបាល
- បកប្រែដល់ជនរងគ្រោះជាភាសាកំណើតរបស់ពួកគេ
- ប្រឹក្សា និងកិច្ចគាំពារផ្នែកច្បាប់
- ធ្វើមាតុភូមិនិវត្តន៍ និងធ្វើសមាហរណកម្មចូលទៅក្នុងសង្គមវិញ ។

សេចក្តីត្រូវការរបស់ជនរងគ្រោះ និងមធ្យោបាយគាំទ្រនានា ដើម្បីដោះស្រាយទៅលើសេចក្តីត្រូវការរបស់ពួកគេ ដែលស្មុគស្មាញ និងតម្រូវឱ្យធ្វើការងារច្រើន ក្រៅពីការងារស្នូល ឬបទពិសោធន៍របស់ស្ថាប័នអនុវត្តច្បាប់ ។ ដូចនេះ ដើម្បីផ្តល់ជំនួយផ្នែកមនុស្សធម៌ដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស វាគឺជាការសំខាន់ដែលថា ស្ថានប័នអនុវត្តច្បាប់ និងទីភ្នាក់ងារគាំពារជនរងគ្រោះធ្វើការងារនៅក្នុងកិច្ចសហប្រតិបត្តិការជិតស្និទ្ធរវាងគ្នាទៅវិញទៅមក ។ ប៉ុន្តែទំនាក់ទំនងនេះ អាចជាបញ្ហាតម្រូវឱ្យមានការប្រុងប្រយ័ត្នខ្លាំង ការបត់បែន និងឆន្ទៈល្អពីភាគីទាំងសងខាង ។

កិច្ចសហប្រតិបត្តិការប្រកបដោយជោគជ័យរវាងភាគីទាំងពីរ តម្រូវឱ្យមានការយោគយល់គ្នា និងឱ្យទទួលយល់ព្រមនូវគំនិតផ្សេងៗពីគ្នា ។ វាជាការសំខាន់ដែលមន្ត្រីនគរបាល យល់ពីកត្តាទាំងអស់នេះ និងបង្កើតឱ្យមានទំនាក់ទំនង ដោយឈរលើមូលដ្ឋាននៃការជឿជាក់គ្នាទៅវិញទៅមក ។ កិច្ចសហប្រតិបត្តិការនេះត្រូវបែងចែករវាងការស៊ើបអង្កេតផ្នែកព្រហ្មទណ្ឌ និងសេវាចិត្តសាស្ត្រ និងសុខុមាលភាពសង្គម ។

**ខ. ការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះ**

នៅក្នុងករណីដែលមានការពាក់ព័ន្ធនឹងជនរងគ្រោះក្នុងស្រុក ឬបរទេស ដោយមូលហេតុផ្សេងៗ មិនអាចត្រឡប់ទៅក្រុមគ្រួសាររបស់ពួកគេវិញ នោះវិធានការគាំទ្រដទៃទៀតដែលអាចមាន គួរតែយកចិត្តទុកដាក់ ទោះបីជនរងគ្រោះសហការ ឬមិនសហការ ជាមួយមន្ត្រីអនុវត្តច្បាប់ក៏ដោយ ។

ទោះបីជនរងគ្រោះបដិសេធមិនសហការជាមួយមន្ត្រីស៊ើបអង្កេតក៏ដោយ ក៏ជនរងគ្រោះនោះស្ថិតនៅក្នុងភាពដែលងាយទទួលរងគ្រោះ ហើយត្រូវការជំនួយគាំទ្រ ។ លើសពីនេះទៀត នៅក្នុងករណីធ្វើមាតុភូមនិវត្តន៍ ជនរងគ្រោះជាជនបរទេសខ្លះមានបញ្ហាទាក់ទងនឹងឯកសារ នៅពេលដែលពួកគេទៅដល់ប្រទេសគោលដៅ ហើយបន្ទាប់មកត្រូវបានគេជួញដូរបន្តទៀត ។ ដូចនេះ គឺជាការសំខាន់ក្នុងការកំណត់ថា ជនណាម្នាក់ជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការទទួលបានយន្តការគាំពារ ដែលអាចកាត់បន្ថយការលំបាកនៃមាតុភូមិនិវត្តន៍ ។

ដើម្បីកាត់បន្ថយហានីភ័យចំពោះការធ្វើមាតុភូមិនិវត្តន៍របស់ជនរងគ្រោះនិងផ្តល់កិច្ចគាំទ្រដល់ការធ្វើសមាហរណកម្មជនរងគ្រោះទៅប្រទេសដើមរបស់ពួកគេវិញ បញ្ហានេះអាចធ្វើទៅបានដោយឱ្យទីភ្នាក់ងារគាំពារជនរងគ្រោះធ្វើការរៀបចំជំនួយគាំទ្រនេះ ។ ដើម្បីសម្រេចបញ្ហានេះ មន្ត្រីស៊ើបអង្កេត ត្រូវយល់ដឹងពីទីភ្នាក់ងារគាំពារជនរងគ្រោះដែលមាននៅក្នុងបណ្តាប្រទេសអាស៊ីអាគ្នេយ៍ ដើម្បីឱ្យដឹងថា តើទីភ្នាក់ងារណាមួយមានសមត្ថភាព និងឆន្ទៈផ្តល់កិច្ចគាំទ្រនោះ ។

ប៉ុន្តែ មុននឹងធ្វើការបញ្ជូនជនរងគ្រោះ មានចំណុចសំខាន់ៗជាច្រើន ដែលត្រូវពិចារណា ៖

- តើជនរងគ្រោះយល់ព្រមទទួលសេវាគាំពារឬទេ? ជានិច្ចកាល ជនរងគ្រោះគួរទទួលបានការពិគ្រោះយោបល់ ហើយគំនិតយល់ព្រមរបស់ខ្លួន និងការអះអាង ត្រូវធ្វើជាលាយលក្ខអក្សរ
- តើមានសុវត្ថិភាពដែរឬទេក្នុងការធ្វើដូច្នេះ? តើមានហានីភ័យដែរឬទេ ក្នុងការស្វែងរកជំនួយពីទីភ្នាក់ងារគាំពារនោះ? ឧទាហរណ៍ ជនរងគ្រោះដោយការកេងប្រវ័ញ្ចផ្លូវភេទ មិនចង់ឱ្យលេចឮរឿងអាស្រូវរបស់ខ្លួនដល់ទីភ្នាក់ងារគាំពារ ។

អាចមានបញ្ហាផ្នែកសាសនា ឬវប្បធម៌សង្គម ដែលត្រូវឱ្យយកចិត្តទុកដាក់ផងដែរ ប្រសិនជនរងគ្រោះកាន់សាសនាឥស្លាម ហើយត្រូវបានគេកេងប្រវ័ញ្ចផ្លូវភេទ ពួកគេអាចប្រឈមនឹងគ្រោះថ្នាក់ធ្ងន់ធ្ងរនៅក្នុងបរិយាកាសគ្រួសារ ប្រសិនបើជនរងគ្រោះ គឺជាកម្មវត្ថុនៃការលក់-ដូរ របស់គ្រួសារពួកគេ ដូចនេះការបញ្ជូនត្រឡប់ទៅក្រុមគ្រួសារវិញ គឺមិនមែនជាជម្រើសល្អនោះទេ ។

- តើទីភ្នាក់ងារគាំពារជនរងគ្រោះ ជួយសង្គ្រោះ និងមានសមត្ថភាពជួយដល់ជនរងគ្រោះដែរឬទេ? ការធានាសុវត្ថិភាព និងសមត្ថភាពទីភ្នាក់ងារគាំពារ គឺមានភាពខុសគ្នា ហើយត្រូវធ្វើការវាយតម្លៃ នៅក្នុងករណីនីមួយៗ
- នៅក្នុងករណីគាំទ្រ ឱ្យមានការធ្វើមាតុភូមិនិវត្តន៍ទៅស្រុកកំណើតវិញ តើមានពេលវេលាគ្រប់គ្រាន់រវាងការធ្វើដំណើរនិងការទៅដល់ ដើម្បីធ្វើការរៀបចំការងារចាំបាច់នានាដែរឬទេ? ការបញ្ជូនជនរងគ្រោះត្រឡប់ទៅប្រទេសដើមវិញ ជាធម្មតា គឺមានរយៈពេលខ្លី ប៉ុន្តែអាចមិនមានពេលគ្រប់គ្រាន់ ក្នុងការធ្វើទំនាក់ទំនងជាមួយទីភ្នាក់ងារគាំពារជនរងគ្រោះឡើយ ។ ដូចនេះ ជាការចាំបាច់ត្រូវបង្កើតទំនាក់ទំនងជាមុនជាមួយអាជ្ញាធរអន្តោប្រវេសន៍ ដើម្បីពន្យាពេលការបញ្ជូនជនរងគ្រោះត្រឡប់ទៅវិញ ហើយរង់ចាំការរៀបចំឱ្យបានសព្វគ្រប់ ។

## III. សេចក្តីសង្ខេប

### ផ្នែកទី១-ការកំណត់ថាជនណាម្នាក់ជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស

- ការកំណត់ឱ្យបានត្រឹមត្រូវ ថាជនណាម្នាក់ជា ជនរងគ្រោះដោយអំពើជួញដូរមនុស្ស មានមូលហេតុ ៣ ៖
    - ជនរងគ្រោះពិតប្រាកដ ត្រូវការជំនួយផ្នែកសុខភាពយ៉ាងខ្លាំង និងជាបន្ទាន់ ទាក់ទងទៅនឹងរាងកាយ ផ្លូវភេទ និងចិត្តសាស្ត្រ
    - ស្តង់ដាអន្តរជាតិបានចែងយ៉ាងច្បាស់ថា ជនដែលត្រូវគេកំណត់ថា ជាជនរងគ្រោះមិនត្រូវផ្តន្ទាទោស ឬធ្វើឱ្យប៉ះពាល់ផ្នែកផ្លូវចិត្តម្តងទៀត ហើយនីតិវិធីកំណត់ថា ជនណាម្នាក់ជាជនរង

គ្រោះឱ្យបានច្បាស់លាស់ គឺជាការសំខាន់ ប្រសិនបើស្តង់ដារនេះ ត្រូវបានគេអនុវត្ត

- ការស៊ើបអង្កេតប្រកបដោយប្រសិទ្ធភាព គឺតម្រូវឱ្យមានការកំណត់ប្រភេទបទល្មើសឱ្យបានត្រឹមត្រូវ ។

• ដំណើរការនៃការកំណត់ជនរងគ្រោះ គឺអាស្រ័យទៅលើយុទ្ធសាស្រ្ត ដែលត្រូវយកចិត្តទុកដាក់ទៅលើការប្រឈមក្នុងការកំណត់ជនរងគ្រោះ ដែលទាក់ទងនឹងទស្សនទាន គឺច្បាប់ ជនល្មើស និងជនរងគ្រោះ ។ គោលបំណងនៃការកំណត់ជនរងគ្រោះ និងការវាយតម្លៃ លើព័ត៌មានដែលមាននៅក្នុងទស្សនទាននេះ គឺដើម្បីធ្វើការកំណត់ឱ្យបានត្រឹមត្រូវ ពីស្ថានភាពរបស់បុគ្គលម្នាក់ៗ

• ភារកិច្ចចម្បង គឺការបែងចែកភាពខុសគ្នារវាង ជនត្រូវគេជួញដូរ និងជនត្រូវគេរត់ពន្ធ

• បើមានវិធីសាស្ត្រដូចគ្នាកើតឡើងចំពោះស្ថានភាពទាំងពីរនេះ គឺមានបញ្ហាគន្លឹះផ្សេងៗជាច្រើន ។ គោលការណ៍ទីមួយគឺថា ទំនាក់ទំនងរវាងអ្នករត់ពន្ធមនុស្ស និងជនដែលត្រូវគេរត់ពន្ធ ត្រូវបានបញ្ចប់ នៅពេលដែលចូលទៅក្នុងប្រទេសគោលដៅដោយខុសច្បាប់ទទួលបានជោគជ័យ ចំណែកឯទំនាក់ទំនងជនជួញដូរមនុស្ស និងជនរងគ្រោះដែលត្រូវគេជួញដូរ គឺលើសពីនេះ ដោយមានការបន្តទំនាក់ទំនងតទៅទៀត ដែលទំនាក់ទំនងនេះ មានលក្ខណៈជាការបង្ខំ និងកេងប្រវ័ញ្ច ។

• ដំណើរការនៃការកំណត់ជនរងគ្រោះ មាន ៤ ដំណាក់កាល ៖

  - ដំណាក់កាលទី១-វាយតម្លៃទៅលើសូចនាករផ្សេងៗ

    ▪ ដំណើរការវាយតម្លៃ ត្រូវពិនិត្យមើលចំណុចផ្សេងៗ ដូចជា អាយុ សញ្ជាតិ ភេទ ឯកសារ និងកាលៈទេសៈនានា... ដែលធ្វើឱ្យមន្ត្រីអនុវត្តច្បាប់ អាចធ្វើការវាយតម្លៃលើជនណាម្នាក់មុនការធ្វើសម្ភាស

    ▪ ចំណុចសំខាន់ៗនៃការកត់សម្គាល់មាន ៖

      - ធ្វើការកំណត់ជនរងគ្រោះឱ្យបានត្រឹមត្រូវ ពីព្រោះនៅក្នុងរឿងក្តីជាច្រើន ជនដែលពាក់ព័ន្ធ អាចជួនកាល បដិសេធឆ្លើយទៅនឹងសំណួរនានា ឬផ្តល់តែព័ត៌មានតិចតួច ឬមិនពិតប្រាកដនៅក្នុងអំឡុងពេលធ្វើការសម្ភាស

      - អាចនឹងប្រើប្រាស់បាន លុះត្រាតែត្រូវបានពិនិត្យ និងសម្របទៅនឹងស្ថានភាពក្នុងស្រុក និងវិធីជួញដូរមនុស្ស

      - មិនអាចបង្កើតឱ្យមានប្រព័ន្ធបង្ហាញភស្តុតាងពេញលេញក្នុងការកំណត់ជនណាម្នាក់ជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស ។

  - ដំណាក់កាលទី២-រៀបចំរចនាសម្ព័ន្ធនៃសំណួរសម្រាប់ធ្វើការសម្ភាស

    ▪ ការសម្ភាសរៀបចំឱ្យមានជារចនាសម្ព័ន្ធ ក្នុងការសម្ភាសជាមួយបុគ្គលមានការភ័យខ្លាច ជំងឺផ្លូវអារម្មណ៍ មិនមានភាពស្និទ្ធស្នាល មិនមានភាពទុកចិត្ត ឬមានស្ថានភាពទាំងអស់នេះ

    ▪ ការសម្ភាស ជាការប្រឈមចំពោះអ្នកសម្ភាស និងតម្រូវឱ្យមានការប្រុងប្រយ័ត្ន

    ▪ ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ភាគច្រើនទទួលរងការប៉ះពាល់ផ្លូវអារម្មណ៍ ជាលទ្ធផលអាចធ្វើឱ្យជះឥទ្ធិពលលើអាកប្បកិរិយាក្នុងការសម្ភាស ។ ការប៉ះពាល់ផ្លូវអារម្មណ៍ គឺបង្ហាញឱ្យឃើញនូវភាពខុសៗគ្នា ហើយអាចរារាំងដល់ជនរងគ្រោះ ក្នុងការទទួលស្គាល់ខ្លួនឯងជា

ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ឬមិនឱ្យផ្តល់ចម្លើយដល់អ្នកសម្ភាស

- ការជ្រើសរើសមន្ត្រីសម្ភាស ត្រូវមានការយល់ដឹងពីកត្តាទាំងនេះ និងផ្តល់ព័ត៌មានចាំបាច់ទៅឱ្យមន្ត្រីសម្ភាសនោះ ។ បើមានជនណាម្នាក់ ដែលគេជឿជាក់ថា ទទួលរងនូវការប៉ះពាល់ផ្លូវអារម្មណ៍ ជននោះគួរតែទទួលបានកិច្ចគាំពារផ្នែកចិត្តសាស្ត្រ ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន
- ការសម្ភាស គួរតែធ្វើទៅតាមគោលការណ៍ណែនាំ ដូចខាងក្រោម ៖
  - បើជនរងគ្រោះ មិនមានការយល់ដឹងគ្រប់គ្រាន់ពីភាសា ត្រូវតែផ្តល់អ្នកបកប្រែភាសា កំណើតរបស់ពួកគាត់
  - ប្រសិនបើជនរងគ្រោះ ទំនងជាទទួលរងការប៉ះពាល់ផ្លូវអារម្មណ៍ ត្រូវមានជំនួយពីអ្នកពិគ្រោះយោបល់ជំនាញផ្នែកចិត្តសាស្ត្រ
  - ប្រសិនបើចាំបាច់ ត្រូវមានអ្នកពិគ្រោះយោបល់ផ្នែកច្បាប់
  - កុមារដែលជាជនរងគ្រោះ គឺងាយទទួលរងគ្រោះថ្នាក់ខ្លាំង ដូចនេះការសម្ភាសត្រូវធ្វើឡើង ដោយមានវត្តមានរបស់ភាគីឯករាជ្យទីបី និងអ្នកពិគ្រោះយោបល់ជំនាញផ្នែកចិត្តសាស្ត្រ និងអ្នកពិគ្រោះយោបល់ផ្នែកច្បាប់
  - សំណួរនានាត្រូវមានការរឹតត្បឹត ហើយការលើកជាសំណួរ គឺដើម្បីរកមូលដ្ឋានឱ្យជឿជាក់ថា កុមារត្រូវបានគេជួញដូរ ហើយត្រូវព្យាយាមបន្តរកជំនួយឯកទេស និងត្រូវបញ្ជូនកុមារជាបន្ទាន់ទៅកន្លែងដែលមានសុវត្ថិភាព និងសមស្រប ។
- មន្ត្រីសម្ភាស គួរតែយកចិត្តទុកដាក់ជាពិសេស ដើម្បីធានាថា លក្ខខណ្ឌនានានៃការសម្ភាស មានភាពសមស្រប ហើយធានាថា តួនាទីរបស់បុគ្គលដែលមានវត្តមាននៅពេលសម្ភាស គួរតែពន្យល់ឱ្យបានច្បាស់លាស់ ទៅដល់អ្នកឆ្លើយសម្ភាសជាមុន
- រចនាសម្ព័ន្ធនៃការសម្ភាស រួមមាន ៣ ដំណាក់កាលនៃបទល្មើស ដែលទាក់ទងនឹងដំណាក់កាល ជ្រើសរើស ដឹកជញ្ជូន និងកេងប្រវ័ញ្ច ។ ការសម្ភាសនេះ គួរគិតទៅដល់ផងដែរ ពីព័ត៌មានបំពេញបន្ថែមផ្សេងទៀត ដូចជា ឯកសារ កំណត់ហេតុផ្ទាល់ខ្លួន លិខិតធ្វើដំណើរ ។ល។
- ការសម្ភាសអាចទទួលបានលទ្ធផលល្អប្រសើរ ប្រសិនបើរចនាសម្ព័ន្ធនៃការសម្ភាសនោះត្រូវបានគេពិនិត្យ និងសម្របទៅនឹងលក្ខខណ្ឌនៅក្នុងស្រុក និងវិធីជួញដូរមនុស្ស
- វាជាការសំខាន់ក្នុងការកត់សម្គាល់ថា សំណួរ និងចម្លើយនីមួយៗ អាចត្រូវបានគេបកស្រាយ នៅក្នុងរបៀបផ្សេងៗគ្នា ហើយគ្មានចម្លើយណាមួយអាចផ្តល់នូវការកំណត់ថា ជនណាម្នាក់ ជាជនរងគ្រោះទាំងស្រុងបាននោះទេ ។ ដំណើរការនៃការកំណត់ជនរងគ្រោះ គឺត្រូវមានការបញ្ចូលគ្នា រវាងការវាយតម្លៃ និងការសម្រេច ។

○ ដំណាក់កាលទី៣-វាយតម្លៃភស្តុតាងបំពេញបន្ថែម ៖ តម្រូវឱ្យមន្ត្រីទទួលបន្ទុក ធ្វើការសម្ភាស ស្វែងរកភស្តុតាងបន្ថែម ដែលអាចបំពេញបន្ថែមទៅលើសូចនាករនានា និង/ឬ ចម្លើយដែលផ្តល់ដោយបុគ្គលនោះ ។

○ ដំណាក់កាលទី៤-ធ្វើការសម្រេចចិត្ត

- ជាភារកិច្ចរបស់មន្ត្រីទទួលបន្ទុកធ្វើការសម្ភាស ក្នុងការវិភាគ និងវាយតម្លៃទៅលើ

សូចនាករជារួម ចំពោះចម្លើយណាមួយដែលបានផ្តល់នៅក្នុងអំឡុងពេលធ្វើការសម្ភាស និងភស្តុតាងបំពេញបន្ថែមណាមួយ ហើយបន្ទាប់មក ធ្វើការសម្រេចចិត្ត ថាតើបុគ្គលនោះ គឺជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស ឬមិនមែន

- ប្រសិនបើការសម្រេចចិត្តថា ជននោះគឺជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស ត្រូវអនុវត្តការប្រព្រឹត្តិទៅលើជននោះ ក្នុងឋានៈជាជនរងគ្រោះ ។

**ផ្នែកទី២-ការប្រព្រឹត្តិទៅលើជនរងគ្រោះដោយអំពើជួញដូរមនុស្ស**

- យោងទៅតាមអនុសាសន៍នៃគោលការណ៍និងសេចក្តីណែនាំស្តីពីសិទ្ធិមនុស្ស និងការជួញដូរមនុស្ស ៖ ជនដែលត្រូវគេជួញដូរ មិនត្រូវបានឃុំឃាំង ចោទប្រកាន់ ឬផ្តន្ទាទោស ចំពោះសកម្មភាពចូលទៅក្នុងប្រទេសណាមួយដោយខុសច្បាប់ ឬស្នាក់នៅក្នុងប្រទេសឆ្លងកាត់ និងប្រទេសគោលដៅដោយខុសច្បាប់ ឬចំពោះការពាក់ព័ន្ធនៃសកម្មភាពខុសច្បាប់ ដែលសកម្មភាពនេះ គឺជាលទ្ធផលដោយផ្ទាល់នៃស្ថានភាពរបស់ជនដែលត្រូវគេជួញដូរ
- មន្ត្រីអនុវត្តច្បាប់ គួរអនុវត្តទៅតាមគោលការណ៍ទាំង៥ នៃការអនុវត្តល្អៗ ទាក់ទងទៅនឹងការកំណត់ជនណាម្នាក់ ជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស
- ជនរងគ្រោះដោយអំពើជួញដូរមនុស្សភាគច្រើន គឺតែងតែមានសេចក្តីត្រូវការខ្លាំង និង និងជាបន្ទាន់ ។

**ផ្នែកទី៣-គោលការណ៍ណែនាំស្តីពី "បែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណបឋមជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប"**

- គោលបំណងនៃការណែនាំស្តីពី "បែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណបឋមជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប" គឺសម្រួលឱ្យការកំណត់អត្តសញ្ញាណជនរងគ្រោះ តាមរយៈការសង្កេត សាកសួរ ប្រមូលព័ត៌មាន និងស្វែងរកភាពរងគ្រោះរបស់បុគ្គលណាម្នាក់ដែលសង្ស័យថា រងគ្រោះដោយអំពើជួញដូរមនុស្ស ហើយអាចសន្និដ្ឋានដើម្បីធ្វើការសន្មត ជាបណ្តោះអាសន្នថា "ជាជនរងគ្រោះ" សម្រាប់ផ្តល់កិច្ចការពារ ការគាំពារ និងសេវាសមស្រប ជួយជនរងគ្រោះបានទាន់ពេលវេលា ប្រកបដោយមនុស្សធម៌ មិនរើសអើង មុនការស៊ើបអង្កេត ស្រាវជ្រាវ តាមនីតិវិធីតុលាការ
- ហេតុអ្វីបានជាការកំណត់អត្តសញ្ញាណជនរងគ្រោះមានសារៈសំខាន់? ប្រសិនបើមិនមានការកំណត់អត្តសញ្ញាណជនរងគ្រោះទេ អ្នកផ្តល់សេវានឹងមិនដឹងថា ជននោះ រងគ្រោះ ឬមិនរងគ្រោះដោយអំពើជួញដូរមនុស្ស ហើយមិនអាចប៉ាន់ប្រមាណបានអំពីទំហំនៃភាពរងគ្រោះ ដើម្បីធ្វើគោលនយោបាយ ផែនការកម្មវិធី ឬសកម្មភាពឆ្លើយតបជាក់លាក់សម្រាប់ការងារបង្ការទប់ស្កាត់ការជួញដូរមនុស្ស ការផ្តល់កិច្ចការពារ និងគាំពារជនរងគ្រោះ ឬចាប់ជនល្មើសមកផ្តន្ទាទោសបានឡើយ ។ ហេតុនេះហើយ ការកំណត់អត្តសញ្ញាណជនរងគ្រោះ មានសារៈសំខាន់ណាស់ ក្នុងការរួមចំណែកលុបបំបាត់អំពើជួញដូរមនុស្ស ។

ការកំណត់អត្តសញ្ញាណជនរងគ្រោះ នឹងអាចនាំទៅដល់ការយល់ដឹងអំពីស្ថានភាព និងសេចក្តីត្រូវការរបស់ជនរងគ្រោះ ដើម្បីឆ្លើយតបឱ្យបានសមស្រប ដូចជា តម្រូវការផ្នែកសន្តិសុខ សុវត្ថិភាព ការព្យាបាលសុខភាពផ្លូវកាយ ផ្លូវចិត្ត/អារម្មណ៍ ជម្រកសុវត្ថិភាពបណ្តោះអាសន្ន ការស្តារនីតិសម្បទា ការធ្វើសមាហរណកម្ម និងការផ្តល់ជំនួយផ្នែកច្បាប់សម្រាប់ជនរងគ្រោះជាដើម ។

ការកំណត់អត្តសញ្ញាណជនរងគ្រោះ អាចផ្តល់នូវព័ត៌មានជាច្រើន ពាក់ព័ន្ធនឹងជនរងគ្រោះដទៃទៀតដែលត្រូវសង្គ្រោះ និងអាចនាំទៅរកការកំណត់មុខសញ្ញាជនជួញដូរមនុស្ស និងបណ្តាញជនល្មើស ដើម្បីយកមកផ្តន្ទាទោស ព្រមទាំងអាចកំណត់បទល្មើសពាក់ព័ន្ធផ្សេងទៀត ដែលជនល្មើស និងបណ្តាញរបស់ពួកវាបានប្រព្រឹត្ត ដូចជា ការសម្អាតប្រាក់ អំពើពុករលួយ ការធ្វើចរាចរគ្រឿងញៀន ។ល។

បើសិនជាការកំណត់អត្តសញ្ញាណនេះមិនអាចធ្វើបាន ឬមិនបានត្រឹមត្រូវ នោះនឹងអាចធ្វើឱ្យជនរងគ្រោះកាន់តែឈឺចាប់ មិនបានទទួលការគាំពារ និងសុវត្ថិភាពផ្លូវចិត្ត ផ្លូវកាយ ព្រមទាំងធ្វើឱ្យបាត់បង់ឱកាសក្នុងការបង្ក្រាបជនល្មើស ហើយជនល្មើសមានឱកាសបន្តប្រព្រឹត្តបទល្មើស និងបង្កភាពរងគ្រោះជាថ្មីទៀត ដល់ជនរងគ្រោះ ។

- ហេតុអ្វីបានជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ តែងតែរារែកក្នុងការកំណត់អត្តសញ្ញាណខ្លួន? ជាទូទៅ ជនដែលរងគ្រោះ ច្រើនតែពឹងផ្អែកលើជនជួញដូរមនុស្ស មេខ្យល់ ឬថៅកែ ដែលបានសន្យាថា នឹងផ្តល់ផលប្រយោជន៍ដល់ខ្លួន ធ្វើឱ្យជនរងគ្រោះមិនដឹងថាខ្លួនកំពុងតែរងគ្រោះ ឬស្ថិតក្នុងស្ថានភាពរងគ្រោះ ព្រោះតែល្បិចកលប៉ិនប្រសប់របស់ជនល្មើស និងអ្នកពាក់ព័ន្ធ ។ ករណីខ្លះ ជនរងគ្រោះកំពុងស្ថិតក្នុងស្ថានភាពរងការគំរាមកំហែង ដែលមិនអាចដកខ្លួនបាន ។ ករណីខ្លះទៀត ជនល្មើសអាចជាអ្នកមានទំនាក់ទំនងជិតស្និទ្ធជាមួយជនរងគ្រោះ ជាសាច់ញាតិ ជាមិត្តភ័ក្តិ ជាដៃគូស្នេហា ជាអ្នកមានគុណ ឬជាអ្នកមានអំណាចលើខ្លួន ។ល។

ហេតុនេះ ជនរងគ្រោះភាគច្រើន ស្នើសុំត្រឹមតែជំនួយសង្គ្រោះបន្ទាន់ ឬការស្តារនីតិសម្បទា ឬជម្រើសក្នុងការរស់នៅដែលមានសុវត្ថិភាព ជាជាងការប្តឹងទាមទារឱ្យផ្តន្ទាទោសជនល្មើស និងអ្នកពាក់ព័ន្ធ ។

- លក្ខណៈសម្គាល់បុគ្គលដែលជាជនរងគ្រោះ ៖
    - ផលប៉ះពាល់ដល់សុខភាពរាងកាយ
    - ផលប៉ះពាល់ដល់សុខភាពផ្លូវភេទ
    - ផលប៉ះពាល់ដល់សុខភាពផ្លូវចិត្ត
    - ផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុ
- ការកំណត់អំពីអាយុរបស់ជនរងគ្រោះ ត្រូវផ្អែកជាសំខាន់លើសំបុត្រកំណើត ប័ណ្ណគ្រួសារ សៀវភៅស្នាក់នៅ អត្តសញ្ញាណប័ណ្ណ ឬលិខិតបញ្ជាក់ ដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច។ ក្នុងករណីមិនមានឯកសារខាងលើទេ ការកំណត់អាយុរបស់ជនរងគ្រោះ ត្រូវធ្វើឡើងដោយអ្នកជំនាញបច្ចេកទេសវេជ្ជសាស្ត្រ ដែលមាននីតិសម្បទា ។ ក្នុងករណីជនរងគ្រោះ មិនត្រូវបានដឹងអាយុពិតប្រាកដ ប៉ុន្តែ **<u>សង្ស័យថាជាកុមារ</u>** ត្រូវចាត់ទុកជនរងគ្រោះនោះ ជាកុមាររហូត

- នីតិវិធីនៃការកំណត់អត្តសញ្ញាណបឋមរបស់ជនរងគ្រោះ

អ្នកមានភារកិច្ចកំណត់អត្តសញ្ញាណបឋមជនរងគ្រោះ ចាំបាច់ត្រូវយកចិត្តទុកដាក់អនុវត្តទៅតាមនីតិវិធី ដូចខាងក្រោម៖




- វិធីសាស្ត្រ និងទម្រង់បែបបទសម្រាប់សម្ភាសន៍កំណត់អត្តសញ្ញាណជនរងគ្រោះ
  - វិធីសាស្ត្រ និងទម្រង់បែបបទសម្ភាសន៍រហ័ស ៖ មន្ត្រីអនុវត្តច្បាប់ និងទីភ្នាក់ងារ

ផ្ដល់សេវាគាំទ្រជនរងគ្រោះ ជួនកាលមិនមានពេលវេលាគ្រប់គ្រាន់សម្រាប់ស្រង់យកព័ត៌មានគ្រប់ជ្រុងជ្រោយ ពីជនរងគ្រោះក្នុងពេលបន្ទាន់ភ្លាមៗឡើយ ។ ករណី បន្ទាន់ទាំងនោះ មានដូចជា ៖ ជនរងគ្រោះត្រូវការជំនួយគាំទ្រសង្គ្រោះបន្ទាន់ភ្លាមៗ ហើយមិនអាចមានលទ្ធភាព ឬពេលវេលាគ្រប់គ្រាន់ដើម្បីទទួលយកការសម្ភាសវែងបាន ឬជនរងគ្រោះកំពុងស្ថិតនៅក្នុងស្ថានភាពគំរាមកំហែងនៅឡើយ កាលៈទេសៈ និងមជ្ឈដ្ឋានជុំវិញ មិនអនុញ្ញាតឱ្យមានការយកព័ត៌មានលម្អិតបានជាដើម ។ ទម្រង់នេះក៏អាចប្រើបានដែរ សម្រាប់ការផ្ដល់ព័ត៌មានពីក្រុមគ្រួសារ ឬមិត្តភ័ក្តិ ឬ អ្នកដទៃទៀត ដែលបានដឹងព័ត៌មានច្បាស់អំពីជនរងគ្រោះ។

- សារៈសំខាន់នៃការប្រើប្រាស់ទម្រង់ខ្លី ៖ ក្នុងស្ថានភាពចាំបាច់បែបនេះ ទម្រង់ខ្លីអាចជួយផ្ដល់ព័ត៌មានបណ្ដោះអាសន្នពីជនរងគ្រោះ សម្រាប់ឈានដល់ការសន្និដ្ឋានថា "ជាជនរងគ្រោះ"

ដើម្បីផ្តល់សេវាសង្គ្រោះបន្ទាន់ និងការពារសុវត្ថិភាព តាមការចាំបាច់ ។ ក្នុងករណីនេះ ក្រោយពីទទួលបានដំណឹងថាមានបទល្មើសកើតឡើង ឬ ទទួលព័ត៌មានពីជនរងគ្រោះ ឬ ក្រុមគ្រួសាររបស់ជនរងគ្រោះ មន្ត្រីអនុវត្តច្បាប់ និងទីភ្នាក់ងារផ្តល់សេវាគាំទ្រជនរងគ្រោះ ត្រូវប្រើប្រាស់ទម្រង់ហើស សម្រាប់កំណត់អត្តសញ្ញាណជនរងគ្រោះ ដូចមានភ្ជាប់ក្នុង"ឧបសម្ព័ន្ធ២"

- សូចនាករស្តីពីអំពើជួញដូរមនុស្ស មាន សកម្មភាព មធ្យោបាយ គោលបំណង។ ការប្រព្រឹត្តសកម្មភាពដោយប្រើប្រាស់មធ្យោបាយខាងលើ ត្រូវធ្វើឡើងក្នុងគោលដៅណាមួយដូចជាកេងប្រវ័ញ្ចលើពេស្យាកម្មជនដទៃ ឈ្លានពានខាងផ្លូវភេទ សេវា ឬ ពលកម្ម ដោយបង្ខំ ទាសភាព ឬ សេវភាព ការដកហូតសរីរាង្គ ស្វែងរកប្រយោជន៍ ឬការកេងប្រវ័ញ្ចន៍ ផលិតរូបភាព និងសម្ភារអាសអាភាស អាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈ សុំកូន ការបញ្ចាំខ្លួនដោះបំណុល ពលកម្មកុមារ ។ល។

ក្នុងករណីដែលជនរងគ្រោះ ផ្តល់ព័ត៌មានជាតម្រុយដែលអាចរកឃើញថា មានជាតុផ្សំយ៉ាង ហោចណាស់ចំនួនពីរ នៅក្រោមជាតុផ្សំពីរប្រភេទផ្សេងគ្នា នោះអ្នកដែលរងគ្រោះដោយបទល្មើសខាងលើ អាចត្រូវចាត់ទុកជាបណ្តោះអាសន្ន ថាជា"ជនរងគ្រោះ" ដោយអំពើជួញដូរមនុស្ស។

ប្រសិនបើរកឃើញមានជាតុផ្សំតែមួយ ឬរកមិនឃើញជាតុផ្សំណាមួយទាល់តែសោះ នោះករណីនេះ មិនអាចសន្និដ្ឋានថាជាបទល្មើសពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សឡើយ ។ ដូច្នេះ មន្ត្រីសម្ភាសគប្បីបញ្ជូនព័ត៌មានពាក់ព័ន្ធនឹងអ្នកដែលអះអាងថា មានការរងគ្រោះទៅសមត្ថកិច្ច ដើម្បីស្រាវជ្រាវបន្ត និងណែនាំសាមីខ្លួន ឱ្យទៅកាន់ស្ថាប័នដែលមានសមត្ថកិច្ចពាក់ព័ន្ធសមស្របដទៃទៀត ប្រសិនបើសាមីខ្លួនយល់ព្រម ។

**កំណត់សម្គាល់៖** ប្រសិនបើជននោះជាកុមារ ដែលមានអាយុក្រោម ១៨ ឆ្នាំ ទោះបីជារកឃើញជាតុផ្សំតែមួយ (ដោយមិនគិតពីមធ្យោបាយ) ក៏ដោយ ក៏កុមារនោះ នៅតែត្រូវចាត់ទុកជាបណ្តោះអាសន្នថាជា ជនរងគ្រោះ ដោយអំពើជួញដូរមនុស្សដែរ ។

ក្នុងករណីសង្ស័យថា ជនរងគ្រោះ ពាក់ព័ន្ធនឹងអំពើជួញដូរផ្លូវភេទ មន្ត្រីសម្ភាសគប្បីប្រើសំណួរជាក់លាក់ ដើម្បីងាយស្រួលក្នុងការវិភាគសន្និដ្ឋាន ។ ក្នុងករណីរកឃើញថា មានអំពើធ្វើអាជីវកម្មផ្លូវភេទណាមួយ ក្នុងចំណោមអំពើទាំងបួនប្រភេទ ដូចបានរៀបរាប់ខាងដើម ដូចជា (អំពើសញ្ជារកម្ម អំពើពេស្យាចារ រូបភាព និងសម្ភារអាសអាភាស និងអំពើអាសប្រឆាំងនឹងអនីតិជនអាយុក្រោម ១៥ ឆ្នាំ) នោះអ្នកដែលរងគ្រោះ ដោយបទល្មើសទាំងនេះគឺជា "ជនរងគ្រោះ"ដោយសារអំពើធ្វើអាជីវកម្មផ្លូវភេទ ។ ការកំណត់ជាតុផ្សំ នៃអំពើធ្វើអាជីវកម្មផ្លូវភេទ ត្រូវធ្វើឡើងស្របទៅតាម"កំណត់ពន្យល់មាត្រានីមួយៗនៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ"។

- វិធីសាស្ត្រ និងទម្រង់បែបបទសម្ភាសន៍លម្អិត ៖ ការសម្ភាសលម្អិតទៅលើជនដែលសង្ស័យថារងគ្រោះ ដោយផ្ទាល់ ត្រូវបានរៀបចំធ្វើឡើងតាមពេលវេលា និងទីកន្លែងសមស្រប ជាពិសេសនៅពេលដែលជនរងគ្រោះមានអារម្មណ៍ និងមានជំនឿទុកចិត្ត លែងតក់ស្លុត ភ័យខ្លាច ហេវហត់ ភ័ន្តភាំងស្មារតីជាដើម និងយល់ព្រមផ្តល់ការសម្ភាស ។ បន្ទាប់ពីទទួលបានការយល់ព្រមពីជនដែលសង្ស័យថារងគ្រោះ អ្នកធ្វើសម្ភាសន៍ត្រូវផ្តើមសំណួរតាមទម្រង់ សម្រាប់ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលមានភ្ជាប់ជា "ឧបសម្ព័ន្ធទី៣" ។ លើសពីនេះទៅទៀត មន្ត្រី

សម្ភាសត្រូវប្រកាន់ខ្ជាប់នូវ វិធីសាស្ត្រ និងក្រមសីលធម៌ក្នុងការសម្ភាស ។

ក្នុងករណីរកឃើញតម្រុយដែលអាចបញ្ជាក់ថា បុគ្គលនោះ អាចជាជនសង្ស័យប្រព្រឹត្តបទល្មើសពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ឬ អំពើធ្វើអាជីវកម្មផ្លូវភេទទៅវិញនោះ មន្ត្រីធ្វើសម្ភាស ត្រូវរាយការណ៍ជាបន្ទាន់ទៅកាន់អាជ្ញាធរមានសមត្ថកិច្ច ដើម្បីចាត់ការតាមនីតិវិធីច្បាប់ជាធរមាន ។

- នីតិវិធីនៃការបញ្ជូនជនរងគ្រោះ

**គំនូសបំព្រួញនៃប្រព័ន្ធបញ្ជូន**



# ឯកសារយោង

- ឯកសារមេរៀនរបស់អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ ២០០៣
  - Bourg, Wendy et al; *A Child Interviewer's Guidebook*, Thousand Oaks, CA: Sage Publications, 1999
  - Goodman, Gail; Bottoms, Bette; *Child Victims, Child Witnesses: Understanding and Improving Testimony*, New York, NY: The Guilford Press, 1993
  - Mapes, Bruce; *Child Eyewitness Testimony in Sexual Abuse Investigations*, Brandon, VT: Clinical Psychology Publishing Co., 1995
  - Milne, Rebecca; Bull, Ray; *Investigative Interviewing: Psychology and Practice*, Chichester, West Sussex, UK: John Wiley & Sons Press, 1999
  - Morgan, Marcia; *How to Interview Sexual Abuse Victims Including the Use Of Anatomical Dolls*, Thousand Oaks, CA: Sage Publications, 1995
  - Poole, Debra A; *Investigative Interviews of Children: A Guide for Helping Professionals*, Washington, DC: American Psychological Association, 1998
  - Schafer, John; Navarro, Joe; *Advanced Interviewing Techniques: Proven Strategies for Law Enforcement, Military, and Security Personnel*, Springfield. IL: Thomas Books, 2003
  - Shuy, Roger W.; *The Language of Confession, Interrogation, and Deception*, Thousand Oaks, CA: Sage Publications, 1998
  - Swanson, Charles R. et al; *Criminal Investigation*, Boston, MA: McGraw Hill Publications, 2003, 8th edition
  - Yeschke, Charles; *The Art of Investigative Interviewing: A Human Approach to Testimonial Evidence*, Boston, MA: Butterworth-Heinemann Press, 1997

  **MANUALS USED**

  - Faller, Kathleen C.; *Child Sexual Abuse: Intervention and Treatment Issues*, U.S. Department of Health and Human Services Administration for Children and Families, McLean, VA: The Circle, Inc, 1993
  - Ministry of Interior, General Director of National Police, Kingdom of Cambodia; *Understanding and Investigating Child Sexual Exploitation*, Law Enforcement Against Sexual Exploitation and Trafficking of Children Project, 2000
  - Ministry of Interior, General Director of National Police, Kingdom of Cambodia; *Training Document on Child Victim Sensitivity*, Law Enforcement Against Sexual Exploitation and Trafficking of Children Project, 2003
  - Sas, Louise; *The Interaction Between Children's Developmental Capabilities and the Courtroom Environment: The Impact on Testimonial Competency*, Report prepared for the Department of Justice Canada, 2002

  **OTHER MATERIALS USED**

  - U. S. Department of State Trafficking in Persons Report, 2004

  **WEB SITES USED**

  - HTTP://www.childdevelopmentinfo.com/development/language_development.shtml
  - HTTP://www.families.qld.gov.au/projectaxis/orgbooklet/development.html
  - HTTP://danenet.wicip.org/dcccrsa/saissues/parent/1.html
  - HTTP://www.aacap.org/publications/factsfam/develop.htm
  - HTTP://www.secasa.com.au/index.php/family/12/120
  - HTTP://www.earlychildhoodbehavioralhealth.com/ChildDev/sexdevelop.htl
  - HTTP://www.ces.perdue.edu/providerparent/Child%20Growth-Development/SexualDEV.htm
  - HTTP://www.state.gov/g/tip/rls/tiprpt/2004/34021pf.htm

- ឯកសារមេរៀនរបស់ ARTIP ២០០៩
- គោលការណ៍ណែនាំស្តីពី បែបបទ និងនីតិវិធី នៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប (ប្រកាសលេខ ១៣៣/១២ ប្រ.ក ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ២០១៥ ) ។

# ឧបសម្ព័ន្ធ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

# គោលការណ៍ណែនាំ

## ស្តីពី

# បែបបទ និងនីតិវិធី

# នៃការកំណត់អត្តសញ្ញាណជនរងគ្រោះ

# ដោយអំពើជួញដូរមនុស្ស

# ដើម្បីផ្តល់សេវាសមស្រប

ដឹកនាំរៀបចំខ្លឹមសារ ដោយៈ  ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងស្ថាប័នពាក់ព័ន្ធ

កែសម្រួលដោយ ៖ ក្រុមបច្ចេកទេស នៃ គ.ជ.ប.ជ និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ

www.ncct.gov.kh

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**

លេខៈ ១៣៣/១២ ប្រ.ក

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ២០១៥

# ប្រកាស
## ស្តីពី ការដាក់ឲ្យអនុវត្តគោលការណ៍ណែនាំ ស្តីពីបែបបទនិងនីតិវិធី នៃការកំណត់អត្តសញ្ញាណបឋមជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប

## ប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការ បង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៦/០០៤ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការ អនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃពិធីសារ ស្តីពីការទប់ស្កាត់ ការបង្ក្រាប និងដាក់ទណ្ឌកម្មការ ជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ ដែលបំពេញបន្ថែមលើអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីការប្រឆាំងនឹងឧក្រិដ្ឋ កម្មឆ្លងដែន ដែលមានអង្គការចាត់តាំង
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៥ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ
- បានឃើញ ព្រះរាជក្រឹត្យលេខនស/រកត/០៦១៤/៨០៨ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការ ជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- បានឃើញសេចក្តីសម្រេចលេខ ០០២/១៤ ស.សរ. ចុះថ្ងៃទី ១៤ ខែតុលា ឆ្នាំ២០១៤ ស្តីពីការបង្កើតក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន សម្រាប់ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- យោងតាមការចាំបាច់

## សម្រេច

**ប្រការ១.**_

ត្រូវបានដាក់ឲ្យអនុវត្ត «គោលការណ៍ណែនាំ ស្តីពី បែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណបឋម ជនរងគ្រោះ ដើម្បីផ្តល់សេវាសមស្រប» ក្នុងគោលបំណងផ្តល់ជំនួយដែលជាតម្រូវការចាំបាច់ បន្ទាន់ សមស្រប ដល់ជនរងគ្រោះ មុននឹងឈានដល់ការអង្កេតស្រាវជ្រាវ តាមនីតិវិធីច្បាប់ ឬការផ្តល់សេវាផ្សេងទៀត។

**ប្រការ២._**

បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ៣._**

អគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) ក្រុមការងារអន្តរក្រសួង ស្ថាប័ន ទទួលបន្ទុកការពារជនរងគ្រោះ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងកិច្ចការនារី លេខាធិការដ្ឋាននៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរាជធានី ខេត្ត (គ.រ.ប.ជ / គ.ខ.ប.ជ) ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពពាក់ព័ន្ធនឹងគោលការណ៍ណែនាំនេះ មានភារកិច្ចអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**និងជាប្រធាន គ.ជ.ប.ជ**

**សម្តេចក្រឡាហោម ស ខេង**

**ចម្លងជូន**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- គ្រប់សមាជិក គ.ជ.ប.ជ
- អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
- គ្រប់ក្រសួង ស្ថាប័នអង្គភាពពាក់ព័ន្ធ
- គ្រប់គណៈកម្មាធិការរាជធានីខេត្ត
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# អារម្ភកថា



ការរៀបចំគោលការណ៍ណែនាំថ្នាក់ជាតិ ស្តីពី «**ការកំណត់អត្តសញ្ញាណបឋមជនរងគ្រោះដោយអំពើជួញដូរមនុស្សដើម្បីផ្តល់សេវាសមស្រប**» បានឆ្លងកាត់ការពិភាក្សា និងពិគ្រោះយោបល់យ៉ាងទូលំទូលាយ តាមរយៈកិច្ចប្រជុំថ្នាក់គោលនយោបាយ ថ្នាក់បច្ចេកទេស សិក្ខាសាលាពិគ្រោះយោបល់ វគ្គបណ្តុះបណ្តាល និងការអនុវត្តសាកល្បង ជាបន្តបន្ទាប់ ។

គោលបំណងសំខាន់នៃការបង្កើតឡើងនូវគោលការណ៍ណែនាំនេះ គឺ ដើម្បីធានានូវការគោរពសិទ្ធិជនរងគ្រោះ ឲ្យអាចទទួលបានសេវា ចាំបាច់ស្រប ដែលជាតម្រូវការជាក់ស្តែងបន្ទាន់ ផ្អែកលើវ័យ យេនឌ័រ មុននឹងឈានទៅទទួលបានការដោះស្រាយតាមផ្លូវច្បាប់ ការផ្តល់សេវា ស្តារនីតិសម្បទា និងសេវាសង្គមដទៃទៀត ។

តាំងពីឆ្នាំ២០១៣មក លេខាធិការដ្ឋានគណៈកម្មាធិការជាតិ ដឹកនាំការបង្ក្រាបអំពើជួញដូរមនុស្ស ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ (ប.ជ.រ.ព.ភ) ដែលបច្ចុប្បន្នជា **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** (**គ.ជ.ប.ជ**) បានដាក់ចេញនូវសេចក្តីសម្រេចបង្កើតគណៈកម្មការ «រៀបចំលិខិតបទដ្ឋានពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណបឋមជនរងគ្រោះដោយអំពើជួញដូរ» ដឹកនាំដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដោយមាន ក្រសួងពាក់ព័ន្ធ អង្គការដៃគូជាតិ និង អន្តរជាតិ ព្រមទាំង ទីភ្នាក់ងារអង្គការសហប្រជាជាតិ ចូលរួមជាសមាជិក និង ត្រូវបានដាក់ជូនក្រុមបច្ចេកទេសនៃគណៈកម្មាធិការជាតិ ដែលដឹកនាំសម្របសម្រួលដោយ **លោកជំទាវ ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ** ពិនិត្យ កែលម្អ រហូតធ្វើឲ្យសម្រេច នូវគោលការណ៍ណែនាំនេះឡើង ក្នុងឆ្នាំ២០១៥ នេះ ។

នេះជាសមិទ្ធផលដ៏សំខាន់មួយ ដែលសម្រេចបានក្នុងក្របខ័ណ្ឌនៃផែនការសកម្មភាពជាតិជំហានទី២ (២០១៤-២០១៨) របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ហើយត្រូវបានដាក់ឲ្យប្រើប្រាស់ដោយឯកភាពគ្នា រវាងអង្គភាព ស្ថាប័នដែលមានភារកិច្ចពាក់ព័ន្ធនឹងការជួយជនរងគ្រោះ ទាំងនៅ ថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ ក៏ដូចជានៅតាមបណ្តាស្ថានបេសកកម្មការទូតនៃព្រះរាជាណាចក្រកម្ពុជាក្នុងបណ្តាប្រទេសគោលដៅ ។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និង ក្នុងនាមគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) ខ្ញុំសូមថ្លែងអំណរគុណដល់ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនៃក្រសួងមហាផ្ទៃ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងកិច្ចការនារី ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងការពារជាតិ ក្រសួងយុត្តិធម៌ មជ្ឈមណ្ឌលសំចតប៉ោយប៉ែត បណ្តាអង្គការដៃគូ ជាតិ និងអន្តរជាតិ ព្រមទាំងទីភ្នាក់ងារអង្គការសហប្រជាជាតិដែលពាក់ព័ន្ធ ដែលបានរួមសហការគ្នាធ្វើការស្រាវជ្រាវ តាក់តែង រៀបចំជាគោលការណ៍ជាតិដ៏មានសារៈសំខាន់នេះ ជាពិសេសការសម្របសម្រួលកែលម្អរបស់ក្រុមបច្ចេកទេស រហូតធ្វើឲ្យសម្រេចជាស្ថាពរនូវ

គោលការណ៍ណែនាំ ស្ដីពី **«បែបបទ និងនីតិវិធីសម្រាប់ការកំណត់អត្តសញ្ញាណបឋមជនរងគ្រោះ ដើម្បីផ្ដល់សេវាសមស្រប»** នេះឡើង ។

ខ្ញុំសូមថ្លែងអំណរគុណដល់គ្រប់ការចូលរួមឧបត្ថម្ភគាំទ្រ ជាថវិកា បច្ចេកទេស និងកម្លាំងកាយចិត្ត ដល់ដំណើរការ រៀបចំគោលការណ៍ណែនាំនេះតាំងពីដើមរហូតដល់ចប់ ដែលរួមចំណែកគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រ នៃការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរបស់រាជរដ្ឋាភិបាលកម្ពុជា ពីគម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៃអង្គការវីនរ៉ក់អន្តរជាតិ (WI:CTIPII) ក្រោមជំនួយឧបត្ថម្ភ របស់ទីភ្នាក់ងារ សហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍអន្តរជាតិ (USAID) អង្គការសហប្រជាជាតិដែលធ្វើសកម្មភាពដើម្បីសហប្រតិបត្តិការប្រឆាំងការជួញដូរមនុស្ស(UN-ACT) និងអង្គការទស្សនៈពិភពលោកកម្ពុជា (WVC) ។ ទន្ទឹមនឹងនេះដែរ ខ្ញុំសូមអរគុណ ដល់អង្គការ IOM, UNODC, IJM, សម្ព័ន្ធអង្គការ Chab Dai, AFESIP, CCPCR, CWCC, Hagar, Transitions Global, HCC និង WHI និង អ្នកពាក់ព័ន្ធដទៃទៀត ដែលបានចូលរួមស្រាវជ្រាវ ពិភាក្សា ពិគ្រោះយោបល់ និងសាកល្បងអនុវត្តគោលការណ៍ណែនាំនេះ។

បន្ទាប់ពីបានប្រកាសដាក់ឲ្យប្រើប្រាស់ជាផ្លូវការរួចហើយ ខ្ញុំសូមអំពាវនាវឱ្យគ្រប់ស្ថាប័ននៃរាជរដ្ឋាភិបាល នៅក្នុងប្រទេស និងប្រចាំនៅក្រៅប្រទេស អង្គការជាតិ និងអន្តរជាតិទាំងអស់ដែលធ្វើការងារពាក់ព័ន្ធការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាពិសេសលើការជួយសង្គ្រោះ ការពារ និងគាំទ្រជនរងគ្រោះ យកចិត្តទុកដាក់រួមសហការគ្នាអនុវត្តគោលការណ៍ណែនាំនេះ ប្រកបដោយសុឆន្ទៈ សុក្រឹត ឥតលម្អៀង សំដៅធានាឲ្យបាននូវការគោរពសិទ្ធិ ការលើកកម្ពស់សុវត្ថិភាពផ្លូវកាយ ផ្លូវចិត្ត ជូនប្រជាពលរដ្ឋគ្រប់រូប។

ខ្ញុំសូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ បារមី វត្ថុសក្តិសិទ្ធក្នុងលោក ជួយថែរក្សា ការពារសម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា និងប្រជាពលរដ្ឋគ្រប់រូបឱ្យទទួលបាននូវជោគជ័យ សិរីមង្គល វិបុលសុខគ្រប់ប្រការកុំបីឃ្លៀងឃ្លាតឡើយ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែ [illegible] ឆ្នាំ ២០១៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ**

**ប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**

**សម្តេចក្រឡាហោម ស ខេង**

# មាតិកា


*សេចក្តីផ្តើម*.................................................................................................................*១*

**១. លក្ខណៈវិនិច្ឆ័យសំខាន់ៗសម្រាប់កំណត់ករណីជួញដូរមនុស្ស និងករណីធ្វើអាជីវកម្មផ្លូវភេទ**

**១.ក. ការកំណត់កេធាតុផ្សំនៃបទល្មើសពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ**

១.ក.១. និយមន័យនៃអំពើជួញដូរមនុស្ស ........................................................................................៧

១.ក.២. ការកំណត់រកធាតុផ្សំនៃបទល្មើសតាមប្រភពច្បាប់អន្តរជាតិ.....................................................................៨

១.ក.៣. ការកំណត់រកធាតុផ្សំផ្សេងទៀត តាមច្បាប់ជាតិ .....................................................................................៩

**១.ខ. លក្ខណៈវិនិច្ឆ័យសម្រាប់កំណត់សម្គាល់ជនរងគ្រោះ**

១.ខ.១. និយមន័យជនរងគ្រោះ ......................................................................................................១០

១.ខ.២. លក្ខណៈសម្គាល់បុគ្គលដែលជាជនរងគ្រោះ .................................................................................១០

១.ខ.៣. ការកំណត់អំពីអាយុរបស់ជនរងគ្រោះ .........................................................................................១២

**២. បែបបទ និង នីតិវិធី នៃការសម្ភាសន៍ដើម្បីកំណត់អត្តសញ្ញាណបឋមជនរងគ្រោះ**

**២.ក. អ្នកមានភារកិច្ចកំណត់អត្តសញ្ញាណបឋមជនរងគ្រោះ** ..........................................................១៣

**២.ខ. តំណាក់កាលសំខាន់ៗនៃការកំណត់អត្តសញ្ញាណបឋម** ...........................................................១៣

**២.គ. វិធានការតំបូង ០៤ ចំណុច** .................................................................................................១៥

**២.ឃ. នីតិវិធីនៃការកំណត់អត្តសញ្ញាណបឋម - គំនូសបំព្រួញ** ..........................................................១៧

**២.ង. វិធីសាស្ត្រ និងទម្រង់បែបបទសម្រាប់ការកំណត់អត្តសញ្ញាណបឋមជនរងគ្រោះ** ...............១៨

២.ង.១. វិធីសាស្ត្រ និងទម្រង់បែបបទសម្ភាសន៍រហ័ស តែសុក្រឹត ...................................................................១៨

២.ង.២. វិធីសាស្ត្រ និងទម្រង់បែបបទាម្ភាសន៍លម្អិត............................................................ ..................២១

**៣. បែបបទ និង នីតិវិធីនៃការបញ្ជូន**

**៣.ក. គំនូសបំព្រួញនៃប្រព័ន្ធបញ្ជូន** .................................................................................................២៣

**៣.ខ. នីតិវិធីនៃការបញ្ជូន** ..............................................................................................................២៤

**៣.គ. ការណែនាំ ០៤ ចំណុច** ..........................................................................................................២៥

**៣.ឃ. វិធានការសំខាន់ៗក្រោយពីបានកំណត់អត្តសញ្ញាណ**............................................................២៧


## ឧបសម្ព័ន្ធ


ឧបសម្ព័ន្ធ ១៖ វិធីសាស្ត្រ និងក្រមសីលធម៌សម្រាប់ការសម្ភាសន៍ជនរងគ្រោះ..........................................៣០

ឧបសម្ព័ន្ធ ២៖ ទម្រង់រហ័សសម្រាប់កំណត់អត្តសញ្ញាណជនរងគ្រោះ......................................................៣៧

ឧបសម្ព័ន្ធ ៣៖ ទម្រង់លម្អិតសម្រាប់កំណត់អត្តសញ្ញាណជនរងគ្រោះ.......................................................៤០

ឧបសម្ព័ន្ធ ៤៖ ទម្រង់ស្នើសុំការយល់ព្រមដើម្បីសម្ភាសកំណត់អត្តសញ្ញាណជនរងគ្រោះ ...........................៥៦

ឧបសម្ព័ន្ធ ៥៖ ទម្រង់បញ្ជូន..........................................................................................................៥៧

# សេចក្តីផ្តើម

ជនរងគ្រោះដោយអំពើជួញដូរមនុស្ស តែងតែទទួលរងនូវការឈឺចាប់ដោយអំពើកេងប្រវ័ញ្ច អំពើរំលោភបំពាន លើផ្លូវកាយ ផ្លូវចិត្ត ផ្លូវភេទ និងសេដ្ឋកិច្ច ឬអំពើកេងប្រវ័ញ្ចលើផលប្រយោជន៍ស្របច្បាប់ដោយជនល្មើស ធ្វើឲ្យខូចខាតដល់សិទ្ធិជាមូលដ្ឋាន ឬសិទ្ធិសេដ្ឋកិច្ច ដែលជាបទល្មើសព្រហ្មទណ្ឌ ។ ជនទាំងនោះត្រូវការជំនួយសង្គ្រោះ និងការលើកទឹកចិត្ត ព្រមទាំងសំណងផ្លូវច្បាប់ពីជនល្មើស ដើម្បីប៉ះប៉ូវការខូចខាតទាំងឡាយដែលបង្កដោយជនល្មើស ក្នុងអំឡុងពេលរងគ្រោះ ។

**គោលបំណង** នៃគោលការណ៍ណែនាំស្តីពី «**បែបបទ និងនីតិវិធី នៃការកំណត់អត្តសញ្ញាណបឋមជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប**» គឺ សម្រួលឲ្យការកំណត់អត្តសញ្ញាណជនរងគ្រោះ តាមរយៈការសង្កេត សាកសួរ ប្រមូលព័ត៌មាន ស្វែងរកភាពរងគ្រោះរបស់បុគ្គលណាម្នាក់ដែលសង្ស័យថារងគ្រោះដោយអំពើជួញដូរមនុស្ស ឱ្យអាចសន្និដ្ឋានឈានទៅធ្វើការសន្មតជាបណ្តោះអាសន្នថា «**ជា ជនរងគ្រោះ**» ដើម្បីផ្តល់កិច្ចការពារ ការគាំពារ និងសេវាសមស្របជួយជនរងគ្រោះបានទាន់ពេលវេលា ប្រកបដោយមនុស្សធម៌ មិនរើសអើង ដោយមិនទាន់គិតអំពីការអង្កេតស្រាវជ្រាវផ្សេងទៀត តាមនីតិវិធីតុលាការដែលចាំបាច់ ។

## ➢ ហេតុអ្វីបានជាការកំណត់អត្តសញ្ញាណជនរងគ្រោះមានសារៈសំខាន់?

ប្រសិនបើមិនមានការកំណត់អត្តសញ្ញាណជនរងគ្រោះទេ អ្នកផ្តល់សេវានឹងមិនដឹងថា ជននោះរងគ្រោះដោយអំពើជួញដូរមនុស្ស ឬមិនមែនឡើយ ហើយក៏មិនអាចប៉ាន់ប្រមាណបានអំពីទំហំនៃភាពរងគ្រោះ ដើម្បីធ្វើគោលនយោបាយ ផែនការ កម្មវិធី ឬសកម្មភាពឲ្យឆ្លើយតបជាក់លាក់សម្រាប់ការងារបង្ការ ទប់ស្កាត់ការជួញដូរមនុស្ស ឬការផ្តល់កិច្ចការពារ និងគាំពារជនរងគ្រោះ ឬការស្វែងរកជនល្មើសមកផ្តន្ទាទោសបានឡើយ ។ ហេតុនេះហើយ ការកំណត់អត្តសញ្ញាណជនរងគ្រោះមានសារៈសំខាន់ណាស់ ក្នុងការរួមចំណែកលុបបំបាត់ អំពើជួញដូរមនុស្ស ។

ការកំណត់អត្តសញ្ញាណជនរងគ្រោះ នឹងអាចនាំទៅដល់ការយល់ដឹងអំពីស្ថានភាព និងសេចក្តីត្រូវការរបស់ជនរងគ្រោះដើម្បីឆ្លើយតបឲ្យបានសមស្រប ដូចជា តម្រូវការផ្នែកសន្តិសុខ សុវត្ថិភាព ការព្យាបាលសុខភាពផ្លូវកាយ ផ្លូវចិត្ត/អារម្មណ៍ ជម្រកសុវត្ថិភាពបណ្តោះអាសន្ន ការស្តារនីតិសម្បទា ការធ្វើសមាហរណកម្ម និងការផ្តល់ជំនួយផ្នែកច្បាប់សម្រាប់ជនរងគ្រោះ ជាដើម ។

ការកំណត់អត្តសញ្ញាណជនរងគ្រោះ ក៏អាចផ្តល់នូវព័ត៌មានជាច្រើនទៀត ពាក់ព័ន្ធនឹងជនរងគ្រោះដទៃទៀតដែលត្រូវសង្គ្រោះ និងអាចមានព័ត៌មានដែលនាំទៅរកការកំណត់មុខសញ្ញានៃជនប្រព្រឹត្តបទល្មើសជួញដូរមនុស្ស និងបណ្តាញជនល្មើសដែលពាក់ព័ន្ធដែលត្រូវស្វែងរក ដើម្បីយកមកផ្តន្ទាទោសថែមទៀត ។

ការកំណត់អត្តសញ្ញាណជនរងគ្រោះ ក៏អាចមានព័ត៌មាន ដែលនាំទៅដល់ការកំណត់នូវបទល្មើសពាក់ព័ន្ធផ្សេងទៀត ដែលជនល្មើស និងបណ្តាញបានប្រព្រឹត្តព្រមជាមួយនឹងការជួញដូរមនុស្ស មានដូចជា ការលាងលុយកខ្វក់ អំពើពុករលួយ ការធ្វើចរាចរណ៍គ្រឿងញៀន ឬឧក្រិដ្ឋកម្មដទៃទៀតជាដើម ដើម្បីសមត្ថកិច្ចបន្តការស៊ើបអង្កេត ។

បើសិនជាការកំណត់អត្តសញ្ញាណនេះមិនអាចធ្វើបាន ឬធ្វើមិនបានត្រឹមត្រូវ នោះនឹងអាចធ្វើឲ្យជនរងគ្រោះកាន់តែឈឺចាប់ដោយមិនបានទទួលការគាំពារ និងសុវត្ថិភាពផ្លូវចិត្ត ផ្លូវកាយ ហើយក៏ធ្វើឲ្យបាត់បង់ឱកាសក្នុងការបង្ក្រាបជនល្មើស និងធ្វើឲ្យជនល្មើសមានឱកាសបន្ត ប្រព្រឹត្តបទល្មើស និងបង្កភាពរងគ្រោះជាថ្មីទៀត ។ ជនរងគ្រោះ និងប្រទេសជាតិ នឹងបន្តខាតបង់ កាន់តែធ្ងន់ធ្ងរថែមទៀត ជាមិនខាន ។

## ➢ ហេតុអ្វីបានជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទតែងតែរារែកក្នុងការឲ្យកំណត់អត្តសញ្ញាណខ្លួន?

ជាទូទៅ ជនដែលរងគ្រោះដោយអំពើជួញដូរមនុស្ស ឬអំពើធ្វើអាជីវកម្មផ្លូវភេទ ច្រើនតែពឹងផ្អែកលើជនជួញដូរមនុស្ស មេខ្យល់ ឬថៅកែ ដែលតែងតែផ្តល់ ឬសន្យាថានឹងផ្តល់ផលប្រយោជន៍ដល់ខ្លួន ធ្វើឲ្យជនរងគ្រោះជាច្រើនមិនដឹងថាខ្លួនកំពុងតែរងគ្រោះ ឬស្ថិតក្នុងស្ថានភាពរងគ្រោះដោយអំពើជួញដូរមនុស្សថែមទៀតផង ព្រោះតែល្បិចកលដ៏ប៉ិនប្រសប់របស់ជនល្មើស និងអ្នកពាក់ព័ន្ធដែលជាបណ្តាញជនល្មើស ។

ករណីខ្លះ ជនរងគ្រោះ កំពុងស្ថិតក្នុងស្ថានភាពរងការគំរាមកំហែង ដែលមិនទាន់អាចដកខ្លួនបាន ។ ករណីខ្លះទៀត ជនល្មើស អាចជាអ្នកដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយជនរងគ្រោះ ជាសាច់ញាតិ ជាមិត្តភក្តិ ជាដៃគូស្នេហា ជាអ្នកមានគុណបំណាច់ ឬជាអ្នកមានអំណាចលើខ្លួន ។

ជនរងគ្រោះ តែងមានអារម្មណ៍អៀនខ្មាស់ចំពោះរឿងរ៉ាវ ដែលខ្លួនគិតថាជារឿងអាស្រូវ នៅពេលដែលពួកគាត់ត្រូវបានគេជួញដូរ ឬរំលោភបំពាន ព្រមទាំងបារម្ភចំពោះការរើសអើងពីសង្គម ។

ជនរងគ្រោះខ្លះ ក៏ធ្លាប់បានប្រព្រឹត្តបទល្មើសក្នុងអំឡុងពេលដែលខ្លួនកំពុងស្ថិតក្នុងស្ថានភាពរងគ្រោះ ដែលធ្វើឲ្យខ្លួនបារម្ភចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត ។

ជនរងគ្រោះ តែងតែបារម្ភអំពីសុវត្ថិភាព និងការខាតបង់បន្ថែមទៀតនៅពេលដែលខ្លួនជាប់ពាក់ព័ន្ធជាមួយ បណ្តឹងដែលនឹងត្រូវការចំណាយប្រាក់កាស និងពេលវេលាសម្រាប់ដំណើរការរឿងក្តី ដោយមិនសង្ឃឹមថាអាចឈ្នះក្តី ឬក៏អាចធ្វើឲ្យមានបញ្ហាកាន់តែធ្ងន់ធ្ងរ សម្រាប់ខ្លួន និងគ្រួសារ ដោយសារតែការបំភ័យពីជនល្មើស ឬ ជនល្មើសមានល្បិចកល និងមានភាពឆ្លាតវៃជាងខ្លួនក្នុងការដោះខ្លួនពីបទល្មើស ។

ហេតុនេះហើយ បានជាជនរងគ្រោះភាគច្រើន ស្នើសុំត្រឹមតែជំនួយសង្គ្រោះបន្ទាន់ ឬការស្តារនីតិសម្បទា ឬជម្រើសក្នុងការរស់នៅដែលមានសុវត្ថិភាព ជាជាងការប្តឹងទាមទារឲ្យផ្តន្ទាទោសជនល្មើស និងអ្នកពាក់ព័ន្ធ ។

បញ្ហានេះ ទាមទារឲ្យសមត្ថកិច្ចពាក់ព័ន្ធទាំងអស់ យល់ពីស្ថានភាព និងអារម្មណ៍របស់ជនរងគ្រោះ ហើយព្យាយាមអស់ពីសមត្ថភាពនិងលទ្ធភាព ដើម្បីជួយដល់ជនរងគ្រោះឲ្យទទួលបាននូវសេវាចាំបាច់ សមស្រប ព្រមទាំងការកំណត់ដោយត្រឹមត្រូវអំពីភាពរងគ្រោះ បទ ល្មើស និងមុខសញ្ញាដែលប្រព្រឹត្តបទល្មើស ដោយចែកឲ្យដាច់ពីគ្នា អំពីភាពរងគ្រោះ និងបទល្មើស ។

## ➢ ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ក្នុងការប្រឆាំងបទល្មើសជួញដូរមនុស្ស

រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា បានចែងក្នុងមាត្រា ៤៥ ៤៦ និង៤៨ថា៖

- ការធ្វើអាជីវកម្មលើការងាររបស់ស្ត្រីត្រូវហាមឃាត់។
- អំពើលក់ដូរមនុស្ស អំពើធ្វើអាជីវកម្មផ្នែកពេស្យាកម្ម និងអំពើអាសអាភាសដែលប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់នារីត្រូវហាមឃាត់។
- រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារ ដែលមានចែងក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ ជាពិសេសសិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលបានការអប់រំរៀនសូត្រ សិទ្ធិទទួលបានការគាំពារក្នុងស្ថានការណ៍មានសង្គ្រាម និងការការពារប្រឆាំងនឹងអាជីវ កម្មសេដ្ឋកិច្ច ឬកាមគុណលើកុមារ។

ផ្តើមចេញពីបញ្ញត្តិច្បាប់ខាងលើ៖

- **ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ** ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/០២០៨/០០៥ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៨ បានកំណត់ជាបទល្មើសព្រហ្មទណ្ឌរាល់អំពើទាំងឡាយដែលទាក់ទងនឹងការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ព្រមទាំងកំណត់សិទ្ធិអាទិភាពលើសំណងខូចខាត និងសំណងបដិទានដល់ជនរងគ្រោះ ។
- **កំណត់ពន្យល់មាត្រានីមួយៗនៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ** ដែលត្រូវបានបោះពុម្ពផ្សាយឱ្យប្រើប្រាស់ជាផ្លូវការដោយក្រសួងយុត្តិធម៌នៅថ្ងៃទី០៩ ខែ មេសា ឆ្នាំ២០១៣ បានគូសបញ្ជាក់យ៉ាងលម្អិតអំពីធាតុផ្សំ និងកាលៈទេសៈនៃបទ ល្មើសនីមួយៗពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងការការពារអត្តសញ្ញាណជនរងគ្រោះ។
- **គោលនយោបាយ និងបទដ្ឋានអប្បបរមាស្តីពី កិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស** ត្រូវបាន ដាក់ ឱ្យអនុវត្តតាមរយៈប្រកាសលេខ ៨៥២ ស.អ.យ. ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៩ និង ប្រកាសលេខ ៨៥៧ ស.អ.យ. ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ ២០០៩ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដោយមាននិយមន័យនៃពាក្យ "ជនរងគ្រោះ" ត្រូវបានកំណត់ឱ្យប្រើប្រាស់ជាផ្លូវការហើយដំណើរការគ្រប់គ្រងករណីជនរងគ្រោះ ត្រូវបានគូស

បញ្ជាក់យ៉ាងលម្អិតស្របតាមសិទ្ធិសំខាន់ៗទាំង១១ ដោយរាប់ចាប់ពីដំណាក់កាលកំណត់អត្តសញ្ញាណជនរងគ្រោះ ការបញ្ជូន រហូតដល់ដំណាក់កាលបិទករណី។

- **«សារាចរណែនាំ លេខ ០០៩ ស.អ.យ.ស្ដីពី ការងារសមាហរណកម្ម និងតាមដានក្រុមជនរងគ្រោះដែលបានស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ និងអង្គការមិនមែនរដ្ឋាភិបាល»** ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០០៧ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានគូសបញ្ជាក់លម្អិតនូវបែបបទតួនាទី និងភារកិច្ចរបស់មន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ថ្នាក់កណ្ដាល ថ្នាក់ រាជធានី-ខេត្តនិងថ្នាក់ស្រុក-ខណ្ឌ ហើយបុគ្គលិករបស់អង្គការមិនមែន រដ្ឋាភិបាលនានា ក្នុងការធ្វើការងារជាមួយជនរងគ្រោះមុនពេល និងក្រោយពេលធ្វើ សមាហរណកម្ម ការគ្រប់គ្រងព័ត៌មាននិងទិន្នន័យ និងទម្រង់ទាំង០៩ប្រភេទ ដែលគ្រប់ អង្គភាពក្រោមឱវាទរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអង្គការ មិនមែនរដ្ឋាភិបាល ដែលធ្វើការងារពាក់ព័ន្ធត្រូវអនុវត្តតាម។
- **«សេចក្ដីសម្រេចលេខ១០៧ ស្ដីពីគោលការណ៍ការពារសិទ្ធិកុមាររងគ្រោះដោយសារការជួញដូរនៃព្រះរាជាណាចក្រកម្ពុជា»** ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៧ របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បានបញ្ជាក់បន្ថែមអំពីនិយមន័យកុមាររងគ្រោះដោយសារការជួញដូរ សិទ្ធិផ្សេងៗរបស់កុមាររងគ្រោះ វិធីសាស្ត្រសន្និដ្ឋានអំពីអាយុរបស់កុមារ វិធានការកំណត់អត្តសញ្ញាណកុមាររងគ្រោះ វិធីសាស្ត្រសម្ភាសន៍ព័ត៌មានសម្ងាត់ជាមួយនឹងកុមារ និងវិធានការបញ្ជូនកុមារដើម្បីទទួលបានសេវាជាដើម។
- **«គោលការណ៍ណែនាំស្ដីពីការអនុវត្តច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ»** ដែលដាក់ចេញ នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨ និង **«សេចក្ដីណែនាំ ស្ដីពីការអនុវត្តកិច្ចប្រតិបត្តិការសង្គ្រោះជនរងគ្រោះដោយអំពើជួញដូរមនុស្ស និង/ឬការធ្វើអាជីវកម្មផ្លូវភេទ នៅតាមបណ្ដាទីតាំងដែលបានកំណត់»** ដែលចេញដោយអគ្គស្នងការដ្ឋាននគរបាលជាតិ នៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០១០ បានកំណត់ពីវិធានការជួយសង្គ្រោះជនរងគ្រោះដោយសារការជួញដូរមនុស្ស ការសម្ភាសជនរងគ្រោះដោយប្រើប្រាស់ជំនាញត្រឹមត្រូវ ការបញ្ជូនជនរងគ្រោះទៅលំនៅឋាន ឬមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលនឹងត្រូវធ្វើការងារបន្តជាមួយអង្គការមិនមែនរដ្ឋាភិបាល។
- **«សេចក្ដីណែនាំអំពីការអនុវត្តគោលការណ៍នានាក្នុងច្បាប់ជាតិ និងអន្តរជាតិដែលកំពុងនៅជាធរមានទាក់ទងនឹងការការពារជនរងគ្រោះនៃបទល្មើសព្រហ្មទណ្ឌ»** ដែលចេញដោយក្រសួងយុត្តិធម៌ នៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៥ ក៏បានឱ្យនិយមន័យជាទូទៅលើពាក្យថាជនរងគ្រោះ និងបានកំណត់បញ្ជាក់ អំពីគោលការណ៍ទូទៅ និងជាក់លាក់សម្រាប់ការពារជនរងគ្រោះនៃបទល្មើសព្រហ្មទណ្ឌ រាប់ចាប់តាំងពីដំណាក់កាលជនរងគ្រោះចូលរួមក្នុងកិច្ចសម្ភាស រហូតដល់

បញ្ចប់ដំណើរការនីតិវិធីរបស់មន្ត្រីនគរបាលយុត្តិធម៌ ព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរ និងចៅក្រមជម្រះ។

- **«កិច្ចព្រមព្រៀងស្តីពីគោលការណ៍ណែនាំអនុវត្ត និងកិច្ចសហការរវាងស្ថាប័នរាជរដ្ឋាភិបាលដែលពាក់ព័ន្ធ និងបណ្តាទីភ្នាក់ងារគាំទ្រជនរងគ្រោះ ក្នុងដំណើរការរឿងក្តីជួញដូរមនុស្ស»** ដែលត្រូវបានចុះហត្ថលេខាដោយក្រសួងចំនួន ០៥ និងអង្គការមិនមែនរដ្ឋាភិបាលចំនួន ២៤ នៅថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ ២០០៧ បានកំណត់ព្រមព្រៀងគ្នាជាលើកដំបូង និងមានលក្ខណៈទូលំទូលាយរវាងភាគីហត្ថលេខីទាំងអស់ ទៅលើការកំណត់អត្តសញ្ញាណជនរងគ្រោះដោយសារការ ជួញដូរមនុស្ស វិធានការបន្ទាន់របស់ទីភ្នាក់ងារដែលជួបជនរងគ្រោះដំបូងគេ ការបញ្ជូន ជនរងគ្រោះដើម្បីទទួលបានកិច្ចការពារ និងការកំណត់អំពីភ័ស្តុតាង និងសក្ខីកម្មរបស់ សាក្សី។
- **«វិធីបទដ្ឋានប្រតិបត្តិការសម្រាប់អង្គភាពឯកទេសប្រឆាំងការជួញដូរមនុស្ស»** ត្រូវបានបោះពុម្ពផ្សាយឱ្យប្រើប្រាស់ជាឯកសារបណ្តុះបណ្តាលមន្ត្រីអនុវត្តន៍ច្បាប់ ដោយអគ្គស្នងការដ្ឋាននគរបាលជាតិ នៅថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០១០ បានកំណត់ពីបច្ចេកទេសកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយសារអំពើជួញដូរមនុស្ស ដោយមន្ត្រីអនុវត្តន៍ច្បាប់ដោយប្រើប្រាស់វិធីសាស្ត្រវាយតម្លៃ សម្ភាសន៍ និងសម្រេចចិត្ត ព្រមទាំងនីតិវិធីពិសេសសម្រាប់កំណត់អត្តសញ្ញាណកុមាររងគ្រោះដោយការជួញដូរ។
- **«នីតិវិធីប្រតិបត្តិបទដ្ឋាន ស្តីពីការផ្តល់ការគាំទ្រផ្នែកសមាហរណកម្មដល់ជនរងគ្រោះជាបុរសដោយអំពើជួញដូរមនុស្ស»** ដែលត្រូវបានបោះពុម្ពផ្សាយឱ្យប្រើប្រាស់ដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១២ បានកំណត់ជាគោលការណ៍រួមនៃនីតិវិធីកំណត់អត្តសញ្ញាណ ការធ្វើមាតុភូមិនិវត្តន៍ និងការគាំទ្រផ្នែកសមាហរណកម្មដល់ជនរងគ្រោះជាបុរសដែលត្រូវបានគេជួញដូរនៅក្រៅប្រទេស។ នីតិវិធីទាំងនោះមានជាអាទិ៍ ការស្រាវជ្រាវរកគ្រួសារ និងការប៉ាន់ប្រមាណស្ថានភាពគ្រួសារនៅកម្ពុជា ការធ្វើមាតុភូមិនិវត្តន៍ និងការទទួល ការផ្តល់ជំនួយបន្ទាន់នៅពេលមកដល់ការប៉ាន់ប្រមាណតម្រូវការបណ្តុះបណ្តាលជំនាញ ការប៉ាន់ប្រមាណអំពីស្ថានភាព ការធ្វើផែនការសមាហរណកម្មនិងការបញ្ជូនទៅរកសេវា និងការតាមដានដំណើរ ការធ្វើសមាហរណកម្មជនរងគ្រោះជាបុរស។
- ទាក់ទងករណីជួញដូរមនុស្សឆ្លងដែន ប្រទេសកម្ពុជាក៏បានផ្តល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិ និងបានចុះកិច្ចព្រមព្រៀងអនុតំបន់ និងទ្វេភាគីមួយចំនួនដូចជា៖ **«អនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីពីការប្រឆាំងបទឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង»** និង **«ពិធីសារស្តីពីការទប់ស្កាត់ បង្ក្រាប និងដាក់ទណ្ឌកម្មការជួញដូរមនុស្ស ជាពិសេសស្ត្រីនិងកុមារ»** ដែលបំពេញបន្ថែមលើ **«អនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីពីការប្រឆាំងបទឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង»** ឆ្នាំ២០០០ (តាមរយៈព្រះរាជក្រមលេខ នស/រកម/១១០៥/០៣៨ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ២០០៥ ព្រះរាជក្រមលេខ នស/រកម/០១០៦/០០៤ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០៦)

«អនុស្សរណៈនៃការយោគយល់គ្នា ស្តីពីកិច្ចសហប្រតិបត្តិការប្រឆាំងអំពើជួញដូរមនុស្សនៅមហាអនុតំបន់មេគង្គ» (ដែលត្រូវបានចុះហត្ថលេខានៅថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០០៤) អនុស្សរណៈនៃការយោគយល់គ្នារវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលនៃរាជាណាចក្រថៃ «ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីលុបបំបាត់ការជួញដូរកុមារនិងស្ត្រី និងជួយដល់ជនរងគ្រោះដោយ សារការជួញដូរ» (ដែលត្រូវបានចុះហត្ថលេខានៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០៣ និងបានធ្វើ វិសោធនកម្ម ហើយចុះហត្ថលេខាជាថ្មីក្នុងឆ្នាំ២០១៤ ដោយក្រសួងបណ្តុះបណ្តាលវិជ្ជាជីវៈកម្ពុជា និងក្រសួង អភិវឌ្ឍន៍សង្គមកិច្ច និងសន្តិសុខមនុស្ស ថៃ) កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសធារណរដ្ឋសង្គមនិយមវៀតណាម «ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគី ដើម្បីប្រឆាំងនឹងអំពើជួញដូរមនុស្ស និងការពារជនរងគ្រោះដោយអំពើជួញដូរ» (ដែលចុះហត្ថលេខា នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០០៥ និងធ្វើវិសោធនកម្មនៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១២) គោលការណ៍ព្រមព្រៀង «ស្តីពីកិច្ចសហប្រតិបត្តិការក្នុងការបង្ការ និងបង្ក្រាបបទល្មើសជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារឆ្លងកាត់ព្រំដែនកម្ពុជា-វៀតណាម» (ដែលចុះហត្ថលេខាដោយនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃក្រសួងមហាផ្ទៃកម្ពុជា និងនាយកដ្ឋាននគរបាលស៊ើបអង្កេតបទល្មើសសណ្តាប់ធ្នាប់សង្គម នៃក្រសួងនគរបាលវៀតណាម នៅថ្ងៃទី ២៤ ខែតុលា ឆ្នាំ ២០០៧) កិច្ចព្រមព្រៀងសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម «ស្តីពី នីតិវិធីប្រតិបត្តិបទដ្ឋានក្នុងការកំណត់អត្តសញ្ញាណ និងការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះដោយសារអំពើជួញ ដូរ» (ដែលត្រូវបានចុះហត្ថលេខាដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងសន្តិសុខសាធារណៈនៃសាធារណៈរដ្ឋសង្គមនិយមវៀតណាម នៅថ្ងៃទី០៣ ខែធ្នូ ឆ្នាំ ២០០៩)។

ដើម្បីធានាបានការអនុវត្តច្បាប់និងគោលនយោបាយដែលមានស្រាប់ ពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងការបញ្ជូនទៅរកសេវាគាំទ្រនៅដំណាក់កាលមុននីតិវិធីតុលាការមានដំណើរការល្អនិងដើម្បីឱ្យជនរងគ្រោះទទួលបានការគាំទ្រសមស្របដោយផ្អែកលើតម្រូវការ សិទ្ធិនិងយេនឌ័រ ដែលជាឧត្តមប្រយោជន៍របស់ជនរងគ្រោះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) កំណត់ដាក់ចេញនូវគោលការណ៍ណែនាំដូចតទៅ៖

# ១. លក្ខណវិនិច្ឆ័យសំខាន់ៗសម្រាប់កំណត់ករណីជួញដូរមនុស្ស និងករណីធ្វើអាជីវកម្មផ្លូវភេទ

## ១.ក. ការកំណត់អត្តសញ្ញាណនៃបទល្មើសអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ

### ១.ក.១. និយមន័យនៃអំពើជួញដូរមនុស្ស

មាត្រា១ នៃច្បាប់ស្តីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ បានចែងច្បាស់ អំពីគោលបំណងអនុវត្តឲ្យបានសមស្រប តាមពិធីសារអង្គការសហប្រជាជាតិ (ពិធីសារប៉ាឡឺម៉ូ) ស្តីពីការទប់ស្កាត់ ការបង្ក្រាប និងការផ្តន្ទាទោសការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ (ដែលព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័ន ថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៦) បន្ថែមលើអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន ឆ្នាំ២០០០ (ដែលព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័ន នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៥) **ឬឧបករណ៍ ឬកិច្ចព្រមព្រៀងអន្តរជាតិ**ផ្សេងៗទៀតទាក់ទងនឹងការជួញដូរមនុស្សដែលព្រះរាជាណាចក្រកម្ពុជាបានឲ្យសច្ចាប័ន ឬចុះហត្ថលេខា ។

**ពិធីសារប៉ាឡឺម៉ូ បានឱ្យនិយមន័យ «បទល្មើសជួញដូរមនុស្ស» នៅក្នុងមាត្រា៣ ថា៖**

(ក) "ការជួញដូរមនុស្ស"មានន័យថា«ការជ្រើសរើស ការដឹកជញ្ជូន ការផ្ទេរ ការផ្តល់កន្លែងលាក់ខ្លួន ឬការទទួលយកមនុស្ស ដោយមធ្យោបាយគំរាមកំហែង ឬការប្រើកម្លាំង ឬ ការបង្ខិតបង្ខំតាមរូបភាពផ្សេងៗ ដូចជា ការចាប់ពង្រត់ ការក្លែងបន្លំ ការ បោក បញ្ឆោត ការរំលោភលើអំណាច ឬតួនាទីទៅលើជនដែលងាយទទួលរងគ្រោះ ឬការផ្តល់ ឬការទទួលជាលុយកាក់ ឬផលកម្រៃ ផ្សេងៗដើម្បីឲ្យមានការយល់ព្រមពីអ្នកគ្រប់គ្រងលើជនម្នាក់ទៀត ក្នុងគោលបំណងដើម្បីធ្វើការកេងប្រវ័ញ្ចៗ ការកេងប្រវ័ញ្ចត្រូវ រាប់បញ្ចូលជាអប្បបរមា ការធ្វើអាជីវកម្មពេស្យាចារលើអ្នកដទៃ ឬការកេងប្រវ័ញ្ចផ្លូវភេទ តាមរូបភាពផ្សេងទៀត ការងារដោយបង្ខំ ឬសេវាកម្មទាសភាព ឬការអនុវត្តដែលមានលក្ខណៈស្រដៀងគ្នា ទៅនឹងទាសភាព ភាពជាអ្នកបម្រើដាច់ថ្លៃ ឬការដកហូតសរីរាង្គ ជាដើម ។

(ខ) ការយល់ព្រមរបស់ជនរងគ្រោះដោយអំពើជួញមនុស្ស ចំពោះការកេងប្រវ័ញ្ចដែលបានធ្វើឡើងដោយចេតនា ដូច មានចែងក្នុងវាក្យខ័ណ្ឌ (ក)នៃមាត្រានេះ នឹងមិនអាចយកជាការបានឡើយ ប្រសិនបើមធ្យោបាយណាមួយដែលមានចែងក្នុង វាក្យខ័ណ្ឌ(ក) ត្រូវបានយកមកប្រើប្រាស់ ។

(គ) ការជ្រើសរើស ការដឹកជញ្ជូន ការផ្ទេរ ការផ្តល់កន្លែងលាក់ខ្លួន ឬការទទួលយកកុមារ ក្នុងគោល បំណងធ្វើអាជីវកម្ម ត្រូវចាត់ទុកថាជា "ការជួញដូរមនុស្ស" ទោះបីជាអំពើនេះ មិនជាប់ពាក់ព័ន្ធទៅនឹងមធ្យោបាយ ណាមួយ ដែលមានចែងក្នុងវាក្យ ខណ្ឌ (ក) នៃមាត្រានេះក៏ដោយ

(ឃ)"កុមារ" មានន័យថាមនុស្សណាម្នាក់ ដែលមានអាយុក្រោម១៨ឆ្នាំ ។

## ១.ក.២. ការកំណត់ធាតុផ្សំនៃបទល្មើសតាមច្បាប់អន្តរជាតិ

ដូចនេះ ផ្អែកតាមនិយមន័យខាងលើ ដើម្បីអាចកំណត់ជាបទល្មើសជួញដូរមនុស្សបានគឺត្រូវមានធាតុផ្សំសំខាន់ៗចំនួន ៣៖

១. **សកម្មភាព៖** ជ្រើសរើស ដឹកជញ្ជូន ផ្ទេរផ្តល់កន្លែងលាក់ខ្លួន ឬទទួលយកមនុស្ស ។

២. **មធ្យោបាយ (វិធីសាស្រ្ត)៖** គំរាមកំហែង ប្រើកម្លាំងឬទម្រង់ផ្សេងៗនៃការបង្ខិតបង្ខំចាប់ពង្រត់ ឆបោក បញ្ឆោត បំពានដោយអំណាច រំលោភលើភាពទន់ខ្សោយ ឬផ្តល់ឬទទួលយកកម្រៃឬអត្ថប្រយោជន៍ណាមួយដើម្បីទទួលបានការយល់ព្រមពីសំណាក់បុគ្គលណាម្នាក់ដែលមានអំណាចគ្រប់គ្រងលើបុគ្គលម្នាក់ទៀត ។

៣. **គោលបំណង៖** កេងប្រវ័ញ្ចលើពេស្យាកម្មជនដទៃ ឬទម្រង់ផ្សេងៗទៀតនៃការកេងប្រវ័ញ្ចផ្លូវភេទពលកម្ម ឬសេវាដោយបង្ខំ ទាសភាព ឬការអនុវត្តស្រដៀងគ្នា នឹងសេវាកម្មទាសភាព ឬការដកហូតយកសរីរាង្គជាដើមៗ

**សម្គាល់៖**

- ដោយឡែក<u>ការជួញដូរមនុស្សអាយុក្រោម១៨ឆ្នាំ</u> បើមាន**ធាតុផ្សំតែ២** គឺ **សកម្មភាព** និង **គោលបំណង** នោះគ្រប់គ្រាន់នឹងអាចឲ្យសន្និដ្ឋានបានថាជាអំពើជួញដូរមនុស្សហើយ ទោះជាប្រើមធ្យោបាយណាក៏ដោយ។
- កុមារសំដៅលើជនទាំងឡាយណាដែលមាន**អាយុក្រោម១៨ឆ្នាំ** <u>ក្នុងអំឡុងពេលដែលបទល្មើសកើត</u>ឡើង។

**ដំណាក់កាលទាំងបី នៃអំពើជួញដូរមនុស្ស៖**

បទល្មើសជួញដូរមនុស្សអាចកើតឡើងបាន ដរាបណាត្រូវឆ្លងកាត់៣ដំណាក់កាលគឺ៖

(១) **ដំណាក់កាលជ្រើសរើស** (២) **ដំណាក់កាលបន្លាស់ទី ឬដឹកជញ្ជូន** និង (៣) **ដំណាក់កាលកេងប្រវ័ញ្ច**ៗ

ដោយឡែក អនុស្សរណៈនៃការយោគយល់គ្នារវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលនៃរាជាណាចក្រថៃ «ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគីដើម្បីលុបបំបាត់ការជួញដូរកុមារ និងស្ត្រី និងជួយដល់ជនរងគ្រោះដោយការជួញដូរ» ក៏ដូចជាកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុ

ជា និង រដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម **«ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគីដើម្បីប្រឆាំងនឹងអំពើជួញដូរមនុស្សនិងការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស»** បានបញ្ជាក់បន្ថែមនូវ ឧទាហរណ៍ មួយចំនួនអំពីគោលបំណងនៃអំពើជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ ដែលមានជាអាទិ៍៖

- ពេស្យាចារ
- ការងារបម្រើតាមផ្ទះដែលត្រូវគេបង្ខំឬរំលោភបំពាន ឬកេងប្រវ័ញ្ច
- ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ
- ការងាររំលោះបំណុល
- អាពាហ៍ពិពាហ៍បែបទាសភាព ឬអាពាហ៍ពិពាហ៍ក្នុងគោលបំណងទុច្ចរិត
- សុំកូនក្លែងក្លាយឬសុំកូនក្នុងឆន្ទៈទុច្ចរិត
- បម្រើក្នុងសេវាកំសាន្ត ឬទេសចរណ៍ផ្លូវភេទ លើកុមារ
- ការផលិត ចែកចាយ រូបភាពនិងសម្ភារអាសអាភាស
- ការសុំទាន និងពលកម្មដែលមានលក្ខណៈធ្ងន់ធ្ងរ គ្រោះថ្នាក់ និងកេងប្រវ័ញ្ច
- ការប្រើប្រាស់ លួងលោម ឬបង្ខិតបង្ខំ ក្នុងសកម្មភាពទាក់ទងនឹងបទល្មើសព្រហ្មទណ្ឌ
- ការប្រើប្រាស់គ្រឿងញៀនជាមធ្យោបាយដើម្បីធ្វើឱ្យបុគ្គលដទៃក្លាយជាទាសករ
- ការដក ឬកាត់យកសរីរាង្គណាមួយ។

## ១.ក.៣. ការកំណត់ធាតុផ្សំផ្សេងទៀតនៃបទល្មើសជួញដូរមនុស្សតាមច្បាប់ជាតិ

ច្បាប់ជាតិស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ (មាត្រា៥១) ឆ្នាំ ២០០៨ ក៏ដូចជាគោលការណ៍ និងសេចក្តីណែនាំស្តីពីសិទ្ធិមនុស្សនិងបញ្ហាជួញដូរមនុស្សដែលរៀបចំដោយឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស នៅឆ្នាំ២០០២ គឺបានចាត់ទុកអំពើរួមផ្សំនិងអំពើពាក់ព័ន្ធទាំងឡាយណា ដែលទាក់ទងនឹងការជួញដូរមនុស្ស ដែលត្រូវបានកំណត់ជានិយមន័យរួមក្នុងពិធីសារប៉ាឡឺម៉ូ ឆ្នាំ២០០០ **ជាបទល្មើសព្រហ្មទណ្ឌ**។

ហេតុនេះ«គោលការណ៍ណែនាំស្តីពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណបឋមជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងការបញ្ជូនទៅរកសេវាគាំទ្រ» នេះគឺអនុលោមតាមច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងមាត្រាមួយចំនួននៃក្រមព្រហ្មទណ្ឌ ។

ធាតុផ្សំនៃបទល្មើសខាងលើ មានពន្យល់យ៉ាងលម្អិតនៅក្នុងកំណត់ពន្យល់មាត្រា នីមួយៗនៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលត្រូវបានផ្សព្វផ្សាយឱ្យប្រើប្រាស់ជាផ្លូវការដោយក្រសួងយុត្តិធម៌ នៅថ្ងៃទី០៤ ខែមេសា ឆ្នាំ ២០១៣។

## ១.ខ. លក្ខណវិនិច្ឆ័យសម្រាប់កំណត់សម្គាល់ជនរងគ្រោះ

### ១.ខ.១. និយមន័យជនរងគ្រោះ

ជនរងគ្រោះនៃអំពើជួញដូរមនុស្ស គឺជាជនដែលទទួលរងគ្រោះដោយអំពើដែលមានចែងក្នុងច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងបញ្ញត្តិពាក់ព័ន្ធក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលបានអនុលោមតាមនិយមន័យនៃ «ការជួញដូរមនុស្ស» ក្នុងមាត្រា៣ នៃពិធីសារប៉ាឡឺម៉ូ។

### ១.ខ.២. លក្ខណៈសម្គាល់បុគ្គលដែលជាជនរងគ្រោះ

ជាទូទៅ បទល្មើសពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ផ្តល់ផលប៉ះពាល់ដល់ជនរងគ្រោះ ហើយដែលអាចសម្គាល់បានដូចតទៅ៖

#### ក. ផលប៉ះពាល់ដល់សុខភាពរាងកាយ

លក្ខណវិនិច្ឆ័យដែលអាចសម្គាល់បានថា ជនរងគ្រោះណាម្នាក់ទទួលរងគ្រោះផ្នែករូបរាងកាយមានជាអាទិ៍៖

- មានរបួស
- ពិការអវយវៈ និងផ្នែកផ្សេងៗនៃរាងកាយ
- កង្វះអាហារូបត្ថម្ភ
- មានជំងឺ
- បាត់បង់ជីវិត។

មូលហេតុដែលបណ្តាលឱ្យជនរងគ្រោះទទួលផលប៉ះពាល់បែបនេះ គឺដោយសារតែមានការបំពារបំពានលើរូបរាងកាយដែលមានដូចជាការបង្ករបួសស្នាមនៃទារុណកម្ម ការបង្អត់ ឬផ្តាច់ ចំណីអាហារ ដំណេក និងខ្វះការថែរក្សាសុខភាព និងការឃុំឃាំង ឬបង្ខាំងមនុស្សអំពើមនុស្សឃោដ។ល។

#### ខ. ផលប៉ះពាល់ដល់សុខភាពផ្លូវភេទ

លក្ខណវិនិច្ឆ័យត្រូវបានកំណត់ដោយវេជ្ជបណ្ឌិតជំនាញអាចសម្គាល់បានថាជនរងគ្រោះណាម្នាក់ទទួលរងផលប៉ះពាល់ផ្នែកសុខភាពផ្លូវភេទមានជាអាទិ៍៖

- ឆ្លងមេរោគហ៊ីវឬជំងឺអេដស៍
- មានជំងឺកាមរោគផ្សេងៗ
- ការមានផ្ទៃពោះដោយបង្ខំ
- ការរលូត ឬពន្លូតកូនដោយបង្ខំ
- ខូចឬរបួសប្រដាប់ភេទ ឬប្រដាប់បន្តពូជ ឬមិនអាចបង្កកំណើតបាន។ល។

មូលហេតុដែលបណ្តាលឱ្យជនរងគ្រោះទទួលផលប៉ះពាល់បែបនេះគឺដោយសារតែមានការបំពារបំពានលើផ្លូវភេទដែលមានដូចជា៖ ការរំលោភតាមប្រដាប់ភេទ ឬតាមមាត់ ឬគូទ ការបង្ខំឲ្យធ្វើពេស្យាចារ ការរួមភេទដោយគ្មានប្រដាប់ការពារ ។ល។

### គ. ផលប៉ះពាល់ដល់សុខភាពផ្លូវចិត្ត

លក្ខណវិនិច្ឆ័យដែលអាចសម្គាល់បានថា ជនរងគ្រោះណាម្នាក់ទទួលរងគ្រោះផ្នែកសុខភាពផ្លូវចិត្តមានជាអាទិ៍៖

- កើតជំងឺថប់ផ្លូវអារម្មណ៍ ឬថប់បារម្ភ
- មានបំណងធ្វើអត្តឃាត
- មានការក្រៀមក្រំផ្លូវចិត្តធ្ងន់ធ្ងរ និងសុបិន្តអាក្រក់
- មានអារម្មណ៍ឯកោ បាត់បង់ទំនុកចិត្ត និងបារម្ភនឹងការរើសអើង
- មានអារម្មណ៍ហត់ នឿយណាយ និងបាត់បង់ដំណេក
- វិកលចរិត
- វង្វេងស្មារតី
- មិនអាចបង្កើតទំនាក់ទំនងអន្តរបុគ្គល ឬសង្គមបាន
- ចេះតែមានអារម្មណ៍ថាមានកំហុស និងអៀនខ្មាស។ល។

មូលហេតុដែលបណ្តាលឱ្យជនរងគ្រោះទទួលផលប៉ះពាល់បែបនេះគឺដោយសារតែមានការប៉ះទង្គិចផ្លូវចិត្តដែលមានដូចជា ការដាក់ឱ្យនៅឯកោ (មិនចេះភាសា ឬខ្វះជំនួយ និងការគាំទ្រ) ការធ្វើឱ្យមានការភ័យខ្លាច ការប្រើអំពើហិង្សាឬទម្រង់ផ្សេងៗនៃការបង្ខិតបង្ខំ ការគំរាមកំហែង និងការឲ្យប្រើប្រាស់សារធាតុញៀនដើម្បីត្រួតត្រាលើជនរងគ្រោះ ។ល។

### ឃ. ផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុ

លក្ខណវិនិច្ឆ័យដែលអាចសម្គាល់បានថាជនរងគ្រោះណាម្នាក់ទទួលរងផលប៉ះពាល់ ផ្នែកហិរញ្ញវត្ថុមានជាអាទិ៍៖

- បង្កើតបំណុលដោយថៅកែ ក្រុមហ៊ុន មេខ្យល់ ឬអ្នកដទៃ ដើម្បីកេងប្រវ័ញ្ច
- ធ្វើការងារមិនទទួលបានកម្រៃសោះ ឬទទួលបានកម្រៃមិនគ្រប់ តាមការសន្យា
- គ្មានឱកាសសម្រាប់ចំណាយត្រឡប់មកផ្ទះវិញ...។ល។

មូលហេតុដែលបណ្តាលឱ្យជនរងគ្រោះទទួលផលប៉ះពាល់បែបនេះគឺដោយសារតែមានការកេងប្រវ័ញ្ចផ្សេងៗដែលមានដូចជា ការឱ្យខ្ចីប្រាក់ ឬមធ្យោបាយណាមួយដើម្បីជាថ្នូរនឹងការយល់ព្រមរបស់ជនរងគ្រោះ ការឆបោកឬការបោកបញ្ឆោត ការដាក់ឱ្យធ្វើការងារដោះបំណុល ការបង្ខំឬគំរាមកំហែងឱ្យធ្វើការ និងការរំលោភលើភាពល្ងង់ខ្លៅឬភាពទន់ខ្សោយ ជាដើម។

ម្យ៉ាងវិញទៀតបុគ្គលដែលសង្ស័យថាអាចរងគ្រោះដោយសារបទល្មើសពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទក៏ត្រូវបានគេសម្គាល់ផងដែរទៅលើស្ថានភាពដូចខាងក្រោម៖

- មិនមានកាន់ឯកសារធ្វើដំណើរផ្សេងៗដោយខ្លួនឯងនៅតាមព្រះលានយន្តហោះ

ស្ថានីយ៍រថយន្តក្រុង ឬរថយន្តឈ្នួល កន្លែងត្រួតពិនិត្យឆ្លងព្រំដែន ជាដើម

- មានអារម្មណ៍ស្លន់ស្លោ ឬធ្វើដំណើរទៅមកដោយគ្មានគោលដៅជាក់លាក់
- មិនចេះភាសា និងត្រូវការឱ្យគេជួយ
- បុគ្គលដែលអាចរងគ្រោះជាអនីតិជន និងកំពុងប្រកបរបរដែលមានទំនាក់ទំនងនឹងសញ្ញារកម្ម អំពើពេស្យាចារ រូបភាព និងសម្ភារអាសអាភាស និងអំពើអាស
- បុគ្គលដែលអាចរងគ្រោះកំពុងស្ថិតនៅក្នុងស្ថានភាពសង្ស័យណាមួយទាក់ទងនឹងការគំរាមកំហែង យាយី បង្ខិតបង្ខំ ប្រើកម្លាំង បង្ខាំងខ្លួន ឬលាក់បំពួន ។ល។

### ១.ខ.៣. ការកំណត់អំពីអាយុរបស់ជនរងគ្រោះ

**ការកំណត់អាយុរបស់ជនរងគ្រោះ**ត្រូវផ្អែកជាសំខាន់លើសំបុត្រកំណើត ប័ណ្ណគ្រួសារ សៀវភៅស្នាក់នៅ អត្តសញ្ញាណប័ណ្ណ ឬលិខិតបញ្ជាក់ដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច។ ក្នុងករណីមិនមានឯកសារខាងលើទេ ការកំណត់អាយុរបស់ជនរងគ្រោះ ត្រូវធ្វើឡើងដោយអ្នកជំនាញបច្ចេកទេសវេជ្ជសាស្ត្រដែលមាននីតិសម្បទា។

ក្នុងករណីជនរងគ្រោះមិនទាន់ត្រូវបានដឹងអាយុពិតប្រាកដ ប៉ុន្តែ**សង្ស័យថាជាកុមារ**ត្រូវចាត់ទុកជនរងគ្រោះនោះជាកុមារ។

# ២.បែបបទ និងនីតិវិធីនៃការសម្ភាសន៍ដើម្បីកំណត់អត្តសញ្ញាណជនរងគ្រោះ

## ២.ក. អ្នកមានភារកិច្ចកំណត់អត្តសញ្ញាណបឋមជនរងគ្រោះ

ក្នុងគោលការណ៍ណែនាំនេះ ពាក្យថា **“អ្នកមានភារកិច្ចកំណត់អត្តសញ្ញាណបឋមជនរងគ្រោះ”** មានជាអាទិ៍ ៖ សមត្ថកិច្ចអាជ្ញាធរមូលដ្ឋាន (ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ ខេត្ត រាជធានី) នគរបាលយុត្តិធម៌ មន្ត្រីសង្គមកិច្ច មន្ត្រីទទួលបន្ទុកកិច្ចការនារី និងកុមារ អង្គការសង្គមស៊ីវិលដែលធ្វើការងារ ពាក់ព័ន្ធនឹងការជួយជនរងគ្រោះដោយអំពើជួញដូរមនុស្សជាពិសេសមន្ត្រី និងអ្នកពាក់ព័ន្ធក្រោមយន្តការ ជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់ថ្នាក់នៃរចនាសម្ព័ន្ធនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។

ក្នុងករណីជនរងគ្រោះនៅក្រៅប្រទេស មន្ត្រីស្ថានតំណាងបេសកកម្មការទូត ទីភ្នាក់ងារផ្តល់ការគាំទ្រជនរងគ្រោះនៅក្នុងប្រទេសដែលមានជនរងគ្រោះ (សហការជាមួយសមត្ថកិច្ចពាក់ព័ន្ធក្នុងប្រទេសសាមី) គឺជាអ្នកមានភារកិច្ចកំណត់អត្តសញ្ញាណបឋម លើជនដែលសង្ស័យថារងគ្រោះ ។

អ្នកមានភារកិច្ចកំណត់អត្តសញ្ញាណបឋមជនរងគ្រោះ មានតួនាទីធ្វើការសម្ភាសន៍ជនរងគ្រោះដែលគប្បីទទួលបានការបណ្តុះបណ្តាលជាមុន អំពីបែបបទ នីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះ វិធីសាស្ត្រ និងសីលធម៌នៃការសម្ភាសន៍ របៀបនៃការប្រាស្រ័យទាក់ទង ជាដើម ដើម្បីមានមូលដ្ឋានជាក់លាក់ក្នុងការអនុវត្ត ។

## ២.ខ. តំណាក់កាលសំខាន់ៗនៃការកំណត់អត្តសញ្ញាណ

តំណាក់កាលសំខាន់នៃការកំណត់អត្តសញ្ញាណជនរងគ្រោះ មានបីគឺ៖

(១) ការជួបដំបូង (២) ការផ្តួចផ្តើមសម្ភាសន៍ (៣) ការសម្ភាសជាផ្លូវការ

គ្រប់តំណាក់កាលត្រូវប្រកបដោយសីលធម៌ និងធានាសុវត្ថិភាពដល់ជនរងគ្រោះ ។

### (១) តំណាក់កាល ជួបដំបូង៖

**គោលបំណង**សំខាន់ គឺដើម្បីចាត់ទុកថា ជននោះ អាចជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងប្រហែលជាគាត់ត្រូវការជំនួយ និងកិច្ចការពារគាត់ ។

អ្នកមានភារកិច្ចធ្វើការសម្ភាសជនរងគ្រោះ ត្រូវធ្វើការសង្កេតជាបឋម គឺទៅលើ វ័យ (បើសង្ស័យថាជាអនីតិជន) ឥរិយាបទ អកប្បកិរិយា របៀបប្រាស្រ័យទាក់ទង ការបង្ហាញអំពីទឹកមុខ ឬអារម្មណ៍ របស់ជនដែលសង្ស័យថារងគ្រោះដើម្បីប៉ាន់ប្រមាណពីស្ថានភាពរងគ្រោះ និងព័ត៌មានដែលផ្តល់ឲ្យដោយអ្នកទីពផ្សេងទៀត ឬតាមរយៈការកំណត់របស់អ្នកដែលបានជួប ។

គួរចងចាំថា ជនរងគ្រោះ តែងតែរារែកក្នុងការបង្ហាញខ្លួនថាគាត់ជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស ឬមិនបានដឹងខ្លួនថាជាជនរងគ្រោះដោយអំពើជួញដូរមនុស្សទៀតផង ។

ការពិនិត្យពិច័យទៅលើជនដែលសង្ស័យថារងគ្រោះ នៅពេលបានជួបដំបូង អាចមានឧបសគ្គខ្លះបង្កដោយ ភាសានិយាយ អារម្មណ៍ភ័យព្រួយ ការអៀនខ្មាស់ វប្បធម៌ដែលខុសគ្នា និងអាចជាបញ្ហាយេនឌ័រផងដែរ ។ បញ្ហានេះក៏មានពាក់ព័ន្ធទៅនឹងមនុស្សដែលនៅជុំវិញ ឬបរិយាកាស ឬការកត់សម្គាល់របស់ជនរងគ្រោះ ទៅលើជនខ្លះដែលអាចមានការពាក់ព័ន្ធកំពុងនៅក្បែរខ្លួន ។

ក្នុងករណីដែលមិនទាន់អាចរកបានភស្តុតាងផ្សេងៗមកបញ្ជាក់ ថាមនុស្សម្នាក់ថាជាជនរងគ្រោះដោយអំពើជួញដូរមនុស្សនៅឡើយ គួរធ្វើការសន្និដ្ឋានជាបណ្ដោះអាសន្ន ថាគាត់ជាជនរងគ្រោះ ដើម្បីស្វែងយល់អំពីភាពរងគ្រោះរបស់គាត់ ដែលធ្វើឲ្យគាត់អាចទទួលបានសិទ្ធិ និងសេវានានា ដូចគ្នាទៅនឹងជនដែលគេកំណត់បានថា ជាជនរងគ្រោះ ។

## (២) ការផ្ដើមសម្ភាសន៍

គោលបំណង គឺត្រូវព្យាយាមរកចំណុចសំខាន់ៗ ដែលនាំឲ្យអាចធ្វើការសន្និដ្ឋានបានថាជាជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអាចប៉ាន់ប្រមាណបានអំពីទំហំនៃភាពរងគ្រោះ ។

អ្នកមានភារកិច្ចធ្វើកិច្ចសម្ភាសន៍ ត្រូវរៀបចំទីតាំងសម្ភាសន៍ឲ្យបានសមរម្យ ដែលមានសុវត្ថិភាព និងមិនធ្វើឲ្យប៉ះទង្គិចដល់អារម្មណ៍របស់ជនរងគ្រោះដែលត្រូវផ្ដល់សម្ភាសន៍ ។ ត្រូវព្យាយាមស្វែងយល់អំពីភាសាទំនាក់ទំនង (រកអ្នកបកប្រែ បើភាសាខុសគ្នា) ប្រកបដោយសុជីវធម៌ សាមញ្ញ ងាយយល់ មិនលំអៀង និងមិនចំអកឡកឡឺយ មិនប្រមាថមាក់ងាយ កុំនិយាយលើសពីការចាំបាច់ ដែលធ្វើឲ្យជនរងគ្រោះអៀនខ្មាស់ ឬភ័យខ្លាចឬកាន់តែឈឺចាប់ និងប៉ះពាល់ដល់ទំនៀមទម្លាប់ ឬជំនឿសាសនា ដែលខុសគ្នារបស់ជនរងគ្រោះ។ អ្នកសម្ភាសន៍ត្រូវប្រើបច្ចេកទេសនៃការសម្ភាសន៍សមស្របទៅតាមចរឹតលក្ខណៈរបស់ជនដែលត្រូវសម្ភាសន៍ ។

អ្នកសម្ភាសន៍ គប្បីប្រាប់អំពីគោលបំណង ដំណើរការ រយៈពេលនៃការសម្ភាស និងផលប្រយោជន៍នៃការផ្ដល់ព័ត៌មានរបស់ជនរងគ្រោះ ដូចជា ការទទួលស្គាល់នូវភាពរងគ្រោះរបស់គាត់ ដើម្បីឈានទៅដល់ការគាំទ្រ ឬការផ្ដល់សេវាចាំបាច់នានាដែលសមស្រប ។

ទាក់ទងនឹង<u>**យេនឌ័រ**</u> ឬវ័យរបស់ជនរងគ្រោះដែលត្រូវសម្ភាសន៍ អ្នកកំណត់អត្តសញ្ញាណ គួរព្យាយាមរកអ្នកដែលមានភេទដូចគ្នា(បើអាចធ្វើបាន) និង ដែលបានទទួលការបណ្ដុះបណ្ដាលអំពីជំនាញសម្ភាសន៍កំណត់អត្តសញ្ញាណជនរងគ្រោះ ឬអ្នកដែលមានបទពិសោធន៍ក្នុងការងារ<u>**យេនឌ័រ**</u> ឬកុមារ មកធ្វើសម្ភាសន៍ ។

## (៣) ការសម្ភាសជាផ្លូវការ

អ្នកមានភារកិច្ចធ្វើសម្ភាសន៍ គប្បីអនុវត្តតាមវិធីសាស្ត្រ និងសីលធម៌នៃអ្នកសម្ភាសន៍កំណត់អត្តសញ្ញាណបឋមជនរងគ្រោះ ដែលមានចែងលំអិតក្នុង «ឧបសម្ព័ន្ធ១» ។

## ២.គ. វិធានការដំបូង០៦ ចំណុច

១. ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ត្រូវទទួលបាននូវការបំពេញតម្រូវការចាំបាច់ ការថែរក្សា និងការគោរពសិទ្ធិ ដូចមានកំណត់នៅក្នុងគោលនយោបាយនិងបទដ្ឋានអប្បបរមាសម្រាប់កិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស ។ អ្នកមានភារកិច្ច ត្រូវតែយកពួកគេចេញពីកន្លែងរកឃើញ និងនាំយកទៅកាន់ទីកន្លែងដែលមានសុវត្ថិភាព និងមានបរិយាកាសល្អ ឬ បញ្ជូនទៅស្ថាប័ន ឬអង្គការដែលអាចផ្តល់សេវានានា ។

២. ក្នុងដំណើការនៃការកំណត់អត្តសញ្ញាណបឋមមិនត្រូវព្យាយាមឲ្យជនដែលសង្ស័យថា ជនរងគ្រោះ រងការប៉ះទង្គិចលើផ្លូវកាយ ផ្លូវចិត្ត ឬការខូចខាតផ្សេងៗបន្ថែមទៀតទេ ។ ម្យ៉ាងវិញទៀត ជនរងគ្រោះបរទេសដែលត្រូវបានកំណត់អត្តសញ្ញាណជាផ្លូវការមិនត្រូវបានឃុំខ្លួន ឬចោទប្រកាន់ពីបទអន្តោប្រវេសន៍ខុសច្បាប់ សញ្ចារកម្ម ឬពេស្យាចារឡើយ ហើយពួកគេត្រូវទទួលបានជម្រក និងកិច្ចការពារក្នុងពេលរង់ចាំដំណើរការធ្វើមាតុភូមិនិវត្តន៍ជាផ្លូវការទៅកាន់ប្រទេសខ្លួនវិញ។

៣. ក្នុងករណីមិនទាន់មានភ័ស្តុតាងពេញលេញយកមកបញ្ជាក់ថាមនុស្សណាម្នាក់ជាជនរងគ្រោះនៅឡើយ គួរធ្វើការ**សន្មតជាបឋមថាជនរូបនោះជា «ជនរងគ្រោះ»** សិន ដើម្បីសម្របសម្រួលឲ្យជននោះទទួលបានសិទ្ធិ ការគាំទ្រ និងសេវាដូចគ្នាទៅនឹងជនដែលគេកំណត់បានថាជាជនរងគ្រោះដោយសារអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។ ការប៉ាន់ប្រមាណអំពីគ្រោះថ្នាក់ដែលអាចកើតមានឡើង និង ការប៉ះទង្គិចផ្លូវចិត្តត្រូវធ្វើឡើងចំពោះជនរងគ្រោះម្នាក់ៗដើម្បីសុវត្ថិភាព និងសន្តិសុខរបស់ពួកគាត់។

៤. ក្នុង**ករណីជនរងគ្រោះសញ្ជាតិខ្មែរ**ដែលត្រូវបានកំណត់អត្តសញ្ញាណបឋម**នៅឯបរទេស** ការទទួលបានសេវានិងការស្នាក់នៅបណ្តោះអាសន្នរបស់ជនដែលបានកំណត់អត្តសញ្ញាណ រួចហើយ ត្រូវចាត់ចែងស្របតាមកិច្ចព្រមព្រៀងរវាងប្រទេសកម្ពុជានិងប្រទេសពាក់ព័ន្ធទាំងនោះ ឬស្របតាមនីតិវិធីច្បាប់ជាធរមាន ។ ទោះជាយ៉ាងណាក៏ដោយ ជនរងគ្រោះកម្ពុជានៅតែទទួលបានសេវាគាំពារចាំបាច់ផ្សេងៗពីស្ថានតំណាងបេសកកម្មការទូតរបស់ប្រទេសកម្ពុជាប្រចាំនៅប្រទេស ឬតំបន់នោះ ហើយស្ថានតំណាងបេសកកម្មការទូតរបស់ប្រទេសកម្ពុជាត្រូវរាយការណ៍ជាបន្ទាន់តាមរយៈក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ទៅក្រសួងមហាផ្ទៃ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីសម្របសម្រួលរាល់បែបបទអន្តោប្រវេសន៍ក្នុងការធ្វើមាតុភូមិនិវត្តន៍ចាត់ចែង ការប្រគល់-ទទួល និងការធ្វើសមាហរណកម្មជនរងគ្រោះតាមនីតិវិធីជាធរមាន។

<u>គ្រប់ករណីទាំងអស់</u> <u>ស្ថានតំណាងបេសកកម្មការទូតរបស់ប្រទេសកម្ពុជាអាចចាត់ចែងសម្របសម្រួលជាមួយទីភ្នាក់ងារផ្តល់សេវាគាំទ្រជនរងគ្រោះ</u> <u>ឬអង្គការជាតិ-អន្តរជាតិប្រចាំប្រទេសកម្ពុជា</u> <u>ឬប្រទេសគោលដៅ</u> <u>ឬទីភ្នាក់ងារជ្រើសរើសពលករឯកជនដែលពាក់ព័ន្ធ</u>

ដើម្បីផ្តល់ការគាំទ្រ និងជំនួយសមស្របដល់ជនរងគ្រោះមុនពេលក្នុងពេល និងក្រោយពេលធ្វើមាតុភូមិនិវត្តន៍។

៥. ក្នុង**ករណីជនដែលសង្ស័យថារងគ្រោះជាជនបរទេស** នគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ឬក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវផ្តល់ព័ត៌មានទៅស្ថាប័នពាក់ព័ន្ធ ជាពិសេស ស្ថានតំណាងបេសកកម្មការទូតនៃប្រទេសដែលជនរងគ្រោះរស់នៅ ប្រចាំកម្ពុជា តាមករណីសមស្រប ដើម្បីសម្របសម្រួលឲ្យជនរងគ្រោះទទួលបានកិច្ចការពារ និងសេវាគាំទ្រនានា និងមានការអនុញ្ញាតស្នាក់នៅជាបណ្តោះអាសន្ន ក្នុងរយៈពេលរង់ចាំដំណើរការមាតុភូមិនិវត្តន៍ ឬចូលរួមក្នុងនីតិវិធីតុលាការកម្ពុជា ស្របទៅតាមច្បាប់ បទប្បញ្ញត្តិ និងនីតិវិធីជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

៦. រាល់ការសម្ភាសន៍ជាមួយជនរងគ្រោះ គប្បីអនុវត្តតាមគោលការណ៍ ដែលជាក្រមសីលធម៌របស់អ្នកសម្ភាសន៍ដូចខាងក្រោម៖

(១). មិនបង្កការឈឺចាប់ គ្រោះថ្នាក់ ការរើសអើងពីសង្គម និងភាពអាម៉ាស់ដល់ជនរងគ្រោះ
(២). ធានាសុវត្ថិភាព សន្តិសុខ និងផាសុកភាព
(៣). ធានាឯកជនភាព
(៤). រក្សាការសម្ងាត់
(៥). ផ្តល់ព័ត៌មានពេញលេញ និងការស្នើសុំការយល់ព្រម
(៦). សួរសំណួរត្រូវមានលក្ខណៈសាមញ្ញ និងប្រកបដោយវិជ្ជាជីវៈ
(៧). ស្តាប់ប្រកបដោយលក្ខណៈសកម្ម និងឆ្លើយតប
(៨). ធានាឱ្យមានអារម្មណ៍ ឬឥរិយាបថមិនលម្អៀង
(៩). ប្រព្រឹត្តប្រកបដោយមនុស្សធម៌ការយល់ចិត្ត ការគោរព និងសមភាព
(១០). សម្រួលឱ្យអ្នកឆ្លើយមានម្ចាស់ការលើខ្លួនឯង និងមិនបន្ទោសខ្លួនឯង
(១១).ពន្យល់ប្រាប់អំពីសិទ្ធិសុំធ្វើកោសល្យវិច័យ និងការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ
(១២). ការបកប្រែភាសា
(១៣). ផ្អាកការសម្ភាសចំពោះករណីចាំបាច់
(១៤). ត្រៀមរៀបចំសម្រាប់ការបញ្ជូនជនរងគ្រោះ
(១៥). ចៀសវាងធ្វើឱ្យអ្នកឆ្លើយរំពឹងទុកខុសពីការពិត។

(ឧបសម្ព័ន្ធ១)

## ២.ឃ. នីតិវិធីនៃការកំណត់អត្តសញ្ញាណបឋមជនរងគ្រោះ

### គំនូសបំព្រួញ៖

អ្នកមានភារកិច្ច កំណត់អត្តសញ្ញាណបឋមជនរងគ្រោះ ចាំបាច់ត្រូវយកចិត្តទុកដាក់អនុវត្ត ទៅតាមនីតិវិធីដូចខាងក្រោម ៖

១. អ្នកមានសមត្ថកិច្ចកំណត់ អត្តសញ្ញាណ → កំណត់បឋមភាពរងគ្រោះ និងផ្តល់ប្រឹក្សា

ទម្រង់ បែបបទ នីតិវិធី ↓

២. នគរបាលយុត្តិធម៌ → កំណត់រកបទល្មើស និងជនល្មើសពាក់ព័ន្ធ

→ ស៊ើបអង្កេត បង្ក្រាប ចាប់ជនសង្ស័យ

→ កសាងសំណុំរឿងបញ្ជូនទៅតុលាការ

ទម្រង់ បែបបទ នីតិវិធី ↓

៣. មន្ត្រីសង្គមកិច្ច → កំណត់រកសេវាជួយជនរងគ្រោះ

ផ្តល់ប្រឹក្សា តាមដានស្ថានភាព

សមាហរណកម្ម

ទម្រង់ បែបបទ នីតិវិធី ↓

៤. កន្លែង ឬអ្នកផ្តល់សេវា → ផ្តល់សេវាសមស្រប៖ សេវាសុខភាព សេវាផ្នែកច្បាប់ ស្តារនីតិសម្បទា ជំនាញ បំណិនជីវិត មុខរបរ និងការឧបត្ថម្ភផ្សេងៗ

## ២.ខ. វិធីសាស្ត្រ និងទម្រង់បែបបទសម្រាប់ការកំណត់អត្តសញ្ញាណបឋមជនរងគ្រោះ

### ២.ខ.១. វិធីសាស្ត្រ និងទម្រង់បែបបទសម្ភាសន៍រហ័ស

មន្ត្រីអនុវត្តច្បាប់ និងទីភ្នាក់ងារផ្តល់សេវាគាំទ្រជនរងគ្រោះ ជួនកាលមិនមានពេលវេលាគ្រប់គ្រាន់សម្រាប់ស្រង់យកព័ត៌មានគ្រប់ជ្រុងជ្រោយពីជនរងគ្រោះក្នុងពេលបន្ទាន់ភ្លាមៗឡើយ។ ករណីបន្ទាន់ទាំងនោះមានដូចជា៖ជនរងគ្រោះត្រូវការជំនួយគាំទ្រសង្គ្រោះបន្ទាន់ ភ្លាមៗ ហើយមិនអាចមានលទ្ធភាព ឬពេលវេលាគ្រប់គ្រាន់ ដើម្បីទទួលយកការសម្ភាសន៍វែងបានឬជនរងគ្រោះកំពុងស្ថិតនៅក្នុងស្ថានភាពគំរាមកំហែងនៅឡើយកាលៈទេសៈ និងមជ្ឈដ្ឋានជុំវិញមិនអនុញ្ញាតឱ្យមានការយកព័ត៌មានលម្អិតបានជាដើម។

ទម្រង់នេះ ក៏អាចប្រើបានដែរ សម្រាប់ការផ្តល់ព័ត៌មានពីក្រុមគ្រួសារ ឬមិត្តភក្តិ ឬអ្នកដទៃទៀតដែលបានដឹងព័ត៌មានច្បាស់អំពីជនរងគ្រោះ ។

#### សារៈសំខាន់នៃការប្រើប្រាស់ទម្រង់ខ្លី

ក្នុងស្ថានភាពចាំបាច់បែបនេះ ទម្រង់ខ្លីអាចជួយផ្តល់ព័ត៌មានបណ្តោះអាសន្នពីជនរងគ្រោះសម្រាប់ឈានដល់ការសន្មតថា "**ជាជនរងគ្រោះ**" ដើម្បីផ្តល់សេវាសង្គ្រោះបន្ទាន់ និងការពារសុវត្ថិភាពតាមការចាំបាច់ ។

ក្នុងករណីនេះ ក្រោយពីទទួលបានដំណឹងថាមានបទល្មើសកើតឡើង ឬទទួលព័ត៌មានពីជនរងគ្រោះឬពីក្រុមគ្រួសាររបស់ជនរងគ្រោះ មន្ត្រីអនុវត្តច្បាប់ និងទីភ្នាក់ងារផ្តល់សេវាគាំទ្រជនរងគ្រោះត្រូវប្រើប្រាស់ទម្រង់រហ័សសម្រាប់កំណត់អត្តសញ្ញាណជនរងគ្រោះដូចមានភ្ជាប់ក្នុង «ឧបសម្ព័ន្ធ២» នៃគោលការណ៍ណែនាំនេះ និងត្រូវលៃយ៉ាងណាប្រើប្រាស់រយៈពេលខ្លីក្នុងការកំណត់រកភាពរងគ្រោះឱ្យបានឆាប់រហ័ស ម៉ត់ចត់ និងជាក់លាក់តាមតែអាចធ្វើបាន ។

#### សូចនាករស្តីពីអំពើជួញដូរមនុស្ស មានដូចខាងក្រោម៖

១. **សកម្មភាព**: គឺត្រូវរកឱ្យឃើញនូវព័ត៌មានទាក់ទងនឹងការប្រព្រឹត្តដោយមិនស្របច្បាប់នូវអំពើណាមួយដូចខាងក្រោម៖

- ជ្រើសរើស ឬជួល ឬឱ្យជនណាមួយបម្រើការងារ
- ដឹកជញ្ជូន
- ផ្ទេរ
- ផ្តល់ជម្រក ឬកន្លែងលាក់បំពួន
- ទទួលយកមនុស្ស
- ធ្វើឱ្យមនុស្សម្នាក់ផ្លាស់ទីទៅកាន់កន្លែងដទៃដែលស្ថិតនៅក្រោមការត្រួតពិនិត្យ

- ប្រគល់ឱ្យឬទទួលយកដោយខុសច្បាប់នូវការគ្រប់គ្រងលើជនរងគ្រោះ
- នាំយកអនីតិជនចេញពីការគ្រប់គ្រងស្របច្បាប់។

**២. មធ្យោបាយ**: គឺត្រូវរកឱ្យឃើញព័ត៌មានទាក់ទងនឹងការប្រើប្រាស់វិធីសាស្រ្តណាមួយដូចខាងក្រោមៈ

- ការគំរាមកំហែង
- ការប្រើប្រាស់កម្លាំង
- មធ្យោបាយបង្ខិតបង្ខំផ្សេងទៀត
- ការចាប់ពង្រត់
- ការឆបោក
- ការបោកបញ្ឆោត
- ការបំពានដោយអំណាច
- ការរំលោភលើភាពទន់ខ្សោយ
- ការផ្តល់ឬទទួលកម្រៃឬអត្ថប្រយោជន៍ដើម្បីទទួលបានការយល់ព្រមពីសំណាក់បុគ្គលម្នាក់ដែលមានអំណាចគ្រប់គ្រងលើជនរងគ្រោះ
- ការល្បួងលោម
- ការបង្ខាំងខ្លួន
- ការដោះប្តូរទៅនឹងរបស់មានតម្លៃអ្វីមួយ
- ការនាំយកចេញដោយគ្មានអំណាចតាមផ្លូវច្បាប់ ឬយុត្តិកម្មតាមផ្លូវច្បាប់។

**៣. គោលបំណង**: ការប្រព្រឹត្តសកម្មភាពដោយប្រើប្រាស់មធ្យោបាយខាងលើត្រូវធ្វើឡើងក្នុងគោលដៅណាមួយដូចខាងក្រោមៈ

- កេងប្រវ័ញ្ចលើពេស្យាកម្មជនដទៃ
- ឈ្នួលពានខាងផ្លូវភេទ
- សេវា ឬពលកម្មដោយបង្ខំ
- ទាសភាព ឬសេវភាព
- ដក ឬកាត់យកសរីរាង្គ
- ស្វែងរកប្រយោជន៍ ឬការកេងប្រវ័ញ្ច
- បង្កើតឱ្យមានរូបភាព និងសម្ភារអាសអាភាស
- ការធ្វើអាជីវកម្មផ្លូវភេទ
- អាពាហ៍ពិពាហ៍បែបទាសភាព ឬអាពាហ៍ពិពាហ៍ក្នុងគោលបំណងទុច្ចរិត
- សុំកូនក្លែងក្លាយឬសុំកូនក្នុងឆន្ទៈទុច្ចរិត
- ការបញ្ចាំខ្លួនដោះបំណុល
- ពលកម្មកុមារ
- សម្រាប់នាំឆ្លងដែន

- ជួយដល់ជនល្មើស។

ក្នុងករណីដែលជនរងគ្រោះផ្តល់ព័ត៌មានជាតម្រុយដែលអាចរកឃើញថា មានធាតុផ្សំយ៉ាងហោចណាស់ចំនួនពីរនៅក្រោមធាតុផ្សំពីរប្រភេទផ្សេងគ្នា នោះអ្នកដែលរងគ្រោះដោយបទល្មើសខាងលើអាចត្រូវបានចាត់ទុកជាបណ្តោះអាសន្នថាជា «**ជនរងគ្រោះ**» ដោយអំពើជួញដូរមនុស្ស។

ប្រសិនបើរកឃើញមានធាតុផ្សំបានតែមួយ ឬរកមិនឃើញធាតុផ្សំណាមួយទាល់តែសោះនោះករណីនេះមិនអាចសន្និដ្ឋានថាជាបទល្មើសពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សឡើយ ។ ដូច្នេះអ្នកសម្ភាសន៍គប្បីបញ្ជូនព័ត៌មានពាក់ព័ន្ធនឹងអ្នកដែលអះអាងថា មានការរងគ្រោះទៅសមត្ថកិច្ចដើម្បីស្រាវជ្រាវបន្ត និងណែនាំសាម៉ីខ្លួនឲ្យទៅកាន់ស្ថាប័នដែលមានសមត្ថកិច្ចពាក់ព័ន្ធសមស្របដទៃទៀត ប្រសិនបើសាមីខ្លួនយល់ព្រម។

**សម្គាល់៖**

ប្រសិនបើជននោះជាកុមារដែលមានអាយុក្រោម ១៨ ឆ្នាំ ទោះបីជារកឃើញធាតុផ្សំតែមួយ (ដោយមិនគិតពីមធ្យោបាយ)ក៏ដោយក៏កុមារនោះនៅតែត្រូវចាត់ទុកជា បណ្តោះអាសន្នថាជា **ជនរងគ្រោះ**ដោយសារអំពើជួញដូរមនុស្សដែរ ។

ក្នុងករណីសង្ស័យថា ជនរងគ្រោះមានពាក់ព័ន្ធនឹងអំពើជួញដូរផ្លូវភេទ អ្នកសម្ភាសន៍ គប្បីប្រើសំនួរជជីកបន្ថែម ដើម្បីងាយស្រួលក្នុងការវិភាគសន្និដ្ឋាន ។

ក្នុងករណីរកឃើញថា <u>មានអំពើធ្វើអាជីវកម្មផ្លូវភេទណាមួយ</u> ក្នុងចំណោមអំពើទាំងបួនប្រភេទដូចបានរៀបរាប់នៅផ្នែកខាងដើម ដែលមានដូចជា (អំពើសញ្ចារកម្មអំពើពេស្យាចារ រូបភាពនិងសម្ភារអាសអាភាស និងអំពើអាសប្រឆាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ) នោះអ្នកដែលរងគ្រោះដោយបទល្មើសទាំងនេះគឺជា "<u>ជនរងគ្រោះ</u>" ដោយសារអំពើធ្វើអាជីវកម្មផ្លូវភេទ។ ការកំណត់ធាតុផ្សំនៃអំពើធ្វើអាជីវកម្មផ្លូវភេទត្រូវធ្វើឡើងស្របទៅតាម «កំណត់ពន្យល់មាត្រានីមួយៗនៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ»។

## ២.១.២. វិធីសាស្ត្រ និងទម្រង់បែបបទសម្ភាសន៍លម្អិត

ការសម្ភាសន៍លម្អិតជនដែលសង្ស័យថារងគ្រោះ<u>ដោយផ្ទាល់</u>ត្រូវបានរៀបចំធ្វើឡើងតាមពេលវេលា និងទីកន្លែងសមស្រប ជាពិសេសនៅពេលដែលជនរងគ្រោះមានអារម្មណ៍និងមានជំនឿទុកចិត្ត លែងតក់ស្លុត ភ័យខ្លាច ហេវហត់ ភាន់ភាំងស្មារតីជាដើម និងយល់ព្រមផ្តល់ការសម្ភាសន៍ ។

បន្ទាប់ពីទទួលបានការយល់ព្រមពីជនដែលសង្ស័យថារងគ្រោះ អ្នកធ្វើសម្ភាសន៍ត្រូវផ្តើម សំណួរតាមទម្រង់លម្អិតសម្រាប់ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្សដែលមានភ្ជាប់ជា «ឧបសម្ព័ន្ធ៣»នៃគោលការណ៍ណែនាំនេះ។ លើសពីនេះទៅទៀត អ្នកសម្ភាស ត្រូវប្រកាន់ខ្ជាប់នូវវិធីសាស្ត្រ និងសីលធម៌ក្នុងការសម្ភាសន៍ ដែលមានភ្ជាប់ជា «ឧបសម្ព័ន្ធ១» ដោយបានឆ្លុះបញ្ចាំងនូវលក្ខណវិនិច្ឆ័យសំខាន់ៗនៅក្នុងវិធីសាស្ត្របឋមខាងលើ។

ក្នុងករណីអ្នកធ្វើសម្ភាសន៍ត្រូវការព័ត៌មានបន្ថែម ហើយកម្រងសំណួរដែលមានក្នុងឧបសម្ព័ន្ធ២ មិនបានបញ្ជាក់ឱ្យលម្អិត ឬអ្នកឆ្លើយទំនងជារៀបរាប់មិនបានអស់សេចក្តី អ្នកធ្វើសម្ភាសន៍អាចសួរសំណួរបន្ថែមទាំងឡាយណាពាក់ព័ន្ធនឹងចំណុចដែលត្រូវការនោះ (អាស្រ័យពេលវេលា)។

បន្ទាប់ពីបញ្ចប់កិច្ចសម្ភាសន៍ អ្នកធ្វើសម្ភាសន៍ត្រូវផ្ទៀងផ្ទាត់ព័ត៌មានដែលទទួលបានទៅនឹងមូលដ្ឋានព័ត៌មានផ្លូវការផ្សេងៗដែលមានរៀបរាប់ក្នុងផ្នែកខាងលើមុននឹងឈានដល់ការធ្វើសេចក្តីសន្និដ្ឋានបឋម ចុងក្រោយដើម្បីកំណត់ថាជននោះ ជាជនរងគ្រោះ។

ដូចគ្នានឹងទម្រង់ខ្លីដែរ ជនរងគ្រោះដែលបានផ្តល់បទសម្ភាសន៍ក្នុងទម្រង់ខ្លីរួចហើយ អាចនឹងផ្តល់ចម្លើយខុសគ្នាក្នុងទម្រង់លម្អិត ។ ដូច្នេះអ្នកសម្ភាសន៍គប្បីធ្វើការវិភាគសន្និដ្ឋានជាថ្មីម្តងទៀត ។

ប្រសិនបើរកឃើញ<u>មានធាតុផ្សំបានតែមួយ ឬរកមិនឃើញធាតុផ្សំណាមួយទាល់តែសោះ</u> នោះករណីនេះ<u>មិនអាចសន្និដ្ឋានថាជាបទល្មើសពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សឡើយ</u> ។ ដូច្នេះអ្នក សម្ភាសន៍គប្បីបញ្ជូនព័ត៌មានពាក់ព័ន្ធនឹងអ្នកដែលអះអាងថាមានការរងគ្រោះទៅសមត្ថកិច្ចដើម្បីស្រាវជ្រាវបន្ត និងណែនាំសាមីខ្លួនឲ្យទៅកាន់ស្ថាប័នដែលមានសមត្ថកិច្ចពាក់ព័ន្ធសមស្របដទៃ ទៀត ប្រសិនបើសាមីខ្លួនយល់ព្រម ។

ក្នុងករណីរកឃើញតម្រុយដែលអាច<u>**បញ្ជាក់ថាបុគ្គលនោះ អាចជាជនសង្ស័យប្រព្រឹត្តបទល្មើសពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ឬអំពើធ្វើអាជីវកម្មផ្លូវភេទទៅវិញនោះ**</u> អ្នកធ្វើសម្ភាសន៍ត្រូវរាយការណ៍ជាបន្ទាន់ទៅអាជ្ញាធរមានសមត្ថកិច្ចដើម្បីចាត់ការតាមនីតិវិធីច្បាប់។

**សម្គាល់៖**

១. ក្នុងករណីដែលជនរងគ្រោះមានស្មារតីវិបល្លាស ឬស្មារតីមិននឹងន ឬស្ថានភាពសុខភាពទន់ខ្សោយខ្លាំង ឬមិនប្រក្រតី ចាំបាច់ត្រូវផ្តល់អន្តរាគមន៍វិបត្តិដើម្បីសង្គ្រោះបន្ទាន់ ឬទុកពេលវេលាឲ្យជនរងគ្រោះមានលទ្ធភាពនៅក្នុងការផ្តល់បទសម្ភាសន៍ឲ្យបានជាក់លាក់។

២. អាស្រ័យលើកាលៈទេសៈជាក់ស្តែង ការសម្ភាសន៍កំណត់អត្តសញ្ញាណជនរងគ្រោះអាចប្រព្រឹត្តទៅតាមវិធីសាស្ត្រពីរប្រភេទគឺ *វិធីសាស្ត្របឋម(ឆាប់រហ័ស)* ដែលមានលក្ខណៈលឿន និងសុក្រឹត និង *វិធីសាស្ត្រសម្ភាសន៍បែបស៊ីជម្រៅ* ដើម្បីទទួលព័ត៌មានលម្អិត។

៣. គ្រប់ការសម្ភាសន៍ទាំងអស់ទោះត្រូវធ្វើឡើងដោយនគរបាលយុត្តិធម៌ ឬស្ថាប័នមានភារកិច្ចកំណត់អត្តសញ្ញាណជនរងគ្រោះ ណាមួយក៏ដោយ ត្រូវអនុវត្តទៅតាមវិធីសាស្ត្រ និងសីលធម៌នៃការសម្ភាសន៍ដោយផ្តោតលើផលប្រយោជន៍របស់ជនរងគ្រោះ។

៤. ក្នុងករណីជនរងគ្រោះជាកុមារ ត្រូវប្រើវិធីសាស្ត្រកុមារមេត្រីនិងត្រូវមានវត្តមានរបស់ឪពុកម្តាយអាណាព្យាបាលអ្នកថែរក្សាស្របច្បាប់ ឬមន្ត្រីដែលច្បាប់អនុញ្ញាត ឬជនពេញវ័យដែលមានការជឿទុកចិត្តពីកុមារ ដើម្បីជួយជឹងឮ និងផ្តល់ភាពកក់ក្តៅដល់កុមារ តែមិនត្រូវឲ្យមានវត្តមានជនដែលសង្ស័យថាពាក់ព័ន្ធនឹងបទល្មើស។

៥. បើអ្នកមានភារកិច្ចសម្ភាសន៍ជនរងគ្រោះ ជាមន្ត្រីនគរបាលយុត្តិធម៌ ឬកម្លាំងសមត្ថកិច្ច គប្បីកុំប្រើប្រាស់ឯកសណ្ឋាន ដែលអាចធ្វើឲ្យជនរងគ្រោះមានការភ័យខ្លាច និងមិនហ៊ានផ្តល់ចម្លើយ។

# ៣. នីតិវិធីនៃការបញ្ជូន

## ៣.ក. គំនូសបំព្រួញ នៃប្រព័ន្ធបញ្ជូន



# ៣.២. នីតិវិធីនៃការកំណត់អត្តសញ្ញាណ និងបញ្ជូន

## ៣.២.១. ការបញ្ជូនដើម្បីស្វែងរកសេវាជួយជនរងគ្រោះ

១. ជនណាក៏ដោយ ដែលបានទទួលព័ត៌មានអំពីភាពរងគ្រោះរបស់ជនណាម្នាក់ ឬជួបប្រទះ ឃើញជនសង្ស័យថារងគ្រោះ ឬត្រូវបានជនដែលសង្ស័យថារងគ្រោះស្នើសុំឲ្យជួយសង្គ្រោះ ៖

ក. បើជាពលរដ្ឋទូទៅ ឬអ្នកដែលមិនមានភារកិច្ចក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះ គប្បីបញ្ជូន ឬនាំជនដែលសង្ស័យថារងគ្រោះ ឬផ្តល់ព័ត៌មានអំពីជនដែលសង្ស័យថារងគ្រោះ ទៅមន្ត្រីមានសមត្ថកិច្ច ឬមន្ត្រីសង្គមកិច្ច ឬ**អង្គការសង្គមស៊ីវិល** ដែលធ្វើការងារពាក់ព័ន្ធនឹងការជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីកំណត់អត្តសញ្ញាណបឋមជនរងគ្រោះ ក្នុងគោលដៅជួយសម្របសម្រួលឲ្យទទួលបានសេវាសមស្របតាមស្ថានភាពជាក់ស្តែង ។

ខ. បើជាអ្នកមានភារកិច្ចកំណត់អត្តសញ្ញាណបឋមជនរងគ្រោះ (ជាមន្ត្រីមានសមត្ថកិច្ច ឬភ្នាក់ងារសង្គមកិច្ច ឬអាជ្ញាធរមូលដ្ឋាន ឬមន្ត្រីកិច្ចការនារី ឬ**អង្គការសង្គមស៊ីវិល**ដែលធ្វើការងារពាក់ព័ន្ធនឹងការជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស) បានឃើញ ឬជួបជនរងគ្រោះ ត្រូវកំណត់អត្តសញ្ញាណបឋមជនរងគ្រោះដោយប្រើទម្រង់សម្ភាសន៍ បែបខ្លី (ឧបសម្ព័ន្ធ២) ប្រសិនបើមានពេលវេលាមិនគ្រប់គ្រាន់ ឬស្ថានភាពមិនអំណោយផល ឬប្រើទម្រង់លម្អិត (ឧបសម្ព័ន្ធ៣) ដោយមានការសន្និដ្ឋានជាក់លាក់តាមការវាយតម្លៃបឋម ។

២. ជនសង្ស័យថារងគ្រោះដែលត្រូវការសេវាសង្គ្រោះបន្ទាន់ ចាំបាច់ត្រូវបញ្ជូនជនរងគ្រោះនោះទៅកន្លែងដែលអាចផ្តល់កិច្ចសង្គ្រោះនិងត្រូវបញ្ជូនព័ត៌មានព្រមជាមួយឯកសារពាក់ព័ន្ធ ទៅមន្ត្រីសង្គមកិច្ច ដើម្បីកំណត់សេវា ដែលត្រូវផ្តល់ជាបណ្តោះអាសន្នបន្តទៀត ។

៣. អ្នកកំណត់អត្តសញ្ញាណ មានភារកិច្ចរាយការណ៍ដោយមានភ្ជាប់ជាមួយនូវឯកសារពាក់ព័ន្ធទៅអធិការដ្ឋាននគរបាល ឬក្នុងករណីចាំបាច់ ត្រូវបញ្ជូនឯកសារ ឬបញ្ជូនទាំងឯកសារ ទាំងជនសង្ស័យថារងគ្រោះត្រង់ទៅនគរបាលប្រឆាំងអំពើជួញដូរមនុស្ស ឬកងរាជអាវុធហត្ថមានសមត្ថកិច្ច ដើម្បីកំណត់រកភាពរងគ្រោះ បទល្មើស និងជនសង្ស័យដែលប្រព្រឹត្ត ក្នុងគោលដៅជួយរកសេវាការពារផ្លូវច្បាប់ជូនជនរងគ្រោះ ក្នុងនីតិវិធីតុលាការ ។

៤. ក្នុងករណីដែលជនរងគ្រោះជាកុមារ (អនីតិជន) នគរបាល ឬទីភ្នាក់ងារដែលរកឃើញមុនគេ ត្រូវទាក់ទងជាបន្ទាន់ទៅភ្នាក់ងារផ្តល់សេវាសង្គមកិច្ច ដើម្បីស្វែងរកឪពុក ម្តាយ ឬអាណាព្យាបាល ឬក្រុមគ្រួសាររបស់កុមាររងគ្រោះ និងពិនិត្យស្ថានភាពគ្រួសារដើម្បីប៉ាន់ប្រមាណអំពីលទ្ធភាពក្នុងការផ្តល់សេវាគាំពារកុមារ ។

៥. ជនរងគ្រោះមានភារកិច្ចសហការ ផ្តល់ព័ត៌មានដល់នគរបាលយុត្តិធម៌ប្រឆាំងការជួញដូរមនុស្ស តាមរយៈការផ្តល់កិច្ចសម្ភាសន៍ដើម្បីកំណត់ភាពរងគ្រោះ ដោយមានការសម្របសម្រួលពីអ្នក

មានភារកិច្ចកំណត់អត្តសញ្ញាណបឋម ។ ក្នុងករណីជនរងគ្រោះបដិសេធ ទីភ្នាក់ងារផ្តល់សេវាជនរងគ្រោះ ដែលបានធ្វើការកំណត់អត្តសញ្ញាណបឋមត្រូវផ្តល់ព័ត៌មាននេះជូនដល់នគរបាលយុត្តិធម៌ប្រឆាំងការជួញដូរមនុស្សដើម្បីសម្របសម្រួលអនុវត្តនីតិវិធីក្នុងការប្រមូលព័ត៌មាន ។

៦. ក្នុងករណីដែលត្រូវការសង្គ្រោះជនរងគ្រោះ និងរកជនរងគ្រោះដទៃទៀត កិច្ចអន្តរាគមន៍ពីនគរបាលយុត្តិធម៌គឺជាវិធានការបន្ទាន់និងចាំបាច់។ នគរបាលយុត្តិធម៌ ឬអ្នកមានភារកិច្ចត្រូវសម្ភាស ឬប្រមូលព័ត៌មានពីអ្នកដែលអាចផ្តល់ព័ត៌មានបន្ថែមពីជនរងគ្រោះដែលអាចជាសាច់ញាតិ មិត្តភក្តិ ក្រុមគ្រួសាររបស់ជនរងគ្រោះ អ្នកពាក់ព័ន្ធ ឬទីភ្នាក់ងារផ្តល់ការគាំទ្រជនរងគ្រោះ។

៧. **<u>ក្រោយពេលប្រតិបត្តិការសង្គ្រោះ</u>** និងរំដោះជនដែលជាប់ក្នុងស្ថានភាពជួញដូរមនុស្ស និង/ឬការធ្វើអាជីវកម្មផ្លូវភេទ នគរបាលយុត្តិធម៌អាចរក្សាទុកជនដែលបានរំដោះឲ្យមានសុវត្ថិភាពដើម្បីធ្វើការសម្ភាសយកព័ត៌មាន និងធ្វើកំណត់ហេតុជាបន្ទាន់ និងឱ្យបានឆាប់បំផុតនៅកន្លែងធ្វើការរបស់នគរបាលយុត្តិធម៌ដើម្បីកំណត់រកជនរងគ្រោះ ជនសង្ស័យ និងអ្នកពាក់ព័ន្ធ។

៨. ក្នុងករណីមាន<u>ពលរដ្ឋខ្មែរកំពុងរងគ្រោះនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា</u> ស្ថានតំណាងបេសកកម្មការទូតរបស់ប្រទេសកម្ពុជាប្រចាំប្រទេស ឬតំបន់នោះ ត្រូវចាត់វិធានការជាបន្ទាន់ជាមួយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសសាមី ដើម្បីធ្វើប្រតិបត្តិការបង្ក្រាប និងសង្គ្រោះជនរងគ្រោះ ព្រមទាំងសហការជាមួយទីភ្នាក់ងារផ្តល់ការគាំទ្រជនរងគ្រោះ ដើម្បីកំណត់អត្តសញ្ញាណ និង ផ្តល់សេវាសមស្របនានា រួមទាំងការបញ្ជូនជាផ្លូវការមកកម្ពុជាវិញ ។

### ៣.ខ.២. ការណែនាំ ០៤ ចំណុច

១. ក្នុងករណីដែល<u>ជនរងគ្រោះ</u> ឬ <u>អ្នកតំណាង</u>របស់ពួកគេមានបំណងដាក់ពាក្យប្តឹង (បណ្តឹងបរិហារ ឬបណ្តឹងទាមទារសំណង)ទីភ្នាក់ងារផ្តល់សេវាគាំទ្រជនរងគ្រោះ ឬស្ថាប័នពាក់ព័ន្ធផ្សេងៗត្រូវបញ្ជូនព័ត៌មានទាក់ទងនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះទៅនគរបាលយុត្តិធម៌ ដើម្បីរាយការណ៍ជាបន្ទាន់ទៅការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត។

ក្នុងករណីជនរងគ្រោះ ឬអ្នកតំណាងរបស់ពួកគេមិនមានបំណងដាក់ពាក្យប្តឹងណាមួយទេ ទីភ្នាក់ងារផ្តល់សេវាគាំទ្រជនរងគ្រោះ ឬស្ថាប័នពាក់ព័ន្ធផ្សេងៗត្រូវបញ្ជូនព័ត៌មានទាក់ទងនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះទៅមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

២. ក្នុងករណីចាំបាច់ នគរបាលយុត្តិធម៌អាចចេញលិខិតកោះហៅជនរងគ្រោះដែលមានអាយុ១៨ឆ្នាំឡើងដើម្បីទៅចូលរួមការសម្ភាសន៍យកព័ត៌មានបន្ថែម ។ ប្រសិនបើជនរងគ្រោះជាអនីតិជន ការបញ្ជូនត្រូវធ្វើឡើងតាមរយៈក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដោយគោរពតាមខ្លឹមសារនៃសេចក្តីសម្រេចលេខ ១០៧ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៧ របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ស្តីពីគោលការណ៍ការពារសិទ្ធិកុមាររងគ្រោះដោយសារការជួញដូរនៃព្រះរាជាណាចក្រកម្ពុជា និងស្របតាមខ្លឹមសារនៃគោលការណ៍ណែនាំលេខ ០០១ស្តីពីការអនុវត្តច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ របស់ក្រុមការងារដឹកនាំ ប.ជ.រ.ព.ភ និង សេចក្តីណែនាំលេខ០០៩ស.អ.យ ស្តីពីការអនុវត្តកិច្ចប្រតិបត្តិការសង្គ្រោះជនរងគ្រោះដោយអំពើជួញដូរមនុស្ស និង/ឬ ការធ្វើអាជីវកម្មផ្លូវភេទនៅតាមបណ្តាទីតាំងដែលបានកំណត់របស់អគ្គស្នងការដ្ឋាននគរបាលជាតិ។

៣. គ្រប់ការបញ្ជូនជនរងគ្រោះទៅរកសេវា និងទៅអាជ្ញាធរមានសមត្ថកិច្ចត្រូវអនុវត្តទៅតាមទម្រង់ ដែលមានភ្ជាប់ក្នុង «ឧបសម្ព័ន្ធទី ៥» នៃគោលការណ៍ណែនាំនេះ និងស្របទៅតាមបែបបទដែលមានកំណត់ក្នុងបទដ្ឋានអប្បបរមាសម្រាប់កិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងសារាចរណែនាំ លេខ ០០៩ ស.អ.យ ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០០៧ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា ស្តីពីការងារសមាហរណកម្ម និងតាមដានក្រុមជនរងគ្រោះដែលបានស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ និងអង្គការមិនមែនរដ្ឋាភិបាល។ ការបញ្ជូនទាំងអស់ត្រូវមានភ្ជាប់ជាមួយនូវទម្រង់កំណត់អត្តសញ្ញាណជនរងគ្រោះ។

៤. ដោយឡែក ការបញ្ជូនរបស់នគរបាលយុត្តិធម៌ត្រូវអនុវត្តស្របតាមខ្លឹមសារនៃគោលការណ៍ណែនាំរបស់ អគ្គស្នងការដ្ឋាននគរបាលជាតិស្តីពីការអនុវត្តកិច្ចប្រតិបត្តិការសង្គ្រោះជនរងគ្រោះដោយអំពើជួញដូរមនុស្ស និង/ឬ ការធ្វើអាជីវកម្មផ្លូវភេទ នៅតាមបណ្តាទីតាំងដែលបានកំណត់។

# ៣.គ. ទិដ្ឋភាពការសំខាន់ៗក្រោយពីបានកំណត់អត្តសញ្ញាណជនរងគ្រោះ ការបញ្ជូនទៅរកសេវាជួយជនរងគ្រោះ

## ៣.គ.១. ករណីជនរងគ្រោះជាជនជាតិកម្ពុជា

ក. <u>ជនរងគ្រោះកម្ពុជាដែលនៅក្នុងប្រទេស៖</u> បន្ទាប់ពីកំណត់អត្តសញ្ញាណរួចហើយជនរងគ្រោះត្រូវបានបញ្ជូនបន្តទៅរកសេវាផ្សេងៗ ឬធ្វើសមាហរណកម្មទៅកាន់សហគមន៍ដើមឬកន្លែងរស់នៅថ្មីដែលនឹងត្រូវសម្របសម្រួល និងផ្តល់ការគាំទ្រដោយមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អាជ្ញាធរមូលដ្ឋាន ទីភ្នាក់ងារផ្តល់សេវាគាំទ្រជនរងគ្រោះ និងអង្គការជាតិ-អន្តរជាតិផ្សេងៗ ។ ការបញ្ជូនទៅរកសេវាត្រូវធ្វើឡើងតាមទម្រង់ដែលមានភ្ជាប់ក្នុង «ឧបសម្ព័ន្ធទី៥» នៃគោលការណ៍ណែនាំនេះ និងស្របទៅតាមបែបបទដែលមានកំណត់ក្នុងបទដ្ឋានអប្បបរមាសម្រាប់កិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងសារាចរណែនាំលេខ ០០៩ ស.អ.យចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ ២០០៧ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា ស្តីពីការងារសមាហរណកម្ម និងតាមដានក្រុមជនរងគ្រោះដែលបានស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ និងអង្គការមិនមែនរដ្ឋាភិបាល **ដែលត្រូវបានទទួលស្គាល់ដោយរាជរដ្ឋាភិបាល។**

ខ. <u>ជនរងគ្រោះកម្ពុជាដែលស្ថិតនៅបរទេស៖</u> បន្ទាប់ពីបានកំណត់អត្តសញ្ញាណបឋមរួច នឹងត្រូវបានការគាំទ្រដោយតំណាងបេសកកម្មការទូតរបស់ប្រទេសកម្ពុជាប្រចាំនៅប្រទេស ឬតំបន់ នោះ និងទីភ្នាក់ងារផ្តល់សេវាគាំទ្រជនរងគ្រោះ។ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មានភារកិច្ចចាត់ចែងសម្របសម្រួលជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងមហាផ្ទៃ ដើម្បីរៀបចំការធ្វើមាតុភូមិនិវត្តន៍ និងធ្វើសមាហរណកម្ម ស្របតាមបែបបទជាធរមាន។ ក្នុងករណីជនរងគ្រោះយល់ព្រមចូលរួមក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌនៃប្រទេសនោះ ស្ថានតំណាងបេសកកម្មការទូតរបស់ប្រទេសកម្ពុជា ត្រូវសម្របសម្រួលចាត់ចែងតាមនីតិវិធីជាមួយអាជ្ញាធរមានសមត្ថកិច្ចរបស់ប្រទេសសាមី ដើម្បីសម្រួលឱ្យជនរងគ្រោះកម្ពុជាមានសិទ្ធិទទួលបានការអនុញ្ញាតឱ្យស្នាក់នៅបណ្តោះអាសន្ន និងទទួលបានជម្រក និងការគាំពារសមស្របពីអាជ្ញាធរមានសមត្ថកិច្ចរបស់ប្រទេសនោះ និងទីភ្នាក់ងារផ្តល់សេវាគាំទ្រជនរងគ្រោះនានា ។ ក្នុងករណីជនរងគ្រោះកម្ពុជាដែលត្រូវបានកំណត់អត្តសញ្ញាណនៅក្នុងប្រទេសដែលមានកិច្ចព្រមព្រៀងជាមួយប្រទេសកម្ពុជាការកំណត់អត្តសញ្ញាណ និងការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះ ត្រូវធ្វើតាមបែបបទដែលមាន<u>កំណត់ក្នុងកិច្ចព្រមព្រៀង</u>នោះ ។

### ៣.គ.២. ករណីជនរងគ្រោះជាជនបរទេស

ក្នុងករណីជនរងគ្រោះនៃប្រទេសដែលមានកិច្ចព្រមព្រៀងជាមួយប្រទេសកម្ពុជា ការធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះត្រូវអនុវត្តស្របតាមខ្លឹមសារនៃកិច្ចព្រមព្រៀងនោះ។

ក្នុងករណីជនរងគ្រោះនៃប្រទេសដែលមិនមានកិច្ចព្រមព្រៀងជាមួយប្រទេសកម្ពុជាក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទាត្រូវសម្របសម្រួលជាមួយក្រសួងមហាផ្ទៃ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនិងទីភ្នាក់ងារផ្តល់សេវាគាំទ្រជនរងគ្រោះ ដើម្បីចាត់ចែង និងរៀបចំការធ្វើមាតុភូមនិវត្តន៍ជនរងគ្រោះស្របតាមនីតិវិធីជាធរមាន។

ទទួលបានគោលការណ៍ណែនាំនេះ ស្ថាប័ន អាជ្ញាធរមានសមត្ថកិច្ច និងអង្គភាពពាក់ព័ន្ធទាំងអស់ ត្រូវយកចិត្តទុកដាក់អនុវត្តឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី...២៥...ខែ..........ឆ្នាំ ២០១៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ជ. គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**

**សម្តេចក្រឡាហោម ស ខេង**

**ចម្លងជូន:**

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- គ្រប់ក្រសួងពាក់ព័ន្ធ
- អគ្គស្នងការដ្ឋាននគរបាលជាតិ
- បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស
- គ្រប់សាលារាជធានី-ខេត្ត
- គ្រប់អង្គការជាតិ-អន្តរជាតិពាក់ព័ន្ធ
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ១៖ ក្រមសីលធម៌ក្នុងការសម្ភាសកំណត់អត្តសញ្ញាណ ជនរងគ្រោះ

ឧបសម្ព័ន្ធ២៖ ទម្រង់សម្ភាសន៍ខ្លី សម្រាប់ការសម្ភាសកំណត់អត្តសញ្ញាណបឋមជនរងគ្រោះដោយអំពើជួញដូរមនុស្ស

ឧបសម្ព័ន្ធ៣៖ ទម្រង់លម្អិត សម្រាប់ការសម្ភាសកំណត់អត្តសញ្ញាណបឋមជនរងគ្រោះដោយអំពើជួញដូរមនុស្ស

ឧបសម្ព័ន្ធ៤៖ ទម្រង់ស្នើសុំការយល់ព្រមដើម្បីសម្ភាសកំណត់អត្តសញ្ញាណជនរងគ្រោះ

ឧបសម្ព័ន្ធ៥៖ ទម្រង់បញ្ជូនទៅរកសេវា

## ឧបសម្ព័ន្ធ១

# ក្រមសីលធម៌ក្នុងការសម្ភាសកំណត់អត្តសញ្ញាណ ជនរងគ្រោះ

អ្នកដែលមានភារកិច្ចក្នុងការធ្វើសម្ភាសន៍ ជនណាម្នាក់ដើម្បីកំណត់រកភាពរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ គប្បី ប្រតិបត្តិតាមក្រមសីលធម៌ ដូចមានចែងខាងក្រោម៖

មុននឹងធ្វើការសម្ភាសកំណត់អត្តសញ្ញាណជនរងគ្រោះ ឬជនដែលសង្ស័យថារងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ (ដែលតទៅនេះហៅថា អ្នកឆ្លើយ) មន្ត្រីឬបុគ្គលិកសម្ភាសន៍(ដែលតទៅនេះហៅថាអ្នកធ្វើសម្ភាសន៍)គប្បីស្វែងរកព័ត៌មាននានាពាក់ព័ន្ធអង្គហេតុ ដែលជាលទ្ធផលនៃកិច្ចសម្ភាស ផ្តល់ដោយអ្នកឆ្លើយ តែមិនមែនជាសំនួរដដែលៗ នាំឲ្យធុញទ្រាន់ ។

ម្យ៉ាងទៀត ការសម្ភាសបែបកុមារមេត្រី ត្រូវយកមកអនុវត្តក្នុងករណីអ្នកឆ្លើយជាកុមារ ។

ប្រសិនបើអាចធ្វើបាន គួររកអ្នកធ្វើសម្ភាសន៍មានភេទដូចគ្នានឹងអ្នកឆ្លើយ និងមានជំនាញ ឬឆ្លងកាត់វគ្គបណ្តុះបណ្តាលស្តីពីវិធីសាស្ត្រសម្ភាសន៍ជនរងគ្រោះ ។

អ្នកធ្វើសម្ភាសន៍ អ្នករៀបចំការសម្ភាស និងអ្នកបញ្ជូនជនរងគ្រោះ ឬជនដែលទំនងជាអាចរងគ្រោះដោយសារអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទត្រូវយកចិត្តទុកដាក់ និងអនុវត្តតាមគោលការណ៍ដែលជាក្រមសីលធម៌សម្រាប់អ្នកសម្ភាសន៍ជនរងគ្រោះ ដូចខាងក្រោម៖

### ១. មិនបង្កការឈឺចាប់ គ្រោះថ្នាក់ ការរើសអើងក្នុងសង្គម និងភាពអាម៉ាស់ដល់ជនរងគ្រោះ៖

អ្នកឆ្លើយអាចប្រឈមនឹងស្ថានភាពគ្រោះថ្នាក់ និងងាយរងការប៉ះទង្គិចផ្លូវចិត្តព្រោះថាពួកគេធ្លាប់បានជួបប្រទះនឹងវិបត្តិធ្ងន់ធ្ងរដែលជាលទ្ធផលនៃអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។ ដូច្នេះ បើសិនណាជាមានហេតុផលណាមួយដែលនាំឱ្យជឿជាក់ថា ការធ្វើសម្ភាសនឹងបង្កគ្រោះថ្នាក់ដល់គេ (អ្នកឆ្លើយ) និងក្រុមគ្រួសាររបស់ពួកគេ ដូចជាការសងសឹក ការប៉ះទង្គិចផ្លូវចិត្ត ការរើសអើង និងភាពអាម៉ាស់ក្នុងសង្គម នោះការសម្ភាសមិនត្រូវអនុវត្តឡើយ ។ អ្នកធ្វើសម្ភាសន៍ត្រូវមានការទទួលខុសត្រូវផ្នែកសីលធម៌ ដើម្បីធ្វើការប៉ាន់ប្រមាណឱ្យបានហ្មត់ចត់អំពីភាពងាយរងគ្រោះដែលអាចកើតឡើងដោយសារការរៀបចំកិច្ចសម្ភាស ។

### ២. ធានាសុវត្ថិភាព សន្តិសុខ និងផាសុកភាព

នៅមុនពេលចាប់ផ្តើមសន្ទនា អ្នកធ្វើសម្ភាសន៍ត្រូវធានាថា អ្នកឆ្លើយពិតជាមានអារម្មណ៍ថាមានសុវត្ថិភាព ។ អ្នកធ្វើសម្ភាសន៍មានកាតព្វកិច្ចស្វែងយល់ និងឆ្លើយតបទៅនឹងតម្រូវការបន្ទាន់ចាំបាច់ផ្សេងៗរបស់អ្នកឆ្លើយ ដែលមានដូចជាតម្រូវការថែទាំផ្នែកវេជ្ជសាស្ត្រ ការពិគ្រោះយោបល់ ចំណីអាហារ និងទឹកជាដើម។

អ្នកឆ្លើយមិនគួរត្រូវបានគេសម្ភាស ខណៈពេលដែលខ្លួនកំពុងមានការឈឺចាប់ មិនស្រួល

ក្នុងចិត្ត ឬត្រូវការសេវាវេជ្ជសាស្ត្របន្ទាន់ឡើយ។ ការរៀបចំកិច្ចសម្ភាសនិងទីកន្លែងសម្ភាសន៍ត្រូវធានានូវផាសុកភាពសម្រាប់អ្នកឆ្លើយ ។ ឧទាហរណ៍ កន្លែងសម្ភាសន៍ត្រូវស្ថិតនៅក្នុងបន្ទប់មួយដោយឡែក មានខ្យល់និងពន្លឺចេញចូលគ្រប់គ្រាន់ និងមានបន្ទប់ទឹក។ល។ក្នុងករណីអ្នកធ្វើសម្ភាសន៍មានគ្នាច្រើន (ដូចជា អ្នកសួរ អ្នកកត់ត្រា អ្នកបកប្រែ អ្នកពិគ្រោះយោបល់និងអ្នកពាក់ព័ន្ធផ្សេងទៀត) ការរៀបចំការសម្ភាសត្រូវលៃយ៉ាងណាមិនឱ្យអ្នកឆ្លើយមានអារម្មណ៍ទទួលការគៀបសង្កត់។ ជាទូទៅដើម្បីបញ្ចៀសការភ័យខ្លាច អ្នកធ្វើសម្ភាសន៍គួរប្រើប្រាស់សម្លៀកបំពាក់ស៊ីវិល។ ចំពោះនគរបាលយុត្តិធម៌ ត្រូវអនុវត្តតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តិ និងក្រមសីលធម៌ជាធរមាន។

### ៣. ធានាឯកជនភាព

រាល់កិច្ចសម្ភាសជាមួយអ្នកឆ្លើយទាំងអស់ ត្រូវរៀបចំឡើងក្នុងបរិយាកាសដែលរក្សាបាននូវលក្ខណៈឯកជនដោយមិនមានការរំខាន។ បើទោះបីជាការសម្ភាសត្រូវធ្វើឡើងនៅក្នុងការិយាល័យមានទំហំតូច និងអ៊ូអរក្តី ភាពជាឯកជនសម្រាប់អ្នកឆ្លើយម្នាក់ៗត្រូវធានាឱ្យបានហើយបើក្នុងករណីមិនអាចធានាឯកជនភាពបានទេ ការសម្ភាសមិនត្រូវធ្វើឡើយ រហូតទាល់តែមានបរិយាកាសសមស្រប។ បើអាចធ្វើបាន ការសម្ភាសត្រូវធ្វើឡើងចំពោះអ្នកឆ្លើយម្តងម្នាក់ៗ (ក្នុងករណីអ្នកឆ្លើយមានចំនួនច្រើននាក់)។

### ៤. រក្សាការសម្ងាត់

ការធានារក្សាការសម្ងាត់មានន័យថាអ្នកធ្វើសម្ភាសន៍ត្រូវធានាថារាល់ទិន្នន័យទាំងអស់ទាក់ទងនឹងអ្នកឆ្លើយ ឬផ្តល់ដោយអ្នកឆ្លើយត្រូវរក្សាជាការសម្ងាត់ និងរក្សាទុកដោយសុវត្ថិភាព ។ អ្នកឆ្លើយគប្បីត្រូវបានប្រាប់ឱ្យដឹងអំពីវិធានការជាក់លាក់ដែលត្រូវអនុវត្តដើម្បីធានាការសម្ងាត់ ។ ការរក្សាការសម្ងាត់ទាមទារឱ្យមានការប្រុងប្រយ័ត្នជាប់ជាប្រចាំទៅលើការរក្សាព័ត៌មានជាលាយលក្ខណ៍អក្សរឬផ្ទាល់មាត់ទិន្នន័យតាមប្រព័ន្ធអេឡិចត្រូនិចទូរសព្ទ វីដេអូ និងទម្រង់ផ្សេងៗនៃព័ត៌មានពាក់ព័ន្ធនឹងអ្នកឆ្លើយ ។ ព័ត៌មានគួរត្រូវបានចែករំលែកនៅក្នុងចំណោមបុគ្គលពាក់ព័ន្ធដោយផ្អែកលើគោលការណ៍នៃ«ភាពចាំបាច់ដែលត្រូវដឹង»។ ការចែករំលែកព័ត៌មានដែលផ្អែកលើគោលការណ៍នេះត្រូវប្រាប់ដល់អ្នកឆ្លើយឱ្យបានដឹង និងត្រូវបញ្ជាក់ឱ្យច្បាស់អំពីវិធានការទាក់ទងនឹងអនាមិកភាព (ដូចជាការប្រើប្រាស់លេខកូដ អក្សរកាត់ ឈ្មោះប្រឌិត ការបិទបាំងមុខមាត់ ទីកន្លែង និងស្លាកសញ្ញានៅក្នុងរូបថត ជាដើម)។ វាជាការរំលោភលើសិទ្ធិបុគ្គលក្នុងករណីដែលមានការចែករំលែកព័ត៌មាន ឬរូបភាពទាក់ទងនឹងសុខភាព វេជ្ជសាស្ត្រ ឬអត្តសញ្ញាណអ្នកឆ្លើយដោយគ្មានការយល់ព្រមច្បាស់លាស់ជាមុនពីអ្នកឆ្លើយ ឬពីឪពុកម្តាយ អ្នកអាណាព្យាបាល ឬអ្នកថែរក្សារបស់ពួកគេ។

### ៥. ផ្តល់ព័ត៌មានពេញលេញ និងការស្នើសុំការយល់ព្រម

ព័ត៌មាន និងលក្ខខណ្ឌទាំងអស់ទាក់ទងនឹងជម្រើសរបស់អ្នកឆ្លើយត្រូវផ្តល់ដល់សាមីខ្លួនជាមុនដើម្បីពួកគេអាចធ្វើសេចក្តីសម្រេចចិត្តត្រឹមត្រូវ និងប្រសើរបំផុតសម្រាប់សុវត្ថិភាពសុខភាព សុខុមាលភាព និងផលប្រយោជន៍របស់ពួកគេ មុននឹងចាប់ផ្តើមទទួលយកការសម្ភាស។ សិទ្ធិទទួលបានព័ត៌មានពេញលេញ និងសិទ្ធិយល់ព្រម ឬបដិសេធការសម្ភាសដើម្បីកំណត់អត្តសញ្ញាណជនរង

គ្រោះព្រមទាំងការថតរូបភាពនិងសំឡេង គឺជាសិទ្ធិមូលដ្ឋានរបស់អ្នកឆ្លើយ។ ចំពោះនគរបាលយុត្តិធម៌ត្រូវអនុវត្តតាមក្រមនីតិវិធីព្រហ្មទណ្ឌ។

ជាទូទៅ អ្នកធ្វើសម្ភាសន៍ត្រូវផ្ដល់ព័ត៌មានដល់អ្នកឆ្លើយដូចតទៅ៖

- ណែនាំខ្លួន ប្រាប់ឈ្មោះ មុខតំណែង តួនាទី និងលទ្ធភាពផ្ដល់ឬបញ្ជូនទៅរកសេវាគាំទ្រផ្សេងៗដល់ជនរងគ្រោះ
- ពន្យល់អំពីគោលបំណងនៃការស្នើសុំការយល់ព្រម និងការសម្ភាស
- ពន្យល់ដោយសង្ខេបអំពីខ្លឹមសារនៃការសម្ភាស
- ពន្យល់អំពីផលប្រយោជន៍នៃកិច្ចសម្ភាស និងដំណើរការនៃកិច្ចសម្ភាសរួមទាំងរយៈពេលសម្ភាសន៍ និងការប៉ះប៉ូវការខាតបង់ពិតប្រាកដ រួមទាំងការខាតបង់ពេលវេលា (ចំណាយធ្វើដំណើរ ឬអាហារ និងការបាត់បង់ពេលវេលាប្រកបរបរទទួលទាន)
- ពន្យល់អំពីសិទ្ធិសាកសួរក្នុងករណីមានចម្ងល់ឬការព្រួយបារម្ភណាមួយ សិទ្ធិមិនឆ្លើយ និងសិទ្ធិមិនឱ្យគេថតរូប-សំឡេង ជាដើម
- ពន្យល់អំពីសិទ្ធិបុគ្គលទាក់ទងនឹងកំណត់ត្រាសម្ភាសន៍ ឯកសារ និងភ័ស្តុតាងផ្នែកវេជ្ជសាស្ត្រ ឬឯកសារផ្ទាល់ខ្លួន។ល។
- ពន្យល់អំពីគោលការណ៍រក្សាការសម្ងាត់ និងផ្ដល់ឱកាសឱ្យអ្នកឆ្លើយសម្រេចចិត្តថាតើព័ត៌មានដែលនឹងផ្ដល់អាចឬមិនអាចប្រើប្រាស់បានក្នុងការបញ្ជូនបន្តទៅនគរបាលយុត្តិធម៌ ឬទីភ្នាក់ងារផ្ដល់សេវាគាំទ្រនានាតាមករណីសមស្រប
- ធានាចំពោះជនរងគ្រោះថាគ្មានចម្លើយណាមួយដែលចាត់ទុកថាត្រូវ ឬខុសឡើយ ហើយសំណួរដែលសួរគឺវាមានលក្ខណៈទូទៅសម្រាប់មនុស្សគ្រប់គ្នា
- ចៀសវាងដាក់សម្ពាធ ឬលក្ខខណ្ឌណាមួយលើអ្នកឆ្លើយ
- សំណួរសំខាន់ចុងក្រោយមុននឹងចាប់ផ្ដើមការសម្ភាសជាផ្លូវការគឺ«*តើខ្ញុំអាចចាប់ផ្ដើមសម្ភាសពេលនេះបានដែរឬទេ?*»។

ការយល់ព្រមទទួលយកការសម្ភាសកំណត់អត្តសញ្ញាណត្រូវបង្ហាញចេញពីឆន្ទៈពិតប្រាកដដោយសេរី ច្បាស់លាស់ និងដឹងជាមុន។ ការយល់ព្រមត្រូវតែផ្ដល់ជាលាយលក្ខណ៍អក្សរ។

### ៦. សួរសំណួរត្រូវមានលក្ខណៈសាមញ្ញ និងប្រកបដោយវិជ្ជាជីវៈ

ជាទូទៅ អ្នកធ្វើសម្ភាសន៍ត្រូវប្រកាន់ខ្ជាប់នូវរបៀបរបប និងឥរិយាបថសួរសំណួរដូចខាងក្រោម៖

- ការសួរ និងប្រើប្រាស់សំឡេងមានលក្ខណៈអព្យាក្រឹត្យនិងមានសុជីវធម៌
- ការប្រើប្រាស់ភាសាសាមញ្ញងាយយល់ និងមានសីលធម៌ ឬពាក្យពេចន៍ដូចគ្នានឹងពាក្យពេចន៍ដែលអ្នកឆ្លើយបានប្រើ
- ការសម្រួលប្រយោគ និងបកស្រាយបំភ្លឺ ក្នុងករណីអ្នកឆ្លើយនៅមិនទាន់យល់ច្បាស់

- ការលើកទឹកចិត្តឱ្យមានសំណួរផ្សេងៗ បើទោះបីជាពេលខ្លះការសួរសំណួរនោះអាចជាការរំខានក៏ដោយ
- ការមិនសួរសំណួរច្រំដែល ឬសំណួរណាដែលអ្នកឆ្លើយបានផ្តល់ចម្លើយរួចហើយ
- ការមិនប្រើសំណួរឌឺដង ឬបញ្ឆិតបញ្ឆៀងការសួរសំណួរផ្តោតតែទៅលើប្រធានបទ និងកុំនិយាយលើសពីការចាំបាច់
- ការធានាមិនឱ្យមានអ្នកធ្វើសម្ភាសន៍ច្រើននាក់សួរសំណួរក្នុងពេលតែមួយ ។ ក្នុងករណីចាំបាច់អ្នកធ្វើសម្ភាសន៍ត្រូវចេះប្រើរបៀបផ្តល់សញ្ញាឱ្យគ្នា
- ការសួរសំណួរតាមលំដាប់លំដោយម្តងមួយៗ ដោយចាប់ផ្តើមពីសំណួរដែលមិនសូវស្មុគស្មាញមុន ហើយវិធីសាស្រ្តនៃការសួរគឺគួរប្រើសំណួរបើកដើម្បីអាចស្វែងយល់បន្ថែមទៀតពីអារម្មណ៍ និងអាកប្បកិរិយា បន្ទាប់មកគួរប្រើសំណួរចំៗដើម្បីទាញយកចម្លើយលម្អិតជាងមុន។ ជាទូទៅ សំណួរដែលចាប់ផ្តើមដំបូងគួរជាសំណួរកសាងទំនុកចិត្តដែលមានដូចជាសំណួរទាក់ទងនឹងសុខុមាលភាព និងតម្រូវការរបស់អ្នកឆ្លើយ(តម្រូវការបន្ទាន់ផ្ទាល់ខ្លួន សុវត្ថិភាព ឬតម្រូវការវេជ្ជសាស្រ្ត ។ល។) បន្ទាប់មកអ្នកធ្វើសម្ភាសន៍គួរសួរសំណួរអព្យាក្រិត្យដែលមានដូចជា ឈ្មោះ អាយុ ទីកន្លែងកំណើត មុខរបរពីមុន ។ល។ សំណួរស្មុគស្មាញ ឬប៉ះពាល់អារម្មណ៍គួរសួរនៅក្រោយគេ ដែលមានដូចជាសំណួរទាក់ទងនឹងសមាជិកគ្រួសារ អាសយដ្ឋានស្នាក់នៅ ការជ្រើសរើស បន្លាស់ទី ការកេងប្រវ័ញ្ច ការរំលោភបំពាន ពេស្យាចារនិងសកម្មភាពខុសច្បាប់នានាពាក់ព័ន្ធនឹងស្ថានភាពរបស់អ្នកឆ្លើយ(ដែលមានដូចជា ការមានឬប្រើប្រាស់ឯកសារក្លែងក្លាយការឆ្លងដែនខុសច្បាប់ ឬការមានឬប្រើប្រាស់សារធាតុញៀន ។ល។)។ការសម្ភាសត្រូវបញ្ចប់ជាមួយនឹងសំណួរដែលមិនសូវរសើប និងមិនធ្វើឱ្យអ្នកឆ្លើយខ្វាយខ្វល់ច្រើន (ដូចជាគោលបំណងឬតម្រូវការនៅពេលខាងមុខបន្ទាប់ពីកិច្ចសម្ភាសនេះ)
- ការសួរមិនត្រូវមានលក្ខណៈជាការសួរចម្លើយ ចោទប្រកាន់ ឬធ្វើឱ្យអ្នកឆ្លើយគិតថាអ្នកធ្វើសម្ភាសន៍មានការសង្ស័យទៅលើចម្លើយរបស់ខ្លួនឡើយ។

## ៧. ស្តាប់ប្រកបដោយលក្ខណៈសកម្ម និងឆ្លើយតប

អ្នកធ្វើសម្ភាសន៍ត្រូវយកចិត្តទុកដាក់ស្តាប់ដោយសកម្ម តាមរយៈការៈ

- បង្ហាញអាការៈឱ្យឃើញថាអ្នកធ្វើសម្ភាសន៍កំពុងស្តាប់
- ផ្ចង់អារម្មណ៍នឹងអ្នកឆ្លើយដោយយកចិត្តទុកដាក់
- ទុកពេលឱ្យអ្នកឆ្លើយរកនឹក និងបញ្ចេញអារម្មណ៍តាមសម្រួល
- សួរសំណួរបញ្ជាក់ឡើងវិញ
- ចេះសង្កេតមើលទឹកមុខ កាយវិការ និងឥរិយាបថរបស់អ្នកឆ្លើយ
- មិននិយាយកាត់នៅពេលអ្នកឆ្លើយកំពុងនិយាយ

- មិននិយាយពិភាក្សាគ្នាជាមួយមិត្តរួមការងារនៅចំពោះមុខអ្នកឆ្លើយក្នុងអំឡុងពេលនៃកិច្ចសម្ភាស។

### ៨. ការធានាឱ្យមានអារម្មណ៍ ឬឥរិយាបថមិនលម្អៀង

ទោះបីជាខ្លួនមានជំនឿ សាសនា វប្បធម៌ ស្ថានភាពសង្គមសេដ្ឋកិច្ច ជាតិពន្ធុ និងបុគ្គលិកលក្ខណៈឬភេទខុសពីអ្នកឆ្លើយក៏ដោយ ក៏អ្នកធ្វើសម្ភាសន៍មិនត្រូវបណ្តោយឱ្យអារម្មណ៍ ឬអាកប្បកិរិយាលម្អៀងដោយសារមូលហេតុខាងលើនេះ កើតឡើងក្នុងអំឡុងពេលសម្ភាសន៍ឡើយ ជាពិសេសគឺមិនត្រូវសំដែងអាកប្បកិរិយាដែលធ្វើឱ្យអ្នកឆ្លើយមានអារម្មណ៍ថាខ្លួនគេអន់ ឬគ្មានតម្លៃ។ ម្យ៉ាងវិញទៀត អ្នកធ្វើសម្ភាសន៍មិនត្រូវប្រើប្រាស់បទពិសោធ និងការសន្មត់ផ្ទាល់ខ្លួនក្នុងការសួរយកព័ត៌មានឡើយ។ អ្នកធ្វើសម្ភាសន៍ក៏ត្រូវរក្សាអារម្មណ៍ និងទឹកមុខរបស់ខ្លួនធម្មតាតាំងពីពេលចាប់ផ្តើមរហូតដល់ពេលបញ្ចប់ការសម្ភាស។

### ៩. ការប្រព្រឹត្តប្រកបដោយមនុស្សធម៌ការយល់ចិត្ត ការគោរព និងសមភាព

